# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ
# បឋមភាគ
# ៦៩



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

## KHUDDAKANIKĀYA

## PAṬISAMBHIDĀMAGGA

## PAṬHAMABHĀGA

## 69

**សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី**
**សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា**

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិញ្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាភិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

# សេចក្តីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរ: **សម្‌ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស្‌ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សន្ទឹកក្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## ខុទ្ទកនិកាយ  បដិសម្ភិទាមគ្គ

## បឋមភាគ

## ៦៩

ព. ស. ២៥០៥

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស បដិសម្ភិទាមគ្គោ

# បឋមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## មាតិកា

សោតាវធានេ បញ្ញា សុតមយេ ញាណំ សុត្វាន សំវរេ បញ្ញា សីលមយេ ញាណំ សំវរិត្វា សមាទហនេ បញ្ញា សមាធិភាវនាមយេ ញាណំ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិ ញាណំ អតីតានាគតប្បច្ចុប្បន្នានំ ធម្មានំ សំខិបិត្វា វវត្ថានេ បញ្ញា សម្មសនេ ញាណំ បច្ចុប្បន្នានំ ធម្មានំ វិបរិណាមានុបស្សនេ បញ្ញា ឧទយព្វយានុបស្សនេ ញាណំ អារម្មណំ បដិសង្ខា ភង្គានុបស្សនេ បញ្ញា វិបស្សនេ ញាណំ ភយតុបដ្ឋានេ បញ្ញា អាទីនវេ ញាណំ មុញ្ចិតុ-កម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ពហិទ្ធាវុដ្ឋានវិវដ្ដនេ បញ្ញា គោត្រភុញ្ញាណំ

# សុត្តន្តបិដក
# ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ
# បឋមភាគ

---

*សូមនមស្ការព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ ។*

## មាតិកា

*បញ្ញា (ការដឹងច្បាស់) ក្នុងការប្រុងត្រចៀក ឈ្មោះថា សុតមយញ្ញាណ បញ្ញាក្នុងការស្តាប់ហើយសង្រួម ឈ្មោះថា សីលមយញ្ញាណ បញ្ញាក្នុងការសង្រួមហើយតម្កល់ទុក ឈ្មោះថា សមាធិភាវនាមយញ្ញាណ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ បញ្ញាក្នុងការបំប្រួញនូវពួកធម៌ជាអតីត អនាគត និងបច្ចុប្បន្ន ហើយកំណត់ទុក ឈ្មោះថា សម្មសនញ្ញាណ បញ្ញាក្នុងការឃើញនូវការប្រែប្រួលនៃពួកធម៌ជាបច្ចុប្បន្ន ឈ្មោះថា ឧទយព្វយានុបស្សនាញាណ បញ្ញាក្នុងការឃើញ នូវអារម្មណ៍ថា បែកធ្លាយ ឈ្មោះថា វិបស្សនាញាណ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ឈ្មោះថា អាទីនវញ្ញាណ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណា ឬការព្រងើយកន្តើយ ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញាក្នុងការចេញនិងការវិលត្រឡប់ ចាកសង្ខារនិមិត្តខាងក្រៅ ឈ្មោះថា គោត្រភុញ្ញាណ*

ឧភតោវុដ្ឋានវិវដ្ដនេ បញ្ញា មគ្គេ ញាណំ បយោ-
គប្បដិប្បស្សទ្ធិបញ្ញា ផលេ ញាណំ ឆិន្នមទុបស្ស-
នេ(១) បញ្ញា វិមុត្តិញាណំ តទា សមុទាគតេ ធម្មេ
បស្សនេ(២) បញ្ញា បច្ចវេក្ខណេ ញាណំ អជ្ឈត្តវ-
វត្ថានេ បញ្ញា វត្ថុនានត្តេ ញាណំ ពហិទ្ធាវវត្ថានេ
បញ្ញា គោចរនានត្តេ ញាណំ ចរិយាវវត្ថានេ បញ្ញា
ចរិយានានត្តេ ញាណំ ចតុធម្មវវត្ថានេ បញ្ញា
ភូមិនានត្តេ ញាណំ នវធម្មវវត្ថានេ បញ្ញា ធម្មនាន-
ត្តេ ញាណំ អភិញ្ញា បញ្ញា ញាតដ្ឋេ ញាណំ
បរិញ្ញា បញ្ញា តីរណដ្ឋេ ញាណំ បហានេ បញ្ញា
បរិច្ចាគដ្ឋេ ញាណំ ភាវនា បញ្ញា ឯករសដ្ឋេ ញាណំ
សច្ឆិកិរិយា បញ្ញា ផស្សនដ្ឋេ(៣) ញាណំ វិបស្សនេ
ញាណំ អត្ថនានត្តេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ
ធម្មនានត្តេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ និរុត្តិ-
នានត្តេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ បដិភា-
ណនានត្តេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ
វិហារនានត្តេ បញ្ញា វិហារដ្ឋេ ញាណំ

---

១ ម. ឆិន្នវដុមនុបស្សនេ ។ ២ ឱ. ម. សមុទាគតេ ធម្មេ វិបស្សនេ ។ ៣ ឱ. ម. ផុស្សនដ្ឋេ ។

បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសភាវៈទាំងពីរ ឈ្មោះថា មគ្គញ្ញាណ បញ្ញាដែលសម្រាប់រម្ងាប់នូវព្យាយាម ឈ្មោះថាផលញ្ញាណ បញ្ញាក្នុងការឃើញនូវកិលេសដែលដាច់ ឈ្មោះថា វិមុត្តិញ្ញាណ បញ្ញាក្នុងការឃើញ នូវធម៌ដែលតាំងឡើងក្នុងខណៈមគ្គផលនោះ ឈ្មោះថា បច្ចវេក្ខណញ្ញាណ បញ្ញាក្នុងការកំណត់នូវអាយតនៈខាងក្នុង ឈ្មោះថាវត្ថុនានត្តញ្ញាណ បញ្ញាក្នុងការកំណត់នូវអារម្មណ៍ខាងក្រៅ ឈ្មោះថាគោចរនានត្តញ្ញាណ បញ្ញាក្នុងការកំណត់នូវការត្រាច់ទៅ(នៃវិញ្ញាណ) ឈ្មោះថា ចរិយានានត្តញ្ញាណ បញ្ញាក្នុងការកំណត់នូវធម៌ ៤ ឈ្មោះថាភូមិនានត្តញ្ញាណ បញ្ញាក្នុងការកំណត់នូវធម៌ ៩ ឈ្មោះថា ធម្មនានត្តញ្ញាណ បញ្ញាដែលជាគ្រឿងដឹងដ៏ប្រសើរ ឈ្មោះថាញាតដ្ឋញ្ញាណ បញ្ញាដែលជាគ្រឿងដឹងជ្រួតជ្រាប ឈ្មោះថាតីរណដ្ឋញ្ញាណ បញ្ញាដែលជាគ្រឿងលះ ឈ្មោះថា បរិច្ចាគដ្ឋញ្ញាណ បញ្ញាជាគ្រឿងអប់រំ ឈ្មោះថា ឯករសដ្ឋញ្ញាណ បញ្ញាជាគ្រឿងធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា ផស្សនដ្ឋញ្ញាណ បញ្ញាក្នុងអត្ថផ្សេង ៗ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ បញ្ញាក្នុងធម៌ផ្សេង ៗ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ បញ្ញាក្នុងនិរុត្តិផ្សេង ៗ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ បញ្ញាក្នុងបដិភាណផ្សេង ៗ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ បញ្ញាក្នុងវិបស្សនាវិហារផ្សេង ៗ ឈ្មោះថាវិហារដ្ឋញ្ញាណ

៣

## មាតិកា

សមាបត្តិនានត្តេ បញ្ញា សមាបត្តដ្ឋេ ញាណំ វិហារ-
សមាបត្តិនានត្តេ បញ្ញា វិហារសមាបត្តដ្ឋេ ញាណំ
អវិក្ខេបបរិសុទ្ធត្តា អាសវសមុច្ឆេទេ បញ្ញា អានន្តរិ-
កសមាធិម្ហិ ញាណំ ទស្សនាធិបតេយ្យំ សន្តោ ច
វិហារាធិគមោ បណីតាធិមុត្តតា បញ្ញា អរណវិហារេ
ញាណំ ទ្វីហិ ពលេហិ សមន្នាគតត្តា តយោ ច
សង្ខារានំ បដិប្បស្សទ្ធិយា សោឡសហិ ញាណចរិ-
យាហិ នវហិ សមាធិចរិយាហិ វសីភាវតា បញ្ញា និរោ-
ធសមាបត្តិយា ញាណំ សម្បជានស្ស បវត្តបរិយាទា-
នេ បញ្ញា បរិនិព្វានេ ញាណំ សព្វធម្មានំ សម្មាស-
មុច្ឆេទេ និរោធេ ច អនុបដ្ឋានតា បញ្ញា សមសីសដ្ឋេ
ញាណំ បុថុនានត្តេកត្តតេជបរិយាទានេ[១] បញ្ញា
សល្លេខដ្ឋេ ញាណំ អសល្លីនត្តបហិតត្តបគ្គហដ្ឋេ
បញ្ញា វីរិយារម្ភេ ញាណំ នានាធម្មប្បកាសនតា
បញ្ញា អត្ថសន្ទស្សនេ ញាណំ សព្វធម្មានំ ឯកសង្គ-
ហតានត្តេកត្តបដិវេធេ បញ្ញា ទស្សនវិសុទ្ធិញាណំ

---
១ ឱ. ម. បុថុនានតេកត្តតេជបរិយាទានេ ។

មាតិកា

បញ្ញាក្នុងផលសមាបត្តិផ្សេងៗ ឈ្មោះថាសមាបត្តដ្ឋញ្ញាណ បញ្ញាក្នុងវិហារសមាបត្តិផ្សេងៗ ឈ្មោះថាវិហារសមាបត្តដ្ឋញ្ញាណ បញ្ញាក្នុងការផ្តាច់បង់នូវអាសវៈ ព្រោះសេចក្តីបរិសុទ្ធ ដោយសេចក្តីមិនរាយមាយ ឈ្មោះថាអានន្តរិកសមាធិញ្ញាណ បញ្ញាគឺទស្សនាធិបតេយ្យផង ការបាននូវវិហារដ៏ស្ងប់ផង សេចក្តីចុះចិត្តស៊ប់ក្នុងធម៌ដ៏ឧត្តមផង ឈ្មោះថាអរណ-វិហារញ្ញាណ បញ្ញាដែលមានភាពស្ទាត់ជំនាញ ព្រោះហេតុប្រកបដោយកម្លាំងសមថៈ និងវិបស្សនាទាំង ២ ផង ព្រោះការរម្ងាប់នូវសង្ខារទាំង ៣ ផង ព្រោះញាណចរិយា ១៦ ផង ព្រោះសមាធិចរិយា ៩ ផង ឈ្មោះថានិរោធសមាបត្តិញ្ញាណ បញ្ញាក្នុងការបង្អស់នូវការប្រព្រឹត្តទៅ (នៃកិលេសនិងខន្ធ) របស់បុគ្គលអ្នកដឹងខ្លួន ឈ្មោះថា បរិនិព្វានញ្ញាណ បញ្ញាដែលមិនប្រាកដក្នុងការផ្តាច់ផ្តិលដោយប្រពៃ នូវធម៌ទាំងពួងផង ក្នុងការរំលត់ផង ឈ្មោះថា សមសីសដ្ឋញ្ញាណ បញ្ញាក្នុងការរំលត់នូវភ្លើងដ៏ក្រាស់មានភាពផ្សេង ៗ និងមានភាពតែមួយ ឈ្មោះថា សល្លេខដ្ឋញ្ញាណ បញ្ញាក្នុងការផ្គង របស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ឈ្មោះថា វិរិយារម្ភញ្ញាណ បញ្ញាគឺការប្រកាសនូវធម៌ផ្សេង ៗ ឈ្មោះថា អត្ថសន្ទស្សនញ្ញាណ បញ្ញាក្នុងការត្រាស់ដឹង នូវការសង្គ្រោះធម៌ទាំងពួងឲ្យមានតែមួយ និងកិលេសមានភាពផ្សេង ៗ ទាំងគុណធម៌មានសភាពតែមួយ ឈ្មោះថា ទស្សនវិសុទ្ធិញ្ញាណ

វិជិតត្តា បញ្ញា ខន្តិញ្ញាណំ ផុដ្ឋត្តា បញ្ញា បរិយោគា-
ហនេ ញាណំ សមោទហនេ បញ្ញា បទេសវិហារេ
ញាណំ អធិបតត្តា បញ្ញា សញ្ញាវិវដ្តេ ញាណំ នាន-
ត្តេ បញ្ញា ចេតោវិវដ្តេ ញាណំ អធិដ្ឋានេ បញ្ញា
ចិត្តវិវដ្តេ ញាណំ សុញ្ញតេ បញ្ញា ញាណវិវដ្តេ ញាណំ
វោស្សគ្គេ បញ្ញា វិមោក្ខវិវដ្តេ[១] ញាណំ តថដ្ឋេ
បញ្ញា សច្ចវិវដ្តេ ញាណំ កាយម្បិ ចិត្តម្បិ ឯកវ-
វត្ថានតា សុខសញ្ញញ្ច លហុសញ្ញញ្ច អធិដ្ឋានវសេន
ឥជ្ឈនដ្ឋេ បញ្ញា ឥទ្ធិវិធេ ញាណំ វិតក្កវិប្ផារវសេន
នានត្តេកត្តសទ្ទនិមិត្តានំ បរិយោគាហនេ បញ្ញា
សោតធាតុវិសុទ្ធិញ្ញាណំ តិណ្ណំ ចិត្តានំ វិប្ផារត្តា ឥន្ទ្រិ-
យានំ បសាទវសេន នានត្តេកត្តវិញ្ញាណចរិយាបរិ-
យោគាហនេ បញ្ញា ចេតោបរិយញ្ញាណំ បច្ចយប្ប-
វត្តានំ ធម្មានំ នានត្តេកត្តកម្មវិប្ផារវសេន បរិ-
យោគាហនេ បញ្ញា បុព្វេនិវាសានុស្សតិញ្ញាណំ

---

១ ម. បញ្ញាធិមោក្ខវិវដ្តេ ។

បញ្ញាព្រោះការដឹង ឈ្មោះថា ខន្តិញ្ញាណ បញ្ញាព្រោះការពាល់ត្រូវ ឈ្មោះថា បរិយោគាហនញ្ញាណ បញ្ញាក្នុងការប្រមូល ឈ្មោះថា បទេសវិហារញ្ញាណ បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្តញ្ញាណ បញ្ញាក្នុងភាពផ្សេង ៗ ឈ្មោះថា ចេតោវិវដ្តញ្ញាណ បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថា ចិត្តវិវដ្តញ្ញាណ បញ្ញាក្នុងសភាវៈសូន្យ ឈ្មោះថា ញាណវិវដ្តញ្ញាណ បញ្ញាក្នុងការលះបង់ ឈ្មោះថា វិមោក្ខវិវដ្តញ្ញាណ បញ្ញាក្នុងសេចក្តីពិត ឈ្មោះថា សច្ចវិវដ្តញ្ញាណ បញ្ញាក្នុងអត្ថថាសម្រេចដោយអំណាចនៃការអធិដ្ឋាន នូវសុខសញ្ញា និងលហុសញ្ញា ព្រោះកំណត់នូវកាយនិងចិត្តថាតែមួយ ឈ្មោះថា ឥទ្ធិវិធញ្ញាណ បញ្ញាក្នុងការស្ទង់នូវសទ្ទនិមិត្ត មានភាពផ្សេង ៗ ទាំងមានភាពតែមួយ ដោយអំណាចនៃកិរិយាផ្សាយទៅនៃវិតក្កៈ ឈ្មោះថា សោតធាតុវិសុទ្ធិញ្ញាណ បញ្ញាក្នុងការស្ទង់នូវការត្រាច់ទៅ នៃវិញ្ញាណដែលមានសភាពផ្សេង ៗ ទាំងមានសភាពតែមួយ ដោយអំណាចនៃបសាទរបស់ឥន្ទ្រិយទាំងឡាយព្រោះផ្សាយទៅនៃចិត្តទាំង ៣ ឈ្មោះថា ចេតោបរិយញ្ញាណ បញ្ញាក្នុងការស្ទង់នូវពួកធម៌ ដែលប្រព្រឹត្តទៅបាន ព្រោះបច្ច័យដោយអំណាចនៃកិរិយាផ្សាយទៅនៃកម្ម ដែលមានសភាពផ្សេងៗគ្នា ទាំងមានសភាពតែមួយ ឈ្មោះថា បុព្វេនិវាសានុស្សតិញ្ញាណ

ឱភាសវសេន នានត្តេកត្តរូបនិមិត្តានំ ទស្សនដ្ឋេ បញ្ញា ទិព្វចក្ខុញ្ញាណំ ចតុសដ្ឋិយា អាការេហិ តិណ្ណំ ឥន្ទ្រិយានំ វសីភាវតា បញ្ញា អាសវានំ ខយេ ញាណំ បរិញ្ញដ្ឋេ បញ្ញា ទុក្ខេ ញាណំ បហានដ្ឋេ បញ្ញា សមុទយេ ញាណំ សច្ឆិកិរិយដ្ឋេ បញ្ញា និរោធេ ញាណំ ភាវនដ្ឋេ បញ្ញា មគ្គេ ញាណំ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ អត្ថបដិសម្ភិទេ ញាណំ ធម្មបដិសម្ភិទេ ញាណំ និរុត្តិបដិសម្ភិទេ ញាណំ បដិភាណបដិសម្ភិទេ ញាណំ ឥន្ទ្រិយបរោបរិយត្តេ ញាណំ សត្តានំ អាសយានុសយេ ញាណំ យមកបាដិហីរេ ញាណំ មហាករុណាសមាបត្តិយា ញាណំ សព្វញ្ញុតញ្ញាណំ អនាវរណញ្ញាណំ ឥមានិ តេសត្តតិ ញាណានិ ឥមេសំ តេសត្តតិយា[១] ញាណានំ សត្តសដ្ឋី ញាណានិ សាវកសាធារណានិ ឆ ញាណានិ អសាធារណានិ សាវកេហីតិ ។

មាតិកា និដ្ឋិតា ។

---

១ ឱ. តេ សត្តតីនំ ។

មាតិកា

បញ្ញាក្នុងអត្ថថាឃើញនូវរូបនិមិត្ត មានសភាវៈផ្សេងៗ ទាំងមានសភាពតែមួយដោយអំណាចនៃពន្លឺ ឈ្មោះថា ទិព្វចក្ខុញ្ញាណ បញ្ញាដែលស្ទាត់ជំនាញនៃឥន្ទ្រិយ ៣ ដោយអាការ ៦៤ ឈ្មោះថា អាសវក្ខយញ្ញាណ បញ្ញាក្នុងអត្ថថាកំណត់ដឹង ឈ្មោះថា ទុក្ខញ្ញាណ បញ្ញាក្នុងអត្ថថាលះ ឈ្មោះថា សមុទយញ្ញាណ បញ្ញា ក្នុងអត្ថថាធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា និរោធញ្ញាណ បញ្ញាក្នុងអត្ថថា ចម្រើន ឈ្មោះថា មគ្គញ្ញាណ ទុក្ខញ្ញាណ ទុក្ខសមុទយញ្ញាណ ទុក្ខនិរោធញ្ញាណ ទុក្ខនិរោធគាមិនីបដិបទាញាណ អត្ថប្បដិសម្ភិទាញាណ ធម្មប្បដិសម្ភិទាញាណ និរុត្តិប្បដិសម្ភិទាញាណ បដិភាណប្បដិសម្ភិទាញាណ ឥន្ទ្រិយបរោបរិយត្តញ្ញាណ សត្តាសយានុសយញ្ញាណ យមកប្បាដិហិរញ្ញាណ មហាករុណាសមាបត្តិញ្ញាណ សព្វញ្ញុតញ្ញាណ អនាវរណញ្ញាណ នេះញាណ ៧៣ បណ្ដាញាណ ៧៣ នេះ ញាណ ៦៧ ជាសាធារណៈដល់ពួកសាវ័ក ញាណ ៦ មិនសាធារណៈដល់ពួកសាវ័កទេ ។

ចប់មាតិកា ។

---

# មហាវគ្គេ ញាណកថា

[១] កថំ សោតាវធានេ បញ្ញា សុតមយេ ញាណំ ឥមេ ធម្មា អភិញ្ញេយ្យាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ ឥមេ ធម្មា បរិញ្ញេយ្យាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ ឥមេ ធម្មា បហាតព្វាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ ឥមេ ធម្មា ភាវេតព្វាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ ឥមេ ធម្មា សច្ឆិកាតព្វាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ ឥមេ ធម្មា ហានភាគិយាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ ឥមេ ធម្មា ឋិតិភាគិយាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ ឥមេ ធម្មា វិសេសភាគិយាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ

# មហាវគ្គ ញាណកថា

[១] បញ្ញាក្នុងការប្រុងត្រចៀក ឈ្មោះថា សុតមយញ្ញាណ តើដូចម្តេច ការប្រុងត្រចៀកថា ធម៌ទាំងនេះ បុគ្គលគួរដឹងច្បាស់ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ បុគ្គលគួរកំណត់ដឹង បញ្ញាជាគ្រឿងដឹង នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ បុគ្គលគួរលះ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ បុគ្គលគួរចម្រើន បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ បុគ្គលគួរធ្វើឲ្យជាក់ច្បាស់ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះគប់រកនូវសេចក្តីសាបសូន្យ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ គប់រកនូវការតាំងនៅ បញ្ញាជាគ្រឿងដឹង នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងនេះ គប់រកនូវគុណវិសេស (ដោយអំណាចនៃការត្រាស់ដឹងនូវគុណវិសេសខាងលើ) បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ

ឥមេ ធម្មា និព្វេធភាគិយាតិ សោតាវធានំ តំ-
បជាននា បញ្ញា សុតមយេ ញាណំ សព្វេ សង្ខា-
រា អនិច្ចាតិ សោតាវធានំ តំបជាននា បញ្ញា
សុតមយេ ញាណំ សព្វេ សង្ខារា ទុក្ខាតិ សោ-
តាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ
សព្វេ ធម្មា អនត្តាតិ សោតាវធានំ តំបជាននា
បញ្ញា សុតមយេ ញាណំ ឥទំ ទុក្ខំ អរិយសច្ចន្តិ
សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ
ឥទំ ទុក្ខសមុទយោ[១] អរិយសច្ចន្តិ សោតាវធានំ
តំបជាននា បញ្ញា សុតមយេ ញាណំ ឥទំ ទុក្ខនិ-
រោធោ[២] អរិយសច្ចន្តិ សោតាវធានំ តំបជាននា
បញ្ញា សុតមយេ ញាណំ ឥទំ ទុក្ខនិរោធគាមិនី
បដិបទា អរិយសច្ចន្តិ សោតាវធានំ តំបជាននា
បញ្ញា សុតមយេ ញាណំ ។

[២] កថំ ឥមេ ធម្មា អភិញ្ញេយ្យាតិ សោតា-
វធានំ តំបជាននា បញ្ញា សុតមយេ ញាណំ

---

១ ឱ. ម. ទុក្ខសមុទយំ ។ ២ ឱ. ម. ទុក្ខនិរោធំ ។

ការប្រុងត្រចៀកថា ធម៌ទាំងនេះគប់នូវការទម្លាយនូវកិលេស បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា សង្ខារទាំងពួងមិនទៀង បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា សង្ខារទាំងពួងជាទុក្ខ បញ្ញាជាគ្រឿងដឹង នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា ធម៌ទាំងពួងជាអនត្តា បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា នេះ ទុក្ខអរិយសច្ច បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា នេះ ទុក្ខសមុទយអរិយសច្ច បញ្ញាជាគ្រឿងដឹង នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា នេះ ទុក្ខនិរោធអរិយសច្ច បញ្ញាជាគ្រឿងដឹង នូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ការប្រុងត្រចៀកថា នេះ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថា សុតមយញ្ញាណ ។

[២] ការប្រុងត្រចៀកថា ធម៌ទាំងនេះបុគ្គលគួរដឹងច្បាស់ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតមយញ្ញាណ តើដូចម្តេច

ឯកោ ធម្មោ អភិញ្ញេយ្យោ សព្វេ សត្តា អាហារ-
ដ្ឋិតិកា ទ្វេ ធម្មា អភិញ្ញេយ្យា ទ្វេ ធាតុយោ តយោ
ធម្មា អភិញ្ញេយ្យា តិស្សោ ធាតុយោ ចត្តារោ ធម្មា
អភិញ្ញេយ្យា ចត្តារិ អរិយសច្ចានិ បញ្ច ធម្មា អភិ-
ញ្ញេយ្យា បញ្ច វិមុត្តាយតនានិ ឆ ធម្មា អភិញ្ញេយ្យា
ឆ អនុត្តរិយានិ សត្ត ធម្មា អភិញ្ញេយ្យា សត្ត និទ្ទ-
សវត្ថូនិ អដ្ឋ ធម្មា អភិញ្ញេយ្យា អដ្ឋ អភិភាយត-
នានិ នវ ធម្មា អភិញ្ញេយ្យា នវ អនុបុព្វវិហារា

ធម៌ ១ ដែលបុគ្គលត្រូវដឹងច្បាស់ បានដល់ពួកសត្វទាំងអស់ ដែលឋិតនៅបានដោយអាហារ ធម៌ ២ ត្រូវដឹងច្បាស់ បានដល់ធាតុ ២ គឺ សង្ខតធាតុ អសង្ខតធាតុ ធម៌ ៣ ត្រូវដឹងច្បាស់ បានដល់ធាតុ ៣ គឺ កាមធាតុ រូបធាតុ អរូបធាតុ ធម៌ ៤ ត្រូវដឹងច្បាស់ បានដល់អរិយសច្ច ៤ ធម៌ ៥ ត្រូវដឹងច្បាស់ បានដល់វិមុត្តាយតនៈ ៥ ធម៌ ៦ ត្រូវដឹងច្បាស់ បានដល់អនុត្តរិយៈ ៦ ធម៌ ៧ ត្រូវដឹងច្បាស់ បានដល់និទ្ទសវត្ថុ(១) ៧ ធម៌ ៨ ត្រូវដឹងច្បាស់ បានដល់អភិភាយតនៈ ៨ ធម៌ ៩ ត្រូវដឹងច្បាស់ បានដល់អនុបុព្វវិហារធម៌(២) ៩

---

១ ហេតុនៃសភាវៈមិនដល់ ១០ នោះមាន ៧ យ៉ាង គឺភិក្ខុមានសេចក្តីប៉ុនប៉ងដ៏ក្លៀវក្លាក្នុងការសមាទាននូវសិក្ខាបទ ហើយមិនប្រាសចាកសេចក្តីស្រឡាញ់ ក្នុងការសមាទាននូវសិក្ខាបទតទៅទៀត ១ មានសេចក្តីប៉ុនប៉ងដ៏ក្លៀវក្លា ក្នុងធម៌ជាគ្រឿងស្ងប់រម្ងាប់ ហើយមិនប្រាសចាកសេចក្តីស្រឡាញ់ក្នុងធម៌ជាគ្រឿងស្ងប់រម្ងាប់តទៅទៀត ១ មានសេចក្តីប៉ុនប៉ុងដ៏ក្លៀវក្លា ក្នុងការបន្ទោបង់នូវតស្សា ហើយមិនប្រាសចាកសេចក្តីស្រឡាញ់ ក្នុងការបន្ទោបង់នូវតស្សាតទៅទៀត ១ មានសេចក្តីប៉ុនប៉ងដ៏ក្លៀវក្លា ក្នុងការសម្ងំនៅក្នុងកម្មដ្ឋាន ហើយមិនប្រាសចាកសេចក្តីស្រឡាញ់ ក្នុងការសម្ងំនៅក្នុងកម្មដ្ឋានតទៅទៀត ១ មានសេចក្តីប៉ុនប៉ងដ៏ក្លៀវក្លា ក្នុងការប្រារព្ធព្យាយាម ហើយមិនប្រាសចាកសេចក្តីស្រឡាញ់ ក្នុងការប្រារព្ធនូវព្យាយាមតទៅទៀត ១ មានសេចក្តីប៉ុនប៉ងដ៏ក្លៀវក្លា ក្នុងស្មារតីដ៏ចាស់ក្លា ហើយមិនប្រាសចាកសេចក្តីស្រឡាញ់ក្នុងស្មារតីដ៏ចាស់ក្លាតទៅទៀត១ មានសេចក្តីប៉ុនប៉ងដ៏ក្លៀវក្លា ក្នុងការត្រាស់ដឹងដោយទិដ្ឋិ ហើយមិនប្រាសចាកសេចក្តីស្រឡាញ់ក្នុងការត្រាស់ដឹងដោយទិដ្ឋិតទៅទៀត ១ ។ អដ្ឋកថា ។ ២ គឺ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន អាកាសានញ្ចាយតនជ្ឈាន វិញ្ញាណញ្ចាយតនជ្ឈាន អាកិញ្ចញ្ញាយតនជ្ឈាន នេវសញ្ញានាសញ្ញាយតនជ្ឈាន សញ្ញាវេទយិតនិរោធជ្ឈាន ។

ឥទំ ធម្មា អភិញ្ញេយ្យា ឥទំ និជ្ជរវត្ថូនិ ។

[៣] សព្វំ ភិក្ខវេ អភិញ្ញេយ្យំ កិញ្ច ភិក្ខវេ សព្វំ អភិញ្ញេយ្យំ ចក្ខុំ ភិក្ខវេ អភិញ្ញេយ្យំ រូបា អភិញ្ញេយ្យា ចក្ខុវិញ្ញាណំ អភិញ្ញេយ្យំ ចក្ខុសម្ផស្សោ អភិញ្ញេយ្យោ យម្បិទំ[១] ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អភិញ្ញេយ្យំ សោតំ អភិញ្ញេយ្យំ សទ្ទា អភិញ្ញេយ្យា ។ បេ ។ ឃានំ អភិញ្ញេយ្យំ គន្ធា អភិញ្ញេយ្យា ជិវ្ហា អភិញ្ញេយ្យា រសា អភិញ្ញេយ្យា កាយោ អភិញ្ញេយ្យោ ផោដ្ឋព្វា អភិញ្ញេយ្យា មនោ អភិញ្ញេយ្យោ ធម្មា អភិញ្ញេយ្យា មនោវិញ្ញាណំ អភិញ្ញេយ្យំ មនោសម្ផស្សោ អភិញ្ញេយ្យោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អភិញ្ញេយ្យំ ។

[៤] រូបំ អភិញ្ញេយ្យំ វេទនា អភិញ្ញេយ្យា សញ្ញា អភិញ្ញេយ្យា សង្ខារា អភិញ្ញេយ្យា វិញ្ញាណំ អភិញ្ញេយ្យំ ចក្ខុំ អភិញ្ញេយ្យំ

១ ឱ. យទិទំ ។ ម. យទំ ។

ធម៌ ១០ ត្រូវដឹងច្បាស់ បានដល់និជ្ជរវត្ថុ[១] ១០ យ៉ាង ។

[៣] ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងអស់ បុគ្គលត្រូវដឹងច្បាស់ ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងអស់ បុគ្គលត្រូវដឹងច្បាស់ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ ចក្ខុ បុគ្គលត្រូវដឹងច្បាស់ រូបត្រូវដឹងច្បាស់ ចក្ខុវិញ្ញាណត្រូវដឹងច្បាស់ ចក្ខុសម្ផស្សត្រូវដឹងច្បាស់ ការទទួលអារម្មណ៍ណាជាសុខក្ដី ជាទុក្ខក្ដី មិនជាទុក្ខមិនជាសុខក្ដី កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះ ត្រូវដឹងច្បាស់ សោតៈត្រូវដឹងច្បាស់ សទ្ទៈ ត្រូវដឹងច្បាស់ ។ បេ ។ ឃានៈ ត្រូវដឹងច្បាស់ គន្ធៈ ត្រូវដឹងច្បាស់ ជិវ្ហា ត្រូវដឹងច្បាស់ រសៈ ត្រូវដឹងច្បាស់ កាយ ត្រូវដឹងច្បាស់ ផោដ្ឋព្វៈត្រូវដឹងច្បាស់ មនៈត្រូវដឹងច្បាស់ ធម៌ត្រូវដឹងច្បាស់ មនោ-វិញ្ញាណត្រូវដឹងច្បាស់ មនោសម្ផស្សត្រូវដឹងច្បាស់ ការទទួលអារម្មណ៍ណា ជាសុខក្ដី ជាទុក្ខក្ដី មិនជាទុក្ខមិនជាសុខក្ដី កើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះ ត្រូវដឹងច្បាស់ ។

[៤] រូបត្រូវដឹងច្បាស់ វេទនាត្រូវដឹងច្បាស់ សញ្ញាត្រូវដឹងច្បាស់ សង្ខារទាំងឡាយត្រូវដឹងច្បាស់ វិញ្ញាណត្រូវដឹងច្បាស់ ចក្ខុត្រូវដឹងច្បាស់

---

១ ហេតុដែលធ្វើឲ្យវិនាស គឺ សម្មាទិដ្ឋិ ធ្វើមិច្ឆាទិដ្ឋិឲ្យវិនាស ។ ល ។ សម្មាវិមុត្តិ ធ្វើមិច្ឆា-វិមុត្តិឲ្យវិនាស ត្រូវជា ១០ ។ អដ្ឋកថា ។

សោតំ អភិញ្ញេយ្យំ ឃានំ អភិញ្ញេយ្យំ ជិវ្ហា អភិញ្ញេយ្យា កាយោ អភិញ្ញេយ្យោ មនោ អភិញ្ញេយ្យោ រូបា អភិញ្ញេយ្យា សទ្ទា អភិញ្ញេយ្យា គន្ធា អភិញ្ញេយ្យា រសា អភិញ្ញេយ្យា ផោដ្ឋព្វា អភិញ្ញេយ្យា ធម្មា អភិញ្ញេយ្យា ចក្ខុវិញ្ញាណំ អភិញ្ញេយ្យំ សោតវិញ្ញាណំ អភិញ្ញេយ្យំ ឃានវិញ្ញាណំ អភិញ្ញេយ្យំ ជិវ្ហាវិញ្ញាណំ អភិញ្ញេយ្យំ កាយវិញ្ញាណំ អភិញ្ញេយ្យំ មនោវិញ្ញាណំ អភិញ្ញេយ្យំ ចក្ខុសម្ផស្សោ អភិញ្ញេយ្យោ សោតសម្ផស្សោ អភិញ្ញេយ្យោ ឃានសម្ផស្សោ អភិញ្ញេយ្យោ ជិវ្ហាសម្ផស្សោ អភិញ្ញេយ្យោ កាយសម្ផស្សោ អភិញ្ញេយ្យោ មនោសម្ផស្សោ អភិញ្ញេយ្យោ ចក្ខុសម្ផស្សជា វេទនា អភិញ្ញេយ្យា សោតសម្ផស្សជា វេទនា អភិញ្ញេយ្យា ឃានសម្ផស្សជា វេទនា អភិញ្ញេយ្យា ជិវ្ហាសម្ផស្សជា វេទនា អភិញ្ញេយ្យា កាយសម្ផស្សជា វេទនា អភិញ្ញេយ្យា មនោសម្ផស្សជា វេទនា អភិញ្ញេយ្យា រូបសញ្ញា អភិញ្ញេយ្យា សទ្ទសញ្ញា អភិញ្ញេយ្យា គន្ធសញ្ញា អភិញ្ញេយ្យា

សោតៈត្រូវដឹងច្បាស់ ឃានៈត្រូវដឹងច្បាស់ ជិវ្ហាត្រូវដឹងច្បាស់ កាយត្រូវដឹងច្បាស់ មនៈត្រូវដឹងច្បាស់ រូបត្រូវដឹងច្បាស់ សទ្ទៈត្រូវដឹងច្បាស់ គន្ធៈត្រូវដឹងច្បាស់ រសៈត្រូវដឹងច្បាស់ ផោដ្ឋព្វៈត្រូវដឹងច្បាស់ ធម៌ត្រូវដឹងច្បាស់ ចក្ខុវិញ្ញាណត្រូវដឹងច្បាស់ សោតវិញ្ញាណត្រូវដឹងច្បាស់ ឃានវិញ្ញាណត្រូវដឹងច្បាស់ ជិវ្ហាវិញ្ញាណត្រូវដឹងច្បាស់ កាយវិញ្ញាណត្រូវដឹងច្បាស់ មនោវិញ្ញាណត្រូវដឹងច្បាស់ ចក្ខុសម្ផស្សត្រូវដឹងច្បាស់ សោតសម្ផស្សត្រូវដឹងច្បាស់ ឃានសម្ផស្សត្រូវដឹងច្បាស់ ជិវ្ហាសម្ផស្សត្រូវដឹងច្បាស់ កាយសម្ផស្សត្រូវដឹងច្បាស់ មនោសម្ផស្សត្រូវដឹងច្បាស់ វេទនាដែលកើតអំពីចក្ខុសម្ផស្សត្រូវដឹងច្បាស់ វេទនាដែលកើតអំពីសោតសម្ផ័ស្សត្រូវដឹងច្បាស់ វេទនាដែលកើតអំពីឃានសម្ផស្ស ត្រូវដឹងច្បាស់ វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស ត្រូវដឹងច្បាស់ វេទនាដែលកើតអំពីកាយសម្ផស្សត្រូវដឹងច្បាស់ វេទនាដែលកើតអំពីមនោសម្ផស្សត្រូវដឹងច្បាស់ រូបសញ្ញាត្រូវដឹងច្បាស់ សទ្ទសញ្ញាត្រូវដឹងច្បាស់ គន្ធសញ្ញាត្រូវដឹងច្បាស់

រសសញ្ញា អភិញ្ញេយ្យា ផោដ្ឋព្វសញ្ញា អភិញ្ញេយ្យា ធម្មសញ្ញា អភិញ្ញេយ្យា រូបសញ្ចេតនា អភិញ្ញេយ្យា សទ្ទសញ្ចេតនា អភិញ្ញេយ្យា គន្ធសញ្ចេតនា អភិ-ញ្ញេយ្យា រសសញ្ចេតនា អភិញ្ញេយ្យា ផោដ្ឋព្វសញ្ចេ-តនា អភិញ្ញេយ្យា ធម្មសញ្ចេតនា អភិញ្ញេយ្យា រូប-តណ្ហា អភិញ្ញេយ្យា សទ្ទតណ្ហា អភិញ្ញេយ្យា គន្ធ-តណ្ហា អភិញ្ញេយ្យា រសតណ្ហា អភិញ្ញេយ្យា ផោដ្ឋ-ព្វតណ្ហា អភិញ្ញេយ្យា ធម្មតណ្ហា អភិញ្ញេយ្យា រូប-វិតក្កោ អភិញ្ញេយ្យោ សទ្ទវិតក្កោ អភិញ្ញេយ្យោ គន្ធវិតក្កោ អភិញ្ញេយ្យោ រសវិតក្កោ អភិញ្ញេយ្យោ ផោដ្ឋព្វវិតក្កោ អភិញ្ញេយ្យោ ធម្មវិតក្កោ អភិញ្ញេ-យ្យោ រូបវិចារោ អភិញ្ញេយ្យោ សទ្ទវិចារោ អភិញ្ញេ-យ្យោ គន្ធវិចារោ អភិញ្ញេយ្យោ រសវិចារោ អភិញ្ញេ-យ្យោ ផោដ្ឋព្វវិចារោ អភិញ្ញេយ្យោ ធម្មវិចារោ អភិញ្ញេយ្យោ ។

[៤] បឋវីធាតុ អភិញ្ញេយ្យា អាបោធាតុ អភិញ្ញេយ្យា តេជោធាតុ អភិញ្ញេយ្យា វាយោធាតុ អភិញ្ញេយ្យា

រសសញ្ញា ត្រូវដឹងច្បាស់ ផោដ្ឋព្វសញ្ញា ត្រូវដឹងច្បាស់ ធម្មសញ្ញា ត្រូវដឹងច្បាស់ រូបសញ្ចេតនា ត្រូវដឹងច្បាស់ សទ្ទសញ្ចេតនា ត្រូវដឹងច្បាស់ គន្ធសញ្ចេតនា ត្រូវដឹងច្បាស់ រសសញ្ចេតនា ត្រូវដឹងច្បាស់ ផោដ្ឋព្វ-សញ្ចេតនាត្រូវដឹងច្បាស់ ធម្មសញ្ចេតនា ត្រូវដឹងច្បាស់ រូបតណ្ហា ត្រូវដឹងច្បាស់ សទ្ទតណ្ហាត្រូវដឹងច្បាស់ គន្ធតណ្ហាត្រូវដឹងច្បាស់ រសតណ្ហា ត្រូវដឹងច្បាស់ ផោដ្ឋព្វតណ្ហាត្រូវដឹងច្បាស់ ធម្មតណ្ហាត្រូវដឹងច្បាស់ រូប-វិតក្កៈត្រូវដឹងច្បាស់ សទ្ទវិតក្កៈត្រូវដឹងច្បាស់ គន្ធវិតក្កៈត្រូវដឹងច្បាស់ រស-វិតក្កៈត្រូវដឹងច្បាស់ ផោដ្ឋព្វវិតក្កៈត្រូវដឹងច្បាស់ ធម្មវិតក្កៈ ត្រូវដឹងច្បាស់ រូបវិចារៈត្រូវដឹងច្បាស់ សទ្ទវិចារៈត្រូវដឹងច្បាស់ គន្ធវិចារៈ ត្រូវដឹងច្បាស់ រសវិចារៈ ត្រូវដឹងច្បាស់ ផោដ្ឋព្វវិចារៈ ត្រូវដឹងច្បាស់ ធម្មវិចារៈ ត្រូវដឹងច្បាស់ ។

[៥] បឋវីធាតុ បុគ្គលត្រូវដឹងច្បាស់ អាបោធាតុ ត្រូវដឹងច្បាស់ តេជោធាតុ ត្រូវដឹងច្បាស់ វាយោធាតុ ត្រូវដឹងច្បាស់

អាកាសធាតុ អភិញ្ញេយ្យា វិញ្ញាណធាតុ អភិញ្ញេយ្យា បឋវីកសិណំ អភិញ្ញេយ្យំ អាបោកសិណំ អភិញ្ញេយ្យំ តេជោកសិណំ អភិញ្ញេយ្យំ វាយោកសិណំ អភិញ្ញេយ្យំ នីលកសិណំ អភិញ្ញេយ្យំ បីតកសិណំ អភិញ្ញេយ្យំ លោហិតកសិណំ អភិញ្ញេយ្យំ ឱទាតកសិណំ អភិញ្ញេយ្យំ អាកាសកសិណំ អភិញ្ញេយ្យំ វិញ្ញាណកសិណំ អភិញ្ញេយ្យំ ។

[៦] កេសា អភិញ្ញេយ្យា លោមា អភិញ្ញេយ្យា នខា អភិញ្ញេយ្យា ទន្តា អភិញ្ញេយ្យា តចោ អភិញ្ញេយ្យោ មំសំ អភិញ្ញេយ្យំ ន្ហារូ អភិញ្ញេយ្យា អដ្ឋី អភិញ្ញេយ្យា អដ្ឋិមិញ្ជំ អភិញ្ញេយ្យំ វក្កំ អភិញ្ញេយ្យំ ហទយំ អភិញ្ញេយ្យំ យកនំ អភិញ្ញេយ្យំ កិលោមកំ អភិញ្ញេយ្យំ បិហកំ អភិញ្ញេយ្យំ បប្ផាសំ អភិញ្ញេយ្យំ អន្តំ អភិញ្ញេយ្យំ អន្តគុណំ អភិញ្ញេយ្យំ ឧទរិយំ អភិញ្ញេយ្យំ ករីសំ អភិញ្ញេយ្យំ បិត្តំ អភិញ្ញេយ្យំ សេម្ហំ អភិញ្ញេយ្យំ បុព្វោ អភិញ្ញេយ្យោ លោហិតំ អភិញ្ញេយ្យំ សេទោ អភិញ្ញេយ្យោ

អាកាសធាតុ ត្រូវដឹងច្បាស់ វិញ្ញាណធាតុ ត្រូវដឹងច្បាស់ បឋវីកសិណ ត្រូវដឹងច្បាស់ អាបោកសិណត្រូវដឹងច្បាស់ តេជោកសិណត្រូវដឹងច្បាស់ វាយោកសិណត្រូវដឹងច្បាស់ នីលកសិណត្រូវដឹងច្បាស់ បីតកសិណត្រូវដឹងច្បាស់ លោហិតកសិណត្រូវដឹងច្បាស់ ឱទាតកសិណត្រូវដឹងច្បាស់ អាកាសកសិណត្រូវដឹងច្បាស់ វិញ្ញាណកសិណត្រូវដឹងច្បាស់ ។

[៦] សក់ បុគ្គលត្រូវដឹងច្បាស់ រោមត្រូវដឹងច្បាស់ ក្រចកត្រូវដឹងច្បាស់ ធ្មេញត្រូវដឹងច្បាស់ ស្បែកត្រូវដឹងច្បាស់ សាច់ត្រូវដឹងច្បាស់ សរសៃត្រូវដឹងច្បាស់ ឆ្អឹងត្រូវដឹងច្បាស់ ខួរក្នុងឆ្អឹងត្រូវដឹងច្បាស់ តម្រងបស្សាវៈ ត្រូវដឹងច្បាស់ បេះដូងត្រូវដឹងច្បាស់ ថ្លើមត្រូវដឹងច្បាស់ វាវត្រូវដឹងច្បាស់ ក្រពះត្រូវដឹងច្បាស់ សួតត្រូវដឹងច្បាស់ ពោះវៀនធំត្រូវដឹងច្បាស់ ពោះវៀនតូចត្រូវដឹងច្បាស់ អាហារថ្មីត្រូវដឹងច្បាស់ អាហារចាស់ ត្រូវដឹងច្បាស់ ប្រមាត់ ត្រូវដឹងច្បាស់ ស្លេស្ម ត្រូវដឹងច្បាស់ ខ្ទុះ ត្រូវដឹងច្បាស់ ឈាម ត្រូវដឹងច្បាស់ ញើស ត្រូវដឹងច្បាស់

មេទោ អភិញ្ញេយ្យោ អស្សុ អភិញ្ញេយ្យំ វសា អភិញ្ញេយ្យា ខេឡោ អភិញ្ញេយ្យោ សឹឃាណិកា អភិញ្ញេយ្យា លសិកា អភិញ្ញេយ្យា មុត្តំ អភិញ្ញេយ្យំ មត្ថលុង្គំ អភិញ្ញេយ្យំ ។

[៧] ចក្ខាយតនំ អភិញ្ញេយ្យំ រូបាយតនំ អភិញ្ញេយ្យំ សោតាយតនំ អភិញ្ញេយ្យំ សទ្ទាយតនំ អភិញ្ញេយ្យំ ឃានាយតនំ អភិញ្ញេយ្យំ គន្ធាយតនំ អភិញ្ញេយ្យំ ជិវ្ហាយតនំ អភិញ្ញេយ្យំ រសាយតនំ អភិញ្ញេយ្យំ កាយាយតនំ អភិញ្ញេយ្យំ ផោដ្ឋព្វាយតនំ អភិញ្ញេយ្យំ មនាយតនំ អភិញ្ញេយ្យំ ធម្មាយតនំ អភិញ្ញេយ្យំ ។ ចក្ខុធាតុ អភិញ្ញេយ្យា រូបធាតុ អភិញ្ញេយ្យា ចក្ខុវិញ្ញាណធាតុ អភិញ្ញេយ្យា សោតធាតុ អភិញ្ញេយ្យា សទ្ទធាតុ អភិញ្ញេយ្យា សោតវិញ្ញាណធាតុ អភិញ្ញេយ្យា ឃានធាតុ អភិញ្ញេយ្យា គន្ធធាតុ អភិញ្ញេយ្យា ឃានវិញ្ញាណធាតុ អភិញ្ញេយ្យា ជិវ្ហាធាតុ អភិញ្ញេយ្យា រសធាតុ អភិញ្ញេយ្យា ជិវ្ហាវិញ្ញាណធាតុ អភិញ្ញេយ្យា កាយធាតុ អភិញ្ញេយ្យា ផោដ្ឋព្វធាតុ អភិញ្ញេយ្យា កាយវិញ្ញាណធាតុ អភិញ្ញេយ្យា

ខ្លាញ់ខាប់ត្រូវដឹងច្បាស់ ទឹកភ្នែកត្រូវដឹងច្បាស់ ខ្លាញ់រាវត្រូវដឹងច្បាស់ ទឹកមាត់ត្រូវដឹងច្បាស់ ទឹកសម្បោរ ត្រូវដឹងច្បាស់ ទឹករំអិល ត្រូវដឹងច្បាស់ ទឹកមូត្រ ត្រូវដឹងច្បាស់ ខួរក្នុងក្បាល ត្រូវដឹងច្បាស់ ។

[៧] ចក្ខាយតនៈ បុគ្គលត្រូវដឹងច្បាស់ រូបាយតនៈ ត្រូវដឹងច្បាស់ សោតាយតនៈត្រូវដឹងច្បាស់ សទ្ទាយតនៈត្រូវដឹងច្បាស់ ឃានាយតនៈត្រូវដឹងច្បាស់ គន្ធាយតនៈត្រូវដឹងច្បាស់ ជិវ្ហាយតនៈត្រូវដឹងច្បាស់ រសាយតនៈត្រូវដឹងច្បាស់ កាយាយតនៈត្រូវដឹងច្បាស់ ផោដ្ឋព្វាយតនៈត្រូវដឹងច្បាស់ មនាយតនៈត្រូវដឹងច្បាស់ ធម្មាយតនៈត្រូវដឹងច្បាស់ ។ ចក្ខុធាតុត្រូវដឹងច្បាស់ រូបធាតុត្រូវដឹងច្បាស់ ចក្ខុវិញ្ញាណធាតុត្រូវដឹងច្បាស់ សោតធាតុត្រូវដឹងច្បាស់ សទ្ទធាតុត្រូវដឹងច្បាស់ សោតវិញ្ញាណធាតុត្រូវដឹងច្បាស់ ឃានធាតុត្រូវដឹងច្បាស់ គន្ធធាតុត្រូវដឹងច្បាស់ ឃានវិញ្ញាណធាតុត្រូវដឹងច្បាស់ ជិវ្ហាធាតុត្រូវដឹងច្បាស់ រសធាតុត្រូវដឹងច្បាស់ ជិវ្ហាវិញ្ញាណធាតុត្រូវដឹងច្បាស់ កាយធាតុត្រូវដឹងច្បាស់ ផោដ្ឋព្វធាតុត្រូវដឹងច្បាស់ កាយវិញ្ញាណធាតុត្រូវដឹងច្បាស់

មនោធាតុ អភិញ្ញេយ្យា ធម្មធាតុ អភិញ្ញេយ្យា មនោ-
វិញ្ញាណធាតុ អភិញ្ញេយ្យា ។ ចក្ខុន្ទ្រិយំ អភិញ្ញេយ្យំ
សោតិន្ទ្រិយំ អភិញ្ញេយ្យំ ឃានិន្ទ្រិយំ អភិញ្ញេយ្យំ ជិវ្ហិ-
ន្ទ្រិយំ អភិញ្ញេយ្យំ កាយិន្ទ្រិយំ អភិញ្ញេយ្យំ មនិន្ទ្រិយំ
អភិញ្ញេយ្យំ ជីវិតិន្ទ្រិយំ អភិញ្ញេយ្យំ ឥត្ថិន្ទ្រិយំ អភិញ្ញេ-
យ្យំ បុរិសិន្ទ្រិយំ អភិញ្ញេយ្យំ សុខិន្ទ្រិយំ អភិញ្ញេ-
យ្យំ ទុក្ខិន្ទ្រិយំ អភិញ្ញេយ្យំ សោមនស្សិន្ទ្រិយំ អភិ-
ញ្ញេយ្យំ ទោមនស្សិន្ទ្រិយំ អភិញ្ញេយ្យំ ឧបេក្ខិន្ទ្រិយំ
អភិញ្ញេយ្យំ សទ្ធិន្ទ្រិយំ អភិញ្ញេយ្យំ វីរិយិន្ទ្រិយំ អភិ-
ញ្ញេយ្យំ សតិន្ទ្រិយំ អភិញ្ញេយ្យំ សមាធិន្ទ្រិយំ អភិ-
ញ្ញេយ្យំ បញ្ញិន្ទ្រិយំ អភិញ្ញេយ្យំ អនញ្ញាតញ្ញស្សាមី-
តិន្ទ្រិយំ អភិញ្ញេយ្យំ អញ្ញិន្ទ្រិយំ អភិញ្ញេយ្យំ អញ្ញា-
តាវិន្ទ្រិយំ អភិញ្ញេយ្យំ ។

[៨] កាមធាតុ អភិញ្ញេយ្យា រូបធាតុ អភិ-
ញ្ញេយ្យា អរូបធាតុ អភិញ្ញេយ្យា កាមភវោ អភិញ្ញេ-
យ្យោ រូបភវោ អភិញ្ញេយ្យោ អរូបភវោ អភិញ្ញេយ្យោ
សញ្ញាភវោ អភិញ្ញេយ្យោ អសញ្ញាភវោ អភិញ្ញេយ្យោ

មនោធាតុត្រូវដឹងច្បាស់ ធម្មធាតុត្រូវដឹងច្បាស់ មនោវិញ្ញាណធាតុត្រូវដឹងច្បាស់ ។ ចក្ខុន្ទ្រិយត្រូវដឹងច្បាស់ សោតិន្ទ្រិយត្រូវដឹងច្បាស់ ឃានិន្ទ្រិយត្រូវដឹងច្បាស់ ជិវ្ហិន្ទ្រិយត្រូវដឹងច្បាស់ កាយិន្ទ្រិយត្រូវដឹងច្បាស់ មនិន្ទ្រិយត្រូវដឹងច្បាស់ ជីវិតិន្ទ្រិយត្រូវដឹងច្បាស់ ឥត្ថិន្ទ្រិយត្រូវដឹងច្បាស់ បុរិសិន្ទ្រិយត្រូវដឹងច្បាស់ សុខិន្ទ្រិយត្រូវដឹងច្បាស់ ទុក្ខិន្ទ្រិយត្រូវដឹងច្បាស់ សោមនស្សិន្ទ្រិយត្រូវដឹងច្បាស់ ទោមនស្សិន្ទ្រិយត្រូវដឹងច្បាស់ ឧបេក្ខិ-ន្ទ្រិយត្រូវដឹងច្បាស់ សទ្ធិន្ទ្រិយត្រូវដឹងច្បាស់ វិរិយិន្ទ្រិយត្រូវដឹងច្បាស់ សតិន្ទ្រិយត្រូវដឹងច្បាស់ សមាធិន្ទ្រិយត្រូវដឹងច្បាស់ បញ្ញិន្ទ្រិយត្រូវដឹងច្បាស់ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយត្រូវដឹងច្បាស់ អញ្ញិន្ទ្រិយត្រូវដឹងច្បាស់ អញ្ញាតាវិន្ទ្រិយ ត្រូវដឹងច្បាស់ ។

[៨] កាមធាតុត្រូវដឹងច្បាស់ រូបធាតុត្រូវដឹងច្បាស់ អរូបធាតុត្រូវដឹងច្បាស់ កាមភពត្រូវដឹងច្បាស់ រូបភពត្រូវដឹងច្បាស់ អរូបភពត្រូវដឹងច្បាស់ សញ្ញាភព ត្រូវដឹងច្បាស់ អសញ្ញាភព ត្រូវដឹងច្បាស់

នេវសញ្ញានាសញ្ញាភវោ អភិញ្ញេយ្យោ ឯកវោការ-ភវោ អភិញ្ញេយ្យោ ចតុវោការភវោ អភិញ្ញេយ្យោ បញ្ចវោការភវោ អភិញ្ញេយ្យោ ។ បឋមជ្ឈានំ អភិ-ញ្ញេយ្យំ ទុតិយជ្ឈានំ អភិញ្ញេយ្យំ តតិយជ្ឈានំ អភិ-ញ្ញេយ្យំ ចតុត្ថជ្ឈានំ អភិញ្ញេយ្យំ ។

[៩] មេត្តា ចេតោវិមុត្តិ អភិញ្ញេយ្យា ករុណា ចេតោវិមុត្តិ អភិញ្ញេយ្យា មុទិតា ចេតោវិមុត្តិ អភិ-ញ្ញេយ្យា ឧបេក្ខា ចេតោវិមុត្តិ អភិញ្ញេយ្យា អាកា-សានញ្ចាយតនសមាបត្តិ អភិញ្ញេយ្យា វិញ្ញាណញ្ចា-យតនសមាបត្តិ អភិញ្ញេយ្យា អាកិញ្ចញ្ញាយតនស-មាបត្តិ អភិញ្ញេយ្យា នេវសញ្ញានាសញ្ញាយតនសមា-បត្តិ អភិញ្ញេយ្យា ។ អវិជ្ជា អភិញ្ញេយ្យា សង្ខារា អភិញ្ញេយ្យា វិញ្ញាណំ អភិញ្ញេយ្យំ នាមរូបំ អភិញ្ញេ-យ្យំ សឡាយតនំ អភិញ្ញេយ្យំ ផស្សោ អភិញ្ញេយ្យោ វេទនា អភិញ្ញេយ្យា តណ្ហា អភិញ្ញេយ្យា ឧបាទានំ អភិញ្ញេយ្យំ ភវោ អភិញ្ញេយ្យោ ជាតិ អភិញ្ញេយ្យា ជរាមរណំ អភិញ្ញេយ្យំ ។

នេវសញ្ញានាសញ្ញាភពត្រូវដឹងច្បាស់ ឯកវោការភព[១] ត្រូវដឹងច្បាស់ ចតុវោការភព[២] ត្រូវដឹងច្បាស់ បញ្ចវោការភព[៣] ត្រូវដឹងច្បាស់ ។ បឋមជ្ឈាន ត្រូវដឹងច្បាស់ ទុតិយជ្ឈាន ត្រូវដឹងច្បាស់ តតិយជ្ឈាន ត្រូវដឹងច្បាស់ ចតុត្ថជ្ឈាន ត្រូវដឹងច្បាស់ ។

[៩] មេត្តាចេតោវិមុត្តិត្រូវដឹងច្បាស់ ករុណាចេតោវិមត្តិត្រូវដឹងច្បាស់ មុទិតាចេតោវិមុត្តិត្រូវដឹងច្បាស់ ឧបេក្ខាចេតោវិមុត្តិត្រូវដឹងច្បាស់ អាកាសានញ្ចាយតនសមាបត្តិត្រូវដឹងច្បាស់ វិញ្ញាណញ្ចាយតនសមាបត្តិត្រូវដឹងច្បាស់ អាកិញ្ចញ្ញាយតនសមាបត្តិត្រូវដឹងច្បាស់ នេវសញ្ញានាសញ្ញាយតនសមាបត្តិត្រូវដឹងច្បាស់ ។ អវិជ្ជាត្រូវដឹងច្បាស់ សង្ខារទាំងឡាយត្រូវដឹងច្បាស់ វិញ្ញាណត្រូវដឹងច្បាស់ នាមរូបត្រូវដឹងច្បាស់ សឡាយតនៈត្រូវដឹងច្បាស់ ផស្សៈត្រូវដឹងច្បាស់ វេទនាត្រូវដឹងច្បាស់ តណ្ហាត្រូវដឹងច្បាស់ ឧបាទានត្រូវដឹងច្បាស់ ភពត្រូវដឹងច្បាស់ ជាតិត្រូវដឹងច្បាស់ ជរាមរណៈត្រូវដឹងច្បាស់ ។

---

១ ភពមានខន្ធមួយគឺ រូបខន្ធ បានដល់អសញ្ញាភព ។ ២ ភពមានខន្ធបួនគឺ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ បានដល់អរូបភព ។ ៣ ភពមានខន្ធ៥ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ បានដល់កាមភព និង រូបភព ។ អដ្ឋកថា ។

[១០] ទុក្ខំ អភិញ្ញេយ្យំ ទុក្ខសមុទយោ អភិញ្ញេយ្យោ ទុក្ខនិរោធោ អភិញ្ញេយ្យោ ទុក្ខនិរោធគាមិនី បដិបទា អភិញ្ញេយ្យា រូបំ អភិញ្ញេយ្យំ រូបសមុទយោ អភិញ្ញេយ្យោ រូបនិរោធោ អភិញ្ញេយ្យោ រូបនិរោធគាមិនី បដិបទា អភិញ្ញេយ្យា វេទនា អភិញ្ញេយ្យា ។ បេ ។ សញ្ញា អភិញ្ញេយ្យា សង្ខារា អភិញ្ញេយ្យា វិញ្ញាណំ អភិញ្ញេយ្យំ ចក្ខុំ ។ បេ ។ ជរាមរណំ អភិញ្ញេយ្យំ ជរាមរណសមុទយោ អភិញ្ញេយ្យោ ជរាមរណនិរោធោ អភិញ្ញេយ្យោ ជរាមរណនិរោធគាមិនី បដិបទា អភិញ្ញេយ្យា ។

[១១] ទុក្ខស្ស បរិញ្ញដ្ឋោ អភិញ្ញេយ្យោ ទុក្ខសមុទយស្ស បហានដ្ឋោ អភិញ្ញេយ្យោ ទុក្ខនិរោធស្ស សច្ឆិកិរិយដ្ឋោ អភិញ្ញេយ្យោ ទុក្ខនិរោធគាមិនិយា បដិបទាយ ភាវនដ្ឋោ អភិញ្ញេយ្យោ ។ រូបស្ស បរិញ្ញដ្ឋោ អភិញ្ញេយ្យោ រូបសមុទយស្ស បហានដ្ឋោ អភិញ្ញេយ្យោ រូបនិរោធស្ស សច្ឆិកិរិយដ្ឋោ អភិញ្ញេយ្យោ រូបនិរោធគាមិនិយា បដិបទាយ ភាវនដ្ឋោ អភិញ្ញេយ្យោ វេទនាយ ។ បេ ។ សញ្ញាយ សង្ខារានំ វិញ្ញាណស្ស

[១០] ទុក្ខ បុគ្គលត្រូវដឹងច្បាស់ ទុក្ខសមុទ័យ ត្រូវដឹងច្បាស់ ទុក្ខនិរោធ ត្រូវដឹងច្បាស់ ទុក្ខនិរោធគាមិនីបដិបទាត្រូវដឹងច្បាស់ រូបត្រូវដឹងច្បាស់ រូបសមុទ័យត្រូវដឹងច្បាស់ រូបនិរោធត្រូវដឹងច្បាស់ រូបនិរោធ-គាមិនីបដិបទាត្រូវដឹងច្បាស់ វេទនាត្រូវដឹងច្បាស់ ។ បេ ។ សញ្ញាត្រូវដឹងច្បាស់ សង្ខារទាំងឡាយត្រូវដឹងច្បាស់ វិញ្ញាណត្រូវដឹងច្បាស់ ចក្ខុត្រូវដឹងច្បាស់ ។ បេ ។ ជរាមរណៈត្រូវដឹងច្បាស់ ជរាមរណសមុទ័យត្រូវដឹងច្បាស់ ជរាមរណនិរោធត្រូវដឹងច្បាស់ ជរាមរណនិរោធគាមិនីបដិបទាត្រូវដឹងច្បាស់ ។

[១១] អត្ថនៃការកំណត់ដឹងនូវទុក្ខ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការលះបង់នូវទុក្ខសមុទ័យ ត្រូវដឹងច្បាស់ អត្ថនៃការធ្វើឲ្យជាក់ច្បាស់នូវទុក្ខ-និរោធ ត្រូវដឹងច្បាស់ អត្ថនៃការចម្រើននូវទុក្ខនិរោធគាមិនីបដិបទា ត្រូវដឹងច្បាស់ ។ អត្ថនៃការកំណត់ដឹងនូវរូបត្រូវដឹងច្បាស់ អត្ថនៃការលះបង់នូវរូបសមុទ័យ ត្រូវដឹងច្បាស់ អត្ថនៃការធ្វើឲ្យជាក់ច្បាស់នូវរូបនិរោធត្រូវដឹងច្បាស់ អត្ថនៃការចម្រើននូវទុក្ខនិរោធគាមិនីបដិបទា ត្រូវដឹងច្បាស់ ។ អត្ថនៃការកំណត់ដឹងនូវរូប ត្រូវដឹងច្បាស់ អត្ថនៃការលះបង់នូវរូបសមុទ័យ ត្រូវដឹងច្បាស់ អត្ថនៃការធ្វើឲ្យជាក់ច្បាស់នូវរូប-និរោធ ត្រូវដឹងច្បាស់ អត្ថនៃការចម្រើននូវរូបនិរោធគាមិនីបដិបទា ត្រូវដឹងច្បាស់ នូវវេទនា ។ បេ ។ នូវសញ្ញា សង្ខារ វិញ្ញាណ

ចក្ខុស្ស ។ បេ ។ ជរាមរណស្ស បរិញ្ញដ្ឋោ អភិញ្ញេយ្យោ ជរាមរណសមុទយស្ស បហានដ្ឋោ អភិញ្ញេយ្យោ ជរាមរណនិរោធស្ស សច្ឆិកិរិយដ្ឋោ អភិញ្ញេយ្យោ ជរាមរណនិរោធគាមិនិយា បដិបទាយ ភាវនដ្ឋោ អភិញ្ញេយ្យោ ។

[១២] ទុក្ខស្ស បរិញ្ញាបដិវេធដ្ឋោ អភិញ្ញេយ្យោ ទុក្ខសមុទយស្ស បហានប្បដិវេធដ្ឋោ អភិញ្ញេយ្យោ ទុក្ខនិរោធស្ស សច្ឆិកិរិយាបដិវេធដ្ឋោ អភិញ្ញេយ្យោ ទុក្ខនិរោធគាមិនិយា បដិបទាយ ភាវនាបដិវេធដ្ឋោ អភិញ្ញេយ្យោ ។ រូបស្ស បរិញ្ញាបដិវេធដ្ឋោ អភិញ្ញេយ្យោ រូបសមុទយស្ស បហានប្បដិវេធដ្ឋោ អភិញ្ញេយ្យោ រូបនិរោធស្ស សច្ឆិកិរិយាបដិវេធដ្ឋោ អភិញ្ញេយ្យោ រូបនិរោធគាមិនិយា បដិបទាយ ភាវនាបដិវេធដ្ឋោ អភិញ្ញេយ្យោ វេទនាយ ។ បេ ។ សញ្ញាយ សង្ខារានំ វិញ្ញាណស្ស ចក្ខុស្ស ។ បេ ។ ជរាមរណស្ស បរិញ្ញាបដិវេធដ្ឋោ អភិញ្ញេយ្យោ ជរាមរណសមុទយស្ស បហានប្បដិវេធដ្ឋោ អភិញ្ញេយ្យោ

ចក្ខុ ។ បេ ។ អត្ថនៃការកំណត់ដឹងនូវជរាមរណៈ ត្រូវដឹងច្បាស់ អត្ថនៃការលះបង់នូវជរាមរណសមុទ័យ ត្រូវដឹងច្បាស់ អត្ថនៃការធ្វើឲ្យជាក់ច្បាស់នូវជរាមរណនិរោធ ត្រូវដឹងច្បាស់ អត្ថនៃការចម្រើននូវជរាមរណ-និរោធគាមិនីបដិបទា ត្រូវដឹងច្បាស់ ។

[១២] អត្ថនៃការចាក់ធ្លុះនូវការកំណត់ដឹងទុក្ខ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវការលះបង់ទុក្ខសមុទ័យ ត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះ នូវការធ្វើឲ្យជាក់ច្បាស់ទុក្ខនិរោធ ត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវសេចក្តីចម្រើនទុក្ខនិរោធគាមិនីបដិបទា ត្រូវដឹងច្បាស់ ។ អត្ថនៃការចាក់ធ្លុះនូវការកំណត់ដឹងរូបត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវការលះបង់រូប-សមុទ័យ ត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះនូវការធ្វើឲ្យជាក់ច្បាស់នូវរូបនិ-រោធ ត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះ នូវការចម្រើនរូបនិរោធគាមិនីបដិ-បទា ត្រូវដឹងច្បាស់ នូវវេទនា ។ បេ ។ នូវសញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ អត្ថនៃការចាក់ធ្លុះ នូវការកំណត់ដឹងជរាមរណៈ ត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះ នូវការលះបង់ជរាមរណសមុទ័យ ត្រូវដឹងច្បាស់

ជរាមរណនិរោធស្ស សច្ឆិកិរិយាបដិវេធដ្ឋោ អភិញ្ញេយ្យោ ជរាមរណនិរោធគាមិនិយា បដិបទាយ ភាវនាបដិវេធដ្ឋោ អភិញ្ញេយ្យោ ។

[១៣] ទុក្ខំ អភិញ្ញេយ្យំ ទុក្ខសមុទយោ អភិញ្ញេយ្យោ ទុក្ខនិរោធោ អភិញ្ញេយ្យោ ទុក្ខស្ស សមុទយនិរោធោ អភិញ្ញេយ្យោ ទុក្ខស្ស ឆន្ទរាគនិរោធោ អភិញ្ញេយ្យោ ទុក្ខស្ស អស្សាទោ អភិញ្ញេយ្យោ ទុក្ខស្ស អាទីនវោ អភិញ្ញេយ្យោ ទុក្ខស្ស និស្សរណំ អភិញ្ញេយ្យំ រូបំ អភិញ្ញេយ្យំ រូបសមុទយោ អភិញ្ញេយ្យោ រូបនិរោធោ អភិញ្ញេយ្យោ រូបស្ស សមុទយនិរោធោ អភិញ្ញេយ្យោ រូបស្ស ឆន្ទរាគនិរោធោ អភិញ្ញេយ្យោ រូបស្ស អស្សាទោ អភិញ្ញេយ្យោ រូបស្ស អាទីនវោ អភិញ្ញេយ្យោ រូបស្ស និស្សរណំ អភិញ្ញេយ្យំ វេទនា អភិញ្ញេយ្យា ។ បេ ។ សញ្ញា អភិញ្ញេយ្យា សង្ខារា អភិញ្ញេយ្យា វិញ្ញាណំ អភិញ្ញេយ្យំ ចក្ខុំ ។ បេ ។ ជរាមរណំ អភិញ្ញេយ្យំ ជរាមរណសមុទយោ អភិញ្ញេយ្យោ ជរាមរណនិរោធោ អភិញ្ញេយ្យោ

អត្ថនៃការចាក់ធ្លុះ នូវការធ្វើឲ្យជាក់ច្បាស់ជរាមរណនិរោធ ត្រូវដឹងច្បាស់ អត្ថនៃការចាក់ធ្លុះ នូវការចម្រើនជរាមរណនិរោធគាមិនីបដិបទា ត្រូវដឹងច្បាស់ ។

[១៣] ទុក្ខ បុគ្គលត្រូវដឹងច្បាស់ ទុក្ខសមុទ័យ ត្រូវដឹងច្បាស់ ទុក្ខ-និរោធ ត្រូវដឹងច្បាស់ ទុក្ខសមុទយនិរោធ ត្រូវដឹងច្បាស់ ទុក្ខឆន្ទរាគ-និរោធ ត្រូវដឹងច្បាស់ ទុក្ខស្សាទៈត្រូវដឹងច្បាស់ ទុក្ខាទីនវៈ ត្រូវដឹងច្បាស់ ទុក្ខនិស្សរណៈ ត្រូវដឹងច្បាស់ រូបត្រូវដឹងច្បាស់ រូបសមុទ័យ ត្រូវដឹងច្បាស់ រូបនិរោធ ត្រូវដឹងច្បាស់ រូបសមុទយនិរោធ ត្រូវដឹងច្បាស់ រូបឆន្ទរាគនិរោធ ត្រូវដឹងច្បាស់ រូបស្សាទៈ ត្រូវដឹងច្បាស់ រូបា-ទីនវៈ ត្រូវដឹងច្បាស់ រូបនិស្សរណៈ ត្រូវដឹងច្បាស់ វេទនា ត្រូវដឹងច្បាស់ ។ បេ ។ សញ្ញា ត្រូវដឹងច្បាស់ សង្ខារទាំងឡាយ ត្រូវដឹងច្បាស់ វិញ្ញាណ ត្រូវដឹងច្បាស់ ចក្ខុ ។ បេ ។ ជរាមរណៈ ត្រូវដឹងច្បាស់ ជរាមរណសមុទ័យ ត្រូវដឹងច្បាស់ ជរាមរណនិរោធ ត្រូវដឹងច្បាស់

ជរាមរណស្ស សមុទយនិរោធោ អភិញ្ញេយ្យោ ជរា-
មរណស្ស ឆន្ទរាគនិរោធោ អភិញ្ញេយ្យោ ជរាមរ-
ណស្ស អស្សាទោ អភិញ្ញេយ្យោ ជរាមរណស្ស
អាទីនវោ អភិញ្ញេយ្យោ ជរាមរណស្ស និស្សរណំ
អភិញ្ញេយ្យំ ។

[១៤] ទុក្ខំ អភិញ្ញេយ្យំ ទុក្ខសមុទយោ អ-
ភិញ្ញេយ្យោ ទុក្ខនិរោធោ អភិញ្ញេយ្យោ ទុក្ខនិរោធ-
គាមិនី បដិបទា អភិញ្ញេយ្យា ទុក្ខស្ស អស្សាទោ
អភិញ្ញេយ្យោ ទុក្ខស្ស អាទីនវោ អភិញ្ញេយ្យោ ទុ-
ក្ខស្ស និស្សរណំ អភិញ្ញេយ្យំ ។ រូបំ អភិញ្ញេយ្យំ
រូបសមុទយោ អភិញ្ញេយ្យោ រូបនិរោធោ អភិញ្ញេយ្យោ
រូបនិរោធគាមិនី បដិបទា អភិញ្ញេយ្យា រូបស្ស អស្សា-
ទោ អភិញ្ញេយ្យោ រូបស្ស អាទីនវោ អភិញ្ញេយ្យោ
រូបស្ស និស្សរណំ អភិញ្ញេយ្យំ វេទនា អភិញ្ញេយ្យា
។ បេ ។ សញ្ញា អភិញ្ញេយ្យា សង្ខារា អភិញ្ញេយ្យា
វិញ្ញាណំ អភិញ្ញេយ្យំ ចក្ខុំ ។ បេ ។ ជរាមរណំ
អភិញ្ញេយ្យំ ជរាមរណសមុទយោ អភិញ្ញេយ្យោ

ជរាមរណសមុទយនិរោធ ត្រូវដឹងច្បាស់ ជរាមរណនិរោធគាមិនីបដិបទា ត្រូវដឹងច្បាស់ ជរាមរណស្សាទៈ ត្រូវដឹងច្បាស់ ជរាមរណាទីនវៈ ត្រូវដឹងច្បាស់ ជរាមរណនិស្សរណៈ ត្រូវដឹងច្បាស់ ។

[១៤] ទុក្ខ បុគ្គលត្រូវដឹងច្បាស់ ទុក្ខសមុទ័យ ត្រូវដឹងច្បាស់ ទុក្ខនិ-រោធ ត្រូវដឹងច្បាស់ ទុក្ខនិរោធគាមិនីបដិបទា ត្រូវដឹងច្បាស់ ទុក្ខស្សា-ទៈ ត្រូវដឹងច្បាស់ ទុក្ខាទីនវៈ ត្រូវដឹងច្បាស់ ទុក្ខនិស្សរណៈ ត្រូវដឹងច្បាស់ ។ រូប ត្រូវដឹងច្បាស់ រូបសមុទ័យ ត្រូវដឹងច្បាស់ រូបនិរោធ ត្រូវដឹងច្បាស់ រូបនិរោធគាមិនីបដិបទា ត្រូវដឹងច្បាស់ រូបស្សាទៈ ត្រូវដឹងច្បាស់ រូបាទីនវៈ ត្រូវដឹងច្បាស់ រូបនិស្សរណៈ ត្រូវដឹងច្បាស់ វេទនា ត្រូវដឹងច្បាស់ ។ បេ ។ សញ្ញា ត្រូវដឹងច្បាស់ សង្ខារទាំងឡាយ ត្រូវដឹងច្បាស់ វិញ្ញាណ ត្រូវដឹងច្បាស់ ចក្ខុ ។ បេ ។ ជរាមរណៈ ត្រូវដឹងច្បាស់ ជរាមរណសមុទ័យ ត្រូវដឹងច្បាស់

ជរាមរណនិរោធោ អភិញ្ញេយ្យោ ជរាមរណនិរោធគាមិនី បដិបទា អភិញ្ញេយ្យា ជរាមរណស្ស អស្សាទោ អភិញ្ញេយ្យោ ជរាមរណស្ស អាទីនវោ អភិញ្ញេយ្យោ ជរាមរណស្ស និស្សរណំ អភិញ្ញេយ្យំ ។

[១៨] អនិច្ចានុបស្សនា អភិញ្ញេយ្យា ទុក្ខានុបស្សនា អភិញ្ញេយ្យា អនត្តានុបស្សនា អភិញ្ញេយ្យា និព្វិទានុបស្សនា អភិញ្ញេយ្យា វិរាគានុបស្សនា អភិញ្ញេយ្យា និរោធានុបស្សនា អភិញ្ញេយ្យា បដិនិស្សគ្គានុបស្សនា អភិញ្ញេយ្យា ។ រូបេ អនិច្ចានុបស្សនា អភិញ្ញេយ្យា រូបេ ទុក្ខានុបស្សនា អភិញ្ញេយ្យា រូបេ អនត្តានុបស្សនា អភិញ្ញេយ្យា រូបេ និព្វិទានុបស្សនា អភិញ្ញេយ្យា រូបេ វិរាគានុបស្សនា អភិញ្ញេយ្យា

ជរាមរណនិរោធ ត្រូវដឹងច្បាស់ ជរាមរណនិរោធគាមិនីបដិបទា ត្រូវដឹងច្បាស់ ជរាមរណស្សាទៈ ត្រូវដឹងច្បាស់ ជរាមរណាទីនវៈ ត្រូវដឹងច្បាស់ ជរាមរណនិស្សរណៈ ត្រូវដឹងច្បាស់ ។

[១៥] អនិច្ចានុបស្សនា (ការពិចារណាឃើញរឿយ ៗ ថាមិនទៀង) បុគ្គលត្រូវដឹងច្បាស់ ទុក្ខានុបស្សនា (ការពិចារណាឃើញរឿយ ៗ ថាជាទុក្ខ) ត្រូវដឹងច្បាស់ អនត្តានុបស្សនា (ការពិចារណាឃើញរឿយ ៗ ថា មិនមែនរបស់ខ្លួន) ត្រូវដឹងច្បាស់ និព្វិទានុបស្សនា (ការពិចារណាឃើញរឿយ ៗ នូវសេចក្តីនឿយណាយ) ត្រូវដឹងច្បាស់ វិរាគានុបស្សនា (ការពិចារណាឃើញរឿយ ៗ នូវសេចក្តីប្រាសចាកតម្រេក) ត្រូវដឹងច្បាស់ និរោធានុបស្សនា (ការពិចារណាឃើញរឿយ ៗ នូវសេចក្តីរលត់) ត្រូវដឹងច្បាស់ បដិនិស្សគ្គានុបស្សនា (ការពិចារណាឃើញរឿយ ៗ នូវសេចក្តីលះបង់) ត្រូវដឹងច្បាស់ ។ ការពិចារណាឃើញរឿយ ៗ ក្នុងរូបថាមិនទៀង ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយ ៗ ក្នុងរូបថាជាទុក្ខ ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយ ៗ ក្នុងរូបថាមិនមែនខ្លួន ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយ ៗ នូវសេចក្តីនឿយណាយក្នុងរូប ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយ ៗ នូវសេចក្តីប្រាសចាកតម្រេកក្នុងរូប ត្រូវដឹងច្បាស់

រូបេ និរោធានុបស្សនា អភិញ្ញេយ្យា រូបេ បដិនិស្សគ្គា-
នុបស្សនា អភិញ្ញេយ្យា វេទនាយ ។ បេ ។ សញ្ញាយ
សង្ខារេសុ វិញ្ញាណេ ចក្ខុស្មឹ ។ បេ ។ ជរាមរណេ
អនិច្ចានុបស្សនា អភិញ្ញេយ្យា ជរាមរណេ ទុក្ខានុ-
បស្សនា អភិញ្ញេយ្យា ជរាមរណេ អនត្តានុបស្សនា
អភិញ្ញេយ្យា ជរាមរណេ និព្វិទានុបស្សនា អភិញ្ញេ-
យ្យា ជរាមរណេ វិរាគានុបស្សនា អភិញ្ញេយ្យា ជ-
រាមរណេ និរោធានុបស្សនា អភិញ្ញេយ្យា ជរាមរណេ
បដិនិស្សគ្គានុបស្សនា អភិញ្ញេយ្យា ។

[១៦] ឧប្បាទោ អភិញ្ញេយ្យោ បវត្តំ អភិញ្ញេ-
យ្យំ និមិត្តំ អភិញ្ញេយ្យំ អាយុហនា អភិញ្ញេយ្យា
បដិសន្ធិ អភិញ្ញេយ្យា គតិ អភិញ្ញេយ្យា និព្វត្តិ
អភិញ្ញេយ្យា ឧបបត្តិ អភិញ្ញេយ្យា ជាតិ អភិញ្ញេ-
យ្យា ជរា អភិញ្ញេយ្យា ព្យាធិ អភិញ្ញេយ្យោ

ការពិចារណាឃើញរឿយ ៗ នូវសេចក្តីរលត់ក្នុងរូប ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយ ៗ នូវសេចក្តីលះបង់ក្នុងរូប ត្រូវដឹងច្បាស់ ក្នុងវេទនា ។ បេ ។ ក្នុងសញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ ការពិចារណាឃើញរឿយ ៗ ក្នុងជរាមរណៈថាមិនទៀង ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយ ៗ ក្នុងជរាមរណៈថាជាទុក្ខ ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយ ៗ ក្នុងជរាមរណៈថា មិនមែនខ្លួន ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយ ៗ ក្នុងជរាមរណៈថាជាសេចក្តីនឿយណាយ ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយ ៗ ក្នុងជរាមរណៈថាជាសេចក្តីប្រាសចាកតម្រេក ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយ ៗ ក្នុងជរាមរណៈថាជាសេចក្តីរលត់ ត្រូវដឹងច្បាស់ ការពិចារណាឃើញរឿយ ៗ ក្នុងជរាមរណៈថាជាសេចក្តីលះបង់ ត្រូវដឹងច្បាស់ ។

[១៦] ការកើតឡើង (ព្រោះកម្មអំពីមុនជាបច្ច័យ) ត្រូវដឹងច្បាស់ ការប្រព្រឹត្តទៅ (របស់ពួកសត្វ) ត្រូវដឹងច្បាស់ ការកំណត់ (នូវសង្ខារ) ត្រូវដឹងច្បាស់ ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិ តទៅទៀត ត្រូវដឹងច្បាស់ បដិសន្ធិ ត្រូវដឹងច្បាស់ គតិ ត្រូវដឹងច្បាស់ ការកើត (នៃខន្ធទាំងឡាយ) ត្រូវដឹងច្បាស់ ការប្រព្រឹត្តទៅនៃវិបាក ត្រូវដឹងច្បាស់ ជាតិ ត្រូវដឹងច្បាស់ ជរា ត្រូវដឹងច្បាស់ ព្យាធិ ត្រូវដឹងច្បាស់

មរណំ អភិញ្ញេយ្យំ សោកោ អភិញ្ញេយ្យោ បរិទេ-
វោ អភិញ្ញេយ្យោ ឧបាយាសោ អភិញ្ញេយ្យោ ។
អនុប្បាទោ អភិញ្ញេយ្យោ អប្បវត្តំ អភិញ្ញេយ្យំ អនិ-
មិត្តំ អភិញ្ញេយ្យំ អនាយូហនា អភិញ្ញេយ្យា អប្ប-
ដិសន្ធិ អភិញ្ញេយ្យា អគតិ អភិញ្ញេយ្យា អនិព្វត្តិ
អភិញ្ញេយ្យា អនុបបត្តិ អភិញ្ញេយ្យា អជាតិ អភិញ្ញេ-
យ្យា អជរា អភិញ្ញេយ្យា អព្យាធិ អភិញ្ញេយ្យោ អមតំ
អភិញ្ញេយ្យំ អសោកោ អភិញ្ញេយ្យោ អបរិទេវោ
អភិញ្ញេយ្យោ អនុបាយាសោ អភិញ្ញេយ្យោ ។

[១៧] ឧប្បាទោ អភិញ្ញេយ្យោ អនុប្បាទោ អ-
ភិញ្ញេយ្យោ បវត្តំ អភិញ្ញេយ្យំ អប្បវត្តំ អភិញ្ញេយ្យំ
និមិត្តំ អភិញ្ញេយ្យំ អនិមិត្តំ អភិញ្ញេយ្យំ អាយូហនា
អភិញ្ញេយ្យា អនាយូហនា អភិញ្ញេយ្យា បដិសន្ធិ អ-
ភិញ្ញេយ្យា អប្បដិសន្ធិ អភិញ្ញេយ្យា គតិ អភិញ្ញេ-
យ្យា អគតិ អភិញ្ញេយ្យា និព្វត្តិ អភិញ្ញេយ្យា

មរណៈ ត្រូវដឹងច្បាស់ សេចក្តីសោក ត្រូវដឹងច្បាស់ សេចក្តីខ្សឹកខ្សួល ត្រូវដឹងច្បាស់ សេចក្តីតានតឹង ត្រូវដឹងច្បាស់ ។ ការមិនកើតឡើង ត្រូវដឹងច្បាស់ ការមិនប្រព្រឹត្តទៅ ត្រូវដឹងច្បាស់ ការមិនកំណត់ ត្រូវដឹងច្បាស់ ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀត ត្រូវដឹងច្បាស់ ការមិនមានបដិសន្ធិ ត្រូវដឹងច្បាស់ ការមិនមានគតិ ត្រូវដឹងច្បាស់ ការមិនកើតឡើង ត្រូវដឹងច្បាស់ ការមិនប្រព្រឹត្តទៅ (នៃវិបាក) ត្រូវដឹងច្បាស់ ការមិនមានជាតិ ត្រូវដឹងច្បាស់ ការមិនមានជរា ត្រូវដឹងច្បាស់ ការមិនមានព្យាធិ ត្រូវដឹងច្បាស់ ការមិនស្លាប់ ត្រូវដឹងច្បាស់ ការមិនសោក ត្រូវដឹងច្បាស់ ការមិនខ្សឹកខ្សួល ត្រូវដឹងច្បាស់ ការមិនតានតឹង ត្រូវដឹងច្បាស់ ។

[១៧] ការកើតឡើង បុគ្គលត្រូវដឹងច្បាស់ ការមិនកើតឡើង ត្រូវដឹងច្បាស់ ការប្រព្រឹត្តទៅ ត្រូវដឹងច្បាស់ ការមិនប្រព្រឹត្តទៅ ត្រូវដឹងច្បាស់ ការកំណត់ ត្រូវដឹងច្បាស់ ការមិនកំណត់ ត្រូវដឹងច្បាស់ ការប្រមូលមកគឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀត ត្រូវដឹងច្បាស់ ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុ នៃបដិសន្ធិតទៅទៀត ត្រូវដឹងច្បាស់ បដិសន្ធិ ត្រូវដឹងច្បាស់ ការមិនមានបដិសន្ធិ ត្រូវដឹងច្បាស់ គតិ ត្រូវដឹងច្បាស់ ការមិនមានគតិ ត្រូវដឹងច្បាស់ ការកើតឡើង ត្រូវដឹងច្បាស់

អនិព្វត្តិ អភិញ្ញេយ្យា ឧបបត្តិ អភិញ្ញេយ្យា អនុបបត្តិ អភិញ្ញេយ្យា ជាតិ អភិញ្ញេយ្យា អជាតិ អភិញ្ញេយ្យា ជរា អភិញ្ញេយ្យា អជរា អភិញ្ញេយ្យា ព្យាធិ អភិ-ញ្ញេយ្យោ អព្យាធិ អភិញ្ញេយ្យោ មរណំ អភិញ្ញេយ្យំ អមតំ អភិញ្ញេយ្យំ សោកោ អភិញ្ញេយ្យោ អសោកោ អភិញ្ញេយ្យោ បរិទេវោ អភិញ្ញេយ្យោ អបរិទេវោ អភិ-ញ្ញេយ្យោ ឧបាយាសោ អភិញ្ញេយ្យោ អនុបាយាសោ អភិញ្ញេយ្យោ ។

[១៨] ឧប្បាទោ ទុក្ខន្តិ អភិញ្ញេយ្យំ បវត្តំ ទុក្ខន្តិ អភិញ្ញេយ្យំ និមិត្តំ ទុក្ខន្តិ អភិញ្ញេយ្យំ អាយុហនា ទុក្ខន្តិ អភិញ្ញេយ្យំ បដិសន្ធិ ទុក្ខន្តិ អភិញ្ញេយ្យំ គតិ ទុក្ខន្តិ អភិញ្ញេយ្យំ និព្វត្តិ ទុក្ខន្តិ អភិញ្ញេយ្យំ ឧបបត្តិ ទុក្ខន្តិ អភិញ្ញេយ្យំ ជាតិ ទុក្ខន្តិ អភិញ្ញេយ្យំ ជរា ទុ-ក្ខន្តិ អភិញ្ញេយ្យំ ព្យាធិ ទុក្ខន្តិ អភិញ្ញេយ្យំ មរណំ ទុក្ខន្តិ អភិញ្ញេយ្យំ សោកោ ទុក្ខន្តិ អភិញ្ញេយ្យំ បរិទេវោ ទុក្ខន្តិ អភិញ្ញេយ្យំ ឧបាយាសោ ទុក្ខន្តិ អភិញ្ញេយ្យំ ។

ការមិនកើតឡើង ត្រូវដឹងច្បាស់ ការប្រព្រឹត្តទៅនៃវិបាក ត្រូវដឹងច្បាស់ ការមិនប្រព្រឹត្តទៅ (នៃវិបាក) ត្រូវដឹងច្បាស់ ជាតិ ត្រូវដឹងច្បាស់ ការមិនមានជាតិ ត្រូវដឹងច្បាស់ ជរា ត្រូវដឹងច្បាស់ ការមិនមានជរា ត្រូវដឹងច្បាស់ ព្យាធិ ត្រូវដឹងច្បាស់ ការមិនមានព្យាធិ ត្រូវដឹងច្បាស់ មរណៈ ត្រូវដឹងច្បាស់ ការមិនមានមរណៈ ត្រូវដឹងច្បាស់ សេចក្តីសោក ត្រូវដឹងច្បាស់ ការមិនមានសេចក្តីសោក ត្រូវដឹងច្បាស់ សេចក្តីខ្សឹកខ្សួល ត្រូវដឹងច្បាស់ ការមិនមានសេចក្តីខ្សឹកខ្សួល ត្រូវដឹងច្បាស់ សេចក្តីតានតឹង ត្រូវដឹងច្បាស់ ការមិនមានសេចក្តីតានតឹង ត្រូវដឹងច្បាស់ ។

[១៨] បុគ្គល ត្រូវដឹងច្បាស់ថា ការកើតឡើងជាទុក្ខ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅជាទុក្ខ ត្រូវដឹងច្បាស់ថា ការកំណត់ (នូវសង្ខារ) ជាទុក្ខ ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀតជាទុក្ខ ត្រូវដឹងច្បាស់ថា បដិសន្ធិជាទុក្ខ ត្រូវដឹងច្បាស់ថា គតិជាទុក្ខ ត្រូវដឹងច្បាស់ថា ការកើតឡើងជាទុក្ខ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាកជាទុក្ខ ត្រូវដឹងច្បាស់ថា ជាតិជាទុក្ខ ត្រូវដឹងច្បាស់ថា ជរាជាទុក្ខ ត្រូវដឹងច្បាស់ថា ព្យាធិជាទុក្ខ ត្រូវដឹងច្បាស់ថា មរណៈជាទុក្ខ ត្រូវដឹងច្បាស់ថា សេចក្តីសោកជាទុក្ខ ត្រូវដឹងច្បាស់ថា សេចក្តីខ្សឹកខ្សួលជាទុក្ខ ត្រូវដឹងច្បាស់ថា សេចក្តីតានតឹងជាទុក្ខ ។

[១៩] អនុប្បាទោ សុខន្តិ អភិញ្ញេយ្យំ អប្បវត្តំ សុខន្តិ អភិញ្ញេយ្យំ អនិមិត្តំ សុខន្តិ អភិញ្ញេយ្យំ អ-នាយុហនា សុខន្តិ អភិញ្ញេយ្យំ អប្បដិសន្ធិ សុខន្តិ អភិញ្ញេយ្យំ អគតិ សុខន្តិ អភិញ្ញេយ្យំ អនិព្វត្តិ សុ-ខន្តិ អភិញ្ញេយ្យំ អនុបបត្តិ សុខន្តិ អភិញ្ញេយ្យំ អជាតិ សុខន្តិ អភិញ្ញេយ្យំ អជរា សុខន្តិ អភិញ្ញេយ្យំ អព្យាធិ សុខន្តិ អភិញ្ញេយ្យំ អមតំ សុខន្តិ អភិញ្ញេ-យ្យំ អសោកោ សុខន្តិ អភិញ្ញេយ្យំ អបរិទេវោ សុ-ខន្តិ អភិញ្ញេយ្យំ អនុបាយាសោ សុខន្តិ អភិញ្ញេយ្យំ ។

[២០] ឧប្បាទោ ទុក្ខំ អនុប្បាទោ សុខន្តិ អ-ភិញ្ញេយ្យំ បវត្តំ ទុក្ខំ អប្បវត្តំ សុខន្តិ អភិញ្ញេយ្យំ និមិត្តំ ទុក្ខំ អនិមិត្តំ សុខន្តិ អភិញ្ញេយ្យំ អាយុហនា ទុក្ខំ អនាយុហនា សុខន្តិ អភិញ្ញេយ្យំ បដិសន្ធិ ទុក្ខំ

[១៩] បុគ្គល ត្រូវដឹងច្បាស់ថា ការមិនកើតឡើងជាសុខ ត្រូវដឹងច្បាស់ថា ការមិនប្រព្រឹត្តទៅជាសុខ ត្រូវដឹងច្បាស់ថា ការមិនកំណត់ (នូវសង្ខារ) ជាសុខ ត្រូវដឹងច្បាស់ថា ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀតជាសុខ ត្រូវដឹងច្បាស់ថា ការមិនមានបដិសន្ធិជាសុខ ត្រូវដឹងច្បាស់ថា ការមិនមានគតិជាសុខ ត្រូវដឹងច្បាស់ថា ការមិនបានកើតឡើងជាសុខ ត្រូវដឹងច្បាស់ថា ការមិនប្រព្រឹត្តទៅនៃវិបាកជាសុខ ត្រូវដឹងច្បាស់ថា ការមិនមានជាតិជាសុខ ត្រូវដឹងច្បាស់ថា ការមិនមានជរាជាសុខ ត្រូវដឹងច្បាស់ថា ការមិនមានព្យាធិជាសុខ ត្រូវដឹងច្បាស់ថា ការមិនស្លាប់ជាសុខ ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីសោកជាសុខ ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីខ្សឹកខ្សួលជាសុខ ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីតានតឹងជាសុខ ។

[២០] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើងជាទុក្ខ ការមិនកើតឡើងជាសុខ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅជាទុក្ខ ការមិនប្រព្រឹត្តទៅជាសុខ ត្រូវដឹងច្បាស់ថា ការកំណត់ (នូវសង្ខារ) ជាទុក្ខ ការមិនកំណត់ (នូវសង្ខារ) ជាសុខ ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀតជាទុក្ខ ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀតជាសុខ ត្រូវដឹងច្បាស់ថា បដិសន្ធិជាទុក្ខ

អប្បដិសន្ធិ សុខន្តិ អភិញ្ញេយ្យំ គតិ ទុក្ខំ អគតិ សុខន្តិ អភិញ្ញេយ្យំ និព្វត្តិ ទុក្ខំ អនិព្វត្តិ សុខន្តិ អភិញ្ញេយ្យំ ឧបបត្តិ ទុក្ខំ អនុបបត្តិ សុខន្តិ អភិញ្ញេយ្យំ ជាតិ ទុក្ខំ អជាតិ សុខន្តិ អភិញ្ញេយ្យំ ជរា ទុក្ខំ អជរា សុខន្តិ អភិញ្ញេយ្យំ ព្យាធិ ទុក្ខំ អព្យាធិ សុខន្តិ អភិញ្ញេយ្យំ មរណំ ទុក្ខំ អមតំ សុខន្តិ អភិញ្ញេយ្យំ សោកោ ទុក្ខំ អសោកោ សុខន្តិ អភិញ្ញេយ្យំ បរិទេវោ ទុក្ខំ អបរិទេវោ សុខន្តិ អភិញ្ញេយ្យំ[១] ឧបាយាសោ ទុក្ខំ អនុបាយាសោ សុខន្តិ អភិញ្ញេយ្យំ ។

[២១] ឧប្បាទោ ភយន្តិ អភិញ្ញេយ្យំ បវត្តំ ភយន្តិ អភិញ្ញេយ្យំ និមិត្តំ ភយន្តិ អភិញ្ញេយ្យំ អាយុហនា ភយន្តិ អភិញ្ញេយ្យំ បដិសន្ធិ ភយន្តិ អភិញ្ញេយ្យំ គតិ ភយន្តិ អភិញ្ញេយ្យំ និព្វត្តិ ភយន្តិ អភិញ្ញេយ្យំ ឧបបត្តិ ភយន្តិ អភិញ្ញេយ្យំ ជាតិ ភយន្តិ អភិញ្ញេយ្យំ ជរា ភយន្តិ អភិញ្ញេយ្យំ ព្យាធិ ភយន្តិ អភិញ្ញេយ្យំ មរណំ ភយន្តិ អភិញ្ញេយ្យំ សោកោ ភយន្តិ អភិញ្ញេយ្យំ

---

១ ម. ឯត្ថន្តរេ ទោមនស្សំ ទុក្ខំ អទោមនស្សំ សុខន្តិ អភិញ្ញេយ្យន្តិ ទិស្សតិ ។

ការមិនមានបដិសន្ធិជាសុខ ត្រូវដឹងច្បាស់ថា គតិជាទុក្ខ ការមិនមានគតិជាសុខ ត្រូវដឹងច្បាស់ថា ការកើតឡើងជាទុក្ខ ការមិនកើតឡើងជាសុខ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាកជាទុក្ខ ការមិនប្រព្រឹត្តទៅនៃវិបាកជាសុខ ត្រូវដឹងច្បាស់ថា ជាតិជាទុក្ខ ការមិនមានជាតិជាសុខ ត្រូវដឹងច្បាស់ថា ជរាជាទុក្ខ ការមិនមានជរាជាសុខ ត្រូវដឹងច្បាស់ថា ព្យាធិជាទុក្ខ ការមិនមានព្យាធិជាសុខ ត្រូវដឹងច្បាស់ថា មរណៈជាទុក្ខ ការមិនមានមរណៈជាសុខ ត្រូវដឹងច្បាស់ថា សេចក្តីសោកជាទុក្ខ ការមិនមានសេចក្តីសោកជាសុខ ត្រូវដឹងច្បាស់ថា សេចក្តីខ្សឹកខ្សួលជាទុក្ខ ការមិនមានសេចក្តីខ្សឹកខ្សួលជាសុខ ត្រូវដឹងច្បាស់ថា សេចក្តីតានតឹងជាទុក្ខ ការមិនមានសេចក្តីតានតឹងជាសុខ ។

[២១] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើងជាភ័យ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅជាភ័យ ត្រូវដឹងច្បាស់ថា ការកំណត់ (នូវសង្ខារ) ជាភ័យ ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀតជាភ័យ ត្រូវដឹងច្បាស់ថា បដិសន្ធិជាភ័យ ត្រូវដឹងច្បាស់ថា គតិជាភ័យ ត្រូវដឹងច្បាស់ថា ការកើតឡើងជាភ័យ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាកជាភ័យ ត្រូវដឹងច្បាស់ថា ជាតិជាភ័យ ត្រូវដឹងច្បាស់ថា ជរាជាភ័យ ត្រូវដឹងច្បាស់ថា ព្យាធិជាភ័យ ត្រូវដឹងច្បាស់ថា មរណៈជាភ័យ ត្រូវដឹងច្បាស់ថា សេចក្តីសោកជាភ័យ ត្រូវដឹងច្បាស់ថា

បរិទេវោ ភយន្តិ អភិញ្ញេយ្យំ ឧបាយាសោ ភយន្តិ អភិញ្ញេយ្យំ ។

[២២] អនុប្បាទោ ខេមន្តិ អភិញ្ញេយ្យំ អប្បវត្តំ ខេមន្តិ អភិញ្ញេយ្យំ អនិមិត្តំ ខេមន្តិ អភិញ្ញេយ្យំ អនាយូហនា ខេមន្តិ អភិញ្ញេយ្យំ អប្បដិសន្ធិ ខេមន្តិ អភិញ្ញេយ្យំ អគតិ ខេមន្តិ អភិញ្ញេយ្យំ អនិព្វត្តិ ខេ-មន្តិ អភិញ្ញេយ្យំ អនុបបត្តិ ខេមន្តិ អភិញ្ញេយ្យំ អជាតិ ខេមន្តិ អភិញ្ញេយ្យំ អជរា ខេមន្តិ អភិញ្ញេយ្យំ អព្យាធិ ខេមន្តិ អភិញ្ញេយ្យំ អមតំ ខេមន្តិ អភិញ្ញេយ្យំ អសោកោ ខេមន្តិ អភិញ្ញេយ្យំ អបរិទេវោ ខេមន្តិ អភិញ្ញេយ្យំ អនុបាយាសោ ខេមន្តិ អភិញ្ញេយ្យំ ។

[២៣] ឧប្បាទោ ភយំ អនុប្បាទោ ខេមន្តិ អភិ-ញ្ញេយ្យំ បវត្តំ ភយំ អប្បវត្តំ ខេមន្តិ អភិញ្ញេយ្យំ និមិត្តំ ភយំ អនិមិត្តំ ខេមន្តិ អភិញ្ញេយ្យំ អាយូហនា

សេចក្ដីខ្សឹកខ្សួលជាភ័យ ត្រូវដឹងច្បាស់ថា សេចក្ដីតានតឹងជាភ័យ ។

[២២] បុគ្គលត្រូវដឹងច្បាស់ថា ការមិនកើតឡើងជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនប្រព្រឹត្តទៅជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនកំណត់ (នូវសង្ខារ) ជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនប្រមូលមកគឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀតជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានបដិសន្ធិជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានគតិជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនកើតឡើងជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនប្រព្រឹត្តទៅនៃវិបាកជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានជាតិជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានជរាជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានព្យាធិជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានមរណៈជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានសេចក្ដីសោកជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានសេចក្ដីខ្សឹកខ្សួលជាទីក្សេម ត្រូវដឹងច្បាស់ថា ការមិនមានសេចក្ដីតានតឹងជាទីក្សេម ។

[២៣] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើងជាភ័យ ការមិនកើតឡើងជាទីក្សេម ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅជាភ័យ ការមិនប្រព្រឹត្តទៅ ជាទីក្សេម ត្រូវដឹងច្បាស់ថា ការកំណត់ (នូវសង្ខារ) ជាភ័យ ការមិនកំណត់ (នូវសង្ខារ) ជាទីក្សេម ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិ តទៅទៀត

កយំ អជាយុហនា ខេមន្តិ អភិញ្ញេយ្យំ បដិសន្ធិ កយំ អប្បដិសន្ធិ ខេមន្តិ អភិញ្ញេយ្យំ គតិ កយំ អគតិ ខេមន្តិ អភិញ្ញេយ្យំ និព្វត្តិ កយំ អនិព្វត្តិ ខេមន្តិ អភិញ្ញេយ្យំ ឧបបត្តិ កយំ អនុបបត្តិ ខេមន្តិ អភិញ្ញេ-យ្យំ ជាតិ កយំ អជាតិ ខេមន្តិ អភិញ្ញេយ្យំ ជរា កយំ អជរា ខេមន្តិ អភិញ្ញេយ្យំ ព្យាធិ កយំ អព្យាធិ ខេមន្តិ អភិញ្ញេយ្យំ មរណំ កយំ អមតំ ខេមន្តិ អភិ-ញ្ញេយ្យំ សោកោ កយំ អសោកោ ខេមន្តិ អភិ-ញ្ញេយ្យំ បរិទេវោ កយំ អបរិទេវោ ខេមន្តិ អភិញ្ញេ-យ្យំ ឧបាយាសោ កយំ អនុបាយាសោ ខេមន្តិ អភិញ្ញេយ្យំ ។

[២៨] ឧប្បាទោ សាមិសន្តិ អភិញ្ញេយ្យំ បវត្តំ សា-មិសន្តិ អភិញ្ញេយ្យំ និមិត្តំ សាមិសន្តិ អភិញ្ញេយ្យំ អា-យុហនា សាមិសន្តិ អភិញ្ញេយ្យំ បដិសន្ធិ សាមិសន្តិ

ជាភ័យ ការមិនប្រមូលមកគឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិ តទៅទៀត ជាទីក្សេម ត្រូវដឹងច្បាស់ថា បដិសន្ធិជាភ័យ ការមិនមានបដិ-សន្ធិជាទីក្សេម ត្រូវដឹងច្បាស់ថា គតិជាភ័យ ការមិនមានគតិជាទីក្សេម ត្រូវដឹងច្បាស់ថា ការកើតឡើងជាភ័យ ការមិនកើតឡើងជាទីក្សេម ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាកជាភ័យ ការមិនប្រព្រឹត្តទៅនៃវិបាកជាទីក្សេម ត្រូវដឹងច្បាស់ថា ជាតិជាភ័យ ការមិនមានជាតិជាទីក្សេម ត្រូវដឹងច្បាស់ថា ជរាជាភ័យ ការមិនមានជរា ជាទីក្សេម ត្រូវដឹងច្បាស់ថា ព្យាធិជាភ័យ ការមិនមានព្យាធិជាទីក្សេម ត្រូវដឹងច្បាស់ថា មរណៈជាភ័យ ការមិនមានមរណៈជាទីក្សេម ត្រូវដឹងច្បាស់ថា សេចក្ដីសោកជាភ័យ ការមិនមានសេចក្ដីសោកជាទីក្សេម ត្រូវដឹងច្បាស់ថា សេចក្ដីខ្សឹកខ្សួលជាភ័យ ការមិនមានសេចក្ដីខ្សឹកខ្សួលជាទីក្សេម ត្រូវដឹងច្បាស់ថា សេចក្ដីតានតឹងជាភ័យ ការមិនមានសេចក្ដីតានតឹងជាទីក្សេម ។

[២៨] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើងប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅ ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការកំណត់ (នូវសង្ខារ) ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិ តទៅទៀត ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា បដិសន្ធិ ប្រកបដោយអាមិសៈ

អភិញ្ញេយ្យំ គតិ សាមិសន្តិ អភិញ្ញេយ្យំ និព្វត្តិ សា-មិសន្តិ អភិញ្ញេយ្យំ ឧបបត្តិ សាមិសន្តិ អភិញ្ញេយ្យំ ជាតិ សាមិសន្តិ អភិញ្ញេយ្យំ ជរា សាមិសន្តិ អភិ-ញ្ញេយ្យំ ព្យាធិ សាមិសន្តិ អភិញ្ញេយ្យំ មរណំ សា-មិសន្តិ អភិញ្ញេយ្យំ សោកោ សាមិសន្តិ អភិញ្ញេយ្យំ បរិទេវោ សាមិសន្តិ អភិញ្ញេយ្យំ ឧបាយាសោ សាមិសន្តិ អភិញ្ញេយ្យំ ។

[២៥] អនុប្បាទោ និរាមិសន្តិ អភិញ្ញេយ្យំ អប្ប-វត្តំ និរាមិសន្តិ អភិញ្ញេយ្យំ អនិមិត្តំ និរាមិសន្តិ អភិញ្ញេយ្យំ អនាយុហនា និរាមិសន្តិ អភិញ្ញេយ្យំ អប្បដិសន្ធិ និរាមិសន្តិ អភិញ្ញេយ្យំ អគតិ និរាមិសន្តិ អភិញ្ញេយ្យំ អនិព្វត្តិ និរាមិសន្តិ អភិញ្ញេយ្យំ អនុ-បបត្តិ និរាមិសន្តិ អភិញ្ញេយ្យំ អជាតិ និរាមិសន្តិ អភិញ្ញេយ្យំ អជរា និរាមិសន្តិ អភិញ្ញេយ្យំ

ត្រូវដឹងច្បាស់ថា គតិ ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការកើតឡើង ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាក ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ជាតិ ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ជរា ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ព្យាធិ ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា មរណៈ ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា សេចក្ដីសោក ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា សេចក្ដីខ្សឹកខ្សួល ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា សេចក្ដីតានតឹង ប្រកបដោយអាមិសៈ ។

[២៩] បុគ្គលត្រូវដឹងច្បាស់ថា ការមិនបានកើតឡើង មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនបានប្រព្រឹត្តទៅ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនបានកំណត់ (នូវសង្ខារ) មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀត មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានបដិសន្ធិមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានគតិមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនបានកើតមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនបានប្រព្រឹត្តទៅនៃវិបាក មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានជាតិមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានជរាមិនប្រកបដោយអាមិសៈ

អព្យាធិ និរាមិសន្តិ អភិញ្ញេយ្យំ អមតំ និរាមិសន្តិ អភិញ្ញេយ្យំ អសោកោ និរាមិសន្តិ អភិញ្ញេយ្យំ អបរិទេវោ និរាមិសន្តិ អភិញ្ញេយ្យំ អនុបាយាសោ និរាមិសន្តិ អភិញ្ញេយ្យំ ។

[២៦] ឧប្បាទោ សាមិសំ អនុប្បាទោ និរា-មិសន្តិ អភិញ្ញេយ្យំ បវត្តំ សាមិសំ អប្បវត្តំ និរាមិ-សន្តិ អភិញ្ញេយ្យំ និមិត្តំ សាមិសំ អនិមិត្តំ និរាមិ-សន្តិ អភិញ្ញេយ្យំ អាយុហនា សាមិសំ អនាយុ-ហនា និរាមិសន្តិ អភិញ្ញេយ្យំ បដិសន្ធិ សាមិសំ អប្បដិសន្ធិ និរាមិសន្តិ អភិញ្ញេយ្យំ គតិ សាមិសំ អគតិ និរាមិសន្តិ អភិញ្ញេយ្យំ និព្វត្តិ សាមិសំ

ត្រូវដឹងច្បាស់ថា ការមិនមានព្យាធិ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានមរណៈ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីសោក មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីខ្សឹកខ្សួល ប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីតានតឹង មិនប្រកបដោយអាមិសៈ ។

[២៦] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើង ប្រកបដោយអាមិសៈ ការមិនកើតឡើង មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅ ប្រកបដោយអាមិសៈ ការមិនប្រព្រឹត្តទៅ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការកំណត់ (នូវសង្ខារ) ប្រកបដោយអាមិសៈ ការមិនកំណត់ (នូវសង្ខារ) មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិសន្ធិតទៅទៀត ប្រកបដោយអាមិសៈ ការមិនប្រមូលមក គឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀត មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា បដិសន្ធិ ប្រកបដោយអាមិសៈ ការមិនមានបដិសន្ធិមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា គតិ ប្រកបដោយអាមិសៈ ការមិនមានគតិមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការកើត ប្រកបដោយអាមិសៈ

អនិព្វត្តិ និរាមិសន្តិ អភិញ្ញេយ្យំ ឧបបត្តិ សាមិសំ អនុបបត្តិ និរាមិសន្តិ អភិញ្ញេយ្យំ ជាតិ សាមិសំ អជាតិ និរាមិសន្តិ អភិញ្ញេយ្យំ ជរា សាមិសំ អជរា និរាមិសន្តិ អភិញ្ញេយ្យំ ព្យាធិ សាមិសំ អព្យាធិ និរាមិសន្តិ អភិញ្ញេយ្យំ មរណំ សាមិសំ អមតំ និរាមិសន្តិ អភិញ្ញេយ្យំ សោកោ សាមិសំ អសោកោ និរាមិសន្តិ អភិញ្ញេយ្យំ បរិទេវោ សាមិសំ អបរិទេ-វោ និរាមិសន្តិ អភិញ្ញេយ្យំ ឧបាយាសោ សាមិសំ អនុបាយាសោ និរាមិសន្តិ អភិញ្ញេយ្យំ ។

[២៧] ឧប្បាទោ សង្ខារាតិ អភិញ្ញេយ្យំ[១] បវត្តំ សង្ខារាតិ អភិញ្ញេយ្យំ និមិត្តំ សង្ខារាតិ អភិញ្ញេយ្យំ អាយុហនា សង្ខារាតិ អភិញ្ញេយ្យំ បដិសន្ធិ សង្ខារាតិ អភិញ្ញេយ្យំ

១ ម. អយំ សព្វសទ្ទោ អភិញ្ញេយ្យោតិ ទិស្សតិ ។

ការមិនកើត មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាក ប្រកបដោយអាមិសៈ ការមិនប្រព្រឹត្តទៅនៃវិបាក មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ជាតិ ប្រកបដោយអាមិសៈ ការមិនមានជាតិមិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ជរាប្រកបដោយអាមិសៈ ការមិនមានជរា មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា ព្យាធិ ប្រកបដោយអាមិសៈ ការមិនមានព្យាធិ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា មរណៈ ប្រកបដោយអាមិសៈ ការមិនមានមរណៈ មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា សេចក្តីសោក ប្រកបដោយអាមិសៈ ការមិនមានសេចក្តីសោក មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា សេចក្តីខ្សឹកខ្សួល ប្រកបដោយអាមិសៈ ការមិនមានសេចក្តីខ្សឹកខ្សួល មិនប្រកបដោយអាមិសៈ ត្រូវដឹងច្បាស់ថា សេចក្តីតានតឹង ប្រកបដោយអាមិសៈ ការមិនមានសេចក្តីតានតឹង មិនប្រកបដោយអាមិសៈ ។

[២៧] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើង ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅ ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា ការកំណត់ ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា ការប្រមូលមក គឺកម្មដែលជាហេតុនៃបដិ-សន្ធិតទៅទៀត ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា បដិសន្ធិ ឈ្មោះថាសង្ខារ

គតិ សង្ខារាតិ អភិញ្ញេយ្យំ និព្វត្តិ សង្ខារាតិ អភិ-ញ្ញេយ្យំ ឧបបត្តិ សង្ខារាតិ អភិញ្ញេយ្យំ ជាតិ សង្ខា-រាតិ អភិញ្ញេយ្យំ ជរា សង្ខារាតិ អភិញ្ញេយ្យំ ព្យាធិ សង្ខារាតិ អភិញ្ញេយ្យំ មរណំ សង្ខារាតិ អភិញ្ញេយ្យំ សោកោ សង្ខារាតិ អភិញ្ញេយ្យំ បរិទេវោ សង្ខារាតិ អភិញ្ញេយ្យំ ឧបាយាសោ សង្ខារាតិ អភិញ្ញេយ្យំ ។

[២៨] អនុប្បាទោ និព្វានន្តិ អភិញ្ញេយ្យំ អប្ប-វត្តំ និព្វានន្តិ អភិញ្ញេយ្យំ អនិមិត្តំ និព្វានន្តិ អភិញ្ញេ-យ្យំ អនាយុហនា និព្វានន្តិ អភិញ្ញេយ្យំ អប្បដិសន្ធិ និព្វានន្តិ អភិញ្ញេយ្យំ អគតិ និព្វានន្តិ អភិញ្ញេយ្យំ អនិព្វត្តិ និព្វានន្តិ អភិញ្ញេយ្យំ អនុបបត្តិ និព្វានន្តិ អភិញ្ញេយ្យំ អជាតិ និព្វានន្តិ អភិញ្ញេយ្យំ អជរា និព្វានន្តិ អភិញ្ញេយ្យំ អព្យាធិ និព្វានន្តិ អភិញ្ញេយ្យំ អមតំ និព្វានន្តិ អភិញ្ញេយ្យំ អសោកោ និព្វានន្តិ

ត្រូវដឹងច្បាស់ថា គតិ ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា ការកើត ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាក ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា ជាតិ ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា ជរា ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា ព្យាធិ ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា មរណៈ ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា សេចក្តីសោក ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា សេចក្តីខ្សឹកខ្សួល ឈ្មោះថាសង្ខារ ត្រូវដឹងច្បាស់ថា សេចក្តីតានតឹង ឈ្មោះថា សង្ខារ ។

[២៨] បុគ្គលត្រូវដឹងច្បាស់ថា ការមិនកើតឡើង ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនប្រព្រឹត្តទៅ ឈ្មោះថា និព្វាន ត្រូវដឹងច្បាស់ថា ការមិនបានកំណត់ ឈ្មោះថា និព្វាន ត្រូវដឹងច្បាស់ថា ការមិនប្រមូលមកគឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀត ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានបដិសន្ធិ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានគតិ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនកើត ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនប្រព្រឹត្តទៅនៃវិបាក ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានជាតិ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានជរា ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានព្យាធិ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានមរណៈ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានសេចក្តីសោក ឈ្មោះថានិព្វាន

អភិញ្ញេយ្យំ អបរិទេវោ និព្វានន្តិ អភិញ្ញេយ្យំ អនុ-ចាយាសោ និព្វានន្តិ អភិញ្ញេយ្យំ ។

[២៩] ឧប្បាទោ សង្ខារា អនុប្បាទោ និព្វានន្តិ អភិញ្ញេយ្យំ បវត្តំ សង្ខារា អប្បវត្តំ និព្វានន្តិ អភិ-ញ្ញេយ្យំ និមិត្តំ សង្ខារា អនិមិត្តំ និព្វានន្តិ អភិញ្ញេ-យ្យំ អាយូហនា សង្ខារា អនាយូហនា និព្វានន្តិ អភិញ្ញេយ្យំ បដិសន្ធិ សង្ខារា អប្បដិសន្ធិ និព្វានន្តិ អភិញ្ញេយ្យំ គតិ សង្ខារា អគតិ និព្វានន្តិ អភិញ្ញេ-យ្យំ និព្វត្តិ សង្ខារា អនិព្វត្តិ និព្វានន្តិ អភិញ្ញេយ្យំ ឧបបត្តិ សង្ខារា អនុបបត្តិ និព្វានន្តិ អភិញ្ញេយ្យំ ជាតិ សង្ខារា អជាតិ និព្វានន្តិ អភិញ្ញេយ្យំ ជរា សង្ខារា អជរា និព្វានន្តិ អភិញ្ញេយ្យំ ព្យាធិ សង្ខារា អព្យាធិ និព្វានន្តិ អភិញ្ញេយ្យំ មរណំ សង្ខារា

ត្រូវដឹងច្បាស់ថា ការមិនមានសេចក្ដីខ្សឹកខ្សួល ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការមិនមានសេចក្ដីតានតឹង ឈ្មោះថានិព្វាន ។

[២៩] បុគ្គលត្រូវដឹងច្បាស់ថា ការកើតឡើង ឈ្មោះថាសង្ខារ ការមិនកើតឡើង ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅ ឈ្មោះថាសង្ខារ ការមិនប្រព្រឹត្តទៅ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការកំណត់ ឈ្មោះថាសង្ខារ ការមិនកំណត់ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការប្រមូលមកគឺកម្ម ដែលជាហេតុនៃបដិសន្ធិតទៅទៀត ឈ្មោះថាសង្ខារ ការមិនប្រមូលមកគឺកម្មដែលមិនមែនជាហេតុនៃបដិសន្ធិតទៅទៀត ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា បដិសន្ធិ ឈ្មោះថាសង្ខារ ការមិនមានបដិសន្ធិ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា គតិ ឈ្មោះថាសង្ខារ ការមិនមានគតិ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការកើត ឈ្មោះថាសង្ខារ ការមិនកើត ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ការប្រព្រឹត្តទៅនៃវិបាក ឈ្មោះថាសង្ខារ ការមិនប្រព្រឹត្តទៅនៃវិបាក ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ជាតិ ឈ្មោះថាសង្ខារ ការមិនមានជាតិ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ជរា ឈ្មោះថាសង្ខារ ការមិនមានជរា ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា ព្យាធិ ឈ្មោះថាសង្ខារ ការមិនមានព្យាធិ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា មរណៈ ឈ្មោះថាសង្ខារ

អមតំ និព្វានន្តិ អភិញ្ញេយ្យំ សោកោ សង្ខារា អសោកោ និព្វានន្តិ អភិញ្ញេយ្យំ បរិទេវោ សង្ខារា អបរិទេវោ និព្វានន្តិ អភិញ្ញេយ្យំ ឧបាយាសោ សង្ខារា អនុបាយាសោ និព្វានន្តិ អភិញ្ញេយ្យំ ។

បឋមភាណវារំ(១) ។

[៣០] បរិគ្គហដ្ឋោ អភិញ្ញេយ្យោ បរិវារដ្ឋោ អភិ-ញ្ញេយ្យោ បរិបូរដ្ឋោ អភិញ្ញេយ្យោ ឯកគ្គដ្ឋោ អភិ-ញ្ញេយ្យោ អវិក្ខេបដ្ឋោ អភិញ្ញេយ្យោ បគ្គហដ្ឋោ អភិញ្ញេយ្យោ អវិសារដ្ឋោ អភិញ្ញេយ្យោ អនាវិលដ្ឋោ អភិញ្ញេយ្យោ អនិញ្ជនដ្ឋោ អភិញ្ញេយ្យោ ឯកត្តុប-ដ្ឋានវសេន ចិត្តស្ស ឋិតដ្ឋោ អភិញ្ញេយ្យោ អារម្ម-ណដ្ឋោ អភិញ្ញេយ្យោ គោចរដ្ឋោ អភិញ្ញេយ្យោ បហានដ្ឋោ អភិញ្ញេយ្យោ បរិច្ចាគដ្ឋោ អភិញ្ញេយ្យោ វុដ្ឋានដ្ឋោ អភិញ្ញេយ្យោ វិវដ្ដនដ្ឋោ អភិញ្ញេយ្យោ សន្តដ្ឋោ[២] អភិញ្ញេយ្យោ បណីតដ្ឋោ អភិញ្ញេយ្យោ

---

១ ឱ. ម. បឋមភាណវារំ និដ្ឋិតំ ។ ២ ម. សន្តុដ្ឋោ ។

មិនមានមរណៈ ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា សេចក្តីសោក ឈ្មោះថាសង្ខារ ការមិនមានសេចក្តីសោក ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា សេចក្តីខ្សឹកខ្សួល ឈ្មោះថាសង្ខារ ការមិនមានសេចក្តីខ្សឹកខ្សួល ឈ្មោះថានិព្វាន ត្រូវដឹងច្បាស់ថា សេចក្តីតានតឹង ឈ្មោះថាសង្ខារ ការមិនមានសេចក្តីតានតឹង ឈ្មោះថានិព្វាន ។

ចប់ បឋមភាណវារៈ ។

[៣០] អត្ថនៃធម៌ដែលគួរកំណត់កាន់យក បុគ្គលត្រូវដឹងច្បាស់ អត្ថនៃធម៌ជាបរិវារ ត្រូវដឹងច្បាស់ អត្ថនៃធម៌ដែលគួរបំពេញ ត្រូវដឹងច្បាស់ អត្ថនៃធម៌ដែលតាំងនៅ ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយ ត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើង ត្រូវដឹងច្បាស់ អត្ថនៃការមិនរាត់រាយ ត្រូវដឹងច្បាស់ អត្ថនៃការមិនកករល្អក់ ត្រូវដឹងច្បាស់ អត្ថនៃការមិនញាប់ញ័រ ត្រូវដឹងច្បាស់ អត្ថនៃការតាំងស៊ប់របស់ចិត្ត ដោយអំណាចនៃការតាំងនៅក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃអារម្មណ៍ ត្រូវដឹងច្បាស់ អត្ថនៃការត្រាច់ទៅរបស់អារម្មណ៍ ត្រូវដឹងច្បាស់ អត្ថនៃការលះចោល ត្រូវដឹងច្បាស់ អត្ថនៃការបរិច្ចាគ ត្រូវដឹងច្បាស់ អត្ថនៃការចេញចាកកិលេស ត្រូវដឹងច្បាស់ អត្ថនៃការប្រែត្រឡប់ ត្រូវដឹងច្បាស់ អត្ថនៃការស្ងប់រម្ងាប់ ត្រូវដឹងច្បាស់ អត្ថនៃធម៌ដ៏ឧត្តម ត្រូវដឹងច្បាស់

វិមុត្តដ្ឋោ អភិញ្ញេយ្យោ អនាសវដ្ឋោ អភិញ្ញេយ្យោ តរណដ្ឋោ អភិញ្ញេយ្យោ អនិមិត្តដ្ឋោ អភិញ្ញេយ្យោ អប្ប-ណិហិតដ្ឋោ អភិញ្ញេយ្យោ សុញ្ញតដ្ឋោ អភិញ្ញេយ្យោ ឯករសដ្ឋោ អភិញ្ញេយ្យោ អនតិវត្តនដ្ឋោ អភិញ្ញេ-យ្យោ យុគនទ្ធដ្ឋោ[១] អភិញ្ញេយ្យោ និយ្យានដ្ឋោ អភិញ្ញេយ្យោ ហេតដ្ឋោ[២] អភិញ្ញេយ្យោ ទស្សនដ្ឋោ អភិញ្ញេយ្យោ អាធិបតេយ្យដ្ឋោ អភិញ្ញេយ្យោ ។

[៣១] សមថស្ស អវិក្ខេបដ្ឋោ អភិញ្ញេយ្យោ វិប-ស្សនាយ អនុបស្សនដ្ឋោ អភិញ្ញេយ្យោ សមថវិបស្ស-នានំ ឯករសដ្ឋោ អភិញ្ញេយ្យោ យុគនទ្ធស្ស អនតិវត្ត-នដ្ឋោ អភិញ្ញេយ្យោ សិក្ខាយ សមាទានដ្ឋោ អភិញ្ញេ-យ្យោ អារម្មណស្ស គោចរដ្ឋោ អភិញ្ញេយ្យោ លីនស្ស ចិត្តស្ស បគ្គហដ្ឋោ អភិញ្ញេយ្យោ ឧទ្ធតស្ស ចិត្តស្ស វិនិគ្គហដ្ឋោ អភិញ្ញេយ្យោ ឧភោវិសុទ្ធានំ អជ្ឈុបេក្ខន-ដ្ឋោ អភិញ្ញេយ្យោ វិសេសាធិគមដ្ឋោ អភិញ្ញេយ្យោ

---

១ ឱ. យុគនន្ធដ្ឋោ ។ ម. យុគនន្ធនដ្ឋោ ។ ២ ឱ. ម. ហេតុដ្ឋោ ។

អត្ថនៃការផុតស្រឡះចាកអារម្មណ៍ ត្រូវដឹងច្បាស់ អត្ថនៃការមិនមានអាសវៈ ត្រូវដឹងច្បាស់ អត្ថនៃការឆ្លង ត្រូវដឹងច្បាស់ អត្ថនៃការមិនមានសង្ខារនិមិត្ត ត្រូវដឹងច្បាស់ អត្ថនៃការមិនតម្កល់ទុកនូវតណ្ហា ត្រូវដឹងច្បាស់ អត្ថនៃសភាពសោះសូន្យ ត្រូវដឹងច្បាស់ អត្ថនៃសភាពមានរសតែមួយ ត្រូវដឹងច្បាស់ អត្ថនៃការមិនប្រព្រឹត្តកន្លង (ទៅវិញទៅមករបស់សមថៈនិងវិបស្សនា) ត្រូវដឹងច្បាស់ អត្ថនៃធម៌ដែលជាប់គ្នាជាគូ ត្រូវដឹងច្បាស់ អត្ថនៃការចេញ (ចាកសង្ខារ) ត្រូវដឹងច្បាស់ អត្ថនៃការញុំាងសត្វឲ្យដល់ (នូវព្រះនិព្វាន) ត្រូវដឹងច្បាស់ អត្ថនៃការឃើញជាក់ស្តែង (នូវព្រះនិព្វាន) ត្រូវដឹងច្បាស់ អត្ថនៃធម៌ជាអធិបតី ត្រូវដឹងច្បាស់ ។

[៣១] អត្ថនៃការមិនរាយមាយរបស់សមថៈ ត្រូវដឹងច្បាស់ អត្ថនៃការឃើញរឿយ ៗ របស់វិបស្សនា ត្រូវដឹងច្បាស់ អត្ថនៃរសតែមួយរបស់សមថៈនិងវិបស្សនា ត្រូវដឹងច្បាស់ អត្ថនៃការមិនប្រព្រឹត្តកន្លងរបស់ធម៌ដែលជាប់គ្នាជាគូ ត្រូវដឹងច្បាស់ អត្ថនៃការសមាទានក្នុងសិក្ខា ត្រូវដឹងច្បាស់ អត្ថនៃគោចររបស់អារម្មណ៍ ត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់ចិត្តដែលរួញរា ត្រូវដឹងច្បាស់ អត្ថនៃការស្ងប់ស្ងៀមរបស់ចិត្តដែលអណ្តែតអណ្តូង ត្រូវដឹងច្បាស់ អត្ថនៃការព្រងើយកន្តើយរបស់ចិត្តដ៏បរិសុទ្ធចាកចំណែកទាំងពីរ ត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹងនូវគុណវិសេស ត្រូវដឹង

ឧត្តរិប្បដិវេធដ្ឋោ អភិញ្ញេយ្យោ សច្ចាភិសមយដ្ឋោ អភិញ្ញេយ្យោ និរោធេ បតិដ្ឋាបកដ្ឋោ អភិញ្ញេយ្យោ ។

[៣២] សទ្ធិន្ទ្រិយស្ស អធិមោក្ខដ្ឋោ អភិញ្ញេយ្យោ វីរិយិន្ទ្រិយស្ស បគ្គហដ្ឋោ អភិញ្ញេយ្យោ សតិន្ទ្រិយស្ស ឧបដ្ឋានដ្ឋោ អភិញ្ញេយ្យោ សមាធិន្ទ្រិយស្ស អវិក្ខេបដ្ឋោ អភិញ្ញេយ្យោ បញ្ញិន្ទ្រិយស្ស ទស្សនដ្ឋោ អភិញ្ញេយ្យោ ។

[៣៣] សទ្ធាពលស្ស អស្សទ្ធិយេ អកម្បិយដ្ឋោ អភិញ្ញេយ្យោ វីរិយពលស្ស កោសជ្ជេ អកម្បិយដ្ឋោ អភិញ្ញេយ្យោ សតិពលស្ស បមាទេ អកម្បិយដ្ឋោ អភិញ្ញេយ្យោ សមាធិពលស្ស ឧទ្ធច្ចេ អកម្បិយដ្ឋោ អភិញ្ញេយ្យោ បញ្ញាពលស្ស អវិជ្ជាយ អកម្បិយដ្ឋោ អភិញ្ញេយ្យោ ។

[៣៤] សតិសម្ពោជ្ឈង្គស្ស ឧបដ្ឋានដ្ឋោ អភិញ្ញេយ្យោ ធម្មវិចយសម្ពោជ្ឈង្គស្ស បវិចយដ្ឋោ អភិញ្ញេយ្យោ វីរិយសម្ពោជ្ឈង្គស្ស បគ្គហដ្ឋោ អភិញ្ញេយ្យោ បីតិសម្ពោជ្ឈង្គស្ស ផរណដ្ឋោ អភិញ្ញេយ្យោ បស្សទ្ធិសម្ពោជ្ឈង្គស្ស ឧបសមដ្ឋោ អភិញ្ញេយ្យោ

ច្បាស់ អត្ថនៃការចាក់ធ្លុះនូវធម៌ដ៏ក្រៃលែង ត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹងនូវសច្ចៈ ៤ ត្រូវដឹងច្បាស់ អត្ថនៃការញុំាងចិត្តឲ្យឋិតនៅក្នុងនិរោធ ត្រូវដឹងច្បាស់ ។

[៣២] អត្ថនៃការជឿស៊ប់របស់សទ្ធិន្ទ្រិយ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់វីរិយិន្ទ្រិយ ត្រូវដឹងច្បាស់ អត្ថនៃការប្រុងប្រយ័ត្នរបស់សតិន្ទ្រិយ ត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយរបស់សមាធិន្ទ្រិយ ត្រូវដឹងច្បាស់ អត្ថនៃការឃើញរបស់បញ្ញិន្ទ្រិយ ត្រូវដឹងច្បាស់ ។

[៣៣] អត្ថនៃការមិនញាប់ញ័រដោយការមិនជឿ របស់សទ្ធាពលៈ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការមិនញាប់ញ័រដោយសេចក្តីខ្ជិលច្រអូសរបស់វីរិយពលៈ ត្រូវដឹងច្បាស់ អត្ថនៃការមិនញាប់ញ័រដោយសេចក្តីប្រមាទរបស់សតិពលៈ ត្រូវដឹងច្បាស់ អត្ថនៃការមិនញាប់ញ័រដោយការអណ្តែតអណ្តូងរបស់សមាធិពលៈ ត្រូវដឹងច្បាស់ អត្ថនៃការមិនញាប់ញ័រដោយសេចក្តីល្ងង់របស់បញ្ញាពលៈ ត្រូវដឹងច្បាស់ ។

[៣៤] អត្ថនៃការប្រុងប្រយ័ត្ន របស់សតិសម្ពោជ្ឈង្គ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការពិចារណា របស់ធម្មវិចយសម្ពោជ្ឈង្គ ត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើង របស់វីរិយសម្ពោជ្ឈង្គ ត្រូវដឹងច្បាស់ សភាពផ្សព្វផ្សាយ របស់បីតិសម្ពោជ្ឈង្គ ត្រូវដឹងច្បាស់ អត្ថនៃការស្ងប់រម្ងាប់ របស់បស្សទ្ធិសម្ពោជ្ឈង្គ ត្រូវដឹងច្បាស់

សមាធិសម្ពោជ្ឈង្គស្ស អវិក្ខេបដ្ឋោ អភិញ្ញេយ្យោ ឧបេក្ខាសម្ពោជ្ឈង្គស្ស បដិសង្ខានដ្ឋោ អភិញ្ញេយ្យោ ។

[៣៥] សម្មាទិដ្ឋិយា ទស្សនដ្ឋោ អភិញ្ញេយ្យោ សម្មាសង្កប្បស្ស អភិនិរោបនដ្ឋោ អភិញ្ញេយ្យោ សម្មាវាចាយ បរិគ្គហដ្ឋោ អភិញ្ញេយ្យោ សម្មាកម្មន្តស្ស សមុដ្ឋានដ្ឋោ អភិញ្ញេយ្យោ សម្មាអាជីវស្ស វោទានដ្ឋោ អភិញ្ញេយ្យោ សម្មាវាយាមស្ស បគ្គហដ្ឋោ អភិញ្ញេយ្យោ សម្មាសតិយា ឧបដ្ឋានដ្ឋោ អភិញ្ញេយ្យោ សម្មាសមាធិស្ស អវិក្ខេបដ្ឋោ អភិញ្ញេយ្យោ ។

[៣៦] ឥន្ទ្រិយានំ អាធិបតេយ្យដ្ឋោ អភិញ្ញេយ្យោ ពលានំ អកម្បិយដ្ឋោ អភិញ្ញេយ្យោ ពោជ្ឈង្គានំ និយ្យានដ្ឋោ អភិញ្ញេយ្យោ មគ្គស្ស ហេតុដ្ឋោ អភិញ្ញេយ្យោ សតិប្បដ្ឋានានំ ឧបដ្ឋានដ្ឋោ អភិញ្ញេយ្យោ សម្មប្បធានានំ បទហនដ្ឋោ អភិញ្ញេយ្យោ ឥទ្ធិប្បាទានំ ឥជ្ឈនដ្ឋោ អភិញ្ញេយ្យោ សច្ចានំ តថដ្ឋោ អភិញ្ញេយ្យោ បយោគានំ[១] បដិប្បស្សទ្ធដ្ឋោ អភិញ្ញេយ្យោ ផលានំ សច្ឆិកិរិយដ្ឋោ អភិញ្ញេយ្យោ

១ ម. មគ្គានំ ។

អត្ថនៃការមិនរាយមាយរបស់សមាធិសម្ពោជ្ឈង្គ ត្រូវដឹងច្បាស់ អត្ថនៃការត្រួតត្រា របស់ឧបេក្ខាសម្ពោជ្ឈង្គ ត្រូវដឹងច្បាស់ ។

[៣៥] អត្ថនៃការឃើញរបស់សម្មាទិដ្ឋិ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការលើកចិត្តឡើងរបស់សម្មាសង្កប្បៈ ត្រូវដឹងច្បាស់ អត្ថនៃការកំណត់នូវវចីសំវរៈ ៤ របស់សម្មាវាចា ត្រូវដឹងច្បាស់ អត្ថនៃការតាំងឡើងរបស់សម្មាកម្មន្តៈ ត្រូវដឹងច្បាស់ អត្ថនៃការផូរផង់របស់សម្មាអាជីវៈ ត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់សម្មាវាយាមៈ ត្រូវដឹងច្បាស់ អត្ថនៃការប្រុងប្រយ័ត្នរបស់សម្មាសតិ ត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយរបស់សម្មាសមាធិ ត្រូវដឹងច្បាស់ ។

[៣៦] អត្ថនៃភាពជាធំរបស់ឥន្ទ្រិយទាំងឡាយ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការមិនញាប់ញ័ររបស់ពលៈទាំងឡាយ ត្រូវដឹងច្បាស់ អត្ថនៃការចេញចាកធម៌ជាសត្រូវរបស់ពោជ្ឈង្គទាំងឡាយ ត្រូវដឹងច្បាស់ អត្ថនៃការញុំាងសត្វឲ្យដល់ (នូវព្រះនិព្វាន) របស់មគ្គ ត្រូវដឹងច្បាស់ អត្ថនៃការប្រុងប្រយ័ត្នរបស់សតិប្បដ្ឋានទាំងឡាយ ត្រូវដឹងច្បាស់ អត្ថនៃការតម្កល់ទុករបស់សម្មប្បធានទាំងឡាយ ត្រូវដឹងច្បាស់ អត្ថនៃការសម្រេចរបស់ឥទ្ធិ-បាទទាំងឡាយ ត្រូវដឹងច្បាស់ អត្ថនៃការទៀងរបស់សច្ចៈទាំងឡាយ ត្រូវដឹងច្បាស់ អត្ថនៃការស្ងប់រម្ងាប់ របស់បយោគទាំងឡាយគឺអរិយមគ្គ ត្រូវដឹងច្បាស់ អត្ថនៃការធ្វើឲ្យជាក់ច្បាស់របស់ផលទាំងឡាយ ត្រូវដឹងច្បាស់

វិតក្កស្ស អភិនិរោបនដ្ឋោ អភិញ្ញេយ្យោ វិចារស្ស ឧបវិចារដ្ឋោ អភិញ្ញេយ្យោ បីតិយា ផរណដ្ឋោ អភិញ្ញេយ្យោ សុខស្ស អភិសន្ទនដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស ឯកគ្គដ្ឋោ អភិញ្ញេយ្យោ អាវជ្ជនដ្ឋោ អភិញ្ញេយ្យោ វិជានដ្ឋោ[១] អភិញ្ញេយ្យោ បជាននដ្ឋោ អភិញ្ញេយ្យោ សញ្ជាននដ្ឋោ អភិញ្ញេយ្យោ ឯកោទដ្ឋោ[២] អភិញ្ញេយ្យោ ។

[៣៧] អភិញ្ញាយ ញាតដ្ឋោ អភិញ្ញេយ្យោ បរិញ្ញាយ តីរណដ្ឋោ អភិញ្ញេយ្យោ បហានស្ស បរិច្ចាគដ្ឋោ អភិញ្ញេយ្យោ ភាវនាយ ឯករសដ្ឋោ អភិញ្ញេយ្យោ សច្ឆិកិរិយាយ ផស្សនដ្ឋោ អភិញ្ញេយ្យោ ខន្ធានំ ខន្ធដ្ឋោ អភិញ្ញេយ្យោ ធាតូនំ ធាតដ្ឋោ[៣] អភិញ្ញេយ្យោ អាយតនានំ អាយតនដ្ឋោ អភិញ្ញេយ្យោ សង្ខតានំ សង្ខតដ្ឋោ អភិញ្ញេយ្យោ អសង្ខតស្ស អសង្ខតដ្ឋោ អភិញ្ញេយ្យោ ។

---

១ ឱ. ម. វិជាននដ្ឋោ ។ ២ ម. ឯករសដ្ឋោ ។ ៣ ឱ. ម. ធាតុដ្ឋោ ។

អត្ថនៃការលើកចិត្តឡើងរបស់វិតក្កៈ ត្រូវដឹងច្បាស់ អត្ថនៃការពិចារណា របស់វិចារៈ ត្រូវដឹងច្បាស់ អត្ថនៃការផ្សាយទៅរបស់បីតិ ត្រូវដឹងច្បាស់ អត្ថនៃការហូរមករបស់សុខ ត្រូវដឹងច្បាស់ អត្ថនៃការតម្កល់នឹង ក្នុងអារម្មណ៍តែមួយរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃការរំពឹងរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃការដឹងផ្សេង ៗ (របស់វិញ្ញាណ) ត្រូវដឹងច្បាស់ អត្ថនៃការដឹងសព្វ (របស់បញ្ញា) ត្រូវដឹងច្បាស់ អត្ថនៃការដឹងព្រម (របស់សញ្ញា) ត្រូវដឹងច្បាស់ អត្ថនៃការខ្ពស់ឯកគឺសមាធិ ត្រូវដឹងច្បាស់ ។

[៣៧] អត្ថនៃការដឹងរបស់អភិញ្ញា បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការត្រិះរិះរបស់បរិញ្ញា ត្រូវដឹងច្បាស់ អត្ថនៃការលះរបស់បហានៈ ត្រូវដឹងច្បាស់ អត្ថនៃរសតែមួយ របស់ភាវនា ត្រូវដឹងច្បាស់ អត្ថនៃការពាល់ត្រូវរបស់សច្ឆិកិរិយា ត្រូវដឹងច្បាស់ អត្ថនៃការទ្រទ្រង់ នូវអវយវៈ (ដោយកិច្ចទាំងឡាយមាននាំមកនូវភារៈដ៏លំបាកជាដើម) របស់ខន្ធទាំង-ឡាយត្រូវដឹងច្បាស់ អត្ថនៃការទ្រទ្រង់ (ដោយកិច្ចមានសោះសូន្យជាដើម) របស់ពួកធាតុ ត្រូវដឹងច្បាស់ អត្ថនៃអណ្តូងរបស់ពួកអាយតនៈ ត្រូវដឹងច្បាស់ អត្ថនៃបច្ច័យតាក់តែងរបស់ពួកសង្ខតធម៌ ត្រូវដឹងច្បាស់ អត្ថនៃបច្ច័យមិនតាក់តែង របស់អសង្ខតធម៌ ត្រូវដឹងច្បាស់ ។

[៣៨] ចិត្តដ្ឋោ អភិញ្ញេយ្យោ ចិត្តានន្តរិកដ្ឋោ[១] អភិញ្ញេយ្យោ ចិត្តស្ស វុដ្ឋានដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស វិវដ្ដនដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស ហេតដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស បច្ចយដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស វត្ថដ្ឋោ[២] អភិញ្ញេយ្យោ ចិត្តស្ស ភុម្មដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស អារម្មណដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស គោចរដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស ចរិយដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស គតដ្ឋោ[៣] អភិញ្ញេយ្យោ ចិត្តស្ស អភិនីហារដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស និយ្យានដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស និស្សរណដ្ឋោ អភិញ្ញេយ្យោ ។

[៣៩] ឯកត្តេ អាវជ្ជនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ វិជាននដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ បជាននដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ សញ្ជាននដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ ឯកោទដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ ឧបនិពន្ធដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ បក្ខន្ទនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ បសីទនដ្ឋោ អភិញ្ញេយ្យោ

---

១ ម. ចិត្តានន្តរិយដ្ឋោ ។ ២ ឱ. ម. វត្ថុដ្ឋោ ។ ៣ ឱ. គាតដ្ឋោ ។

[៣៨] អត្ថនៃការគិតនូវអារម្មណ៍ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃចិត្តមិនមានចន្លោះ ត្រូវដឹងច្បាស់ អត្ថនៃការចេញរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃការវិលត្រឡប់របស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃហេតុរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃបច្ច័យរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃវត្ថុរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃភូមិរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃអារម្មណ៍របស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃគោចររបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃការត្រាច់ទៅរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃដំណើររបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃការប្រមូលរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃការចេញចាកវដ្ដៈរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃការរលាស់ចេញរបស់ចិត្ត ត្រូវដឹងច្បាស់ ។

[៣៩] អត្ថនៃការរំពឹងក្នុងអារម្មណ៍តែមួយ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការដឹងច្បាស់ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការដឹងសព្វក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការដឹងព្រមក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការខ្ពស់ឯកក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការចងក្រៀកទុកក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការស្ទុះទៅក្នុងអារម្មណ៍តែមួយត្រូវដឹងច្បាស់ អត្ថនៃការជ្រះថ្លាក្នុងអារម្មណ៍តែមួយ

ឯកត្តេ សន្តិដ្ឋនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ វិមុច្ច-
នដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ ឯតំ សន្តន្តិ បស្ស-
នដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ យានីកតដ្ឋោ អភិ-
ញ្ញេយ្យោ ឯកត្តេ វត្ថុកតដ្ឋោ អភិញ្ញេយ្យោ ឯក-
ត្តេ អនុដ្ឋិតដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ បរិចិតដ្ឋោ
អភិញ្ញេយ្យោ ឯកត្តេ សុសមារទ្ធដ្ឋោ អភិញ្ញេយ្យោ
ឯកត្តេ បរិគ្គហដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ បរិវារ-
ដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ បរិបូរដ្ឋោ អភិញ្ញេយ្យោ
ឯកត្តេ សមោធានដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ អធិ-
ដ្ឋានដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ អាសេវនដ្ឋោ អភិ-
ញ្ញេយ្យោ ឯកត្តេ ភាវនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ
ពហុលីកម្មដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ សុសមុគ្គត-
ដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ សុវិមុត្តដ្ឋោ អភិញ្ញេយ្យោ
ឯកត្តេ ពុជ្ឈនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ អនុ-
ពុជ្ឈនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ បដិពុជ្ឈនដ្ឋោ

ត្រូវដឹងច្បាស់ អត្ថនៃការតាំងនៅព្រម ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការផុតស្រឡះ ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការឃើញច្បាស់ ក្នុងអារម្មណ៍តែមួយថា នុ៎ះជាទីស្ងប់រម្ងាប់ ត្រូវដឹងច្បាស់ អត្ថនៃការធ្វើដូចជាយាន ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការធ្វើដូចជាវត្ថុ ជាទីតាំង ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការតាំងនៅស៊ប់ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការសន្សំក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការប្រារព្ធព្យាយាមល្អក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការកំណត់កាន់យកក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃធម៌ជាបរិវារ ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃធម៌ដែលត្រូវបំពេញក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការប្រជុំចុះក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការតាំងចិត្តមាំក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការថ្នឹកក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការចម្រើនក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការធ្វើឲ្យច្រើនក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការអណ្តែតឡើងក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការផុតស្រឡះ ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹងក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹងរឿយៗ ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹងចំពោះ ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់

អភិញ្ញេយ្យោ ឯកត្តេ សម្ពុជ្ឈនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ ពោធនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ អនុពោធនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ បដិពោធនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ សម្ពោធនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ ពោធិបក្ខិយដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ អនុពោធិបក្ខិយដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ បដិពោធិបក្ខិយដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ សម្ពោធិបក្ខិយដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ ជោតនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ ឧជ្ជោតនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ អនុជោតនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ បដិជោតនដ្ឋោ អភិញ្ញេយ្យោ ឯកត្តេ សញ្ជោតនដ្ឋោ អភិញ្ញេយ្យោ ។

[៤០] បតាបនដ្ឋោ[១] អភិញ្ញេយ្យោ វិរោចនដ្ឋោ[២] អភិញ្ញេយ្យោ កិលេសានំ សន្តាបនដ្ឋោ អភិញ្ញេយ្យោ អមលដ្ឋោ អភិញ្ញេយ្យោ វិមលដ្ឋោ អភិញ្ញេយ្យោ និម្មលដ្ឋោ អភិញ្ញេយ្យោ

---

១ ឱ. ម. បកាសនដ្ឋោ ។ ២ ម. រោចនដ្ឋោ ។

អត្ថនៃការត្រាស់ដឹងព្រម ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការញ៉ាំងជនឲ្យត្រាស់ដឹង ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការញ៉ាំងជនឲ្យត្រាស់ដឹងរឿយ ៗ ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការញ៉ាំងជនឲ្យត្រាស់ដឹងចំពោះ ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការញ៉ាំងជនឲ្យត្រាស់ដឹងព្រមក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃធម៌ជាចំណែកការត្រាស់ដឹង ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃធម៌ជាចំណែកការត្រាស់ដឹងរឿយៗ ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃធម៌ជាចំណែកការត្រាស់ដឹងចំពោះ ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃធម៌ជាចំណែកនៃការត្រាស់ដឹងព្រម ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការបំភ្លឺក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការទ្រោលបំភ្លឺ ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការបំភ្លឺរឿយ ៗ ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការបំភ្លឺចំពោះ ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ អត្ថនៃការបំភ្លឺព្រម ក្នុងអារម្មណ៍តែមួយ ត្រូវដឹងច្បាស់ ។

[៨០] អត្ថនៃការញ៉ាំងជនឲ្យភ្លឺច្បាស់ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃការរុងរឿង ត្រូវដឹងច្បាស់ អត្ថនៃការញ៉ាំងកិលេសឲ្យក្តៅសព្វ ត្រូវដឹងច្បាស់ អត្ថនៃធម៌មិនមានមន្ទិល ត្រូវដឹងច្បាស់ អត្ថនៃធម៌ប្រាសចាកមន្ទិល ត្រូវដឹងច្បាស់ អត្ថនៃធម៌ដែលគ្មានមន្ទិល ត្រូវដឹងច្បាស់

សមដ្ឋោ អភិញ្ញេយ្យោ សមយដ្ឋោ អភិញ្ញេយ្យោ វិវេកដ្ឋោ អភិញ្ញេយ្យោ វិវេកចរិយដ្ឋោ អភិញ្ញេយ្យោ វិរាគដ្ឋោ អភិញ្ញេយ្យោ វិរាគចរិយដ្ឋោ អភិញ្ញេយ្យោ និរោធដ្ឋោ អភិញ្ញេយ្យោ និរោធចរិយដ្ឋោ អភិញ្ញេយ្យោ វោស្សគ្គដ្ឋោ អភិញ្ញេយ្យោ វោស្សគ្គចរិយដ្ឋោ អភិញ្ញេយ្យោ វិមុត្តដ្ឋោ អភិញ្ញេយ្យោ វិមុត្តិចរិយដ្ឋោ អភិញ្ញេយ្យោ ។

[៤១] ឆន្ទដ្ឋោ អភិញ្ញេយ្យោ ឆន្ទស្ស មូលដ្ឋោ អភិញ្ញេយ្យោ ឆន្ទស្ស បាទដ្ឋោ អភិញ្ញេយ្យោ ឆន្ទស្ស បធានដ្ឋោ អភិញ្ញេយ្យោ ឆន្ទស្ស ឥជ្ឈនដ្ឋោ អភិញ្ញេយ្យោ ឆន្ទស្ស អធិមោក្ខដ្ឋោ អភិញ្ញេយ្យោ ឆន្ទស្ស បគ្គហដ្ឋោ អភិញ្ញេយ្យោ ឆន្ទស្ស ឧបដ្ឋានដ្ឋោ អភិញ្ញេយ្យោ ឆន្ទស្ស អវិក្ខេបដ្ឋោ អភិញ្ញេយ្យោ ឆន្ទស្ស ទស្សនដ្ឋោ អភិញ្ញេយ្យោ ។

[៤២] វីរិយដ្ឋោ អភិញ្ញេយ្យោ វីរិយស្ស មូលដ្ឋោ អភិញ្ញេយ្យោ វីរិយស្ស បាទដ្ឋោ អភិញ្ញេយ្យោ

អត្ថនៃសភាពស្មើ ត្រូវដឹងច្បាស់ អត្ថនៃការលះកិលេស ត្រូវដឹងច្បាស់ អត្ថនៃការស្ងប់ស្ងាត់ ត្រូវដឹងច្បាស់ អត្ថនៃការប្រព្រឹត្តទៅក្នុងការស្ងប់ស្ងាត់ ត្រូវដឹងច្បាស់ អត្ថនៃការប្រាសចាករាគៈ ត្រូវដឹងច្បាស់ អត្ថនៃការប្រព្រឹត្តទៅក្នុងការប្រាសចាករាគៈ ត្រូវដឹងច្បាស់ អត្ថនៃការរលត់ទុក្ខ ត្រូវដឹងច្បាស់ អត្ថនៃការប្រព្រឹត្តទៅក្នុងការរលត់ទុក្ខ ត្រូវដឹងច្បាស់ អត្ថនៃការលះកិលេស ត្រូវដឹងច្បាស់ អត្ថនៃការប្រព្រឹត្តទៅក្នុងការលះកិលេស ត្រូវដឹងច្បាស់ អត្ថនៃការរួចចាកកិលេស ត្រូវដឹងច្បាស់ អត្ថនៃការប្រព្រឹត្តទៅក្នុងការរួចចាកកិលេស ត្រូវដឹងច្បាស់ ។

[៨១] អត្ថនៃឆន្ទៈ ត្រូវដឹងច្បាស់ អត្ថនៃមូលរបស់ឆន្ទៈ ត្រូវដឹងច្បាស់ អត្ថនៃគ្រឿងទ្ររបស់ឆន្ទៈ ត្រូវដឹងច្បាស់ អត្ថនៃគ្រឿងតម្កល់របស់ឆន្ទៈ ត្រូវដឹងច្បាស់ អត្ថនៃការសម្រេចរបស់ឆន្ទៈ ត្រូវដឹងច្បាស់ អត្ថនៃការជឿស៊ប់របស់ឆន្ទៈ ត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់ឆន្ទៈ ត្រូវដឹងច្បាស់ អត្ថនៃការតម្កល់របស់ឆន្ទៈ ត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយរបស់ឆន្ទៈ ត្រូវដឹងច្បាស់ អត្ថនៃការឃើញច្បាស់របស់ឆន្ទៈ ត្រូវដឹងច្បាស់ ។

[៨២] អត្ថនៃវីរិយៈ បុគ្គលត្រូវដឹងច្បាស់ អត្ថនៃមូលរបស់វីរិយិន្ទ្រិយ ត្រូវដឹងច្បាស់ អត្ថនៃគ្រឿងទ្ររបស់វីរិយៈ ត្រូវដឹងច្បាស់

វីរិយស្ស បធានដ្ឋោ អភិញ្ញេយ្យោ វីរិយស្ស ឥជ្ឈនដ្ឋោ អភិញ្ញេយ្យោ វីរិយស្ស អធិមោក្ខដ្ឋោ អភិញ្ញេយ្យោ វីរិយស្ស បគ្គហដ្ឋោ អភិញ្ញេយ្យោ វីរិយស្ស ឧបដ្ឋានដ្ឋោ អភិញ្ញេយ្យោ វីរិយស្ស អវិក្ខេបដ្ឋោ អភិញ្ញេយ្យោ វីរិយស្ស ទស្សនដ្ឋោ អភិញ្ញេយ្យោ ។

[៤៣] ចិត្តដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស មូលដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស បាទដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស បធានដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស ឥជ្ឈនដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស អធិមោក្ខដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស បគ្គហដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស ឧបដ្ឋានដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស អវិក្ខេបដ្ឋោ អភិញ្ញេយ្យោ ចិត្តស្ស ទស្សនដ្ឋោ អភិញ្ញេយ្យោ ។

[៤៤] វីមំសដ្ឋោ អភិញ្ញេយ្យោ វីមំសាយ មូលដ្ឋោ អភិញ្ញេយ្យោ វីមំសាយ បាទដ្ឋោ អភិញ្ញេយ្យោ វីមំសាយ បធានដ្ឋោ អភិញ្ញេយ្យោ វីមំសាយ ឥជ្ឈនដ្ឋោ អភិញ្ញេយ្យោ វីមំសាយ អធិមោក្ខដ្ឋោ អភិញ្ញេយ្យោ វីមំសាយ បគ្គហដ្ឋោ អភិញ្ញេយ្យោ

អត្ថនៃគ្រឿងតម្កល់របស់វិរិយៈ ត្រូវដឹងច្បាស់ អត្ថនៃការសម្រេចរបស់វិរិយៈ ត្រូវដឹងច្បាស់ អត្ថនៃការជឿស៊ប់របស់វិរិយៈ ត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់វិរិយៈ ត្រូវដឹងច្បាស់ អត្ថនៃការតាំងខ្ជាប់របស់វិរិយៈ ត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយរបស់វិរិយៈ ត្រូវដឹងច្បាស់ អត្ថនៃការឃើញច្បាស់របស់វិរិយៈ ត្រូវដឹងច្បាស់ ។

[៤៣] អត្ថនៃចិត្ត (ការគិតនូវអារម្មណ៍) ត្រូវដឹងច្បាស់ អត្ថនៃមូលរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃគ្រឿងទ្រូវរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃគ្រឿងតម្កល់របស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃការសម្រេចរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃការចុះចិត្តស៊ប់របស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃការតាំងខ្ជាប់របស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយរបស់ចិត្ត ត្រូវដឹងច្បាស់ អត្ថនៃការឃើញច្បាស់របស់ចិត្ត ត្រូវដឹងច្បាស់ ។

[៤៤] អត្ថនៃវីមំសា ត្រូវដឹងច្បាស់ អត្ថនៃមូលរបស់វីមំសា ត្រូវដឹងច្បាស់ អត្ថនៃគ្រឿងទ្រ របស់វីមំសា ត្រូវដឹងច្បាស់ អត្ថនៃគ្រឿងតម្កល់ របស់វីមំសា ត្រូវដឹងច្បាស់ អត្ថនៃគ្រឿងសម្រេចរបស់វីមំសា ត្រូវដឹងច្បាស់ អត្ថនៃការចុះចិត្តស៊ប់ របស់វីមំសា ត្រូវដឹងច្បាស់ អត្ថនៃការផ្គងឡើងរបស់វីមំសា ត្រូវដឹងច្បាស់

វីមំសាយ ឧបដ្ឋានដ្ឋោ អភិញ្ញេយ្យោ វីមំសាយ អវិក្ខេបដ្ឋោ អភិញ្ញេយ្យោ វីមំសាយ ទស្សនដ្ឋោ អភិញ្ញេយ្យោ ។

[៤៨] ទុក្ខដ្ឋោ អភិញ្ញេយ្យោ ទុក្ខស្ស បីឡនដ្ឋោ អភិញ្ញេយ្យោ ទុក្ខស្ស សង្ខតដ្ឋោ អភិញ្ញេយ្យោ ទុក្ខស្ស សន្តាបដ្ឋោ អភិញ្ញេយ្យោ ទុក្ខស្ស វិបរិណាមដ្ឋោ អភិញ្ញេយ្យោ សមុទយដ្ឋោ អភិញ្ញេយ្យោ សមុទយស្ស អាយុហនដ្ឋោ អភិញ្ញេយ្យោ សមុទយស្ស និទានដ្ឋោ អភិញ្ញេយ្យោ សមុទយស្ស សញ្ញោគដ្ឋោ អភិញ្ញេយ្យោ សមុទយស្ស បលិពោធដ្ឋោ អភិញ្ញេយ្យោ និរោធដ្ឋោ អភិញ្ញេយ្យោ និរោធស្ស និស្សរណដ្ឋោ អភិញ្ញេយ្យោ និរោធស្ស វិវេកដ្ឋោ អភិញ្ញេយ្យោ និរោធស្ស អសង្ខតដ្ឋោ អភិញ្ញេយ្យោ និរោធស្ស អមតដ្ឋោ អភិញ្ញេយ្យោ មគ្គដ្ឋោ អភិញ្ញេយ្យោ មគ្គស្ស និយ្យានដ្ឋោ អភិញ្ញេយ្យោ មគ្គស្ស ហេតដ្ឋោ អភិញ្ញេយ្យោ មគ្គស្ស ទស្សនដ្ឋោ អភិញ្ញេយ្យោ មគ្គស្ស អាធិបតេយ្យដ្ឋោ អភិញ្ញេយ្យោ ។

អត្ថនៃការតាំងខ្ជាប់របស់វីមំសា ត្រូវដឹងច្បាស់ អត្ថនៃការមិនរាយមាយរបស់វីមំសា ត្រូវដឹងច្បាស់ អត្ថនៃការឃើញច្បាស់ របស់វីមំសា ត្រូវដឹងច្បាស់ ។

[៤៥] អត្ថនៃទុក្ខ ត្រូវដឹងច្បាស់ អត្ថនៃការបៀតបៀនរបស់ទុក្ខ ត្រូវដឹងច្បាស់ អត្ថនៃការតាក់តែងរបស់ទុក្ខ ត្រូវដឹងច្បាស់ អត្ថនៃការក្តៅសព្វរបស់ទុក្ខ ត្រូវដឹងច្បាស់ អត្ថនៃការប្រែប្រួលរបស់ទុក្ខ ត្រូវដឹងច្បាស់ អត្ថនៃសមុទ័យ ត្រូវដឹងច្បាស់ អត្ថនៃការប្រមូលមក របស់សមុទ័យ ត្រូវដឹងច្បាស់ អត្ថនៃហេតុរបស់សមុទ័យ ត្រូវដឹងច្បាស់ អត្ថនៃការប្រកបព្រម របស់សមុទ័យ ត្រូវដឹងច្បាស់ អត្ថនៃកង្វល់របស់សមុទ័យ ត្រូវដឹងច្បាស់ អត្ថនៃនិរោធ ត្រូវដឹងច្បាស់ អត្ថនៃការរលាស់ចេញរបស់និរោធ ត្រូវដឹងច្បាស់ អត្ថនៃវិវេករបស់និរោធ ត្រូវដឹងច្បាស់ អត្ថនៃការមិនតាក់តែងរបស់និរោធ ត្រូវដឹងច្បាស់ អត្ថនៃការមិនស្លាប់របស់និរោធ ត្រូវដឹងច្បាស់ អត្ថនៃមគ្គ ត្រូវដឹងច្បាស់ អត្ថនៃការនាំចេញទៅរបស់មគ្គ ត្រូវដឹងច្បាស់ អត្ថនៃហេតុរបស់មគ្គ ត្រូវដឹងច្បាស់ អត្ថនៃការឃើញច្បាស់របស់មគ្គ ត្រូវដឹងច្បាស់ អត្ថនៃភាពជាអធិបតីរបស់មគ្គ ត្រូវដឹងច្បាស់ ។

[៤៦] តថដ្ឋោ អភិញ្ញេយ្យោ អនត្តដ្ឋោ អភិញ្ញេយ្យោ សច្ចដ្ឋោ អភិញ្ញេយ្យោ បដិវេធដ្ឋោ អភិញ្ញេយ្យោ អភិជាននដ្ឋោ អភិញ្ញេយ្យោ បរិជាននដ្ឋោ អភិញ្ញេយ្យោ ធម្មដ្ឋោ អភិញ្ញេយ្យោ ធាតដ្ឋោ អភិញ្ញេយ្យោ ញាតដ្ឋោ អភិញ្ញេយ្យោ សច្ឆិកិរិយដ្ឋោ អភិញ្ញេយ្យោ ផស្សនដ្ឋោ អភិញ្ញេយ្យោ អភិសមយដ្ឋោ អភិញ្ញេយ្យោ ។

[៤៧] នេក្ខម្មំ អភិញ្ញេយ្យំ អព្យាបាទោ អភិញ្ញេយ្យោ អាលោកសញ្ញា អភិញ្ញេយ្យា អវិក្ខេបោ អភិញ្ញេយ្យោ ធម្មវវត្ថានំ អភិញ្ញេយ្យំ ញាណំ អភិញ្ញេយ្យំ បាមុជ្ជំ អភិញ្ញេយ្យំ បឋមជ្ឈានំ អភិញ្ញេយ្យំ ទុតិយជ្ឈានំ អភិញ្ញេយ្យំ តតិយជ្ឈានំ អភិញ្ញេយ្យំ ចតុត្ថជ្ឈានំ អភិញ្ញេយ្យំ អាកាសានញ្ចាយតនសមាបត្តិ អភិញ្ញេយ្យា វិញ្ញាណញ្ចាយតនសមាបត្តិ អភិញ្ញេយ្យា អាកិញ្ចញ្ញាយតនសមាបត្តិ អភិញ្ញេយ្យា នេវសញ្ញានាសញ្ញាយតនសមាបត្តិ អភិញ្ញេយ្យា ។

[៤៨] អនិច្ចានុបស្សនា អភិញ្ញេយ្យា ទុក្ខានុបស្សនា

[៤៦] អត្ថនៃសភាពទៀង ត្រូវដឹងច្បាស់ អត្ថនៃសភាពមិនមែនខ្លួន ត្រូវដឹងច្បាស់ អត្ថនៃសភាពពិត ត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹង ត្រូវដឹងច្បាស់ អត្ថនៃការដឹងច្បាស់ ត្រូវដឹងច្បាស់ អត្ថនៃការកំណត់ដឹង ត្រូវដឹងច្បាស់ អត្ថនៃធម៌ ត្រូវដឹងច្បាស់ អត្ថនៃធាតុ ត្រូវដឹងច្បាស់ អត្ថនៃការដឹង ត្រូវដឹងច្បាស់ អត្ថនៃការធ្វើឲ្យជាក់ច្បាស់ ត្រូវដឹងច្បាស់ អត្ថនៃការប៉ះពាល់ ត្រូវដឹងច្បាស់ អត្ថនៃការត្រាស់ដឹង ត្រូវដឹងច្បាស់ ។

[៤៧] នេក្ខម្មៈ ត្រូវដឹងច្បាស់ អព្យាបាទៈ ត្រូវដឹងច្បាស់ អាលោកសញ្ញា ត្រូវដឹងច្បាស់ ការមិនរាយមាយ ត្រូវដឹងច្បាស់ ការកំណត់នូវធម៌ ត្រូវដឹងច្បាស់ ញាណ ត្រូវដឹងច្បាស់ បាមុជ្ជៈ ត្រូវដឹងច្បាស់ បឋមជ្ឈាន ត្រូវដឹងច្បាស់ ទុតិយជ្ឈាន ត្រូវដឹងច្បាស់ តតិយជ្ឈាន ត្រូវដឹងច្បាស់ ចតុត្ថជ្ឈាន ត្រូវដឹងច្បាស់ អាកាសានញ្ចាយតនសមាបត្តិ ត្រូវដឹងច្បាស់ វិញ្ញាណញ្ចាយតនសមាបត្តិ ត្រូវដឹងច្បាស់ អាកិញ្ចញ្ញាយតនសមាបត្តិ ត្រូវដឹងច្បាស់ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ត្រូវដឹងច្បាស់ ។

[៤៨] អនិច្ចានុបស្សនា ត្រូវដឹងច្បាស់ ទុក្ខានុបស្សនា

អភិញ្ញេយ្យា អនត្តានុបស្សនា អភិញ្ញេយ្យា និព្វិទា-នុបស្សនា អភិញ្ញេយ្យា វិរាគានុបស្សនា អភិញ្ញេយ្យា និរោធានុបស្សនា អភិញ្ញេយ្យា បដិនិស្សគ្គានុបស្សនា អភិញ្ញេយ្យា ខយានុបស្សនា អភិញ្ញេយ្យា វយានុ-ស្សនា អភិញ្ញេយ្យា វិបរិណាមានុបស្សនា អភិញ្ញេ-យ្យា អនិមិត្តានុបស្សនា អភិញ្ញេយ្យា អប្បណិហិ-តានុបស្សនា អភិញ្ញេយ្យា សុញ្ញតានុបស្សនា អភិ-ញ្ញេយ្យា អធិប្បញ្ញាធម្មវិបស្សនា អភិញ្ញេយ្យា យថា-ភូតញ្ញាណទស្សនំ អភិញ្ញេយ្យំ អាទីនវានុបស្សនា អភិញ្ញេយ្យា បដិសង្ខានុបស្សនា អភិញ្ញេយ្យា វិវដ្ដនានុបស្សនា អភិញ្ញេយ្យា ។

[៤៩] សោតាបត្តិមគ្គោ អភិញ្ញេយ្យោ សោតា-បត្តិផលសមាបត្តិ អភិញ្ញេយ្យា សកទាគាមិមគ្គោ អភិញ្ញេយ្យោ សកទាគាមិផលសមាបត្តិ អភិញ្ញេយ្យា អនាគាមិមគ្គោ អភិញ្ញេយ្យោ អនាគាមិផលសមាបត្តិ អភិញ្ញេយ្យា អរហត្តមគ្គោ អភិញ្ញេយ្យោ អរហត្តផល-សមាបត្តិ អភិញ្ញេយ្យា ។

ត្រូវដឹងច្បាស់ អនត្តានុបស្សនា ត្រូវដឹងច្បាស់ និព្វិទានុបស្សនា ត្រូវដឹងច្បាស់ វិរាគានុបស្សនា ត្រូវដឹងច្បាស់ និរោធានុបស្សនា ត្រូវដឹងច្បាស់ បដិនិស្សគ្គានុបស្សនា ត្រូវដឹងច្បាស់ ខយានុបស្សនា ត្រូវដឹងច្បាស់ វយានុបស្សនា ត្រូវដឹងច្បាស់ វិបរិណាមានុបស្សនា ត្រូវដឹងច្បាស់ អនិមិត្តានុបស្សនា ត្រូវដឹងច្បាស់ អប្បណិហិតានុបស្សនា ត្រូវដឹងច្បាស់ សុញ្ញតានុបស្សនា ត្រូវដឹងច្បាស់ អធិប្បញ្ញាធម្មវិបស្សនា ត្រូវដឹងច្បាស់ យថាភូតញ្ញាណទស្សនៈ ត្រូវដឹងច្បាស់ អាទីនវានុបស្សនា ត្រូវដឹងច្បាស់ បដិសង្ខានុបស្សនា ត្រូវដឹងច្បាស់ វិវដ្ដនានុបស្សនា ត្រូវដឹងច្បាស់ ។

[៤៩] សោតាបត្តិមគ្គ ត្រូវដឹងច្បាស់ សោតាបត្តិផលសមាបត្តិ ត្រូវដឹងច្បាស់ សកទាគាមិមគ្គ ត្រូវដឹងច្បាស់ សកទាគាមិផលសមាបត្តិ ត្រូវដឹងច្បាស់ អនាគាមិមគ្គ ត្រូវដឹងច្បាស់ អនាគាមិផលសមាបត្តិ ត្រូវដឹងច្បាស់ អរហត្តមគ្គ ត្រូវដឹងច្បាស់ អរហត្តផលសមាបត្តិ ត្រូវដឹងច្បាស់ ។

[៤០] អធិមោក្ខដ្ឋេន សទ្ធិន្ទ្រិយំ អភិញ្ញេយ្យំ បគ្គហដ្ឋេន វីរិយិន្ទ្រិយំ អភិញ្ញេយ្យំ ឧបដ្ឋានដ្ឋេន សតិន្ទ្រិយំ អភិញ្ញេយ្យំ អវិក្ខេបដ្ឋេន សមាធិន្ទ្រិយំ អភិញ្ញេយ្យំ ទស្សនដ្ឋេន បញ្ញិន្ទ្រិយំ អភិញ្ញេយ្យំ អស្សទ្ធិយេ អកម្បិយដ្ឋេន សទ្ធាពលំ អភិញ្ញេយ្យំ កោសជ្ជេ អកម្បិយដ្ឋេន វីរិយពលំ អភិញ្ញេយ្យំ បមាទេ អកម្បិយដ្ឋេន សតិពលំ អភិញ្ញេយ្យំ ឧទ្ធច្ចេ អកម្បិយដ្ឋេន សមាធិពលំ អភិញ្ញេយ្យំ អវិជ្ជាយ អកម្បិយដ្ឋេន បញ្ញាពលំ អភិញ្ញេយ្យំ ។

[៤១] ឧបដ្ឋានដ្ឋេន សតិសម្ពោជ្ឈង្គោ អភិញ្ញេយ្យោ បវិចយដ្ឋេន ធម្មវិចយសម្ពោជ្ឈង្គោ អភិញ្ញេយ្យោ បគ្គហដ្ឋេន វីរិយសម្ពោជ្ឈង្គោ អភិញ្ញេយ្យោ ផរណដ្ឋេន បីតិសម្ពោជ្ឈង្គោ អភិញ្ញេយ្យោ ឧបសមដ្ឋេន បស្សទ្ធិសម្ពោជ្ឈង្គោ អភិញ្ញេយ្យោ អវិក្ខេបដ្ឋេន សមាធិសម្ពោជ្ឈង្គោ អភិញ្ញេយ្យោ បដិសង្ខានដ្ឋេន ឧបេក្ខាសម្ពោជ្ឈង្គោ អភិញ្ញេយ្យោ ។

[៩០] *សទ្ធិន្ទ្រិយដោយអត្ថថាជឿស៊ប់ ត្រូវដឹងច្បាស់ វីរិយិន្ទ្រិយ ដោយអត្ថថាផ្គងឡើង ត្រូវដឹងច្បាស់ សតិន្ទ្រិយដោយអត្ថថាប្រុងប្រយ័ត្ន ត្រូវដឹងច្បាស់ សមាធិន្ទ្រិយដោយអត្ថថាមិនរាយមាយ ត្រូវដឹងច្បាស់ បញ្ញិន្ទ្រិយដោយអត្ថថាឃើញ ត្រូវដឹងច្បាស់ សទ្ធាពលៈដោយអត្ថថា មិនកម្រើក ព្រោះការមិនជឿ ត្រូវដឹងច្បាស់ វីរិយពលៈដោយអត្ថថា មិនកម្រើក ព្រោះការខ្ជិលច្រអូស ត្រូវដឹងច្បាស់ សតិពលៈដោយ អត្ថថាមិនកម្រើក ព្រោះការប្រមាទ ត្រូវដឹងច្បាស់ សមាធិពលៈដោយ អត្ថថាមិនកម្រើក ព្រោះការអណ្តែតអណ្តូង ត្រូវដឹងច្បាស់ បញ្ញាពលៈ ដោយអត្ថថាមិនកម្រើក ព្រោះអវិជ្ជា ត្រូវដឹងច្បាស់ ។*

[៦១] *សតិសម្ពោជ្ឈង្គដោយអត្ថថាប្រុងប្រយ័ត្ន ត្រូវដឹងច្បាស់ ធម្មវិចយសម្ពោជ្ឈង្គ ដោយអត្ថថាពិចារណា ត្រូវដឹងច្បាស់ វីរិយ-សម្ពោជ្ឈង្គ ដោយអត្ថថាផ្គងឡើង ត្រូវដឹងច្បាស់ បីតិសម្ពោជ្ឈង្គ ដោយអត្ថថាផ្សាយទៅ ត្រូវដឹងច្បាស់ បស្សទ្ធិសម្ពោជ្ឈង្គ ដោយអត្ថថា ស្ងប់រម្ងាប់ ត្រូវដឹងច្បាស់ សមាធិសម្ពោជ្ឈង្គ ដោយអត្ថថាមិនរាយមាយ ត្រូវដឹងច្បាស់ ឧបេក្ខាសម្ពោជ្ឈង្គ ដោយអត្ថថាត្រួតត្រា ត្រូវដឹងច្បាស់ ។*

[៤២] ទស្សនដ្ឋេន សម្មាទិដ្ឋិ អភិញ្ញេយ្យា អភិនិរោបនដ្ឋេន សម្មាសង្កប្បោ អភិញ្ញេយ្យោ បរិគ្គហដ្ឋេន សម្មាវាចា អភិញ្ញេយ្យា សមុដ្ឋានដ្ឋេន សម្មាកម្មន្តោ អភិញ្ញេយ្យោ វោទានដ្ឋេន សម្មាអាជីវោ អភិញ្ញេយ្យោ បគ្គហដ្ឋេន សម្មាវាយាមោ អភិញ្ញេយ្យោ ឧបដ្ឋានដ្ឋេន សម្មាសតិ អភិញ្ញេយ្យា អវិក្ខេបដ្ឋេន សម្មាសមាធិ អភិញ្ញេយ្យោ ។

[៤៣] អាធិបតេយ្យដ្ឋេន ឥន្ទ្រិយា អភិញ្ញេយ្យា អកម្បិយដ្ឋេន ពលា អភិញ្ញេយ្យា និយ្យានដ្ឋេន ពោជ្ឈង្គា អភិញ្ញេយ្យា ហេតដ្ឋេន មគ្គោ អភិញ្ញេយ្យោ ឧបដ្ឋានដ្ឋេន សតិប្បដ្ឋានា អភិញ្ញេយ្យា បទហនដ្ឋេន សម្មប្បធានា អភិញ្ញេយ្យា ឥជ្ឈនដ្ឋេន ឥទ្ធិបាទា អភិញ្ញេយ្យា តថដ្ឋេន សច្ចា អភិញ្ញេយ្យា អវិក្ខេបដ្ឋេន សមថោ អភិញ្ញេយ្យោ អនុបស្សនដ្ឋេន វិបស្សនា អភិញ្ញេយ្យា ឯករសដ្ឋេន សមថវិបស្សនា

[៥២] *សម្មាទិដ្ឋិដោយអត្ថថាឃើញច្បាស់ ត្រូវដឹងច្បាស់ សម្មា-សង្កប្បៈ ដោយអត្ថថាលើកចិត្តឡើង ត្រូវដឹងច្បាស់ សម្មាវាចា ដោយអត្ថថាកំណត់ (នូវវចីសំវរៈ ៤) ត្រូវដឹងច្បាស់ សម្មាកម្មន្តៈ ដោយអត្ថថាតាំងឡើង ត្រូវដឹងច្បាស់ សម្មាអាជីវៈ ដោយអត្ថថាផូរផង់ ត្រូវដឹងច្បាស់ សម្មាវាយាមៈ ដោយអត្ថថាផ្គងឡើង ត្រូវដឹងច្បាស់ សម្មាសតិដោយអត្ថថាប្រុងប្រយ័ត្ន ត្រូវដឹងច្បាស់ សម្មាសមាធិដោយអត្ថថាមិនរាយមាយ ត្រូវដឹងច្បាស់ ។*

[៥៣] *ឥន្ទ្រិយទាំងឡាយ ដោយអត្ថថាជាធំ ត្រូវដឹងច្បាស់ ពលៈទាំងឡាយ ដោយអត្ថថាមិនកម្រើក ត្រូវដឹងច្បាស់ ពោជ្ឈង្គទាំងឡាយ ដោយអត្ថថាចេញចាកធម៌ជាសត្រូវ ត្រូវដឹងច្បាស់ មគ្គ ដោយអត្ថថាញុំាងសត្វឲ្យដល់ (នូវព្រះនិព្វាន) ត្រូវដឹងច្បាស់ សតិប្បដ្ឋាន ដោយអត្ថថាប្រុងប្រយ័ត្ន ត្រូវដឹងច្បាស់ សម្មប្បធានទាំងឡាយ ដោយអត្ថថាតម្កល់ទុក ត្រូវដឹងច្បាស់ ឥទ្ធិ-បាទទាំងឡាយ ដោយអត្ថថាសម្រេច ត្រូវដឹងច្បាស់ សច្ចៈទាំង-ឡាយ ដោយអត្ថថាទៀង ត្រូវដឹងច្បាស់ សមថៈ ដោយអត្ថថាមិនរាយមាយ ត្រូវដឹងច្បាស់ វិបស្សនា ដោយអត្ថថា ពិចារណារឿយ ៗ ត្រូវដឹងច្បាស់ សមថៈនិងវិបស្សនា ដោយអត្ថថាមានរសតែមួយ*

អភិញ្ញេយ្យា អនតិវត្តនដ្ឋេន យុគនទ្ធំ អភិញ្ញេយ្យំ ។

[៥៤] សំវរដ្ឋេន សីលវិសុទ្ធិ អភិញ្ញេយ្យា អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ អភិញ្ញេយ្យា ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ អភិញ្ញេយ្យា មុត្តដ្ឋេន វិមោក្ខោ អភិញ្ញេយ្យោ បដិវេធដ្ឋេន វិជ្ជា អភិញ្ញេយ្យា បរិច្ចាគដ្ឋេន វិមុត្តិ អភិញ្ញេយ្យា សមុច្ឆេទដ្ឋេន ខយេ ញាណំ អភិញ្ញេយ្យំ បដិប្បស្សទ្ធដ្ឋេន អនុប្បាទេ ញាណំ អភិញ្ញេយ្យំ ឆន្ទោ មូលដ្ឋេន អភិញ្ញេយ្យោ មនសិការោ សមុដ្ឋានដ្ឋេន អភិញ្ញេយ្យោ ផស្សោ សមោធានដ្ឋេន អភិញ្ញេយ្យោ វេទនា សមោសរណដ្ឋេន អភិញ្ញេយ្យា សមាធិ បមុខដ្ឋេន អភិញ្ញេយ្យោ សតិ អាធិបតេយ្យដ្ឋេន អភិញ្ញេយ្យា បញ្ញា តទុត្តរដ្ឋេន[១] អភិញ្ញេយ្យា វិមុត្តិ សារដ្ឋេន អភិញ្ញេយ្យា អមតោគធំ និព្វានំ បរិយោសានដ្ឋេន អភិញ្ញេយ្យំ ។

១ ឱ. ម. តតុត្តរដ្ឋេន ។

ត្រូវដឹងច្បាស់ ធម៌ដែលជាប់គ្នាជាគូ ដោយអត្ថថាមិនប្រព្រឹត្តកន្លងត្រូវដឹងច្បាស់ ។

[៥៤] សីលវិសុទ្ធិ ដោយអត្ថថាសង្រួម ត្រូវដឹងច្បាស់ ចិត្តវិសុទ្ធិ ដោយអត្ថថាមិនរាយមាយ ត្រូវដឹងច្បាស់ ទិដ្ឋិវិសុទ្ធិ ដោយអត្ថថាឃើញ ត្រូវដឹងច្បាស់ វិមោក្ខ ដោយអត្ថថារួចស្រឡះ ត្រូវដឹងច្បាស់ វិជ្ជាដោយអត្ថថាត្រាស់ដឹង ត្រូវដឹងច្បាស់ វិមុត្តិ ដោយអត្ថថាលះបង់ ត្រូវដឹងច្បាស់ ខយញ្ញាណ ដោយអត្ថថាផ្តិលផ្តាច់ ត្រូវដឹងច្បាស់ អនុប្បាទញ្ញាណ ដោយអត្ថថាស្ងប់រម្ងាប់ ត្រូវដឹងច្បាស់ ឆន្ទៈ ត្រូវដឹងច្បាស់ ដោយអត្ថថាជាមូល មនសិការៈ ត្រូវដឹងច្បាស់ ដោយអត្ថថាតាំងឡើងព្រម ផស្សៈ ត្រូវដឹងច្បាស់ ដោយអត្ថថាប្រមូលមក វេទនា ត្រូវដឹងច្បាស់ ដោយអត្ថថាប្រជុំចុះ សមាធិ ត្រូវដឹងច្បាស់ ដោយអត្ថថាជាប្រធាន សតិត្រូវដឹងច្បាស់ ដោយអត្ថថាជាធំ បញ្ញាត្រូវដឹងច្បាស់ ដោយអត្ថថាដ៏ប្រសើរជាងពួកកុសលធម៌នោះ វិមុត្តិ ត្រូវដឹងច្បាស់ ដោយអត្ថថាជាខ្លឹមសារ និព្វានជាគុណជាតមិនស្លាប់ជាទីពឹង (របស់សត្វ) ត្រូវដឹងច្បាស់ ដោយអត្ថថាចប់ស្រេច (នៃសាសនា) ។

[៤៥] យេ យេ ធម្មា អភិញ្ញាតា ហោន្តិ តេ តេ ធម្មា ញាតា ហោន្តិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ឥមេ ធម្មា អភិញ្ញេយ្យាតិ សោតាវធានំ តំបជានា បញ្ញា សុតមយេ ញាណំ ។

ទុតិយភាណវារំ ។

[៤៦] កថំ ឥមេ ធម្មា បរិញ្ញេយ្យាតិ សោតាវធានំ តំបជានា បញ្ញា សុតមយេ ញាណំ ឯកោ ធម្មោ បរិញ្ញេយ្យោ ផស្សោ សាសវោ ឧបាទានិយោ ទ្វេ ធម្មា បរិញ្ញេយ្យា នាមញ្ច រូបញ្ច តយោ ធម្មា បរិញ្ញេយ្យា តិស្សោ វេទនា ចត្តារោ ធម្មា បរិញ្ញេយ្យា ចត្តារោ អាហារា បញ្ច ធម្មា បរិញ្ញេយ្យា បញ្ចុបាទានក្ខន្ធា ឆ ធម្មា បរិញ្ញេយ្យា ឆ អជ្ឈត្តិកានិ អាយតនានិ សត្ត ធម្មា បរិញ្ញេយ្យា សត្ត វិញ្ញាណដ្ឋិតិយោ អដ្ឋ ធម្មា បរិញ្ញេយ្យា អដ្ឋ លោកធម្មា នវ ធម្មា បរិញ្ញេយ្យា នវ សត្តាវាសា ទស ធម្មា បរិញ្ញេយ្យា ទសាយតនានិ ។

[៩៥] ពួកធម៌ណា ៗ ដែលបុគ្គលចេះប្រាកដហើយ ពួកធម៌នោះ ៗ ឈ្មោះថាបុគ្គលដឹងហើយ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាជាគ្រឿងដឹងសព្វ នូវធម៌នោះ ហេតុនោះ លោកពោលថា ការប្រុងត្រចៀកថា ពួកធម៌នេះ បុគ្គលត្រូវដឹងច្បាស់ បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតមយញ្ញាណ ។

ចប់ ទុតិយភាណវារៈ ។

[៩៦] ការប្រុងត្រចៀកថា ធម៌ទាំងឡាយនេះ បុគ្គលត្រូវកំណត់ដឹង បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតមយញ្ញាណតើដូចម្តេច ធម៌ ១ បុគ្គលត្រូវកំណត់ដឹង គឺផស្សៈប្រកបដោយអាសវៈដែលជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ ២ ត្រូវកំណត់ដឹង គឺ នាម ១ រូប ១ ពួកធម៌ ៣ ត្រូវកំណត់ដឹង គឺវេទនា ៣ ពួកធម៌ ៤ ត្រូវកំណត់ដឹង គឺ អាហារ ៤ ពួកធម៌ ៥ ត្រូវកំណត់ដឹង គឺឧបាទានក្ខន្ធ ៥ ពួកធម៌ ៦ ត្រូវកំណត់ដឹង គឺ អាយតនៈខាងក្នុង ៦ ពួកធម៌ ៧ ត្រូវកំណត់ដឹង គឺវិញ្ញាណដ្ឋិតិ ៧ ពួកធម៌ ៨ ត្រូវកំណត់ដឹង គឺ លោកធម៌ ៨ ពួកធម៌ ៩ ត្រូវកំណត់ដឹង គឺសត្តាវាស ៩ ពួកធម៌ ១០ ត្រូវកំណត់ដឹង គឺអាយតនៈ ១០ ។

[៤៧] សព្វំ ភិក្ខវេ បរិញ្ញេយ្យំ កិញ្ច ភិក្ខវេ សព្វំ បរិញ្ញេយ្យំ ចក្ខុំ ភិក្ខវេ បរិញ្ញេយ្យំ រូបា បរិញ្ញេយ្យា ចក្ខុវិញ្ញាណំ បរិញ្ញេយ្យំ ចក្ខុសម្ផស្សោ បរិញ្ញេយ្យោ យម្បិទំ[១] ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ បរិញ្ញេយ្យំ សោតំ បរិញ្ញេយ្យំ សទ្ទា បរិញ្ញេយ្យា ។ បេ ។ ឃានំ បរិញ្ញេយ្យំ គន្ធា បរិញ្ញេយ្យា ជិវ្ហា បរិញ្ញេយ្យា រសា បរិញ្ញេយ្យា កាយោ បរិញ្ញេយ្យោ ផោដ្ឋព្វា បរិញ្ញេយ្យា មនោ បរិញ្ញេយ្យោ ធម្មា បរិញ្ញេយ្យា មនោវិញ្ញាណំ បរិញ្ញេយ្យំ មនោសម្ផស្សោ បរិញ្ញេយ្យោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ បរិញ្ញេយ្យំ ។

[៤៨] រូបំ បរិញ្ញេយ្យំ វេទនា បរិញ្ញេយ្យា សញ្ញា បរិញ្ញេយ្យា សង្ខារា បរិញ្ញេយ្យា វិញ្ញាណំ បរិញ្ញេយ្យំ ចក្ខុំ ។ បេ ។ ជរាមរណំ ។ បេ ។

---

១ ឱ. យទិទំ ។ ម. យមិទំ ។

[៥៧] ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងពួង បុគ្គលត្រូវកំណត់ដឹង ម្នាលភិក្ខុទាំងឡាយ ចុះអាយតនៈទាំងពួង ដែលត្រូវកំណត់ដឹង តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ចក្ខុ ត្រូវកំណត់ដឹង រូប ត្រូវកំណត់ដឹង ចក្ខុវិញ្ញាណ ត្រូវកំណត់ដឹង ចក្ខុសម្ផស្ស ត្រូវកំណត់ដឹង ការទទួលអារម្មណ៍ណា ទោះជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះឯង ក៏ត្រូវកំណត់ដឹង សោតៈ ត្រូវកំណត់ដឹង សទ្ទៈ ត្រូវកំណត់ដឹង ។ បេ ។ ឃានៈ ត្រូវកំណត់ដឹង គន្ធៈ ត្រូវកំណត់ដឹង ជិវ្ហា ត្រូវកំណត់ដឹង រសៈ ត្រូវកំណត់ដឹង កាយ ត្រូវកំណត់ដឹង ផោដ្ឋព្វៈ ត្រូវកំណត់ដឹង មនៈ ត្រូវកំណត់ដឹង ធម្មារម្មណ៍ ត្រូវកំណត់ដឹង មនោវិញ្ញាណ ត្រូវកំណត់ដឹង មនោសម្ផស្ស ត្រូវកំណត់ដឹង ការទទួលអារម្មណ៍ណា ទោះជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះឯង ក៏ត្រូវកំណត់ដឹង ។

[៥៨] រូប បុគ្គលត្រូវកំណត់ដឹង វេទនា ត្រូវកំណត់ដឹង សញ្ញា ត្រូវកំណត់ដឹង សង្ខារទាំងឡាយ ត្រូវកំណត់ដឹង វិញ្ញាណ ត្រូវកំណត់ដឹង ចក្ខុ ។ បេ ។ ជរាមរណៈ ។ បេ ។

អមតោគធំ និព្វានំ បរិយោសានដ្ឋេន បរិញ្ញេយ្យំ យេសំ យេសំ ធម្មានំ បដិលាភត្ថាយ វាយមន្តស្ស តេ តេ ធម្មា បដិលទ្ធា ហោន្តិ ឯវំ តេ ធម្មា បរិញ្ញាតា ចេវ ហោន្តិ តីរិតា ច ។

[៤៩] នេក្ខម្មំ បដិលាភត្ថាយ វាយមន្តស្ស នេក្ខម្មំ បដិលទ្ធំ ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច អព្យាបាទំ បដិលាភត្ថាយ វាយមន្តស្ស អព្យាបាទោ បដិលទ្ធោ ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច អាលោក-សញ្ញំ បដិលាភត្ថាយ វាយមន្តស្ស អាលោកសញ្ញា បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច អវិក្ខេបំ បដិលាភត្ថាយ វាយម-ន្តស្ស អវិក្ខេបោ បដិលទ្ធោ ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច

ព្រះនិព្វានឈ្មោះអមតៈ ជាទីពំនាក់ (របស់ពួកសត្វ) ត្រូវកំណត់ដឹង ដោយអត្ថថាចប់ស្រេច (នៃសាសនា) កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវធម៌ទាំងឡាយណា ៗ ធម៌ទាំងឡាយនោះៗ ក៏បុគ្គលបានចំពោះហើយ ធម៌ទាំងឡាយនោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង ។

[៥៩] កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវនេក្ខម្មៈ នេក្ខម្មៈក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវអព្យាបាទ អព្យាបាទក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវអាលោកសញ្ញា អាលោកសញ្ញា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវអវិក្ខេបៈ (ការមិនរាយមាយ) អវិក្ខេបៈ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង

ជម្មវវត្ថានំ បដិលាភត្ថាយ វាយមន្តស្ស ជម្មវវត្ថានំ បដិលទ្ធំ ហោតិ ឯវំ សោ ជម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច ញាណំ បដិលាភត្ថាយ វាយមន្តស្ស ញាណំ បដិលទ្ធំ ហោតិ ឯវំ សោ ជម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច ចាមុជ្ជំ បដិលាភត្ថាយ វាយមន្តស្ស ចាមុជ្ជំ បដិលទ្ធំ ហោតិ ឯវំ សោ ជម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច ។

[៦០] បឋមជ្ឈានំ បដិលាភត្ថាយ វាយមន្តស្ស បឋមជ្ឈានំ បដិលទ្ធំ ហោតិ ឯវំ សោ ជម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច ទុតិយជ្ឈានំ ។ បេ ។ តតិយជ្ឈានំ ចតុត្ថជ្ឈានំ បដិលាភត្ថាយ វាយមន្តស្ស ចតុត្ថជ្ឈានំ បដិលទ្ធំ ហោតិ ឯវំ សោ ជម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច អាកាសានញ្ចាយតនសមាបត្តឹ បដិលាភត្ថាយ វាយមន្តស្ស អាកាសានញ្ចាយតនសមាបត្តិ បដិលទ្ធា ហោតិ ឯវំ សោ ជម្មោ បរិញ្ញាតោ ចេវ ហោតិ

កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវធម្មវវត្ថានៈ (ការកំណត់នូវធម៌) ធម្មវវត្ថានៈ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវញាណ ញាណក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវបាមុជ្ជៈ (សេចក្តីរីករាយ) បាមុជ្ជៈក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង ។

[៦០] កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវបឋមជ្ឈាន បឋមជ្ឈានបុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង នូវទុតិយជ្ឈាន ។ បេ ។ នូវតតិយជ្ឈាន កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវចតុត្ថជ្ឈាន ចតុត្ថជ្ឈាន ក៏បុគ្គលបានចំពោះហើយ ធម៌នោះឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវអាកាសានញ្ចាយតនសមាបត្តិ អាកាសានញ្ចាយតនសមាបត្តិ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង

តីរិតោ ច វិញ្ញាណញ្ចាយតនសមាបត្តឹ បដិលាភត្ថាយ វាយមន្តស្ស វិញ្ញាណញ្ចាយតនសមាបត្តិ បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច អាកិញ្ចញ្ញាយតនសមាបត្តឹ បដិលាភ-ត្ថាយ វាយមន្តស្ស អាកិញ្ចញ្ញាយតនសមាបត្តិ បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច នេវសញ្ញានាសញ្ញាយតនសមាបត្តឹ បដិលាភត្ថាយ វាយមន្តស្ស នេវសញ្ញានាសញ្ញា-យតនសមាបត្តិ បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច ។

[៦១] អនិច្ចានុបស្សនំ បដិលាភត្ថាយ វាយមន្ត-ស្ស អនិច្ចានុបស្សនា បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច ទុក្ខានុបស្សនំ បដិលាភត្ថាយ វាយមន្តស្ស ទុក្ខានុបស្សនា បដិ-លទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ

កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវវិញ្ញាណញ្ចា-យតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវអា-កិញ្ចញ្ញាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ នេវសញ្ញានាសញ្ញាយតន-សមាបត្តិ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង ។

[៦១] កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវអនិច្ចានុបស្សនា អនិច្ចានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវទុក្ខានុបស្សនា ទុក្ខានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង

តីរិតោ ច អនត្តានុបស្សនំ បដិលាភត្ថាយ វាយមន្តស្ស អនត្តានុបស្សនា បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច និព្វិទានុបស្សនំ បដិលាភត្ថាយ វាយមន្តស្ស និព្វិទានុបស្សនា បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច វិរាគានុបស្សនំ បដិលាភត្ថាយ វាយមន្តស្ស វិរាគានុបស្សនា បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច និរោធានុបស្សនំ បដិលាភត្ថាយ វាយមន្តស្ស និរោធានុបស្សនា បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច បដិនិស្សគ្គានុបស្សនា បដិលាភត្ថាយ វាយមន្តស្ស បដិនិស្សគ្គានុបស្សនា បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច ខយានុបស្សនំ បដិលាភត្ថាយ វាយមន្តស្ស ខយានុបស្សនា បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច

កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវអនត្តានុ-បស្សនា អនត្តានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គល ព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវនិព្វិទានុបស្សនា និព្វិទា-នុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បី ប្រយោជន៍ដល់ការបានចំពោះ នូវវិរាគានុបស្សនា វិរាគានុបស្សនា ក៏ បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារ-ណាហើយផង យ៉ាងនេះឯង បុគ្គលកាលព្យាយាមដើម្បីប្រយោជន៍ដល់ ការបានចំពោះនូវនិរោធានុបស្សនា និរោធានុបស្សនា ក៏បុគ្គលបានចំពោះ ហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវបដិនិស្សគ្គានុបស្សនា បដិនិស្សគ្គានុបស្សនា ក៏បុគ្គលបានចំពោះ ហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវ ខយានុបស្សនា ខយានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង

វយានុបស្សនំ បដិលាភត្ថាយ វាយមន្តស្ស វយានុប-
ស្សនា បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញា-
តោ ចេវ ហោតិ តីរិតោ ច វិបរិណាមានុបស្សនំ
បដិលាភត្ថាយ វាយមន្តស្ស វិបរិណាមានុបស្សនា
បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ
ហោតិ តីរិតោ ច អនិមិត្តានុបស្សនំ បដិលាភត្ថាយ
វាយមន្តស្ស អនិមិត្តានុបស្សនា បដិលទ្ធា ហោតិ ឯវំ
សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច
អប្បណិហិតានុបស្សនំ បដិលាភត្ថាយ វាយមន្តស្ស
អប្បណិហិតានុបស្សនា បដិលទ្ធា ហោតិ ឯវំ សោ
ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច សុញ្ញតា-
នុបស្សនំ បដិលាភត្ថាយ វាយមន្តស្ស សុញ្ញតានុ-
បស្សនា បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញា-
តោ ចេវ ហោតិ តីរិតោ ច ។

[៦២] អធិប្បញ្ញាធម្មវិបស្សនំ បដិលាភត្ថាយ
វាយមន្តស្ស អធិប្បញ្ញាធម្មវិបស្សនា បដិលទ្ធា ហោតិ
ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច

កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវវយានុបស្សនា វយានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវវិបរិណាមានុបស្សនា វិបរិណាមានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវអនិមិត្តានុបស្សនា អនិមិត្តានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវអប្បណិហិតានុបស្សនា អប្បណិហិតានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង បុគ្គលកាលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវសុញ្ញតានុបស្សនា សុញ្ញតានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង ។

[៦២] កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះនូវអធិប្បញ្ញាធម្មវិបស្សនា អធិប្បញ្ញាធម្មវិបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង

យថាភូតញ្ញាណទស្សនំ បដិលាភត្ថាយ វាយមន្តស្ស យថាភូតញ្ញាណទស្សនំ បដិលទ្ធំ ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច អាទីនវានុបស្សនំ បដិលាភត្ថាយ វាយមន្តស្ស អាទីនវានុបស្សនា បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច បដិសង្ខានុបស្សនំ បដិលាភត្ថាយ វាយមន្តស្ស បដិសង្ខានុបស្សនា បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច វិវដ្ដនានុបស្សនំ[១] បដិលាភត្ថាយ វាយមន្តស្ស វិវដ្ដនានុបស្សនា បដិលទ្ធា ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច ។

[៦៣] សោតាបត្តិមគ្គំ បដិលាភត្ថាយ វាយមន្តស្ស សោតាបត្តិមគ្គោ បដិលទ្ធោ ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច សកទាគាមិមគ្គំ បដិលាភត្ថាយ វាយមន្តស្ស សកទាគាមិមគ្គោ បដិលទ្ធោ ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច

---

១ ឱ. វិវដ្ដានុបស្សនំ ។ ម. វិវដ្ដនានុបស្សនានំ ។

កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវយថាភូតញ្ញាណទស្សនៈ យថាភូតញ្ញាណទស្សនៈ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវអាទីនវានុបស្សនា អាទីនវានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាមដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវបដិសង្ខានុបស្សនា បដិសង្ខានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គល ព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវវិវដ្តនានុបស្សនា វិវដ្តនានុបស្សនា ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គល កំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង ។

[៦៣] កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបាន ចំពោះនូវសោតាបត្តិមគ្គ សោតាបត្តិមគ្គ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវ សកទាគាមិមគ្គ សកទាគាមិមគ្គ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថា បុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង

អនាគាមិមគ្គំ បដិលាភត្ថាយ វាយមន្តស្ស អនាគាមិមគ្គោ បដិលទ្ធោ ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច អរហត្តមគ្គំ បដិលាភត្ថាយ វាយមន្តស្ស អរហត្តមគ្គោ បដិលទ្ធោ ហោតិ ឯវំ សោ ធម្មោ បរិញ្ញាតោ ចេវ ហោតិ តីរិតោ ច យេសំ យេសំ ធម្មានំ បដិលាភត្ថាយ វាយមន្តស្ស តេ តេ ធម្មា បដិលទ្ធា ហោន្តិ ឯវំ តេ ធម្មា បរិញ្ញាតា ចេវ ហោន្តិ តីរិតា ច តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ឥមេ ធម្មា បរិញ្ញេយ្យាតិ សោតាវធានំ តំបជានន បញ្ញា សុតមយេ ញាណំ[១] ។

[៦៨] កថំ ឥមេ ធម្មា បហាតព្វាតិ សោតាវធានំ តំបជានន បញ្ញា សុតមយេ ញាណំ ឯកោ ធម្មោ បហាតព្វោ អស្មិមានោ ទ្វេ ធម្មា បហាតព្វា អវិជ្ជា ច ភវតណ្ហា ច តយោ ធម្មា បហាតព្វា តិស្សោ តណ្ហា ចត្តារោ ធម្មា បហាតព្វា ចត្តារោ ឱឃា

១ ឱ. ម. ញាណន្តិ ។

កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវអនាគាមិមគ្គ អនាគាមិមគ្គ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះនូវអរហត្តមគ្គ អរហត្តមគ្គ ក៏បុគ្គលបានចំពោះហើយ ធម៌នោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារណាហើយផង យ៉ាងនេះឯង កាលបុគ្គលព្យាយាម ដើម្បីប្រយោជន៍ដល់ការបានចំពោះ នូវធម៌ទាំងឡាយណាៗ ធម៌ទាំងឡាយនោះៗ ក៏បុគ្គលបានចំពោះហើយ ធម៌ទាំងឡាយនោះ ឈ្មោះថាបុគ្គលកំណត់ដឹងផង ពិចារ-ណាហើយផង យ៉ាងនេះឯង ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ព្រោះហេតុនោះ លោកពោលថា ការប្រុងត្រចៀកថា ធម៌ទាំងឡាយនេះ បុគ្គលត្រូវកំណត់ដឹង បញ្ញាជាគ្រឿងដឹងនូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតមយញ្ញាណ ។

[៦៤] ការប្រុងត្រចៀកថា ធម៌ទាំងឡាយនេះ បុគ្គលត្រូវលះ បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតមយញ្ញាណ តើដូចម្តេច ធម៌ ១ ដែលត្រូវលះ គឺអស្មិមានះ ធម៌ ២ ដែលត្រូវលះគឺអវិជ្ជា ១ ភវតណ្ហា ១ ធម៌ ៣ ដែលត្រូវលះគឺតណ្ហា ៣ ធម៌ ៤ ដែលត្រូវលះគឺឱឃៈ៤

បញ្ច ធម្មា បហាតព្វា បញ្ច នីវរណានិ ឆ ធម្មា បហាតព្វា ឆ តណ្ហាកាយា សត្ត ធម្មា បហាតព្វា សត្តានុសយា អដ្ឋ ធម្មា បហាតព្វា អដ្ឋ មិច្ឆត្តា នវ ធម្មា បហាតព្វា នវ តណ្ហាមូលកា ធម្មា ទស ធម្មា បហាតព្វា ទស មិច្ឆត្តា ។

[៦៤] ទ្វេ បហានានិ សមុច្ឆេទប្បហានំ បដិប្បស្សទ្ធិប្បហានំ សមុច្ឆេទប្បហានញ្ច លោកុត្តរំ ខយគាមិមគ្គំ ភាវយតោ បដិប្បស្សទ្ធិប្បហានញ្ច ផលក្ខណេ ។ តីណិ បហានានិ កាមានមេតំ និស្សរណំ យទិទំ នេក្ខម្មំ រូបានមេតំ និស្សរណំ យទិទំ អារុប្បំ យំ ខោ បន កិញ្ចិ ភូតំ សង្ខតំ បដិច្ចសមុប្បន្នំ និរោធោ តស្ស និស្សរណំ នេក្ខម្មំ បដិលទ្ធស្ស កាមា បហីនា ចេវ ហោន្តិ បរិច្ចត្តា ច អារុប្បំ បដិលទ្ធស្ស រូបា បហីនា ចេវ ហោន្តិ បរិច្ចត្តា ច និរោធំ បដិលទ្ធស្ស សង្ខារា បហីនា ចេវ ហោន្តិ បរិច្ចត្តា ច ។ ចត្តារិ បហានានិ ទុក្ខសច្ចំ បរិញ្ញាបដិវេធំ បដិវិជ្ឈន្តោ បជហាតិ

ធម៌ ៥ ដែលត្រូវលះគឺនីវរណៈ ៥ ធម៌ ៦ ដែលត្រូវលះគឺពួកតណ្ហា ៦ ធម៌ ៧ ដែលត្រូវលះគឺអនុស័យ ៧ ធម៌ ៨ ដែលត្រូវលះគឺមិច្ឆត្តៈ ៨ ធម៌ ៩ ដែលត្រូវលះគឺឫសគល់តណ្ហា ៩ ធម៌ ១០ ដែលត្រូវលះគឺមិច្ឆត្តៈ ១០ ។

[៦៥] បហាន (ការលះ) ២ យ៉ាង គឺ សមុច្ឆេទប្បហាន ១ បដិប្បស្សទ្ធិប្បហាន ១ ឯសមុច្ឆេទប្បហានសម្រាប់បុគ្គលកាលចម្រើននូវខយគាមិមគ្គជាលោកុត្តរ បដិប្បស្សទ្ធិប្បហាន កើតក្នុងខណៈនៃផល ។ បហាន ៣ យ៉ាង គឺ នេក្ខម្មៈ ដែលជាគ្រឿងរលាស់ចេញនូវកាមទាំង-ឡាយ ១ អារុប្បជ្ឈាន ដែលជាគ្រឿងរលាស់ចេញនូវរូបទាំងឡាយ ១ ធម្ម-ជាតណាដែលកើតហើយ ត្រូវបច្ច័យតាក់តែង កើតឡើងព្រោះអាស្រ័យបច្ច័យ ការរលត់ ការរលាស់ចោល នូវធម្មជាតនោះ ១ កាមទាំងឡាយរបស់បុគ្គលដែលបានចំពោះនូវនេក្ខម្មៈ ឈ្មោះថាជាកិលេសដែលលោកបន្សាត់ចោលផង លះចេញផង រូបទាំងឡាយរបស់បុគ្គលដែលបានចំពោះនូវអារុប្បជ្ឈាន ឈ្មោះថាជាគុណដែលលោកបន្សាត់ចោលផង លះចេញផង សង្ខារទាំងឡាយរបស់បុគ្គលដែលបានចំពោះនូវនិរោធ ឈ្មោះថាជាធម៌ដែលលោកបន្សាត់ចោលផង លះចេញផង ។ បហាន ៤ យ៉ាងគឺ បុគ្គលកាលត្រាស់ដឹងនូវទុក្ខសច្ច ដែលជាបរិញ្ញាបដិវេធ ហើយលះបង់ ១

សមុទយសច្ចំ បហានប្បដិវេធំ បដិវិជ្ឈន្តោ បជហាតិ និរោធសច្ចំ សច្ឆិកិរិយាបដិវេធំ បដិវិជ្ឈន្តោ បជហាតិ មគ្គសច្ចំ ភាវនាបដិវេធំ បដិវិជ្ឈន្តោ បជហាតិ ។ បញ្ច បហានានិ វិក្ខម្ភនប្បហានំ តទង្គប្បហានំ សមុច្ឆេទប្បហានំ បដិប្បស្សទ្ធិប្បហានំ និស្សរណប្បហានំ វិក្ខម្ភនប្បហានញ្ច នីវរណានំ បឋមជ្ឈានំ ភាវយតោ តទង្គប្បហានញ្ច ទិដ្ឋិគតានំ និព្វេធភាគិយំ សមាធឹ ភាវយតោ សមុច្ឆេទប្បហានញ្ច លោកុត្តរំ ខយគាមិមគ្គំ ភាវយតោ បដិប្បស្សទ្ធិប្បហានញ្ច ផលក្ខណេ និស្សរណប្បហានញ្ច និរោធោ និព្វានំ ។

[៦៦] សព្វំ ភិក្ខវេ បហាតព្វំ កិញ្ច ភិក្ខវេ សព្វំ បហាតព្វំ ចក្ខុំ ភិក្ខវេ បហាតព្វំ រូបា បហាតព្វា ចក្ខុវិញ្ញាណំ បហាតព្វំ ចក្ខុសម្ផស្សោ បហាតព្វោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ បហាតព្វំ សោតំ បហាតព្វំ សទ្ទា បហាតព្វា ។ បេ ។

បុគ្គលកាលត្រាស់ដឹងនូវសមុទយសច្ច ដែលជាបហានប្បដិវេធហើយលះបង់ ១ បុគ្គលកាលត្រាស់ដឹងនូវនិរោធសច្ច ដែលជាសច្ឆិកិរិយាបដិវេធហើយលះបង់ ១ បុគ្គលកាលត្រាស់ដឹងនូវមគ្គសច្ច ដែលជាភាវនាបដិវេធហើយលះបង់ ១ ។ បហាន ៥ យ៉ាង គឺ វិក្ខម្ភនប្បហាន ១ តទង្គប្បហាន ១ សមុច្ឆេទប្បហាន ១ បដិប្បស្សទ្ធិប្បហាន ១ និស្សរណប្បហាន ១ ឯវិក្ខម្ភនប្បហាន សម្រាប់បុគ្គលចម្រើននូវធម៌ជាគ្រឿងដុតបំផ្លាញនូវនីវរណៈទាំងឡាយជាបឋម តទង្គប្បហាន សម្រាប់បុគ្គលចម្រើននូវសមាធិ ជាចំណែកនៃការទម្លុះទម្លាយនូវទិដ្ឋិទាំងឡាយ សមុច្ឆេទប្បហាន សម្រាប់បុគ្គលចម្រើននូវខយគាមិមគ្គ ជាលោកុត្តរៈ បដិប្បស្សទ្ធិប្បហាន កើតឡើងក្នុងខណៈនៃផល និស្សរណប្បហាន គឺព្រះនិព្វាន ជាគ្រឿងរលត់ទុក្ខ ។

[៦៦] ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងពួង បុគ្គលត្រូវលះ ម្នាលភិក្ខុទាំងឡាយ ចុះអាយតនៈទាំងពួងដែលបុគ្គលត្រូវលះតើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ចក្ខុត្រូវលះ រូបត្រូវលះ ចក្ខុវិញ្ញាណត្រូវលះ ចក្ខុសម្ផស្សត្រូវលះ ការទទួលអារម្មណ៍ណា ទោះជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះឯង ក៏ត្រូវលះ សោតៈត្រូវលះ សទ្ទៈត្រូវលះ ។បេ។

ឃានំ បហាតព្វំ គន្ធា បហាតព្វា ជិវ្ហា បហាតព្វា រសា បហាតព្វា កាយោ បហាតព្វោ ផោដ្ឋព្វា បហាតព្វា មនោ បហាតព្វោ ធម្មា បហាតព្វា មនោវិញ្ញាណំ បហាតព្វំ មនោសម្ផស្សោ បហាតព្វោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ បហាតព្វំ ។

រូបំ បស្សន្តោ បជហាតិ វេទនំ បស្សន្តោ បជហាតិ សញ្ញំ បស្សន្តោ បជហាតិ សង្ខារេ បស្សន្តោ បជហាតិ វិញ្ញាណំ បស្សន្តោ បជហាតិ ចក្ខុំ ។ បេ ។ ជរាមរណំ អមតោគធំ និព្វានំ បរិយោសានដ្ឋេន បស្សន្តោ បជហាតិ យេ យេ ធម្មា បហីនា ហោន្តិ តេ តេ ធម្មា បរិច្ចត្តា ហោន្តិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ឥមេ ធម្មា បហាតព្វាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ ។

តតិយភាណវារំ ។

ឃានៈត្រូវលះ គន្ធៈត្រូវលះ ជិវ្ហាត្រូវលះ រសត្រូវលះ កាយត្រូវលះ ផោដ្ឋព្វៈត្រូវលះ មនៈត្រូវលះ ធម្មារម្មណ៍ត្រូវលះ មនោវិញ្ញាណត្រូវលះ មនោសម្ផស្សត្រូវលះ ការទទួលអារម្មណ៍ណា ទោះជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី ដែលកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះឯង ក៏ត្រូវលះចេញ ។

បុគ្គលកាលឃើញនូវរូប រមែងលះបង់[១] កាលឃើញនូវវេទនា រមែងលះបង់ កាលឃើញនូវសញ្ញា រមែងលះបង់ កាលឃើញនូវសង្ខារទាំងឡាយ រមែងលះបង់ កាលឃើញនូវវិញ្ញាណ រមែងលះបង់ នូវចក្ខុ ។ បេ ។ នូវជរានិងមរណៈ កាលឃើញនូវនិព្វាន ឈ្មោះអមតៈ ជាទីពំនាក់ (របស់ពួកសត្វ) ដោយអត្ថថាចប់ស្រេច (នៃសាសនា) រមែងលះបង់ ធម៌ទាំងឡាយណាៗ ដែលបុគ្គលបានបន្សាត់ហើយ ធម៌ទាំងនោះ ឈ្មោះថាបុគ្គលលះចេញហើយ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាជាគ្រឿងដឹងច្បាស់នូវធម៌នោះ ហេតុនោះ ទើបលោកពោលថា ការប្រុងត្រចៀកថាធម៌ទាំងឡាយនេះ បុគ្គលត្រូវលះ បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតមយញ្ញាណ ។

ចប់ តតិយភាណវារៈ ។

---

១ បុគ្គលកាលឃើញរូបថាមិនទៀងជាដើម រមែងលះកិលេសចេញបាន ។ អដ្ឋកថា ។

[៦៧] កថំ ឥមេ ធម្មា ភាវេតព្វាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ ឯកោ ធម្មោ ភាវេតព្វោ កាយគតា សតិ សាតសហគតា ទ្វេ ធម្មា ភាវេតព្វា សមថោ ច វិបស្សនា ច តយោ ធម្មា ភាវេតព្វា តយោ សមាធិ ចត្តារោ ធម្មា ភាវេតព្វា ចត្តារោ សតិប្បដ្ឋានា បញ្ច ធម្មា ភាវេតព្វា បញ្ច-ង្គិកោ សម្មាសមាធិ ឆ ធម្មា ភាវេតព្វា ឆ អនុស្ស-តិដ្ឋានានិ សត្ត ធម្មា ភាវេតព្វា សត្ត ពោជ្ឈង្គា អដ្ឋ ធម្មា ភាវេតព្វា អរិយោ អដ្ឋង្គិកោ មគ្គោ នវ ធម្មា ភាវេតព្វា នវ បារិសុទ្ធិប្បធានិយង្គានិ ទស ធម្មា ភាវេតព្វា ទស កសិណាយតនានិ ។

[៦៨] ទ្វេ ភាវនា លោកិយា ច ភាវនា លោ-កុត្តរា ច ភាវនា ។ តិស្សោ ភាវនា រូបាវចរកុស-លានំ ធម្មានំ ភាវនា អរូបាវចរកុសលានំ ធម្មានំ ភាវនា អបរិយាបន្នានំ កុសលានំ ធម្មានំ ភាវនា ។ រូបាវចរកុសលានំ ធម្មានំ ភាវនា អត្ថិ ហីនា អត្ថិ មជ្ឈិ-មា អត្ថិ បណីតា អរូបាវចរកុសលានំ ធម្មានំ ភាវនា

[៦៧] ការប្រុងត្រៀកថា ធម៌ទាំងឡាយនេះ បុគ្គលត្រូវចំរើន បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រៀកនោះ ឈ្មោះថាសុតមយញ្ញាណ តើដូចម្តេច ធម៌ ១ ដែលត្រូវចម្រើន គឺកាយគតាសតិ ដែលប្រកបដោយសេចក្តីសុខស្រួល ធម៌ ២ ដែលត្រូវចម្រើន គឺសមថៈ ១ វិបស្សនា ១ ធម៌ ៣ ដែលត្រូវចម្រើន គឺសមាធិ ៣ ធម៌ ៤ ដែលត្រូវចម្រើន គឺសតិប្បដ្ឋាន ៤ ធម៌ ៥ ដែលត្រូវចម្រើន គឺសម្មាសមាធិមានអង្គ ៥ ធម៌ ៦ ដែលត្រូវចម្រើន គឺអនុស្សតិដ្ឋាន ៦ ធម៌ ៧ ដែលត្រូវចម្រើន គឺពោជ្ឈង្គ ៧ ធម៌ ៨ ដែលត្រូវចម្រើន គឺអរិយមគ្គ ប្រកបដោយអង្គ ៨ ធម៌ ៩ ដែលត្រូវចម្រើន គឺបារិសុទ្ធិប្បធានិយង្គៈ ៩ ធម៌ ១០ ដែលត្រូវចម្រើន គឺកសិណាយតនៈ ១០ ។

[៦៨] ភាវនា (ការចម្រើន) ២ យ៉ាង គឺលោកិយភាវនា ១ លោកុត្តរភាវនា ១ ។ ភាវនា ៣ យ៉ាង គឺការចម្រើនពួកធម៌ ជារូបាវចរកុសល ១ ការចម្រើនពួកធម៌ជាអរូបាវចរកុសល ១ ការចម្រើនពួកធម៌ជាកុសល ដែលមិនបានរាប់បញ្ចូល (ក្នុងវដ្តៈ) គឺលោកុត្តរៈ ១ ។ ការចម្រើនពួកធម៌ជារូបាវចរកុសលដ៏ថោកទាបក៏មាន ជាកណ្តាលក៏មាន ដ៏ខ្ពង់ខ្ពស់ក៏មាន ការចម្រើនពួកធម៌ ជាអរូបាវចរកុសល ដ៏ថោកទាបក៏មាន

អត្ថិ ហីនា អត្ថិ មជ្ឈិមា អត្ថិ បណីតា អបរិយាបន្នានំ កុសលានំ ធម្មានំ ភាវនា បណីតា ។ ចតស្សោ ភាវនា ទុក្ខសច្ចំ បរិញ្ញាបដិវេធំ បដិវិជ្ឈន្តោ ភាវេតិ សមុទយសច្ចំ បហានប្បដិវេធំ បដិវិជ្ឈន្តោ ភាវេតិ និរោធសច្ចំ សច្ឆិកិរិយាបដិវេធំ បដិវិជ្ឈន្តោ ភាវេតិ មគ្គសច្ចំ ភាវនាបដិវេធំ បដិវិជ្ឈន្តោ ភាវេតិ ឥមា ចតស្សោ ភាវនា ។

[៦៩] អបរាបិ ចតស្សោ ភាវនា ឯសនាភាវនា បដិលាភភាវនា ឯករសាភាវនា អាសេវនាភាវនា ។

កតមា ឯសនាភាវនា សព្វេសំ សមាធឹ សមាបជ្ជន្តានំ តត្ថ ជាតា ធម្មា ឯករសា ហោន្តីតិ អយំ ឯសនាភាវនា ។

កតមា បដិលាភភាវនា សព្វេសំ សមាធឹ សមាបន្នានំ តត្ថ ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ អយំ បដិលាភភាវនា ។

[៧០] កតមា ឯករសាភាវនា អធិមោក្ខដ្ឋេន សទ្ធិន្ទ្រិយំ ភាវយតោ សទ្ធិន្ទ្រិយស្ស វសេន ចត្តារិ ឥន្ទ្រិយានិ ឯករសា ហោន្តីតិ

ជាកណ្តាលក៏មាន ដ៏ខ្ពង់ខ្ពស់ក៏មាន ការចម្រើនធម៌ជាកុសលដែលមិនបានរាប់បញ្ចូល (ក្នុងវដ្តៈ) គឺលោកុត្តរៈដ៏ខ្ពង់ខ្ពស់ ។ ភាវនា ៤ យ៉ាង គឺបុគ្គលកាលត្រាស់ដឹង ដែលជាបរិញ្ញាបដិវេធហើយចម្រើន ១[១] កាលត្រាស់ដឹងនូវសមុទយសច្ច ដែលជាបហានប្បដិវេធហើយចម្រើន ១ កាលត្រាស់ដឹងនូវនិរោធសច្ច ដែលជាសច្ឆិកិរិយាបដិវេធ ហើយចម្រើន ១ កាលត្រាស់ដឹងនូវមគ្គសច្ច ដែលជាភាវនាបដិវេធ ហើយចម្រើន ១ ភាវនាមាន ៤ យ៉ាងនេះឯង ។

[៦៩] ភាវនា ៤ យ៉ាងដោយឡែកទៀតគឺ ឯសនាភាវនា ១ បដិលាភភាវនា ១ ឯករសាភាវនា ១ អាសេវនាភាវនា ១ ។

ឯសនាភាវនា តើដូចម្តេច កាលពួកជនទាំងពួងកំពុងចូលកាន់សមាធិ ធម៌ទាំងឡាយដែលកើតក្នុងចំណែកខាងដើមនោះ ជាធម៌មានកិច្ចស្មើគ្នា នេះឈ្មោះថា ឯសនាភាវនា ដោយប្រការដូច្នេះ ។

បដិលាភភាវនា តើដូចម្តេច កាលពួកជនទាំងពួងដែលបានចូលកាន់សមាធិហើយ ធម៌ទាំងឡាយ ដែលកើតក្នុងសមាធិនោះ រមែងមិនកន្លងនូវគ្នានឹងគ្នាឡើយ នេះឈ្មោះថា បដិលាភភាវនា ដោយប្រការដូច្នេះ ។

[៧០] ឯករសាភាវនា តើដូចម្តេច កាលបុគ្គលចម្រើនសទ្ធិន្ទ្រិយ ដោយអត្ថថាជឿស៊ប់ ឥន្ទ្រិយទាំង ៤ ជាធម្មជាត មានរសតែមួយ

១ ចម្រើន អរិយមគ្គ ។ អដ្ឋកថា ។

ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា បគ្គហដ្ឋេន វីរិយិន្ទ្រិយំ ភាវយតោ វីរិយិន្ទ្រិយស្ស វសេន ចត្តារិ ឥន្ទ្រិយានិ ឯករសា ហោន្តីតិ ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា ឧបដ្ឋានដ្ឋេន សតិន្ទ្រិយំ ភាវយតោ សតិន្ទ្រិយស្ស វសេន ចត្តារិ ឥន្ទ្រិយានិ ឯករសា ហោន្តីតិ ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា អវិក្ខេបដ្ឋេន សមាធិន្ទ្រិយំ ភាវយតោ សមាធិន្ទ្រិយស្ស វសេន ចត្តារិ ឥន្ទ្រិយានិ ឯករសា ហោន្តីតិ ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា ទស្សនដ្ឋេន បញ្ញិន្ទ្រិយំ ភាវយតោ បញ្ញិន្ទ្រិយស្ស វសេន ចត្តារិ ឥន្ទ្រិយានិ ឯករសា ហោន្តីតិ ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា អស្សទ្ធិយេ អកម្បិយដ្ឋេន សទ្ធាពលំ ភាវយតោ សទ្ធាពលស្ស វសេន ចត្តារិ ពលានិ ឯករសា ហោន្តីតិ ពលានំ ឯករសដ្ឋេន ភាវនា

ដោយអំណាចនៃសទ្ធិន្ទ្រិយ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាពួកឥន្ទ្រិយមានរសតែមួយ កាលបុគ្គលចម្រើនវីរិយិន្ទ្រិយ ដោយអត្ថថាផ្គងឡើង ឥន្ទ្រិយទាំង ៤ ជាធម្មជាត មានរសតែមួយ ដោយអំណាចនៃវីរិយិន្ទ្រិយ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាពួកឥន្ទ្រិយមានរសតែមួយ កាលបុគ្គលចម្រើនសតិន្ទ្រិយ ដោយអត្ថថាប្រុងប្រយ័ត្ន ឥន្ទ្រិយទាំង ៤ ជាធម្មជាតមានរសតែមួយ ដោយអំណាចនៃសតិន្ទ្រិយ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាពួកឥន្ទ្រិយមានរសតែមួយ បុគ្គលកាលចម្រើនសមាធិន្ទ្រិយ ដោយអត្ថថាមិនរាយមាយ ឥន្ទ្រិយទាំង ៤ ជាធម្មជាតមានរសតែមួយ ដោយអំណាចនៃសមាធិន្ទ្រិយ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាពួកឥន្ទ្រិយមានរសតែមួយ កាលបុគ្គលចម្រើនបញ្ញិន្ទ្រិយ ដោយអត្ថថាឃើញច្បាស់ ឥន្ទ្រិយទាំង ៤ ជាធម្មជាតមានរសតែមួយ ដោយអំណាចនៃបញ្ញិន្ទ្រិយ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាពួកឥន្ទ្រិយមានរសតែមួយ កាលបុគ្គលចម្រើនសទ្ធាពលៈ ដោយអត្ថថាមិនញាប់ញ័រ ព្រោះសេចក្តីមិនជឿ ពលៈទាំង ៤ ជាធម្មជាតមានរសតែមួយ ដោយអំណាចនៃសទ្ធាពលៈ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាពលៈទាំងឡាយមានរសតែមួយ

៦៤



កោសជ្ជេ អកម្បិយដ្ឋេន វីរិយពលំ ភាវយតោ វីរិយពលស្ស វសេន ចត្តារិ ពលានិ ឯករសា ហោន្តីតិ ពលានំ ឯករសដ្ឋេន ភាវនា បមាទេ អកម្បិយដ្ឋេន សតិពលំ ភាវយតោ សតិពលស្ស វសេន ចត្តារិ ពលានិ ឯករសា ហោន្តីតិ ពលានំ ឯករសដ្ឋេន ភាវនា ឧទ្ធច្ចេ អកម្បិយដ្ឋេន សមាធិពលំ ភាវយតោ សមាធិពលស្ស វសេន ចត្តារិ ពលានិ ឯករសា ហោន្តីតិ ពលានំ ឯករសដ្ឋេន ភាវនា អវិជ្ជាយ អកម្បិយដ្ឋេន បញ្ញាពលំ ភាវយតោ បញ្ញាពលស្ស វសេន ចត្តារិ ពលានិ ឯករសា ហោន្តីតិ ពលានំ ឯករសដ្ឋេន ភាវនា ឧបដ្ឋានដ្ឋេន សតិសម្ពោជ្ឈង្គំ ភាវយតោ សតិសម្ពោជ្ឈង្គស្ស វសេន ឆ ពោជ្ឈង្គា ឯករសា ហោន្តីតិ ពោជ្ឈង្គានំ ឯករសដ្ឋេន ភាវនា បវិចយដ្ឋេន ធម្មវិចយសម្ពោជ្ឈង្គំ ភាវយតោ

បុគ្គលកាលចម្រើនវីរិយពលៈ ដោយអត្ថថាមិនញាប់ញ័រព្រោះសេចក្ដីខ្ជិលច្រអូស ពលៈទាំង ៤ ជាធម្មជាត មានរសតែមួយ ដោយអំណាចនៃវីរិយពលៈ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាពលៈទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសតិពលៈ ដោយអត្ថថាមិនញាប់ញ័រព្រោះសេចក្ដីប្រមាទ ពលៈទាំង ៤ ជាធម្មជាត មានរសតែមួយ ដោយអំណាចនៃសតិពលៈ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាពលៈទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសមាធិ-ពលៈ ដោយអត្ថថាមិនញាប់ញ័រព្រោះការអណ្ដែតអណ្ដូង ពលៈទាំង ៤ ជាធម្មជាតមានរសតែមួយ ដោយអំណាចនៃសមាធិពលៈ ហេតុនោះទើបឈ្មោះថាភាវនា ដោយអត្ថថាពលៈទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនបញ្ញាពលៈ ដោយអត្ថថាមិនញាប់ញ័រព្រោះអវិជ្ជា ពលៈទាំង ៥ ជាធម្មជាតមានរសតែមួយ ដោយអំណាចនៃបញ្ញាពលៈ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាពលៈទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសតិសម្ពោជ្ឈង្គ ដោយអត្ថថាប្រុងប្រយ័ត្ន ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយ ដោយអំណាចនៃសតិសម្ពោជ្ឈង្គ ហេតុនោះទើបឈ្មោះថាភាវនា ដោយអត្ថថាពោជ្ឈង្គទាំងឡាយ មានរសតែមួយ កាលបុគ្គលចម្រើន ធម្មវិចយសម្ពោជ្ឈង្គ ដោយអត្ថថាជ្រើសរើស

៦៨



ធម្មវិចយសម្ពោជ្ឈង្គស្ស វសេន ឆ ពោជ្ឈង្គា ឯករសា ហោន្តីតិ ពោជ្ឈង្គានំ ឯករសដ្ឋេន ភាវនា បគ្គហដ្ឋេន វីរិយសម្ពោជ្ឈង្គំ ភាវយតោ វីរិយសម្ពោជ្ឈង្គស្ស វសេន ឆ ពោជ្ឈង្គា ឯករសា ហោន្តីតិ ពោជ្ឈង្គានំ ឯករសដ្ឋេន ភាវនា ផរណដ្ឋេន បីតិសម្ពោជ្ឈង្គំ ភាវយតោ បីតិសម្ពោជ្ឈង្គស្ស វសេន ឆ ពោជ្ឈង្គា ឯករសា ហោន្តីតិ ពោជ្ឈង្គានំ ឯករសដ្ឋេន ភាវនា ឧបសមដ្ឋេន បស្សទ្ធិសម្ពោជ្ឈង្គំ ភាវយតោ បស្សទ្ធិសម្ពោជ្ឈង្គស្ស វសេន ឆ ពោជ្ឈង្គា ឯករសា ហោន្តីតិ ពោជ្ឈង្គានំ ឯករសដ្ឋេន ភាវនា អវិក្ខេបដ្ឋេន សមាធិសម្ពោជ្ឈង្គំ ភាវយតោ សម្មាសមាធិសម្ពោជ្ឈង្គស្ស វសេន ឆ ពោជ្ឈង្គា ឯករសា ហោន្តីតិ ពោជ្ឈង្គានំ ឯករសដ្ឋេន ភាវនា បដិសង្ខានដ្ឋេន ឧបេក្ខាសម្ពោជ្ឈង្គំ ភាវយតោ ឧបេក្ខាសម្ពោជ្ឈង្គស្ស វសេន ឆ ពោជ្ឈង្គា ឯករសា ហោន្តីតិ ពោជ្ឈង្គានំ ឯករសដ្ឋេន ភាវនា ។

ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយ ដោយអំណាចនៃធម្មវិចយ-សម្ពោជ្ឈង្គ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថាសម្ពោជ្ឈង្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនវីរិយសម្ពោជ្ឈង្គ ដោយអត្ថថាផ្គងឡើង ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយ ដោយអំណាចនៃវីរិយសម្ពោជ្ឈង្គ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថាពោជ្ឈង្គទាំងឡាយ មានរសតែមួយ កាលបុគ្គលចម្រើនបីតិសម្ពោជ្ឈង្គ ដោយអត្ថថាផ្សាយទៅ ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយ ដោយអំណាចនៃបីតិសម្ពោជ្ឈង្គ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាពោជ្ឈង្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ ដោយអត្ថថាស្ងប់រម្ងាប់ ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយ ដោយអំណាចនៃបស្សទ្ធិសម្ពោជ្ឈង្គ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាពោជ្ឈង្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសមាធិ-សម្ពោជ្ឈង្គ ដោយអត្ថថាមិនរាយមាយ ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយ ដោយអំណាចនៃសមាធិសម្ពោជ្ឈង្គ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថាសម្ពោជ្ឈង្គទាំងឡាយមានរសតែមួយ បុគ្គលកាលចម្រើនឧបេក្ខាសម្ពោជ្ឈង្គ ដោយអត្ថថាត្រួតត្រា ពោជ្ឈង្គទាំង ៦ ជាធម៌មានរសតែមួយ ដោយអំណាចនៃឧបេក្ខាសម្ពោជ្ឈង្គ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាពោជ្ឈង្គទាំងឡាយមានរសតែមួយ ។

ទស្សនដ្ឋេន សម្មាទិដ្ឋឹ ការយតោ សម្មាទិដ្ឋិយា វសេន សត្ត មគ្គង្គា ឯករសា ហោន្តីតិ មគ្គង្គានំ ឯករសដ្ឋេន ការណា អភិនិរោបនដ្ឋេន សម្មាសង្កប្បំ ការយតោ សម្មាសង្កប្បស្ស វសេន សត្ត មគ្គង្គា ឯករសា ហោន្តីតិ មគ្គង្គានំ ឯករសដ្ឋេន ការណា បរិគ្គហដ្ឋេន សម្មាវាចំ ការយតោ សម្មាវាចាយ វសេន សត្ត មគ្គង្គា ឯករសា ហោន្តីតិ មគ្គង្គានំ ឯករស-ដ្ឋេន ការណា សមុដ្ឋានដ្ឋេន សម្មាកម្មន្តំ ការយតោ សម្មាកម្មន្តស្ស វសេន សត្ត មគ្គង្គា ឯករសា ហោន្តីតិ មគ្គង្គានំ ឯករសដ្ឋេន ការណា វោទានដ្ឋេន សម្មាអាជីវំ ការយតោ សម្មាអាជីវស្ស វសេន សត្ត មគ្គង្គា ឯករសា ហោន្តីតិ មគ្គង្គានំ ឯករសដ្ឋេន ការណា បគ្គហដ្ឋេន សម្មាវាយាមំ ការយតោ សម្មាវាយាមស្ស វសេន សត្ត មគ្គង្គា ឯករសា ហោន្តីតិ មគ្គង្គានំ ឯករសដ្ឋេន ការណា

កាលបុគ្គលចម្រើនសម្មាទិដ្ឋិ ដោយអត្ថថាឃើញជាក់លាក់ អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយ ដោយអំណាចនៃសម្មាទិដ្ឋិ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថាអង្គមគ្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសម្មាសង្កប្បៈ ដោយអត្ថថាជាទីលើកឡើងនូវចិត្ត អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយ ដោយអំណាចនៃសម្មាសង្កប្បៈ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាអង្គមគ្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសម្មាវាចា ដោយអត្ថថារក្សាទុក អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយ ដោយអំណាចនៃសម្មាវាចា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថាអង្គមគ្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសម្មា-កម្មន្តៈដោយអត្ថថាតាំងឡើង អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយ ដោយអំណាចនៃសម្មាកម្មន្តៈ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាអង្គមគ្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសម្មាអាជីវៈដោយអត្ថថាផូរផង់ អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយ ដោយអំណាចនៃសម្មាអាជីវៈ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាអង្គមគ្គទាំងឡាយមានរសតែមួយ កាលបុគ្គលចម្រើនសម្មាវាយាមៈដោយអត្ថថាផ្គងឡើង អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយ ដោយអំណាចនៃសម្មាវាយាមៈ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាអង្គមគ្គទាំងឡាយមានរសតែមួយ

ឧបដ្ឋានដ្ឋេន សម្មាសតី ភាវយតោ សម្មាសតិយា រសេន សត្ត មគ្គង្គា ឯការសា ហោន្តីតិ មគ្គង្គានំ ឯការសដ្ឋេន ភាវនា អវិក្ខេបដ្ឋេន សម្មាសមាធី ភាវយតោ សម្មាសមាធិស្ស រសេន សត្ត មគ្គង្គា ឯការសា ហោន្តីតិ មគ្គង្គានំ ឯការសដ្ឋេន ភាវនា អយំ ឯការសា ភាវនា ។

[៧១] កតមា អាសេវនា ភាវនា ឥធ ភិក្ខវេ បុព្វ-ណ្ហសមយំបិ អាសេវតិ មជ្ឈន្តិកសមយំបិ អាសេវតិ សាយណ្ហសមយំបិ អាសេវតិ បុរេភត្តំបិ អាសេវតិ បច្ឆាភត្តំបិ អាសេវតិ បុរិមេបិ យាមេ អាសេវតិ មជ្ឈិ-មេបិ យាមេ អាសេវតិ បច្ឆិមេបិ យាមេ អាសេវតិ រត្តឹបិ អាសេវតិ ទិវាបិ អាសេវតិ រត្តិន្ទិវាបិ អាសេវតិ កាឡេបិ អាសេវតិ ជុណ្ហេបិ អាសេវតិ វស្សេបិ អា-សេវតិ ហេមន្តេបិ អាសេវតិ គិម្ហេបិ អាសេវតិ បុរិមេបិ វយោខន្ធេ អាសេវតិ មជ្ឈិមេបិ វយោខន្ធេ អាសេវតិ

*កាលបុគ្គលចម្រើនសម្មាសតិ ដោយអត្ថថាប្រុងប្រយ័ត្ន អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយ ដោយអំណាចនៃសម្មាសតិ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាអង្គមគ្គទាំងឡាយមានរសតែមួយ បុគ្គលកាលចម្រើនសម្មាសមាធិ ដោយអត្ថថាមិនរាយមាយ អង្គមគ្គទាំង ៧ ជាធម៌មានរសតែមួយ ដោយអំណាចនៃសម្មាសមាធិ ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថាអង្គមគ្គទាំងឡាយមានរសតែមួយ នេះឈ្មោះថា ឯករសាភាវនា ។*

[៧១] *អាសេវនាភាវនា តើដូចម្តេច ភិក្ខុក្នុងសាសនានេះឧស្សាហ៍គប់រក* (*នូវសមាធិ*) *ក្នុងវេលាព្រឹកខ្លះ ឧស្សាហ៍គប់រកក្នុងវេលាថ្ងៃត្រង់ខ្លះ ឧស្សាហ៍គប់រកក្នុងវេលាថ្ងៃរសៀលខ្លះ ឧស្សាហ៍គប់រកក្នុងកាលមុនភត្តខ្លះ ឧស្សាហ៍គប់រកក្នុងកាលក្រោយភត្តខ្លះ ឧស្សាហ៍គប់រក ក្នុងយាមខាងដើមខ្លះ ឧស្សាហ៍គប់រក ក្នុងយាមកណ្តាលខ្លះ ឧស្សាហ៍គប់រក ក្នុងយាមខាងចុងខ្លះ ឧស្សាហ៍គប់រក ក្នុងវេលាយប់ខ្លះ ឧស្សាហ៍គប់រក ក្នុងវេលាថ្ងៃខ្លះ ឧស្សាហ៍គប់រកក្នុងវេលាយប់និងវេលាថ្ងៃខ្លះ ឧស្សាហ៍គប់រក ក្នុងចំណែកខាងខ្មៅខ្លះ ឧស្សាហ៍គប់រក ក្នុងចំណែកខាងខ្នើតខ្លះ ឧស្សាហ៍គប់រកក្នុងរដូវភ្លៀងខ្លះ ឧស្សាហ៍គប់រកក្នុងរដូវត្រជាក់ខ្លះ ឧស្សាហ៍គប់រកក្នុងរដូវក្តៅខ្លះ ឧស្សាហ៍គប់រកក្នុងចំណែកនៃវ័យខាងដើមខ្លះ ឧស្សាហ៍គប់រក ក្នុងចំណែកនៃវ័យកណ្តាលខ្លះ*

បច្ឆិមេបិ វេយោទង្វេ អាសេវតិ អយំ អាសេវនា ការនា ឥមា ចតស្សោ ការនា ។

[៧២] អបរាបិ ចតស្សោ ការនា តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ការនា ឥន្ទ្រិយានំ ឯករសដ្ឋេន ការនា តទុបគវីរិយវាហនដ្ឋេន ការនា អាសេវនដ្ឋេន ការនា ។

[៧៣] កថំ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ការនា កាមច្ឆន្ទំ បជហតោ នេក្ខម្មវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ការនា ព្យាបាទំ បជហតោ អព្យាបាទវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ការនា ថីនមិទ្ធំ បជហតោ អាលោកសញ្ញាវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ការនា

ឧស្សាហ៍គប់រក ក្នុងចំណែកនៃវ័យខាងចុងខ្ទះ នេះឈ្មោះថាអាសេវនា-ភាវនា ភាវនាមាន ៤ យ៉ាងនេះឯង ។

[៧២] ភាវនា ៤ យ៉ាងដោយឡែកទៀត គឺភាវនាដោយអត្ថថាមិនប្រព្រឹត្តកន្លង នូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ ១ ភាវនាដោយអត្ថថាឥន្ទ្រិយទាំងឡាយ មានរសតែមួយ ១ ភាវនាដោយអត្ថថាជាទីនាំទៅនូវវីរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ ១ ភាវនាដោយអត្ថថាឧស្សាហ៍គប់រក ១ ។

[៧៣] ភាវនាដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ តើដូចម្តេច កាលបុគ្គលលះកាមច្ឆន្ទៈ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃនេក្ខម្មៈ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះព្យាបាទ ធម៌ទាំងឡាយដែលកើតហើយដោយអំណាចនៃការមិនព្យាបាទ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះថីនមិទ្ធៈ ធម៌ទាំងឡាយ ដែលកើតហើយ ដោយអំណាច នៃអាលោកសញ្ញា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លង នូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ

ឧទ្ធច្ចំ បជហតោ អវិក្ខេបវសេន ជាតា ធម្មា អញ្ញមញ្ញំ ជាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិ-វត្តនដ្ឋេន ភាវនា វិចិកិច្ឆំ បជហតោ ធម្មវវត្ថាន-វសេន ជាតា ធម្មា អញ្ញមញ្ញំ ជាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា អវិជ្ជំ បជ-ហតោ ញាណវសេន ជាតា ធម្មា អញ្ញមញ្ញំ ជាតិ-វត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា អរតឹ បជហតោ បាមុជ្ជវសេន ជាតា ធម្មា អញ្ញមញ្ញំ ជាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា នីវរណេ[1] បជហតោ បឋមជ្ឈានវសេន ជាតា ធម្មា អញ្ញមញ្ញំ ជាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា វិតក្កវិចារេ បជហតោ

---

១ ឱ. ម. នីវរណំ ។

កាលបុគ្គលលះឧទ្ធច្ចៈ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃការមិនអណ្តែតអណ្តូង រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះវិចិកិច្ឆា ធម៌ទាំងឡាយដែលកើតហើយដោយអំណាចនៃការកំណត់នូវធម៌ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថា ភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះអវិជ្ជា ធម៌ទាំងឡាយ ដែលកើតហើយ ដោយអំណាចនៃញាណ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះអរតិ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃបាមុជ្ជៈ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះនីវរណៈ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃបឋមជ្ឈាន រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំង-ឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះវិតក្កៈនិងវិចារៈ

ទុតិយជ្ឈានវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា បីតឹ បជហតោ តតិយជ្ឈានវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា សុខទុក្ខេ បជហតោ ចតុត្ថជ្ឈានវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្ត-នដ្ឋេន ភាវនា រូបសញ្ញំ បដិឃសញ្ញំ នានត្តសញ្ញំ បជហតោ អាកាសានញ្ចាយតនសមាបត្តិវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា អាកាសានញ្ចាយតនសញ្ញំ បជហតោ វិញ្ញាណញ្ចាយតនសមាបត្តិវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិ-វត្តនដ្ឋេន ភាវនា វិញ្ញាណញ្ចាយតនសញ្ញំ បជហតោ

ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃទុតិយជ្ឈាន រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតហើយ ក្នុងភាវនាវិសេសនោះ កាលបុគ្គលលះបីតិ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃតតិយជ្ឈាន រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសុខនិងទុក្ខ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃចតុត្ថជ្ឈាន រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះរូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា ធម៌ទាំងឡាយដែលកើតហើយដោយអំណាចនៃអាកាសានញ្ចាយតនសមាបត្តិ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើត ក្នុងភាវនាវិសេសនោះ កាលបុគ្គលលះអាកាសានញ្ចាយ-តនសញ្ញា ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃវិញ្ញាណ-ញ្ចាយតនសមាបត្តិ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លង នូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះវិញ្ញាណញ្ចាយតនសញ្ញា

៧១



អាកិញ្ចញ្ញាយតនសមាបត្តិវសេន ជាតា ធម្មា អញ្ញមញ្ញំ ណាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា អាកិញ្ចញ្ញាយតនសញ្ញំ បជហតោ នេវសញ្ញានាសញ្ញាយតនសមាបត្តិវសេន ជាតា ធម្មា អញ្ញមញ្ញំ ណាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា និច្ចសញ្ញំ បជហតោ អនិច្ចានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ ណាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា សុខសញ្ញំ បជហតោ ទុក្ខានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ ណាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា អត្តសញ្ញំ បជហតោ អនត្តានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ ណាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា នន្ទឹ បជហតោ

ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃអាកិញ្ចញ្ញាយតនសមាបត្តិ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតហើយក្នុងភាវនាវិសេសនោះ កាលបុគ្គលលះអាកិញ្ចញ្ញាយតនសញ្ញា ធម៌ទាំងឡាយដែលកើតហើយដោយអំណាចនៃនេវសញ្ញានាសញ្ញាយតនសមាបត្តិ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះនិច្ចសញ្ញា ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាច នៃអនិច្ចានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លង នូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសុខសញ្ញា ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃទុក្ខានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះអត្តសញ្ញា ធម៌ទាំងឡាយដែលកើតហើយដោយអំណាចនៃអនត្តានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គល

និព្វិទានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ ជាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា រាគំ បជហតោ វិរាគានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ ជាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា សមុទយំ បជហតោ និរោធានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ ជាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា អាទានំ បជហតោ បដិនិស្សគ្គានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ ជាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ឃនសញ្ញំ បជហតោ ខយានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ ជាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា

លះនន្ទិ ធម៌ទាំងឡាយដែលកើតហើយដោយអំណាចនៃនិព្វិទានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះរាគៈ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃវិរាគានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើត ក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសមុទយៈ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃនិរោធានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះការប្រកាន់មាំ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចនៃបដិនិស្សគ្គា-នុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសេចក្តីសម្គាល់ថាជាប់នៅរឹងប៉ឹង ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចខយានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ

អាយុហនំ បជហតោ វយានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ធុវសញ្ញំ បជហតោ វិបរិណាមានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា និមិត្តំ បជហតោ អនិមិត្តានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា បណិធឹ បជហ-តោ អប្បណិហិតានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិ-វត្តនដ្ឋេន ភាវនា អភិនិវេសំ បជហតោ សុញ្ញតា-នុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ

កាលបុគ្គលលះការប្រមូលមក ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចវយានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះការសម្គាល់ថាមាំមួន ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចវិបរិណាមានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះការកំណត់ថាទៀង ធម៌ទាំងឡាយ ដែលកើតហើយដោយអំណាចអនិមិត្តានុបស្សនា រមែងមិនប្រព្រឹត្តកន្លង នូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសេចក្ដីប្រាថ្នា ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចអប្បណិហិតានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លង នូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសេចក្ដីប្រកាន់ ធម៌ទាំងឡាយដែលកើតហើយដោយអំណាចសុញ្ញតានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា

តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា សារា-ទានាភិនិវេសំ បជហតោ អធិប្បញ្ញាធម្មវិបស្សនា-វសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា សម្មោហា-ភិនិវេសំ បជហតោ យថាភូតញាណទស្សនវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា អាលយាភិនិវេសំ បជហតោ អាទីនវានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា អប្បដិសង្ខំ បជហតោ បដិសង្ខានុបស្សនា-វសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា

ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំង-ឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសេចក្តីប្រកាន់មាំ និងការប្រកាន់ស្អិតថាមានខ្លឹម ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចអធិប្បញ្ញា នឹងធម្មវិបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំង-ឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គល លះសេចក្តីប្រកាន់ ដោយការវង្វេងខ្លាំង ធម៌ទាំងឡាយ ដែលកើតហើយដោយអំណាចយថាភូតញ្ញាណទស្សនៈ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លង នូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះសេចក្តីប្រកាន់ ដោយអាល័យ ធម៌ទាំងឡាយដែលកើតហើយដោយអំណាចអាទីនវានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លង នូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះការមិនពិចារណា ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចបដិសង្ខានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លង នូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ

សញ្ញោគាភិនិវេសំ បជហតោ វិវដ្ដានុបស្សនាវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ទិដ្ឋេកដ្ឋេ កិលេសេ បជហតោ សោតាបត្តិមគ្គវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិ-វត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ឱឡារិកេ កិលេសេ បជហតោ សកទាគាមិមគ្គ-វសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា អណុសហគតេ កិលេសេ បជហតោ អនាគាមិមគ្គវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា សព្ពកិលេសេ បជហតោ អរហត្តមគ្គវសេន ជាតា ធម្មា អញ្ញមញ្ញំ នាតិវត្តន្តីតិ

កាលបុគ្គលលះសេចក្តីប្រកាន់ ដោយការប្រកបទុក ធម៌ទាំងឡាយដែល កើតហើយ ដោយអំណាចវិវដ្តនានុបស្សនា រមែងមិនប្រព្រឹត្តកន្លងនូវគ្នា និងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវ ធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កិលេសទាំងឡាយដែល ឋិតនៅក្នុងទីតែមួយជាមួយនិងទិដ្ឋិ ធម៌ទាំងឡាយដែលកើតហើយដោយ អំណាចសោតាបត្តិមគ្គ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លង នូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះកិលេសទាំងឡាយដ៏ គ្រោតគ្រាត ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចសកទាគា-មិមគ្គ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវ-នា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនា វិសេសនោះ កាលបុគ្គលលះកិលេសទាំងឡាយដ៏ល្អិត ធម៌ទាំងឡាយ ដែលកើតហើយ ដោយអំណាចអនាគាមិមគ្គ រមែងមិនប្រព្រឹត្តកន្លងនូវ គ្នានឹងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លង នូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ កាលបុគ្គលលះកិលេស ទាំងអស់ ធម៌ទាំងឡាយដែលកើតហើយ ដោយអំណាចអរហត្តមគ្គ រមែងមិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ហេតុនោះ ទើបឈ្មោះថាភាវនា

តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ឯវំ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា ។

[៧៤] កថំ ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា កាមច្ឆន្ទំ បជហតោ នេក្ខម្មវសេន បញ្ចិន្ទ្រិយានិ ឯករសា ហោន្តីតិ ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា ព្យាបាទំ បជហតោ អព្យាបាទវសេន បញ្ចិន្ទ្រិយានិ ឯករសា ហោន្តីតិ ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា ។ បេ ។ សព្វកិលេសេ បជហតោ អរហត្តមគ្គ-វសេន បញ្ចិន្ទ្រិយានិ ឯករសា ហោន្តីតិ ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា ឯវំ ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា ។

[៧៥] កថំ តទុបគវិរិយវាហនដ្ឋេន[១] ភាវនា កាមច្ឆន្ទំ បជហន្តោ នេក្ខម្មវសេន វិរិយំ វាហេតីតិ តទុបគវិរិយវាហនដ្ឋេន ភាវនា ព្យាបាទំ បជហន្តោ

១ ម. តទុបគវិរិយវាហដ្ឋេន ។

ដោយអត្ថថាមិនប្រព្រឹត្តកន្លង នូវធម៌ទាំងឡាយ ដែលកើតក្នុងភាវនាវិសេសនោះ ភាវនា ដោយអត្ថថាមិនប្រព្រឹត្តកន្លងនូវធម៌ទាំងឡាយដែលកើតក្នុងភាវនាវិសេសនោះ យ៉ាងនេះឯង ។

[៧៤] ភាវនា ដោយអត្ថថាឥន្ទ្រិយទាំងឡាយមានរសតែមួយ តើដូចម្ដេច កាលបុគ្គលលះកាមច្ឆន្ទៈ ឥន្ទ្រិយទាំង ៥ មានរសតែមួយ ដោយអំណាចនេក្ខម្មៈ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាឥន្ទ្រិយទាំងឡាយមានរសតែមួយ កាលបុគ្គលលះព្យាបាទ ឥន្ទ្រិយទាំង៥ មានរសតែមួយ ដោយអំណាចការមិនព្យាបាទ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាឥន្ទ្រិយទាំងឡាយមានរសតែមួយ ។ បេ ។ កាលបុគ្គលលះកិលេសទាំងអស់ ឥន្ទ្រិយទាំង ៥ មានរសតែមួយ ដោយអំណាចអរហត្តមគ្គ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាឥន្ទ្រិយទាំងឡាយមានរសតែមួយ ភាវនា ដោយអត្ថថាឥន្ទ្រិយទាំងឡាយមានរសតែមួយ យ៉ាងនេះឯង ។

[៧៥] ភាវនា ដោយអត្ថថាជាទីនាំទៅនូវវីរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ តើដូចម្ដេច បុគ្គលកាលលះកាមច្ឆន្ទៈហើយនាំទៅនូវវីរិយៈ ដោយអំណាចនេក្ខម្មៈ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាជាទីនាំទៅនូវវីរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ បុគ្គលកាលលះព្យាបាទ

អព្យាបាទវសេន វីរិយំ ភាវេតីតិ តទុបត្ថម្ភវីរិយភាវ-

នដ្ឋេន ភាវនា ។ បេ ។ សព្វកិលេសេ បជហន្តោ

អរហត្តមគ្គវសេន វីរិយំ ភាវេតីតិ តទុបត្ថម្ភវីរិយភាវ-

នដ្ឋេន ភាវនា ឯវំ តទុបត្ថម្ភវីរិយភាវនដ្ឋេន ភាវនា ។

[៧៦] កថំ អាសេវនដ្ឋេន ភាវនា កាមច្ឆន្ទំ

បជហន្តោ នេក្ខម្មំ អាសេវតីតិ អាសេវនដ្ឋេន ភាវ-

នា ព្យាបាទំ បជហន្តោ អព្យាបាទំ អាសេវតីតិ

អាសេវនដ្ឋេន ភាវនា ។ បេ ។ សព្វកិលេសេ បជ-

ហន្តោ អរហត្តមគ្គំ អាសេវតីតិ អាសេវនដ្ឋេន ភាវនា

ឯវំ អាសេវនដ្ឋេន ភាវនា ឥមា ចតស្សោ ភាវនា

រូបំ បស្សន្តោ ភាវេតិ វេទនំ បស្សន្តោ ភាវេតិ សញ្ញំ

បស្សន្តោ ភាវេតិ សង្ខារេ បស្សន្តោ ភាវេតិ វិញ្ញា-

ណំ បស្សន្តោ ភាវេតិ ចក្ខុំ ។ បេ ។ ជរាមរណំ

ហើយនាំទៅនូវវីរិយៈដោយអំណាចការមិនព្យាបាទ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាជាទីនាំទៅនូវវីរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ ។ បេ ។ បុគ្គលកាលលះកិលេសទាំងអស់ហើយនាំទៅ នូវវីរិយៈដោយអំណាចអរហត្តមគ្គ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាជាទីនាំទៅនូវវីរិយៈ ដ៏សមគួរដល់ឥន្ទ្រិយនោះ ភាវនា ដោយអត្ថថាជាទីនាំទៅនូវវីរិយៈដ៏សមគួរដល់ឥន្ទ្រិយនោះ យ៉ាងនេះឯង ។

[៧៦] ភាវនា ដោយអត្ថថាឧស្សាហ៍គប់រក តើដូចម្ដេច បុគ្គលកាលលះកាមច្ឆន្ទៈ ឧស្សាហ៍គប់រកនេក្ខម្មៈ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាឧស្សាហ៍គប់រក បុគ្គលកាលលះព្យាបាទ ឧស្សាហ៍គប់រកការមិនព្យាបាទ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាឧស្សាហ៍គប់រក ។ បេ ។ បុគ្គលកាលលះកិលេសទាំងអស់ ឧស្សាហ៍គប់រកអរហត្តមគ្គ ហេតុនោះ ទើបឈ្មោះថាភាវនា ដោយអត្ថថាឧស្សាហ៍គប់រក ភាវនាដោយអត្ថថាឧស្សាហ៍គប់រក យ៉ាងនេះឯង នេះភាវនា ៤ បុគ្គលកាលឃើញរូបក៏ចម្រើន (នូវធម៌ដែលគួរចម្រើន) កាលឃើញវេទនា ក៏ចម្រើន កាលឃើញសញ្ញា ក៏ចម្រើន កាលឃើញសង្ខារទាំងឡាយ ក៏ចម្រើន កាលឃើញវិញ្ញាណ ក៏ចម្រើន ចក្ខុ ។ បេ ។ ជរាមរណៈ

អមតោគធំ និព្វានំ បរិយោសានដ្ឋេន បស្សន្តោ ភាវេតិ យេ យេ ធម្មា ភាវិតា ហោន្តិ តេ តេ ធម្មា ឯករសា ហោន្តិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ឥមេ ធម្មា ភាវេតព្វាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ ។

ចតុត្ថភាណវារំ ។

[៧៩] កថំ ឥមេ ធម្មា សច្ឆិកាតព្វាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ ឯកោ ធម្មោ សច្ឆិកាតព្វោ អកុប្បា ចេតោវិមុត្តិ ទ្វេ ធម្មា សច្ឆិកាតព្វា វិជ្ជា ច វិមុត្តិ ច តយោ ធម្មា សច្ឆិកាតព្វា តិស្សោ វិជ្ជា ចត្តារោ ធម្មា សច្ឆិកាតព្វា ចត្តារិ សាមញ្ញផលានិ បញ្ច ធម្មា សច្ឆិកាតព្វា បញ្ច ធម្មក្ខន្ធា ឆ ធម្មា សច្ឆិកាតព្វា ឆ អភិញ្ញា សត្ត ធម្មា សច្ឆិកាតព្វា សត្ត ខីណាសវពលានិ អដ្ឋ ធម្មា សច្ឆិកាតព្វា អដ្ឋ វិមោក្ខា នវ ធម្មា សច្ឆិកាតព្វា នវ អនុបុព្វនិរោធា ទស ធម្មា សច្ឆិកាតព្វា ទស អសេក្ខា ធម្មា ។

កាលឃើញព្រះនិព្វានឈ្មោះអមតៈជាទីពឹង (របស់សត្វ) ដោយអត្ថថា ចប់ស្រេច (នៃសាសនា) ក៏ចម្រើន ធម៌ទាំងឡាយណា ៗ ដែលបុគ្គលចម្រើនហើយ ធម៌ទាំងនោះ ៗ មានរសតែមួយ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា ការប្រុងត្រចៀកថាធម៌ទាំងនេះ បុគ្គលត្រូវចម្រើន បញ្ញាជាគ្រឿងដឹងច្បាស់ នូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតមយញ្ញាណ ។

ចប់ ភាណវារៈ ទី ៤ ។

[៧៧] ការប្រុងត្រចៀកថា ធម៌ទាំងនេះ បុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតមយញ្ញាណ តើដូចម្តេច ធម៌ ១ ដែលបុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ គឺចេតោវិមុត្តិដ៏មិនកម្រើក ធម៌ ២ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺវិជ្ជា ១ វិមុត្តិ ១ ធម៌ ៣ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺវិជ្ជា ៣ ធម៌ ៤ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺសាមញ្ញផល ៤ ធម៌ ៥ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺធម្មក្ខន្ធ ៥ ធម៌ ៦ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺអភិញ្ញា ៦ ធម៌ ៧ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺខីណាសវពលៈ ៧ ធម៌ ៨ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺវិមោក្ខ ៨ ធម៌ ៩ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺអនុបុព្វនិរោធ ៩ ធម៌ ១០ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ គឺអសេក្ខធម៌ ១០ ។

[៧៨] សព្វំ ភិក្ខវេ សច្ឆិកាតព្វំ កិញ្ច ភិក្ខវេ សព្វំ សច្ឆិកាតព្វំ ចក្ខុំ ភិក្ខវេ សច្ឆិកាតព្វំ រូបា សច្ឆិកាតព្វា ចក្ខុវិញ្ញាណំ សច្ឆិកាតព្វំ ចក្ខុសម្ផស្សោ សច្ឆិកាតព្វោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ សច្ឆិកាតព្វំ សោតំ សច្ឆិកាតព្វំ សទ្ទា សច្ឆិកាតព្វា ។ បេ ។ ឃានំ សច្ឆិកាតព្វំ គន្ធា សច្ឆិកាតព្វា ជិវ្ហា សច្ឆិកាតព្វា រសា សច្ឆិកាតព្វា កាយោ សច្ឆិកាតព្វោ ផោដ្ឋព្វា សច្ឆិកាតព្វា មនោ សច្ឆិកាតព្វោ ធម្មា សច្ឆិកាតព្វា មនោវិញ្ញាណំ សច្ឆិកាតព្វំ មនោសម្ផស្សោ សច្ឆិកាតព្វោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ សច្ឆិកាតព្វំ ។

រូបំ បស្សន្តោ សច្ឆិករោតិ វេទនំ បស្សន្តោ សច្ឆិករោតិ សញ្ញំ បស្សន្តោ សច្ឆិករោតិ

មហាវគ្គ ញាណកថា

[៧៨] ម្នាលភិក្ខុទាំងឡាយ អាយតនៈទាំងពួង បុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ ម្នាលភិក្ខុទាំងឡាយ ចុះអាយតនៈទាំងពួងដែលបុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ចក្ខុ បុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ រូប ត្រូវធ្វើឲ្យជាក់ច្បាស់ ចក្ខុវិញ្ញាណ ត្រូវធ្វើឲ្យជាក់ច្បាស់ ចក្ខុសម្ផស្សត្រូវធ្វើឲ្យជាក់ច្បាស់ ការទទួលអារម្មណ៍ណា ទោះជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី រមែងកើតឡើងព្រោះចក្ខុ-សម្ផស្សជាបច្ច័យ ការទទួលអារម្មណ៍នោះឯង បុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ សោតៈ ត្រូវធ្វើឲ្យជាក់ច្បាស់ សទ្ទៈ ត្រូវធ្វើឲ្យជាក់ច្បាស់ ។ បេ ។ ឃានៈត្រូវធ្វើឲ្យជាក់ច្បាស់ គន្ធៈ ត្រូវធ្វើឲ្យជាក់ច្បាស់ ជិវ្ហា ត្រូវធ្វើឲ្យជាក់ច្បាស់ រសៈ ត្រូវធ្វើឲ្យជាក់ច្បាស់ កាយ ត្រូវធ្វើឲ្យជាក់ច្បាស់ ផោដ្ឋព្វៈ ត្រូវធ្វើឲ្យជាក់ច្បាស់ មនៈ ត្រូវធ្វើឲ្យជាក់ច្បាស់ ធម្មារម្មណ៍ ត្រូវធ្វើឲ្យជាក់ច្បាស់ មនោវិញ្ញាណ ត្រូវធ្វើឲ្យជាក់ច្បាស់ មនោសម្ផស្ស ត្រូវធ្វើឲ្យជាក់ច្បាស់ ការទទួលអារម្មណ៍ណា ទោះជាសុខក្តី ជាទុក្ខក្តី មិនជាទុក្ខមិនជាសុខក្តី រមែងកើតឡើង ព្រោះមនោសម្ផស្ស ជាបច្ច័យ ការទទួលអារម្មណ៍នោះឯង ត្រូវធ្វើឲ្យជាក់ច្បាស់ ។

បុគ្គលកាលឃើញរូប រមែងធ្វើឲ្យជាក់ច្បាស់ កាលឃើញវេទនា រមែងធ្វើឲ្យជាក់ច្បាស់ កាលឃើញសញ្ញា រមែងធ្វើឲ្យជាក់ច្បាស់

សង្ខារេ បស្សន្តោ សច្ឆិករោតិ វិញ្ញាណំ បស្សន្តោ សច្ឆិករោតិ ចក្ខុំ ។ បេ ។ ជរាមរណំ អមតោគធំ និព្វានំ បរិយោសានដ្ឋេន បស្សន្តោ សច្ឆិករោតិ យេ យេ ធម្មា សច្ឆិកតា ហោន្តិ តេ តេ ធម្មា ផុសិតា[១] ហោន្តិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ឥមេ ធម្មា សច្ឆិកាតព្វាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ ។

កថំ ឥមេ ធម្មា ហានភាគិយា ឥមេ ធម្មា ឋិតិភាគិយា ឥមេ ធម្មា វិសេសភាគិយា ឥមេ ធម្មា និព្វេធភាគិយាតិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ បឋមជ្ឈានស្ស លាភឹ កាមសហគតា សញ្ញាមនសិការា សមុទាចរន្តិ ហានភាគិយោ ធម្មោ តទនុធម្មតា សតិ សន្តិដ្ឋតិ ឋិតិភាគិយោ

---

១ ឱ. ផស្សិតា ។ ម. បស្សិតា ។

កាលឃើញសង្ខារទាំងឡាយ រមែងធ្វើឲ្យជាក់ច្បាស់ កាលឃើញវិញ្ញាណ រមែងធ្វើឲ្យជាក់ច្បាស់ ចក្ខុ ។ បេ ។ ជរានិងមរណៈ កាលឃើញ ព្រះនិព្វានដែលឈ្មោះអមតៈជាទីពឹងរបស់សត្វ ដោយអត្ថថាចប់ស្រេច (នៃសាសនា) រមែងធ្វើឲ្យជាក់ច្បាស់ ធម៌ទាំងឡាយណាៗ ដែលបុគ្គល ធ្វើឲ្យជាក់ច្បាស់ហើយ ធម៌ទាំងឡាយនោះៗ ឈ្មោះថាបុគ្គលពាល់ត្រូវ ហើយ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា ការប្រុងត្រចៀកថា ធម៌ទាំងឡាយនេះបុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ បញ្ញា ជាគ្រឿងដឹងច្បាស់ នូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតមយញ្ញាណ។

ការប្រុងត្រចៀកថា ធម៌ទាំងឡាយនេះ គប់រកនូវសេចក្តីសាប-សូន្យ ធម៌ទាំងឡាយនេះ គប់រកនូវការឋិតនៅ ធម៌ទាំងឡាយនេះ គប់រកនូវគុណវិសេស ធម៌ទាំងឡាយនេះ គប់រកនូវការទម្លុះទម្លាយកិ-លេស បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថាសុត-មយញ្ញាណ តើដូចម្តេច សញ្ញានិងមនសិការៈដែលប្រកបដោយកាមរបស់ បុគ្គលអ្នកបាននូវបឋមជ្ឈាន រមែងប្រព្រឹត្តទៅ នេះឈ្មោះថាធម៌គប់ រកនូវសេចក្តីសាបសូន្យ សតិដ៏សមគួរដល់ឈាននោះ តាំងនៅដដែល នេះឈ្មោះថា ធម៌គប់រកនូវការតាំងនៅដដែល សញ្ញានិងមនសិការៈ

៨១



ធម្មា អវិតក្កសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិសេសភាគិយោ ធម្មា និព្វិទាសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិរាគូបសញ្ហិតា និព្វេធភាគិយោ ធម្មា ទុតិយជ្ឈានស្ស លាភឹ វិតក្កសហគតា សញ្ញាមនសិការា សមុទាចរន្តិ ហានភាគិយោ ធម្មា តទនុធម្មតា សតិ សន្តិដ្ឋតិ ឋិតិភាគិយោ ធម្មា ឧបេក្ខាសុខសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិសេសភាគិយោ ធម្មា និព្វិទាសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិរាគូបសញ្ហិតា និព្វេធភាគិយោ ធម្មា តតិយជ្ឈានស្ស លាភឹ បីតិសុខសហគតា សញ្ញាមនសិការា សមុទាចរន្តិ ហានភាគិយោ ធម្មា តទនុធម្មតា សតិ សន្តិដ្ឋតិ ឋិតិភាគិយោ ធម្មា អទុក្ខមសុខសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិសេសភាគិយោ ធម្មា និព្វិទាសហគតា សញ្ញាមនសិការា សមុទាចរន្តិ

ដែលប្រទ្បំដោយឈានមិនមានវិតក្កៈ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវគុណវិសេស សញ្ញានិងមនសិការៈដែលប្រទ្បំដោយនិព្វិទាវិបស្សនា ប្រកបដោយវិរាគធម៌គឺអរិយមគ្គ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវការទម្លាយកិលេស សញ្ញានិងមនសិការៈ ដែលប្រទ្បំដោយវិតក្កៈ របស់បុគ្គលអ្នកបានទុតិយជ្ឈាន រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវសេចក្តីសាបសូន្យ សតិដ៏សមគួរដល់ឈាននោះ តាំងនៅដដែល ឈ្មោះថាធម៌គប់រកនូវការតាំងនៅដដែល សញ្ញានិងមនសិការៈដែលប្រទ្បំ ដោយឧបេក្ខានិងសុខៈ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវគុណវិសេស សញ្ញានិងមនសិការៈដែលប្រទ្បំ ដោយនិព្វិទាវិបស្សនា ប្រកបដោយវិរាគធម៌ គឺអរិយមគ្គ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវការទម្លាយកិលេស សញ្ញានិងមនសិការៈដែលប្រទ្បំដោយបីតិនិងសុខៈ របស់បុគ្គលអ្នកបានតតិយជ្ឈាន រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវសេចក្តីសោះសូន្យ សតិដ៏សមគួរដល់ឈាននោះ តាំងនៅដដែល ឈ្មោះថាធម៌គប់រកនូវការតាំងនៅដដែល សញ្ញានិងមនសិការៈ ដែលប្រទ្បំ ដោយអទុក្ខមសុខៈ គឺឧបេក្ខាភាវនា រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវគុណវិសេស សញ្ញានិងមនសិការៈ ដែលប្រទ្បំ ដោយនិព្វិទាវិបស្សនា ប្រកបដោយវិរាគធម៌គឺអរិយមគ្គ រមែងប្រព្រឹត្តទៅ

វិភត្ថបសញ្ហិតា និព្វេធភាគិយោ ធម្មោ ចតុត្ថជ្ឈានស្ស លាភឹ ឧបេក្ខាសុខសហគតា សញ្ញាមនសិការា សមុទាចរន្តិ ហានភាគិយោ ធម្មោ តទនុធម្មតា សតិ សន្តិដ្ឋតិ ឋិតិភាគិយោ ធម្មោ អាកាសានញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិសេសភាគិយោ ធម្មោ និព្វិទាសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិរាគូបសញ្ហិតា និព្វេធភាគិយោ ធម្មោ អាកាសានញ្ចាយតនស្ស លាភឹ រូបសហគតា សញ្ញាមនសិការា សមុទាចរន្តិ ហានភាគិយោ ធម្មោ តទនុធម្មតា សតិ សន្តិដ្ឋតិ ឋិតិភាគិយោ ធម្មោ វិញ្ញាណញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិសេសភាគិយោ ធម្មោ និព្វិទាសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិរាគូបសញ្ហិតា និព្វេធភាគិយោ ធម្មោ វិញ្ញាណញ្ចាយតនស្ស លាភឹ អាកាសានញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ

ឈ្មោះថាធម៌គប់រកនូវការទម្លាយកិលេស សញ្ញានិងមនសិការៈ ដែលប្រទូំដោយឧបេក្ខានិងសុខៈ របស់បុគ្គលអ្នកបាននូវចតុត្ថជ្ឈាន រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវសេចក្តីសាបសូន្យ សតិដ៏សមគួរដល់ឈាននោះ តាំងនៅដដែល ឈ្មោះថាធម៌គប់រកនូវការតាំងនៅដដែល សញ្ញានិងមនសិការៈ ដែលប្រទូំដោយអាកាសានញ្ចាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវគុណវិសេស សញ្ញានិងមនសិការៈ ដែលប្រទូំដោយនិព្វិទាវិបស្សនា ប្រកបដោយវិរាគធម៌ គឺអរិយមគ្គ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវការទម្លាយកិលេស សញ្ញានិងមនសិការៈ ដែលប្រទូំដោយរូប របស់បុគ្គលអ្នកបាននូវអាកាសានញ្ចាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវសេចក្តីសាបសូន្យ សតិដ៏សមគួរដល់ឈាននោះ តាំងនៅដដែល ឈ្មោះថាធម៌គប់រក នូវការតាំងនៅដដែល សញ្ញានិងមនសិការៈ ដែលប្រទូំដោយវិញ្ញាណញ្ចាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវគុណវិសេស សញ្ញានិងមនសិការៈ ដែលប្រទូំដោយនិព្វិទាវិបស្សនា ប្រកបដោយវិរាគធម៌គឺអរិយមគ្គ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវការទម្លាយកិលេស សញ្ញានិងមនសិការៈ ដែលប្រទូំដោយអាកាសានញ្ចាយតនៈ របស់បុគ្គលអ្នកបានវិញ្ញាណញ្ចាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថា

ហានភាគិយោ ធម្មោ តទនុធម្មតា សតិ សន្តិដ្ឋតិ ឋិតិភាគិយោ ធម្មោ អាកិញ្ចញ្ញាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិសេសភាគិយោ ធម្មោ និព្វិទាសហគតា សញ្ញាមនសិការា សមុទា-ចរន្តិ វិរាគូបសញ្ហិតា និព្វេធភាគិយោ ធម្មោ អាកិញ្ច-ញ្ញាយតនស្ស លាភី វិញ្ញាណញ្ចាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ ហានភាគិយោ ធម្មោ តទនុធម្មតា សតិ សន្តិដ្ឋតិ ឋិតិភាគិយោ ធម្មោ នេវ-សញ្ញានាសញ្ញាយតនសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិសេសភាគិយោ ធម្មោ និព្វិទាសហគតា សញ្ញាមនសិការា សមុទាចរន្តិ វិរាគូបសញ្ហិតា និព្វេ-ធភាគិយោ ធម្មោ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ឥមេ ធម្មា ហានភាគិយា ឥមេ ធម្មា ឋិតិភាគិយា ឥមេ ធម្មា វិសេសភាគិយា ឥមេ ធម្មា

ធម៌គប់រកនូវសេចក្តីសាបសូន្យ សតិដ៏សមគួរដល់ឈាននោះ តាំងនៅដដែល ឈ្មោះថាធម៌គប់រកនូវការតាំងនៅដដែល សញ្ញានិងមនសិការៈដែលច្រឡំដោយអាកិញ្ចញ្ញាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវគុណវិសេស សញ្ញានិងមនសិការៈដែលច្រឡំដោយនិព្វិទាវិបស្សនាប្រកបដោយវិរាគធម៌គឺអរិយមគ្គ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវការទម្លាយកិលេស សញ្ញានិងមនសិការៈ ដែលច្រឡំដោយវិញ្ញាណញ្ចាយតនៈ របស់បុគ្គលអ្នកបានអាកិញ្ចញ្ញាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវសេចក្តីសាបសូន្យ សតិដ៏សមគួរដល់ឈាននោះ តាំងនៅដដែល ឈ្មោះថាធម៌គប់រកនូវការតាំងនៅ សញ្ញានិងមនសិការៈដែលច្រឡំដោយនេវសញ្ញានាសញ្ញាយតនៈ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវគុណវិសេស សញ្ញានិងមនសិការៈ ដែលច្រឡំដោយនិព្វិទាវិបស្សនា ប្រកបដោយវិរាគធម៌គឺអរិយមគ្គ រមែងប្រព្រឹត្តទៅ ឈ្មោះថាធម៌គប់រកនូវការទម្លាយកិលេស ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ព្រោះហេតុនោះ លោកពោលថា ការប្រុងត្រចៀកថា ធម៌ទាំងឡាយនេះគប់រកនូវសេចក្តីសាបសូន្យ ធម៌ទាំងឡាយនេះគប់រកនូវការតាំងនៅដដែល ធម៌ទាំងឡាយនេះ គប់រកនូវគុណវិសេស ធម៌ទាំងឡាយនេះ

និព្វេធភាគិយាតិ សោតាវធានំ តំបជានធា បញ្ញា សុតមយេ ញាណំ ។

[៧៩] កាថំ សព្វេ សង្ខារា អនិច្ចា សព្វេ សង្ខារា ទុក្ខា សព្វេ ធម្មា អនត្តាតិ សោតាវធានំ តំបជានធា បញ្ញា សុតមយេ ញាណំ រូបំ អនិច្ចំ ខយដ្ឋេន ទុក្ខំ ភយដ្ឋេន អនត្តា អសារកដ្ឋេនាតិ សោតាវធានំ តំបជានធា បញ្ញា សុតមយេ ញាណំ វេទនា សញ្ញា សង្ខារា វិញ្ញាណំ ចក្ខុំ ។ បេ ។ ជរាមរណំ អនិច្ចំ ខយដ្ឋេន ទុក្ខំ ភយដ្ឋេន អនត្តា អសារ-កដ្ឋេនាតិ សោតាវធានំ តំបជានធា បញ្ញា សុត-មយេ ញាណំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ សព្វេ សង្ខារា អនិច្ចា សព្វេ សង្ខារា ទុក្ខា សព្វេ ធម្មា អនត្តាតិ សោតាវធានំ តំបជានធា បញ្ញា សុតមយេ ញាណំ ។

[៨០] កាថំ ឥទំ ទុក្ខំ អរិយសច្ចំ ឥទំ ទុក្ខ-សមុទយោ[១] អរិយសច្ចំ ឥទំ ទុក្ខនិរោធោ[២] អរិ-យសច្ចំ ឥទំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចន្តិ

---

១ ឱ. ម. ទុក្ខសមុទយំ ។ ២ ឱ. ម. ទុក្ខនិរោធំ ។

គប់រកនូវការទម្លាយកិលេស បញ្ញាជាគ្រឿងដឹងច្បាស់ នូវការប្រុងត្រ-ចៀកនោះ ឈ្មោះថាសុតមយញ្ញាណ ។

[៧៩] ការប្រុងត្រចៀកថា សង្ខារទាំងពួងមិនទៀង សង្ខារទាំងពួងជាទុក្ខ ធម៌ទាំងពួង ជាអនត្តា បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតមយញ្ញាណ តើដូចម្តេច ការប្រុងត្រចៀកថា រូបមិនទៀងដោយអត្ថថាអស់ទៅ ជាទុក្ខ ដោយអត្ថថាជាភ័យ ជាអនត្តាដោយអត្ថថាមិនមានខ្លឹម បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតមយញ្ញាណ ការប្រុងត្រចៀកថា វេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ ជរា មរណៈ មិនទៀង ដោយអត្ថថាអស់ទៅ ជាទុក្ខ ដោយអត្ថថាជាភ័យ ជាអនត្តា ដោយអត្ថថាមិនមានខ្លឹម បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតម-យញ្ញាណ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា ការប្រុងត្រចៀកថា សង្ខារទាំងពួងមិនទៀង សង្ខារទាំងពួងជាទុក្ខ ធម៌ទាំងពួងជាអនត្តា បញ្ញាជាគ្រឿងដឹងច្បាស់នូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតមយញ្ញាណ ។

[៨០] ការប្រុងត្រចៀកថា នេះទុក្ខអរិយសច្ច នេះទុក្ខសមុទយ-អរិយសច្ច នេះទុក្ខនិរោធអរិយសច្ច នេះទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច

សោតាវធានំ តំបជានធា បញ្ញា សុតមយេ ញាណំ ។

តត្ថ កតមំ ទុក្ខំ អរិយសច្ចំ ។ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ ទុក្ខោ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា[១] ទុក្ខា ។

តត្ថ កតមា ជាតិ ។ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ ឱក្កន្តិ និព្វត្តិ អភិនិព្វត្តិ ខន្ធានំ បាតុភាវោ អាយតនានំ បដិលាភោ អយំ វុច្ចតិ ជាតិ ។

តត្ថ កតមា ជរា ។ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតិ ជរា ។

---

១ ឱ. ម. បញ្ចុបាទានក្ខន្ធាបិ ។

បញ្ញាជាគ្រឿងដឹងច្បាស់ នូវការប្រុងត្រចៀកនោះ ឈ្មោះថាសុតមយ-ញាណ តើដូចម្តេច ។

បណ្តាអរិយសច្ចទាំងនោះ ទុក្ខអរិយសច្ច តើដូចម្តេច ជាតិក៏ជាទុក្ខ ជរាក៏ជាទុក្ខ មរណៈក៏ជាទុក្ខ ការសោក ការខ្សឹកខ្សួល ការលំ-បាកកាយ ការអាក់អន់ចិត្ត ការចង្អៀតចង្អល់ចិត្ត ក៏សុទ្ធតែជាទុក្ខ ការគប់ប្រសព្វដោយពួកសត្វនិងសង្ខារមិនជាទីស្រឡាញ់ក៏ជាទុក្ខ ការព្រាត់ប្រាសចាកពួកសត្វនិងសង្ខារជាទីស្រឡាញ់ក៏ជាទុក្ខ ចង់បានរបស់ណាមិនបាន ការមិនបាននោះក៏ជាទុក្ខ បើពោលដោយបំប្រួញ ឧបាទា-នក្ខន្ធទាំង ៥ ក៏ជាទុក្ខ ។

បណ្តាធម៌ទាំងនោះ ជាតិ តើដូចម្តេច ។ ការកើត ការកើតព្រម ការចុះកាន់គភ៌ ការចម្រើនឡើង ការកើតចំពោះ ការកើតប្រាកដឡើង នៃខន្ធទាំងឡាយ ការបានចំពោះនូវអាយតនៈណា នៃពួកសត្វនោះ ៗ ក្នុងសត្តនិកាយនោះៗ នេះ ហៅថា ជាតិ ។

បណ្តាធម៌ទាំងនោះ ជរា តើដូចម្តេច ។ ជរា ការគ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវ ការរួញថយអាយុ ការចាស់នៃឥន្ទ្រិយណា នៃពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ នេះហៅថា ជរា ។

តត្ថ កតមំ មរណំ ។ យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ឥទំ វុច្ចតិ មរណំ ។

[៨១] តត្ថ កតមោ សោកោ ។ យោ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោចនា សោចិតត្តំ អន្តោសោកោ អន្តោបរិសោកោ ចេតសោ បរិជ្ឈាយនា ទោមនស្សំ សោកសល្លំ អយំ វុច្ចតិ សោកោ ។

*បណ្តាធម៌ទាំងនោះ មរណៈ តើដូចម្តេច ។ ការច្យុត ការឃ្លាត ការបែកធ្លាយ ការអន្តរធាន មច្ចុ សេចក្តីស្លាប់ កាលកិរិយា ការបែកធ្លាយទៅនៃខន្ធ ការដាក់ចោលនូវសាកសព ការដាច់បង់ទៅនៃជីវិតិន្ទ្រិយណា នៃពួកសត្វនោះៗ ចាកសត្តនិកាយនោះៗ នេះហៅថា មរណៈ ។*

[៨១] *បណ្តាធម៌ទាំងនោះ ការសោក តើដូចម្តេច ។ ការសោក អាការសោកស្តាយ ភាពនៃការសោកស្តាយ ការស្ងួតស្ងប់ខាងក្នុង ការក្រៀមក្រំខាងក្នុង ការសញ្ជប់សញ្ជឹងនៃចិត្ត ការតូចចិត្ត សរគឺសេចក្តីសោកណា នៃបុគ្គលដែលត្រូវសេចក្តីវិនាសចាកញាតិប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសចាកភោគៈប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺរោគប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសចាកសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសទិដ្ឋិប៉ះពាល់ក្តី ឬប្រកបដោយសេចក្តីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ នេះ ហៅថា សោក ។*

តត្ថ កតមោ បរិទេវោ ។ យោ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ វាចាបលាបោ វិប្បលាបោ លាលប្បោ លាលប្បនា លាលប្បិតត្តំ អយំ វុច្ចតិ បរិទេវោ ។

តត្ថ កតមំ ទុក្ខំ ។ យំ កាយិកំ អសាតំ កាយិកំ ទុក្ខំ កាយសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ កាយសម្ផស្សជា អសាតា ទុក្ខា វេទនា ឥទំ វុច្ចតិ ទុក្ខំ ។

តត្ថ កតមំ ទោមនស្សំ ។ យំ ចេតសិកំ អសាតំ ចេតសិកំ ទុក្ខំ ចេតោសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ ចេតោសម្ផស្សជា អសាតា ទុក្ខា វេទនា ឥទំ វុច្ចតិ ទោមនស្សំ ។

បណ្ដាធម៌ទាំងនោះ ការខ្សឹកខ្សួល តើដូចម្ដេច ។ សេចក្ដីខ្សឹកខ្សួល ការអណ្ដឺតអណ្ដក អាការៈជាទីខ្សឹកខ្សួល អាការៈជាទីអណ្ដឺតអណ្ដក ភាពនៃសេចក្ដីខ្សឹកខ្សួល ភាពនៃសេចក្ដីអណ្ដឺតអណ្ដក ការពោលរៀបរាប់ដោយវាចា ការពោលរៀបរាប់ដដែល ៗ ការទួញយំ អាការៈជាទីទួញយំ ភាពនៃការទួញយំ របស់បុគ្គលដែលត្រូវសេចក្ដីវិនាសចាកញាតិប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសចាកភោគៈប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសគឺរោគប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសចាកសីលប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសនៃទិដ្ឋិប៉ះពាល់ក្ដី ឬប្រកបដោយសេចក្ដីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ នេះ ហៅថា ការខ្សឹកខ្សួល ។

បណ្ដាធម៌ទាំងនោះ សេចក្ដីទុក្ខ តើដូចម្ដេច ។ សេចក្ដីមិនសប្បាយកាយ សេចក្ដីលំបាកកាយ ការទទួលរងមិនសប្បាយ ជាទុក្ខដែលកើតអំពីកាយសម្ផស្ស អាការទទួលរងមិនសប្បាយ ជាទុក្ខ ដែលកើតអំពីកាយសម្ផស្ស ណា នេះ ហៅថា ទុក្ខ ។

បណ្ដាធម៌ទាំងនោះ ទោមនស្ស តើដូចម្ដេច ។ សេចក្ដីមិនសប្បាយចិត្ត ការលំបាកចិត្ត ការទទួលរងមិនសប្បាយ ជាទុក្ខ ដែលកើតអំពីមនោសម្ផ័ស្ស អាការទទួលរងមិនសប្បាយ ជាទុក្ខ ដែលកើតអំពីមនោសម្ផស្ស ណា នេះ ហៅថា ទោមនស្ស ។

តត្ថ កតមោ ឧបាយាសោ ។ យោ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាយាសោ ឧបាយាសោ[១] អាយាសិតត្តំ ឧបាយាសិតត្តំ អយំ វុច្ចតិ ឧបាយាសោ ។

[៨២] តត្ថ កតមោ អប្បិយេហិ សម្បយោគោ ទុក្ខោ ។ ឥធ យស្ស តេ ហោន្តិ អនិដ្ឋា អកន្តា អមនាបា រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា យេ វា បនស្ស តេ ហោន្តិ អនត្ថកាមា អហិតកាមា អផាសុកាមា អយោគក្ខេមកាមា យា តេហិ[២] សង្គតិ សមាគមោ សមោធានំ មិស្សីភាវោ អយំ វុច្ចតិ អប្បិយេហិ សម្បយោគោ ទុក្ខោ ។

តត្ថ កតមោ បិយេហិ វិប្បយោគោ ទុក្ខោ ។

---

១ ឱ. ម. ឯត្ថន្តរេ អាយាសនា ឧបាយាសនាតិ ទិស្សតិ ។ ២ ម. តេហិ សទ្ធឹ ។

បណ្តាធម៌ទាំងនោះ ឧបាយាសៈ (សេចក្តីចង្អៀតចង្អល់) តើដូចម្តេច ។ សេចក្តីតានតឹង ការទង្គឹះ ភាពនៃសេចក្តីតានតឹង ភាពនៃសេចក្តីទង្គឹះណា របស់បុគ្គលដែលត្រូវសេចក្តីវិនាសចាកញាតិប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសចាកភោគៈប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺរោគប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសចាកសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសនៃទិដ្ឋិប៉ះពាល់ក្តី ឬប្រកបដោយសេចក្តីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ នេះ ហៅថា ឧបាយាសៈ ។

[៨២] បណ្តាធម៌ទាំងនោះ អប្បិយេហិ សម្បយោគទុក្ខ (ការគប់ប្រសព្វដោយសត្វនិងសង្ខារទាំងឡាយមិនជាទីស្រឡាញ់ ក៏ជាទុក្ខ) តើដូចម្តេច ។ បុគ្គលនោះក្នុងលោកនេះ មានរូប សំឡេង ក្លិន រស ផ្សព្វ ណា មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ពុំនោះសោត ពួកជនណា ជាអ្នកប្រាថ្នាសេចក្តីវិនាស ប្រាថ្នាអំពើមិនជាប្រយោជន៍ ប្រាថ្នាសេចក្តីមិនសប្បាយ ប្រាថ្នាសេចក្តីមិនក្សេមចាកយោគៈ ដល់បុគ្គលនោះ ការចួបប្រទះ ការចួបជុំ ការគប់ប្រសព្វ ការច្រឡូកច្រឡំ ដោយអារម្មណ៍ទាំងនោះ ឬដោយបុគ្គលទាំងនោះឯណា នេះ ហៅថា អប្បិយេហិ សម្បយោគទុក្ខ ។

បណ្តាធម៌ទាំងនោះ បិយេហិ វិប្បយោគទុក្ខ (ការព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ក៏ជាទុក្ខ) តើដូចម្តេច ។

ឥធ យស្ស តេ ហោន្តិ ឥដ្ឋា កន្តា មនាបា រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា យេ វា បនស្ស តេ ហោន្តិ អត្ថកាមា ហិតកាមា ផាសុកាមា យោគក្ខេមកាមា មាតា វា បិតា វា ភាតា វា ភគិនី វា មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា យា តេហិ[១] អសង្គតិ អសមាគមោ អសមោធានំ អមិស្សីភាវោ អយំ វុច្ចតិ បិយេហិ វិប្បយោគោ ទុក្ខោ ។

តត្ថ កតមំ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។ ជាតិធម្មានំ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ អហោ វត មយំ ន ជាតធម្មា អស្សាម ន ច វត នោ ជាតិ អាគច្ឆេយ្យាតិ នខោ បនេតំ ឥច្ឆាយ បត្តព្វំ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ជរាធម្មានំ សត្តានំ ។ បេ ។ ព្យាធិធម្មានំ សត្តានំ មរណធម្មានំ សត្តានំ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មានំ សត្តានំ

---
១ ម. តេហិ សទ្ធឹ ។

បុគ្គលនោះ មានរូប សំឡេង ក្លិន រស ផ្សព្វ ណា ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ក្នុងលោកនេះ ពុំនោះសោត ពួកជនណាទោះជាមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី មិត្តក្តី អាមាត្យក្តី ញាតិក្តី សាលោហិតក្តី ជាអ្នកប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីសប្បាយ ប្រាថ្នានូវសេចក្តីក្សេមចាកយោគៈដល់បុគ្គលនោះ ការមិនចួបប្រទះ ការមិនជួបជុំ ការមិនគប់ប្រសព្វ ការមិនបានមូលមិត្ត ដោយអារម្មណ៍ ឬដោយពួកជនទាំងនោះ ឯណា នេះលោកហៅថា បិយេហិវិប្បយោគទុក្ខ ។

បណ្តាធម៌ទាំងនោះ បុគ្គលប្រាថ្នារបស់ណាមិនបាន ការដែលគេប្រាថ្នារបស់នោះមិនបាននោះ នាំមកនូវទុក្ខ តើដូចម្តេច ។ សត្វទាំងឡាយដែលមានជាតិជាធម្មតា តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ សូមឲ្យយើងទាំងឡាយ កុំមានជាតិជាធម្មតា ឬថាជាតិមិនគប្បីមកដល់យើងទាំងឡាយ ដំណើរនុ៎ះ ពួកសត្វមិនគប្បីសម្រេចបានតាមប្រាថ្នាឡើយ ហេតុនេះឯង ទើបឈ្មោះថាបុគ្គលប្រាថ្នារបស់ណា មិនបាន ការដែលគេប្រាថ្នារបស់នោះមិនបាននោះឯង នាំមកនូវទុក្ខ ពួកសត្វមានជរាជាធម្មតា ។ បេ ។ ពួកសត្វមានព្យាធិជាធម្មតា ពួកសត្វមានមរណៈជាធម្មតា ពួកសត្វមានសោកបរិទេវទុក្ខទោមនស្សុបាយាសៈ ជាធម្មតា

ឯវំ ឥច្ឆា ឧប្បជ្ជតិ អហោ វត មយំ ន សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មា អស្សាម ន ច វត នោ សោកបរិទេវទុក្ខទោមនស្សុបាយាសា អាគច្ឆេយ្យុន្តិ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។

តត្ថ កតមេ សំខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។ សេយ្យថីទំ រូបូបាទានក្ខន្ធោ វេទនូបាទានក្ខន្ធោ សញ្ញូបាទានក្ខន្ធោ សង្ខារូបាទានក្ខន្ធោ វិញ្ញាណូបាទានក្ខន្ធោ ឥមេ វុច្ចន្តិ សំខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ឥទំ វុច្ចតិ ទុក្ខំ អរិយសច្ចំ ។

[៨៣] តត្ថ កតមំ ទុក្ខសមុទយោ អរិយសច្ចំ ។ យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា សា ខោ បនេសា តណ្ហា កត្ថ ឧប្បជ្ជមានា ឧប្បជ្ជតិ កត្ថ និវិសមានា និវិសតិ យំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា

តែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ សូមឲ្យយើងទាំងឡាយកុំមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ការចង្អៀតចង្អល់ ឬថា សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ការចង្អៀតចង្អល់មិនគប្បីមកដល់យើងទាំងឡាយឡើយ ដំណើរនុ៎ះ ពួកសត្វមិនគប្បីសម្រេចបានតាមប្រាថ្នាឡើយ នេះឯង ឈ្មោះថាបុគ្គលប្រាថ្នារបស់ណាមិនបានការដែលគេប្រាថ្នារបស់នោះ មិនបាននោះ នាំមកនូវទុក្ខ ។

បណ្តាធម៌ទាំងនោះ បើដោយសេចក្តីបំប្រួញ ឧបាទានក្ខន្ធទាំង ៥ នាំមកនូវទុក្ខ តើដូចម្តេច ។ រូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ទាំងនេះឈ្មោះថាឧបាទានក្ខន្ធទាំង ៥ នាំមកនូវទុក្ខ ដោយសេចក្តីបំប្រួញ នេះលោកហៅថា ទុក្ខអរិយសច្ច ។

[៨៣] បណ្តាអរិយសច្ចទាំងនោះ ទុក្ខសមុទយអរិយសច្ច តើដូចម្តេច ។ តណ្ហាណា ជាកិលេសជាតិនាំសត្វឲ្យកើតក្នុងភពថ្មីទៀត ប្រកបដោយនន្ទិរាគ ត្រេកត្រអាលក្នុងអារម្មណ៍នោះ ៗ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ តណ្ហានោះឯង កាលកើតឡើង តើកើតឡើងក្នុងអារម្មណ៍ណា កាលជាប់នៅ តើជាប់នៅក្នុងអារម្មណ៍ណា អារម្មណ៍ណាមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង ក៏កើតឡើងក្នុងអារម្មណ៍នុ៎ះ

ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ កិញ្ច លោកេ បិយរូបំ សាតរូបំ ចក្ខុំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ សោតំ លោកេ ឃានំ លោកេ ជិវ្ហា លោកេ កាយោ លោកេ មនោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ រូបា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ សទ្ទា លោកេ ។ បេ ។ ធម្មា លោកេ ចក្ខុវិញ្ញា-ណំ លោកេ ។ បេ ។ មនោវិញ្ញាណំ លោកេ ចក្ខុសម្ផស្សោ លោកេ ។ បេ ។ មនោសម្ផស្សោ លោកេ ចក្ខុសម្ផស្សជា វេទនា លោកេ ។ បេ ។ មនោសម្ផស្សជា វេទនា លោកេ រូបសញ្ញា លោកេ ។ បេ ។ ធម្មសញ្ញា លោកេ រូបសញ្ចេតនា លោកេ ។ បេ ។ ធម្មសញ្ចេតនា លោកេ រូប-តណ្ហា លោកេ ។ បេ ។ ធម្មតណ្ហា លោកេ រូបវិតក្កោ លោកេ ។ បេ ។ ធម្មវិតក្កោ លោកេ

កាលជាប់នៅ ក៏ជាប់នៅក្នុងអារម្មណ៍នុ៎ះ ចុះអារម្មណ៍ដូចម្ដេច មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក ចក្ខុមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង រមែងកើតឡើងក្នុងចក្ខុនុ៎ះ កាលជាប់នៅ រមែងជាប់នៅក្នុងចក្ខុនុ៎ះ សោតៈក្នុងលោក ឃានៈក្នុងលោក ជិវ្ហាក្នុងលោក កាយក្នុងលោក មនៈ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង ក៏កើតឡើងក្នុងសោតៈជាដើមនុ៎ះ កាលជាប់នៅ ក៏ជាប់នៅក្នុងសោតៈជាដើមនុ៎ះ រូបទាំងឡាយ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង ក៏កើតឡើងក្នុងរូបនុ៎ះ កាលជាប់នៅ ក៏ជាប់នៅក្នុងរូបនុ៎ះ សទ្ទៈក្នុងលោក ។ បេ ។ ធម្មារម្មណ៍ក្នុងលោក ចក្ខុវិញ្ញាណ ក្នុងលោក ។ បេ ។ មនោវិញ្ញាណ ក្នុងលោក ចក្ខុសម្ផស្ស ក្នុងលោក ។ បេ ។ មនោសម្ផស្ស ក្នុងលោក វេទនាកើតអំពីចក្ខុសម្ផស្ស ក្នុងលោក ។ បេ ។ វេទនាកើតអំពីមនោសម្ផស្ស ក្នុងលោក រូបសញ្ញា ក្នុងលោក ។ បេ ។ ធម្មសញ្ញា ក្នុងលោក រូបសញ្ចេតនាក្នុងលោក ។ បេ ។ ធម្មសញ្ចេតនា ក្នុងលោក រូបតណ្ហាក្នុងលោក ។ បេ ។ ធម្មតណ្ហាក្នុងលោក រូបវិតក្កៈ ក្នុងលោក ។ បេ ។ ធម្មវិតក្កៈ ក្នុងលោក

រូបវិចារោ លោកេ ។ បេ ។ ធម្មវិចារោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ឥទំ វុច្ចតិ ទុក្ខសមុទយោ អរិយសច្ចំ ។

[៨៤] តត្ថ កាតមំ ទុក្ខនិរោធោ អរិយសច្ចំ ។ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ សា ខោ បនេសា តណ្ហា កត្ថ បហីយមានា បហីយតិ កត្ថ និរុជ្ឈមានា និរុជ្ឈតិ យំ លោកេ បិយរូបំ សាត-រូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ[១] ចក្ខុំ លោកេ បិយរូបំ សា-តរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ សោតំ លោកេ ។ បេ ។ ធម្មវិ-ចារោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ឥទំ វុច្ចតិ ទុក្ខនិរោធោ អរិយសច្ចំ ។

---

១ ឱ. ម. ឯត្ថន្តរេ កិញ្ចិ លោកេ បិយរូបំ សាតរូបន្តិ ទិស្សតិ ។

រូបវិចារៈ ក្នុងលោក ។ បេ ។ ធម្មវិចារៈ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ក្នុងលោក តណ្ហានុ៎ះ កាលកើតឡើង ក៏កើតឡើងក្នុងសទ្ទារម្មណ៍ជាដើមនុ៎ះ កាលជាប់នៅ ក៏ជាប់នៅក្នុងសទ្ទារម្មណ៍ជាដើមនុ៎ះ នេះ លោកហៅថា ទុក្ខសមុទយអរិយសច្ច ។

[៨៤] បណ្ដាអរិយសច្ចទាំងនោះ ទុក្ខនិរោធអរិយសច្ច តើដូចម្ដេច ។ ការរលត់ដោយអរិយមគ្គឥតសេសសល់ ការលះបង់ ការរលាស់ចេញ ការរួចស្រឡះ សេចក្ដីមិនមានអាល័យ នៃតណ្ហានោះឯណា ក៏តណ្ហានោះឯង កាលបុគ្គលលះបង់ តើលះបង់ក្នុងអារម្មណ៍ណា កាលរលត់ទៅ តើរលត់ទៅក្នុងអារម្មណ៍ណា អារម្មណ៍ណា មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងអារម្មណ៍នុ៎ះ កាលរលត់ទៅ រមែងរលត់ទៅក្នុងអារម្មណ៍នុ៎ះ ចក្ខុមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងចក្ខុនុ៎ះ កាលរលត់ទៅ រមែងរលត់ទៅក្នុងចក្ខុនុ៎ះ សោតៈក្នុងលោក ។ បេ ។ ធម្មវិចារៈ មានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរក្នុងលោក តណ្ហានុ៎ះ កាលបុគ្គលលះបង់ រមែងលះបង់ក្នុងសោតៈជាដើមនុ៎ះ កាលរលត់ទៅ រមែងរលត់ទៅក្នុងសោតៈជាដើមនុ៎ះ នេះ លោកហៅថា ទុក្ខនិរោធអរិយសច្ច ។

[៨៩] តត្ថ កាតមំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មា-សតិ សម្មាសមាធិ ។

តត្ថ កាតមា សម្មាទិដ្ឋិ ។ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខ-និរោធគាមិនិយា បដិបទាយ ញាណំ អយំ វុច្ចតិ សម្មាទិដ្ឋិ ។

តត្ថ កាតមោ សម្មាសង្កប្បោ ។ នេក្ខម្មសង្កប្បោ អព្យាបាទសង្កប្បោ អវិហឹសាសង្កប្បោ អយំ វុច្ចតិ សម្មាសង្កប្បោ ។

តត្ថ កាតមា សម្មាវាចា ។ មុសាវាទា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរ-មណី សម្ផប្បលាបា វេរមណី អយំ វុច្ចតិ សម្មាវាចា ។

តត្ថ កាតមោ សម្មាកម្មន្តោ ។ បាណា-តិបាតា វេរមណី អទិន្នាទានា វេរមណី

[៨៥] បណ្ដាអរិយសច្ចទាំងនោះ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច តើដូចម្ដេច ។ អរិយមគ្គមានអង្គ ៨ នេះឯង គឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។

បណ្ដាអរិយមគ្គទាំងនោះ សម្មាទិដ្ឋិ តើដូចម្ដេច ។ ការដឹងច្បាស់ក្នុងកងទុក្ខ ការដឹងច្បាស់ក្នុងហេតុជាទីកើតឡើងនៃកងទុក្ខ ការដឹងច្បាស់ ក្នុងទីរលត់នៃកងទុក្ខ ការដឹងច្បាស់ក្នុងផ្លូវប្រតិបត្តិជាដំណើរទៅកាន់ទីរលត់កងទុក្ខ នេះ លោកហៅថា សម្មាទិដ្ឋិ ។

បណ្ដាអរិយមគ្គ ទាំងនោះ សម្មាសង្កប្បៈ តើដូចម្ដេច ។ នេក្ខម្មសង្កប្បៈ (ការត្រិះរិះក្នុងការចេញចាកកាម) អព្យាបាទសង្កប្បៈ (ការត្រិះរិះក្នុងការមិនព្យាបាទ) អវិហឹសាសង្កប្បៈ (ការត្រិះរិះក្នុងការមិនបៀតបៀន) នេះ លោកហៅថា សម្មាសង្កប្បៈ ។

បណ្ដាអរិយមគ្គទាំងនោះ សម្មាវាចា តើដូចម្ដេច ។ ចេតនាជាហេតុវៀរចាកមុសាវាទ ចេតនាជាហេតុវៀរចាកបិសុណាវាចា ចេតនាជាហេតុវៀរចាកផរុសវាចា ចេតនាជាហេតុវៀរចាកសម្ផប្បលាបៈ នេះ លោកហៅថា សម្មាវាចា ។

បណ្ដាអរិយមគ្គទាំងនោះ សម្មាកម្មន្តៈ តើដូចម្ដេច ។ ចេតនាជាហេតុវៀរចាកបាណាតិបាត ចេតនាជាហេតុវៀរចាកអទិន្នាទាន

កាមេសុ មិច្ឆាចារា វេរមណី អយំ វុច្ចតិ សម្មា-
កម្មន្តោ ។

តត្ថ កតមោ សម្មាអាជីវោ ។ ឥធ អរិយសាវ-
កោ មិច្ឆាអាជីវំ បហាយ សម្មាអាជីវេន ជីវិតំ
កប្បេតិ អយំ វុច្ចតិ សម្មាអាជីវោ ។

តត្ថ កតមោ សម្មាវាយាមោ ។ ឥធ ភិក្ខុ
អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បា-
ទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ
បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុស-
លានំ ធម្មានំ បហានាយ ។ បេ ។ អនុប្បន្នានំ
កុសលានំ ធម្មានំ ឧប្បាទាយ ។ បេ ។ ឧប្បន្នានំ
កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោ-
ភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ
វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ
អយំ វុច្ចតិ សម្មាវាយាមោ ។

តត្ថ កតមា សម្មាសតិ ។ ឥធ ភិក្ខុ កាយេ
កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា
វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ

ចេតនាជាហេតុវៀរចាកកាមេសុមិច្ឆាចារ នេះ លោកហៅថា សម្មា-កម្មន្តៈ ។

បណ្តាអរិយមគ្គទាំងនោះ សម្មាអាជីវៈ តើដូចម្តេច ។ អរិយ-សាវ័ក ក្នុងសាសនានេះ លះបង់ការចិញ្ចឹមជីវិតខុស សម្រេចនូវការចិញ្ចឹមជីវិតដោយការចិញ្ចឹមជីវិតត្រូវ នេះ លោកហៅថា សម្មាអាជីវៈ ។

បណ្តាអរិយមគ្គទាំងនោះ សម្មាវាយាមៈ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ រមែងបង្កើតឆន្ទៈ ប្រឹងប្រែងប្រារព្ធព្យាយាម ផ្គងតម្កល់ចិត្ត ដើម្បីញុាំងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ដើម្បីលះបង់នូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ។ បេ ។ ដើម្បីញុាំងពួកកុសលធម៌ ដែលមិនទាន់កើតឡើងឲ្យកើតឡើង ។ បេ ។ ភិក្ខុ រមែងបង្កើតឆន្ទៈ ប្រឹងប្រែងប្រារព្ធព្យា-យាម ផ្គង តម្កល់ចិត្ត ដើម្បីឋិតនៅ ដើម្បីមិនឲ្យវិនាស ដើម្បីឲ្យចម្រើនក្រៃលែង ដើម្បីធំទូលាយ ដើម្បីចម្រើន ដើម្បីបំពេញនូវពួកកុសលធម៌ ដែលកើតឡើងហើយ នេះ លោកហៅថា សម្មាវាយាមៈ ។

បណ្តាអរិយមគ្គទាំងនោះ សម្មាសតិ តើដូចម្តេច ។ ភិក្ខុក្នុងសាស-នានេះ ជាអ្នកពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតីកម្ចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ក្នុងវេទនាទាំងឡាយ

មហាវគ្គេ ញាណកថា

។ បេ ។ ចិត្តេ ។ បេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ អយំ វុច្ចតិ សម្មាសតិ ។

តត្ថ កតមោ សម្មាសមាធិ ។ ឥធ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជម្បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិ-ជម្បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្ប-ជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយជ្ឈា-នំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ

។ បេ ។ ក្នុងចិត្ត ។ បេ ។ ពិចារណាឃើញរឿយ ៗ នូវធម៌ ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក នេះ លោកហៅថា សម្មាសតិ ។

បណ្តាអរិយមគ្គទាំងនោះ សម្មាសមាធិ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំង-ឡាយ បានសម្រេចបឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងាត់ បានសម្រេចទុតិយជ្ឈាន ជាធម្ម-ជាតកើតមានខាងក្នុងសន្តាន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតនិងសុខៈ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ព្រោះរម្ងាប់នូវវិតក្កៈ វិចារៈ ជាអ្នកព្រងើយកន្តើយផង មានស្មារតីដឹងខ្លួនផង ព្រោះលះបង់បីតិ រមែងទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំង-ឡាយ តែងសរសើរភិក្ខុនោះថា ជាអ្នកមានចិត្តប្រកបដោយឧបេក្ខា មានស្មារតី មានការនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ភិក្ខុនោះក៏បានសម្រេចតតិយជ្ឈាននោះ ព្រោះលះបង់សុខផង លះបង់ទុក្ខផង ព្រោះវិនាសទៅនៃសោមនស្ស និងទោមនស្ស ក្នុងកាលមុន

អដ្ឋង្គមា អទុក្ខមសុខំ ឧបេក្ខាសតិចារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ សម្មាសមាធិ ឥទំ វុច្ចតិ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ។ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ឥទំ ទុក្ខំ អរិយសច្ចំ ឥទំ ទុក្ខសមុទយោ អរិយសច្ចំ ឥទំ ទុក្ខនិរោធោ អរិយសច្ចំ ឥទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចន្តិ សោតាវធានំ តំបជាននា បញ្ញា សុតមយេ ញាណំ ឯវំ សោតាវធានេ បញ្ញា សុតមយេ ញាណំ ។

[៨៦] កថំ សុត្វាន សំវរេ បញ្ញា សីលមយេ ញាណំ បញ្ច សីលានិ បរិយន្តចារិសុទ្ធិសីលំ អបរិយន្តចារិសុទ្ធិសីលំ បរិបុណ្ណចារិសុទ្ធិសីលំ អបរាមដ្ឋចារិសុទ្ធិសីលំ បដិប្បស្សទ្ធិចារិសុទ្ធិសីលន្តិ ។

តត្ថ កតមំ បរិយន្តចារិសុទ្ធិសីលំ ។ អនុបសម្បន្នានំ បរិយន្តសិក្ខាបទានំ ឥទំ បរិយន្តចារិសុទ្ធិសីលំ ។

កតមំ អបរិយន្តចារិសុទ្ធិសីលំ ។ ឧបសម្បន្នានំ អបរិយន្តសិក្ខាបទានំ ឥទំ អបរិយន្តចារិសុទ្ធិសីលំ ។

ភិក្ខុនោះ ក៏បានសម្រេចចតុត្ថជ្ឈាន ដែលមិនមានទុក្ខ មិនមានសុខ មាន តែសតិដ៏បរិសុទ្ធដោយឧបេក្ខា នេះលោកហៅថា សម្មាសមាធិ នេះ លោកហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ ដែលឈ្មោះថា ញាណ ដោយអត្ថថាដឹង នូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថា ដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា ការប្រុងត្រចៀកថា នេះទុក្ខអរិយសច្ច នេះទុក្ខសមុទយអរិយសច្ច នេះទុក្ខនិរោធអរិយសច្ច នេះទុក្ខនិរោធគាមិនីបដិទាអរិយសច្ច បញ្ញាជាគ្រឿងដឹងច្បាស់ នូវការ ប្រុងត្រចៀកនោះ ឈ្មោះថាសុតមយញ្ញាណ បញ្ញាក្នុងការប្រុងត្រចៀក ឈ្មោះថាសុតមយញ្ញាណ យ៉ាងនេះឯង ។

[៨៦] បញ្ញា ក្នុងការស្តាប់ហើយសង្រួម ឈ្មោះថាសីល-មយញ្ញាណ តើដូចម្តេច សីល ៥ គឺ បរិយន្តបារិសុទ្ធិសីល ១ អបរិ-យន្តបារិសុទ្ធិសីល ១ បរិបុណ្ណបារិសុទ្ធិសីល ១ អបរាមដ្ឋបារិសុទ្ធិសីល ១ បដិប្បស្សទ្ធិបារិសុទ្ធិសីល ១ ។

បណ្តាសីលទាំង ៥ នោះ បរិយន្តបារិសុទ្ធិសីល តើដូចម្តេច ។ សីលរបស់អនុបសម្បន្នទាំងឡាយ ដែលមានសិក្ខាបទមានទីបំផុត នេះ ឈ្មោះថាបរិយន្តបារិសុទ្ធិសីល ។

អបរិយន្តបារិសុទ្ធិសីល តើដូចម្តេច ។ សីលរបស់ឧបសម្បន្ន ទាំងឡាយ ដែលមានសិក្ខាបទមិនមានទីបំផុត នេះ ឈ្មោះថាអបរិ-យន្តបារិសុទ្ធិសីល ។

កតមំ បរិបុណ្ណចារិសុទ្ធិសីលំ ។ បុថុជ្ជនកល្យាណកានំ កុសលធម្មេ យុត្តានំ អសេក្ខបរិយន្តេ បរិបូរកានំ(១) កាយេ ច ជីវិតេ ច អនបេក្ខានំ បរិច្ចត្តជីវិតានំ ឥទំ បរិបុណ្ណចារិសុទ្ធិសីលំ ។

កតមំ អបរាមដ្ឋចារិសុទ្ធិសីលំ ។ សត្តន្នំ សេក្ខានំ ឥទំ អបរាមដ្ឋចារិសុទ្ធិសីលំ ។

កតមំ បដិប្បស្សទ្ធិចារិសុទ្ធិសីលំ ។ តថាគតសាវកានំ ខីណាសវានំ បច្ចេកពុទ្ធានំ តថាគតានំ អរហន្តានំ សម្មាសម្ពុទ្ធានំ ឥទំ បដិប្បស្សទ្ធិចារិសុទ្ធិសីលំ ។

[៨៧] អត្ថិ សីលំ បរិយន្តំ អត្ថិ សីលំ អបរិយន្តំ ។ តត្ថ កតមន្តំ សីលំ បរិយន្តំ ។ អត្ថិ សីលំ លាភបរិយន្តំ អត្ថិ សីលំ យសបរិយន្តំ អត្ថិ សីលំ ញាតិបរិយន្តំ អត្ថិ សីលំ អង្គបរិយន្តំ អត្ថិ សីលំ ជីវិតបរិយន្តំ ។

កតមន្តំ សីលំ លាភបរិយន្តំ ។ ឥធេកច្ចោ លាភហេតុ លាភប្បច្ចយា លាភការណា យថាសមាទិន្នំ សិក្ខាបទំ វីតិក្កមតិ ឥទន្តំ សីលំ លាភបរិយន្តំ ។

---

១ ឱ. ម. សេក្ខបរិយន្តេ ។ បរិបូរការីនំ ។

បរិបុណ្ណបារិសុទ្ធិសីល តើដូចម្តេច ។ សីលរបស់កល្យាណបុថុជ្ជន ទាំងឡាយ ដែលប្រកបក្នុងកុសលធម៌ ជាអ្នកបំពេញក្នុងអសេក្ខបរិយន្ត-សីល មិនស្តាយកាយនិងជីវិត ជាអ្នកមានជីវិតលះបង់ហើយ នេះ ឈ្មោះថាបរិបុណ្ណបារិសុទ្ធិសីល ។

អបរាមដ្ឋបារិសុទ្ធិសីល តើដូចម្តេច ។ សីលរបស់សេក្ខបុគ្គល ៧ ពួក នេះ ឈ្មោះថាអបរាមដ្ឋបារិសុទ្ធិសីល ។

បដិប្បស្សទ្ធិបារិសុទ្ធិសីល តើដូចម្តេច ។ សីលរបស់ព្រះខីណា-ស្រព ជាសាវ័កនៃព្រះតថាគត របស់ព្រះបច្ចេកពុទ្ធ របស់ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នេះ ឈ្មោះថាបដិប្បស្សទ្ធិបារិសុទ្ធិសីល ។

[៨៧] សីលមានទីបំផុតក៏មាន សីលមិនមានទីបំផុតក៏មាន ។ បណ្តាសីលទាំង ២ យ៉ាងនោះ សីលមានទីបំផុតនោះ តើដូចម្តេច ។ សីលមានលាភជាទីបំផុតក៏មាន សីលមានយសជាទីបំផុតក៏មាន សីល មានញាតិជាទីបំផុតក៏មាន សីលមានអវយវៈជាទីបំផុតក៏មាន សីលមាន ជីវិតជាទីបំផុតក៏មាន ។

សីលមានលាភជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោក នេះ ប្រព្រឹត្តកន្លងនូវសិក្ខាបទ ដែលខ្លួនសមាទានហើយ ព្រោះហេតុ នៃលាភ ព្រោះលាភជាបច្ច័យ ព្រោះលាភជាហេតុ នេះ ឈ្មោះថា សីលមានលាភជាទីបំផុត ។

កាតមន្តំ សីលំ យសបរិយន្តំ ។ ឥធេកច្ចោ យសហេតុ យសប្បច្ចយា យសការណា យថាសមាទិន្នំ សិក្ខាបទំ វីតិក្កមតិ ឥទន្តំ សីលំ យសបរិយន្តំ ។

កាតមន្តំ សីលំ ញាតិបរិយន្តំ ។ ឥធេកច្ចោ ញាតិហេតុ ញាតិប្បច្ចយា ញាតិការណា យថាសមាទិន្នំ សិក្ខាបទំ វីតិក្កមតិ ឥទន្តំ សីលំ ញាតិបរិយន្តំ ។

កាតមន្តំ សីលំ អង្គបរិយន្តំ ។ ឥធេកច្ចោ អង្គហេតុ អង្គប្បច្ចយា អង្គការណា យថាសមាទិន្នំ សិក្ខាបទំ វីតិក្កមតិ ឥទន្តំ សីលំ អង្គបរិយន្តំ ។

កាតមន្តំ សីលំ ជីវិតបរិយន្តំ ។ ឥធេកច្ចោ ជីវិតហេតុ ជីវិតប្បច្ចយា ជីវិតការណា យថាសមាទិន្នំ សិក្ខាបទំ វីតិក្កមតិ ឥទន្តំ សីលំ ជីវិតបរិយន្តំ ។ ឯវរូបានិ សីលានិ ខណ្ឌានិ ឆិទ្ទានិ សពលានិ កម្មាសានិ ន កុជិស្សានិ

សីលមានយសជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ប្រព្រឹត្តកន្លងនូវសិក្ខាបទ ដែលខ្លួនសមាទានហើយ ព្រោះហេតុនៃយស ព្រោះយសជាបច្ច័យ ព្រោះយសជាហេតុ នេះ ឈ្មោះថាសីលមានយសជាទីបំផុត ។

សីលមានញាតិជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ ប្រព្រឹត្តកន្លងនូវសិក្ខាបទ ដែលខ្លួនសមាទានហើយ ព្រោះហេតុនៃញាតិ ព្រោះញាតិជាបច្ច័យ ព្រោះញាតិជាហេតុ នេះ ឈ្មោះថាសីលមានញាតិជាទីបំផុត ។

សីលមានអវយវៈជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តកន្លងនូវសិក្ខាបទ ដែលខ្លួនសមាទានហើយ ព្រោះហេតុនៃអវយវៈ ព្រោះអវយវៈជាបច្ច័យ ព្រោះអវយវៈជាហេតុ នេះ ឈ្មោះថាសីលមានអវយវៈជាទីបំផុត ។

សីលមានជីវិតជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តកន្លងនូវសិក្ខាបទ ដែលខ្លួនសមាទានហើយ ព្រោះហេតុនៃជីវិត ព្រោះជីវិតជាបច្ច័យ ព្រោះជីវិតជាហេតុ នេះ ឈ្មោះថាសីលមានជីវិតជាទីបំផុត ។ សីលទាំងឡាយមានសភាពយ៉ាងនេះ ជាសីលដាច់ សីលធ្លុះ សីលពពាល សីលពព្រុស មិនមែនជាសីលរបស់អ្នកជា

ន វិញ្ញុបសត្ថានិ បរាមដ្ឋានិ អសមាធិសំវត្តនិកានិ ន អវិប្បដិសារវត្ថុកានិ ន បាមុជ្ជវត្ថុកានិ ន បីតិ-វត្ថុកានិ ន បស្សទ្ធិវត្ថុកានិ ន សុខវត្ថុកានិ ន សមាធិវត្ថុកានិ ន យថាភូតញាណទស្សនវត្ថុកានិ ន ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ[១] សំវត្តន្តិ ឥទន្តំ សីលំ បរិយន្តំ ។

[៨៨] កាតមន្តំ សីលំ អបរិយន្តំ ។ អត្ថិ សីលំ ន លាភបរិយន្តំ អត្ថិ សីលំ ន យសបរិយន្តំ អត្ថិ សីលំ ន ញាតិបរិយន្តំ អត្ថិ សីលំ ន អង្គបរិយន្តំ អត្ថិ សីលំ ន ជីវិតបរិយន្តំ ។

កាតមន្តំ សីលំ ន លាភបរិយន្តំ ។ ឥធេកច្ចោ លាភហេតុ លាភប្បច្ចយា លាភការណា យថាសមា-ទិន្នំ សិក្ខាបទំ វីតិក្កមាយ ចិត្តំបិ ន ឧប្បាទេតិ កឹ សោ វីតិក្កមិស្សតិ ឥទន្តំ សីលំ ន លាភបរិយន្តំ ។

កាតមន្តំ សីលំ ន យសបរិយន្តំ ។ ឥធេកច្ចោ

១ ឱ. ម. ន វិរាគាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ ។

មិនមែនជាសីល ដែលវិញ្ញូជនសរសើរទេ ជាសីលដែលតណ្ហានិងទិដ្ឋិបបោសអង្អែល ជាសីលមិនប្រព្រឹត្តទៅ ដើម្បីសមាធិ មិនមែនជាទីតាំងនៃសេចក្តីមិនក្តៅក្រហាយ មិនមែនជាទីតាំងនៃបាមោជ្ជៈ មិនមែនជាទីតាំងនៃបីតិ មិនមែនជាទីតាំងនៃបស្សទ្ធិ មិនមែនជាទីតាំងនៃសុខៈ មិនមែនជាទីតាំងនៃសមាធិ មិនមែនជាទីតាំងនៃយថាភូតញ្ញាណទស្សនៈ មិនមែនប្រព្រឹត្តទៅ ដើម្បីនិព្វិទាដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីនិរោធ ដើម្បីសេចក្តីស្ងប់ស្ងាត់ ដើម្បីអភិញ្ញា ដើម្បីការត្រាស់ដឹង ដើម្បីនិព្វានឡើយ នេះ ឈ្មោះថាសីលមានទីបំផុត ។

[៨៨] សីលមិនមានទីបំផុតនោះ តើដូចម្តេច ។ សីលមិនមានលាភជាទីបំផុតក៏មាន សីលមិនមានយសជាទីបំផុតក៏មាន សីលមិនមានញាតិជាទីបំផុតក៏មាន សីលមិនមានអវយវៈជាទីបំផុតក៏មាន សីលមិនមានជីវិតជាទីបំផុតក៏មាន ។

សីលមិនមានលាភជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនញុំាងចិត្តឲ្យកើតឡើង ដើម្បីប្រព្រឹត្តកន្លងសិក្ខាបទដែលខ្លួនសមាទានហើយ ព្រោះហេតុនៃលាភ ព្រោះលាភជាបច្ច័យ ព្រោះដំណើរលាភទេ តើបុគ្គលនោះ នឹងប្រព្រឹត្តកន្លងដូចម្តេចបាន នេះ ឈ្មោះថាសីលមិនមានលាភជាទីបំផុត ។

សីលមិនមានយសជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុង

យសហេតុ យសប្បច្ចយា យសការណា យថាសមាទិន្នំ សិក្ខាបទំ វីតិក្កមាយ ចិត្តំបិ ន ឧប្បាទេតិ កឹ សោ វីតិក្កមិស្សតិ ឥទន្តំ សីលំ ន យសបរិយន្តំ ។

កតមន្តំ សីលំ ន ញាតិបរិយន្តំ ។ ឥធេកច្ចោ ញាតិហេតុ ញាតិប្បច្ចយា ញាតិការណា យថាសមាទិន្នំ សិក្ខាបទំ វីតិក្កមាយ ចិត្តំបិ ន ឧប្បាទេតិ កឹ សោ វីតិក្កមិស្សតិ ឥទន្តំ សីលំ ន ញាតិបរិយន្តំ ។

កតមន្តំ សីលំ ន អង្គបរិយន្តំ ។ ឥធេកច្ចោ អង្គហេតុ អង្គប្បច្ចយា អង្គការណា យថាសមាទិន្នំ សិក្ខាបទំ វីតិក្កមាយ ចិត្តំបិ ន ឧប្បាទេតិ កឹ សោ វីតិក្កមិស្សតិ ឥទន្តំ សីលំ ន អង្គបរិយន្តំ ។

កតមន្តំ សីលំ ន ជីវិតបរិយន្តំ ។ ឥធេកច្ចោ ជីវិតហេតុ ជីវិតប្បច្ចយា ជីវិតការណា យថាសមាទិន្នំ សិក្ខាបទំ វីតិក្កមាយ ចិត្តំបិ ន ឧប្បាទេតិ កឹ សោ វីតិក្កមិស្សតិ ឥទន្តំ សីលំ ន ជីវិតបរិយន្តំ ។

លោកនេះ មិនញ៉ាំងចិត្តឲ្យកើតឡើង ដើម្បីប្រព្រឹត្តកន្លងនូវសិក្ខាបទដែលខ្លួនសមាទានហើយ ព្រោះហេតុនៃយស ព្រោះយសជាបច្ច័យ ព្រោះដំណើរយសទេ តើបុគ្គលនោះ នឹងប្រព្រឹត្តកន្លងដូចម្តេច នេះឈ្មោះថាសីលមិនមានយសជាទីបំផុត ។

សីលមិនមានញាតិជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ មិនញ៉ាំងចិត្តឲ្យកើតឡើង ដើម្បីកន្លងនូវសិក្ខាបទ ដែលខ្លួនសមាទានហើយ ព្រោះហេតុនៃញាតិ ព្រោះញាតិជាបច្ច័យ ព្រោះដំណើរញាតិទេ តើបុគ្គលនោះ នឹងប្រព្រឹត្តកន្លងដូចម្តេចបាន នេះឈ្មោះថាសីលមិនមានញាតិជាទីបំផុត ។

សីលមិនមានអវយវៈជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ មិនញ៉ាំងចិត្តឲ្យកើតឡើង ដើម្បីប្រព្រឹត្តកន្លងនូវសិក្ខាបទដែលខ្លួនសមាទានហើយ ព្រោះហេតុនៃអវយវៈ ព្រោះអវយវៈជាបច្ច័យ ព្រោះដំណើរអវយវៈទេ តើបុគ្គលនោះ នឹងប្រព្រឹត្តកន្លងដូចម្តេចបាន នេះ ឈ្មោះថាសីលមិនមានអវយវៈជាទីបំផុត ។

សីលមិនមានជីវិតជាទីបំផុតនោះ តើដូចម្តេច ។ បុគ្គលខ្លះ ក្នុងលោកនេះ មិនញ៉ាំងចិត្តឲ្យកើតឡើង ដើម្បីប្រព្រឹត្តកន្លងនូវសិក្ខាបទដែលខ្លួនសមាទានហើយ ព្រោះហេតុនៃជីវិត ព្រោះជីវិតជាបច្ច័យ ព្រោះដំណើរជីវិត តើបុគ្គលនោះ នឹងប្រព្រឹត្តកន្លងដូចម្តេចបាន នេះឈ្មោះថាសីលមិនមានជីវិតជាទីបំផុត ។

ឯវរូបានិ សីលានិ អក្ខណ្ឌានិ អច្ឆិទ្ទានិ អស-
ពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញូបសត្ថានិ អប-
រាមដ្ឋានិ សមាធិសំវត្តនិកានិ អវិប្បដិសារវត្ថុកានិ
បាមុជ្ជវត្ថុកានិ បីតិវត្ថុកានិ បស្សទ្ធិវត្ថុកានិ សុខ-
វត្ថុកានិ សមាធិវត្ថុកានិ យថាភូតញ្ញាណទស្សន-
វត្ថុកានិ ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ
ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ
សំវត្តន្តិ ឥទន្តំ សីលំ អបរិយន្តំ ។

[៨៩] កឹ សីលំ កតិ សីលានិ កឹសមុដ្ឋានំ
សីលំ កតិធម្មសមោធានំ សីលំ ។

កឹ សីលន្តិ ចេតនា សីលំ ចេតសិកំ សីលំ
សំវរោ សីលំ អវីតិក្កមោ សីលំ ។

កតិ សីលានីតិ តីណិ សីលានិ កុសលសីលំ
អកុសលសីលំ អព្យាកតសីលំ ។

កឹសមុដ្ឋានំ សីលន្តិ កុសលចិត្តសមុដ្ឋានំ កុស-
លសីលំ អកុសលចិត្តសមុដ្ឋានំ អកុសលសីលំ
អព្យាកតចិត្តសមុដ្ឋានំ អព្យាកតសីលំ ។

សីលទាំងឡាយបែបនេះ ជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរបស់អ្នកជា ជាសីលដែលវិញ្ញូជនសរសើរ ជាសីល ដែលមិនមានតណ្ហានិងទិដ្ឋិបបោសអង្អែល ប្រព្រឹត្តទៅ ដើម្បីសមាធិ ជាទីតាំងនៃសេចក្តីមិនក្តៅក្រហាយ ជាទីតាំងនៃបាមោជ្ជៈ ជាទីតាំងនៃបីតិ ជាទីតាំងនៃបស្សទ្ធិ ជាទីតាំងនៃសុខៈ ជាទីតាំងនៃសមាធិ ជាទីតាំងនៃយថាភូតញ្ញាណទស្សនៈ ប្រព្រឹត្តទៅ ដើម្បីនិព្វិទាដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីនិរោធ ដើម្បីសេចក្តីស្ងាប់ស្ងាត់ ដើម្បីអភិញ្ញា ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន នេះឈ្មោះថាសីលមិនមានទីបំផុត ។

[៨៩] អ្វី ឈ្មោះថាសីល សីលមានប៉ុន្មាន សីលមានសមុដ្ឋានដូចម្តេច សីលជាទីប្រជុំចុះនៃធម៌អ្វីខ្លះ ។

សំណួរថា អ្វី ឈ្មោះថាសីល ចេតនា ឈ្មោះថាសីល ចេតសិក ឈ្មោះថាសីល សេចក្តីសង្រួម ឈ្មោះថាសីល ការមិនប្រព្រឹត្តកន្លង ឈ្មោះថាសីល ។

សំណួរថា សីលមានប៉ុន្មាន សីលមាន ៣ គឺ កុសលសីល ១ អកុសលសីល ១ អព្យាកតសីល ១ ។

សំណួរថា សីលមានសមុដ្ឋានដូចម្តេច កុសលសីល មានកុសលចិត្តជាសមុដ្ឋាន អកុសលសីល មានអកុសលចិត្តជាសមុដ្ឋាន អព្យាកតសីល មានអព្យាកតចិត្តជាសមុដ្ឋាន ។

កាតិជម្មសមោធានំ សីលន្តិ សំវរសមោធានំ សីលំ អវីតិក្កមសមោធានំ សីលំ តថាភាវេ ជាតចេ-តនាសមោធានំ សីលំ ។ ចាណាតិចាតំ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ អជិន្នាជានំ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ កាមេសុ មិច្ឆាចារំ សំវរ-ដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ មុសាវាជំ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ បិសុណាវាចំ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ ផរុសវាចំ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ សម្ផប្បលាបំ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ អភិជ្ឈំ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ ព្យាចាជំ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ មិច្ឆាជិដ្ឋឹ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ នេក្ខម្មេន កាមច្ឆន្ទំ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ អព្យាចាទេន ព្យាចាជំ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ អាលោកសញ្ញាយ ថីនមិទ្ធំ អវិក្ខេបដ្ឋេន ឧទ្ធច្ចំ ជម្ម-វត្ថានេន វិចិកិច្ឆំ ជម្មញ្ញាណេន អវិជ្ជំ ចាមុជ្ជេន អរតឹ

សំណួរថា សីលជាទីប្រជុំចុះនៃធម៌អ្វីខ្លះ សីលជាទីប្រជុំចុះនៃការសង្រួម សីល ជាទីប្រជុំចុះនៃការមិនប្រព្រឹត្តកន្លង សីល ជាទីប្រជុំចុះនៃចេតនា ដែលកើតហើយក្នុងសភាពដូច្នោះ ។ សីល ដោយអត្ថថាបិទនូវបាណាតិបាត សីលដោយអត្ថថាមិនប្រព្រឹត្តកន្លង សីលដោយអត្ថថាបិទនូវអទិន្នាទាន សីលដោយអត្ថថាមិនប្រព្រឹត្តកន្លង សីលដោយអត្ថថាបិទនូវកាមេសុមិច្ឆាចារ សីលដោយអត្ថថាមិនប្រព្រឹត្តកន្លង សីលដោយអត្ថថាបិទនូវមុសាវាទ សីលដោយអត្ថថាមិនប្រព្រឹត្តកន្លង សីលដោយអត្ថថាបិទនូវបិសុណវាចា សីលដោយអត្ថថាមិនប្រព្រឹត្តកន្លង សីលដោយអត្ថថាបិទនូវផរុសវាចា សីលដោយអត្ថថាមិនប្រព្រឹត្តកន្លង សីលដោយអត្ថថាបិទនូវសម្ផប្បលាបៈ សីលដោយអត្ថថាមិនប្រព្រឹត្តកន្លង សីលដោយអត្ថថាបិទនូវអភិជ្ឈា សីលដោយអត្ថថាមិនប្រព្រឹត្តកន្លង សីលដោយអត្ថថាបិទនូវព្យាបាទ សីលដោយអត្ថថាមិនប្រព្រឹត្តកន្លង សីលដោយអត្ថថាបិទនូវមិច្ឆាទិដ្ឋិ សីលដោយអត្ថថាមិនប្រព្រឹត្តកន្លង សីលដោយអត្ថថាបិទនូវកាមច្ឆន្ទៈដោយនេក្ខម្មៈ សីលដោយអត្ថថាមិនប្រព្រឹត្តកន្លង សីលដោយអត្ថថាបិទនូវព្យាបាទ ដោយអព្យាបាទ សីលដោយអត្ថថាមិនប្រព្រឹត្តកន្លង សីលដោយអត្ថថាបិទនូវថីនមិទ្ធៈ ដោយអាលោកសញ្ញា នូវឧទ្ធច្ចៈ ដោយសេចក្តីមិនរវើរវាយ នូវវិចិកិច្ឆា ដោយកិរិយាកំណត់ធម៌ នូវអវិជ្ជា ដោយញាណ នូវអរតិ ដោយបាមោជ្ជៈ

បឋមជ្ឈានេន នីវរណេ ទុតិយជ្ឈានេន វិតក្កវិចារេ តតិយជ្ឈានេន បីតឹ ចតុត្ថជ្ឈានេន សុខទុក្ខំ អាកាសានញ្ចាយតនសមាបត្តិយា រូបសញ្ញំ បដិឃសញ្ញំ នានត្តសញ្ញំ វិញ្ញាណញ្ចាយតនសមាបត្តិយា អាកាសានញ្ចាយតនសញ្ញំ អាកិញ្ចញ្ញាយតនសមាបត្តិយា វិញ្ញាណញ្ចាយតនសញ្ញំ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា អាកិញ្ចញ្ញាយតនសញ្ញំ អនិច្ចានុបស្សនាយ និច្ចសញ្ញំ ទុក្ខានុបស្សនាយ សុខសញ្ញំ អនត្តានុបស្សនាយ អត្តសញ្ញំ និព្វិទានុបស្សនាយ នន្ទឹ វិរាគានុបស្សនាយ រាគំ និរោធានុបស្សនាយ សមុទយំ បដិនិស្សគ្គានុបស្សនាយ អាទានំ ខយានុបស្សនាយ ឃនសញ្ញំ វយានុបស្សនាយ អាយុហនំ វិបរិណាមានុបស្សនាយ ធុវសញ្ញំ អនិមិត្តានុបស្សនាយ និមិត្តំ អប្បណិហិតានុបស្សនាយ បណិធឹ សុញ្ញតានុបស្សនាយ អភិនិវេសំ អធិប្បញ្ញាធម្មវិបស្សនាយ សារាទានាភិនិវេសំ[១]

---

១ ឱ. ម. សារាគាភិនិវេសំ ។

នូវនីវរណៈទាំងឡាយដោយបឋមជ្ឈាន នូវវិតក្កៈនិងវិចារៈដោយទុតិយ-ជ្ឈាន នូវបីតិ ដោយតតិយជ្ឈាន នូវសុខនិងទុក្ខដោយចតុត្ថជ្ឈាន នូវរូប-សញ្ញាបដិឃសញ្ញានិងនានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមា-បត្តិ នូវអាកាសានញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ នូវវិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ នូវអាកិញ្ច-ញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ នូវសេចក្តីស-ម្គាល់ថាទៀងដោយការពិចារណាឃើញថាមិនទៀង នូវសេចក្តីសម្គាល់ថាសុខដោយការពិចារណាឃើញថាទុក្ខ នូវសេចក្តីសម្គាល់ថាខ្លួនដោយការពិចារណាឃើញថាមិនមែនខ្លួន នូវតម្រេកដោយការពិចារណាឃើញថាគួរនឿយណាយចាករាគៈ ដោយការពិចារណាឃើញថាប្រាសចាករាគៈ នូវការកើតឡើងដោយការពិចារណាឃើញថា រលត់ នូវសេចក្តីប្រកាន់ដោយការពិចារណាឃើញថាគួររលាស់ចោល នូវសេចក្តីសម្គាល់ថារឹងប៉ឹងដោយការពិចារណាឃើញថាអស់ទៅ នូវការប្រមូលមក ដោយការពិចារ-ណាឃើញថាសូន្យទៅ នូវសេចក្តីសម្គាល់ថាឋិតថេរ ដោយការពិចារណាឃើញថាប្រែប្រួល នូវគ្រឿងចំណាំ ដោយការពិចារណាឃើញថាមិនមានគ្រឿងចំណាំ នូវសេចក្តីប្រាថ្នា ដោយការពិចារណាឃើញថាមិនគួរប្រាថ្នា នូវសេចក្តីប្រកាន់មាំ ដោយការពិចារណាឃើញថាសូន្យ នូវសេចក្តីប្រ-កាន់មាំនិងការប្រកាន់ស្អិតថាខ្លឹមសារ ដោយអធិប្បញ្ញានិងធម្មវិបស្សនា

យថាភូតញ្ញាណទស្សនេន សម្មោហាភិនិវេសំ អាទីន-
វានុបស្សនាយ អាលយាភិនិវេសំ បដិសំខានុបស្សនា-
យ អប្បដិសង្ខា វិវដ្ដនានុបស្សនាយ សញ្ញោគាភិនិ-
វេសំ សោតាបត្តិមគ្គេន ទិដ្ឋេកដ្ឋេ កិលេសេ សក-
ទាគាមិមគ្គេន ឱឡារិកេ កិលេសេ អនាគាមិមគ្គេន
អណុសហគតេ កិលេសេ អរហត្តមគ្គេន សព្វកិ្ល-
លេសេ សំវរដ្ឋេន សីលំ អវីតិក្កមដ្ឋេន សីលំ ។

[៩០] បញ្ច សីលានិ បាណាតិបាតស្ស បហានំ
សីលំ វេរមណី សីលំ ចេតនា សីលំ សំវរោ សីលំ
អវីតិក្កមោ សីលំ ឯវរូបានិ សីលានិ ចិត្តស្ស អវិ-
ប្បដិសារាយ សំវត្តន្តិ បាមុជ្ជាយ សំវត្តន្តិ បីតិយា
សំវត្តន្តិ បស្សទ្ធិយា សំវត្តន្តិ សោមនស្សាយ
សំវត្តន្តិ អាសេវនាយ សំវត្តន្តិ ភាវនាយ សំវត្តន្តិ
ពហុលីកម្មាយ សំវត្តន្តិ អលង្ការាយ សំវត្តន្តិ
បរិក្ខារាយ សំវត្តន្តិ បរិវារាយ សំវត្តន្តិ បារិ-
បូរិយា សំវត្តន្តិ ឯកន្តនិព្វិទាយ វិរាគាយ
និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ

នូវសេចក្ដីប្រកាន់មាំព្រោះការវង្វេងខ្លាំង ដោយយថាភូតញ្ញាណទស្សនៈ នូវសេចក្ដីប្រកាន់មាំដោយសេចក្ដីអាល័យ ដោយការពិចារណាឃើញថាទោស នូវការមិនពិចារណា ព្រោះការឃើញដោយការពិចារណា នូវសេចក្ដីប្រកាន់មាំ ព្រោះកិលេសជាគ្រឿងប្រកប ដោយការពិចារណាឃើញនូវធម៌ជាគ្រឿងបើក (គោត្រភូញាណ) នូវពួកកិលេសដែលតាំងនៅក្នុងទីតែមួយជាមួយនឹងទិដ្ឋិ ដោយសោតាបត្តិមគ្គ នូវពួកកិលេសដ៏គ្រោតគ្រាត ដោយសកទាគាមិមគ្គ នូវពួកកិលេសដ៏ល្អិតដោយអនាគាមិមគ្គ នូវពួកកិលេសទាំងអស់ ដោយអរហត្តមគ្គ នូវសីលដោយអត្ថថាសង្រួម នូវសីល ដោយអត្ថថាមិនប្រព្រឹត្តកន្លង ។

[៩០] សីល ៥ គឺ ការលះបង់បាណាតិបាត ឈ្មោះថាសីល ១ ការវៀរ ឈ្មោះថាសីល ១ ចេតនា ឈ្មោះថាសីល ១ សេចក្ដីសង្រួមឈ្មោះថាសីល ១ ការមិនប្រព្រឹត្តកន្លង ឈ្មោះថាសីល ១ ពួកសីលមានសភាពយ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីមិនក្ដៅក្រហាយចិត្ត ប្រព្រឹត្តទៅដើម្បីបាមោជ្ជៈ ប្រព្រឹត្តទៅ ដើម្បីបីតិ ប្រព្រឹត្តទៅ ដើម្បីបស្សទ្ធិ ប្រព្រឹត្តទៅ ដើម្បីសោមនស្ស ប្រព្រឹត្តទៅ ដើម្បីសេព ប្រព្រឹត្តទៅ ដើម្បីភាវនា ប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យច្រើន ប្រព្រឹត្តទៅ ដើម្បីអលង្ការ ប្រព្រឹត្តទៅ ដើម្បីបរិក្ខារ ប្រព្រឹត្តទៅ ដើម្បីបរិវារ ប្រព្រឹត្តទៅ ដើម្បីបំពេញ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីនឿយណាយដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីនិរោធ ដើម្បីស្ងប់ស្ងាត់ ដើម្បីអភិញ្ញា ដើម្បីត្រាស់ដឹង

និព្វានាយ សំវត្តន្តិ ឯវរូបានំ សីលានំ សំវរបារិសុទ្ធិ អធិសីលំ សំវរបារិសុទ្ធិយា ឋិតំ ចិត្តំ ន វិក្ខេបំ គច្ឆតិ អវិក្ខេបបារិសុទ្ធិ អធិចិត្តំ សំវរបារិសុទ្ធឹ សម្មា បស្សតិ អវិក្ខេបបារិសុទ្ធឹ សម្មា បស្សតិ ទស្សនបារិសុទ្ធិ អធិបញ្ញា យោ តត្ថ សំវរដ្ឋោ អយំ អធិសីលសិក្ខា យោ តត្ថ អវិក្ខេបដ្ឋោ អយំ អធិចិត្តសិក្ខា យោ តត្ថ ទស្សនដ្ឋោ អយំ អធិ-បញ្ញាសិក្ខា ឥមា តិស្សោ សិក្ខាយោ អាវជ្ជន្តោ សិក្ខតិ ជានន្តោ សិក្ខតិ បស្សន្តោ សិក្ខតិ បច្ចវេ-ក្ខន្តោ សិក្ខតិ ចិត្តំ អធិដ្ឋហន្តោ សិក្ខតិ សទ្ធាយ អធិមុច្ចន្តោ សិក្ខតិ វីរិយំ បគ្គណ្ហន្តោ សិក្ខតិ សតឹ ឧបដ្ឋហន្តោ[១] សិក្ខតិ ចិត្តំ សមាទហន្តោ សិក្ខតិ បញ្ញាយ បជានន្តោ សិក្ខតិ អភិញ្ញេយ្យំ អភិជានន្តោ សិក្ខតិ បរិញ្ញេយ្យំ បរិជានន្តោ សិក្ខតិ បហាតព្វំ បជហន្តោ សិក្ខតិ ភាវេតព្វំ ភាវេន្តោ សិក្ខតិ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខតិ ។

---

១ ឱ. ម. ឧបដ្ឋបេន្តោ ។

ដើម្បីនិព្វាន សេចក្តីបរិសុទ្ធគឺការសង្រួម នូវសីលទាំងឡាយ មានសភាព យ៉ាងនេះ ឈ្មោះថាអធិសីល ចិត្តដែលតាំងនៅ ក្នុងសេចក្តីបរិសុទ្ធគឺការ សង្រួម មិនដល់នូវការរាយមាយ សេចក្តីបរិសុទ្ធិគឺការមិនរាយមាយ ឈ្មោះ ថាអធិចិត្ត បុគ្គលឃើញដោយប្រពៃ នូវសេចក្តីបរិសុទ្ធ គឺការសង្រួម ឃើញដោយប្រពៃ នូវសេចក្តីបរិសុទ្ធគឺការមិនរាយមាយ សេចក្តីបរិសុទ្ធ គឺការឃើញ ឈ្មោះថាអធិប្បញ្ញា អត្ថនៃសេចក្តីសង្រួមណាក្នុងសំវរបារិ-សុទ្ធិនោះ នេះឈ្មោះថាអធិសីលសិក្ខា អត្ថនៃសេចក្តីមិនរាយមាយណាក្នុង អវិក្ខេបបារិសុទ្ធិនោះ នេះឈ្មោះថាអធិចិត្តសិក្ខា អត្ថនៃសេចក្តីឃើញណា ក្នុងទស្សនបារិសុទ្ធិនោះ នេះឈ្មោះថាអធិប្បញ្ញាសិក្ខា បុគ្គលកាលពិចា-រណានូវសិក្ខាទាំង ៣ នេះ ទើបសិក្សា កាលដឹងទើបសិក្សា កាលឃើញ ទើបសិក្សា កាលពិចារណាឃើញទើបសិក្សា កាលតាំងចិត្តទើបសិក្សា កាលចុះចិត្តស៊ប់ដោយសទ្ធាទើបសិក្សា កាលផ្គងទុកនូវព្យាយាមទើបសិក្សា កាលប្រុងនូវស្មារតីទើបសិក្សា កាលតាំងចិត្តទុកទើបសិក្សា កាលដឹងច្បាស់ ដោយបញ្ញាទើបសិក្សា កាលដឹងចំពោះនូវធម៌ដែលគប្បីដឹងច្បាស់ទើប សិក្សា កាលកំណត់ដឹងនូវទុក្ខសច្ចដែលគប្បីកំណត់ដឹងទើបសិក្សា កាល លះបង់នូវសមុទយសច្ចដែលគប្បីលះបង់ទើបសិក្សា កាលចម្រើននូវមគ្គ-សច្ចដែលគប្បីចម្រើនទើបសិក្សា កាលធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ចដែល គប្បីធ្វើឲ្យជាក់ច្បាស់ទើបសិក្សា ។

[៩១] បញ្ច សីលានិ បាណាតិបាតស្ស អទិន្នាទានស្ស កាមេសុ មិច្ឆាចារស្ស មុសាវាទស្ស បិសុណាយ វាចាយ ផរុសាយ វាចាយ សម្ផប្បលាបស្ស អភិជ្ឈាយ ព្យាបាទស្ស មិច្ឆាទិដ្ឋិយា នេក្ខម្មេន កាមច្ឆន្ទស្ស អព្យាបាទេន ព្យាបាទស្ស អាលោកសញ្ញាយ ថីនមិទ្ធស្ស អវិក្ខេបេន ឧទ្ធច្ចស្ស ធម្មវវត្ថានេន វិចិកិច្ឆាយ ញាណេន អវិជ្ជាយ បាមុជ្ជេន អរតិយា បឋមជ្ឈានេន នីវរណានំ ទុតិយជ្ឈានេន វិតក្កវិចារានំ តតិយជ្ឈានេន បីតិយា ចតុត្ថជ្ឈានេន សុខទុក្ខានំ អាកាសានញ្ចាយតនសមាបត្តិយា រូបសញ្ញាយ បដិឃសញ្ញាយ នានត្តសញ្ញាយ វិញ្ញាណញ្ចាយតនសមាបត្តិយា អាកាសានញ្ចាយតនសញ្ញាយ អាកិញ្ចញ្ញាយតនសមាបត្តិយា វិញ្ញាណញ្ចាយតនសញ្ញាយ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា អាកិញ្ចញ្ញាយតនសញ្ញាយ អនិច្ចានុបស្សនាយ និច្ចសញ្ញាយ ទុក្ខានុបស្សនាយ សុខសញ្ញាយ អនត្តានុបស្សនាយ អត្តសញ្ញាយ និព្វិទានុបស្សនាយ នន្ទិយា វិរាគានុបស្សនាយ រាគស្ស និរោធានុបស្សនាយ សមុទយស្ស

[៩១] សីល ៥ គឺការលះបង់ នូវបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាបៈ អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ នូវកាមច្ឆន្ទៈ ដោយនេក្ខម្មៈ នូវព្យាបាទ ដោយអព្យាបាទ នូវថីនមិទ្ធៈ ដោយអាលោកសញ្ញា នូវឧទ្ធច្ចៈ ដោយការមិនរាយមាយ នូវវិចិកិច្ឆា ដោយការកំណត់នូវធម៌ នូវអវិជ្ជា ដោយញាណ នូវអរតិ ដោយបាមោជ្ជៈ នូវនីវរណៈទាំងឡាយ ដោយបឋមជ្ឈាន នូវវិតក្កៈ វិចារៈ ដោយទុតិយជ្ឈាន នូវបីតិ ដោយតតិយជ្ឈាន នូវសុខនិងទុក្ខ ដោយចតុត្ថជ្ឈាន នូវរូបសញ្ញា បដិឃសញ្ញានិងនានត្តសញ្ញាដោយអាកាសានញ្ចាយតនសមាបត្តិ នូវអាកាសានញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ នូវសេចក្តីសម្គាល់ក្នុងវិញ្ញាណញ្ចាយតនៈ ដោយអាកិញ្ចញ្ញាយតនសមាបត្តិ នូវសេចក្តីសម្គាល់ក្នុងអាកិញ្ចញ្ញាយតនៈ ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ នូវសេចក្តីសម្គាល់ថាទៀង ដោយការពិចារណាឃើញថាមិនទៀង នូវសេចក្តីសម្គាល់ថាសុខ ដោយការពិចារណាឃើញថាជាទុក្ខ នូវសេចក្តីសម្គាល់ថាខ្លួន ដោយការពិចារណាឃើញថាមិនមែនខ្លួន នូវសេចក្តីត្រេកត្រអាល ដោយការពិចារណាឃើញថាគួរនឿយណាយ នូវរាគៈ ដោយការពិចារណាឃើញថាប្រាសចាករាគៈ នូវការកើតឡើង ដោយការពិចារណាឃើញថារលត់ទៅ

បដិនិស្សគ្គានុបស្សនាយ អាទានស្ស ខយានុ-
បស្សនាយ ឃនសញ្ញាយ វយានុបស្សនាយ អាយុ-
ហនស្ស វិបរិណាមានុបស្សនាយ ធុវសញ្ញាយ អនិ-
មិត្តានុបស្សនាយ និមិត្តស្ស អប្បណិហិតានុបស្សនា-
យ បណិធិយា សុញ្ញតានុបស្សនាយ អភិនិវេសស្ស
អធិប្បញ្ញាធម្មវិបស្សនាយ សារាទានាភិនិវេសស្ស
យថាភូតញ្ញាណទស្សនេន សម្មោហាភិនិវេសស្ស
អាទីនវានុបស្សនាយ អាលយាភិនិវេសស្ស បដិសង្ខា-
នុបស្សនាយ អប្បដិសង្ខាយ វិវដ្ដនានុបស្សនាយ
សញ្ញោគាភិនិវេសស្ស សោតាបត្តិមគ្គេន ទិដ្ឋេ-
កដ្ឋានំ កិលេសានំ សកទាគាមិមគ្គេន ឱឡារិ-
កានំ កិលេសានំ អនាគាមិមគ្គេន អណុសហ-
គតានំ កិលេសានំ អរហត្តមគ្គេន សព្វកិ-
លេសានំ បហានំ សីលំ វេរមណី សីលំ

នូវសេចក្តីប្រកាន់ ដោយការពិចារណាឃើញថាគួររលាស់ចោល នូវសេចក្តីសម្គាល់ថារឹងប៉ឹង ដោយការពិចារណាឃើញថាអស់ទៅ នូវការប្រមូលមក ដោយការពិចារណាឃើញថាសូន្យទៅ នូវសេចក្តីសម្គាល់ថាឋិតថេរ ដោយការពិចារណាឃើញថាប្រែប្រួល នូវគ្រឿងចំណាំ ដោយការពិចារណាឃើញថាមិនមានគ្រឿងចំណាំ នូវសេចក្តីប្រាថ្នា ដោយការពិចារណាឃើញថាមិនគួរប្រាថ្នា នូវការប្រកាន់មាំ ដោយការពិចារណាឃើញថាសូន្យ នូវសេចក្តីប្រកាន់មាំនិងសេចក្តីប្រកាន់ស្អិតថាមានខ្លឹមសារ ដោយអធិប្បញ្ញានិងធម្មវិបស្សនា នូវសេចក្តីប្រកាន់មាំ ព្រោះសេចក្តីវង្វេងខ្លាំង ដោយយថាភូតញ្ញាណទស្សនៈ នូវសេចក្តីប្រកាន់មាំព្រោះអាល័យ ដោយការពិចារណាឃើញថាជាទោស នូវការមិនពិចារណាដោយការឃើញដោយការពិចារណា នូវសេចក្តីប្រកាន់មាំព្រោះកិលេសជាគ្រឿងប្រកបទុក ដោយការពិចារណាឃើញ នូវធម៌ជាគ្រឿងបើក (គោត្រភូញាណ) នូវពួកកិលេសដែលតាំងនៅក្នុងទីតែមួយជាមួយនឹងទិដ្ឋិ ដោយសោតាបត្តិមគ្គ នូវកិលេសដ៏គ្រោតគ្រាត ដោយសកទាគាមិមគ្គ នូវពួកកិលេសដ៏ល្អិត ដោយអនាគាមិមគ្គ នូវកិលេសទាំងអស់ ដោយអរហត្តមគ្គ ឈ្មោះថាសីល ១ ការវៀរបង់ ឈ្មោះថាសីល ១

ចេតនា សីលំ សំវរោ សីលំ អវីតិក្កមោ សីលំ ។ ឯវរូបានិ សីលានិ ចិត្តស្ស អវិប្បដិសារាយ សំវត្តន្តិ បាមុជ្ជាយ សំវត្តន្តិ បីតិយា សំវត្តន្តិ បស្សទ្ធិយា សំវត្តន្តិ សោមនស្សាយ សំវត្តន្តិ អាសេវនាយ សំវត្តន្តិ ភាវនាយ សំវត្តន្តិ ពហុលីកម្មាយ សំវត្តន្តិ អលង្ការាយ សំវត្តន្តិ បរិក្ខារាយ សំវត្តន្តិ បរិវារាយ សំវត្តន្តិ បារិបូរិយា សំវត្តន្តិ ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ឯវរូបានំ សីលានំ សំវរបារិសុទ្ធិ អធិសីលំ សំវរបារិសុទ្ធិយា ឋិតំ ចិត្តំ ន វិក្ខេបំ គច្ឆតិ អវិក្ខេបបារិសុទ្ធិ អធិចិត្តំ សំវរបារិសុទ្ធឹ សម្មា បស្សតិ អវិក្ខេបបារិសុទ្ធឹ សម្មា បស្សតិ ទស្សនបារិសុទ្ធិ អធិប្បញ្ញា យោ តត្ថ សំវរដ្ឋោ អយំ អធិសីលសិក្ខា យោ តត្ថ អវិក្ខេបដ្ឋោ អយំ អធិចិត្តសិក្ខា យោ តត្ថ ទស្សនដ្ឋោ អយំ អធិប្បញ្ញាសិក្ខា ឥមា តិស្សោ សិក្ខាយោ អាវជ្ជន្តោ សិក្ខតិ ជានន្តោ សិក្ខតិ បស្សន្តោ សិក្ខតិ

ចេតនា ឈ្មោះថាសីល ១ ការសង្រួម ឈ្មោះថាសីល ១ ការមិនប្រព្រឹត្តកន្លង ឈ្មោះថាសីល ១ ។ សីលមានសភាពយ៉ាងនេះ ប្រព្រឹត្តទៅដើម្បីការមិនក្តៅក្រហាយចិត្ត ប្រព្រឹត្តទៅដើម្បីបាមោជ្ជៈ ប្រព្រឹត្តទៅដើម្បីបីតិ ប្រព្រឹត្តទៅដើម្បីបស្សទ្ធិ ប្រព្រឹត្តទៅដើម្បីសោមនស្ស ប្រព្រឹត្តទៅដើម្បីអាសេវនៈ ប្រព្រឹត្តទៅដើម្បីភាវនា ប្រព្រឹត្តទៅដើម្បីធ្វើឲ្យច្រើន ប្រព្រឹត្តទៅដើម្បីគ្រឿងអលង្ការ ប្រព្រឹត្តទៅដើម្បីគ្រឿងបរិក្ខារ ប្រព្រឹត្តទៅដើម្បីបរិវារ ប្រព្រឹត្តទៅដើម្បីការបំពេញ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីនិរោធ ដើម្បីសេចក្តីស្ងប់ស្ងាត់ ដើម្បីអភិញ្ញា ដើម្បីត្រាស់ដឹង ដើម្បីនិព្វាន សេចក្តីបរិសុទ្ធគឺការសង្រួម នូវសីល មានសភាពយ៉ាងនេះ ឈ្មោះថាអធិសីល ចិត្តដែលតាំងនៅ ក្នុងសេចក្តីបរិសុទ្ធគឺសេចក្តីសង្រួម មិនដល់នូវសេចក្តីរាយមាយ សេចក្តីបរិសុទ្ធគឺសេចក្តីមិនរាយមាយ ឈ្មោះថាអធិចិត្ត បុគ្គលឃើញ ដោយប្រពៃ នូវសេចក្តីបរិសុទ្ធគឺការសង្រួម ឃើញដោយប្រពៃ នូវសេចក្តីបរិសុទ្ធគឺការមិនរាយមាយ សេចក្តីបរិសុទ្ធគឺការឃើញ ឈ្មោះថាអធិប្បញ្ញា សេចក្តីសង្រួមណា ក្នុងសំវរបារិសុទ្ធិនោះ នេះឈ្មោះថាអធិសីលសិក្ខា សេចក្តីមិនរាយមាយណា ក្នុងអវិក្ខេបបារិសុទ្ធិនោះ នេះឈ្មោះថាអធិចិត្តសិក្ខា សេចក្តីឃើញណា ក្នុងទស្សនបារិសុទ្ធិនោះ នេះ ឈ្មោះថាអធិប្បញ្ញាសិក្ខា បុគ្គល កាលពិចារណាឃើញនូវសិក្ខាទាំង ៣ នេះ ទើបសិក្សា កាលដឹងទើបសិក្សា កាលឃើញទើបសិក្សា

បច្ចវេក្ខន្តោ សិក្ខតិ ចិត្តំ អធិដ្ឋហន្តោ សិក្ខតិ សទ្ធាយ អធិមុច្ចន្តោ សិក្ខតិ វីរិយំ បគ្គណ្ហន្តោ សិក្ខតិ សតឹ ឧបដ្ឋបេន្តោ សិក្ខតិ ចិត្តំ សមាទ-ហន្តោ សិក្ខតិ បញ្ញាយ ជានន្តោ សិក្ខតិ អភិញ្ញេយ្យំ អភិជានន្តោ សិក្ខតិ បរិញ្ញេយ្យំ បរិជានន្តោ សិក្ខតិ បហាតព្វំ បជហន្តោ សិក្ខតិ ភាវេតព្វំ ភាវេន្តោ សិក្ខតិ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខតិ តំ-ញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ សុត្វាន សំវរេ បញ្ញា សីលមយេ ញាណំ ។

[៩២] កថំ សំវរិត្វា សមាទហនេ បញ្ញា សមាធិភាវនាមយេ ញាណំ ឯកោ សមាធិ ចិត្តស្ស ឯកគ្គតា ។ ទ្វេ សមាធី លោកិយោ សមាធិ លោ-កុត្តរោ សមាធិ ។ តយោ សមាធី សវិតក្កសវិចា-រោ សមាធិ អវិតក្កវិចារមត្តោ សមាធិ អវិតក្កាវិចា-រោ សមាធិ ។ ចត្តារោ សមាធី ហានភាគិយោ សមាធិ ឋិតិភាគិយោ សមាធិ វិសេសភាគិយោ សមាធិ និព្វេធភាគិយោ សមាធិ ។

កាលពិចារណាឃើញច្បាស់ទើបសិក្សា កាលតាំងចិត្តទុក ទើបសិក្សា កាលចុះចិត្តស៊ប់ដោយសទ្ធាទើបសិក្សា កាលផ្គងទុកនូវសេចក្តីព្យាយាម ទើបសិក្សា កាលប្រុងស្មារតីទើបសិក្សា កាលតម្កល់ចិត្តទុកដោយប្រពៃ ទើបសិក្សា កាលដឹងដោយបញ្ញាទើបសិក្សា កាលដឹងចំពោះនូវធម៌ ដែលគប្បីដឹងចំពោះទើបសិក្សា កាលកំណត់ដឹងនូវទុក្ខសច្ច ដែលគប្បី កំណត់ដឹងទើបសិក្សា កាលលះបង់នូវសមុទយសច្ច ដែលគួរលះបង់ ទើបសិក្សា កាលចម្រើននូវមគ្គសច្ច ដែលគប្បីចម្រើនទើបសិក្សា កាលធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ដែលគប្បីធ្វើឲ្យជាក់ច្បាស់ទើបសិក្សា ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកហៅថាបញ្ញាក្នុងការស្តាប់ ហើយសង្រួម ឈ្មោះថាសីលមយញ្ញាណ ។

[៩២] បញ្ញាក្នុងការសង្រួមហើយតម្កល់ទុក ឈ្មោះថាសមាធិភាវនាមយញ្ញាណ តើដូចម្តេច សមាធិ ១ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ។ សមាធិ ២ គឺ លោកិយសមាធិ ១ លោកុត្តរសមាធិ ១ ។ សមាធិ ៣ គឺ សមាធិប្រកបដោយវិតក្កៈប្រកបដោយវិចារៈ ១ សមាធិដែលមិនមានវិតក្កៈ មានតែវិចារៈ ១ សមាធិដែលមិនមានវិតក្កៈមិនមានវិចារៈ ១ ។ សមាធិ ៤ គឺ សមាធិគប់រកនូវសេចក្តីសាបសូន្យ ១ សមាធិគប់រកនូវការតាំងនៅ ១ សមាធិគប់រកនូវគុណវិសេស ១ សមាធិគប់រកនូវការទម្លាយកិលេស ១ ។

បញ្ច សមាធី បីតិផរណតា សុខផរណតា[១] ចេតោផរណតា អាលោកផរណតា បច្ចវេក្ខណានិមិត្តំ ។ ឆ សមាធី ពុទ្ធានុស្សតិវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ធម្មានុស្សតិវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ សង្ឃានុស្សតិវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ សីលានុស្សតិវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ចាគានុស្សតិវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ទេវតានុស្សតិវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ។ សត្ត សមាធី សមាធិស្ស កុសលតា[២] សមាធិស្ស សមាបត្តិកុសលតា សមាធិស្ស ឋិតិកុសលតា សមាធិស្ស វុដ្ឋានកុសលតា សមាធិស្ស កល្លិតកុសលតា[៣] សមាធិស្ស គោចរកុសលតា សមាធិស្ស អភិនីហារកុសលតា ។ អដ្ឋ សមាធី បឋវីកសិណវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ អាបោកសិណវសេន ។ បេ ។ តេជោកសិណវសេន វាយោកសិណវសេន នីល-

---

១ ម. ឯត្ថន្តរេ ឧបេក្ខាផរណតាតិ ទិស្សតិ ។ ២ ឱ. ម. សមាធិកុសលតា ។ ៣. ឱ. ម. កល្យតា កុសលតា ។

សមាធិ ៥ គឺការផ្សាយនៃបីតិ ១ ការផ្សាយនៃសេចក្តីសុខ ១ ការផ្សាយនៃចិត្ត ១ ការផ្សាយនៃពន្លឺ ១ ការកំណត់នូវការពិចារណា ១ ។ សមាធិ ៦ គឺចិត្តជាឯកគ្គតា ដោយអំណាចពុទ្ធានុស្សតិ ឈ្មោះថាអវិក្ខេបសមាធិ ១ ចិត្តជាឯកគ្គតា ដោយអំណាចធម្មានុស្សតិ ឈ្មោះថាអវិក្ខេបសមាធិ ១ ចិត្តជាឯកគ្គតា ដោយអំណាចនៃសង្ឃានុស្សតិ ឈ្មោះថាអវិក្ខេបសមាធិ ១ ចិត្តជាឯកគ្គតា ដោយអំណាចនៃសីលានុស្សតិ ឈ្មោះថាអវិក្ខេបសមាធិ ១ ចិត្តជាឯកគ្គតា ដោយអំណាចនៃចាគានុស្សតិ ឈ្មោះថាអវិក្ខេបសមាធិ ១ ចិត្តជាឯកគ្គតា ដោយអំណាចនៃទេវតានុស្សតិ ឈ្មោះថាអវិក្ខេបសមាធិ ១ ។ សមាធិ ៧ គឺភាពនៃសេចក្តីឈ្លាសវៃក្នុងសមាធិ ១ ភាពនៃសេចក្តីឈ្លាសវៃក្នុងការចូលកាន់សមាធិ ១ ភាពនៃសេចក្តីឈ្លាសវៃក្នុងការតាំងនៅក្នុងសមាធិ ១ ភាពនៃសេចក្តីឈ្លាសវៃក្នុងការចេញចាកសមាធិ ១ ភាពនៃសេចក្តីឈ្លាសវៃក្នុងសេចក្តីស្រួលក្នុងសមាធិ ១ ភាពនៃសេចក្តីឈ្លាសវៃក្នុងអារម្មណ៍នៃសមាធិ ១ ភាពនៃសេចក្តីឈ្លាសវៃក្នុងការប្រមូលមកនូវសមាធិ ១ ។ សមាធិ ៨ គឺចិត្តជាឯកគ្គតា ដោយអំណាចនៃបឋវីកសិណ ឈ្មោះថាអវិក្ខេបសមាធិ ១ ដោយអំណាចនៃអាបោកសិណ ១ ។ បេ ។ ដោយអំណាចនៃតេជោកសិណ ១ ដោយអំណាចនៃវាយោកសិណ ១

កសិណវសេន បីតកសិណវសេន លោហិតកសិណវសេន ឱទាតកសិណវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ។ នវ សមាធី រូបាវចរោ សមាធិ អត្ថិ ហីនោ អត្ថិ មជ្ឈិមោ អត្ថិ បណីតោ អរូបាវចរោ សមាធិ អត្ថិ ហីនោ អត្ថិ មជ្ឈិមោ អត្ថិ បណីតោ សុញ្ញតោ សមាធិ អនិមិត្តោ សមាធិ អប្បណិហិតោ សមាធិ ។ ទស សមាធី ឧទ្ធុមាតកសញ្ញាវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ វិនីលកសញ្ញាវសេន ។ បេ ។ វិបុព្វកសញ្ញាវសេន វិច្ឆិទ្ទកសញ្ញាវសេន វិក្ខាយិតកសញ្ញាវសេន វិក្ខិត្តកសញ្ញាវសេន ហតវិក្ខាយិតកសញ្ញាវសេន លោហិតកសញ្ញាវសេន បុលវកសញ្ញាវសេន អដ្ឋិកសញ្ញាវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ ឥមេ បញ្ចបញ្ញាស សមាធី ។

[៩៣] អបិ ច បញ្ចវីសតិ សមាធិស្ស សមាធិដ្ឋា បរិគ្គហដ្ឋេន សមាធិ បរិវារដ្ឋេន សមាធិ បរិបូរដ្ឋេន សមាធិ ឯកគ្គដ្ឋេន សមាធិ

ដោយអំណាចនៃនីលកសិណ ១ ដោយអំណាចនៃបីតកសិណ ១ ដោយអំណាចនៃលោហិតកសិណ ១ ចិត្តជាឯកគ្គតា ដោយអំណាចនៃឱទាតកសិណ ឈ្មោះថាអវិក្ខេបសមាធិ ១ ។ សមាធិ ៩ គឺរូបាវចរសមាធិជាន់ទាប ១ ជាន់កណ្តាល ១ ជាន់ខ្ពស់ ១ អរូបាវចរសមាធិជាន់ទាប ១ ជាន់កណ្តាល ១ ជាន់ខ្ពស់ ១ សុញ្ញតសមាធិ ១ អនិមិត្តសមាធិ ១ អប្បណិហិតសមាធិ ១ ។ សមាធិ ១០ គឺ ចិត្តជាឯកគ្គតា ដោយអំណាចនៃឧទ្ធុមាតកសញ្ញា ឈ្មោះថាអវិក្ខេបសមាធិ ១ ដោយអំណាចនៃវិនីលកសញ្ញា ១ ។ បេ ។ ដោយអំណាចវិបុព្វកសញ្ញា ១ ដោយអំណាចវិច្ឆិទ្ទកសញ្ញា ១ ដោយអំណាចវិក្ខាយិតកសញ្ញា ១ ដោយអំណាចវិក្ខិត្តកសញ្ញា ១ ដោយអំណាចហតវិក្ខាយិតកសញ្ញា ១ ដោយអំណាចលោហិតកសញ្ញា ១ ដោយអំណាចបុលុវកសញ្ញា ១ ចិត្តជាឯកគ្គតាដោយអំណាចអដ្ឋិកសញ្ញា ឈ្មោះថាអវិក្ខេបសមាធិ ១ នេះសមាធិ ៥៥ ។

[៩៣] ម្យ៉ាងទៀត អត្ថក្នុងសមាធិ នៃសមាធិ មាន ២៥ គឺ សមាធិ ដោយអត្ថថាកំណត់ ១ សមាធិដោយអត្ថថាជាបរិវារ ១ សមាធិដោយអត្ថថាពេញលេញ ១ សមាធិដោយអត្ថថាមានអារម្មណ៍តែមួយ ១

អវិក្ខេបដ្ឋេន សមាធិ អវិសារដ្ឋេន សមាធិ អនាវិលដ្ឋេន សមាធិ អនិញ្ជនដ្ឋេន សមាធិ វិមុត្តដ្ឋេន សមាធិ ឯកត្តុបដ្ឋានវសេន ចិត្តស្ស ឋិតត្តា សមាធិ សមំ ឯសតីតិ សមាធិ វិសមំ នេសតីតិ សមាធិ សមំ ឯសិតត្តា សមាធិ វិសមំ នេសិតត្តា សមាធិ សមំ អាទិយតីតិ[1] សមាធិ វិសមំ នាទិយតីតិ[2] សមាធិ សមំ អាទិន្នត្តា សមាធិ វិសមំ អនាទិន្នត្តា សមាធិ សមំ បដិបជ្ជតីតិ សមាធិ វិសមំ នប្បដិបជ្ជតីតិ សមាធិ សមំ បដិបន្នត្តា សមាធិ វិសមំ នប្បដិបន្នត្តា សមាធិ សមំ ឈាយតីតិ សមាធិ

១ ម. អាទិស្សតីតិ ។ ២ ម. នាទិស្សតីតិ ។

សមាធិ ដោយអត្ថថាមិនរាយមាយ ១ សមាធិ ដោយអត្ថថាមិនប្រាស ចាកខ្លឹមសារ ១ សមាធិ ដោយអត្ថថាមិនល្អក់ ១ សមាធិ ដោយអត្ថថាមិនញាប់ញ័រ ១ សមាធិ ដោយអត្ថថាផុតស្រឡះ ១ ភាពនៃចិត្តតាំងនៅដោយអំណាចនៃការតាំងនៅក្នុងអារម្មណ៍តែមួយ[១] ឈ្មោះថាសមាធិ ១ សភាវៈដែលស្វែងរកនូវការស្ងប់ ឈ្មោះថាសមាធិ ១ សភាវៈដែលមិនស្វែងរកនូវធម៌ប្រាសចាកការស្ងប់ ឈ្មោះថាសមាធិ ១ ភាពនៃធម៌ស្វែងរកនូវការស្ងប់ ឈ្មោះថាសមាធិ ១ ភាពនៃធម៌មិនស្វែងរកនូវធម៌ប្រាសចាកការស្ងប់ ឈ្មោះថាសមាធិ ១ សភាវៈដែលកាន់យកនូវការស្ងប់ ឈ្មោះថាសមាធិ ១ សភាវៈដែលមិនកាន់យកនូវធម៌ប្រាសចាកការស្ងប់ ឈ្មោះថាសមាធិ ១ ភាពនៃធម៌កាន់យកនូវការស្ងប់ ឈ្មោះថាសមាធិ ១ ភាពនៃធម៌មិនកាន់យកនូវធម៌ប្រាសចាកការស្ងប់ ឈ្មោះថាសមាធិ ១ សភាវៈ ដែលដើរទៅកាន់ការស្ងប់ ឈ្មោះថាសមាធិ ១ សភាវៈដែលមិនដើរទៅកាន់ធម៌ប្រាសចាកការស្ងប់ ឈ្មោះថាសមាធិ ១ ភាពនៃធម៌ដែលដើរទៅកាន់ការស្ងប់ ឈ្មោះថាសមាធិ ១ ភាពនៃធម៌ដែលមិនដើរទៅកាន់ធម៌ប្រាសចាកការស្ងប់ ឈ្មោះថាសមាធិ ១ សភាវៈដែលដុតនូវ

---

១ នេះ មិនមែនជាអត្ថរបស់សមាធិទេ ។ អដ្ឋកថា ។

វិសមំ ឈាបេតីតិ សមាធិ សមំ ឈាតត្តា សមាធិ វិសមំ ឈាបិតត្តា សមាធិ សមោ ច ហិតោ ច សុខោ ចាតិ សមាធិ ឥមេ បញ្ចវីសតិ សមាធិស្ស សមាធិដ្ឋា តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ សំវរិត្វា សមាទហនេ បញ្ញា សមាធិភាវនាមយេ ញាណំ ។

[៩៨] កថំ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញ្ញាណំ អវិជ្ជា សង្ខារានំ ឧប្បាទដ្ឋិតិ ច បវត្តដ្ឋិតិ ច និមិត្តដ្ឋិតិ ច អាយុហនដ្ឋិតិ ច សញ្ញោគដ្ឋិតិ ច បលិពោធដ្ឋិតិ ច សមុទយដ្ឋិតិ ច ហេតុដ្ឋិតិ ច បច្ចយដ្ឋិតិ ច ឥមេហិ នវហាការេហិ អវិជ្ជា បច្ចយោ សង្ខារា បច្ចយសមុប្បន្នា ឧភោបេតេ ធម្មា បច្ចយសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញ្ញាណំ

ការស្ងប់ ឈ្មោះថាសមាធិ ១ ភាពនៃធម៌ដែលដុត នូវធម៌ប្រាសចាកការស្ងប់ ឈ្មោះថាសមាធិ ១ ភាពនៃធម៌ដែលដុតនូវការស្ងប់ ឈ្មោះថាសមាធិ ១ ភាពនៃធម៌ដែលដុតនូវធម៌ ប្រាសចាកការស្ងប់ ឈ្មោះថាសមាធិ ១ ធម៌មានសភាពស្ងប់ផង មានប្រយោជន៍ផង មានសេចក្ដីសុខផង ឈ្មោះថាសមាធិ[១] នេះអត្ថក្នុងសមាធិ របស់សមាធិ ២៥ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់ នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការសង្រួមហើយតម្កល់ទុក ឈ្មោះថាសមាធិភាវនាមយញ្ញាណ ។

[៩២] បញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ តើដូចម្ដេច អវិជ្ជាជាទីតាំងនៃការកើតឡើងផង ជាទីតាំងនៃការប្រព្រឹត្តទៅផង ជាទីតាំងនៃគ្រឿងកំណត់ផង ជាទីតាំងនៃការប្រមូលផង ជាទីតាំងនៃការប្រកបផង ជាទីតាំងនៃកង្វល់ផង ជាទីតាំងនៃការប្រជុំកើតផង ជាទីតាំងនៃហេតុផង ជាទីតាំងនៃបច្ច័យផង របស់សង្ខារទាំងឡាយ នេះអវិជ្ជាជាបច្ច័យដោយអាការ ៩ យ៉ាង សង្ខារទាំងឡាយកើតឡើងព្រោះបច្ច័យ ធម៌ទាំង ២ នុ៎ះ សុទ្ធតែកើតឡើងព្រោះបច្ច័យ ហេតុនោះបញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ

---
១ ត្រង់នេះមិនមែនជាអត្ថរបស់សមាធិទេ ។ អដ្ឋកថា ។

អតីតម្បិ អទ្ធានំ អវិជ្ជា សង្ខារានំ អនាគតម្បិ អទ្ធានំ អវិជ្ជា សង្ខារានំ ឧប្បាទដ្ឋិតិ ច បវត្តដ្ឋិតិ ច និមិត្តដ្ឋិតិ ច អាយុហនដ្ឋិតិ ច សញ្ញោគដ្ឋិតិ ច បលិពោធដ្ឋិតិ ច សមុទយដ្ឋិតិ ច ហេតុដ្ឋិតិ ច បច្ចយដ្ឋិតិ ច ឥមេហិ នវហាការេហិ អវិជ្ជា បច្ចយោ សង្ខារា បច្ចយសមុប្បន្នា ឧភោបេតេ ធម្មា បច្ចយសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញ្ញាណំ សង្ខារា វិញ្ញាណស្ស ។ បេ ។ វិញ្ញាណំ នាមរូបស្ស នាមរូបំ សឡាយតនស្ស សឡាយតនំ ផស្សស្ស ផស្សោ វេទនាយ វេទនា តណ្ហាយ តណ្ហា ឧបាទានស្ស ឧបាទានំ ភវស្ស ភវោ ជាតិយា ជាតិ ជរាមរណស្ស ឧប្បាទដ្ឋិតិ ច បវត្តដ្ឋិតិ ច និមិត្តដ្ឋិតិ ច អាយុហនដ្ឋិតិ ច សញ្ញោគដ្ឋិតិ ច បលិពោធដ្ឋិតិ ច សមុទយដ្ឋិតិ ច ហេតុដ្ឋិតិ ច បច្ចយដ្ឋិតិ ច

អវិជ្ជាជាទីតាំងនៃការកើតឡើងរបស់សង្ខារទាំងឡាយ អស់អតីតកាលផង អវិជ្ជាជាទីតាំងនៃការកើតឡើងផង ជាទីតាំងនៃការប្រព្រឹត្តទៅផង ជាទីតាំងនៃនិមិត្តផង ជាទីតាំងនៃការប្រមូលផង ជាទីតាំងនៃការប្រកបព្រមផង ជាទីតាំងនៃកង្វល់ផង ជាទីតាំងនៃការប្រជុំកើតផង ជាទីតាំងនៃហេតុផង ជាទីតាំងនៃបច្ច័យផង របស់សង្ខារទាំងឡាយ អស់អនាគតកាលផង នេះអវិជ្ជាជាបច្ច័យ ដោយអាការ ៩ យ៉ាង សង្ខារទាំងឡាយកើតឡើងព្រោះបច្ច័យ ធម៌ទាំងពីរនុ៎ះ កើតឡើងព្រោះបច្ច័យ ហេតុនោះបញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ សង្ខារទាំងឡាយជាទីតាំងនៃការកើតឡើងរបស់វិញ្ញាណ ។ បេ ។ វិញ្ញាណជាទីតាំងនៃការកើតឡើងរបស់នាមរូប នាមរូប ជាទីតាំងនៃការកើតឡើងរបស់អាយតនៈប្រាំមួយ អាយតនៈប្រាំមួយ ជាទីតាំងនៃការកើតឡើងរបស់ផស្សៈ ផស្សៈជាទីតាំងនៃការកើតឡើងរបស់វេទនា វេទនា ជាទីតាំងនៃការកើតឡើងរបស់តណ្ហា តណ្ហា ជាទីតាំងនៃការកើតឡើងរបស់ឧបាទាន ឧបាទាន ជាទីតាំងនៃការកើតឡើងរបស់ភព ភព ជាទីតាំងនៃការកើតឡើងរបស់ជាតិ ជាតិ ជាទីតាំងនៃការកើតឡើងផង ជាទីតាំងនៃការប្រព្រឹត្តទៅផង ជាទីតាំងនៃនិមិត្តផង ជាទីតាំងនៃការប្រមូលផង ជាទីតាំងនៃការប្រកបព្រមផង ជាទីតាំងនៃកង្វល់ផង ជាទីតាំងនៃការប្រជុំកើតផង ជាទីតាំងនៃហេតុផង ជាទីតាំងនៃបច្ច័យផង របស់ជរានិងមរណៈ

ឥមេហិ នវហាកាវេហិ ជាតិប្បច្ចយោ ជរាមរណំ បច្ចយសមុប្បន្នំ ឧភោបេតេ ធម្មា បច្ចយសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញ្ញាណំ អតីតម្បិ អទ្ធានំ អនាគតម្បិ អទ្ធានំ ជាតិ ជរាមរណស្ស ឧប្បាទដ្ឋិតិ ច បវត្តដ្ឋិតិ ច និមិត្តដ្ឋិតិ ច អាយុហនដ្ឋិតិ ច សញ្ញោគដ្ឋិតិ ច បលិពោធដ្ឋិតិ ច សមុទយដ្ឋិតិ ច ហេតុដ្ឋិតិ ច បច្ចយដ្ឋិតិ ច ឥមេហិ នវហាកាវេហិ ជាតិប្បច្ចយោ ជរាមរណំ បច្ចយសមុប្បន្នំ ឧភោ-បេតេ ធម្មា បច្ចយសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញ្ញាណំ ។

[៩៥] អវិជ្ជា ហេតុ សង្ខារា ហេតុសមុប្បន្នា ឧភោ-បេតេ ធម្មា ហេតុសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញ្ញាណំ អតីតម្បិ អទ្ធានំ អនាគតម្បិ អទ្ធានំ អវិជ្ជា ហេតុ សង្ខារា ហេតុសមុប្បន្នា ឧភោបេតេ ធម្មា ហេតុសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញ្ញា-ណំ សង្ខារា វិញ្ញាណំ ហេតុសមុប្បន្នំ វិញ្ញាណំ ហេតុ

នេះជាតិជាបច្ច័យដោយអាការ ៩ យ៉ាង ជរានិងមរណៈ កើតឡើង ព្រោះបច្ច័យ ធម៌ទាំងឡាយពីរនុ៎ះ កើតឡើងព្រោះបច្ច័យ ហេតុនោះ បញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ ជាតិជាទីតាំងនៃការកើតឡើងផង ជាទីតាំងនៃការប្រព្រឹត្តទៅផង ជាទីតាំងនៃនិមិត្តផង ជាទីតាំងនៃការប្រមូលផង ជាទីតាំងនៃការប្រកបព្រមផង ជាទីតាំងនៃកង្វល់ផង ជាទីតាំងនៃការប្រជុំកើតផង ជាទីតាំងនៃហេតុផង ជាទីតាំងនៃបច្ច័យផង របស់ជរានិងមរណៈ អស់អតីតកាលផង អស់អនាគតកាលផង នេះជាតិជាបច្ច័យដោយអាការ ៩ យ៉ាង ជរានិងមរណៈ កើតឡើងព្រោះបច្ច័យ ធម៌ទាំងពីរនុ៎ះ កើតឡើងព្រោះបច្ច័យ ហេតុនោះ បញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ ។

[៩៥] អវិជ្ជា ជាហេតុ សង្ខារទាំងឡាយកើតឡើងព្រោះហេតុ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះហេតុ ហេតុនោះ បញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ អវិជ្ជាជាហេតុ សង្ខារទាំងឡាយ កើតឡើងព្រោះហេតុ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះហេតុ អស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ សង្ខារទាំងឡាយជាហេតុ វិញ្ញាណកើតឡើងព្រោះហេតុ វិញ្ញាណជាហេតុ

ជាមរូបំ ហេតុ សឡាយតនំ ហេតុសមុប្បន្នំ សឡា-
យតនំ ហេតុ ផស្សោ ហេតុសមុប្បន្នោ ផស្សោ
ហេតុ វេទនា ហេតុសមុប្បន្នា វេទនា ហេតុ តណ្ហា
ហេតុសមុប្បន្នា តណ្ហា ហេតុ ឧបាទានំ ហេតុសមុប្ប-
ន្នំ ឧបាទានំ ហេតុ ភវោ ហេតុសមុប្បន្នោ ភវោ
ហេតុ ជាតិ ហេតុសមុប្បន្នា ជាតិ ហេតុ ជរាម-
រណំ ហេតុសមុប្បន្នំ ឧភោបេតេ ធម្មា ហេតុ-
សមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញាណំ
អតីតម្បិ អទ្ធានំ អនាគតម្បិ អទ្ធានំ ជាតិ ហេតុ
ជរាមរណំ ហេតុសមុប្បន្នំ ឧភោបេតេ ធម្មា ហេតុ-
សមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញាណំ ។

[៩៦] អវិជ្ជា បដិច្ច សង្ខារា បដិច្ចសមុប្បន្នា ឧភោ-
បេតេ ធម្មា បដិច្ចសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា
ធម្មដ្ឋិតិញាណំ អតីតម្បិ អទ្ធានំ អនាគតម្បិ អទ្ធានំ
អវិជ្ជា បដិច្ច សង្ខារា បដិច្ចសមុប្បន្នា ឧភោបេតេ ធម្មា

នាមនិងរូប កើតឡើងព្រោះហេតុ នាមនិងរូបជាហេតុ អាយតនៈប្រាំ-មួយកើតឡើងព្រោះហេតុ អាយតនៈប្រាំមួយជាហេតុ ផស្សៈកើតឡើងព្រោះហេតុ ផស្សៈជាហេតុ វេទនាកើតឡើងព្រោះហេតុ វេទនាជាហេតុ តណ្ហាកើតឡើងព្រោះហេតុ តណ្ហាជាហេតុ ឧបាទានកើតឡើងព្រោះហេតុ ឧបាទានជាហេតុ ភពកើតឡើងព្រោះហេតុ ភពជាហេតុ ជាតិកើតឡើងព្រោះហេតុ ជាតិជាហេតុ ជរានិងមរណៈ កើតឡើងព្រោះហេតុ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះហេតុ ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ ជាតិជាហេតុ ជរានិងមរណៈកើតឡើង ព្រោះហេតុ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះហេតុ អស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ ។

[៩៦] អវិជ្ជា ជាគ្រឿងអាស្រ័យ សង្ខារកើតឡើងព្រោះគ្រឿងអា-ស្រ័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះគ្រឿងអាស្រ័យ ហេតុនោះ បញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ អវិជ្ជាជាគ្រឿងអាស្រ័យ សង្ខារកើតឡើងព្រោះគ្រឿងអាស្រ័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះគ្រឿងអាស្រ័យ អស់អតីតកាលផង អស់អនាគតកាលផង

១១៧

បដិច្ចសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញាណំ សង្ខារា បដិច្ច វិញ្ញាណំ បដិច្ចសមុប្បន្នំ វិញ្ញាណំ បដិច្ច នាមរូបំ បដិច្ចសមុប្បន្នំ នាមរូបំ បដិច្ច សឡាយតនំ បដិច្ចសមុប្បន្នំ សឡាយតនំ បដិច្ច ផស្សោ បដិច្ចសមុប្បន្នោ ផស្សោ បដិច្ច វេទនា បដិច្ចសមុប្បន្នា វេទនា បដិច្ច តណ្ហា បដិច្ចសមុប្បន្នា តណ្ហា បដិច្ច ឧបាទានំ បដិច្ចសមុប្បន្នំ ឧបាទានំ បដិច្ច ភវោ បដិច្ចសមុប្បន្នោ ភវោ បដិច្ច ជាតិ បដិច្ចសមុប្បន្នា ជាតិ បដិច្ច ជរាមរណំ បដិច្ចសមុប្បន្នំ ឧភោបេតេ ធម្មា បដិច្ចសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញាណំ អតីតម្បិ អទ្ធានំ អនាគតម្បិ អទ្ធានំ ជាតិ បដិច្ច ជរាមរណំ បដិច្ចសមុប្បន្នំ ឧភោបេតេ ធម្មា បដិច្ចសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញាណំ ។

ហេតុនោះ បញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ សង្ខារជាគ្រឿងអាស្រ័យ វិញ្ញាណកើតឡើង ព្រោះគ្រឿងអាស្រ័យ វិញ្ញាណជាគ្រឿងអាស្រ័យ នាមនិងរូបកើតឡើង ព្រោះគ្រឿងអាស្រ័យ នាមនិងរូបជាគ្រឿងអាស្រ័យ អាយតនៈប្រាំមួយកើតឡើង ព្រោះគ្រឿងអាស្រ័យ អាយតនៈប្រាំមួយជាគ្រឿងអាស្រ័យ ផស្សៈកើតឡើងព្រោះគ្រឿងអាស្រ័យ ផស្សៈជាគ្រឿងអាស្រ័យ វេទនាកើតឡើងព្រោះគ្រឿងអាស្រ័យ វេទនាជាគ្រឿងអាស្រ័យ តណ្ហាកើតឡើង ព្រោះគ្រឿងអាស្រ័យ តណ្ហាជាគ្រឿងអាស្រ័យ ឧបាទានកើតឡើងព្រោះគ្រឿងអាស្រ័យ ឧបាទានជាគ្រឿងអាស្រ័យ ភពកើតឡើង ព្រោះគ្រឿងអាស្រ័យ ភពជាគ្រឿងអាស្រ័យ ជាតិកើតឡើងព្រោះគ្រឿងអាស្រ័យ ជាតិជាគ្រឿងអាស្រ័យ ជរានិងមរណៈកើតឡើង ព្រោះគ្រឿងអាស្រ័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើង ព្រោះគ្រឿងអាស្រ័យ ហេតុនោះ បញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ ជាតិជាគ្រឿងអាស្រ័យ ជរានិងមរណៈកើតឡើងព្រោះគ្រឿងអាស្រ័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះគ្រឿងអាស្រ័យ អស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ ។

[៩៧] អវិជ្ជា បច្ចយោ សង្ខារា បច្ចយសមុប្បន្នា ឧភោបេតេ ធម្មា បច្ចយសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញ្ញាណំ អតីតម្បិ អទ្ធានំ អនាគតម្បិ អទ្ធានំ អវិជ្ជា បច្ចយោ សង្ខារា បច្ចយសមុប្បន្នា ឧភោបេតេ ធម្មា បច្ចយសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញ្ញាណំ សង្ខារា បច្ចយោ វិញ្ញាណំ បច្ចយសមុប្បន្នំ វិញ្ញាណំ បច្ចយោ នាមរូបំ បច្ចយ-សមុប្បន្នំ នាមរូបំ បច្ចយោ សឡាយតនំ បច្ចយ-សមុប្បន្នំ សឡាយតនំ បច្ចយោ ផស្សោ បច្ចយ-សមុប្បន្នោ ផស្សោ បច្ចយោ វេទនា បច្ចយសមុប្ប-ន្នា វេទនា បច្ចយោ តណ្ហា បច្ចយសមុប្បន្នា តណ្ហា បច្ចយោ ឧបាទានំ បច្ចយសមុប្បន្នំ ឧបាទានំ បច្ចយោ ភវោ បច្ចយសមុប្បន្នោ ភវោ បច្ចយោ ជាតិ បច្ចយ-សមុប្បន្នា ជាតិ បច្ចយោ ជរាមរណំ បច្ចយសមុប្បន្នំ ឧភោបេតេ ធម្មា បច្ចយសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញ្ញាណំ អតីតម្បិ អទ្ធានំ អនាគតម្បិ អទ្ធានំ ជាតិ បច្ចយោ ជរាមរណំ បច្ចយសមុប្បន្នំ ឧភោបេតេ ធម្មា បច្ចយសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញ្ញាណំ ។

[៩៧] អវិជ្ជាជាបច្ច័យ សង្ខារទាំងឡាយកើតឡើងព្រោះបច្ច័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះបច្ច័យ ហេតុនោះ បញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ អវិជ្ជាជាបច្ច័យ សង្ខារ កើតឡើងព្រោះបច្ច័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើង ព្រោះ បច្ច័យ អស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញា ក្នុង ការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ សង្ខារជាបច្ច័យ វិញ្ញាណ កើតឡើងព្រោះបច្ច័យ វិញ្ញាណជាបច្ច័យ នាមនិងរូបកើតឡើង ព្រោះ បច្ច័យ នាមនិងរូបជាបច្ច័យ អាយតនៈប្រាំមួយកើតឡើង ព្រោះ បច្ច័យ អាយតនៈប្រាំមួយជាបច្ច័យ ផស្សៈកើតឡើងព្រោះបច្ច័យ ផស្សៈជាបច្ច័យ វេទនាកើតឡើងព្រោះបច្ច័យ វេទនាជាបច្ច័យ តណ្ហា កើតឡើងព្រោះបច្ច័យ តណ្ហាជាបច្ច័យ ឧបាទានកើតឡើងព្រោះបច្ច័យ ឧបាទានជាបច្ច័យ ភពកើតឡើងព្រោះបច្ច័យ ភពជាបច្ច័យ ជាតិកើត ឡើងព្រោះបច្ច័យ ជាតិជាបច្ច័យ ជរានិងមរណៈកើតឡើងព្រោះបច្ច័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើងព្រោះបច្ច័យ ហេតុនោះ បញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ ជាតិជាបច្ច័យ ជរា និងមរណៈកើតឡើងព្រោះបច្ច័យ ធម៌ទាំងពីរនុ៎ះ សុទ្ធតែកើតឡើង ព្រោះបច្ច័យ អស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញា ក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ ។

[៩៨] បុរិមកម្មភវស្មឹ មោហោ អវិជ្ជា អាយុហនា សង្ខារា និកន្តិ តណ្ហា ឧបគមនំ ឧបាទានំ ចេតនា ភវោ ឥមេ បញ្ច ធម្មា បុរិមកម្មភវស្មឹ ឥធ បដិសន្ធិយា បច្ចយា ឥធ បដិសន្ធិ វិញ្ញាណំ ឱក្កន្តិ នាមរូបំ បសាទោ អាយតនំ ផុដ្ឋោ ផស្សោ វេទយិតំ វេទនា ឥមេ បញ្ច ធម្មា ឥធុបបត្តិភវស្មឹ បុរេ កតស្ស កម្មស្ស បច្ចយា ឥធ បរិបក្កត្តា អាយតនានំ មោហោ អវិជ្ជា អាយុហនា សង្ខារា និកន្តិ តណ្ហា ឧបគមនំ ឧបាទានំ ចេតនា ភវោ ឥមេ បញ្ច ធម្មា ឥធ កម្មភវស្មឹ អាយតិប្បដិសន្ធិយា[១] បច្ចយា អាយតិប្បដិសន្ធិ វិញ្ញាណំ ឱក្កន្តិ នាមរូបំ បសាទោ អាយតនំ ផុដ្ឋោ ផស្សោ វេទយិតំ វេទនា ឥមេ បញ្ច ធម្មា អាយតឹ ឧបបត្តិភវស្មឹ ឥធ កតស្ស កម្មស្ស បច្ចយា ឥតិ ឥមេ ចតុស្សង្ខេបេ តយោ អទ្ធេ វីសតិយា អាការេហិ តិសន្ធឹ បដិច្ចសមុប្បាទំ ជានាតិ បស្សតិ អញ្ញាតិ[២] បដិវិជ្ឈតិ តំញាតដ្ឋេន ញាណំ បជានានដ្ឋេន បញ្ញា តេន វុច្ចតិ បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញាណំ ។

១ ម. អាយតឹ បដិសន្ធិយា ។ ២ ម. អញ្ញាតំ ។

[៩៨] ក្នុងកម្មភពមុន មោហៈ គឺអវិជ្ជា ការប្រមូលមក គឺសង្ខារ សេចក្តីប្រាថ្នា គឺតណ្ហា កិរិយាប្រកាន់មាំ គឺឧបាទាន ចេតនាគឺភព ធម៌ទាំង ៥ យ៉ាងនេះ ក្នុងកម្មភពមុន ជាបច្ច័យនៃបដិសន្ធិក្នុងបច្ចុប្បន្នភពនេះ បដិសន្ធិក្នុងបច្ចុប្បន្នភពនេះ ជាតួវិញ្ញាណ ការចុះកាន់គភ៌ គឺនាមនិងរូប បសាទៈ គឺអាយតនៈ សភាពដែលបុគ្គលពាល់ត្រូវ គឺផស្សៈ ការទទួលអារម្មណ៍ គឺវេទនា ធម៌ទាំង ៥ យ៉ាងនេះ ក្នុងឧបបត្តិភពនេះ ប្រព្រឹត្តទៅព្រោះបច្ច័យរបស់កម្ម ដែលបុគ្គលធ្វើទុកហើយក្នុងកាលមុន ព្រោះតែអាយតនៈចាស់ក្នុងបច្ចុប្បន្ននេះ មោហៈ គឺអវិជ្ជា ការប្រមូល គឺសង្ខារ សេចក្តីប្រាថ្នា គឺតណ្ហា ការប្រកាន់មាំ គឺឧបាទាន ចេតនាគឺភព ធម៌ទាំង ៥ យ៉ាងនេះ ក្នុងកម្មភព ជាបច្ចុប្បន្ននេះ ជាបច្ច័យនៃបដិសន្ធិក្នុងអនាគត បដិសន្ធិក្នុងអនាគត ជាតួវិញ្ញាណ ការចុះកាន់គភ៌ គឺនាមនិងរូប បសាទៈ គឺអាយតនៈ ធម៌ដែលបុគ្គលពាល់ត្រូវគឺផស្សៈ ការទទួលអារម្មណ៍ គឺវេទនា ធម៌ទាំង ៥ យ៉ាងនេះ ក្នុងឧបបត្តិភពជាអនាគត ប្រព្រឹត្តទៅព្រោះបច្ច័យនៃកម្ម ដែលបុគ្គលធ្វើទុកហើយក្នុងបច្ចុប្បន្នភពនេះ បុគ្គលដឹង ឃើញ យល់ ត្រាស់ដឹងនូវសង្ខេប ៤ កាល ៣ សន្ធិ ៣ នេះ និងបដិច្ចសមុប្បាទ ដោយអាការៈ ២០ យ៉ាង ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថាធម្មដ្ឋិតិញ្ញាណ ។

[៩៩] កថំ អតីតានាគតប្បច្ចុប្បន្នានំ ធម្មានំ សង្ខិបិត្វា វវត្ថានេ បញ្ញា សម្មសនេ ញាណំ យំ-កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ អនិច្ចតោ វវត្ថេតិ ឯកំ សម្មសនំ ទុក្ខតោ វវត្ថេតិ ឯកំ សម្មសនំ អនត្តតោ វវត្ថេតិ ឯកំ សម្មសនំ យា កាចិ វេទនា ។ បេ ។ យា កាចិ សញ្ញា យេកេចិ សង្ខារា យំ-កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ អនិច្ចតោ វវត្ថេតិ ឯកំ សម្មសនំ ទុក្ខតោ វវត្ថេតិ ឯកំ សម្មសនំ អនត្តតោ វវត្ថេតិ ឯកំ សម្មសនំ ចក្ខុំ ។ បេ ។ ជរាមរណំ អតីតានាគតប្បច្ចុប្បន្នំ អនិច្ចតោ វវត្ថេតិ ឯកំ សម្មសនំ ទុក្ខតោ វវត្ថេតិ ឯកំ សម្មសនំ អនត្តតោ វវត្ថេតិ ឯកំ សម្មសនំ ។

[១០០] រូបំ អតីតានាគតប្បច្ចុប្បន្នំ អនិច្ចំ

[៩៩] បញ្ញាក្នុងការបំប្រួញ នូវពួកធម៌ជាអតីត អនាគតនិង បច្ចុប្បន្ន ហើយកំណត់ទុក ឈ្មោះជាសម្មសនញ្ញាណ តើដូចម្តេច ។ រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបណា ក្នុងទីឆ្ងាយឬទីជិតក្តី បុគ្គលកំណត់ទុក នូវរូបទាំងអស់នោះថាមិនទៀង ឈ្មោះជាសម្មសនញ្ញាណ ១ កំណត់ទុកថាជាទុក្ខ ឈ្មោះជាសម្មសនញ្ញាណ ១ កំណត់ទុកថាមិនមែនខ្លួន ឈ្មោះជាសម្មសនញ្ញាណ ១ វេទនាណាមួយ ។ បេ ។ សញ្ញាណាមួយ សង្ខារណាមួយ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វិញ្ញាណណា ក្នុងទីឆ្ងាយឬទីជិតក្តី បុគ្គលកំណត់ទុក នូវវិញ្ញាណទាំងអស់នោះ ថា មិនទៀង ឈ្មោះជាសម្មសនញ្ញាណ ១ កំណត់ទុកថាជាទុក្ខ ឈ្មោះជាសម្មសនញ្ញាណ ១ កំណត់ទុកថាមិនមែនខ្លួន ឈ្មោះជាសម្មសនញ្ញាណ ១ កំណត់ទុកនូវចក្ខុ ។ បេ ។ កំណត់ទុក នូវជរានិងមរណៈ ជាអតីត អនាគត បច្ចុប្បន្នថាមិនទៀង ឈ្មោះជាសម្មសនញ្ញាណ ១ កំណត់ទុកថាជាទុក្ខ ឈ្មោះជាសម្មសនញ្ញាណ ១ កំណត់ទុកថាមិនមែនខ្លួន ឈ្មោះជាសម្មសនញ្ញាណ ១ ។

[១០០] រូបជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះជាមិនទៀង

ខយដ្ឋេន ទុក្ខំ ភយដ្ឋេន អនត្តា អសារកដ្ឋេនាតិ សង្ខិបិត្វា វវត្ថានេ បញ្ញា សម្មសនេ ញាណំ វេទ-នា សញ្ញា សង្ខារា វិញ្ញាណំ ចក្ខុំ ។ បេ ។ ជរា-មរណំ អតីតានាគតបច្ចុប្បន្នំ អនិច្ចំ ខយដ្ឋេន ទុក្ខំ ភយដ្ឋេន អនត្តា អសារកដ្ឋេនាតិ សង្ខិបិត្វា វវត្ថានេ បញ្ញា សម្មសនេ ញាណំ ។

[១០១] រូបំ អតីតានាគតបច្ចុប្បន្នំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មន្តិ សង្ខិបិត្វា វវត្ថានេ បញ្ញា សម្មសនេ ញាណំ វេទនា សញ្ញា សង្ខារា វិញ្ញាណំ ចក្ខុំ ។ បេ ។ ជរាមរណំ អតីតានាគតបច្ចុប្បន្នំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មន្តិ សង្ខិបិត្វា វវត្ថានេ បញ្ញា សម្មសនេ ញាណំ ។

[១០២] ជាតិប្បច្ចយា ជរាមរណំ អសតិ ជាតិយា

ដោយអត្ថថាអស់ទៅ ឈ្មោះថាទុក្ខ ដោយអត្ថថាគួរខ្លាច ឈ្មោះថាអនត្តា ដោយអត្ថថាមិនមានខ្លឹម ហេតុនោះ បញ្ញា ក្នុងការបំប្រួញហើយកំណត់ទុក ឈ្មោះថាសម្មសនញ្ញាណ វេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ ជរានិងមរណៈ ជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថាមិនទៀង ដោយអត្ថថាអស់ទៅ ឈ្មោះថាទុក្ខ ដោយអត្ថថាគួរខ្លាច ឈ្មោះថាមិនមែនខ្លួន ដោយអត្ថថាមិនមានខ្លឹម ហេតុនោះ បញ្ញា ក្នុងការបំប្រួញហើយកំណត់ទុក ឈ្មោះថាសម្មសនញ្ញាណ ។

[១០១] រូបជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថាមិនទៀង ត្រូវបច្ច័យតាក់តែង កើតឡើងព្រោះគ្រឿងអាស្រ័យ មានការអស់ទៅជាធម្មតា សូន្យទៅជាធម្មតា ប្រាសចាកតម្រេកជាធម្មតា រលត់ទៅជាធម្មតា ហេតុនោះ បញ្ញាក្នុងការបំប្រួញហើយកំណត់ទុក ឈ្មោះថាសម្មសនញ្ញាណ វេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ ជរានិងមរណៈ ជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថាមិនទៀង ត្រូវបច្ច័យតាក់តែង កើតឡើងព្រោះគ្រឿងអាស្រ័យ មានការអស់ទៅជាធម្មតា សូន្យទៅជាធម្មតា ប្រាសចាកតម្រេកជាធម្មតា រលត់ទៅជាធម្មតា ហេតុនោះ បញ្ញាក្នុងការបំប្រួញហើយកំណត់ទុក ឈ្មោះថាសម្មសនញ្ញាណ។

[១០២] ជរានិងមរណៈមាន ព្រោះជាតិជាបច្ច័យ កាលជាតិមិនមាន

ជត្តិ ជរាមរណន្តិ សង្ខិបិត្វា វវត្ថានេ បញ្ញា សម្មសនេ ញាណំ អតីតម្បិ អទ្ធានំ អនាគតម្បិ អទ្ធានំ ជាតិប្បច្ចយា ជរាមរណំ អសតិ ជាតិយា ជត្តិ ជរាមរណន្តិ សង្ខិបិត្វា វវត្ថានេ បញ្ញា សម្មសនេ ញាណំ ភវប្បច្ចយា ជាតិ អសតិ ។ បេ ។ ឧបាទា-នប្បច្ចយា ភវោ អសតិ តណ្ហាបច្ចយា ឧបាទានំ អសតិ វេទនាបច្ចយា តណ្ហា អសតិ ផស្សប្ប-ច្ចយា វេទនា អសតិ សឡាយតនប្បច្ចយា ផស្សោ អសតិ នាមរូបប្បច្ចយា សឡាយតនំ អសតិ វិញ្ញាណ-ប្បច្ចយា នាមរូបំ អសតិ សង្ខារប្បច្ចយា វិញ្ញាណំ អសតិ អវិជ្ជាបច្ចយា សង្ខារា អសតិ អវិជ្ជាយ ជត្តិ សង្ខារាតិ សង្ខិបិត្វា វវត្ថានេ បញ្ញា សម្មសនេ ញាណំ

ជរានិងមរណៈ ក៏មិនមាន ហេតុនោះ បញ្ញាក្នុងការបំប្រួញហើយ កំណត់ទុក ឈ្មោះថាសម្មសនញ្ញាណ ជរានិងមរណៈមាន ព្រោះជាតិជាបច្ច័យ កាលបើជាតិមិនមាន ជរានិងមរណៈក៏មិនមាន អស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញាក្នុងការបំប្រួញហើយកំណត់ទុក ឈ្មោះថាសម្មសនញ្ញាណ ជាតិមានព្រោះភពជាបច្ច័យ កាលបើភពមិនមាន ។ បេ ។ ភពមាន ព្រោះឧបាទានជាបច្ច័យ កាលបើឧបាទានមិនមាន ភពក៏មិនមាន ឧបាទានមានព្រោះតណ្ហាជាបច្ច័យ កាលបើតណ្ហាមិនមាន ឧបាទានក៏មិនមាន តណ្ហាមាន ព្រោះវេទនាជាបច្ច័យ កាលបើវេទនាមិនមាន តណ្ហាក៏មិនមាន វេទនាមាន ព្រោះផស្សៈជាបច្ច័យ កាលបើផស្សៈមិនមាន វេទនាក៏មិនមាន ផស្សៈមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ កាលបើអាយតនៈ ៦ មិនមាន ផស្សៈក៏មិនមាន អាយតនៈ ៦ មាន ព្រោះនាមនិងរូបជាបច្ច័យ កាលបើនាមនិងរូបមិនមាន អាយតនៈ ៦ ក៏មិនមាន នាមនិងរូបមាន ព្រោះវិញ្ញាណជាបច្ច័យ កាលបើវិញ្ញាណមិនមាន នាមនិងរូបក៏មិនមាន វិញ្ញាណមាន ព្រោះសង្ខារជាបច្ច័យ កាលបើសង្ខារមិនមាន វិញ្ញាណក៏មិនមាន សង្ខារមាន ព្រោះអវិជ្ជាជាបច្ច័យ កាលបើអវិជ្ជាមិនមាន សង្ខារក៏មិនមាន ហេតុនោះ បញ្ញា ក្នុងការបំប្រួញហើយកំណត់ទុក ឈ្មោះថាសម្មសនញ្ញាណ

អតីតម្បិ អទ្ធានំ អនាគតម្បិ អទ្ធានំ អវិជ្ជាបច្ចយា សង្ខារា អសតិ អវិជ្ជាយ នត្ថិ សង្ខារាតិ សង្ខិបិត្វា វវត្ថានេ បញ្ញា សម្មសនេ ញាណំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ អតីតា-នាគតប្បច្ចុប្បន្នានំ ធម្មានំ សង្ខិបិត្វា វវត្ថានេ បញ្ញា សម្មសនេ ញាណំ ។

[១០៣] កថំ បច្ចុប្បន្នានំ ធម្មានំ វិបរិណាមា-នុបស្សនេ បញ្ញា ឧទយព្វយានុបស្សនេ ញាណំ ។ ជាតំ រូបំ បច្ចុប្បន្នំ តស្ស និព្វត្តិលក្ខណំ ឧទយោ វិបរិណាមលក្ខណំ វយោ អនុបស្សនាញាណំ ជាតា វេទនា ជាតា សញ្ញា ជាតា សង្ខារា ជាតំ វិញ្ញាណំ ជាតំ ចក្ខុំ ។ បេ ។ ជាតោ ភវោ បច្ចុប្បន្នោ តស្ស និព្វត្តិលក្ខណំ ឧទយោ វិបរិណាមលក្ខណំ វយោ អនុបស្សនា ញាណំ ។

[១០៤] បញ្ចន្នំ ខន្ធានំ ឧទយំ បស្សន្តោ កតិ លក្ខណានិ បស្សតិ វយំ បស្សន្តោ កតិ លក្ខណានិ បស្សតិ ឧទយព្វយំ បស្សន្តោ កតិលក្ខណានិ បស្សតិ

សង្ខារមាន ព្រោះអវិជ្ជាជាបច្ច័យ កាលបើអវិជ្ជាមិនមាន សង្ខារក៏មិនមាន អស់អតីតកាលផង អស់អនាគតកាលផង ហេតុនោះ បញ្ញាក្នុងការបំ-ប្រួញហើយកំណត់ទុក ឈ្មោះថាសម្មសនញ្ញាណ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការបំប្រួញហើយកំណត់ទុក នូវពួកធម៌ជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថាសម្មសនញ្ញាណ ។

[១០៣] បញ្ញាក្នុងការឃើញ នូវការប្រែប្រួលនៃពួកធម៌ជាបច្ចុប្បន្ន ឈ្មោះថាឧទយព្វយានុបស្សនាញាណ តើដូចម្ដេច ។ រូបជាបច្ចុប្បន្នកើតហើយ ការចម្រើនឡើងនៃរូបនោះ ជាលក្ខណៈនៃការកើត ការសូន្យទៅ ជាលក្ខណៈនៃការប្រែប្រួល ឈ្មោះថាអនុបស្សនាញាណ វេទនាកើតហើយ សញ្ញាកើតហើយ សង្ខារកើតហើយ វិញ្ញាណកើតហើយ ចក្ខុកើតហើយ ។ បេ ។ ភពជាបច្ចុប្បន្នកើតហើយ ការចម្រើនឡើងនៃភពនោះ ជាលក្ខណៈនៃការកើត ការសូន្យទៅ ជាលក្ខណៈនៃការប្រែប្រួល ឈ្មោះថាអនុបស្សនាញាណ ។

[១០៤] បុគ្គលកាលឃើញនូវការចម្រើនឡើងនៃបញ្ចក្ខន្ធ តើឃើញលក្ខណៈប៉ុន្មាន កាលឃើញនូវការសូន្យទៅ តើឃើញលក្ខណៈប៉ុន្មាន កាលឃើញនូវការចម្រើនឡើងនិងការសូន្យទៅ តើឃើញលក្ខណៈប៉ុន្មាន

បញ្ចន្នំ ខន្ធានំ ឧទយំ បស្សន្តោ បញ្ចវីសតិ លក្ខ-ណានិ បស្សតិ វយំ បស្សន្តោ បញ្ចវីសតិ លក្ខណានិ បស្សតិ ឧទយព្វយំ បស្សន្តោ បញ្ញាសំ លក្ខណានិ បស្សតិ ។

[១០៥] រូបក្ខន្ធស្ស ឧទយំ បស្សន្តោ កតិ លក្ខណានិ បស្សតិ វយំ បស្សន្តោ កតិ លក្ខ-ណានិ បស្សតិ ឧទយព្វយំ បស្សន្តោ កតិ លក្ខ-ណានិ បស្សតិ វេទនាខន្ធស្ស សញ្ញាខន្ធស្ស សង្ខា-រក្ខន្ធស្ស វិញ្ញាណក្ខន្ធស្ស ឧទយំ បស្សន្តោ កតិ លក្ខណានិ បស្សតិ វយំ បស្សន្តោ កតិ លក្ខណានិ បស្សតិ ឧទយព្វយំ បស្សន្តោ កតិ លក្ខណានិ បស្សតិ ។ រូបក្ខន្ធស្ស ឧទយំ បស្សន្តោ បញ្ច លក្ខណានិ បស្សតិ វយំ បស្សន្តោ បញ្ច លក្ខណានិ បស្សតិ ឧទយព្វយំ បស្សន្តោ ទស លក្ខណានិ បស្សតិ វេទនាខន្ធស្ស សញ្ញាខន្ធស្ស សង្ខារក្ខន្ធស្ស វិញ្ញាណក្ខន្ធស្ស ឧទយំ បស្សន្តោ បញ្ច លក្ខណានិ បស្សតិ វយំ បស្សន្តោ បញ្ច លក្ខណានិ បស្សតិ ឧទយព្វយំ បស្សន្តោ ទស លក្ខណានិ បស្សតិ ។

បុគ្គលកាលឃើញនូវការចម្រើនឡើងនៃបញ្ចក្ខន្ធ រមែងឃើញនូវលក្ខណៈ ២៥ កាលឃើញនូវការសូន្យទៅ រមែងឃើញនូវលក្ខណៈ ២៥ កាលឃើញនូវការចម្រើនឡើងនិងការសូន្យទៅ រមែងឃើញនូវលក្ខណៈ៥០ ។

[១០៥] បុគ្គលកាលឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ តើឃើញលក្ខណៈប៉ុន្មាន កាលឃើញនូវការសូន្យទៅ តើឃើញលក្ខណៈប៉ុន្មាន កាលឃើញនូវការចម្រើនឡើងនិងការសូន្យទៅ តើឃើញលក្ខណៈប៉ុន្មាន បុគ្គលកាលឃើញនូវការចម្រើនឡើងនៃវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ តើឃើញលក្ខណៈប៉ុន្មាន កាលឃើញនូវការសូន្យទៅ តើឃើញលក្ខណៈប៉ុន្មាន កាលឃើញនូវការចម្រើនឡើងនិងសូន្យទៅ តើឃើញលក្ខណៈប៉ុន្មាន ។ បុគ្គលកាលឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ រមែងឃើញលក្ខណៈ ៥ កាលឃើញ នូវការសូន្យទៅ រមែងឃើញលក្ខណៈ ៥ កាលឃើញនូវការចម្រើនឡើងនិងសូន្យទៅ រមែងឃើញលក្ខណៈ ១០ បុគ្គលកាលឃើញនូវការចម្រើនឡើងនៃវេទនាខន្ធ សញ្ញា-ខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ រមែងឃើញលក្ខណៈ ៥ កាលឃើញនូវការសូន្យទៅ រមែងឃើញលក្ខណៈ ៥ កាលឃើញនូវការចម្រើនឡើងនិងការសូន្យទៅ រមែងឃើញលក្ខណៈ ១០ ។

[១០៦] រូបក្ខន្ធស្ស ឧទយំ បស្សន្តោ កាតមានិ បញ្ច លក្ខណានិ បស្សតិ ។ អវិជ្ជាសមុទយា រូបសមុទយោតិ បច្ចយសមុទយដ្ឋេន រូបក្ខន្ធស្ស ឧទយំ បស្សតិ តណ្ហាសមុទយា រូបសមុទយោតិ បច្ចយសមុទយដ្ឋេន រូបក្ខន្ធស្ស ឧទយំ បស្សតិ កម្មសមុទយា រូបសមុទយោតិ បច្ចយសមុទយដ្ឋេន រូបក្ខន្ធស្ស ឧទយំ បស្សតិ អាហារសមុទយា រូបសមុទយោតិ បច្ចយសមុទយដ្ឋេន រូបក្ខន្ធស្ស ឧទយំ បស្សតិ និព្វត្តិលក្ខណំ បស្សន្តោបិ រូបក្ខន្ធស្ស ឧទយំ បស្សតិ រូបក្ខន្ធស្ស ឧទយំ បស្សន្តោ ឥមានិ បញ្ច លក្ខណានិ បស្សតិ ។

[១០៧] វយំ បស្សន្តោ កាតមានិ បញ្ច លក្ខណានិ បស្សតិ ។ អវិជ្ជានិរោធា រូបនិរោធោតិ បច្ចយនិរោធដ្ឋេន រូបក្ខន្ធស្ស វយំ បស្សតិ តណ្ហានិរោធា រូបនិរោធោតិ បច្ចយនិរោធដ្ឋេន រូបក្ខន្ធស្ស វយំ បស្សតិ កម្មនិរោធា រូបនិរោធោតិ បច្ចយនិរោធដ្ឋេន រូបក្ខន្ធស្ស វយំ បស្សតិ

[១០៦] បុគ្គលកាលឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ រមែងឃើញលក្ខណៈ ៥ តើដូចម្តេច ។ បុគ្គលឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ ដោយអត្ថថាកើតឡើងនៃបច្ច័យ ថា ការកើតឡើងនៃរូប ព្រោះកើតឡើងនៃអវិជ្ជា ១ ឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ ដោយអត្ថថាកើតឡើងនៃបច្ច័យ ថា ការកើតឡើងនៃរូប ព្រោះកើតឡើងនៃតណ្ហា ១ ឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ ដោយអត្ថថាកើតឡើងនៃបច្ច័យ ថា ការកើតឡើងនៃរូប ព្រោះកើតឡើងនៃកម្ម ១ ឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ ដោយអត្ថថាកើតឡើងនៃបច្ច័យ ថា ការកើតឡើងនៃរូប ព្រោះកើតឡើងនៃអាហារ ១ មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈនៃការកើត ឈ្មោះថាឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ ១ បុគ្គលកាលឃើញនូវការចម្រើនឡើងនៃរូបក្ខន្ធ រមែងឃើញលក្ខណៈទាំង ៥ នេះ ។

[១០៧] បុគ្គលកាលឃើញនូវការសូន្យទៅ (នៃរូបក្ខន្ធ) រមែងឃើញលក្ខណៈ ៥ តើដូចម្តេច ។ បុគ្គលឃើញនូវការសូន្យទៅនៃរូបក្ខន្ធ ដោយអត្ថថារលត់ទៅនៃបច្ច័យ ថា ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃអវិជ្ជា១ ឃើញនូវការសូន្យទៅនៃរូបក្ខន្ធ ដោយអត្ថថារលត់ទៅនៃបច្ច័យ ថា ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃតណ្ហា ១ ឃើញនូវការសូន្យទៅនៃរូប-ក្ខន្ធ ដោយអត្ថថារលត់ទៅនៃបច្ច័យ ថា ការរលត់ទៅនៃរូបព្រោះរលត់

អាហារនិរោធា រូបនិរោធោតិ បច្ចយនិរោធដ្ឋេន រូបក្ខន្ធស្ស វយំ បស្សតិ វិបរិណាមលក្ខណំ បស្សន្តោបិ រូបក្ខន្ធស្ស វយំ បស្សតិ រូបក្ខន្ធស្ស វយំ បស្សន្តោ ឥមានិ បញ្ច លក្ខណានិ បស្សតិ ឧទយព្វយំ បស្សន្តោ ឥមានិ ទស លក្ខណានិ បស្សតិ ។

[១០៨] វេទនាខន្ធស្ស ឧទយំ បស្សន្តោ កតមានិ បញ្ច លក្ខណានិ បស្សតិ ។ អវិជ្ជាសមុទយា វេទនាសមុទយោតិ បច្ចយសមុទយដ្ឋេន វេទនាខន្ធស្ស ឧទយំ បស្សតិ តណ្ហាសមុទយា វេទនាសមុទយោតិ បច្ចយសមុទយដ្ឋេន វេទនាខន្ធស្ស ឧទយំ បស្សតិ កម្មសមុទយា វេទនាសមុទយោតិ បច្ចយសមុទយដ្ឋេន វេទនាខន្ធស្ស ឧទយំ បស្សតិ ផស្សសមុទយា វេទនាសមុទយោតិ បច្ចយសមុទយដ្ឋេន វេទនាខន្ធស្ស ឧទយំ បស្សតិ និព្វត្តិលក្ខណំ បស្សន្តោបិ វេទនាខន្ធស្ស ឧទយំ បស្សតិ វេទនាខន្ធស្ស ឧទយំ បស្សន្តោ ឥមានិ បញ្ច លក្ខណានិ បស្សតិ ។

ទៅនៃកម្ម ១ ឃើញនូវការសូន្យទៅនៃរូបក្ខន្ធ ដោយអត្ថថារលត់ទៅនៃបច្ច័យ ថា ការរលត់ទៅនៃរូប ព្រោះរលត់ទៅនៃអាហារ ១ មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈប្រែប្រួល ឈ្មោះថាឃើញនូវការសូន្យទៅនៃរូបក្ខន្ធ ១ បុគ្គលកាលឃើញនូវការសូន្យទៅនៃរូបក្ខន្ធ រមែងឃើញលក្ខណៈទាំង ៥ នេះ បុគ្គលកាលឃើញនូវការចម្រើនឡើងនិងការសូន្យទៅ (នៃរូបក្ខន្ធ) រមែងឃើញលក្ខណៈទាំង ១០ នេះឯង ។

[១០៨] បុគ្គលកាលឃើញនូវការចម្រើននៃវេទនាខន្ធ រមែងឃើញលក្ខណៈ ៥ តើដូចម្ដេច ។ បុគ្គលឃើញនូវការចម្រើនឡើងនៃវេទនាខន្ធ ដោយអត្ថថាកើតឡើងនៃបច្ច័យ ថា ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃអវិជ្ជា ១ ឃើញនូវការចម្រើនឡើងនៃវេទនាខន្ធ ដោយអត្ថថាកើតឡើងនៃបច្ច័យ ថា ការកើតឡើងនៃវេទនាព្រោះកើតឡើងនៃតណ្ហា១ ឃើញនូវការចម្រើនឡើងនៃវេទនាខន្ធ ដោយអត្ថថាកើតឡើងនៃបច្ច័យ ថា ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃកម្ម ១ ឃើញនូវការចម្រើនឡើងនៃវេទនាខន្ធ ដោយអត្ថថាកើតឡើងនៃបច្ច័យ ថា ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃផស្សៈ ១ មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈកើតឡើង ឈ្មោះថាឃើញនូវការចម្រើនឡើងនៃវេទនាខន្ធ ១ បុគ្គលកាលឃើញ នូវការចម្រើនឡើងនៃវេទនាខន្ធ រមែងឃើញលក្ខណៈទាំង ៥ នេះ ។

[១០៩] វយំ បស្សន្តោ កតមានិ បញ្ច លក្ខ-ណានិ បស្សតិ ។ អវិជ្ជានិរោធា វេទនានិរោធោតិ បច្ចយនិរោធដ្ឋេន វេទនាខន្ធស្ស វយំ បស្សតិ តណ្ហានិរោធា វេទនានិរោធោតិ បច្ចយនិរោធដ្ឋេន វេទនាខន្ធស្ស វយំ បស្សតិ កម្មនិរោធា វេទនានិរោ-ធោតិ បច្ចយនិរោធដ្ឋេន វេទនាខន្ធស្ស វយំ បស្សតិ ផស្សនិរោធា វេទនានិរោធោតិ បច្ចយនិរោធដ្ឋេន វេទនាខន្ធស្ស វយំ បស្សតិ វិបរិណាមលក្ខណំ បស្ស-ន្តោបិ វេទនាខន្ធស្ស វយំ បស្សតិ វេទនាខន្ធស្ស វយំ បស្សន្តោ ឥមានិ បញ្ច លក្ខណានិ បស្សតិ ឧទយព្វយំ បស្សន្តោ ឥមានិ ទស លក្ខណានិ បស្សតិ ។

[១១០] សញ្ញាខន្ធស្ស សង្ខារក្ខន្ធស្ស វិញ្ញា-ណក្ខន្ធស្ស ឧទយំ បស្សន្តោ កតមានិ បញ្ច លក្ខណានិ បស្សតិ ។ អវិជ្ជាសមុទយា វិញ្ញាណ-សមុទយោតិ បច្ចយសមុទយដ្ឋេន វិញ្ញាណក្ខន្ធស្ស ឧទយំ បស្សតិ តណ្ហាសមុទយា វិញ្ញាណសមុទ-យោតិ បច្ចយសមុទយដ្ឋេន វិញ្ញាណក្ខន្ធស្ស

[១០៩] បុគ្គលកាលឃើញនូវការសូន្យទៅ (នៃវេទនាខន្ធ) រមែងឃើញលក្ខណៈ ៥ តើដូចម្តេច ។ បុគ្គលឃើញនូវការសូន្យទៅនៃវេទនាខន្ធ ដោយអត្ថថារលត់ទៅនៃបច្ច័យ ថា ការរលត់ទៅនៃវេទនា ព្រោះរលត់ទៅនៃអវិជ្ជា ឃើញនូវការសូន្យទៅនៃវេទនាខន្ធ ដោយអត្ថថារលត់ទៅនៃបច្ច័យ ថាការរលត់ទៅនៃវេទនា ព្រោះរលត់ទៅនៃតណ្ហា ឃើញនូវការសូន្យទៅនៃវេទនាខន្ធ ដោយអត្ថថារលត់ទៅនៃបច្ច័យ ថា ការរលត់ទៅនៃវេទនា ព្រោះរលត់ទៅនៃកម្ម ឃើញនូវការសូន្យទៅនៃវេទនាខន្ធ ដោយអត្ថថារលត់ទៅនៃបច្ច័យ ថា ការរលត់ទៅនៃវេទនា ព្រោះរលត់ទៅនៃផស្សៈ ១ មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈប្រែប្រួល ឈ្មោះថាឃើញនូវការសូន្យទៅនៃវេទនាខន្ធ ១ បុគ្គលកាលឃើញនូវការសូន្យទៅនៃវេទនាខន្ធ រមែងឃើញលក្ខណៈទាំង ៥ នេះ បុគ្គលកាលឃើញនូវការចម្រើនឡើងនិងការសូន្យទៅ (នៃវេទនាខន្ធ) រមែងឃើញលក្ខណៈទាំង ១០ នេះឯង ។

[១១០] បុគ្គលកាលឃើញ នូវការចម្រើនឡើងនៃសញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ រមែងឃើញលក្ខណៈ ៥ តើដូចម្តេច ។ បុគ្គលឃើញ នូវការចម្រើនឡើងនៃវិញ្ញាណក្ខន្ធ ដោយអត្ថថាកើតឡើងនៃបច្ច័យ ថា ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃអវិជ្ជា ១ ឃើញនូវការចម្រើនឡើង នៃវិញ្ញាណខន្ធ ដោយអត្ថថាកើតឡើងនៃបច្ច័យ ថា ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃតណ្ហា ១

ឧទយំ បស្សតិ កម្មសមុទយា វិញ្ញាណសមុទយោតិ បច្ចយសមុទយដ្ឋេន វិញ្ញាណក្ខន្ធស្ស ឧទយំ បស្សតិ នាមរូបសមុទយា វិញ្ញាណសមុទយោតិ បច្ចយស-មុទយដ្ឋេន វិញ្ញាណក្ខន្ធស្ស ឧទយំ បស្សតិ និព្វត្តិ-លក្ខណំ បស្សន្តោបិ វិញ្ញាណក្ខន្ធស្ស ឧទយំ បស្សតិ វិញ្ញាណក្ខន្ធស្ស ឧទយំ បស្សន្តោ ឥមានិ បញ្ច លក្ខណានិ បស្សតិ ។

[១១១] វយំ បស្សន្តោ កតមានិ បញ្ច លក្ខ-ណានិ បស្សតិ ។ អវិជ្ជានិរោធា វិញ្ញាណនិរោធោតិ បច្ចយនិរោធដ្ឋេន វិញ្ញាណក្ខន្ធស្ស វយំ បស្សតិ តណ្ហានិរោធា វិញ្ញាណនិរោធោតិ បច្ចយនិរោធដ្ឋេន វិញ្ញាណក្ខន្ធស្ស វយំ បស្សតិ កម្មនិរោធា វិញ្ញា-ណនិរោធោតិ បច្ចយនិរោធដ្ឋេន វិញ្ញាណក្ខន្ធស្ស វយំ បស្សតិ នាមរូបនិរោធា វិញ្ញាណនិរោធោតិ បច្ចយនិរោធដ្ឋេន វិញ្ញាណក្ខន្ធស្ស វយំ បស្សតិ វិបរិណាមលក្ខណំ បស្សន្តោបិ វិញ្ញាណក្ខន្ធស្ស វយំ បស្សតិ វិញ្ញាណក្ខន្ធស្ស វយំ បស្សន្តោ

ឃើញនូវការចម្រើនឡើងនៃវិញ្ញាណក្ខន្ធ ដោយអត្ថថាកើតឡើងនៃបច្ច័យ ថា ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃកម្ម ១ ឃើញនូវការចម្រើនឡើងនៃវិញ្ញាណក្ខន្ធ ដោយអត្ថថាកើតឡើងនៃបច្ច័យ ថា ការកើតឡើងនៃវិញ្ញាណ ព្រោះកើតឡើងនៃនាមនិងរូប ១ មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈកើត ឈ្មោះថាឃើញនូវការចម្រើនឡើងនៃវិញ្ញាណក្ខន្ធ ១ បុគ្គលកាលឃើញនូវការចម្រើនឡើងនៃវិញ្ញាណក្ខន្ធ រមែងឃើញលក្ខណៈទាំង ៥ នេះ ។

[១១១] បុគ្គលកាលឃើញនូវការសូន្យទៅ (នៃវិញ្ញាណ) រមែងឃើញលក្ខណៈ ៥ តើដូចម្តេច ។ បុគ្គលឃើញនូវការសូន្យទៅនៃវិញ្ញាណក្ខន្ធ ដោយអត្ថថារលត់ទៅនៃបច្ច័យ ថា ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់ទៅនៃអវិជ្ជា ១ ឃើញនូវការសូន្យទៅនៃវិញ្ញាណក្ខន្ធ ដោយអត្ថថារលត់ទៅនៃបច្ច័យ ថា ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់ទៅនៃតណ្ហា ១ ឃើញនូវការសូន្យទៅនៃវិញ្ញាណក្ខន្ធ ដោយអត្ថថារលត់ទៅនៃបច្ច័យ ថា ការរលត់ទៅនៃវិញ្ញាណព្រោះរលត់ទៅនៃកម្ម ១ ឃើញនូវការសូន្យទៅនៃវិញ្ញាណក្ខន្ធដោយអត្ថថារលត់ទៅនៃបច្ច័យ ថា ការរលត់ទៅនៃវិញ្ញាណ ព្រោះរលត់ទៅនៃនាមនិងរូប មួយទៀត បុគ្គលកាលឃើញនូវលក្ខណៈប្រែប្រួល ឈ្មោះថាឃើញនូវការសូន្យទៅ នៃវិញ្ញាណក្ខន្ធ ១ បុគ្គលកាលឃើញនូវការសូន្យទៅ នៃវិញ្ញាណក្ខន្ធ រមែងឃើញ

ឥមានិ បញ្ច លក្ខណានិ បស្សតិ ឧទយព្វយំ បស្ស-ន្តោ ឥមានិ ទស លក្ខណានិ បស្សតិ បញ្ចន្នំ ខន្ធានំ ឧទយំ បស្សន្តោ ឥមានិ បញ្ចវីសតិ លក្ខណានិ បស្សតិ វយំ បស្សន្តោ ឥមានិ បញ្ចវីសតិ លក្ខណានិ បស្សតិ ឧទយព្វយំ បស្សន្តោ ឥមានិ បញ្ញាសំ លក្ខណានិ បស្សតិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ បច្ចុប្បន្នានំ ធម្មានំ វិបរិណាមានុបស្សនេ បញ្ញា ឧទយព្វយានុបស្សនេ ញាណំ ។

រូបក្ខន្ធា អាហារសមុទយា[១] វេទនា សញ្ញា សង្ខារាតិ សេសា[២] ខន្ធា ផស្សសមុទយា វិញ្ញាណក្ខន្ធា នាមរូបសមុទយា ។

[១១២] កថំ អារម្មណំ បដិសង្ខា ភង្គានុបស្សនេ បញ្ញា វិបស្សនេ ញាណំ ។ រូបារម្មណតាចិត្តំ[៣] ឧប្បជ្ជិត្វា ភិជ្ជតិ តំ អារម្មណំ បដិសង្ខា តស្ស ចិត្តស្ស ភង្គំ អនុបស្សតិ ។ អនុបស្សតីតិ កថំ អនុបស្សតិ ។ អនិច្ចតោ អនុបស្សតិ នោ និច្ចតោ ទុក្ខតោ អនុបស្សតិ នោ សុខតោ អនត្តតោ អនុបស្សតិ នោ អត្តតោ

១ ឱ. ម. បញ្ញាយ ។ ២ ឱ. អវិមុត្តតា ។ ៣ បដិសម្ភិទាមគ្គដ្ឋកថាយំ រូបារម្មណតាចិត្តន្តិ រូបារម្មណំ ចិត្តន្តិ ទិស្សតិ ។

នូវលក្ខណៈ ៥ នេះ កាលឃើញនូវការចម្រើនឡើង និងការសូន្យទៅ តែងឃើញនូវលក្ខណៈ ១០ នេះ កាលឃើញនូវការចម្រើនឡើងនៃខន្ធទាំង ៥ តែងឃើញនូវលក្ខណៈ ២៥ នេះ កាលឃើញនូវការសូន្យទៅ តែងឃើញនូវលក្ខណៈ ២៥ នេះ កាលឃើញនូវការចម្រើនឡើងនិងការសូន្យទៅ តែងឃើញនូវលក្ខណៈ ៥០ នេះ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា ក្នុងការឃើញនូវការប្រែប្រួលនៃពួកធម៌ជាបច្ចុប្បន្ន ឈ្មោះថាឧទយព្វយានុបស្សនាញាណ ។ រូបក្ខន្ធ កើតឡើងព្រោះអាហារ ខន្ធដ៏សេស គឺ វេទនា សញ្ញា សង្ខារ កើតឡើងព្រោះផស្សៈ វិញ្ញាណក្ខន្ធកើតឡើង ព្រោះនាមនិងរូប ។

[១១២] បញ្ញា ក្នុងការពិចារណាឃើញ នូវអារម្មណ៍ថាបែកធ្លាយ ឈ្មោះថាវិបស្សនាញាណ តើដូចម្តេច ។ ចិត្ត មានរូបជាអារម្មណ៍ កើតឡើងហើយបែកធ្លាយទៅវិញ បុគ្គលពិចារណាឃើញនូវការបែកធ្លាយ នៃចិត្តនោះ ព្រោះពិចារណា នូវអារម្មណ៍នោះ ។ ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញ ដូចម្តេច ។ ពិចារណាឃើញថាមិនទៀង មិនមែនពិចារណាឃើញ ថាទៀងទេ ពិចារណាឃើញថាជាទុក្ខ មិនមែនពិចារណាឃើញ ថាជាសុខទេ ពិចារណាឃើញថាមិនមែនខ្លួន មិនមែនពិចារណាឃើញ ថាខ្លួនទេ

និព្វិន្ទតិ នោ នន្ទតិ វិរជ្ជតិ នោ រជ្ជតិ និរោធេតិ នោ សមុទេតិ បដិនិស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហាតិ ទុក្ខតោ អនុប-ស្សន្តោ សុខសញ្ញំ បជហាតិ អនត្តតោ អនុបស្សន្តោ អត្តសញ្ញំ បជហាតិ និព្វិន្ទន្តោ នន្ទឹ បជហាតិ វិរជ្ជន្តោ រាគំ បជហាតិ និរោធេន្តោ សមុទយំ បជហាតិ បដិនិស្សជ្ជន្តោ អាទានំ បជហាតិ ។

[១១៣] វេទនារម្មណតា ។ បេ ។ សញ្ញារម្មណតា សង្ខារារម្មណតា វិញ្ញាណារម្មណតាចិត្តំ ។ បេ ។ ជរា-មរណារម្មណតាចិត្តំ ឧប្បជ្ជិត្វា ភិជ្ជតិ តំ អារម្មណំ បដិសង្ខា តស្ស ចិត្តស្ស ភង្គំ អនុបស្សតិ ។ អនុ-បស្សតីតិ កថំ អនុបស្សតិ ។ អនិច្ចតោ អនុបស្សតិ នោ និច្ចតោ ទុក្ខតោ អនុបស្សតិ នោ សុខតោ អនត្តតោ អនុបស្សតិ នោ អត្តតោ និព្វិន្ទតិ នោ នន្ទតិ វិរជ្ជតិ នោ រជ្ជតិ និរោធេតិ នោ សមុទេតិ បដិនិស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហាតិ ទុក្ខតោ អនុបស្សន្តោ

នឿយណាយ មិនរីករាយ ធុញទ្រាន់ មិនត្រេកអរ រំលត់ មិនឲ្យកើតឡើង រលាស់ចោល មិនកាន់យក បុគ្គលកាលពិចារណាឃើញថាមិនទៀង ក៏លះបង់នូវសញ្ញាថាទៀង កាលពិចារណាឃើញថាជាទុក្ខ ក៏លះបង់នូវសញ្ញាថាជាសុខ កាលពិចារណាឃើញថាមិនមែនខ្លួន ក៏លះបង់នូវសញ្ញាថាខ្លួន កាលនឿយណាយ ក៏លះបង់នូវសេចក្តីរីករាយ កាលធុញទ្រាន់ ក៏លះបង់នូវតម្រេក កាលរំលត់ ក៏លះបង់នូវការកើតឡើង កាលរលាស់ចោល ក៏លះបង់នូវសេចក្តីប្រកាន់ ។

[១១៣] ចិត្តមានវេទនាជាអារម្មណ៍ ។ បេ ។ មានសញ្ញាជាអារម្មណ៍ មានសង្ខារជាអារម្មណ៍ មានវិញ្ញាណជាអារម្មណ៍ ។ បេ ។ ចិត្តមានជរានិងមរណៈជាអារម្មណ៍ កើតឡើងហើយបែកធ្លាយទៅវិញ បុគ្គលពិចារណាឃើញនូវការបែកធ្លាយនៃចិត្តនោះ ព្រោះការពិចារណានូវអារម្មណ៍នោះ ។ ពាក្យថា ពិចារណាឃើញ តើពិចារណាឃើញ ដូចម្តេច ។ បុគ្គលពិចារណាឃើញថាមិនទៀង មិនមែនពិចារណាឃើញថាទៀងទេ ពិចារណាឃើញថាជាទុក្ខ មិនមែនពិចារណាឃើញថាជាសុខទេ ពិចារណាឃើញថាមិនមែនខ្លួន មិនមែនពិចារណាឃើញថាខ្លួនទេ នឿយណាយ មិនរីករាយ ធុញទ្រាន់ មិនត្រេកអរ រំលត់ មិនឲ្យកើតឡើង រលាស់ចោល មិនកាន់យក បុគ្គលកាលពិចារណាឃើញថាមិនទៀង ក៏លះបង់នូវសញ្ញាថាទៀង កាលពិចារណាឃើញថាជាទុក្ខ

សុខសញ្ញំ បជហាតិ អនត្តតោ អនុបស្សន្តោ អត្ត-សញ្ញំ បជហាតិ និព្វិន្ទន្តោ នន្ទឹ បជហាតិ វិរជ្ជន្តោ រាគំ បជហាតិ និរោធេន្តោ សមុទយំ បជហាតិ បដិនិស្សជ្ជន្តោ អាទានំ បជហាតិ ។

[១១៤] វត្ថុសង្កមនា ចេវ　បញ្ញាយ ច វិវដ្ដនា
អាវជ្ជនា ពលញ្ចេវ　បដិសង្ខា វិបស្សនា
អារម្មណំ អន្វយេន　ឧភោ ឯកវវត្ថនា
និរោធេ អធិមុត្តតា[១]　វយលក្ខណវិបស្សនា
អារម្មណញ្ច បដិសង្ខា　ភង្គញ្ច អនុបស្សតិ
សុញ្ញតោ ច ឧបដ្ឋានំ　អធិប្បញ្ញាវិបស្សនា
កុសលោ តីសុ អនុបស្សនាសុ　ចតូសុ ច វិបស្សនាសុ
តយោ ឧបដ្ឋានេ កុសលតា　នានាទិដ្ឋីសុ ន កម្បតីតិ ។

តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ អារម្មណំ បដិសង្ខា ភង្គានុបស្សនេ បញ្ញា វិបស្សនេ ញាណំ ។

---
១ ឱ. អវិមុត្តតា ។

ក៏លះបង់នូវសញ្ញាថាជាសុខ កាលពិចារណាឃើញថាមិនមែនខ្លួន ក៏លះបង់នូវសញ្ញាថាខ្លួន កាលនឿយណាយ ក៏លះបង់នូវសេចក្ដីរីករាយ កាលធុញទ្រាន់ ក៏លះបង់នូវតម្រេក កាលរំលត់ ក៏លះបង់នូវការកើតឡើង កាលរលាស់ចោល ក៏លះបង់នូវសេចក្ដីប្រកាន់ ។

[១១៤] ការរំកិលចិត្តចាកវត្ថុមុន ទៅកាន់វត្ថុផ្សេងវិញក្ដី ការវិវដ្តន៍នៃចិត្ត(១) ដោយបញ្ញាក្ដី កម្លាំងគឺការរំពឹងរក (នូវការបែកធ្លាយ) ក្ដី ឈ្មោះថាការពិចារណាឃើញ (នូវការបែកធ្លាយ) ការកំណត់នូវសភាពទាំងពីរថាតែមួយ ដោយការប្រព្រឹត្តតាមអារម្មណ៍ ភាពនៃបុគ្គលមានចិត្តចុះស៊ប់ក្នុងការរលត់ ឈ្មោះថាពិចារណាឃើញនូវលក្ខណៈ នៃការសូន្យ ការពិចារណានូវអារម្មណ៍ក្ដី បុគ្គលឃើញ នូវការបែកធ្លាយក្ដី ការប្រាកដឡើងថាសូន្យក្ដី ឈ្មោះថាការពិចារណាឃើញដោយបញ្ញាដ៏ក្រៃលែង ភិក្ខុអ្នកឈ្លាសវៃក្នុងអនុបស្សនាទាំង ៣ ផង ក្នុងវិបស្សនាទាំង ៤ ផង រមែងមិនញាប់ញ័រ ក្នុងទិដ្ឋិទាំងឡាយផ្សេងៗ ព្រោះខ្លួនជាអ្នកឈ្លាសវៃ ក្នុងការប្រាកដទាំង ៣ ។

ដែលឈ្មោះថាញាណនោះ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការដឹងនូវអារម្មណ៍ថាបែកធ្លាយ ឈ្មោះថាវិបស្សនាញាណ ។

១-ដំណើរចិត្តដែលលះបង់នូវការកើតនៃបញ្ចក្ខន្ធ ហើយតាំងនៅក្នុងការរលត់នៃបញ្ចក្ខន្ធ ។

[១១៩] កថំ ភយតុបដ្ឋានេ បញ្ញា អាទីនវេ ញាណំ ។ ឧប្បាទោ ភយន្តិ ភយតុបដ្ឋានេ បញ្ញា អាទីនវេ ញាណំ បវត្តំ ភយន្តិ ភយតុបដ្ឋានេ បញ្ញា អាទីនវេ ញាណំ និមិត្តំ ភយន្តិ ។ បេ ។ អាយុ-ហនា ភយន្តិ បដិសន្ធិ ភយន្តិ គតិ ភយន្តិ និព្វត្តិ ភយន្តិ ឧបបត្តិ ភយន្តិ ជាតិ ភយន្តិ ជរា ភយន្តិ ព្យាធិ ភយន្តិ មរណំ ភយន្តិ សោកោ ភយន្តិ បរិទេវោ ភយន្តិ ឧបាយាសោ ភយន្តិ ភយតុបដ្ឋានេ បញ្ញា អាទីនវេ ញាណំ ។ អនុប្បាទោ ខេមន្តិ សន្តិបទេ ញាណំ អប្បវត្តំ ខេមន្តិ សន្តិបទេ ញាណំ ។ បេ ។ អនុបាយាសោ ខេមន្តិ សន្តិបទេ ញាណំ ឧប្បាទោ ភយំ អនុប្បាទោ ខេមន្តិ សន្តិបទេ ញា-ណំ បវត្តំ ភយំ អប្បវត្តំ ខេមន្តិ សន្តិបទេ ញាណំ ។ បេ ។ ឧបាយាសោ ភយំ អនុបាយាសោ ខេមន្តិ សន្តិបទេ ញាណំ ឧប្បាទោ ទុក្ខន្តិ ភយ-តុបដ្ឋានេ បញ្ញា អាទីនវេ ញាណំ ។ បេ ។

[១១៥] បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ឈ្មោះថាអាទីនវញ្ញាណ តើដូចម្តេច ។ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យថា ការកើតជាភ័យ ឈ្មោះថាអាទីនវញ្ញាណ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យថា ការប្រព្រឹត្តជាភ័យ ឈ្មោះថាអាទីនវញ្ញាណ ថា និមិត្តជាភ័យ ។ បេ ។ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យថា ការប្រមូលមក ជាភ័យ ថា បដិសន្ធិជាភ័យ ថា គតិជាភ័យ ថា ការប្រព្រឹត្តជាភ័យ ថា ការកើតជាភ័យ ថា ជាតិជាភ័យ ថា ជរាជាភ័យ ថា ព្យាធិជាភ័យ ថា មរណៈជាភ័យ ថា សោកជាភ័យ ថា ការខ្សឹកខ្សួលជាភ័យ ថា ការចង្អៀតចង្អល់ចិត្តជាភ័យ ឈ្មោះថាអាទីនវញ្ញាណ ។ ញាណក្នុងសន្តិបទ (បទស្ងប់រម្ងាប់) ថា ការមិនកើតជាសេចក្តីក្សេម ញាណក្នុងសន្តិបទថា ការមិនប្រព្រឹត្ត ជាសេចក្តីក្សេម ។ បេ ។ ញាណក្នុងសន្តិបទថា សេចក្តីមិនចង្អៀតចង្អល់ចិត្ត ជាសេចក្តីក្សេម ញាណក្នុងសន្តិបទថា ការកើតជាភ័យ ការមិនកើតឡើង ជាសេចក្តីក្សេម ញាណក្នុងសន្តិបទថា ការប្រព្រឹត្ត ជាភ័យ ការមិនប្រព្រឹត្ត ជាសេចក្តីក្សេម ។ បេ ។ ញាណ ក្នុងសន្តិបទថា ការចង្អៀតចង្អល់ចិត្ត ជាភ័យ ការមិនចង្អៀតចង្អល់ចិត្ត ជាសេចក្តីក្សេម បញ្ញា ក្នុងការប្រាកដឡើងថាជាភ័យថា ការកើត ជាទុក្ខ ឈ្មោះថាអាទីនវញ្ញាណ ។ បេ ។

ឧទាយាសោ ទុក្ខន្តិ ភយតុបដ្ឋានេ បញ្ញា អាទីនវេ ញាណំ អនុប្បាទោ សុខន្តិ សន្តិបទេ ញាណំ អប្បវត្តំ សុខន្តិ សន្តិបទេ ញាណំ ។ បេ ។ អនុទាយាសោ សុខន្តិ សន្តិបទេ ញាណំ ។

[១១៦] ឧប្បាទោ ទុក្ខំ អនុប្បាទោ សុខន្តិ សន្តិបទេ ញាណំ បវត្តំ ទុក្ខំ អប្បវត្តំ សុខន្តិ សន្តិបទេ ញាណំ ។ បេ ។ ឧទាយាសោ ទុក្ខំ អនុទាយាសោ សុខន្តិ សន្តិបទេ ញាណំ ។

[១១៧] ឧប្បាទោ សាមិសន្តិ ភយតុបដ្ឋានេ បញ្ញា អាទីនវេ ញាណំ បវត្តំ សាមិសន្តិ ភយតុប-ដ្ឋានេ បញ្ញា អាទីនវេ ញាណំ ។ បេ ។ ឧទាយា-សោ សាមិសន្តិ ភយតុបដ្ឋានេ បញ្ញា អាទីនវេ ញាណំ អនុប្បាទោ និរាមិសន្តិ សន្តិបទេ ញាណំ អប្បវត្តំ និរាមិសន្តិ សន្តិបទេ ញាណំ ។ បេ ។ អនុ-ទាយាសោ និរាមិសន្តិ សន្តិបទេ ញាណំ ឧប្បាទោ

បញ្ញាក្នុងការប្រាកដឡើងថាជាភ័យថា ការចង្អៀតចង្អល់ចិត្ត ជាទុក្ខ ឈ្មោះថាអាទីនវញ្ញាណ ញាណក្នុងសន្តិបទថា ការមិនកើតជាសុខ ញាណក្នុងសន្តិបទថា ការមិនប្រព្រឹត្តជាសុខ ។ បេ ។ ញាណក្នុងសន្តិបទថា ការមិនចង្អៀតចង្អល់ចិត្តជាសុខ ។

[១១៦] ញាណក្នុងសន្តិបទថា ការកើត ជាទុក្ខ ការមិនកើតជាសុខ ញាណក្នុងសន្តិបទថា ការប្រព្រឹត្ត ជាទុក្ខ ការមិនប្រព្រឹត្តជាសុខ ។ បេ ។ ញាណក្នុងសន្តិបទថា ការចង្អៀតចង្អល់ចិត្ត ជាទុក្ខ ការមិនចង្អៀតចង្អល់ចិត្ត ជាសុខ ។

[១១៧] បញ្ញាក្នុងការប្រាកដឡើងថាជាភ័យថា ការកើត ប្រកបដោយអាមិសៈ ឈ្មោះថាអាទីនវញ្ញាណ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យថា ការប្រព្រឹត្ត ប្រកបដោយអាមិសៈ ឈ្មោះថាអាទីនវញ្ញាណ ។ បេ ។ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យថា ការចង្អៀតចង្អល់ចិត្ត ប្រកបដោយអាមិសៈ ឈ្មោះថាអាទីនវញ្ញាណ ញាណក្នុងសន្តិបទថា ការមិនកើត មិនប្រកបដោយអាមិសៈ ញាណក្នុងសន្តិបទថា ការមិនប្រព្រឹត្ត មិនប្រកបដោយអាមិសៈ ។ បេ ។ ញាណក្នុងសន្តិបទថា ការមិនចង្អៀតចង្អល់ចិត្ត មិនប្រកបដោយអាមិសៈ ញាណក្នុងសន្តិបទថា ការកើត

សាមិសំ អនុប្បាទោ និរាមិសន្តិ សន្តិបទេ ញាណំ បវត្តំ សាមិសំ អប្បវត្តំ និរាមិសន្តិ សន្តិបទេ ញាណំ ។ បេ ។ ឧបាយាសោ សាមិសំ អនុបាយាសោ និរាមិសន្តិ សន្តិបទេ ញាណំ ។

[១១៨] ឧប្បាទោ សង្ខារាតិ ភយតុបដ្ឋានេ បញ្ញា អាទីនវេ ញាណំ ។ បេ ។ ឧបាយាសោ សង្ខារាតិ ភយតុបដ្ឋានេ បញ្ញា អាទីនវេ ញាណំ អនុប្បាទោ និព្វានន្តិ សន្តិបទេ ញាណំ អប្បវត្តំ និព្វានន្តិ សន្តិបទេ ញាណំ ។ បេ ។ អនុបាយាសោ និព្វានន្តិ សន្តិបទេ ញាណំ ឧប្បាទោ សង្ខារា អនុប្បាទោ និព្វានន្តិ សន្តិបទេ ញាណំ បវត្តំ សង្ខារា អប្បវត្តំ និព្វានន្តិ សន្តិបទេ ញាណំ ។ បេ ។ ឧបាយាសោ សង្ខារា អនុបាយាសោ និព្វានន្តិ សន្តិបទេ ញាណំ ។

[១១៩] ឧប្បាទញ្ច បវត្តញ្ច និមិត្តំ ទុក្ខន្តិ បស្សតិ
អាយុហានំ បដិសន្ធឹ ញាណំ អាទីនវេ ឥទំ

ប្រកបដោយអាមិសៈ ការមិនកើត មិនប្រកបដោយអាមិសៈ ញាណក្នុងសន្តិបទថា ការប្រព្រឹត្ត ប្រកបដោយអាមិសៈ ការមិនប្រព្រឹត្ត មិនប្រកបដោយអាមិសៈ ។ បេ ។ ញាណក្នុងសន្តិបទថា ការចង្អៀតចង្អល់ចិត្ត ប្រកបដោយអាមិសៈ ការមិនចង្អៀតចង្អល់ចិត្ត មិនប្រកបដោយអាមិសៈ ។

[១១៨] បញ្ញាក្នុងការប្រាកដឡើងថាជាភ័យថា ការកើត ជាសង្ខារ ឈ្មោះថាអាទីនវញ្ញាណ ។ បេ ។ បញ្ញាក្នុងការប្រាកដឡើងថាជាភ័យថា ការចង្អៀតចង្អល់ចិត្ត ជាសង្ខារ ឈ្មោះថាអាទីនវញ្ញាណ ញាណក្នុងសន្តិបទថា ការមិនកើត ជានិព្វាន ញាណក្នុងសន្តិបទថា ការមិនប្រព្រឹត្ត ជានិព្វាន ។ បេ ។ ញាណក្នុងសន្តិបទថា ការមិនចង្អៀតចង្អល់ចិត្ត ជានិព្វាន ញាណក្នុងសន្តិបទថា ការកើត ជាសង្ខារ ការមិនកើត ជានិព្វាន ញាណក្នុងសន្តិបទថា ការប្រព្រឹត្ត ជាសង្ខារ ការមិនប្រព្រឹត្ត ជានិព្វាន ។ បេ ។ ញាណក្នុងសន្តិបទថា ការចង្អៀតចង្អល់ចិត្ត ជាសង្ខារ កាមិនចង្អៀតចង្អល់ចិត្ត ជានិព្វាន ។

[១១៩] បុគ្គលឃើញ នូវការកើត នូវការប្រព្រឹត្ត នូវនិមិត្ត នូវការ
ប្រមូលមក និងបដិសន្ធិ ថាជាទុក្ខ នេះឈ្មោះថាអាទីនវញ្ញាណ

អនុប្បាទំ អប្បវត្តំ អនិមិត្តំ សុខន្តិ ច
អនាយុហនំ អប្បដិសន្ធឹ ញាណំ សន្តិបទេ ឥទំ
ឥទំ អាទីនវេ ញាណំ បញ្ចដ្ឋានេសុ ជាយតិ
បញ្ចដ្ឋានេ សន្តិបទេ ទស ញាណេ បជានាតិ
ទ្វិន្នំ ញាណានំ កុសលតា នានាទិដ្ឋីសុ ន កម្បតីតិ ។

តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ភយតុបដ្ឋានេ បញ្ញា អាទីនវេ ញាណំ ។

[១២០] កថំ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ។ ឧប្បាទមុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ បវត្តមុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ និមិត្តមុញ្ចិតុកម្យតា ។ បេ ។ អាយុហនមុញ្ចិតុកម្យតា បដិសន្ធិមុញ្ចិតុកម្យតា គតិមុញ្ចិតុកម្យតា និព្វត្តិមុញ្ចិតុកម្យតា ឧបបត្តិមុញ្ចិតុកម្យតា ជាតិមុញ្ចិតុកម្យតា

បុគ្គលឃើញ នូវការមិនកើត នូវការមិនប្រព្រឹត្ត នូវការមិនមាននិមិត្ត នូវការមិនប្រមូលមកនិងការមិនបដិសន្ធិ ថាជាសុខ នេះឈ្មោះថាញាណក្នុងសន្តិបទ អាទីនវញ្ញាណនេះ តែងកើតក្នុងឋាន ៥ ញាណក្នុងសន្តិបទនេះតែងកើតក្នុងឋាន ៥ បុគ្គលរមែងដឹងច្បាស់នូវញាណទាំង ១០ (នេះឯង)ភាពនៃបុគ្គលអ្នកឈ្លាសវៃក្នុងញាណទាំង ២ ទើបមិនញាប់ញ័រក្នុងទិដ្ឋិផ្សេង ៗ ។ ដែលឈ្មោះថាញាណដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការប្រាកដឡើងថាជាភ័យ ឈ្មោះថាអាទីនវញ្ញាណ ។

[១២០] បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយ ឈ្មោះថាសង្ខារុបេក្ខាញាណ តើដូចម្តេច ។ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយក្នុងការកើត ឈ្មោះថាសង្ខារុបេក្ខាញាណ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួចឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយក្នុងការប្រព្រឹត្ត ឈ្មោះថាសង្ខារុបេក្ខាញាណ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច...ក្នុងនិមិត្ត ។ បេ ។ សេចក្តីប្រាថ្នាដើម្បីរួច... ក្នុងការប្រមូលមក សេចក្តីប្រាថ្នាដើម្បីរួច... ក្នុងបដិសន្ធិ សេចក្តីប្រាថ្នាដើម្បីរួច... ក្នុងគតិ សេចក្តីប្រាថ្នាដើម្បីរួច... ក្នុងការវិលមក សេចក្តីប្រាថ្នាដើម្បីរួច...ក្នុងការកើត សេចក្តីប្រាថ្នាដើម្បីរួច...ក្នុងជាតិ

ជរាមុញ្ចិតុកម្យតា ព្យាធិមុញ្ចិតុកម្យតា មរណមុញ្ចិតុកម្យតា សោកមុញ្ចិតុកម្យតា បរិទេវមុញ្ចិតុកម្យតា ឧបាយាសមុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា[១] បញ្ញា សង្ខារុបេក្ខាសុ ញាណំ ។

[១២១] ឧប្បាទោ ទុក្ខន្តិ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ បវត្តំ ទុក្ខន្តិ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ និមិត្តំ ទុក្ខន្តិ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ។ បេ ។ ឧបាយាសោ ទុក្ខន្តិ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ឧប្បាទោ ភយន្តិ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ បវត្តំ ភយន្តិ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ។ បេ ។

---

១ ឱ. អាយុហានំ បដិសន្ធឹ គតឹ និព្វត្តឹ ឧបបត្តឹ ជាតឹ ជរំ ព្យាធឹ មរណំ សោកំ បរិទេវំ ឧបាយាសំ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនាតិ ទិស្សតិ ។

សេចក្តីប្រាថ្នាដើម្បីរួច...ក្នុងជរា សេចក្តីប្រាថ្នាដើម្បីរួច...ក្នុងព្យាធិ សេចក្តីប្រាថ្នាដើម្បីរួច...ក្នុងមរណៈ សេចក្តីប្រាថ្នាដើម្បីរួច...ក្នុងសេចក្តីសោក សេចក្តីប្រាថ្នាដើម្បីរួច...ក្នុងការខ្សឹកខ្សួល បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយ ក្នុងសេចក្តីចង្អៀតចង្អល់ចិត្ត ឈ្មោះថាសង្ខារុបេក្ខាញាណ ។

[១២១] បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការកើតជាទុក្ខ ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការប្រព្រឹត្តជាទុក្ខ ឈ្មោះសង្ខារុបេក្ខាញាណ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា និមិត្ត ជាទុក្ខ ឈ្មោះថាសង្ខារុបេក្ខាញាណ ។ បេ ។ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា សេចក្តីចង្អៀតចង្អល់ចិត្ត ជាទុក្ខ ឈ្មោះថាសង្ខារុបេក្ខាញាណ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការកើត ជាភ័យ ឈ្មោះថាសង្ខារុបេក្ខាញាណ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការប្រព្រឹត្ត ជាភ័យ ឈ្មោះថាសង្ខារុបេក្ខាញាណ ។ បេ ។

ឧទាយាសោ ភយន្តិ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ។

[១២២] ឧប្បាទោ សាមិសន្តិ មុញ្ចិតុកម្យតាបដិ-សង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ បវត្តំ សាមិសន្តិ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ។ បេ ។ ឧទាយាសោ សាមិសន្តិ មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ឧប្បាទោ សង្ខារាតិ មុញ្ចិ-តុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ បវត្តំ សង្ខារាតិ មុញ្ចិតុកម្យតាបដិសង្ខា-សន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ។ បេ ។ ឧទាយាសោ សង្ខារាតិ មុញ្ចិតុកម្យតាបដិសង្ខា-សន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ។

[១២៣] ឧប្បាទោ សង្ខារា តេ សង្ខារេ អជ្ឈុបេក្ខតីតិ សង្ខារុបេក្ខា យេ ច សង្ខារា យា ច ឧបេក្ខា ឧភោបេតេ សង្ខារា តេ

បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា សេចក្តីចង្អៀតចង្អល់ចិត្តជាភ័យ ឈ្មោះថាសង្ខារុបេក្ខាញាណ ។

[១២២] បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការកើត ប្រកបដោយអាមិសៈ ឈ្មោះថាសង្ខារុបេក្ខាញាណ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការប្រព្រឹត្ត ប្រកបដោយអាមិសៈ ឈ្មោះថាសង្ខារុបេក្ខាញាណ ។ បេ ។ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា សេចក្តីចង្អៀតចង្អល់ចិត្តប្រកបដោយអាមិសៈ ឈ្មោះថាសង្ខារុបេក្ខាញាណ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការកើតជាសង្ខារ ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា ការប្រព្រឹត្ត ជាសង្ខារ ឈ្មោះថាសង្ខារុបេក្ខាញាណ ។ បេ ។ បញ្ញាគឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយថា សេចក្តីចង្អៀតចង្អល់ចិត្ត ជាសង្ខារ ឈ្មោះថាសង្ខារុបេក្ខាញាណ ។

[១២៣] ការកើតឡើង ចាត់ជាសង្ខារ បុគ្គលរំពឹងមើលនូវសង្ខារទាំងឡាយនោះ ឈ្មោះថាសង្ខារុបេក្ខា សង្ខារ និង ឧបេក្ខា ទាំង ២ នុ៎ះ

សង្ខារេ អជ្ឈុបេក្ខតីតិ សង្ខារុបេក្ខា បវត្តំ សង្ខារា ។ បេ ។ និមិត្តំ សង្ខារា អាយុហនា សង្ខារា បដិសន្ធិ សង្ខារា គតិ សង្ខារា និព្វត្តិ សង្ខារា ឧបបត្តិ សង្ខារា ជាតិ សង្ខារា ជរា សង្ខារា ព្យាធិ សង្ខារា មរណំ សង្ខារា សោកោ សង្ខារា បរិទេវោ សង្ខារា ឧបាយាសោ សង្ខារា តេ សង្ខារេ អជ្ឈុបេក្ខតីតិ សង្ខារុបេក្ខា យេ ច សង្ខារា យា ច ឧបេក្ខា ឧភោបេតេ សង្ខារា តេ សង្ខារេ អជ្ឈុបេក្ខតីតិ សង្ខារុបេក្ខា ។

[១២៤] កតិហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ ។ អដ្ឋហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ ។ បុថុជ្ជនស្ស កតិហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ សេក្ខស្ស កតិហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ វីតរាគស្ស កតិហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ ។

ចាត់ជាសង្ខារ បុគ្គលរំពឹងមើល នូវសង្ខារទាំងឡាយនោះ ឈ្មោះថាសង្ខារុបេក្ខា ការប្រព្រឹត្ត ចាត់ជាសង្ខារ ។ បេ ។ និមិត្ត ចាត់ជាសង្ខារ ការប្រមូលមក ចាត់ជាសង្ខារ បដិសន្ធិ ចាត់ជាសង្ខារ គតិ ចាត់ជាសង្ខារ ការវិលមក ចាត់ជាសង្ខារ ការកើត ចាត់ជាសង្ខារ ជាតិ ចាត់ជាសង្ខារ ជរា ចាត់ជាសង្ខារ ព្យាធិ ចាត់ជាសង្ខារ មរណៈ ចាត់ជាសង្ខារ សេចក្តីសោក ចាត់ជាសង្ខារ សេចក្តីខ្សឹកខ្សួល ចាត់ជាសង្ខារ សេចក្តីចង្អៀតចង្អល់ចិត្ត ចាត់ជាសង្ខារ បុគ្គលរំពឹងមើលនូវសង្ខារទាំងឡាយនោះ ឈ្មោះថាសង្ខារុបេក្ខា សង្ខារ និង ឧបេក្ខាទាំង ២ នុ៎ះ ចាត់ជាសង្ខារ បុគ្គលរំពឹងមើលនូវសង្ខារទាំងឡាយនោះ ឈ្មោះថាសង្ខារុបេក្ខា ។

[១២៤] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា ដោយអាការប៉ុន្មានយ៉ាង ។ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា ដោយអាការ ៨ យ៉ាង ។ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន[១] ដោយអាការប៉ុន្មានយ៉ាង ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់សេក្ខបុគ្គល ដោយអាការប៉ុន្មានយ៉ាង ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់អសេក្ខបុគ្គល ដោយអាការប៉ុន្មានយ៉ាង ។

---

១ បុថុជ្ជនមាន ២ ពួកគឺ អន្ធបុថុជ្ជន ពួក ១ កល្យាណបុថុជ្ជន ពួក ១ ក្នុងទីនេះ សំដៅយកកល្យាណបុថុជ្ជន ។ អដ្ឋកថា ។

បុថុជ្ជនស្ស ទ្វីហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ សេក្ខស្ស តីហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ វីតរាគស្ស តីហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ ។

[១២៨] បុថុជ្ជនស្ស កតមេហិ ទ្វីហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ ។ បុថុជ្ជនោ សង្ខារុបេក្ខំ អភិនន្ទតិ វា វិបស្សតិ វា បុថុជ្ជនស្ស ឥមេហិ ទ្វីហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ ។

សេក្ខស្ស កតមេហិ តីហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ ។ សេក្ខោ សង្ខារុបេក្ខំ អភិនន្ទតិ វា វិបស្សតិ វា បដិសង្ខាយ វា ផលសមាបត្តឹ សមាបជ្ជតិ សេក្ខស្ស ឥមេហិ តីហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ ។

វីតរាគស្ស កតមេហិ តីហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ ។ វីតរាគោ សង្ខារុបេក្ខំ វិបស្សតិ វា បដិសង្ខាយ វា ផលសមាបត្តឹ សមាបជ្ជតិ តទជ្ឈុបេក្ខិត្វា សុញ្ញតវិហារេន វា

ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន ដោយអាការ ២ យ៉ាង ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់សេក្ខបុគ្គល ដោយអាការ ៣ យ៉ាង ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់អសេក្ខបុគ្គល ដោយអាការ ៣ យ៉ាង ។

[១២៥] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន ដោយអាការ ២ យ៉ាង ដូចម្ដេចខ្លះ ។ បុថុជ្ជនត្រេកអរចំពោះសង្ខារុបេក្ខា ឬពិចារណាឃើញនូវសង្ខារុបេក្ខា នេះ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន ដោយអាការ ២ យ៉ាង ។

ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់សេក្ខបុគ្គល ដោយអាការ ៣ យ៉ាង ដូចម្ដេចខ្លះ ។ សេក្ខបុគ្គល ត្រេកអរចំពោះសង្ខារុបេក្ខា ឬពិចារណាឃើញនូវសង្ខារុបេក្ខា ឬក៏ចូលកាន់ផលសមាបត្តិ ដោយការពិចារណា នេះ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់សេក្ខបុគ្គល ដោយអាការ ៣ យ៉ាង ។

ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់អសេក្ខបុគ្គល ដោយអាការ ៣ យ៉ាង ដូចម្ដេចខ្លះ ។ អសេក្ខបុគ្គល ពិចារណាឃើញនូវសង្ខារុបេក្ខា ឬចូលកាន់ផលសមាបត្តិ ដោយការពិចារណា ឬក៏រំពឹងមើល នូវសង្ខារុបេក្ខានោះ ហើយនៅដោយសុញ្ញតវិហារធម៌ក្តី

អនិមិត្តវិហារេន វា អប្បណិហិតវិហារេន វា វិហរតិ វីតរាគស្ស ឥមេហិ តីហាការេហិ សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ហោតិ ។

[១២៦] កថំ បុថុជ្ជនស្ស ច សេក្ខស្ស ច សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ឯកត្តំ ហោតិ ។ បុថុជ្ជនស្ស សង្ខារុបេក្ខំ អភិនន្ទតោ ចិត្តំ កិលិស្សតិ ភាវនាយ បរិបន្ថោ ហោតិ បដិវេធស្ស អន្តរាយោ ហោតិ អាយតិប្បដិសន្ធិយា បច្ចយោ ហោតិ សេក្ខ-ស្សបិ សង្ខារុបេក្ខំ អភិនន្ទតោ ចិត្តំ កិលិស្សតិ ភាវនាយ បរិបន្ថោ ហោតិ ឧត្តរិប្បដិវេធស្ស អន្តរាយោ ហោតិ អាយតិប្បដិសន្ធិយា បច្ចយោ ហោតិ ឯវំ បុថុជ្ជនស្ស ច សេក្ខស្ស ច សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ឯកត្តំ ហោតិ អភិនន្ទនដ្ឋេន ។

[១២៧] កថំ បុថុជ្ជនស្ស ច សេក្ខស្ស ច វីតរាគស្ស ច សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ឯកត្តំ ហោតិ ។ បុថុជ្ជនោ សង្ខារុបេក្ខំ អនិច្ច-តោបិ ទុក្ខតោបិ អនត្តតោបិ វិបស្សតិ សេក្ខោបិ សង្ខារុបេក្ខំ អនិច្ចតោបិ ទុក្ខតោបិ អនត្តតោបិ

ដោយអនិមិត្តវិហារធម៌ក្តី ដោយអប្បណិហិតវិហារធម៌ក្តី នេះ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់អសេក្ខបុគ្គល ដោយអាការ ៣ យ៉ាង ។

[១២៦] ការបង្អោនចិត្តទៅ ក្នុងសង្ខារុបេក្ខា របស់បុថុជ្ជនក្តី របស់សេក្ខបុគ្គលក្តី មានភាពតែមួយ តើដូចម្តេច ។ កាលបុថុជ្ជនត្រេកអរចំពោះសង្ខារុបេក្ខា ចិត្តនឹងសៅហ្មង វិបស្សនាភាវនា ក៏មានគ្រោះថ្នាក់ ការត្រាស់ដឹង (នូវសច្ចធម៌) ក៏មានសេចក្តីអន្តរាយ បដិសន្ធិតទៅទៀត ក៏មានបច្ច័យ កាលសេក្ខបុគ្គល ត្រេកអរចំពោះសង្ខារុបេក្ខា ចិត្តនឹងសៅហ្មង វិបស្សនាភាវនា ក៏មានគ្រោះថ្នាក់ ការត្រាស់ដឹងនូវគុណជាតិដ៏ខ្ពង់ខ្ពស់ ក៏មិនមានអន្តរាយ បដិសន្ធិតទៅទៀត ក៏មានបច្ច័យ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជនក្តី របស់សេក្ខបុគ្គលក្តី មានភាពតែមួយ ដោយអត្ថថាត្រេកអរចំពោះ យ៉ាងនេះឯង ។

[១២៧] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពតែមួយ តើដូចម្តេច ។ បុថុជ្ជន ពិចារណាឃើញនូវសង្ខារុបេក្ខា ថាមិនទៀងក្តី ថាជាទុក្ខក្តី ថាមិនមែនខ្លួនក្តី សេក្ខបុគ្គល ពិចារណាឃើញ នូវសង្ខារុបេក្ខា ថាមិនទៀងក្តី ថាជាទុក្ខក្តី ថាមិនមែនខ្លួនក្តី

វិបស្សតិ វីតរាគោបិ សង្ខារុបេក្ខំ អនិច្ចតោបិ ទុក្ខតោបិ អនត្តតោបិ វិបស្សតិ ឯវំ បុថុជ្ជនស្ស ច សេក្ខស្ស ច វីតរាគស្ស ច សង្ខារុបេក្ខាយ ចិត្ត-ស្ស អភិនីហារោ ឯកត្តំ ហោតិ អនុបស្សនដ្ឋេន ។

[១២៨] កថំ បុថុជ្ជនស្ស ច សេក្ខស្ស ច វីតរាគស្ស ច សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ នានត្តំ ហោតិ ។ បុថុជ្ជនស្ស សង្ខារុបេក្ខា កុសលា ហោតិ សេក្ខស្សបិ សង្ខារុបេក្ខា កុសលា ហោតិ វីតរាគស្ស សង្ខារុបេក្ខា អព្យាកតា ហោតិ ឯវំ បុថុជ្ជនស្ស ច សេក្ខស្ស ច វីតរាគស្ស ច សង្ខារុ-បេក្ខាយ ចិត្តស្ស អភិនីហារោ នានត្តំ ហោតិ កុសលាព្យាកតដ្ឋេន ។

[១២៩] កថំ បុថុជ្ជនស្ស ច សេក្ខស្ស ច វីត-រាគស្ស ច សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ នា-នត្តំ ហោតិ ។ បុថុជ្ជនស្ស សង្ខារុបេក្ខា កិញ្ចិកា-លេ សុវិទិតា ហោតិ កិញ្ចិកាលេ ន សុវិទិតា ហោតិ សេក្ខស្សបិ សង្ខារុបេក្ខា កិញ្ចិកាលេ

អសេក្ខបុគ្គលពិចារណាឃើញ នូវសង្ខារុបេក្ខា ថាមិនទៀងក្តី ថាជាទុក្ខក្តី ថាមិនមែនខ្លួនក្តី ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពតែមួយ ដោយអត្ថថាពិចារណាឃើញ យ៉ាងនេះឯង ។

[១២៨] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា តើដូចម្តេច ។ បុថុជ្ជនមានសង្ខារុបេក្ខាជាកុសល សេក្ខបុគ្គល ក៏មានសង្ខារុបេក្ខាជាកុសលដែរ ឯអសេក្ខបុគ្គល មានសង្ខារុបេក្ខាជាអព្យាក្រឹត ការបង្អោនចិត្តទៅ ក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា ដោយអត្ថថាជាកុសលនិងអព្យាក្រឹត យ៉ាងនេះឯង ។

[១២៩] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន របស់សេក្ខ-បុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា តើដូចម្តេច ។ បុថុជ្ជនមានសង្ខារុបេក្ខា ដែលខ្លួនដឹងច្បាស់ក្នុងកាលខ្លះ មិនដឹងច្បាស់ក្នុងកាលខ្លះ ឯសេក្ខបុគ្គល មានសង្ខារុបេក្ខា ដែលខ្លួនដឹងច្បាស់ ក្នុងកាលខ្លះ

សុវិជិតា ហោតិ[១] វីតរាគស្ស សង្ខារុបេក្ខា អច្ចន្តំ សុវិជិតា ហោតិ ឯវំ បុថុជ្ជនស្ស ច សេក្ខស្ស ច វីតរាគស្ស ច សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ណានត្តំ ហោតិ វិជិតដ្ឋេន ច អវិជិតដ្ឋេន ច ។

[១៣០] កថំ បុថុជ្ជនស្ស ច សេក្ខស្ស ច វីតរាគស្ស ច សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ណានត្តំ ហោតិ ។ បុថុជ្ជនោ សង្ខារុបេក្ខា[២] អតិត្ត-ត្តា វិបស្សតិ សេក្ខោបិ សង្ខារុបេក្ខា អតិត្តត្តា វិបស្សតិ វីតរាគោ សង្ខារុបេក្ខា តិត្តត្តា វិបស្សតិ ឯវំ បុថុជ្ជនស្ស ច សេក្ខស្ស ច វីតរាគស្ស ច សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ណានត្តំ ហោតិ តិត្តដ្ឋេន ច អតិត្តដ្ឋេន ច ។

[១៣១] កថំ បុថុជ្ជនស្ស ច សេក្ខស្ស ច វីតរាគស្ស ច សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ ណានត្តំ ហោតិ ។ បុថុជ្ជនោ សង្ខារុបេក្ខំ តិណ្ណំ

១ ឱ. ឯត្តន្តរេ កិញ្ចិកាលេ ន សុវិទិតា ហោតីតិ ទិស្សតិ ។ ២ ឱ. ម. សង្ខា-រុបេក្ខំ ។

អសេក្ខបុគ្គលមានសង្ខារុបេក្ខា ដែលខ្លួនដឹងច្បាស់ ដោយចំណែកមួយ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន របស់សេក្ខ-បុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា ដោយអត្ថថាដឹងច្បាស់ផង ដោយអត្ថថាមិនដឹងច្បាស់ផង យ៉ាងនេះឯង ។

[១៣០] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា តើដូចម្តេច ។ បុថុជ្ជនឃើញច្បាស់ នូវសង្ខារុបេក្ខាព្រោះមិនទាន់ឆ្អែត សេក្ខបុគ្គលក៏ឃើញច្បាស់ នូវសង្ខារុបេក្ខាព្រោះមិនទាន់ឆ្អែតដែរ ឯអសេក្ខបុគ្គលឃើញច្បាស់ នូវសង្ខារុបេក្ខាព្រោះឆ្អែត ការបង្អោនចិត្តទៅក្នុងសង្ខា-រុបេក្ខា របស់បុថុជ្ជន របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា ដោយអត្ថថាឆ្អែតផង មិនឆ្អែតផង យ៉ាងនេះឯង ។

[១៣១] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា តើដូចម្តេច ។ បុថុជ្ជន ឃើញច្បាស់នូវសង្ខារុបេក្ខា ដើម្បីលះបង់នូវសញ្ញោជនៈ ៣

សញ្ញោជនានំ បហានាយ សោតាបត្តិមគ្គំ បដិលាភត្ថាយ វិបស្សតិ សេក្ខោ សង្ខារុបេក្ខំ តិណ្ណំ សញ្ញោជនានំ បហីនត្តា ឧត្តរិប្បដិលាភត្ថាយ វិបស្សតិ វីតរាគោ សង្ខារុបេក្ខំ សព្វក្កិលេសានំ បហីនត្តា ទិដ្ឋធម្មសុខវិហារត្ថាយ វិបស្សតិ ឯវំ បុថុជ្ជនស្ស ច សេក្ខស្ស ច វីតរាគស្ស ច សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ នានត្តំ ហោតិ បហីនដ្ឋេន ច អប្បហីនដ្ឋេន ច ។

[១៣២] កថំ សេក្ខស្ស[១] ច វីតរាគស្ស ច សង្ខារុបេក្ខាយ ចិត្តស្ស អភិនីហារោ នានត្តំ ហោតិ[៣] ។ សេក្ខោ សង្ខារុបេក្ខំ អភិនន្ទតិ វា វិបស្សតិ វា បដិសង្ខាយ វា ផលសមាបត្តឹ សមាបជ្ជតិ វីតរាគោ សង្ខារុបេក្ខំ វិបស្សតិ វា បដិសង្ខាយ វា ផលសមាបត្តឹ សមាបជ្ជតិ តទជ្ឈុបេក្ខិត្វា សុញ្ញតវិហារេន វា អនិមិត្តវិហារេន វា

១ ឱ. ម. កថំ បុថុជ្ជនស្ស ច សេក្ខស្ស ច ។ ២ ឱ. ម. ឯត្ថន្តរេ បុថុជ្ជនោបិ សង្ខារុបេក្ខំ អភិនន្ទតិ វា វិបស្សតិ វា បដិសង្ខាយ វាតិ ទិស្សតិ ។

ដើម្បីប្រយោជន៍ដល់ការបាននូវសោតាបត្តិមគ្គ សេក្ខបុគ្គល ឃើញច្បាស់នូវសង្ខារុបេក្ខា ដើម្បីប្រយោជន៍ដល់ការបាននូវគុណវិសេសតទៅទៀត ព្រោះបានលះបង់នូវសញ្ញោជនៈ ៣ ឯអសេក្ខបុគ្គលឃើញច្បាស់នូវសង្ខារុបេក្ខា ដើម្បីប្រយោជន៍ដល់សុខវិហារធម៌ក្នុងបច្ចុប្បន្ន ព្រោះបានលះបង់នូវកិលេសទាំងអស់ហើយ ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់បុថុជ្ជន របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា ដោយអត្ថថាលះបង់ផង មិនទាន់លះបង់ផង យ៉ាងនេះឯង ។

[១៣២] ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា តើដូចម្តេច ។ សេក្ខបុគ្គលតែងត្រេកអរចំពោះសង្ខារុបេក្ខា ឬពិចារណានូវសង្ខារុបេក្ខា ឬក៏ចូលផលសមាបត្តិដោយការពិចារណា ឯអសេក្ខបុគ្គល តែងពិចារណាឃើញនូវសង្ខារុបេក្ខា ឬចូលកាន់ផលសមាបត្តិ ដោយការពិចារណា ឬក៏រំពឹងមើលនូវសង្ខារុបេក្ខានោះ ហើយនៅដោយសុញ្ញតវិហារធម៌ក្តី ដោយអនិមិត្តវិហារធម៌ក្តី

អប្បណិហិតវិហារេន វា វិហរតិ ឯវំ[១] សេក្ខស្ស ច វីតរាគស្ស ច សង្ខារុបេក្ខាយ ចិត្តស្ស អភិនី-ហារេ ញាណត្តំ ហោតិ វិហារសមាបត្តដ្ឋេន ។

[១៣៣] កតិ សង្ខារុបេក្ខា សមថវសេន ឧប្ប-ជ្ជន្តិ កតិ សង្ខារុបេក្ខា វិបស្សនាវសេន ឧប្បជ្ជន្តិ ។ អដ្ឋ សង្ខារុបេក្ខា សមថវសេន ឧប្បជ្ជន្តិ ទស សង្ខារុបេក្ខា វិបស្សនាវសេន ឧប្បជ្ជន្តិ ។

កតមា អដ្ឋ សង្ខារុបេក្ខា សមថវសេន ឧប្ប-ជ្ជន្តិ ។ បឋមជ្ឈានំ បដិលាភត្ថាយ នីវរណេ បដិសង្ខា សន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ទុតិយជ្ឈានំ បដិលាភត្ថាយ វិតក្កវិចារេ បដិសង្ខា សន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ តតិយជ្ឈានំ បដិលាភត្ថាយ បីតឹ[២] បដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ចតុត្ថជ្ឈានំ បដិលាភត្ថាយ សុខទុក្ខេ បដិ-សង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ អា-កាសានញ្ចាយតនសមាបត្តឹ បដិលាភត្ថាយ រូបសញ្ញំ បដិឃសញ្ញំ នានត្តសញ្ញំ បដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ វិញ្ញាណញ្ចាយតនសមាបត្តឹ

១ ឱ. ម. បុថុជ្ជនស្ស ចាតិ ទិស្សតិ ។ ២ ម. បីតិយា ។

ដោយអប្បណិហិតវិហារធម៌ក្តី ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា របស់សេក្ខបុគ្គល និងរបស់អសេក្ខបុគ្គល មានភាពផ្សេងគ្នា ដោយអត្ថថាជាវិហារសមាបត្តិ យ៉ាងនេះឯង ។

[១៣៣] សង្ខារុបេក្ខាប៉ុន្មាន កើតដោយអំណាចសមថៈ សង្ខារុបេក្ខាប៉ុន្មាន កើតដោយអំណាចវិបស្សនា ។ សង្ខារុបេក្ខា ៨ កើតដោយអំណាចសមថៈ សង្ខារុបេក្ខា ១០ កើតដោយអំណាចវិបស្សនា ។

សង្ខារុបេក្ខា ៨ កើតដោយអំណាចសមថៈ តើដូចម្តេច ។ បញ្ញាគឺការពិចារណា និងការព្រងើយកន្តើយ ចំពោះនីវរណៈទាំងឡាយ ដើម្បីប្រយោជន៍ដល់ការបាននូវបឋមជ្ឈាន ឈ្មោះថាសង្ខារុបេក្ខាញាណ បញ្ញាគឺការពិចារណានិងការព្រងើយកន្តើយ ចំពោះវិតក្កៈនិងវិចារៈ ដើម្បីប្រយោជន៍ដល់ការបាននូវទុតិយជ្ឈាន ឈ្មោះថាសង្ខារុបេក្ខាញាណ បញ្ញាគឺការពិចារណា និងការព្រងើយកន្តើយ ចំពោះបីតិ ដើម្បីប្រយោជន៍ដល់ការបាននូវតតិយជ្ឈាន ឈ្មោះថាសង្ខារុបេក្ខាញាណ បញ្ញាគឺការពិចារណា និងការព្រងើយកន្តើយ ចំពោះសុខនិងទុក្ខ ដើម្បីប្រយោន៍ដល់ការបាននូវចតុត្ថជ្ឈាន ឈ្មោះថាសង្ខារុបេក្ខាញាណ បញ្ញាគឺការពិចារណា និងការព្រងើយកន្តើយ ចំពោះរូបសញ្ញា បដិឃសញ្ញា និងនានត្តសញ្ញាដើម្បីប្រយោជន៍ដល់ការបាននូវអាកាសានញ្ចាយតនសមាបត្តិ ឈ្មោះថា សង្ខារុបេក្ខាញាណ បញ្ញាគឺការពិចារណា និងការព្រងើយកន្តើយ ចំពោះអាកាសានញ្ចាយតនសញ្ញា ដើម្បីប្រយោជន៍ដល់ការបាននូវវិញ្ញាណញ្ចាយតន-

បដិលាភត្ថាយ អាកាសានញ្ចាយតនសញ្ញំ បដិសង្ខា សន្តិដ្ឋតា បញ្ញា សង្ខារុបេក្ខាសុ ញាណំ អាកិញ្ចញ្ញាយតនសមាបត្តី បដិលាភត្ថាយ វិញ្ញាណញ្ចាយតនសញ្ញំ បដិសង្ខា សន្តិដ្ឋតា បញ្ញា សង្ខារុបេក្ខាសុ ញាណំ នេវសញ្ញានាសញ្ញាយតនសមាបត្តី បដិលាភត្ថាយ អាកិញ្ចញ្ញាយតនសញ្ញំ បដិសង្ខា សន្តិដ្ឋតា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ឥមា អដ្ឋ សង្ខារុបេក្ខា សមថវសេន ឧប្បជ្ជន្តិ ។

[១៣៤] កតមា ទស សង្ខារុបេក្ខា វិបស្សនាវសេន ឧប្បជ្ជន្តិ ។ សោតាបត្តិមគ្គំ បដិលាភត្ថាយ ឧប្បាទំ បវត្តំ និមិត្តំ អាយុហនំ បដិសន្ធឹ គតឹ និព្វត្តឹ ឧបបត្តឹ ជាតឹ ជរំ ព្យាធឹ មរណំ សោកំ បរិទេវំ ឧបាយាសំ បដិសង្ខា សន្តិដ្ឋតា បញ្ញា សង្ខារុបេក្ខាសុ ញាណំ សោតាបត្តិផលសមាបត្តត្ថាយ ឧប្បាទំ បវត្តំ និមិត្តំ អាយុហនំ បដិសន្ធឹ គតឹ និព្វត្តឹ ឧបបត្តឹ ជាតឹ ជរំ ព្យាធឹ មរណំ សោកំ បរិទេវំ ឧបាយាសំ បដិសង្ខា សន្តិដ្ឋតា បញ្ញា សង្ខារុបេក្ខាសុ ញាណំ សកទាគាមិមគ្គំ បដិលាភត្ថាយ ។ បេ ។

សមាបត្តិ ឈ្មោះថាសង្ខារុបេក្ខាញាណ បញ្ញាគឺការពិចារណា និងការព្រងើយកន្តើយ ចំពោះវិញ្ញាណញ្ចាយតនសញ្ញា ដើម្បីប្រយោជន៍ដល់ការបាន នូវអាកិញ្ចញ្ញាយតនសមាបត្តិ ឈ្មោះថាសង្ខារុបេក្ខាញាណ បញ្ញាគឺការពិចារណា និងការព្រងើយកន្តើយ ចំពោះអាកិញ្ចញ្ញាយតន-សញ្ញា ដើម្បីប្រយោជន៍ដល់ការបាន នូវនេវសញ្ញានាសញ្ញាយតន-សមាបត្តិ ឈ្មោះថាសង្ខារុបេក្ខាញាណ នេះ សង្ខារុបេក្ខា ៨ កើតឡើងដោយអំណាចសមថៈ ។

[១៣៤] សង្ខារុបេក្ខា ១០ កើតឡើងដោយអំណាចវិបស្សនា តើដូចម្តេច ។ បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយ នូវការកើត ការប្រព្រឹត្ត និមិត្ត ការប្រមូលមក បដិសន្ធិ គតិ ការវិលមក ឧបបត្តិ ជាតិ ជរា ព្យាធិ មរណៈ សោក ការខ្សឹកខ្សួល ការចង្អៀតចង្អល់ចិត្ត ដើម្បីប្រយោជន៍ដល់ការបាននូវសោតាបត្តិមគ្គ ឈ្មោះថាសង្ខារុបេក្ខា-ញាណ ១ បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយ នូវការកើត ការប្រព្រឹត្ត និមិត្ត ការប្រមូលមក បដិសន្ធិ គតិ ការវិលមក ឧបបត្តិ ជាតិ ជរា ព្យាធិ មរណៈ សោក ការខ្សឹកខ្សួល ការចង្អៀតចង្អល់ចិត្ត ដើម្បីប្រយោជន៍ដល់សោតាបត្តិផលសមាបត្តិ ឈ្មោះថាសង្ខារុបេក្ខា-ញាណ ១ ដើម្បីប្រយោជន៍ដល់ការបាននូវសកទាគាមិមគ្គ ។ បេ ។ ១

សកទាគាមិផលសមាបត្តត្ថាយ ។ បេ ។ អនាគាមិមគ្គំ បដិលាភត្ថាយ អនាគាមិផលសមាបត្តត្ថាយ អរហត្តមគ្គំ បដិលាភត្ថាយ ឧប្បាទំ បវត្តំ និមិត្តំ អាយុហនំ បដិសន្ធឹ គតឹ និព្វត្តឹ ឧបបត្តឹ ជាតឹ ជរំ ព្យាធឹ មរណំ សោកំ បរិទេវំ ឧបាយាសំ បដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ អរហត្តផលសមាបត្តត្ថាយ ។ បេ ។ សុញ្ញតវិហារសមាបត្តត្ថាយ ។ បេ ។ អនិមិត្តវិហារសមាបត្តត្ថាយ ឧប្បាទំ បវត្តំ និមិត្តំ អាយុហនំ បដិសន្ធឹ គតឹ និព្វត្តឹ ឧបបត្តឹ ជាតឹ ជរំ ព្យាធឹ មរណំ សោកំ បរិទេវំ ឧបាយាសំ បដិសង្ខា សន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ឥមា ទស សង្ខារុបេក្ខា វិបស្សនាវសេន ឧប្បជ្ជន្តិ ។

[១៣៥] កតិ សង្ខារុបេក្ខា កុសលា កតិ អកុសលា កតិ អព្យាកតា ។ បណ្ណរស សង្ខារុបេក្ខា កុសលា តិស្សោ សង្ខារុបេក្ខា អព្យាកតា នត្ថិ សង្ខារុបេក្ខា អកុសលា ។

ដើម្បីប្រយោជន៍ដល់សកទាគាមិផលសមាបត្តិ ។ បេ ។ ១ ដើម្បីប្រយោជន៍ដល់ការបានអនាគាមិមគ្គ ១ ដើម្បីប្រយោជន៍ដល់អនាគាមិផលសមាបត្តិ ១ បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយ នូវការកើត ការប្រព្រឹត្ត និមិត្ត ការប្រមូលមក បដិសន្ធិ គតិ ការវិលមក ឧបបត្តិ ជាតិ ជរា ព្យាធិ មរណៈ សោក ការខ្សឹកខ្សួល ការចង្អៀតចង្អល់ចិត្ត ដើម្បីប្រយោជន៍ដល់អរហត្តមគ្គ ឈ្មោះថាសង្ខារុបេក្ខាញាណ ១ ដើម្បីប្រយោជន៍ដល់អរហត្តផលសមាបត្តិ ។ បេ ។ ១ ដើម្បីប្រយោជន៍ដល់សុញ្ញតវិហារសមាបត្តិ ។ បេ ។ ១ បញ្ញា គឺការពិចារណា និងការព្រងើយកន្តើយ នូវការកើត ការប្រព្រឹត្ត និមិត្ត ការប្រមូលមក បដិសន្ធិ គតិ ការវិលមក ឧបបត្តិ ជាតិ ជរា ព្យាធិ មរណៈ សោក ការខ្សឹកខ្សួល ការចង្អៀតចង្អល់ចិត្ត ដើម្បីប្រយោជន៍ដល់អនិមិត្តវិហារសមាបត្តិ ឈ្មោះថាសង្ខារុបេក្ខាញាណ ១ នេះ សង្ខារុបេក្ខាទាំង ១០ កើតឡើងដោយអំណាចវិបស្សនា ។

[១៣៥] សង្ខារុបេក្ខា ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ សង្ខារុបេក្ខា ជាកុសល ១៥ សង្ខារុបេក្ខា ជាអព្យាក្រឹត ៣ សង្ខារុបេក្ខា ជាអកុសល មិនមានទេ ។

បដិសង្ខា សន្តិដ្ឋនា បញ្ញា    អដ្ឋ ចិត្តស្ស គោចរា
បុថុជ្ជនស្ស ទ្វេ ហោន្តិ    តយោ សេក្ខស្ស គោចរា
តយោ ច វីតរាគស្ស    យេហិ ចិត្តំ វិវដ្ដតិ
អដ្ឋ សមាធិស្ស បច្ចយា    ទស ញាណស្ស គោចរា
អដ្ឋារស សង្ខារុបេក្ខា    តិណ្ណំ វិមោក្ខានប្បច្ចយា
ឥមេ អដ្ឋារសាការា    បញ្ញាយស្ស បរិចិតា
កុសលោ សង្ខារុបេក្ខាសុ    នានាទិដ្ឋីសុ ន កម្បតីតិ ។

តំ ញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ មុច្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុបេក្ខាសុ ញាណំ ។

[១៣៦] កថំ ពហិទ្ធាវុដ្ឋានវិវដ្ដនេ បញ្ញា គោត្រភូញាណំ ។ ឧប្បាទំ អភិភុយ្យតីតិ គោត្រភូ បវត្តំ អភិភុយ្យតីតិ គោត្រភូ និមិត្តំ អភិភុយ្យតីតិ

បញ្ញា គឺការពិចារណានិងការព្រងើយកន្តើយ ឈ្មោះថាសង្ខារុ-
បេក្ខា មាន ៨ ជាភូមិរបស់ចិត្ត គឺសង្ខារុបេក្ខា ២ ជាភូមិរបស់
បុថុជ្ជន សង្ខារុបេក្ខា ៣ ជាភូមិរបស់សេក្ខបុគ្គល សង្ខារុបេក្ខា
៣ ជាភូមិរបស់អសេក្ខបុគ្គល ជាសង្ខារុបេក្ខា ដែលចិត្តប្រាស
ចេញ សង្ខារុបេក្ខា ៨ ជាបច្ច័យនៃអប្បនាសមាធិ សង្ខារុបេក្ខា
១០ ជាភូមិរបស់ញាណ សង្ខារុបេក្ខា ១៨ ជាបច្ច័យរបស់
វិមោក្ខ ៣ អាការទាំង ១៨ នេះ បុគ្គលនោះបានសន្សំហើយ
ដោយបញ្ញា បុគ្គលអ្នកឈ្លាសវៃ ក្នុងសង្ខារុបេក្ខាទាំងឡាយ
រមែងមិនញាប់ញ័រក្នុងទិដ្ឋិផ្សេង ៗ ។

ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា គឺសេចក្តីប្រាថ្នាដើម្បីរួច ឬការពិចារណារកឧបាយ ឬក៏ការព្រងើយកន្តើយ ឈ្មោះថាសង្ខារុបេក្ខាញាណ ។

[១៣៦] បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសង្ខារនិមិត្តខាងក្រៅ ឈ្មោះថាគោត្រភូញាណ តើដូចម្តេច ។ ញាណគ្របសង្កត់នូវការកើតឡើង ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់នូវការប្រព្រឹត្ត ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់នូវនិមិត្ត

កោត្រក្ខ អាយុហានំ អភិកុយ្យតីតិ កោត្រក្ខ បដិសន្ធឹ អភិកុយ្យតីតិ កោត្រក្ខ គតឹ អភិកុយ្យតីតិ កោត្រក្ខ និព្វត្តឹ អភិកុយ្យតីតិ កោត្រក្ខ ឧបបត្តឹ អភិកុយ្យតីតិ កោត្រក្ខ ជាតឹ អភិកុយ្យតីតិ កោត្រក្ខ ជរំ អភិកុយ្យ-តីតិ កោត្រក្ខ ព្យាធឹ អភិកុយ្យតីតិ កោត្រក្ខ មរណំ អភិកុយ្យតីតិ កោត្រក្ខ សោកំ អភិកុយ្យតីតិ កោ-ត្រក្ខ បរិទេវំ អភិកុយ្យតីតិ កោត្រក្ខ ឧបាយាសំ អភិ-កុយ្យតីតិ កោត្រក្ខ ពហិទ្ធាសង្ខារនិមិត្តំ អភិកុយ្យតីតិ កោត្រក្ខ អនុប្បាទំ បក្ខន្ទតីតិ កោត្រក្ខ ។ បេ ។ និរោធំ និព្វានំ បក្ខន្ទតីតិ កោត្រក្ខ ឧប្បាទំ អភិកុ-យ្យិត្វា អនុប្បាទំ បក្ខន្ទតីតិ កោត្រក្ខ បវត្តំ អភិកុយ្យិត្វា អប្បវត្តំ បក្ខន្ទតីតិ កោត្រក្ខ

ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់ នូវការប្រមូលមក ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់នូវបដិសន្ធិ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់នូវគតិ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់ នូវការវិលកើត ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់ នូវការប្រព្រឹត្តនៃវិបាក ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់នូវជាតិ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់នូវជរា ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់ នូវព្យាធិ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់ នូវមរណៈ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់ នូវសោក ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់ នូវការខ្សឹកខ្សួល ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់ នូវការចង្អៀតចង្អល់ចិត្ត ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់ នូវសង្ខារនិមិត្តខាងក្រៅ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណស្ទុះទៅកាន់ការមិនផ្តើមកើតឡើង ហេតុនោះ ឈ្មោះថាគោត្រភូ ។ បេ ។ ញាណស្ទុះទៅ កាន់និព្វានជាគ្រឿងរលត់ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់នូវការកើតឡើង ហើយស្ទុះទៅកាន់ការមិនកើតឡើង ហេតុនោះ ឈ្មោះថាគោត្រភូ ញាណគ្របសង្កត់ នូវការប្រព្រឹត្ត ហើយស្ទុះទៅកាន់ការមិនប្រព្រឹត្ត ហេតុនោះ ឈ្មោះថាគោត្រភូ ញាណ

និមិត្តំ អភិកុយ្សិត្វា អនិមិត្តំ បក្ខន្ទតីតិ គោត្រភូ ។ បេ ។ ពហិទ្ធាសង្ខារនិមិត្តំ អភិកុយ្សិត្វា និរោធំ និព្វានំ បក្ខន្ទតីតិ គោត្រភូ ។

[១៣៧] ឧប្បាទា វុដ្ឋាតីតិ គោត្រភូ បវត្តា វុដ្ឋាតីតិ គោត្រភូ និមិត្តា វុដ្ឋាតីតិ គោត្រភូ អាយុហនា វុដ្ឋាតីតិ គោត្រភូ បដិសន្ធិយា វុដ្ឋាតីតិ គោត្រភូ គតិយា វុដ្ឋាតីតិ គោត្រភូ និព្វត្តិយា វុដ្ឋាតីតិ គោត្រភូ ឧបបត្តិយា វុដ្ឋាតីតិ គោត្រភូ ជាតិយា វុដ្ឋាតីតិ គោត្រភូ ជរាយ វុដ្ឋាតីតិ គោត្រភូ ព្យាធិម្ហា វុដ្ឋាតីតិ គោត្រភូ មរណា វុដ្ឋាតីតិ គោត្រភូ សោកា វុដ្ឋាតីតិ គោត្រភូ បរិទេវា វុដ្ឋាតីតិ គោត្រភូ ឧបាយាសា វុដ្ឋាតីតិ គោត្រភូ ពហិទ្ធាសង្ខារនិមិត្តា វុដ្ឋាតីតិ គោត្រភូ

គ្របសង្កត់នូវនិមិត្ត ហើយស្ទុះទៅកាន់អនិមិត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ។ បេ ។ ញាណគ្របសង្កត់នូវសង្ខារនិមិត្តខាងក្រៅ ហើយស្ទុះទៅកាន់និព្វានជាគ្រឿងរលត់ ហេតុនោះ ឈ្មោះថាគោត្រភូ ។

[១៣៧] ញាណ ចេញចាកការកើត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកការប្រព្រឹត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកនិមិត្ត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកការប្រមូលមក ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកបដិសន្ធិ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកគតិ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកការវិលកើត ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកការប្រព្រឹត្ត នៃវិបាក ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកជាតិ ហេតុនោះ ឈ្មោះថា គោ-ត្រភូ ញាណចេញចាកជរា ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកព្យាធិ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកមរណៈ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកសោក ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកការខ្សឹកខ្សួល ហេតុនោះ ឈ្មោះថាគោត្រ-ភូ ញាណចេញចាកការចង្អៀតចង្អល់ចិត្ត ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកសង្ខារនិមិត្តខាងក្រៅ ហេតុនោះ ឈ្មោះថាគោត្រភូ

អនុប្បាទំ បក្ខន្ទតីតិ គោត្រភូ អប្បវត្តំ បក្ខន្ទតីតិ គោត្រភូ ។ បេ ។ និរោធំ និព្វានំ បក្ខន្ទតីតិ គោត្រភូ ឧប្បាទា វុដ្ឋិត្វា អនុប្បាទំ បក្ខន្ទតីតិ គោត្រភូ បវត្តា វុដ្ឋិត្វា អប្បវត្តំ បក្ខន្ទតីតិ គោត្រភូ និមិត្តា វុដ្ឋិត្វា អនិមិត្តំ បក្ខន្ទតីតិ គោត្រភូ អាយូហនា វុដ្ឋិត្វា អនាយូហនំ បក្ខន្ទតីតិ គោត្រភូ បដិសន្ធិយា វុដ្ឋិត្វា អប្បដិសន្ធឹ បក្ខន្ទតីតិ គោត្រភូ គតិយា វុដ្ឋិត្វា អគតឹ បក្ខន្ទតីតិ គោត្រភូ និព្វត្តិយា វុដ្ឋិត្វា អនិព្វត្តឹ បក្ខន្ទតីតិ គោត្រភូ ឧបបត្តិយា វុដ្ឋិត្វា អនុបបត្តឹ បក្ខន្ទតីតិ គោត្រភូ ជាតិយា វុដ្ឋិត្វា អជាតឹ បក្ខន្ទតីតិ គោត្រភូ ជរាយ វុដ្ឋិត្វា អជរំ បក្ខន្ទតីតិ គោត្រភូ

ញាណស្ទុះទៅ កាន់ការមិនកើត ហេតុនោះ ឈ្មោះថាគោត្រភូ ញាណស្ទុះទៅ កាន់ការមិនប្រព្រឹត្ត ហេតុនោះ ឈ្មោះថាគោត្រភូ ។ បេ ។ ញាណស្ទុះទៅកាន់និព្វានជាគ្រឿងរលត់ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកការកើត ហើយស្ទុះទៅកាន់ការមិនកើត ហេតុនោះ ឈ្មោះថា គោត្រភូ ញាណចេញចាកការប្រព្រឹត្ត ហើយស្ទុះទៅកាន់ការមិនប្រព្រឹត្ត ហេតុនោះឈ្មោះថាគោត្រភូ ញាណចេញចាកនិមិត្ត ហើយស្ទុះទៅកាន់អនិមិត្ត ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកការប្រមូលមក ហើយស្ទុះទៅកាន់ការមិនប្រមូលមក ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកបដិសន្ធិ ហើយស្ទុះទៅកាន់ការមិនបដិសន្ធិ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកគតិ ហើយស្ទុះទៅកាន់អគតិ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកការវិលកើត ហើយស្ទុះទៅកាន់ការមិនវិលកើត ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកការប្រព្រឹត្តនៃវិបាក ហើយស្ទុះទៅកាន់ការមិនប្រព្រឹត្តនៃវិបាក ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកជាតិ ហើយស្ទុះទៅកាន់ការមិនមានជាតិ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកជរា ហើយស្ទុះទៅកាន់ការមិនមានជរា ហេតុនោះ ឈ្មោះថាគោត្រភូ ញាណ

ព្យាធិម្ហា វុដ្ឋិត្វា អព្យាធឹ បក្ខន្ទតីតិ គោត្រភូ មរណា វុដ្ឋិត្វា អមតំ បក្ខន្ទតីតិ គោត្រភូ សោកា វុដ្ឋិត្វា អសោកំ បក្ខន្ទតីតិ គោត្រភូ បរិទេវា វុដ្ឋិត្វា អបរិ-ទេវំ បក្ខន្ទតីតិ គោត្រភូ ឧបាយាសា វុដ្ឋិត្វា អនុបា-យាសំ បក្ខន្ទតីតិ គោត្រភូ ពហិទ្ធាសង្ខារនិមិត្តា វុដ្ឋិត្វា និរោធំ និព្វានំ បក្ខន្ទតីតិ គោត្រភូ ឧប្បាទា វិវដ្ដតីតិ គោត្រភូ បវត្តា វិវដ្ដតីតិ គោត្រភូ ។ បេ ។ ពហិទ្ធាសង្ខារនិមិត្តា វិវដ្ដតីតិ គោត្រភូ អនុប្បាទំ បក្ខន្ទតីតិ គោត្រភូ អប្បវត្តំ បក្ខន្ទតីតិ គោត្រភូ ។ បេ ។ និរោធំ និព្វានំ បក្ខន្ទតីតិ គោត្រភូ ឧប្បាទា វិវដ្ដិត្វា អនុប្បាទំ បក្ខន្ទតីតិ គោត្រភូ

ចេញចាកព្យាធិ ហើយស្ទុះទៅកាន់ការមិនមានព្យាធិ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកមរណៈ ហើយស្ទុះទៅកាន់អមតៈ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកសោក ហើយស្ទុះទៅកាន់ការមិនមានសោក ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកសេចក្តីខ្សឹកខ្សួល ហើយស្ទុះទៅកាន់ការមិនមានសេចក្តីខ្សឹកខ្សួល ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកសេចក្តីចង្អៀតចង្អល់ចិត្ត ហើយស្ទុះទៅកាន់ការមិនមានសេចក្តីចង្អៀតចង្អល់ចិត្ត ហេតុនោះ ឈ្មោះថាគោត្រភូ ញាណចេញចាកសង្ខារនិមិត្តខាងក្រៅ ហើយស្ទុះទៅកាន់និព្វានជាគ្រឿងរលត់ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណត្រឡប់ចាកការកើត ហេតុនោះ ឈ្មោះថាគោត្រភូ ញាណត្រឡប់ចាកការប្រព្រឹត្ត ហេតុនោះ ឈ្មោះថាគោត្រភូ ។ បេ ។ ញាណត្រឡប់ចាកសង្ខារនិមិត្តខាងក្រៅ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណស្ទុះទៅកាន់ការមិនកើត ហេតុនោះ ឈ្មោះថាគោត្រភូ ញាណស្ទុះទៅកាន់ការមិនប្រព្រឹត្ត ហេតុនោះ ឈ្មោះថាគោត្រភូ ។ បេ ។ ញាណ ស្ទុះទៅកាន់និព្វានជាគ្រឿងរលត់ ហេតុនោះ ឈ្មោះថាគោត្រភូ ញាណត្រឡប់ចាកការកើត ហើយស្ទុះទៅកាន់ការមិនកើត ហេតុនោះ ឈ្មោះថាគោត្រភូ

បវត្តា វិវដ្ដិត្វា អប្បវត្តំ បក្ខន្ទតីតិ គោត្រភូ ។ បេ ។ ពហិទ្ធាសង្ខារនិមិត្តា វិវដ្ដិត្វា និរោធំ និព្វានំ បក្ខន្ទតីតិ គោត្រភូ ។

[១៣៨] កតិ គោត្រភូធម្មា សមថវសេន ឧប្បជ្ជន្តិ កតិ គោត្រភូធម្មា វិបស្សនាវសេន ឧប្បជ្ជន្តិ ។ អដ្ឋ គោត្រភូធម្មា សមថវសេន ឧប្បជ្ជន្តិ ទស គោត្រភូធម្មា វិបស្សនាវសេន ឧប្បជ្ជន្តិ ។

[១៣៩] កតមេ អដ្ឋ គោត្រភូធម្មា សមថវសេន ឧប្បជ្ជន្តិ ។ បឋមជ្ឈានំ បដិលាភត្ថាយ នីវរណេ អភិភុយ្យតីតិ គោត្រភូ ទុតិយជ្ឈានំ បដិលាភត្ថាយ វិតក្កវិចារេ អភិភុយ្យតីតិ គោត្រភូ តតិយជ្ឈានំ បដិលាភត្ថាយ បីតឹ អភិភុយ្យតីតិ គោត្រភូ ចតុត្ថជ្ឈានំ បដិលាភត្ថាយ សុខទុក្ខេ អភិភុយ្យតីតិ គោត្រភូ អាកាសានញ្ចាយតនសមាបត្តឹ បដិលាភត្ថាយ រូបសញ្ញំ បដិឃសញ្ញំ នានត្តសញ្ញំ អភិភុយ្យតីតិ គោត្រភូ

ញាណត្រឡប់ ចាកការប្រព្រឹត្ត ហើយស្ទុះទៅកាន់ការមិនប្រព្រឹត្ត ហេតុនោះ ឈ្មោះថាគោត្រភូ ។ បេ ។ ញាណ ត្រឡប់ចាកសង្ខារនិមិត្ត ខាងក្រៅ ហើយស្ទុះទៅកាន់និព្វានជាគ្រឿងរលត់ ហេតុនោះ ឈ្មោះ ថាគោត្រភូ ។

[១៣៨] គោត្រភូធម៌ប៉ុន្មាន កើតឡើងដោយអំណាចសមថៈ គោត្រភូធម៌ប៉ុន្មាន កើតឡើងដោយអំណាចវិបស្សនា ។ គោត្រភូធម៌ ៨ កើតឡើងដោយអំណាចសមថៈ គោត្រភូធម៌ ១០ កើតឡើងដោយ អំណាចវិបស្សនា ។

[១៣៩] គោត្រភូធម៌ ៨ ដូចម្តេចខ្លះ កើតឡើងដោយអំណាច សមថៈ ។ ធម៌គ្របសង្កត់នូវនីវរណៈ ដើម្បីប្រយោជន៍ដល់ការបាននូវបឋ-មជ្ឈាន ហេតុនោះ ឈ្មោះថាគោត្រភូ ១ ធម៌គ្របសង្កត់ នូវវិតក្កៈនិងវិចារៈ ដើម្បីប្រយោជន៍ដល់ការបាននូវទុតិយជ្ឈាន ហេតុនោះ ឈ្មោះថាគោត្រ-ភូ ១ ធម៌គ្របសង្កត់នូវបីតិ ដើម្បីប្រយោជន៍ដល់ការបាននូវតតិយជ្ឈាន ហេតុនោះ ឈ្មោះថាគោត្រភូ ១ ធម៌គ្របសង្កត់នូវសុខនិងទុក្ខ ដើម្បីប្រ-យោជន៍ដល់ការបាននូវចតុត្ថជ្ឈាន ហេតុនោះ ឈ្មោះថាគោត្រភូ ១ ធម៌ គ្របសង្កត់នូវរូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា ដើម្បីប្រយោជន៍ដល់ ការបាននូវអាកាសានញ្ចាយតនសមាបត្តិ ហេតុនោះ ឈ្មោះថាគោត្រភូ ១

វិញ្ញាណញ្ចាយតនសមាបត្តិំ បដិលាភត្ថាយ អាកា-
សានញ្ចាយតនសញ្ញំ អភិកុយ្យតីតិ គោត្រភូ អាកិ-
ញ្ចញ្ញាយតនសមាបត្តិំ បដិលាភត្ថាយ វិញ្ញាណ-
ញ្ចាយតនសញ្ញំ អភិកុយ្យតីតិ គោត្រភូ នេវសញ្ញា-
នាសញ្ញាយតនសមាបត្តិំ បដិលាភត្ថាយ អាកិញ្ចញ្ញា-
យតនសញ្ញំ អភិកុយ្យតីតិ គោត្រភូ ឥមេ អដ្ឋ
គោត្រភូធម្មា សមថវសេន ឧប្បជ្ជន្តិ ។

[១៤០] កតមេ ទស គោត្រភូធម្មា វិបស្សនា-
វសេន ឧប្បជ្ជន្តិ សោតាបត្តិមគ្គំ បដិលាភត្ថាយ
ឧប្បាទំ បវត្តំ និមិត្តំ អាយុហនំ បដិសន្ធឹ គតឹ និព្វត្តឹ
ឧបបត្តឹ ជាតឹ ជរំ ព្យាធឹ មរណំ សោកំ បរិទេវំ
ឧបាយាសំ ពហិទ្ធាសង្ខារនិមិត្តំ អភិកុយ្យតីតិ គោត្រភូ
សោតាបត្តិផលសមាបត្តត្ថាយ ឧប្បាទំ បវត្តំ និមិត្តំ
អាយុហនំ បដិសន្ធឹ អភិកុយ្យតីតិ គោត្រភូ
សកទាគាមិមគ្គំ បដិលាភត្ថាយ ។ បេ ។

ធម៌គ្របសង្កត់នូវអាកាសានញ្ចាយតនសញ្ញា ដើម្បីប្រយោជន៍ដល់ការបាននូវវិញ្ញាណញ្ចាយតនសមាបត្តិ ហេតុនោះ ឈ្មោះថាគោត្រភូ ១ ធម៌គ្របសង្កត់នូវវិញ្ញាណញ្ចាយតនសញ្ញា ដើម្បីប្រយោជន៍ដល់ការបាននូវអាកិញ្ចញ្ញាយតនសមាបត្តិ ហេតុនោះ ឈ្មោះថាគោត្រភូ ១ ធម៌គ្របសង្កត់នូវអាកិញ្ចញ្ញាយតនសញ្ញា ដើម្បីប្រយោជន៍ដល់ការបាននូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ហេតុនោះ ឈ្មោះថាគោត្រភូ ១ នេះគោត្រភូធម៌ ៨ យ៉ាង កើតឡើងដោយអំណាចសមថៈ ។

[១៤០] គោត្រភូធម៌ ១០ ដូចម្តេចខ្លះ កើតឡើងដោយអំណាចវិបស្សនា ។ ធម៌គ្របសង្កត់ នូវការកើត ការប្រព្រឹត្ត និមិត្ត ការប្រមូលមក បដិសន្ធិ គតិ ការវិលកើត ការប្រព្រឹត្តនៃវិបាក ជាតិ ជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ឧបាយាសៈ និងសង្ខារនិមិត្តខាងក្រៅ ដើម្បីប្រយោជន៍ដល់ការបាននូវសោតាបត្តិមគ្គ ហេតុនោះ ឈ្មោះថាគោត្រភូ ១ ធម៌គ្របសង្កត់នូវការកើត ការប្រព្រឹត្ត និមិត្ត ការប្រមូលមក បដិសន្ធិ ដើម្បីប្រយោជន៍ដល់សោតាបត្តិផលសមាបត្តិ ហេតុនោះ ឈ្មោះថាគោត្រភូ ១ ដើម្បីប្រយោជន៍ដល់ការបាននូវសកទាគាមិមគ្គ ។ បេ ។ ១

សកទាគាមិផលសមាបត្តត្ថាយ ។ បេ ។ អនាគាមិមគ្គំ បដិលាភត្ថាយ អនាគាមិផលសមាបត្តត្ថាយ អរហត្ត-មគ្គំ បដិលាភត្ថាយ ឧប្បាទំ បវត្តំ និមិត្តំ អាយុហនំ បដិសន្ធឹ គតឹ និព្វត្តឹ ឧបបត្តឹ ជាតឹ ជរំ ព្យាធឹ មរណំ សោកំ បរិទេវំ ឧបាយាសំ ពហិទ្ធាសង្ខារនិមិត្តំ អភិ-កុយ្យតីតិ គោត្រភូ អរហត្តផលសមាបត្តត្ថាយ ។ បេ ។ សុញ្ញតវិហារសមាបត្តត្ថាយ ។ បេ ។ អនិមិត្តវិហារស-មាបត្តត្ថាយ ឧប្បាទំ បវត្តំ និមិត្តំ អាយុហនំ បដិសន្ធឹ អភិកុយ្យតីតិ គោត្រភូ ឥមេ ទស គោត្រភូធម្មា វិបស្សនាវសេន ឧប្បជ្ជន្តិ ។

[១៤១] កតិ គោត្រភូធម្មា កុសលា កតិ អកុសលា កតិ អព្យាកតា ។ បណ្ណរស គោត្រ-ភូធម្មា កុសលា តយោ គោត្រភូធម្មា អព្យាកតា នត្ថិ គោត្រភូធម្មា អកុសលា ។

[១៤២] សាមិសញ្ច និរាមិសំ បណិហិតញ្ច អប្បណិហិតំ[១] សញ្ញុត្តញ្ច[២] វិសញ្ញុត្តំ វុដ្ឋិតញ្ច អវុដ្ឋិតំ

១ ម. បណិហិតប្បណិហិតំ ។ ២ ឱ. សុញ្ញតញ្ច ។

ដើម្បីប្រយោជន៍ដល់សកទាគាមិផលសមាបត្តិ ។ បេ ។ ១ ដើម្បីប្រយោជន៍ដល់ការបាននូវអនាគាមិមគ្គ ១ ដើម្បីប្រយោជន៍ដល់អនាគាមិផលសមាបត្តិ ១ ធម៌គ្របសង្កត់ នូវការកើត ការប្រព្រឹត្ត និមិត្ត ការប្រមូលមក បដិសន្ធិ គតិ កាលវិលកើត ការប្រព្រឹត្តនៃវិបាក ជាតិ ជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ឧបាយាសៈ និងសង្ខារនិមិត្តខាងក្រៅ ដើម្បីប្រយោជន៍ដល់ការបាននូវអរហត្តមគ្គ ហេតុនោះ ឈ្មោះថាគោត្រភូ ១ ដើម្បីប្រយោជន៍ដល់អរហត្តផលសមាបត្តិ ។ បេ ។ ១ ដើម្បីប្រយោជន៍ដល់សុញ្ញតវិហារសមាបត្តិ ។ បេ ។ ១ ធម៌គ្របសង្កត់នូវការកើត ការប្រព្រឹត្ត និមិត្ត ការប្រមូលមក បដិសន្ធិ ដើម្បីប្រយោជន៍ដល់អនិមិត្តវិហារសមាបត្តិ ហេតុនោះ ឈ្មោះថាគោត្រភូ ១ នេះគោត្រភូធម៌ ១០ កើតឡើងដោយអំណាចវិបស្សនា ។

[១៤១] គោត្រភូធម៌ ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ គោត្រភូធម៌ ជាកុសល ១៥ គោត្រភូធម៌ ជាអព្យាក្រឹត ៣ ឯគោត្រភូធម៌ ជាអកុសល មិនមានទេ ។

[១៤២] គោត្រភូញាណ ៨ គឺគោត្រភូញាណប្រកបដោយអាមិសៈ ១ មិនមានអាមិសៈ ១ មានទីតាំង (នៃសេចក្តីត្រេកអរ) ១ មិនមានទីតាំង ១ ប្រកប (ដោយសេចក្តីត្រេកអរ) ១ មិនប្រកប ១ ចេញហើយ (ចាកសេចក្តីត្រេកអរ) ១ មិនទាន់ចេញហើយ ១

អដ្ឋ សមាធិស្ស បច្ចយា ទស ញាណស្ស គោចរា
អដ្ឋារស គោត្រភូធម្មា តិណ្ណំ វិមោក្ខាន បច្ចយា
ឥមេ អដ្ឋារសាការា បញ្ញាយស្ស បរិចិតា
កុសលោ វិវដ្ដេ វុដ្ឋានេ នានាទិដ្ឋីសុ ន កម្បតីតិ ។

តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ពហិទ្ធាវុដ្ឋានវិវដ្ដនេ បញ្ញា គោត្រភូញាណំ ។

[១៤៣] កថំ ទុភតោវុដ្ឋានវិវដ្ដនេ បញ្ញា មគ្គេ ញាណំ ។ សោតាបត្តិមគ្គក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ មិច្ឆាទិដ្ឋិយា វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តេន វុច្ចតិ ទុភតោវុដ្ឋានវិវដ្ដនេ បញ្ញា មគ្គេ ញាណំ ។ អភិនិរោបនដ្ឋេន សម្មាសង្កប្បោ មិច្ឆាសង្កប្បា វុដ្ឋាតិ

គោត្រភូធម៌ ៨ ជាបច្ច័យនៃសមាធិ គោត្រភូធម៌ ១០ ជាគោចរនៃញាណ គោត្រភូធម៌ ១៨ ជាបច្ច័យនៃវិមោក្ខ ៣ អាការៈទាំង ១៨ នេះ ព្រះយោគីនោះសន្សំហើយដោយប្រាជ្ញា ព្រះយោគីអ្នកឈ្លាសវៃ រមែងមិនញាប់ញ័រ ក្នុងការប្រាសចាកវដ្តៈ ក្នុងការចេញ (ចាកអកុសល) និងក្នុងទិដ្ឋិផ្សេងៗ ឡើយ ។ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ ចាកសង្ខារនិមិត្តខាងក្រៅ ឈ្មោះថាគោត្រភូញាណ ។

[១៤៣] បញ្ញា ក្នុងការចេញនិងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថាមគ្គញ្ញាណ តើដូចម្តេច ។ ក្នុងខណៈនៃសោតាបត្តិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ រមែងចេញចាកមិច្ឆាទិដ្ឋិ រមែងចេញចាកកិលេសដែលប្រព្រឹត្តតាម នូវមិច្ឆាទិដ្ឋិនោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួង ខាងក្រៅផង ហេតុនោះលោកពោលថា បញ្ញាក្នុងការចេញនិងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថាមគ្គញ្ញាណ សម្មាសង្កប្បៈ ដោយអត្ថថាលើកចិត្តឡើង (កាន់អារម្មណ៍) រមែងចេញ ចាកមិច្ឆាសង្កប្បៈ ចេញ

១៨៦

តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តេន វុច្ចតិ ឧភតោវុដ្ឋានវិវដ្ដេ បញ្ញា មគ្គេ ញាណំ បរិគ្គហដ្ឋេន សម្មាវាចា មិច្ឆាវាចាយ វុដ្ឋាតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តេន វុច្ចតិ ឧភតោវុដ្ឋានវិវដ្ដេ បញ្ញា មគ្គេ ញាណំ សមុដ្ឋានដ្ឋេន សម្មាកម្មន្តោ មិច្ឆាកម្មន្តា វុដ្ឋាតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ ច វុដ្ឋាតិ តេន វុច្ចតិ ឧភតោវុដ្ឋានវិវដ្ដេ បញ្ញា មគ្គេ ញាណំ វោទានដ្ឋេន សម្មាអាជីវោ មិច្ឆាអាជីវា វុដ្ឋាតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តេន វុច្ចតិ ឧភតោវុដ្ឋានវិវដ្ដេ បញ្ញា មគ្គេ ញាណំ បគ្គហដ្ឋេន សម្មាវាយាមោ មិច្ឆាវាយាមា វុដ្ឋាតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច

ចាកកិលេសដែលប្រព្រឹត្តតាម នូវមិច្ឆាសង្កប្បៈនោះផង ចាកខន្ធទាំង-ឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញនិងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថាមគ្គញ្ញាណ សម្មាវាចា ដោយអត្ថថារក្សាទុក រមែងចេញចាកមិច្ឆាវាចា ចេញចាកកិលេស ដែលប្រព្រឹត្តតាម នូវមិច្ឆាវាចានោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញនិងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថាមគ្គញ្ញាណ សម្មាកម្មន្តៈ ដោយអត្ថថាតាំងឡើង រមែងចេញចាកមិច្ឆាកម្មន្តៈ ចេញចាកកិលេសដែលប្រព្រឹត្តតាម នូវមិច្ឆាកម្មន្តៈនោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថាមគ្គញ្ញាណ សម្មាអាជីវៈ ដោយអត្ថថាផូរផង់ រមែងចេញចាកមិច្ឆាអាជីវៈ ចេញចាកកិលេសដែលប្រព្រឹត្តតាម នូវមិច្ឆាអាជីវៈនោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថាមគ្គញ្ញាណ សម្មាវា-យាមៈ ដោយអត្ថថាផ្គងឡើង រមែងចេញចាកមិច្ឆាវាយាមៈ ចេញចាកកិ-លេសដែលប្រព្រឹត្តតាមនូវមិច្ឆាវាយាមៈនោះផង ចាកខន្ធទាំងឡាយផង

វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តេន វុច្ចតិ ឧភតោវុដ្ឋានវិវដ្ដេ បញ្ញា មគ្គេ ញាណំ ឧបដ្ឋានដ្ឋេន សម្មាសតិ មិច្ឆាសតិយា វុដ្ឋាតិ តទនុវត្តកក្កិលេ- សេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិ- ត្តេហិ វុដ្ឋាតិ តេន វុច្ចតិ ឧភតោវុដ្ឋានវិវដ្ដេ បញ្ញា មគ្គេ ញាណំ អវិក្ខេបដ្ឋេន សម្មាសមាធិ មិច្ឆាសមាធិតោ វុដ្ឋាតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តេន វុច្ចតិ ឧភតោវុដ្ឋានវិវដ្ដេ បញ្ញា មគ្គេ ញាណំ ។

[១៤៤] សកទាគាមិមគ្គក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធិ ឱឡារិកា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា ឱឡារិកា កាមរាគានុសយា បដិឃានុសយា វុដ្ឋាតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិ- ទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តេន វុច្ចតិ ឧភតោ- វុដ្ឋានវិវដ្ដេ បញ្ញា មគ្គេ ញាណំ ។

រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញា ក្នុងការចេញនិងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថាមគ្គ-ញ្ញាណ សម្មាសតិ ដោយអត្ថថាប្រុងប្រយ័ត្ន រមែងចេញចាកមិច្ឆាសតិ ចេញចាកកិលេសដែលប្រព្រឹត្តតាម នូវមិច្ឆាសតិនោះផង ចាកខន្ធទាំង-ឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញ និងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថាមគ្គញ្ញាណ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងចេញចាកមិច្ឆាសមាធិ ចេញចាកកិលេសដែលប្រព្រឹត្តតាមនូវមិច្ឆាសមាធិនោះផង ចាកខន្ធទាំងឡាយផង រមែងចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញនិងការវិលត្រឡប់ចាកសភាវៈទាំង ២ ឈ្មោះថាមគ្គញ្ញាណ ។

[១៤៤] ក្នុងខណៈនៃសកទាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ ។ បេ ។ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងចេញចាកកាមរាគសញ្ញោជនៈ និងបដិឃសញ្ញោជនៈ ដ៏គ្រោតគ្រាត ចាកកាមរាគា-នុស័យនិងបដិឃានុស័យ ដ៏គ្រោតគ្រាត ចេញចាកកិលេសដែលប្រព្រឹត្តតាមសញ្ញោជនៈនិងអនុស័យនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញនិងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថាមគ្គញ្ញាណ ។

[១៤៥] អនាគាមិមគ្គក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធិ អនុសហគតា កាមរាគសញ្ញោជនា បដិឃសញ្ញោ-ជនា អនុសហគតា កាមរាគានុសយា បដិឃានុសយា វុដ្ឋាតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តេន វុច្ចតិ ឧភតោ-វុដ្ឋានវិវដ្ដនេ បញ្ញា មគ្គេ ញាណំ ។

[១៤៦] អរហត្តមគ្គក្ខណេ ទស្សនដ្ឋេន សម្មា-ទិដ្ឋិ ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធិ រូបរាគា អរូបរាគា មានា ឧទ្ធច្ចា អវិជ្ជាយ មានានុសយា ភវរាគានុសយា អវិជ្ជានុសយា វុដ្ឋាតិ តទនុវត្តកក្កិ-លេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វ-និមិត្តេហិ វុដ្ឋាតិ តេន វុច្ចតិ ឧភតោវុដ្ឋានវិវដ្ដនេ បញ្ញា មគ្គេ ញាណំ ។

[១៤៧] អជាតំ ឈាបេតិ ជាតេន ឈានេន្ដន បវុច្ចតិ
ឈានវិមោក្ខេ[១] កុសលតា នានាទិដ្ឋីសុ ន កម្បតីតិ ។

---

១ ឱ. ញាបេតិ ជាតនេ ញាណេន្តន បវុច្ចតិ ញាណវិមោក្ខេ ។

[១៤៥] ក្នុងខណៈនៃអនាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ ។ បេ ។ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងចេញចាកកាម-រាគសញ្ញោជនៈ និងបដិឃសញ្ញោជនៈដ៏ល្អិត ចាកកាមរាគានុស័យនិងបដិឃានុស័យដ៏ល្អិត ចេញចាកកិលេសដែលប្រព្រឹត្តតាមសញ្ញោជនៈនិងអនុស័យនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញនិងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថាមគ្គញ្ញាណ ។

[១៤៦] ក្នុងខណៈនៃអរហត្តមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ ។ បេ ។ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងចេញចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យនិងអវិជ្ជានុស័យ ចេញចាកកិលេសដែលប្រព្រឹត្តតាមនូវអនុសយក្កិលេសនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញនិងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថាមគ្គញ្ញាណ ។

[១៤៧ ]យោគីរមែងដុតបំផ្លាញ នូវកិលេសដែលមិនទាន់កើត ដោយអដ្ឋឈានដែលកើតហើយ ហេតុនោះ លោកហៅថា ឈាន យោគីរមែងមិនញាប់ញ័រ ក្នុងទិដ្ឋិផ្សេងៗ ព្រោះភាពជាបុគ្គលឈ្លាសវៃ ក្នុងឈាននិងវិមោក្ខ ។

សមាទហិត្វា យថា ចេ វិបស្សតិ
វិបស្សមានោ[1] តថា ចេ សមាទហេ
វិបស្សនា ច សមថោ តទា អហុ
សមានភាគា យុគនទ្ធា[2] វត្តរេ

ទុក្ខា សង្ខារា សុខោ និរោធោតិ ទស្សនំ
ទុភតោ វុដ្ឋិតា បញ្ញា ផស្សេតិ អមតំ បទំ
វិមោក្ខចរិយំ ជានាតិ នានត្តេកត្តកោវិទោ
ទ្វិន្នំ ញាណានំ កុសលតា នានាទិដ្ឋីសុ ន កម្បតីតិ ។

តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ទុភតោវុដ្ឋានវិវដ្ដនេ បញ្ញា មគ្គេ ញាណំ ។

[១៤៨] កថំ បយោគប្បដិប្បស្សទ្ធិប្បញ្ញា ផលេ ញាណំ ។ សោតាបត្តិមគ្គក្ខណេ ទស្សនដ្ឋេន សម្មា-ទិដ្ឋិ មិច្ឆាទិដ្ឋិយា វុដ្ឋាតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តំបយោគប្បដិប្បស្សទ្ធត្តា ឧប្បជ្ជតិ សម្មាទិដ្ឋិ មគ្គស្សេតំ ផលំ អភិនិរោបនដ្ឋេន សម្មាសង្កប្បោ

១ ម. យថា ។ ២ ឱ. ម. យុគនន្ធា ។

បើយោគីតម្កល់ចិត្តហើយពិចារណា រមែងឃើញច្បាស់យ៉ាងណា គប្បីតម្កល់ចិត្តទុកយ៉ាងនោះ វិបស្សនានិងសមថៈ ជាធម៌មានចំណែកស្មើគ្នាជាគូជាប់គ្នា រមែងប្រព្រឹត្តទៅក្នុងកាលណោះ ការឃើញថា សង្ខារទាំងឡាយជាទុក្ខ និរោធជាសុខ បញ្ញាដែលចេញចាកសភាវៈទាំង ២ រមែងពាល់ត្រូវនូវព្រះនិព្វាន ឈ្មោះអមតៈ យោគីអ្នកឈ្លាសវៃ ក្នុងភាពនៃធម៌ផ្សេងគ្នានិងធម៌ដូចគ្នា រមែងដឹងនូវកិរិយាប្រព្រឹត្តក្នុងវិមោក្ខ រមែងមិនញាប់ញ័រក្នុងទិដ្ឋិផ្សេង ៗ ព្រោះភាពជាបុគ្គលឈ្លាសវៃក្នុងញាណទាំងពីរ ។ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការចេញនិងការវិលត្រឡប់ ចាកសភាវៈទាំង ២ ឈ្មោះថាមគ្គញាណ ។

[១៤៨] បញ្ញាសម្រាប់រម្ងាប់នូវព្យាយាម ឈ្មោះថាផលញ្ញាណ តើដូចម្ដេច ។ ក្នុងខណៈនៃសោតាបត្តិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ រមែងចេញចាកមិច្ឆាទិដ្ឋិ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆាទិដ្ឋិនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាទិដ្ឋិ រមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ ទុំះជាផលរបស់មគ្គ សម្មាសង្កប្បៈ ដោយអត្ថថាលើកចិត្តឡើង (កាន់អារម្មណ៍)

មិច្ឆាសង្កប្បា វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ ច វុដ្ឋាតិ តំបយោគប្បដិប្បស្សទ្ធត្តា ឧប្បជ្ជតិ សម្មាសង្កប្បោ មគ្គស្សេតំ ផលំ បរិគ្គហដ្ឋេន សម្មាវាចា មិច្ឆាវាចាយ វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តំបយោគប្បដិប្បស្សទ្ធត្តា ឧប្បជ្ជតិ សម្មាវាចា មគ្គស្សេតំ ផលំ សមុដ្ឋានដ្ឋេន សម្មាកម្មន្តោ មិច្ឆាកម្មន្តា វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តំបយោគប្បដិប្បស្សទ្ធត្តា ឧប្បជ្ជតិ សម្មាកម្មន្តោ មគ្គស្សេតំ ផលំ វោទានដ្ឋេន សម្មាអាជីវោ មិច្ឆាអាជីវា វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តំបយោគប្បដិប្បស្សទ្ធត្តា ឧប្បជ្ជតិ សម្មាអាជីវោ មគ្គស្សេតំ ផលំ បគ្គហដ្ឋេន សម្មាវាយាមោ មិច្ឆាវាយាមា វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ ច វុដ្ឋាតិ

រមែងចេញចាកមិច្ឆាសង្កប្បៈ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆាសង្កប្បៈនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាសង្កប្បៈ រមែងកើតឡើង ព្រោះការរម្ងាប់ព្យាយាមក្នុងការចេញនោះ នុ៎ះជាផលរបស់មគ្គ សម្មាវាចា ដោយអត្ថថារក្សាទុក រមែងចេញចាកមិច្ឆាវាចា ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆា-វាចានោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាវាចា រមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ នុ៎ះជាផលរបស់មគ្គ សម្មាកម្មន្តៈ ដោយអត្ថថាតាំងឡើង រមែងចេញចាកមិច្ឆាកម្មន្តៈ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆាកម្មន្តៈនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មា-កម្មន្តៈ រមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាម ក្នុងការចេញនោះ នុ៎ះជាផលរបស់មគ្គ សម្មាអាជីវៈ ដោយអត្ថថាផូរផង់ រមែងចេញចាកមិច្ឆាអាជីវៈ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាម នូវមិច្ឆាអាជីវៈនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាអាជីវៈរមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ នុ៎ះជាផលរបស់មគ្គ សម្មាវាយាមៈ ដោយអត្ថថាផ្គងឡើង រមែងចេញចាកមិច្ឆាវាយាមៈ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆាវាយាមៈនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង

តំបយោគប្បដិប្បស្សទ្ធត្តា ឧប្បជ្ជតិ សម្មាវាយាមោ មគ្គស្សេតំ ផលំ ឧបដ្ឋានដ្ឋេន សម្មាសតិ មិច្ឆាសតិយា វុដ្ឋាតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តំបយោគប្បដិប្បស្សទ្ធត្តា ឧប្បជ្ជតិ សម្មាសតិ មគ្គស្សេតំ ផលំ អវិក្ខេបដ្ឋេន សម្មាសមាធិ មិច្ឆាសមាធិតោ វុដ្ឋាតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តំបយោគប្បដិប្បស្សទ្ធត្តា ឧប្បជ្ជតិ សម្មាសមាធិ មគ្គស្សេតំ ផលំ ។

[១៨៩] សកទាគាមិមគ្គក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធិ ឱឡារិកា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា ឱឡារិកា កាមរាគានុសយា បដិឃានុសយា វុដ្ឋាតិ តទនុវត្តកក្កិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តំបយោគប្បដិប្បស្សទ្ធត្តា ឧប្បជ្ជតិ សម្មាសមាធិ មគ្គស្សេតំ ផលំ ។

[១៩០] អនាគាមិមគ្គក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធិ

សម្មាវាយាមៈ រមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ ទុំះជាផលរបស់មគ្គ សម្មាសតិ ដោយអត្ថថាប្រុងប្រយ័ត្ន រមែងចេញចាកមិច្ឆាសតិ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆាសតិនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាសតិ រមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ ទុំះជាផលរបស់មគ្គ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងចេញចាកមិច្ឆាសមាធិ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវមិច្ឆាសមាធិនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាសមាធិ រមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ ទុំះជាផលរបស់មគ្គ ។

[១៤៩] ក្នុងខណៈនៃសកទាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ ។ បេ ។ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងចេញចាកកាមរាគសញ្ញោជនៈនិងបដិឃសញ្ញោជនៈ ដ៏គ្រោតគ្រាត ចាកកាមរាគានុស័យនិងបដិឃានុស័យ ដ៏គ្រោតគ្រាត ចេញចាកកិលេស ដែលប្រព្រឹត្តទៅតាមសញ្ញោជនៈនិងអនុស័យនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាសមាធិ រមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ ទុំះជាផលរបស់មគ្គ ។

[១៥០] ក្នុងខណៈនៃអនាគាមិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ ។ បេ ។ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងចេញចាក

អនុសហគតា កាមរាគសញ្ញោជនា បដិឃសញ្ញោជនា អនុសហគតា កាមរាគានុសយា បដិឃានុសយា វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តំបយោគប្បដិប្បស្សទ្ធត្តា ឧប្បជ្ជតិ សម្មាសមាធិ មគ្គស្សេតំ ផលំ ។

[១៨១] អរហត្តមគ្គក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ ។ បេ ។ អវិក្ខេបដ្ឋេន សម្មាសមាធិ រូបរាគា អរូបរាគា មានា ឧទ្ធច្ចា ជីវមិទ្ធា អវិជ្ជាយ ការរាគានុសយា មានានុសយា អវិជ្ជានុសយា វុដ្ឋាតិ តទនុវត្តកកិលេសេហិ ច ខន្ធេហិ ច វុដ្ឋាតិ ពហិទ្ធា ច សព្វនិមិត្តេហិ វុដ្ឋាតិ តំបយោគប្បដិប្បស្សទ្ធត្តា ឧប្បជ្ជតិ សម្មាសមាធិ មគ្គសេ តំ ផលំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ បយោគប្បដិប្បស្សទ្ធិប្បញ្ញា ផលេ ញាណំ ។

[១៨២] កថំ ធិន្នមនុបស្សនេ[១] បញ្ញា វិមុត្តិញ្ញាណំ ។ សោតាបត្តិមគ្គេន សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ អត្តនោ ចិត្តស្ស ឧបក្កិលេសា សម្មា សមុច្ឆិន្នា ហោន្តិ

១ ម. ឆិន្នវដ្តមនុបស្សនេ ។

*កាមរាគសញ្ញោជនៈនិងបដិឃសញ្ញោជនៈ ដ៏ល្អិត ចាកកាមរាគានុស័យ និងបដិឃានុស័យ ដ៏ល្អិត ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវសញ្ញោជនៈនិងអនុស័យនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាសមាធិ រមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ នុ៎ះជាផលរបស់មគ្គ ។*

*[១៥១] ក្នុងខណៈនៃអរហត្តមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ ។ បេ ។ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ រមែងចេញចាករូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ ថីនមិទ្ធៈ អវិជ្ជា ភវរាគានុស័យ មានានុស័យ និងអវិជ្ជានុស័យ ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមនូវសញ្ញោជនៈនិងអនុស័យនោះផង ចាកខន្ធទាំងឡាយផង ចេញចាកនិមិត្តទាំងពួងខាងក្រៅផង សម្មាសមាធិ រមែងកើតឡើង ព្រោះការរម្ងាប់នូវព្យាយាមក្នុងការចេញនោះ នុ៎ះជាផលរបស់មគ្គ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា សម្រាប់រម្ងាប់នូវព្យាយាម ឈ្មោះថាផលញ្ញាណ ។*

*[១៥២] បញ្ញា ក្នុងការឃើញ នូវកិលេស ដែលដាច់ ឈ្មោះថា វិមុត្តិញ្ញាណ តើដូចម្តេច ។ ពួកឧបក្កិលេស នៃចិត្តរបស់ខ្លួន គឺសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ លោកផ្តាច់បង់ប្រពៃហើយ ដោយសោតាបត្តិមគ្គ*

ឥមេហិ បញ្ចហិ ឧបក្កិលេសេហិ សបរិយុដ្ឋានេហិ ចិត្តំ វិមុត្តំ ហោតិ សុវិមុត្តំ តំវិមុត្តិញ្ញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ជិន្នមនុបស្សនេ បញ្ញា វិមុត្តិញ្ញាណំ ។

[១៨៣] សកជាតាមិមគ្គេន ឱឡារិកំ កាមរាគ-សញ្ញោជនំ បដិឃសញ្ញោជនំ ឱឡារិកោ កាមរាគា-នុសយោ បដិឃានុសយោ អត្តនោ ចិត្តស្ស ឧបក្កិ-លេសា សម្មា សមុច្ឆិន្នា ហោន្តិ ឥមេហិ ចតូហិ ឧបក្កិលេសេហិ សបរិយុដ្ឋានេហិ ចិត្តំ វិមុត្តំ ហោតិ សុវិមុត្តំ តំវិមុត្តិញ្ញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ជិន្នមនុបស្សនេ បញ្ញា វិមុត្តិញ្ញាណំ ។

[១៨៤] អជាតាមិមគ្គេន អនុសហាគតំ កាមរាគ-សញ្ញោជនំ បដិឃសញ្ញោជនំ អនុសហាគតោ កាមរា-គានុសយោ បដិឃានុសយោ អត្តនោ ចិត្តស្ស ឧបក្កិលេសា សម្មា សមុច្ឆិន្នា ហោន្តិ ឥមេហិ ចតូហិ ឧបក្កិលេសេហិ សបរិយុដ្ឋានេហិ ចិត្តំ វិមុត្តំ ហោតិ សុវិមុត្តំ តំវិមុត្តិញ្ញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ជិន្នមនុបស្សនេ បញ្ញា វិមុត្តិញ្ញាណំ ។

ចិត្តរួចស្រឡះ ផុតស្រឡះដោយប្រពៃ ចាកឧបក្កិលេស ៥ នេះឯង ព្រមទាំងបរិយុដ្ឋានក្កិលេស (កិលេសជាគ្រឿងរួបរឹតចិត្ត) ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវការរួចស្រឡះចាកឧបក្កិលេសនោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់ ហេតុនោះ លោកពោលថា បញ្ញាក្នុងការឃើញនូវកិលេសដែលដាច់ ឈ្មោះថាវិមុត្តិញ្ញាណ ។

[១៥៣] ពួកឧបក្កិលេសនៃចិត្តរបស់ខ្លួន គឺកាមរាគសញ្ញោជនៈនិងបដិឃសញ្ញោជនៈ ដ៏គ្រោតគ្រាត កាមរាគានុស័យនិងបដិឃានុស័យដ៏គ្រោតគ្រាត លោកបានផ្តាច់បង់ប្រពៃហើយ ដោយសកទាគាមិមគ្គ ចិត្តរួចស្រឡះ ផុតស្រឡះដោយប្រពៃ ចាកឧបក្កិលេស ៤ នេះឯង ព្រមទាំងបរិយុដ្ឋានក្កិលេស ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវការរួចស្រឡះចាកឧបក្កិលេសនោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់ ហេតុនោះ លោកពោលថា បញ្ញាក្នុងការឃើញនូវកិលេសដែលដាច់ ឈ្មោះថាវិមុត្តិញ្ញាណ ។

[១៥៤] ពួកឧបក្កិលេសនៃចិត្តរបស់ខ្លួន គឺកាមរាគសញ្ញោជនៈបដិឃសញ្ញោជនៈដ៏ល្អិត កាមរាគានុស័យនិងបដិឃានុស័យដ៏ល្អិត លោកបានផ្តាច់បង់ប្រពៃហើយ ដោយអនាគាមិមគ្គ ចិត្តរួចស្រឡះ ផុតស្រឡះដោយប្រពៃ ចាកឧបក្កិលេស ៤ នេះឯង ព្រមទាំងបរិយុដ្ឋានក្កិលេស ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវការរួចស្រឡះចាកឧបក្កិលេសនោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់ ហេតុនោះ លោកពោលថា បញ្ញាក្នុងការឃើញនូវកិលេសដែលដាច់ ឈ្មោះថាវិមុត្តិញ្ញាណ ។

[១៩៥] អរហត្តមគ្គេន រូបរាគោ អរូបរាគោ មានោ ឧទ្ធច្ចំ អវិជ្ជា មានានុសយោ ភវរាគានុសយោ អវិជ្ជានុសយោ អត្តនោ ចិត្តស្ស ឧបក្កិលេសា សម្មា សមុច្ឆិន្នា ហោន្តិ ឥមេហិ អដ្ឋហិ ឧបក្កិលេសេហិ សបរិយុដ្ឋានេហិ ចិត្តំ វិមុត្តំ ហោតិ សុវិមុត្តំ តំ-វិមុត្តិញ្ញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ធិន្នមនុបស្សនេ បញ្ញា វិមុត្តិញ្ញាណំ តំញាត-ដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ធិន្នមនុបស្សនេ បញ្ញា វិមុត្តិញ្ញាណំ ។

[១៩៦] កថំ តជា សមុចាគតេ(១) ធម្មេ បស្ស-នេ(២) បញ្ញា បច្ចវេក្ខណេ ញាណំ ។ សោតាបត្តិ-មគ្គក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ តជា សមុចាគតា អភិនិរោបនដ្ឋេន សម្មាសង្កប្បោ តជា សមុចាគតោ បរិគ្គហដ្ឋេន សម្មាវាចា តជា សមុចាគតា សមុដ្ឋា-នដ្ឋេន សម្មាកម្មន្តោ តជា សមុចាគតោ វោទាន-ដ្ឋេន សម្មាអាជីវោ តជា សមុចាគតោ បគ្គហដ្ឋេន សម្មាវាយាមោ តជា សមុចាគតោ ឧបដ្ឋានដ្ឋេន សម្មាសតិ តជា សមុចាគតា អវិក្ខេបដ្ឋេន

១ ឱ. ម. សមុទាគតេ ។ ២ ឱ. ម. វិបស្សនេ ។

[១៥៥] ពួកឧបក្កិលេសនៃចិត្តរបស់ខ្លួន គឺរូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា មានានុស័យ ភវរាគានុស័យ អវិជ្ជានុស័យ លោកបាន ផ្តាច់បង់ប្រពៃហើយ ដោយអរហត្តមគ្គ ចិត្តរួចស្រឡះ ផុតស្រឡះដោយ ប្រពៃ ចាកឧបក្កិលេស ៨ នេះឯង ព្រមទាំងបរិយុដ្ឋានក្កិលេស ឈ្មោះថា ញាណ ដោយអត្ថថាដឹងនូវការរួចចាកឧបក្កិលេសនោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់ ហេតុនោះ លោកពោលថា បញ្ញាក្នុងការឃើញ នូវកិលេសដែលដាច់ ឈ្មោះថាវិមុត្តិញ្ញាណ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវ ធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការឃើញនូវកិលេស ដែលដាច់ ឈ្មោះថាវិមុត្តិញ្ញាណ ។

[១៥៦] បញ្ញា ក្នុងការឃើញនូវធម៌ដែលតាំងឡើង ក្នុងកាល នោះ ឈ្មោះថាបច្ចវេក្ខណញ្ញាណ តើដូចម្តេច ។ ក្នុងខណៈនៃសោតា-បត្តិមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ តាំងឡើង ក្នុងកាលណោះ សម្មាសង្កប្បៈ ដោយអត្ថថាលើកចិត្ត តាំងឡើងក្នុងកាលណោះ សម្មា-វាចា ដោយអត្ថថារក្សាទុក តាំងឡើង ក្នុងកាលណោះ សម្មាកម្មន្តៈ ដោយអត្ថថាផ្តួចផ្តើម តាំងឡើងក្នុងកាលណោះ សម្មាអាជីវៈ ដោយអត្ថ ថាផូរផង់ តាំងឡើងក្នុងកាលណោះ សម្មាវាយាមៈ ដោយអត្ថថាផ្គង់ទុក តាំងឡើងក្នុងកាលណោះ សម្មាសតិ ដោយអត្ថថាប្រុងប្រយ័ត្ន តាំងឡើង

សម្មាសមាធិ តទា សមុទាគតោ ឧបដ្ឋានដ្ឋេន សតិសម្ពោជ្ឈង្គោ តទា សមុទាគតោ បវិចយដ្ឋេន ធម្មវិចយសម្ពោជ្ឈង្គោ តទា សមុទាគតោ បគ្គហដ្ឋេន វីរិយសម្ពោជ្ឈង្គោ តទា សមុទាគតោ ផរណដ្ឋេន បីតិសម្ពោជ្ឈង្គោ តទា សមុទាគតោ ឧបសមដ្ឋេន បស្សទ្ធិសម្ពោជ្ឈង្គោ តទា សមុទាគតោ អវិក្ខេបដ្ឋេន សមាធិសម្ពោជ្ឈង្គោ តទា សមុទាគតោ បដិសង្ខានដ្ឋេន ឧបេក្ខាសម្ពោជ្ឈង្គោ តទា សមុទាគតោ អស្សទ្ធិយេ[១] អកម្បិយដ្ឋេន សទ្ធាពលំ តទា សមុទាគតំ កោសជ្ជេ អកម្បិយដ្ឋេន វីរិយពលំ តទា សមុទាគតំ បមាទេ អកម្បិយដ្ឋេន សតិពលំ តទា សមុទាគតំ ឧទ្ធច្ចេ អកម្បិយដ្ឋេន សមាធិពលំ តទា សមុទាគតំ អវិជ្ជាយ អកម្បិយដ្ឋេន បញ្ញាពលំ តទា សមុទាគតំ អធិមោក្ខដ្ឋេន សទ្ធិន្ទ្រិយំ តទា សមុទាគតំ បគ្គហដ្ឋេន វីរិយិន្ទ្រិយំ តទា សមុទាគតំ ឧបដ្ឋានដ្ឋេន សតិន្ទ្រិយំ តទា សមុទាគតំ អវិក្ខេបដ្ឋេន សមាធិន្ទ្រិយំ តទា សមុទាគតំ ទស្សនដ្ឋេន

១ ឱ. ម. អស្សទ្ធិយេ ។

ក្នុងកាលណោះ សម្មាសមាធិ ដោយអត្ថថាមិនរាយមាយ តាំងឡើងក្នុងកាលណោះ សតិសម្ពោជ្ឈង្គ ដោយអត្ថថាប្រុងប្រយ័ត្ន តាំងឡើងក្នុងកាលណោះ ធម្មវិចយសម្ពោជ្ឈង្គ ដោយអត្ថថាឈ្វេចឈ្វៃ តាំងឡើងក្នុងកាលណោះ វិរិយសម្ពោជ្ឈង្គ ដោយអត្ថថាផ្គងទុក តាំងឡើងក្នុងកាលណោះ បីតិសម្ពោជ្ឈង្គដោយអត្ថថាផ្សាយទៅ តាំងឡើងក្នុងកាលណោះ បស្សទ្ធិ-សម្ពោជ្ឈង្គ ដោយអត្ថថាស្ងប់រម្ងាប់ តាំងឡើងក្នុងកាលណោះ សមាធិ-សម្ពោជ្ឈង្គដោយអត្ថថាមិនរាយមាយ តាំងឡើងក្នុងកាលណោះ ឧបេក្ខា-សម្ពោជ្ឈង្គ ដោយអត្ថថាពិចារណា តាំងឡើងក្នុងកាលណោះ សទ្ធាពលៈ ដោយអត្ថថាមិនកម្រើកដោយអស្សទ្ធិយៈ (ការមិនជឿ)តាំងឡើងក្នុងកាលណោះ វិរិយពលៈ ដោយអត្ថថាមិនកម្រើកដោយកោសជ្ជៈ (សេចក្តីខ្ជិលច្រអូស) តាំងឡើងក្នុងកាលណោះ សតិពលៈ ដោយអត្ថថាមិនកម្រើកដោយបមាទៈ តាំងឡើងក្នុងកាលណោះ សមាធិពលៈ ដោយអត្ថថាមិនកម្រើកដោយឧទ្ធច្ចៈ តាំងឡើងក្នុងកាលណោះ បញ្ញាពលៈ ដោយអត្ថថាមិនកម្រើកដោយអវិជ្ជា តាំងឡើងក្នុងកាលណោះ សទ្ធិន្ទ្រិយដោយអត្ថថាជឿ តាំងឡើងក្នុងកាលណោះ វិរិយិន្ទ្រិយ ដោយអត្ថថាផ្គងទុក តាំងឡើងក្នុងកាលណោះ សតិន្ទ្រិយ ដោយអត្ថថាប្រុងប្រយ័ត្ន តាំងឡើងក្នុងកាលណោះ សមាធិន្ទ្រិយ ដោយអត្ថថាមិនរាយមាយ តាំងឡើងក្នុងកាលណោះ

បញ្ញិន្ទ្រិយំ តថា សមុទាគតំ អាធិបតេយ្យដ្ឋេន ឥន្ទ្រិយំ តថា សមុទាគតំ[១] អកម្បិយដ្ឋេន ពលំ តថា សមុទាគតំ និយ្យានដ្ឋេន សម្ពោជ្ឈង្គោ តថា សមុទាគតោ ហេតដ្ឋេន[២] មគ្គោ តថា សមុទាគតោ ឧបដ្ឋានដ្ឋេន សតិប្បដ្ឋានា តថា សមុទាគតា បទហនដ្ឋេន សម្មប្បធានា តថា សមុទាគតា ឥជ្ឈនដ្ឋេន ឥទ្ធិបាទា តថា សមុទាគតា តថដ្ឋេន សច្ចា តថា សមុទាគតា អវិក្ខេបដ្ឋេន សមថោ តថា សមុទាគតោ អនុបស្សនដ្ឋេន វិបស្សនា តថា សមុទាគតា ឯករសដ្ឋេន សមថវិបស្សនា តថា សមុទាគតា អនតិវត្តនដ្ឋេន យុគនទ្ធំ តថា សមុទាគតំ សំវរដ្ឋេន សីលវិសុទ្ធិ តថា សមុទាគតា អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ តថា សមុទាគតា ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ តថា សមុទាគតា វិមុត្តដ្ឋេន វិមោក្ខោ តថា សមុទាគតោ បដិវេធដ្ឋេន វិជ្ជា តថា សមុទាគតា បរិច្ចាគដ្ឋេន វិមុត្តិ តថា សមុទាគតា សមុច្ឆេទដ្ឋេន ខយេ ញាណំ តថា សមុទាគតំ

១ ឱ. ម. ឥន្ទ្រិយា តថា សមុទាគតា ។ ២ ឱ. ម. ហេតុដ្ឋេន ។

បញ្ញិន្ទ្រិយ ដោយអត្ថថាឃើញ តាំងឡើងក្នុងកាលណោះ ឥន្ទ្រិយ ដោយអត្ថថាជាធំ តាំងឡើង ក្នុងកាលណោះ ពលៈ ដោយអត្ថថាមិនកម្រើក តាំងឡើងក្នុងកាលណោះ សម្ពោជ្ឈង្គ ដោយអត្ថថាស្រោចស្រង់ តាំងឡើងក្នុងកាលណោះ មគ្គដោយអត្ថថាជាហេតុ តាំងឡើងក្នុងកាលណោះ សតិប្បដ្ឋាន ដោយអត្ថថាប្រុងប្រយ័ត្ន តាំងឡើងក្នុងកាលណោះ សម្មប្ប-ធាន ដោយអត្ថថាតម្កល់ទុក តាំងឡើងក្នុងកាលណោះ ឥទ្ធិបាទ ដោយអត្ថថាសម្រេច តាំងឡើងក្នុងកាលណោះ សច្ចៈ ដោយអត្ថថាពិត តាំងឡើងក្នុងកាលណោះ សមថៈ ដោយអត្ថថាមិនរាយមាយ តាំងឡើងក្នុងកាលណោះ វិបស្សនា ដោយអត្ថថាពិចារណារឿយៗ តាំងឡើងក្នុងកាលណោះ សមថៈនិងវិបស្សនា ដោយអត្ថថាមានរសតែមួយ តាំងឡើងក្នុងកាលណោះ ការជាប់គ្នាជាគូ ដោយអត្ថថាមិនប្រព្រឹត្តកន្លង (នូវគ្នានិងគ្នា) តាំងឡើងក្នុងកាលណោះ សីលវិសុទ្ធិ ដោយអត្ថថាសង្រួម តាំងឡើងក្នុងកាលណោះ ចិត្តវិសុទ្ធិ ដោយអត្ថថាមិនរវើរវាយ តាំងឡើងក្នុងកាលណោះ ទិដ្ឋិវិសុទ្ធិ ដោយអត្ថថាឃើញ តាំងឡើងក្នុងកាលណោះ វិមោក្ខ ដោយអត្ថថារួចស្រឡះ តាំងឡើងក្នុងកាលណោះ វិជ្ជា ដោយអត្ថថាត្រាស់ដឹង តាំងឡើងក្នុងកាលណោះ វិមុត្តិ ដោយអត្ថថាលះបង់ស្រឡះ តាំងឡើងក្នុងកាលណោះ ខយញ្ញាណ (ញាណក្នុងការអស់កិលេស) ដោយអត្ថថាផ្តាច់ផ្តិល តាំងឡើងក្នុងកាលណោះ

ឆន្ទោ មូលដ្ឋេន តថា សមុទាគតោ មនសិការោ សមុដ្ឋានដ្ឋេន តថា សមុទាគតោ ផស្សោ សមោធា-នដ្ឋេន តថា សមុទាគតោ វេទនា សមោសរណដ្ឋេន តថា សមុទាគតា សមាធិ បមុខដ្ឋេន តថា សមុទាគ-តោ សតិ អាធិបតេយ្យដ្ឋេន តថា សមុទាគតា បញ្ញា តទុត្តរដ្ឋេន តថា សមុទាគតា វិមុត្តិ សារដ្ឋេន តថា សមុទាគតា អមតោគធំ និព្វានំ បរិយោសានដ្ឋេន តថា សមុទាគតំ វុដ្ឋហិត្វា បច្ចវេក្ខតិ ឥមេ ធម្មា តថា សមុទាគតា ។

[១៨៧] សោតាបត្តិផលក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ តថា សមុទាគតា អភិនិរោបនដ្ឋេន សម្មា-សង្កប្បោ តថា សមុទាគតោ ។ បេ ។ បដិប្បស្ស-ទ្ធដ្ឋេន អនុប្បាទេ ញាណំ តថា សមុទាគតំ ឆន្ទោ មូលដ្ឋេន តថា សមុទាគតោ មនសិការោ សមុដ្ឋាន-ដ្ឋេន តថា សមុទាគតោ ផស្សោ សមោធានដ្ឋេន តថា សមុទាគតោ វេទនា សមោសរណដ្ឋេន តថា សមុទាគតា សមាធិ បមុខដ្ឋេន តថា សមុទាគតោ

ឆន្ទៈ ដោយអត្ថថាជាឫសគល់ តាំងឡើងក្នុងកាលណោះ មនសិការៈ ដោយអត្ថថាផ្ដួចផ្ដើម តាំងឡើងក្នុងកាលណោះ ផស្សៈ ដោយអត្ថថាប្រជុំចុះ តាំងឡើងក្នុងកាលណោះ វេទនា ដោយអត្ថថាប្រជុំព្រម តាំងឡើងក្នុងកាលណោះ សមាធិ ដោយអត្ថថាជាប្រធាន តាំងឡើងក្នុងកាលណោះ សតិ ដោយអត្ថថាជាធំ តាំងឡើងក្នុងកាលណោះ បញ្ញា ដោយអត្ថថាប្រសើរជាងនោះ តាំងឡើងក្នុងកាលណោះ វិមុត្តិ ដោយអត្ថថាជាខ្លឹម តាំងឡើងក្នុងកាលណោះ និព្វាន ឈ្មោះអមតៈ (ជាទីពឹងរបស់សត្វ) ដោយអត្ថថាចប់ស្រេច (នៃកិច្ចក្នុងសាសនា) តាំងឡើងក្នុងកាលណោះ ព្រះអរិយបុគ្គល លុះចេញ (ចាកអារម្មណ៍ទាំងឡាយ) ហើយរមែងពិចារណា (នូវអារម្មណ៍ទាំងនោះ) នេះធម៌ទាំងឡាយ តាំងឡើងក្នុងកាលណោះ ។

[១៥៧] ក្នុងខណៈនៃសោតាបត្តិផល សម្មាទិដ្ឋិ ដោយអត្ថថាឃើញ តាំងឡើងក្នុងកាលណោះ សម្មាសង្កប្បៈ ដោយអត្ថថាលើកចិត្ត (កាន់អារម្មណ៍) តាំងឡើងក្នុងកាលណោះ ។ បេ ។ ញាណ ក្នុងការមិនកើតឡើង ដោយអត្ថថាស្ងប់រម្ងាប់ តាំងឡើងក្នុងកាលណោះ ឆន្ទៈ ដោយអត្ថថាជាឫសគល់ តាំងឡើងក្នុងកាលណោះ មនសិការៈ ដោយអត្ថថាផ្ដួចផ្ដើម តាំងឡើងក្នុងកាលណោះ ផស្សៈ ដោយអត្ថថាប្រជុំចុះ តាំងឡើងក្នុងកាលណោះ វេទនា ដោយអត្ថថាប្រជុំព្រម តាំងឡើងក្នុងកាលណោះ សមាធិ ដោយអត្ថថាជាប្រធាន តាំងឡើងក្នុងកាលណោះ

សតិ អាធិបតេយ្យដ្ឋេន តជា សមុចាគតា បញ្ញា តទុត្តរដ្ឋេន តជា សមុចាគតា វិមុត្តិ សារដ្ឋេន តជា សមុចាគតា អមតោគធំ និព្វានំ បរិយោសានដ្ឋេន តជា សមុចាគតំ វុដ្ឋហិត្វា បច្ចវេក្ខតិ ឥមេ ធម្មា តជា សមុចាគតា ។

[១៩៨] សកទាគាមិមគ្គក្ខណេ ។ បេ ។ សកទាគាមិផលក្ខណេ ។ បេ ។ អនាគាមិមគ្គ-ក្ខណេ ។ បេ ។ អនាគាមិផលក្ខណេ ។ បេ ។ អរហត្តមគ្គក្ខណេ ទស្សនដ្ឋេន សម្មាទិដ្ឋិ តជា សមុ-ចាគតា ។ បេ ។ សមុច្ឆេទដ្ឋេន ខយេ ញាណំ តជា សមុចាគតំ ឆន្ទោ មូលដ្ឋេន តជា សមុចាគតោ ។ បេ ។ អមតោគធំ និព្វានំ បរិយោសានដ្ឋេន តជា សមុចាគតំ វុដ្ឋហិត្វា បច្ចវេក្ខតិ ឥមេ ធម្មា តជា សមុចាគតា ។

[១៩៩] អរហត្តផលក្ខណេ ទស្សនដ្ឋេន សម្មា-ទិដ្ឋិ តជា សមុចាគតា ។ បេ ។ បដិប្បស្សទ្ធដ្ឋេន អនុប្បាទេ ញាណំ តជា សមុចាគតំ ឆន្ទោ មូលដ្ឋេន តជា សមុចាគតោ ។ បេ ។

សតិ ដោយអត្ថថាជាធំ តាំងឡើងក្នុងកាលណោះ បញ្ញា ដោយអត្ថថាប្រសើរជាងនោះ តាំងឡើងក្នុងកាលណោះ វិមុត្តិ ដោយអត្ថថាជាខ្លឹម តាំងឡើងក្នុងកាលណោះ និព្វានឈ្មោះអមតៈ (ជាទីពឹងរបស់សត្វ) ដោយអត្ថថាចប់ស្រេច (នៃកិច្ចក្នុងសាសនា) តាំងឡើងក្នុងកាលណោះ ព្រះអរិយបុគ្គល លុះចេញ (ចាកអារម្មណ៍ទាំងឡាយ) ហើយ រមែងពិចារណា (នូវអារម្មណ៍ទាំងនោះ) នេះធម៌ទាំងឡាយតាំងឡើងក្នុងកាលណោះ ។

[១៥៨] ក្នុងខណៈនៃសកទាគាមិមគ្គ ។ បេ ។ ក្នុងខណៈនៃសកទាគាមិផល ។ បេ ។ ក្នុងខណៈនៃអនាគាមិមគ្គ ។ បេ ។ ក្នុងខណៈនៃអនាគាមិផល ។ បេ ។ ក្នុងខណៈនៃអរហត្តមគ្គ សម្មាទិដ្ឋិ ដោយអត្ថថាឃើញ តាំងឡើងក្នុងកាលណោះ ។ បេ ។ ខយញ្ញាណ ដោយអត្ថថាផ្តាច់ផ្តិល តាំងឡើងក្នុងកាលណោះ ឆន្ទៈ ដោយអត្ថថាជាឫសគល់ តាំងឡើងក្នុងកាលណោះ ។ បេ ។ និព្វានឈ្មោះអមតៈ (ជាទីពឹងរបស់សត្វ) ដោយអត្ថថាចប់ស្រេច (នៃកិច្ចក្នុងសាសនា) តាំងឡើងក្នុងកាលណោះ ព្រះអរិយបុគ្គលលុះចេញ (ចាកអារម្មណ៍ទាំងឡាយ) ហើយ រមែងពិចារណា (នូវអារម្មណ៍ទាំងនោះ) នេះធម៌ទាំងឡាយតាំងឡើងក្នុងកាលណោះ ។

[១៥៩] ក្នុងខណៈនៃអរហត្តផល សម្មាទិដ្ឋិ ដោយអត្ថថាឃើញ តាំងឡើង ក្នុងកាលណោះ ។ បេ ។ ញាណ ក្នុងការមិនកើតឡើង ដោយអត្ថថាស្ងប់រម្ងាប់ តាំងឡើង ក្នុងកាលណោះ ឆន្ទៈ ដោយអត្ថថាជាឫសគល់ តាំងឡើង ក្នុងកាលណោះ ។ បេ ។

អមតោគធំ និព្វានំ បរិយោសានដ្ឋេន តថា សមុទាគតំ វុដ្ឋហិត្វា បច្ចវេក្ខតិ ឥមេ ធម្មា តថា សមុទាគតា តំ ញាតដ្ឋេន ញាណំ បជានដ្ឋេន បញ្ញា តេន វុច្ចតិ តថា សមុទាគតេ ធម្មេ បស្សនេ បញ្ញា បច្ចវេក្ខណេ ញាណំ ។

[១៦០] កថំ អជ្ឈត្តវវត្ថានេ បញ្ញា វត្ថុនានត្តេ ញាណំ ។

កថំ អជ្ឈត្តធម្មេ វវត្ថេតិ ។ ចក្ខុំ អជ្ឈត្តំ វវត្ថេតិ សោតំ អជ្ឈត្តំ វវត្ថេតិ ឃានំ អជ្ឈត្តំ វវត្ថេតិ ជិវ្ហំ អជ្ឈត្តំ វវត្ថេតិ កាយំ អជ្ឈត្តំ វវត្ថេតិ មនំ អជ្ឈត្តំ វវត្ថេតិ ។

[១៦១] កថំ ចក្ខុំ អជ្ឈត្តំ វវត្ថេតិ ។ ចក្ខុំ អវិជ្ជាសម្ភូតន្តិ វវត្ថេតិ ចក្ខុំ តណ្ហាសម្ភូតន្តិ វវត្ថេតិ ចក្ខុំ កម្មសម្ភូតន្តិ វវត្ថេតិ ចក្ខុំ អាហារសម្ភូតន្តិ វវត្ថេតិ ចក្ខុំ ចតុន្នំ មហាភូតានំ ឧបាទាយាតិ វវត្ថេតិ ចក្ខុំ ឧប្បន្នន្តិ វវត្ថេតិ ចក្ខុំ សមុទាគតន្តិ វវត្ថេតិ

និព្វានឈ្មោះអមតៈ (ជាទីពឹងរបស់សត្វ) ដោយអត្ថថាចប់ស្រេច (នៃកិច្ចក្នុងសាសនា) តាំងឡើងក្នុងកាលណោះ ព្រះអរិយបុគ្គលលុះចេញ (ចាកអារម្មណ៍ទាំងឡាយ)ហើយរមែងពិចារណា (នូវអារម្មណ៍ទាំងនោះ) នេះធម៌ទាំងឡាយ តាំងឡើងក្នុងកាលណោះ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹង នូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការពិចារណាឃើញនូវពួកធម៌តាំងឡើងក្នុងកាលនោះ ឈ្មោះថាបច្ចវេក្ខណាញ្ញាណ ។

[១៦០] បញ្ញាក្នុងការកំណត់នូវធម៌ខាងក្នុង ឈ្មោះថាវត្ថុនានត្តញ្ញាណ តើដូចម្តេច ។

បុគ្គលកំណត់នូវធម៌ខាងក្នុង តើដូចម្តេច ។ បុគ្គលកំណត់នូវចក្ខុខាងក្នុង កំណត់នូវសោតៈខាងក្នុង កំណត់នូវឃានៈខាងក្នុង កំណត់នូវជិវ្ហាខាងក្នុង កំណត់នូវកាយខាងក្នុង កំណត់នូវចិត្តខាងក្នុង ។

[១៦១] បុគ្គលកំណត់នូវចក្ខុខាងក្នុង តើដូចម្តេច ។ បុគ្គលកំណត់ថា ចក្ខុកើតហើយ ព្រោះអវិជ្ជា កំណត់ថា ចក្ខុកើតហើយ ព្រោះតណ្ហា កំណត់ថា ចក្ខុកើតហើយ ព្រោះកម្ម កំណត់ថា ចក្ខុកើតហើយ ព្រោះអាហារ កំណត់ថា ចក្ខុអាស្រ័យនូវមហាភូតរូប ៤ កំណត់ថា ចក្ខុកើតឡើងហើយ កំណត់ថា ចក្ខុតាំងឡើងហើយ

ចក្ខុំ អហុត្វា សម្ភូតំ ហុត្វា ន ភវិស្សតីតិ បស្សតិ ចក្ខុំ អន្តវន្តតោ បស្សតិ ចក្ខុំ អទ្ធុវំ អសស្សតំ វិបរិណាមធម្មន្តិ បស្សតិ ចក្ខុំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មន្តិ បស្សតិ ចក្ខុំ អនិច្ចតោ បស្សតិ នោ និច្ចតោ ទុក្ខតោ បស្សតិ នោ សុខតោ អនត្តតោ បស្សតិ នោ អត្តតោ និព្វិន្ទតិ នោ នន្ទតិ វិរជ្ជតិ នោ រជ្ជតិ និរោធេតិ នោ សមុទេតិ បដិនិស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ បស្សន្តោ និច្ចសញ្ញំ បជហតិ ទុក្ខតោ បស្សន្តោ សុខសញ្ញំ បជហតិ អនត្តតោ បស្សន្តោ អត្តសញ្ញំ បជហតិ និព្វិន្ទន្តោ នន្ទឹ[១] បជហតិ វិរជ្ជន្តោ រាគំ បជហតិ និរោធេន្តោ សមុទយំ បជហតិ បដិនិស្សជ្ជន្តោ អាទានំ បជហតិ ឯវំ ចក្ខុំ អជ្ឈត្តំ បស្សតិ ។

[១៦២] កថំ សោតំ អជ្ឈត្តំ បស្សតិ ។ សោតំ អវិជ្ជាសម្ភូតន្តិ បស្សតិ ។ បេ ។

---

១ ឱ. នន្ទំ ។

កំណត់ថា ចក្ខុដែលមិនទាន់មាន មានហើយ ដែលមានហើយបែរជានឹងមិនមានវិញ កំណត់នូវចក្ខុ ថាមានទីបំផុត កំណត់ថា ចក្ខុមិនមាំមួនមិនឋិតថេរ មានសេចក្តីប្រែប្រួលជាធម្មតា កំណត់ថា ចក្ខុមិនទៀងត្រូវបច្ច័យតាក់តែង កើតឡើងហើយព្រោះអាស្រ័យហេតុ មានការអស់ជាធម្មតា មានការសូន្យជាធម្មតា មានការប្រាសនិរាសជាធម្មតា មានការរលត់ជាធម្មតា កំណត់នូវចក្ខុថា មិនទៀង មិនកំណត់ថាទៀង កំណត់ថាជាទុក្ខ មិនកំណត់ថាជាសុខ កំណត់ថាជាអនត្តា មិនកំណត់ថាជាអត្តា រមែងនឿយណាយ មិនត្រេកអរ ធុញទ្រាន់ មិនរីករាយ រំលត់ មិនឲ្យកើតឡើង រលាស់ចោល មិនកាន់យក កាលកំណត់ថា មិនទៀង រមែងលះបង់នូវនិច្ចសញ្ញា កាលកំណត់ថាជាទុក្ខ រមែងលះបង់នូវសុខសញ្ញា កាលកំណត់ថាជាអនត្តា រមែងលះបង់នូវអត្តសញ្ញា កាលនឿយណាយ រមែងលះបង់នូវសេចក្តីរីករាយ កាលធុញទ្រាន់ រមែងលះបង់នូវរាគៈ កាលរំលត់ រមែងលះបង់នូវការកើតឡើង កាលរលាស់ចោល រមែងលះបង់នូវការប្រកាន់មាំ បុគ្គលកំណត់នូវចក្ខុខាងក្នុងដោយប្រការយ៉ាងនេះឯង ។

[១៦២] បុគ្គលកំណត់ នូវសោតៈខាងក្នុង តើដូចម្តេច ។ បុគ្គលកំណត់ថា សោតៈកើតហើយ ព្រោះអវិជ្ជា ។ បេ ។

ឯវំ សោតំ អជ្ឈត្តំ វវត្ថេតិ ។

កថំ ឃានំ អជ្ឈត្តំ វវត្ថេតិ ។ ឃានំ អវិជ្ជាស-
ម្ភូតន្តិ វវត្ថេតិ ។ បេ ។ ឯវំ ឃានំ អជ្ឈត្តំ វវត្ថេតិ ។

កថំ ជិវ្ហំ អជ្ឈត្តំ វវត្ថេតិ ។ ជិវ្ហា អវិជ្ជាសម្ភូ-
តាតិ វវត្ថេតិ ជិវ្ហា តណ្ហាសម្ភូតាតិ វវត្ថេតិ ជិវ្ហា
កម្មសម្ភូតាតិ វវត្ថេតិ ជិវ្ហា អាហារសម្ភូតាតិ វវត្ថេតិ
ជិវ្ហា ចតុន្នំ មហាភូតានំ ឧបាទាយាតិ វវត្ថេតិ
ជិវ្ហា ឧប្បន្នាតិ វវត្ថេតិ ជិវ្ហា សមុទាគតាតិ វវត្ថេតិ
ជិវ្ហា អហុត្វា សម្ភូតា ហុត្វា ន ភវិស្សតីតិ វវត្ថេតិ
ជិវ្ហំ អន្តវន្តតោ វវត្ថេតិ ជិវ្ហា អទ្ធុវា អសស្សតា
វិបរិណាមធម្មាតិ វវត្ថេតិ ជិវ្ហា អនិច្ចា សង្ខតា បដិ-
ច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធ-
ធម្មាតិ វវត្ថេតិ ជិវ្ហំ អនិច្ចតោ វវត្ថេតិ នោ និច្ចតោ
។ បេ ។ បដិនិស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ
វវត្ថេន្តោ និច្ចសញ្ញំ បជហតិ ។ បេ ។ បដិនិស្សជ្ជ-
ន្តោ អាទានំ បជហតិ ឯវំ ជិវ្ហំ អជ្ឈត្តំ វវត្ថេតិ ។

បុគ្គលកំណត់នូវសោតៈខាងក្នុង ដោយប្រការយ៉ាងនេះឯង ។

បុគ្គលកំណត់នូវឃានៈខាងក្នុង តើដូចម្តេច ។ បុគ្គលកំណត់ថា ឃានៈកើតហើយ ព្រោះអវិជ្ជា ។ បេ ។ បុគ្គលកំណត់នូវឃានៈខាងក្នុង ដោយប្រការយ៉ាងនេះឯង ។

បុគ្គលកំណត់នូវជិវ្ហាខាងក្នុង តើដូចម្តេច ។ បុគ្គលកំណត់ថា ជិវ្ហាកើតហើយ ព្រោះអវិជ្ជា កំណត់ថា ជិវ្ហាកើតហើយព្រោះតណ្ហា កំណត់ថា ជិវ្ហាកើតហើយព្រោះកម្ម កំណត់ថា ជិវ្ហាកើតហើយ ព្រោះអាហារ កំណត់ថា ជិវ្ហាអាស្រ័យនូវមហាភូតរូប ៤ កំណត់ថា ជិវ្ហាកើតឡើងហើយ កំណត់ថា ជិវ្ហាតាំងឡើងហើយ កំណត់ថា ជិវ្ហាដែលមិនទាន់មាន មានហើយ ដែលមានហើយ បែរជានឹងមិនមានវិញ កំណត់នូវជិវ្ហា ថាមានទីបំផុត កំណត់ថា ជិវ្ហាមិនមាំមួន មិនឋិតថេរ មានសេចក្តីប្រែប្រួលជាធម្មតា កំណត់ថា ជិវ្ហាមិនទៀង ត្រូវបច្ច័យតាក់តែង កើតឡើងព្រោះអាស្រ័យហេតុ មានការអស់ជាធម្មតា មានការសូន្យជាធម្មតា មានសេចក្តីវិនាសជាធម្មតា មានការរលត់ជាធម្មតា កំណត់នូវជិវ្ហាថាមិនទៀង មិនកំណត់ថាទៀង ។ បេ ។ រមែងរលាស់ចោល មិនកាន់យក កាលកំណត់ថាមិនទៀង រមែងលះបង់នូវនិច្ចសញ្ញា ។ បេ ។ កាលរលាស់ចោល រមែងលះបង់នូវសេចក្តីប្រកាន់មាំ បុគ្គលកំណត់នូវជិវ្ហាខាងក្នុង ដោយប្រការយ៉ាងនេះឯង ។

កថំ កាយំ អជ្ឈត្តំ វវត្ថេតិ ។ កាយោ អវិជ្ជាសម្ភូតោតិ វវត្ថេតិ កាយោ តណ្ហាសម្ភូតោតិ វវត្ថេតិ កាយោ កម្មសម្ភូតោតិ វវត្ថេតិ កាយោ អាហារសម្ភូតោតិ វវត្ថេតិ កាយោ ចតុន្នំ មហាភូតានំ ឧបាទាយាតិ វវត្ថេតិ កាយោ ឧប្បន្នោតិ វវត្ថេតិ កាយោ សមុទាគតោតិ វវត្ថេតិ កាយោ អហុត្វា សម្ភូតោ ហុត្វា ន ភវិស្សតីតិ វវត្ថេតិ កាយំ អន្តវន្តតោ វវត្ថេតិ កាយោ អទ្ធុវោ អសស្សតោ វិបរិណាមធម្មោតិ វវត្ថេតិ កាយោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ ខយធម្មោ វយធម្មោ វិរាគធម្មោ និរោធធម្មោតិ វវត្ថេតិ កាយំ អនិច្ចតោ វវត្ថេតិ នោ និច្ចតោ ទុក្ខតោ វវត្ថេតិ នោ សុខតោ ។ បេ ។ បដិនិស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ វវត្ថេន្តោ និច្ចសញ្ញំ បជហតិ ទុក្ខតោ វវត្ថេន្តោ សុខសញ្ញំ បជហតិ ។ បេ ។ បដិនិស្សជ្ជន្តោ អាទានំ បជហតិ ឯវំ កាយំ អជ្ឈត្តំ វវត្ថេតិ ។

កថំ មនំ អជ្ឈត្តំ វវត្ថេតិ ។ មនោ អវិជ្ជាសម្ភូតោតិ វវត្ថេតិ មនោ តណ្ហាសម្ភូតោតិ វវត្ថេតិ

បុគ្គលកំណត់នូវកាយខាងក្នុង តើដូចម្តេច ។ បុគ្គលកំណត់ថា កាយកើតហើយព្រោះអវិជ្ជា កំណត់ថា កាយកើតហើយ ព្រោះតណ្ហា កំណត់ថា កាយកើតហើយព្រោះកម្ម កំណត់ថា កាយកើតហើយព្រោះអាហារ កំណត់ថា កាយអាស្រ័យនូវមហាភូតរូប ៤ កំណត់ថា កាយកើតឡើងហើយ កំណត់ថា កាយតាំងឡើងហើយ កំណត់ថា កាយដែលមិនទាន់មាន មានហើយ ដែលមានហើយ បែរជានឹងមិនមានវិញ កំណត់នូវកាយថា មានទីបំផុត កំណត់ថា កាយមិនមាំមួន មិនឋិតថេរ មានសេចក្តីប្រែប្រួលជាធម្មតា កំណត់ថា កាយមិនទៀង ត្រូវបច្ច័យតាក់តែង កើតឡើងហើយ ព្រោះអាស្រ័យហេតុ មានការអស់ជាធម្មតា មានការសូន្យជាធម្មតា មានការរសាយជាធម្មតា មានការរលត់ជាធម្មតា កំណត់នូវកាយថា មិនទៀង មិនកំណត់ថា ទៀង កំណត់ថាជាទុក្ខ មិនកំណត់ថាជាសុខ ។ បេ ។ រមែងរលាស់ចោល មិនកាន់យក កាលកំណត់ថាមិនទៀង រមែងលះបង់នូវនិច្ចសញ្ញា កាលកំណត់ថាជាទុក្ខ រមែងលះបង់នូវសុខសញ្ញា ។ បេ ។ កាលរលាស់ចោល រមែងលះបង់នូវសេចក្តីប្រកាន់មាំ បុគ្គលកំណត់នូវកាយខាងក្នុងដោយប្រការយ៉ាងនេះឯង ។

បុគ្គលកំណត់ នូវចិត្តខាងក្នុង តើដូចម្តេច ។ បុគ្គលកំណត់ថា ចិត្តកើតហើយ ព្រោះអវិជ្ជា កំណត់ថា ចិត្តកើតហើយ ព្រោះតណ្ហា

១៧៣



មនោ កម្មសម្ភូតោតិ វវត្ថេតិ មនោ អាហារសម្ភូតោតិ វវត្ថេតិ មនោ ឧប្បន្នោតិ វវត្ថេតិ មនោ សមុដ្ឋាន-តោតិ វវត្ថេតិ មនោ អហុត្វា សម្ភូតោ ហុត្វា ន ភវិស្សតីតិ វវត្ថេតិ មនំ អន្តវន្តតោ វវត្ថេតិ មនោ អទ្ធុវោ អសស្សតោ វិបរិណាមធម្មោតិ វវត្ថេតិ មនោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ ខយធម្មោ វយ-ធម្មោ វិរាគធម្មោ និរោធធម្មោតិ វវត្ថេតិ មនំ អនិ-ច្ចតោ វវត្ថេតិ នោ និច្ចតោ ទុក្ខតោ វវត្ថេតិ នោ សុខតោ អនត្តតោ វវត្ថេតិ នោ អត្តតោ និព្វិន្ទតិ នោ នន្ទតិ វិរជ្ជតិ នោ រជ្ជតិ និរោធេតិ នោ សមុ-ទេតិ បដិនិស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ វវត្ថេន្តោ និច្ចសញ្ញំ បជហតិ ទុក្ខតោ វវត្ថេន្តោ សុខសញ្ញំ បជហតិ អនត្តតោ វវត្ថេន្តោ អត្តសញ្ញំ បជហតិ និព្វិន្ទន្តោ នន្ទឹ បជហតិ វិរជ្ជន្តោ រាគំ បជហតិ និរោធេន្តោ សមុទយំ បជហតិ បដិនិស្សជ្ជន្តោ អាទានំ បជហតិ ឯវំ មនំ អជ្ឈត្តំ វវត្ថេតិ

កំណត់ថា ចិត្តកើតហើយ ព្រោះកម្ម កំណត់ថា ចិត្តកើតហើយ ព្រោះអាហារ កំណត់ថា ចិត្តកើតឡើងហើយ កំណត់ថា ចិត្តតាំងឡើងហើយ កំណត់ថា ចិត្តដែលមិនទាន់មាន មានហើយ ដែលមានហើយ បែរជានឹងមិនមានវិញ កំណត់នូវចិត្តថា មានទីបំផុត កំណត់ថា ចិត្តមិនមាំមួន មិនឋិតថេរ មានសេចក្តីប្រែប្រួលជាធម្មតា កំណត់ថា ចិត្តមិនទៀង ត្រូវបច្ច័យតាក់តែង កើតឡើងហើយ ព្រោះអាស្រ័យហេតុ មានការអស់ជាធម្មតា មានការសូន្យជាធម្មតា មានការរសាយជាធម្មតា មានការរលត់ជាធម្មតា កំណត់នូវចិត្តថា មិនទៀង មិនកំណត់ថាទៀង កំណត់ថាជាទុក្ខ មិនកំណត់ថាជាសុខ កំណត់ថាជាអនត្តា មិនកំណត់ថាជាអត្តា រមែងនឿយណាយ មិនត្រេកអរ ធុញទ្រាន់ មិនរីករាយ រំលត់ មិនឲ្យកើតឡើង រលាស់ចោល មិនកាន់យក កាលកំណត់ថាមិនទៀង រមែងលះបង់នូវនិច្ចសញ្ញា កាលកំណត់ថាជាទុក្ខ រមែងលះបង់នូវសុខសញ្ញា កាលកំណត់ថាជាអនត្តា រមែងលះបង់នូវអត្តសញ្ញា កាលនឿយណាយ រមែងលះបង់នូវសេចក្តីរីករាយ កាលធុញទ្រាន់ រមែងលះបង់នូវរាគៈ កាលរំលត់ រមែងលះបង់នូវការកើតឡើង កាលរលាស់ចោល រមែងលះបង់នូវសេចក្តីប្រកាន់មាំ បុគ្គលកំណត់នូវចិត្តខាងក្នុង ដោយប្រការយ៉ាងនេះឯង

ឯវំ អជ្ឈត្តធម្មេ វវត្ថេតិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ អជ្ឈត្តវវត្ថានេ បញ្ញា វត្ថុនានត្តេ ញាណំ ។

[១៦៣] កថំ ពហិទ្ធាវវត្ថានេ បញ្ញា គោចរនានត្តេ ញាណំ ។ កថំ ពហិទ្ធា ធម្មេ វវត្ថេតិ ។ រូបេ ពហិទ្ធា វវត្ថេតិ សទ្ទេ ពហិទ្ធា វវត្ថេតិ គន្ធេ ពហិទ្ធា វវត្ថេតិ រសេ ពហិទ្ធា វវត្ថេតិ ផោដ្ឋព្វេ ពហិទ្ធា វវត្ថេតិ ធម្មេ ពហិទ្ធា វវត្ថេតិ ។

កថំ រូបេ ពហិទ្ធា វវត្ថេតិ ។ រូបា អវិជ្ជាសម្ភូតាតិ វវត្ថេតិ រូបា តណ្ហាសម្ភូតាតិ វវត្ថេតិ រូបា កម្មសម្ភូតាតិ វវត្ថេតិ រូបា អាហារសម្ភូតាតិ វវត្ថេតិ រូបា ចតុន្នំ មហាភូតានំ ឧបាទាយាតិ វវត្ថេតិ រូបា ឧប្បន្នាតិ វវត្ថេតិ រូបា សមុទាគតាតិ វវត្ថេតិ រូបា អហុត្វា សម្ភូតា ហុត្វា ន ភវិស្សន្តីតិ វវត្ថេតិ រូបេ អន្តវន្តតោ វវត្ថេតិ រូបា អទ្ធុវា អសស្សតា វិបរិណាមធម្មាតិ វវត្ថេតិ រូបា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា

បុគ្គលកំណត់នូវធម៌ខាងក្នុង ដោយប្រការយ៉ាងនេះឯង ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញា ក្នុងការកំណត់នូវធម៌ខាងក្នុង ឈ្មោះថាវត្ថុនានត្តញ្ញាណ ។

[១៦៣] បញ្ញាក្នុងការកំណត់នូវធម៌ខាងក្រៅ ឈ្មោះថាគោចរ-នានត្តញ្ញាណ តើដូចម្តេច ។ បុគ្គលកំណត់នូវធម៌ទាំងឡាយខាងក្រៅ តើដូចម្តេច ។ បុគ្គលកំណត់នូវរូបខាងក្រៅ កំណត់នូវសំឡេងខាងក្រៅ កំណត់នូវក្លិនខាងក្រៅ កំណត់នូវរសខាងក្រៅ កំណត់នូវផ្សព្វខាងក្រៅ កំណត់នូវធម៌ខាងក្រៅ ។

បុគ្គលកំណត់នូវរូបខាងក្រៅ តើដូចម្តេច ។ បុគ្គលកំណត់ថា រូបកើតហើយព្រោះអវិជ្ជា កំណត់ថា រូបកើតហើយព្រោះតណ្ហា កំណត់ថារូបកើតហើយព្រោះកម្ម កំណត់ថា រូបកើតហើយព្រោះអាហារ កំ-ណត់ថា រូបអាស្រ័យនូវមហាភូតរូប ៤ កំណត់ថា រូបកើតឡើងហើយ កំណត់ថា រូបតាំងឡើងហើយ កំណត់ថា រូបដែលមិនទាន់មាន មានហើយ ដែលមានហើយ បែរជានឹងមិនមានវិញ កំណត់នូវរូបថាមានទីបំផុត កំណត់ថា រូបមិនមាំមួន មិនឋិតថេរ មានសេចក្តីប្រែប្រួលជាធម្មតា កំណត់ថា រូបមិនទៀង ត្រូវបច្ច័យតាក់តែង កើតឡើងហើយព្រោះអាស្រ័យហេតុ មានការអស់ជាធម្មតា មានការសូន្យជាធម្មតា

វិរាគធម្មា និរោធធម្មាតិ វវត្ថេតិ រូបេ អនិច្ចតោ វវត្ថេតិ នោ និច្ចតោ ទុក្ខតោ វវត្ថេតិ នោ សុខតោ អនត្តតោ វវត្ថេតិ នោ អត្តតោ និព្វិន្ទតិ នោ នន្ទតិ វិរជ្ជតិ នោ រជ្ជតិ និរោធេតិ នោ សមុទេតិ បដិនិ-ស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ វវត្ថេន្តោ និច្ចសញ្ញំ បជហតិ ទុក្ខតោ វវត្ថេន្តោ សុខសញ្ញំ បជហតិ អនត្តតោ វវត្ថេន្តោ អត្តសញ្ញំ បជហតិ និព្វិន្ទន្តោ នន្ទឹ បជហតិ វិរជ្ជន្តោ រាគំ បជហតិ និរោធេន្តោ សមុទយំ បជហតិ បដិនិស្សជ្ជន្តោ អាទានំ បជហតិ ឯវំ រូបេ ពហិទ្ធា វវត្ថេតិ ។

[១៦៤] កថំ សង្ខេ ពហិទ្ធា វវត្ថេតិ ។ សង្ខា អវិជ្ជា-សម្ភូតាតិ វវត្ថេតិ ។ បេ ។ សង្ខា ចតុន្នំ មហាភូតានំ ឧបាទាយាតិ វវត្ថេតិ សង្ខា ឧប្បន្នាតិ វវត្ថេតិ សង្ខា សមុបាគតាតិ វវត្ថេតិ សង្ខា អហុត្វា សម្ភូតា ហុត្វា ន ភវិស្សន្តីតិ វវត្ថេតិ សង្ខេ អន្តវន្តតោ វវត្ថេតិ សង្ខា អទ្ធុវា អសស្សតា វិបរិណាមធម្មាតិ វវត្ថេតិ សង្ខា អនិច្ចា

មានការរសាយជាធម្មតា មានការរលត់ជាធម្មតា កំណត់នូវរូប ថាមិនទៀង មិនកំណត់ថាទៀង កំណត់ថាជាទុក្ខ មិនកំណត់ថាជាសុខ កំណត់ថាជាអនត្តា មិនកំណត់ថាជាអត្តា រមែងនឿយណាយ មិនត្រេកអរ ធុញទ្រាន់ មិនរីករាយ រំលត់ មិនឲ្យកើតឡើង រលាស់ចោល មិនកាន់យក កាលកំណត់ថា មិនទៀង រមែងលះបង់នូវនិច្ចសញ្ញា កាលកំណត់ថាជាទុក្ខ រមែងលះបង់នូវសុខសញ្ញា កាលកំណត់ថាជាអនត្តា រមែងលះបង់នូវអត្តសញ្ញា កាលនឿយណាយ រមែងលះបង់នូវសេចក្តីរីករាយ កាលធុញទ្រាន់ រមែងលះបង់នូវរាគៈ កាលរំលត់ រមែងលះបង់នូវការកើតឡើង កាលរលាស់ចោល រមែងលះបង់នូវសេចក្តីប្រកាន់មាំ បុគ្គលកំណត់នូវរូបខាងក្រៅ ដោយប្រការយ៉ាងនេះឯង ។

[១៦៤] បុគ្គលកំណត់ នូវសំឡេងខាងក្រៅ តើដូចម្តេច ។ បុគ្គលកំណត់ថា សំឡេងកើតហើយ ព្រោះអវិជ្ជា ។ បេ ។ កំណត់ថា សំឡេងអាស្រ័យនូវមហាភូតរូប ៤ កំណត់ថា សំឡេងកើតឡើងហើយ កំណត់ថា សំឡេងតាំងឡើងហើយ កំណត់ថា សំឡេងដែលមិនទាន់មាន មានហើយ ដែលមានហើយ បែរជានឹងមិនមានវិញ កំណត់នូវសំឡេងថា មានទីបំផុត កំណត់ថា សំឡេងមិនមាំមួន មិនឋិតថេរ មានសេចក្តីប្រែប្រួលជាធម្មតា កំណត់ថា សំឡេងមិនទៀង

សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មាតិ វវត្ថេតិ សព្វេ អនិច្ចតោ វវត្ថេតិ ។ បេ ។ ឯវំ សព្វេ ពហិទ្ធា វវត្ថេតិ ។

កថំ គន្ធេ ពហិទ្ធា វវត្ថេតិ ។ គន្ធា អវិជ្ជា-សម្ភូតាតិ វវត្ថេតិ គន្ធា តណ្ហាសម្ភូតាតិ វវត្ថេតិ ។ បេ ។ ឯវំ គន្ធេ ពហិទ្ធា វវត្ថេតិ ។

កថំ រសេ ពហិទ្ធា វវត្ថេតិ ។ រសា អវិជ្ជា-សម្ភូតាតិ វវត្ថេតិ រសា តណ្ហាសម្ភូតាតិ វវត្ថេតិ ។ បេ ។ ឯវំ រសេ ពហិទ្ធា វវត្ថេតិ ។

កថំ ផោដ្ឋព្វេ ពហិទ្ធា វវត្ថេតិ ។ ផោដ្ឋព្វា អវិជ្ជាសម្ភូតាតិ វវត្ថេតិ ផោដ្ឋព្វា តណ្ហាសម្ភូតាតិ វវត្ថេតិ ផោដ្ឋព្វា កម្មសម្ភូតាតិ វវត្ថេតិ ផោដ្ឋព្វា អាហារសម្ភូតាតិ វវត្ថេតិ ផោដ្ឋព្វា ឧប្បន្នាតិ វវត្ថេតិ ផោដ្ឋព្វា សមុទាគតាតិ វវត្ថេតិ ។ បេ ។ ឯវំ ផោដ្ឋព្វេ ពហិទ្ធា វវត្ថេតិ ។

ត្រូវបច្ច័យតាក់តែង កើតឡើងហើយ ព្រោះអាស្រ័យហេតុ មានការអស់ជាធម្មតា មានការសូន្យជាធម្មតា មានការរសាយជាធម្មតា មានការរលត់ជាធម្មតា កំណត់នូវសំឡេងថា មិនទៀង ។ បេ ។ បុគ្គលកំណត់នូវសំឡេងខាងក្រៅ ដោយប្រការយ៉ាងនេះឯង ។

បុគ្គលកំណត់នូវក្លិនខាងក្រៅ តើដូចម្តេច ។ បុគ្គលកំណត់ថា ក្លិនកើតហើយ ព្រោះអវិជ្ជា កំណត់ថា ក្លិនកើតហើយ ព្រោះតណ្ហា ។ បេ ។ បុគ្គលកំណត់នូវក្លិនខាងក្រៅ ដោយប្រការយ៉ាងនេះឯង ។

បុគ្គល កំណត់នូវរសខាងក្រៅ តើដូចម្តេច ។ បុគ្គលកំណត់ថា រសកើតហើយ ព្រោះអវិជ្ជា កំណត់ថា រសកើតហើយ ព្រោះតណ្ហា ។ បេ ។ បុគ្គលកំណត់ នូវរសខាងក្រៅ ដោយប្រការយ៉ាងនេះឯង ។

បុគ្គលកំណត់ នូវផ្សព្វខាងក្រៅ តើដូចម្តេច ។ បុគ្គលកំណត់ថា ផ្សព្វកើតហើយ ព្រោះអវិជ្ជា កំណត់ថា ផ្សព្វកើតហើយ ព្រោះតណ្ហា កំណត់ថា ផ្សព្វកើតហើយ ព្រោះកម្ម កំណត់ថាផ្សព្វកើតហើយ ព្រោះអាហារ កំណត់ថា ផ្សព្វកើតឡើងហើយ កំណត់ថា ផ្សព្វតាំងឡើងហើយ ។ បេ ។ បុគ្គលកំណត់ នូវផ្សព្វខាងក្រៅ ដោយប្រការយ៉ាងនេះឯង ។

កថំ ធម្មេ ពហិទ្ធា វវត្ថេតិ ។ ធម្មា អវិជ្ជាសម្ភូតាតិ វវត្ថេតិ ធម្មា តណ្ហាសម្ភូតាតិ វវត្ថេតិ ធម្មា កម្មសម្ភូតាតិ វវត្ថេតិ ធម្មា អាហារសម្ភូតាតិ វវត្ថេតិ ធម្មា ឧប្បន្នាតិ វវត្ថេតិ ធម្មា សមុទាគតាតិ វវត្ថេតិ ធម្មា អហុត្វា សម្ភូតា ហុត្វា ន ភវិស្សន្តីតិ វវត្ថេតិ ធម្មេ អន្តវន្តតោ វវត្ថេតិ ធម្មា អទ្ធុវា អសស្សតា វិបរិណាមធម្មាតិ វវត្ថេតិ ធម្មា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មាតិ វវត្ថេតិ ធម្មេ អនិច្ចតោ វវត្ថេតិ នោ និច្ចតោ ទុក្ខតោ វវត្ថេតិ នោ សុខតោ អនត្តតោ វវត្ថេតិ នោ អត្តតោ និព្វិន្ទតិ នោ នន្ទតិ វិរជ្ជតិ នោ រជ្ជតិ និរោធេតិ នោ សមុទេតិ បដិនិស្សជ្ជតិ នោ អាទិយតិ អនិច្ចតោ វវត្ថេន្តោ និច្ចសញ្ញំ បជហតិ ទុក្ខតោ វវត្ថេន្តោ សុខសញ្ញំ បជហតិ អនត្តតោ វវត្ថេន្តោ អត្តសញ្ញំ បជហតិ និព្វិន្ទន្តោ នន្ទឹ បជហតិ វិរជ្ជន្តោ រាគំ បជហតិ

*បុគ្គលកំណត់ នូវធម៌[១] ខាងក្រៅ តើដូចម្ដេច ។ បុគ្គលកំណត់ថា ធម៌កើតហើយ ព្រោះអវិជ្ជា កំណត់ថា ធម៌កើតហើយ ព្រោះតណ្ហា កំណត់ថា ធម៌កើតហើយព្រោះកម្ម កំណត់ថា ធម៌កើតហើយព្រោះអាហារ កំណត់ថា ធម៌កើតឡើងហើយ កំណត់ថា ធម៌តាំងឡើងហើយ កំណត់ថា ធម៌ដែលមិនទាន់មាន មានហើយ ដែលមានហើយ បែរជានឹងមិនមានវិញ កំណត់នូវធម៌ថា មានទីបំផុត កំណត់ថា ធម៌មិនមាំមួន មិនឋិតថេរ មានសេចក្ដីប្រែប្រួលជាធម្មតា កំណត់ថា ធម៌មិនទៀង ត្រូវបច្ច័យតាក់តែង កើតឡើងហើយ ព្រោះអាស្រ័យហេតុ មានការអស់ជាធម្មតា មានការសូន្យជាធម្មតា មានការរសាយជាធម្មតា មានការរលត់ជាធម្មតា កំណត់នូវធម៌ថា មិនទៀង មិនកំណត់ថាទៀង កំណត់ថាជាទុក្ខ មិនកំណត់ថាជាសុខ កំណត់ថាជាអនត្តា មិនកំណត់ថាជាអត្តា រមែងនឿយណាយ មិនត្រេកអរ ធុញទ្រាន់ មិនរីករាយ រំលត់ មិនឲ្យកើតឡើង រមែងរលាស់ចោល មិនកាន់យក កាលកំណត់ ថាមិនទៀង រមែងលះបង់នូវនិច្ចសញ្ញា កាលកំណត់ថាជាទុក្ខ រមែងលះបង់នូវសុខសញ្ញា កាលកំណត់ថាជាអនត្តា រមែងលះបង់នូវអត្តសញ្ញា កាលនឿយណាយ រមែងលះបង់នូវសេចក្ដីរីករាយ កាលធុញទ្រាន់ រមែងលះបង់នូវរាគៈ កាលរំលត់*

១ ពាក្យថា ធម៌ ក្នុងទីនេះ បានដល់អរូបក្ខន្ធ ៣ គឺវេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ ។ អដ្ឋកថា ។

និរោធេន្តោ សមុទយំ បជហតិ បដិនិស្សជ្ជន្តោ អាទានំ បជហតិ ឯវំ ធម្មេ ពហិទ្ធា វវត្ថេតិ តំ-ញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ពហិទ្ធាវវត្ថានេ បញ្ញា គោចរនានត្តេ ញាណំ ។

[១៦៤] កថំ ចរិយាវវត្ថានេ បញ្ញា ចរិយានា-នត្តេ ញាណំ ។ ចរិយាតិ តិស្សោ ចរិយាយោ វិញ្ញាណចរិយា អញ្ញាណចរិយា ញាណចរិយា ។

កតមា វិញ្ញាណចរិយា ។ រូបេសុ ទស្សនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា រូបេសុ ទស្សនត្ថោ ចក្ខុវិញ្ញាណំ វិញ្ញាណចរិយា រូបេសុ ទិដ្ឋត្តា អភិរោបនវិចាកមនោធាតុ[១] វិញ្ញាណចរិយា រូបេសុ អភិរោបិតត្តា[២] វិចាកមនោវិញ្ញាណធាតុ

១ ឱ. ម. អភិនិរោបនា ។ ២ ឱ. ម. អភិនិរោបិ ។

រមែងលះបង់នូវការកើតឡើង កាលរលាស់ចោល រមែងលះបង់នូវសេចក្តីប្រកាន់មាំ បុគ្គលកំណត់នូវធម៌ខាងក្រៅ ដោយប្រការយ៉ាងនេះឯង ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការកំណត់នូវអារម្មណ៍ខាងក្រៅ ឈ្មោះថាគោចរនានត្តញ្ញាណ ។

[១៦៥] បញ្ញាក្នុងការកំណត់ នូវចរិយា ឈ្មោះថាចរិយានានត្តញ្ញាណ តើដូចម្តេច ។ ពាក្យថា ចរិយា បានដល់ចរិយា ៣ យ៉ាង គឺ វិញ្ញាណចរិយា ១ អញ្ញាណចរិយា ១ ញាណចរិយា ១ ។

វិញ្ញាណចរិយា តើដូចម្តេច ។ អាវជ្ជនកិរិយា (កិរិយានៃការរំពឹង) ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការឃើញ (នូវរូប) ក្នុងរូបទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា ចក្ខុវិញ្ញាណ មានអត្ថថាសម្រាប់ឃើញ (នូវរូប) ក្នុងរូបទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា វិបាកមនោធាតុ សម្រាប់ឡើង (កាន់អារម្មណ៍) ព្រោះភាពនៃអារម្មណ៍ ដែលបុគ្គលឃើញក្នុងរូបទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា វិបាកមនោវិញ្ញាណធាតុ ព្រោះ

វិញ្ញាណចរិយា សទ្ទេសុ សវនត្ថាយ អាវជ្ជនកិរិយា-ព្យាកតា វិញ្ញាណចរិយា សទ្ទេសុ សវនត្ថោ សោត-វិញ្ញាណំ វិញ្ញាណចរិយា សទ្ទេសុ សុតត្តា អភិរោបន-វិបាកមនោធាតុ វិញ្ញាណចរិយា សទ្ទេសុ អភិរោបិ-តត្តា វិបាកមនោវិញ្ញាណធាតុ វិញ្ញាណចរិយា គន្ធេសុ ឃាយនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា គន្ធេសុ ឃាយនត្ថោ ឃានវិញ្ញាណំ វិញ្ញាណចរិយា គន្ធេសុ ឃាយិតត្តា អភិរោបនវិបាកមនោធាតុ វិញ្ញា-ណចរិយា គន្ធេសុ អភិរោបិតត្តា វិបាកមនោវិញ្ញាណ-ធាតុ វិញ្ញាណចរិយា រសេសុ សាយនត្ថាយ អាវជ្ជន-កិរិយាព្យាកតា វិញ្ញាណចរិយា រសេសុ សាយនត្ថោ

ភាពនៃវិបាកមនោវិញ្ញាណធាតុ ឡើងកាន់អារម្មណ៍ក្នុងរូបទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្តាប់ (នូវសំឡេង) ក្នុងសំឡេងទាំងឡាយ ឈ្មោះថាវិញ្ញាណ-ចរិយា សោតវិញ្ញាណ មានអត្ថថាសម្រាប់ឮ (នូវសំឡេង) ក្នុងសំឡេងទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា វិបាកមនោធាតុ សម្រាប់ឡើង (កាន់អារម្មណ៍) ព្រោះភាពនៃអារម្មណ៍ដែលបុគ្គលឮ ក្នុងសំឡេងទាំង-ឡាយ ឈ្មោះថាវិញ្ញាណចរិយា វិបាកមនោវិញ្ញាណធាតុ ព្រោះភាពនៃវិបាកមនោវិញ្ញាណធាតុ ឡើងកាន់អារម្មណ៍ ក្នុងសំឡេងទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការហិត (នូវក្លិន) ក្នុងក្លិនទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា ឃានវិញ្ញាណ មានអត្ថថាសម្រាប់ហិតក្លិន ក្នុងក្លិនទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា វិបាកមនោធាតុ សម្រាប់ឡើង (កាន់អារម្មណ៍) ព្រោះភាពនៃអារម្មណ៍ ដែលបុគ្គលហិត ក្នុងក្លិនទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា វិបាកមនោវិញ្ញាណធាតុ ព្រោះភាពនៃវិបាក-មនោវិញ្ញាណធាតុ ឡើងកាន់អារម្មណ៍ ក្នុងក្លិនទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការលិទ្ធភ្លក្ស (នូវរស) ក្នុងរសទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា

ជិវ្ហាវិញ្ញាណំ វិញ្ញាណចរិយា រសេសុ សាយិតត្តា អភិរោបនវិបាកមនោធាតុ វិញ្ញាណចរិយា រសេសុ អភិរោបិតត្តា វិបាកមនោវិញ្ញាណធាតុ វិញ្ញាណចរិយា ផោដ្ឋព្វេសុ ផុសនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា ផោដ្ឋព្វេសុ ផុសនត្ថោ កាយ-
វិញ្ញាណំ វិញ្ញាណចរិយា ផោដ្ឋព្វេសុ ផុដ្ឋត្តា អភិ-
រោបនវិបាកមនោធាតុ វិញ្ញាណចរិយា ផោដ្ឋព្វេសុ អភិរោបិតត្តា វិបាកមនោវិញ្ញាណធាតុ វិញ្ញាណ-
ចរិយា ធម្មេសុ វិជាននត្ថាយ អាវជ្ជនកិរិយាព្យា-
កតា វិញ្ញាណចរិយា ធម្មេសុ វិជាននត្ថោ មនោ-
វិញ្ញាណំ វិញ្ញាណចរិយា ធម្មេសុ វិញ្ញាតត្តា អភិរោបនវិបាកមនោធាតុ វិញ្ញាណចរិយា ធម្មេសុ

ជិវ្ហាវិញ្ញាណ មានអត្ថថាសម្រាប់លិទ្ធភ្លក្សនូវរសទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា វិបាកមនោធាតុ សម្រាប់ឡើង(កាន់អារម្មណ៍) ព្រោះភាពនៃអារម្មណ៍ដែលបុគ្គលលិទ្ធភ្លក្ស នូវរសទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា វិបាកមនោវិញ្ញាណធាតុ ព្រោះភាពនៃវិបាកមនោវិញ្ញាណធាតុឡើង (កាន់អារម្មណ៍) ក្នុងរសទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការប៉ះពាល់ក្នុងផ្សព្វទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា កាយវិញ្ញាណ មានអត្ថថាសម្រាប់ពាល់ត្រូវ (នូវផ្សព្វ) ក្នុងផ្សព្វទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា វិបាកមនោធាតុ សម្រាប់ឡើង (កាន់អារម្មណ៍) ព្រោះភាពនៃអារម្មណ៍ដែលបុគ្គលពាល់ត្រូវក្នុងផ្សព្វទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា វិបាកមនោវិញ្ញាណធាតុ ព្រោះភាពនៃវិបាកមនោវិញ្ញាណធាតុ ឡើងកាន់អារម្មណ៍ក្នុងផ្សព្វទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការដឹងច្បាស់ (នូវធម៌) ក្នុងធម៌ទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា មនោវិញ្ញាណធាតុ មានអត្ថថាសម្រាប់ដឹងច្បាស់ក្នុងធម៌ទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា វិបាកមនោធាតុ សម្រាប់ឡើង (កាន់អារម្មណ៍) ព្រោះភាពនៃអារម្មណ៍ដែលបុគ្គលដឹងច្បាស់ក្នុងធម៌ទាំងឡាយ ឈ្មោះថាវិញ្ញាណចរិយា វិបាកមនោវិញ្ញាណធាតុ

អភិរោបិតត្ថា វិចារកមនោវិញ្ញាណធាតុ វិញ្ញាណ-
ចរិយា ។

[១៦៦] វិញ្ញាណចរិយាតិ កេនដ្ឋេន វិញ្ញាណ-
ចរិយា ។ និរាគា ចរតីតិ វិញ្ញាណចរិយា និទ្ទោសា
ចរតីតិ វិញ្ញាណចរិយា និម្មោហា ចរតីតិ វិញ្ញាណ-
ចរិយា និម្មានា ចរតីតិ វិញ្ញាណចរិយា និទ្ទិដ្ឋិ ចរតីតិ
វិញ្ញាណចរិយា និឧទ្ធច្ចា ចរតីតិ វិញ្ញាណចរិយា
និព្វិចិកិច្ឆា ចរតីតិ វិញ្ញាណចរិយា ជានុសយា
ចរតីតិ វិញ្ញាណចរិយា រាគវិប្បយុត្តា ចរតីតិ
វិញ្ញាណចរិយា ទោសវិប្បយុត្តា ចរតីតិ វិញ្ញាណ-
ចរិយា មោហវិប្បយុត្តា ចរតីតិ វិញ្ញាណចរិយា

ព្រោះភាពនៃវិបាកមនោវិញ្ញាណធាតុ ឡើងកាន់អារម្មណ៍ ក្នុងធម៌ទាំង-ឡាយ ឈ្មោះថាវិញ្ញាណចរិយា ។

[១៦៦] សំណួរត្រង់ពាក្យថា វិញ្ញាណចរិយា តើវិញ្ញាណចរិយាដោយអត្ថដូចម្ដេច ។ ធម្មជាតិណា មិនមានរាគៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា មិនមានទោសៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា មិនមានមោហៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណ-ចរិយា ធម្មជាតិណា មិនមានមានះ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា មិនមានទិដ្ឋិ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា មិនមានឧទ្ធច្ចៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា មិនមានវិចិកិច្ឆា រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតិណា មិនមានអនុស័យ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាករាគៈ រមែងប្រព្រឹត្តទៅ ធម្ម-ជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកទោសៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកមោហៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា

មានវិប្បយុត្តា ចរតីតិ វិញ្ញាណចរិយា ទិដ្ឋិវិប្បយុត្តា ចរតីតិ វិញ្ញាណចរិយា ឧទ្ធច្ចវិប្បយុត្តា ចរតីតិ វិញ្ញាណចរិយា វិចិកិច្ឆាវិប្បយុត្តា ចរតីតិ វិញ្ញាណ-ចរិយា អនុសយវិប្បយុត្តា ចរតីតិ វិញ្ញាណចរិយា កុសលេហិ កម្មេហិ វិប្បយុត្តា ចរតីតិ វិញ្ញាណ-ចរិយា អកុសលេហិ កម្មេហិ វិប្បយុត្តា[(១)] ចរតីតិ វិញ្ញាណចរិយា សាវជ្ជេហិ កម្មេហិ វិប្បយុត្តា ចរតីតិ វិញ្ញាណចរិយា អនវជ្ជេហិ កម្មេហិ វិប្បយុត្តា[(២)] ចរតីតិ វិញ្ញាណចរិយា កណ្ហេហិ កម្មេហិ វិប្បយុត្តា ចរតីតិ វិញ្ញាណចរិយា សុក្កេហិ កម្មេហិ វិប្ប-យុត្តា[(៣)] ចរតីតិ វិញ្ញាណចរិយា សុខុទ្រយេហិ កម្មេហិ វិប្បយុត្តា ចរតីតិ វិញ្ញាណចរិយា

---

១-២-៣- សម្បយុត្តា ។

ធម្មជាតិណា ប្រាសចាកមានះ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថា វិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកទិដ្ឋិ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកឧទ្ធច្ចៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកវិចិកិច្ឆា រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកអនុស័យ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្ម ជាកុសល រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្ម ជាអកុសល រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្ម ប្រកបដោយទោស រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្មមិនមានទោស រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្មខ្មៅ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្មស រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្មដែលចម្រើនដោយសេចក្តីសុខ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា

ឱត្តប្បិន្ទ្រិយេហិ កម្មេហិ វិប្បយុត្តា ចរតីតិ វិញ្ញាណចរិយា សុខវិចាកេហិ កម្មេហិ វិប្បយុត្តា[១] ចរតីតិ វិញ្ញាណចរិយា ទុក្ខវិចាកេហិ កម្មេហិ វិប្បយុត្តា ចរតីតិ វិញ្ញាណចរិយា វិញ្ញាតេ[២] ចរតីតិ វិញ្ញាណចរិយា វិញ្ញាណស្ស ឯវរូចា ចរិយា ហោតីតិ វិញ្ញាណចរិយា បកតិបរិសុទ្ធមិទំ ចិត្តំ និក្កិលេសដ្ឋេនាតិ វិញ្ញាណចរិយា អយំ វិញ្ញាណចរិយា ។

[១៦៧] កតមា អញ្ញាណចរិយា ។ មនាបិយេសុ[៣] រូបេសុ រាគស្ស ជវនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា រាគស្ស ជវនា អញ្ញាណចរិយា អមនាបិយេសុ រូបេសុ ទោសស្ស ជវនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា ទោសស្ស ជវនា អញ្ញាណចរិយា

១ ម. សម្បយុត្តា ។ ២ ឱ. វិញ្ញាណោ ។ ៣ មនាបិកេសូតិ អដ្ឋកថា ។

ធម្មជាតិណា ប្រាសចាកកម្មដែលចម្រើនដោយសេចក្តីទុក្ខ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្មមានផលជាសុខ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្មមានផលជាទុក្ខ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ធម្មជាតិណា រមែងប្រព្រឹត្តទៅ ក្នុងអារម្មណ៍ដែលខ្លួនដឹង ធម្មជាតិនោះ ឈ្មោះថាវិញ្ញាណចរិយា ចរិយារបស់វិញ្ញាណ មានសភាពយ៉ាងនេះ ហេតុនោះ ឈ្មោះថាវិញ្ញាណ-ចរិយា ចិត្តនេះបរិសុទ្ធជាប្រក្រតី ដោយអត្ថថាមិនមានកិលេស ហេតុនោះ ឈ្មោះថាវិញ្ញាណចរិយា នេះវិញ្ញាណចរិយា ។

[១៦៤] អញ្ញាណចរិយា តើដូចម្តេច ។ អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅ ឬ លឿនទៅ របស់រាគៈ ក្នុងរូបទាំង-ឡាយ ជាទីពេញចិត្ត ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅរបស់រាគៈ ឈ្មោះថាអញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់ទោសៈ ក្នុងរូបទាំងឡាយមិនជាទីពេញចិត្ត ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅរបស់ទោសៈ ឈ្មោះថាអញ្ញាណចរិយា

តទុភយេន អសម្បេក្ខនស្មឹ វត្ថុស្មឹ មោហស្ស ជវនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា មោហស្ស ជវនា អញ្ញាណចរិយា វិនិពន្ធស្ស មានស្ស ជវនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា មានស្ស ជវនា អញ្ញាណចរិយា បរាមដ្ឋាយ ទិដ្ឋិយា ជវនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា ទិដ្ឋិយា ជវនា អញ្ញាណចរិយា វិក្ខេបគតស្ស ឧទ្ធច្ចស្ស ជវនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា ឧទ្ធច្ចស្ស ជវនា អញ្ញាណចរិយា អនិដ្ឋាគតាយ[១] វិចិកិច្ឆាយ ជវនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា វិចិកិច្ឆាយ ជវនា អញ្ញាណចរិយា ថាមគតស្ស អនុសយស្ស ជវនត្ថាយ

---

១ ឱ. ម. អនិដ្ឋង្គតាយ ។

អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅ របស់មោហៈ ក្នុងវត្ថុមិនគួរក្រឡេកមើល ដោយហេតុទាំងពីរនោះ ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅ របស់មោហៈ ឈ្មោះថាអញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅ របស់មានះជាគ្រឿងចាក់ស្រេះ ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅ របស់មានះ ឈ្មោះថាអញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅនៃទិដ្ឋិ ជាកិលេសស្ទាបអង្អែល ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅ របស់ទិដ្ឋិ ឈ្មោះថាអញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅ របស់ឧទ្ធច្ចៈដែលរវើរវាយ ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅ របស់ឧទ្ធច្ចៈ ឈ្មោះថាអញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ ដល់ការស្ទុះទៅ របស់វិចិកិច្ឆា ដែលដល់នូវសេចក្តីមិនដាច់ស្រេច ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅ របស់វិចិកិច្ឆា ឈ្មោះថាអញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅ របស់អនុស័យ ដែលមានកម្លាំង

អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា អនុសយស្ស ជវនា អញ្ញាណចរិយា មនាបិយេសុ សទ្ទេសុ ។ បេ ។ មនាបិយេសុ គន្ធេសុ មនាបិយេសុ រសេសុ មនាបិយេសុ ផោដ្ឋព្វេសុ មនាបិយេសុ ធម្មេសុ រាគស្ស ជវនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា រាគស្ស ជវនា អញ្ញាណចរិយា អមនាបិយេសុ ធម្មេសុ[១] ទោសស្ស ជវនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា ទោសស្ស ជវនា អញ្ញាណចរិយា តទុភយេន អសម្បេក្ខនស្មឹ វត្ថុស្មឹ មោហស្ស ជវនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា មោហស្ស ជវនា អញ្ញាណចរិយា[២] បរាមដ្ឋាយ ទិដ្ឋិយា ជវនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា ទិដ្ឋិយា ជវនា អញ្ញាណចរិយា វិក្ខេបគតស្ស ឧទ្ធច្ចស្ស ជវនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា ឧទ្ធច្ចស្ស ជវនា អញ្ញាណចរិយា

---

១ ឱ. រូបេសុ ។ ២ ឱ. ម. ឯត្ថន្តរេ វិនិពន្ធស្ស មានស្ស ជវនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា មានស្ស ជវនា អញ្ញាណចរិយាតិ ទិស្សន្តិ ។

ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅរបស់អនុស័យ ឈ្មោះថាអញ្ញាណ-ចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់រាគៈ ក្នុងសំឡេងទាំងឡាយ ជាទីពេញចិត្ត ។ បេ ។ ក្នុងក្លិនទាំងឡាយជាទីពេញចិត្ត ក្នុងរសទាំងឡាយជាទីពេញចិត្ត ក្នុងផ្សព្វទាំង-ឡាយជាទីពេញចិត្ត ក្នុងធម្មារម្មណ៍ទាំងឡាយជាទីពេញចិត្ត ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅរបស់រាគៈ ឈ្មោះថាអញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅ របស់ទោសៈ ក្នុងធម្មារម្មណ៍ទាំងឡាយមិនជាទីពេញចិត្ត ឈ្មោះថាវិញ្ញាណ-ចរិយា ការស្ទុះទៅរបស់ទោសៈ ឈ្មោះថាអញ្ញាណចរិយា អាវជ្ជន-កិរិយាជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់មោហៈ ក្នុងវត្ថុមិនគួរក្រឡេកមើលដោយហេតុទាំងពីរនោះ ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅរបស់មោហៈ ឈ្មោះថាអញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅ របស់ទិដ្ឋិ ជាធម្មជាតិស្ទាបអង្អែល ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅរបស់ទិដ្ឋិ ឈ្មោះថាអញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅ របស់ឧទ្ធច្ចៈ ជាកិលេសរវើរវាយ ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅរបស់ឧទ្ធច្ចៈ ឈ្មោះថាអញ្ញាណចរិយា

អធិដ្ឋាគតាយ វិចិកិច្ឆាយ ជវនត្តាយ អាវជ្ជនកិរិយា-ព្យាកតា វិញ្ញាណកិរិយា វិចិកិច្ឆាយ ជវនា អញ្ញា-ណចរិយា ថាមគតស្ស អនុសយស្ស ជវនត្តាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា អនុសយ-ស្ស ជវនា អញ្ញាណចរិយា ។

[១៦៨] អញ្ញាណចរិយាតិ កេនដ្ឋេន អញ្ញាណ-ចរិយា ។ សរាគា ចរតីតិ អញ្ញាណចរិយា សទោ-សា ចរតីតិ អញ្ញាណចរិយា សមោហា ចរតីតិ អញ្ញាណចរិយា សមានា ចរតីតិ អញ្ញាណចរិយា សទិដ្ឋិ ចរតីតិ អញ្ញាណចរិយា សឧទ្ធច្ចា ចរតីតិ អញ្ញាណចរិយា សវិចិកិច្ឆា ចរតីតិ អញ្ញាណ-ចរិយា សានុសយា ចរតីតិ អញ្ញាណចរិយា

អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់វិចិកិច្ឆា ដែលដល់នូវសេចក្តីមិនដាច់ស្រេច ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅរបស់វិចិកិច្ឆា ឈ្មោះថាអញ្ញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់ការស្ទុះទៅរបស់អនុស័យ ដែលមានកម្លាំង ឈ្មោះថាវិញ្ញាណចរិយា ការស្ទុះទៅរបស់អនុស័យ ឈ្មោះថាអញ្ញាណចរិយា ។

[១៦៨] សំណួរត្រង់ពាក្យថា អញ្ញាណចរិយា តើអញ្ញាណចរិយាដោយអត្ថថាដូចម្តេច ។ ធម្មជាតិណា ប្រកបដោយរាគៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រកបដោយទោសៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រកបដោយមោហៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រកបដោយមានះ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រកបដោយទិដ្ឋិ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណាប្រកបដោយឧទ្ធច្ចៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រកបដោយវិចិកិច្ឆា រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រកបដោយអនុស័យ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា

រាគសម្បយុត្តា ចរតីតិ អញ្ញាណចរិយា ទោសសម្បយុត្តា ចរតីតិ អញ្ញាណចរិយា មោហសម្បយុត្តា ចរតីតិ អញ្ញាណចរិយា មានសម្បយុត្តា ចរតីតិ អញ្ញាណចរិយា ទិដ្ឋិសម្បយុត្តា ចរតីតិ អញ្ញាណចរិយា ឧទ្ធច្ចសម្បយុត្តា ចរតីតិ អញ្ញាណចរិយា វិចិកិច្ឆាសម្បយុត្តា ចរតីតិ អញ្ញាណចរិយា អនុសយសម្បយុត្តា ចរតីតិ អញ្ញាណចរិយា កុសលេហិ កម្មេហិ វិប្បយុត្តា ចរតីតិ អញ្ញាណចរិយា អកុសលេហិ កម្មេហិ សម្បយុត្តា[១] ចរតីតិ អញ្ញាណចរិយា សាវជ្ជេហិ កម្មេហិ សម្បយុត្តា ចរតីតិ អញ្ញាណចរិយា អនវជ្ជេហិ កម្មេហិ វិប្បយុត្តា ចរតីតិ អញ្ញាណចរិយា កណ្ហេហិ

---

១ ឱ. វិប្បយុត្តា ។

ធម្មជាតិណា ប្រកបព្រមដោយរាគៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតិណា ប្រកបព្រមដោយទោសៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រកបព្រមដោយមោហៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតិណា ប្រកបព្រមដោយមានះ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រកបព្រមដោយ ទិដ្ឋិ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រកបព្រមដោយឧទ្ធច្ចៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថា អញ្ញាណចរិយា ធម្មជាតិណា ប្រកបព្រមដោយវិចិកិច្ឆា រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណាប្រកបព្រមដោយ អនុស័យ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្មជាកុសល រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រកបព្រមដោយកម្មជាអកុសល រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រកបព្រមដោយកម្មមានទោស រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្មមិនមានទោស រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា

កម្មេហិ សម្បយុត្តា(១) ចរតីតិ អញ្ញាណចរិយា សុក្កេហិ កម្មេហិ វិប្បយុត្តា ចរតីតិ អញ្ញាណចរិយា សុខុន្ទ្រិយេហិ កម្មេហិ វិប្បយុត្តា ចរតីតិ អញ្ញាណចរិយា ទុក្ខុន្ទ្រិយេហិ កម្មេហិ សម្បយុត្តា(២) ចរតីតិ អញ្ញាណចរិយា សុខវិបាកេហិ កម្មេហិ វិប្បយុត្តា ចរតីតិ អញ្ញាណចរិយា ទុក្ខវិបាកេហិ កម្មេហិ សម្បយុត្តា(៣) ចរតីតិ អញ្ញាណចរិយា អញ្ញាតេ(៤) ចរតីតិ អញ្ញាណចរិយា អញ្ញាណស្ស ឯវរូបា ចរិយា ហោតីតិ អញ្ញាណចរិយា អយំ អញ្ញាណចរិយា ។

[១៦៩] កតមា ញាណចរិយា ។ អនិច្ចានុបស្សនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា អនិច្ចានុបស្សនា ញាណចរិយា ទុក្ខានុបស្សនត្ថាយ អាវជ្ជនកិរិយាព្យាកតា

១-២-៣- ឱ. វិប្បយុត្តា ។ ៤- ម. អញ្ញាណោ ។

ធម្មជាតិណា ប្រកបព្រមដោយកម្មខ្មៅ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្មស រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្មដែលចម្រើនដោយសេចក្តីសុខ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រកបព្រមដោយកម្មដែលចម្រើនដោយសេចក្តីទុក្ខ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រាសចាកកម្ម មានផលជាសុខ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា ប្រកបព្រមដោយកម្មមានផលជាទុក្ខ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ធម្មជាតិណា រមែងប្រព្រឹត្តទៅក្នុងហេតុដែលខ្លួនមិនដឹង ធម្មជាតិនោះ ឈ្មោះថាអញ្ញាណចរិយា ចរិយារបស់អញ្ញាណៈ (សេចក្តីមិនដឹង) មានសភាពយ៉ាងនេះ ហេតុនោះ ឈ្មោះថាអញ្ញាណ-ចរិយា នេះឈ្មោះថាអញ្ញាណចរិយា ។

[១៦៩] ញាណចរិយា តើដូចម្តេច ។ អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់អនិច្ចានុបស្សនា (ការពិចារណាឃើញថាមិនទៀង) ឈ្មោះថាវិញ្ញាណចរិយា តួអនិច្ចានុបស្សនា ឈ្មោះថាញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ ដល់ទុក្ខានុបស្សនា (ការពិចារណាឃើញថាជាទុក្ខ)

១៨៩



វិញ្ញាណចរិយា ទុក្ខានុបស្សនា ញាណចរិយា អនត្តានុបស្សនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា អនត្តានុបស្សនា ញាណចរិយា និព្វិទានុបស្សនត្ថាយ ។ បេ ។ វិរាគានុបស្សនត្ថាយ និរោធានុបស្សនត្ថាយ បដិនិស្សគ្គានុបស្សនត្ថាយ ខយានុបស្សនត្ថាយ វយានុបស្សនត្ថាយ វិបរិណាមានុបស្សនត្ថាយ អនិមិត្តានុបស្សនត្ថាយ អប្បណិហិតានុបស្សនត្ថាយ សុញ្ញតានុបស្សនត្ថាយ អធិប្បញ្ញាធម្មានុបស្សនត្ថាយ យថាភូតញ្ញាណទស្សនត្ថាយ

ឈ្មោះថាវិញ្ញាណចរិយា តួទុក្ខានុបស្សនា ឈ្មោះថាញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ ដល់អនត្តានុបស្សនា (ការពិចារណាឃើញថាជាអនត្តា) ឈ្មោះថាវិញ្ញាណចរិយា តួអនត្តា-នុបស្សនា ឈ្មោះថាញាណចរិយា អាវជ្ជនកិរិយា ជាអព្យាក្រឹត ដើម្បីប្រយោជន៍ដល់និព្វិទានុបស្សនា (ការពិចារណាឃើញថាគួរនឿយណាយ) ។ បេ ។ ដើម្បីប្រយោជន៍ដល់វិរាគានុបស្សនា (ការពិចារ-ណាឃើញថាប្រាសចាករាគៈ) ដើម្បីប្រយោជន៍ដល់និរោធានុបស្សនា (ការពិចារណាឃើញនូវការរលត់) ដើម្បីប្រយោជន៍ដល់បដិនិស្សគ្គា-នុបស្សនា (ការពិចារណាឃើញថាគួររលាស់ចេញ) ដើម្បីប្រយោជន៍ដល់ខយានុបស្សនា (ការពិចារណាឃើញនូវការអស់) ដើម្បីប្រយោជន៍ដល់វយានុបស្សនា (ការពិចារណាឃើញនូវការសូន្យ) ដើម្បីប្រយោជន៍ដល់វិបរិណាមានុបស្សនា (ការពិចារណាឃើញ នូវការប្រែប្រួល) ដើម្បីប្រយោជន៍ ដល់អនិមិត្តានុបស្សនា (ការពិចារណាឃើញថាសង្ខារមិនមានកំណត់) ដើម្បីប្រយោជន៍ដល់អប្បណិហិតានុបស្សនា (ការពិចារណាឃើញថាសង្ខារមិនមានទីតម្កល់មាំ) ដើម្បីប្រយោជន៍ដល់សុញ្ញតានុបស្សនា (ការពិចារណាឃើញថាសង្ខារសូន្យ) ដើម្បីប្រយោជន៍ ដល់អធិប្បញ្ញាធម្មានុបស្សនា (ការពិចារណានូវធម៌ដោយបញ្ញាដ៏ក្រៃលែង) ដើម្បីប្រយោជន៍ ដល់យថាភូតញ្ញាណទស្សនៈ

អាយូហនានុបស្សនត្ថាយ បដិសង្ខានុបស្សនត្ថាយ អាវជ្ជនកិរិយាព្យាកតា វិញ្ញាណចរិយា បដិសង្ខានុបស្សនា ញាណចរិយា វិវដ្ដនានុបស្សនា ញាណចរិយា សោតាបត្តិមគ្គោ ញាណចរិយា សោតាបត្តិផលសមាបត្តិ ញាណចរិយា សកទាគាមិមគ្គោ ញាណចរិយា សកទាគាមិផលសមាបត្តិ ញាណចរិយា អនាគាមិមគ្គោ ញាណចរិយា អនាគាមិផលសមាបត្តិ ញាណចរិយា អរហត្តមគ្គោ ញាណចរិយា អរហត្តផលសមាបត្តិ ញាណចរិយា ។

[១៧០] ញាណចរិយាតិ កេនដ្ឋេន ញាណចរិយា ។ និរាគា ចរតីតិ ញាណចរិយា និទ្ទោសា ចរតីតិ ញាណចរិយា ។ បេ ។ នានុសយា ចរតីតិ ញាណចរិយា រាគវិប្បយុត្តា ចរតីតិ ញាណចរិយា ទោសវិប្បយុត្តា ចរតីតិ ញាណចរិយា

(ការឃើញដោយញាណតាមសេចក្តីពិត) ដើម្បីប្រយោជន៍ដល់អាទីនវានុបស្សនា (ការពិចារណាឃើញថាជាទោស) ដើម្បីប្រយោជន៍ដល់បដិសង្ខានុបស្សនា (ការពិចារណាឃើញដោយឧបាយបញ្ញា) ឈ្មោះថាវិញ្ញាណចរិយា តួបដិសង្ខានុបស្សនា ឈ្មោះថាញាណចរិយា វិវដ្តនានុបស្សនា ឈ្មោះថាញាណចរិយា សោតាបត្តិមគ្គ ឈ្មោះថាញាណចរិយា សោតាបត្តិផលសមាបត្តិ ឈ្មោះថាញាណចរិយា សកទាគាមិមគ្គ ឈ្មោះថាញាណចរិយា សកទាគាមិផលសមាបត្តិ ឈ្មោះថាញាណចរិយា អនាគាមិមគ្គ ឈ្មោះថាញាណចរិយា អនាគាមិផលសមាបត្តិ ឈ្មោះថាញាណចរិយា អរហត្តមគ្គ ឈ្មោះថាញាណចរិយា អរហត្តផលសមាបត្តិ ឈ្មោះថាញាណចរិយា ។

[១៧០] សំណួរត្រង់ពាក្យថា ញាណចរិយា តើញាណចរិយាដោយអត្ថដូចម្តេច ។ ធម្មជាតិណា មិនមានរាគៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាញាណចរិយា ធម្មជាតិណា មិនមានទោសៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាញាណចរិយា ។ បេ ។ ធម្មជាតិណា មិនមានអនុស័យ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាញាណចរិយា ធម្មជាតិណា ប្រាសចាករាគៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាញាណចរិយា ធម្មជាតិណា ប្រាសចាកទោសៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាញាណចរិយា

១៩១

មោហវិប្បយុត្តា ចរតីតិ ញាណចរិយា មានវិប្បយុត្តា ។ បេ ។ ទិដ្ឋិវិប្បយុត្តា ឧទ្ធច្ចវិប្បយុត្តា វិចិកិច្ឆាវិប្បយុត្តា អនុសយវិប្បយុត្តា កុសលេហិ កម្មេហិ សម្បយុត្តា អកុសលេហិ កម្មេហិ វិប្បយុត្តា សាវជ្ជេហិ កម្មេហិ វិប្បយុត្តា អនវជ្ជេហិ កម្មេហិ សម្បយុត្តា កណ្ហេហិ កម្មេហិ វិប្បយុត្តា សុក្កេហិ កម្មេហិ សម្បយុត្តា សុខុទ្រយេហិ កម្មេហិ សម្បយុត្តា ទុក្ខុទ្រយេហិ កម្មេហិ វិប្បយុត្តា សុខវិបាកេហិ កម្មេហិ សម្បយុត្តា ចរតីតិ ញាណចរិយា ទុក្ខវិបាកេហិ កម្មេហិ វិប្បយុត្តា ចរតីតិ ញាណចរិយា ញាណេ[១] ចរតីតិ ញាណចរិយា ញាណស្ស ឯវរូបា ចរិយា ហោតីតិ ញាណចរិយា អយំ ញាណចរិយា វិញ្ញាណចរិយា អញ្ញាណចរិយា ញាណចរិយា[២] តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ចរិយាវវត្ថានេ បញ្ញា ចរិយានានត្តេ ញាណំ ។

១ ឱ. ញាតេ ។ ២ ឱ. ម. អញ្ញាវិញ្ញាណចរិយា អញ្ញាអញ្ញាណចរិយា អញ្ញាញាណចរិយាតិ ។

ធម្មជាតិណា ប្រាសចាកមោហៈ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាញាណចរិយា ធម្មជាតិណា ប្រាសចាកមានះ ។ បេ ។ ធម្ម-ជាតិណា ប្រាសចាកទិដ្ឋិ ប្រាសចាកឧទ្ធច្ចៈ ប្រាសចាកវិចិកិច្ឆា ប្រាសចាកអនុស័យ ប្រកបព្រមដោយកម្មជាកុសល ប្រាសចាកកម្មជាអកុសល ប្រាសចាកកម្មមានទោស ប្រកបព្រមដោយកម្មមិនមានទោស ប្រាសចាកកម្មខ្មៅ ប្រកបព្រមដោយកម្មស ប្រកបព្រមដោយកម្មដែលចម្រើនដោយសេចក្តីសុខ ប្រាសចាកកម្មដែលចម្រើនដោយសេចក្តីទុក្ខ ប្រកបព្រមដោយកម្មមានផលជាសុខ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាញាណចរិយា ធម្មជាតិណា ប្រាសចាកកម្មមានផលជាទុក្ខ រមែងប្រព្រឹត្តទៅ ធម្មជាតិនោះ ឈ្មោះថាញាណចរិយា ធម្មជាតិណា ប្រ-ព្រឹត្តទៅក្នុងញាណ ធម្មជាតិនោះ ឈ្មោះថាញាណចរិយា ចរិយារបស់ញាណ មានសភាពយ៉ាងនេះ ហេតុនោះ ឈ្មោះថាញាណចរិយានេះ ឈ្មោះថាញាណចរិយា ។ វិញ្ញាណចរិយា អញ្ញាណចរិយា ញាណចរិយា (យ៉ាងនេះឯង) ។ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការកំណត់នូវចរិយា ឈ្មោះថាចរិយានានត្តញ្ញាណ ។

[១៧១] កាជំ ចតុធម្មវវត្ថានេ បញ្ញា ភូមិជានត្តេ ញាណំ ។ ចតស្សោ ភូមិយោ កាមាវចរា ភូមិ រូបាវចរា ភូមិ អរូបាវចរា ភូមិ អបរិយាបន្នា ភូមិ ។

[១៧២] កាតមា កាមាវចរា ភូមិ ។ ហេដ្ឋតោ អវីចិនិរយំ បរិយន្តំ ការិត្វា ឧបរិតោ បរនិម្មិតវសវត្តី ទេវេ អន្តោ ការិត្វា យំ ឯតស្មឹ អន្តេ ឯត្ថាវចរា ឯត្ថ បរិយាបន្នា ខន្ធធាតុ អាយតនា រូបា វេទនា សញ្ញា សង្ខារា វិញ្ញាណំ អយំ កាមាវចរា ភូមិ ។

[១៧៣] កាតមា រូបាវចរា ភូមិ ។ ហេដ្ឋតោ ព្រហ្មលោកំ បរិយន្តំ ការិត្វា ឧបរិតោ អកានិដ្ឋេ ទេវេ អន្តោ ការិត្វា យំ ឯតស្មឹ អន្តរេ ឯត្ថាវចរា ឯត្ថ បរិយាបន្នា សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារស្ស វា ចិត្តចេតសិកា ធម្មា អយំ រូបាវចរា ភូមិ ។

[១៧៤] កាតមា អរូបាវចរា ភូមិ ។ ហេដ្ឋតោ អាកាសានញ្ចាយតនុបគេ ទេវេ បរិយន្តំ ការិត្វា ឧបរិតោ នេវសញ្ញានាសញ្ញាយតនុបគេ ទេវេ

[១៧១] បញ្ញាក្នុងការកំណត់នូវធម៌ ៤ ឈ្មោះថាភូមិនានត្តញ្ញាណ តើដូចម្តេច ។ ភូមិមាន ៤ គឺកាមាវចរភូមិ ១ រូបាវចរភូមិ ១ អរូបាវចរភូមិ ១ អបរិយាបន្នភូមិ ១ ។

[១៧២] កាមាវចរភូមិ តើដូចម្តេច ។ ខាងក្រោម កំណត់ត្រឹមអវីចិនរកជាទីបំផុត ខាងលើ កំណត់ត្រឹមបរនិម្មិតវសវត្តីទេវតា ជាទីបំផុត ខន្ធ ធាតុ អាយតនៈ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា មានក្នុងចន្លោះនុ៎ះ រង្គាត់ទៅក្នុងចន្លោះនុ៎ះ រាប់បញ្ចូលក្នុងចន្លោះនុ៎ះ នេះឈ្មោះថាកាមាវចរភូមិ ។

[១៧៣] រូបាវចរភូមិ តើដូចម្តេច ។ ខាងក្រោម កំណត់ត្រឹមព្រហ្មលោកជាទីបំផុត ខាងលើ កំណត់ត្រឹមអកនិដ្ឋទេវតាជាទីបំផុត ធម៌ទាំងឡាយ គឺចិត្តនិងចេតសិកណា របស់អ្នកចូលកាន់សមាបត្តិក្តី របស់អ្នកកើតក្នុងព្រហ្មលោកក្តី របស់អ្នកមានធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នក្តី មានក្នុងចន្លោះនុ៎ះ រង្គាត់ទៅក្នុងចន្លោះនុ៎ះ រាប់បញ្ចូលក្នុងចន្លោះនុ៎ះ នេះឈ្មោះថារូបាវចរភូមិ ។

[១៧៤] អរូបាវចរភូមិ តើដូចម្តេច ។ ខាងក្រោម កំណត់ត្រឹមពួកទេវតាអ្នកចូលកាន់អាកាសានញ្ចាយតនភពជាទីបំផុត ខាងលើ កំណត់ត្រឹមពួកទេវតា អ្នកចូលកាន់នេវសញ្ញានាសញ្ញាយតនភព ជា

អន្តោ ករិត្វា យំ ឯតស្មឹ អន្តរេ ឯត្ថាវចរា ឯត្ថ បរិយា-
បន្នា សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារ-
ស្ស វា ចិត្តចេតសិកា ធម្មា អយំ អរូបាវចរា ភូមិ ។

[១៧៤] កតមា អបរិយាបន្នា ភូមិ ។ អបរិ-
យាបន្នា មគ្គា ច ផលានិ ច អសង្ខតា ច ធាតុ
អយំ អបរិយាបន្នា ភូមិ ឥមា ចតស្សោ ភូមិយោ ។

[១៧៦] អបរាបិ ចតស្សោ ភូមិយោ ចត្តារោ
សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា
ចត្តារិ ឈានានិ ចតស្សោ អប្បមញ្ញាយោ ចតស្សោ
អរូបាវចរសមាបត្តិយោ ចតស្សោ បដិសម្ភិទា ចត-
ស្សោ បដិបទា ចត្តារិ អារម្មណានិ ចត្តារោ អរិយ-
វំសា ចត្តារិ សង្គហវត្ថូនិ ចត្តារិ ចក្កានិ ចត្តារិ
ធម្មបទានិ ឥមា ចតស្សោ ភូមិយោ តំញាតដ្ឋេន
ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ចតុធម្ម-
វវត្ថានេ បញ្ញា ភូមិនានត្តេ ញាណំ ។

[១៧៧] កថំ នវធម្មវវត្ថានេ បញ្ញា ធម្មនានត្តេ
ញាណំ ។ កថំ ធម្មេ វវត្ថេតិ ។ កាមាវចរេ

ទីបំផុត ធម៌ទាំងឡាយ គឺចិត្តនិងចេតសិក ណា របស់អ្នកចូលកាន់សមាបត្តិក្តី របស់អ្នកចូលទៅកើតក្នុងព្រហ្មលោកក្តី របស់អ្នកមានធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នក្តី មានក្នុងចន្លោះនុ៎ះ វង្កាត់ទៅក្នុងចន្លោះនុ៎ះ រាប់បញ្ចូលក្នុងចន្លោះនុ៎ះ នេះឈ្មោះថាអរូបាវចរភូមិ ។

[១៧៥] អបរិយាបន្នភូមិ តើដូចម្តេច ។ មគ្គ ផល និងអសង្ខតធាតុ ដែលមិនបានរាប់បញ្ចូល (ក្នុងភូមិនោះ) នេះឈ្មោះថាអបរិយាបន្នភូមិ នេះភូមិ ៤ ។

[១៧៦] ភូមិ ៤ ដទៃទៀត គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឈាន ៤ អប្បមញ្ញា ៤ អរូបាវចរសមាបត្តិ ៤ បដិសម្ភិទា ៤ បដិបទា ៤ អារម្មណ៍ ៤ អរិយវង្ស ៤ សង្គហវត្ថុ ៤ ចក្ក ៤ ធម្មបទ ៤ ទាំងនេះឈ្មោះថាភូមិ ៤ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់ នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការកំណត់នូវធម៌ ៤ ឈ្មោះថាភូមិនានត្តញ្ញាណ ។

[១៧៧] បញ្ញាក្នុងការកំណត់នូវធម៌ ៩ ឈ្មោះថាធម្មនានត្តញ្ញាណ តើដូចម្តេច ។ បុគ្គលកំណត់ នូវធម៌ទាំងឡាយ តើដូចម្តេច ។

ធម្មា កុសលតោ វត្តន្តិ អកុសលតោ វត្តន្តិ អព្យាកតតោ វត្តន្តិ រូបាវចរេ ធម្មា កុសលតោ វត្តន្តិ អព្យាកតតោ វត្តន្តិ អរូបាវចរេ ធម្មា កុសលតោ វត្តន្តិ អព្យាកតតោ វត្តន្តិ អបរិយាបន្នេ ធម្មា កុសលតោ[១] វត្តន្តិ អព្យាកតតោ វត្តន្តិ ។

[១៧៨] កថំ កាមាវចរេ ធម្មា កុសលតោ វត្តន្តិ អកុសលតោ វត្តន្តិ អព្យាកតតោ វត្តន្តិ ។ ទស កុសលកម្មបថេ កុសលតោ វត្តន្តិ ទស អកុសលកម្មបថេ អកុសលតោ វត្តន្តិ រូបញ្ច វិបាកញ្ច កិរិយញ្ច អព្យាកតតោ វត្តន្តិ ឯវំ កាមាវចរេ ធម្មា កុសលតោ វត្តន្តិ អកុសលតោ វត្តន្តិ អព្យាកតតោ វត្តន្តិ ។

[១៧៩] កថំ រូបាវចរេ ធម្មា កុសលតោ វត្តន្តិ អព្យាកតតោ វត្តន្តិ ។ ឥធដ្ឋស្ស ចត្តារិ ឈានានិ កុសលតោ វត្តន្តិ តត្រូបបន្នស្ស ចត្តារិ ឈានានិ អព្យាកតតោ វត្តន្តិ ឯវំ រូបាវចរេ ធម្មា កុសល-តោ វត្តន្តិ អព្យាកតតោ វត្តន្តិ ។

១ អកុសលតោ ។

បុគ្គលកំណត់នូវពួកកាមាវចរធម៌ ថាជាកុសល កំណត់ថាជាអកុសល កំណត់ថាជាអព្យាក្រឹត កំណត់នូវពួករូបាវចរធម៌ ថាជាកុសល កំណត់ថាជាអព្យាក្រឹត កំណត់នូវពួកអរូបាវចរធម៌ ថាជាកុសល កំណត់ថាជាអព្យាក្រឹត កំណត់នូវពួកអបរិយាបន្នធម៌ ថាជាកុសល កំណត់ថាជាអព្យាក្រឹត ។

[១៧៨] បុគ្គលកំណត់នូវពួកកាមាវចរធម៌ ថាជាកុសល កំណត់ថាជាអកុសល កំណត់ថាជាកុសល កំណត់ថាជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលកំណត់នូវកុសលកម្មបថ ១០ ថាជាកុសល កំណត់នូវអកុសលកម្មបថ ១០ ថាជាអកុសល កំណត់នូវរូប វិបាក និងកិរិយា ថាជាអព្យាក្រឹត បុគ្គលកំណត់ នូវពួកកាមាវចរធម៌ ថាជាកុសល កំណត់ថាជាអកុសល កំណត់ថាជាអព្យាក្រឹត យ៉ាងនេះឯង ។

[១៧៩] បុគ្គលកំណត់នូវពួករូបាវចរធម៌ ថាជាកុសល កំណត់ថាជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលកំណត់នូវឈាន ៤ របស់ជនដែលឋិតនៅក្នុងមនុស្សលោកនេះ ថាជាកុសល កំណត់នូវឈាន ៤ របស់ជនដែលកើតក្នុងព្រហ្មលោកនោះ ថាជាអព្យាក្រឹត បុគ្គលកំណត់នូវពួករូបាវចរធម៌ថាជាកុសល កំណត់ថាជាអព្យាក្រឹត យ៉ាងនេះឯង ។

[១៨០] កថំ អរូបាវចរេ ធម្មេ កុសលតោ វវត្ថេតិ អព្យាកតតោ វវត្ថេតិ ។ ឥធដ្ឋស្ស ចតស្សោ អរូបាវចរសមាបត្តិយោ កុសលតោ វវត្ថេតិ តត្រូបបន្នស្ស ចតស្សោ អរូបាវចរសមាបត្តិយោ អព្យាកតតោ វវត្ថេតិ ឯវំ អរូបាវចរេ ធម្មេ កុសលតោ វវត្ថេតិ អព្យាកតតោ វវត្ថេតិ ។

[១៨១] កថំ អបរិយាបន្នេ ធម្មេ កុសលតោ វវត្ថេតិ អព្យាកតតោ វវត្ថេតិ ។ ចត្តារោ អរិយមគ្គេ កុសលតោ វវត្ថេតិ ចត្តារិ សាមញ្ញផលានិ និព្វានញ្ច អព្យាកតតោ វវត្ថេតិ ឯវំ អបរិយាបន្នេ ធម្មេ កុសលតោ វវត្ថេតិ អព្យាកតតោ វវត្ថេតិ ឯវំ ធម្មេ វវត្ថេតិ ។

[១៨២] នវ បាមុជ្ជមូលកា ធម្មា អនិច្ចតោ មនសិករោតោ បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ សមាហិតេ ចិត្តេ យថាភូតំ បជានាតិ បស្សតិ យថាភូតំ

[១៨០] បុគ្គលកំណត់នូវពួកអរូបាវចរធម៌ ថាជាកុសល កំណត់ថាជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលកំណត់នូវអរូបាវចរសមាបត្តិ ៤ របស់ជនដែលឋិតនៅក្នុងមនុស្សលោកនេះ ថាជាកុសល កំណត់នូវអរូបាវចរសមាបត្តិ ៤ របស់ជនដែលកើតនៅក្នុងព្រហ្មលោកនោះ ថាជាអព្យាក្រឹត បុគ្គលកំណត់នូវពួកអរូបាវចរធម៌ថាជាកុសល កំណត់ថាជាអព្យាក្រឹត យ៉ាងនេះឯង ។

[១៨១] បុគ្គលកំណត់នូវពួកអបរិយាបន្នធម៌ថាជាកុសល កំណត់ថាជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលកំណត់នូវអរិយមគ្គ ៤ ថាជាកុសល កំណត់នូវសាមញ្ញផល ៤ និងព្រះនិព្វាន ថាជាអព្យាក្រឹត បុគ្គលកំណត់នូវពួកអបរិយាបន្នធម៌ថាជាកុសល កំណត់ថាជាអព្យាក្រឹត យ៉ាងនេះ បុគ្គលកំណត់នូវធម៌ទាំងឡាយ យ៉ាងនេះឯង ។

[១៨២] ធម៌ ៩ មានបាមុជ្ជៈ (សេចក្តីត្រេកអរទន់) ជាមូល គឺ កាលបុគ្គលធ្វើទុកក្នុងចិត្តថាមិនទៀង បាមុជ្ជៈរមែងកើត កាលបុគ្គលមានចិត្តរីករាយហើយ បីតិ រមែងកើត កាលបុគ្គលមានចិត្តប្រកបដោយបីតិហើយ កាយរមែងស្ងប់ បុគ្គលអ្នកមានកាយស្ងប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបុគ្គលមានសេចក្តីសុខ ចិត្តរមែងតម្កល់មាំ កាលបើចិត្តតម្កល់មាំ បុគ្គលរមែងដឹង រមែងឃើញ តាមពិត

ញាណំ បស្សំ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ទុក្ខតោ មនសិការោតោ ចាមុជ្ជំ ជាយតិ ។ បេ ។ អនត្តតោ មនសិការោតោ ចាមុជ្ជំ ជាយតិ រូបំ អនិច្ចតោ មនសិការោតោ ចាមុជ្ជំ ជាយតិ រូបំ ទុក្ខតោ មនសិការោតោ ។ បេ ។ រូបំ អនត្តតោ ។ បេ ។ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ ចក្ខុំ ។ បេ ។ ជរាមរណំ អនិច្ចតោ មនសិការោតោ ចាមុជ្ជំ ជាយតិ ។ បេ ។ ជរាមរណំ ទុក្ខតោ មនសិការោតោ ចាមុជ្ជំ ជាយតិ ជរាមរណំ អនត្តតោ មនសិការោតោ ចាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ សមាហិតេ ចិត្តេ យថាភូតំ បជានាតិ បស្សតិ យថាភូតំ ញាណំ បស្សំ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ឥមេ នវ ចាមុជ្ជមូលកា ធម្មា ។

កាលបុគ្គលដឹង ឃើញ តាមពិត រមែងនឿយណាយ កាលបុគ្គលនឿយណាយ រមែងធុញទ្រាន់ បុគ្គលផុតស្រឡះ ព្រោះតែការធុញទ្រាន់ កាលបុគ្គលធ្វើទុកក្នុងចិត្តថាជាទុក្ខ បាមុជ្ជៈ រមែងកើត ។ បេ ។ កាលបុគ្គលធ្វើទុកក្នុងចិត្តនូវរូបថាជាអនត្តា បាមុជ្ជៈរមែងកើត កាលធ្វើទុកក្នុងចិត្តនូវរូបថាមិនទៀង បាមុជ្ជៈ រមែងកើតឡើង កាលធ្វើទុកក្នុងចិត្ត នូវរូបថាជាទុក្ខ ។ បេ ។ នូវរូបថាជាអនត្តា ។ បេ ។ កាលធ្វើទុកក្នុងចិត្តនូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ នូវជរាមរណៈ ថាជារបស់មិនទៀង បាមុជ្ជៈ រមែងកើត ។ បេ ។ កាលធ្វើទុកក្នុងចិត្ត នូវជរាមរណៈ ថាជាទុក្ខ បាមុជ្ជៈរមែងកើត កាលធ្វើទុកក្នុងចិត្ត នូវជរាមរណៈ ថាជាអនត្តា បាមុជ្ជៈ រមែងកើត កាលបុគ្គលមានចិត្តរីករាយហើយ បីតិរមែងកើត កាលបុគ្គលមានចិត្តប្រកបដោយបីតិហើយ កាយរមែងស្ងប់ បុគ្គលអ្នកមានកាយស្ងប់ហើយរមែងទទួលនូវសេចក្តីសុខ កាលបុគ្គលមានសេចក្តីសុខ ចិត្តរមែងតម្កល់មាំ កាលបើចិត្តតម្កល់មាំ បុគ្គលរមែងដឹង រមែងឃើញតាមពិត កាលដឹងឃើញតាមពិត រមែងនឿយណាយ កាលនឿយណាយ រមែងធុញទ្រាន់ បុគ្គលផុតស្រឡះ ព្រោះតែការធុញទ្រាន់ នេះធម៌ ៩ ដែលមានបាមុជ្ជៈជាមូល ។

[១៨៣] នវ យោនិសោ មនសិការមូលកា ធម្មា អនិច្ចតោ យោនិសោ មនសិករោតោ ចាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កា-យោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិ-នោ ចិត្តំ សមាធិយតិ សមាហិតេន ចិត្តេន ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថា-ភូតំ បជានាតិ ទុក្ខតោ យោនិសោ មនសិករោតោ ចាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ សមាហិតេន ចិត្តេន ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុ-ទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ អនត្តតោ យោនិសោ មនសិ-ករោតោ ចាមុជ្ជំ ជាយតិ ។ បេ ។ រូបំ អនិច្ចតោ យោនិសោ មនសិករោតោ ចាមុជ្ជំ ជាយតិ

[១៨៣] ធម៌ ៩ មានការធ្វើទុកក្នុងចិត្តដោយត្រូវទំនងជាមូល គឺ កាលបុគ្គលធ្វើទុកក្នុងចិត្តដោយត្រូវទំនង ថាមិនទៀង បាមុជ្ជៈរមែង កើត កាលបុគ្គលមានចិត្តរីករាយហើយ បីតិ រមែងកើត កាល បុគ្គលមានចិត្តប្រកបដោយបីតិ កាយរមែងស្ងប់ បុគ្គលមានកាយស្ងប់ រមែងទទួលនូវសេចក្តីសុខ កាលបុគ្គលមានសេចក្តីសុខ ចិត្តរមែង តាំងមាំ បុគ្គលដែលមានចិត្តតាំងមាំ រមែងដឹងច្បាស់តាមពិតថា នេះ ជាទុក្ខ រមែងដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ រមែង ដឹងច្បាស់តាមពិតថា នេះជាទីរំលត់ទុក្ខ រមែងដឹងច្បាស់តាមពិតថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរំលត់ទុក្ខ កាលបុគ្គលធ្វើទុកក្នុង ចិត្ត ដោយត្រូវទំនងថាជាទុក្ខ បាមុជ្ជៈ រមែងកើត កាលបុគ្គលមាន ចិត្តរីករាយហើយ បីតិរមែងកើត កាលបុគ្គលមានចិត្តប្រកបដោយ បីតិ កាយរមែងស្ងប់ បុគ្គលមានកាយស្ងប់ រមែងទទួលនូវសុខ កាល បុគ្គលមានសេចក្តីសុខ ចិត្តរមែងតម្កល់មាំ បុគ្គលមានចិត្តតម្កល់មាំ រមែងដឹងច្បាស់តាមពិតថា នេះជាទុក្ខ រមែងដឹងច្បាស់តាមពិតថា នេះ ជាហេតុនាំឲ្យកើតទុក្ខ រមែងដឹងច្បាស់តាមពិតថា នេះជាបដិបទាជា ដំណើរទៅកាន់ទីរំលត់ទុក្ខ កាលបុគ្គលធ្វើទុកក្នុងចិត្ត ដោយត្រូវទំនង ថាជាអនត្តា បាមុជ្ជៈរមែងកើត ។ បេ ។ កាលបុគ្គលធ្វើទុកក្នុងចិត្ត នូវរូប ដោយត្រូវទំនង ថាមិនទៀង បាមុជ្ជៈ រមែងកើត

រូបំ ទុក្ខតោ យោនិសោ មនសិករោតោ បាមុជ្ជំ ជាយ-
តិ រូបំ អនត្តតោ យោនិសោ មនសិករោតោ បាមុ-
ជ្ជំ ជាយតិ ។ បេ ។ វេទនំ សញ្ញំ សង្ខារេ វិញ្ញា-
ណំ ចក្ខុំ ។ បេ ។ ជរាមរណំ អនិច្ចតោ យោនិ-
សោ មនសិករោតោ បាមុជ្ជំ ជាយតិ ជរាមរណំ
ទុក្ខតោ យោនិសោ មនសិករោតោ បាមុជ្ជំ ជា-
យតិ ។ បេ ។ ជរាមរណំ អនត្តតោ យោនិសោ
មនសិករោតោ បាមុជ្ជំ ជាយតិ បមុទិតស្ស បីតិ
ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកា-
យោ សុខំ វេទេតិ សុខិនោ ចិត្តំ សមាធិយតិ
សមាហិតេន ចិត្តេន ឥទំ ទុក្ខន្តិ យថាភូតំ
បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ
អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ
ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ
ឥមេ នវ យោនិសោ មនសិការមូលកា ធម្មា ។

[១៨៤] នវ នានត្តា ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ
ផស្សនានត្តំ ផស្សនានត្តំ បដិច្ច ឧប្បជ្ជតិ វេទនានានត្តំ

កាលបុគ្គលធ្វើទុកក្នុងចិត្ត នូវរូបដោយត្រូវទំនង ថាជាទុក្ខ បាមុជ្ជៈ រមែងកើត កាលបុគ្គលធ្វើទុកក្នុងចិត្តនូវរូប ដោយត្រូវទំនង ថាជាអនត្តា បាមុជ្ជៈ រមែងកើត ។ បេ ។ កាលបុគ្គល ធ្វើទុកក្នុងចិត្ត នូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ នូវជរាមរណៈ ដោយត្រូវទំនង ថាជារបស់មិនទៀង បាមុជ្ជៈ រមែងកើត កាលបុគ្គលធ្វើទុកក្នុងចិត្តនូវជរា-មរណៈ ដោយត្រូវទំនង ថាជាទុក្ខ បាមុជ្ជៈ រមែងកើត ។ បេ ។ កាលបុគ្គលធ្វើទុកក្នុងចិត្តនូវជរាមរណៈ ដោយត្រូវទំនង ថាជាអនត្តា បាមុជ្ជៈ រមែងកើត កាលបុគ្គលមានចិត្តរីករាយហើយ បីតិរមែងកើត កាលបុគ្គលមានចិត្តប្រកបដោយបីតិ កាយរមែងស្ងប់ បុគ្គលមានកាយស្ងប់ រមែងទទួលនូវសេចក្ដីសុខ កាលបុគ្គលមានសេចក្ដីសុខ ចិត្តរមែងតម្កល់មាំ បុគ្គលមានចិត្តតម្កល់មាំ រមែងដឹងច្បាស់តាមពិតថា នេះជាសេចក្ដីទុក្ខ រមែងដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ រមែងដឹងច្បាស់តាមពិតថា នេះជាទីរំលត់ទុក្ខ រមែងដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ នេះធម៌ ៩ ដែលមានការធ្វើទុកក្នុងចិត្តដោយត្រូវទំនង ជាមូល ។

[១៨២] សេចក្ដីផ្សេង ៗ មាន ៩ គឺ សេចក្ដីផ្សេង ៗ គឺផស្សៈ កើតឡើង ព្រោះអាស្រ័យសេចក្ដីផ្សេង។ គឺធាតុ សេចក្ដីផ្សេង ៗ គឺវេទនា កើតឡើង ព្រោះអាស្រ័យសេចក្ដីផ្សេង ៗ គឺផស្សៈ

វេទនានានត្តំ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ សង្កប្បនានត្តំ សង្កប្បនានត្តំ បដិច្ច ឧប្បជ្ជតិ ឆន្ទនានត្តំ ឆន្ទនានត្តំ បដិច្ច ឧប្បជ្ជតិ បរិឡាហនានត្តំ បរិឡាហនានត្តំ បដិច្ច ឧប្បជ្ជតិ បរិយេសនានានត្តំ បរិយេសនានានត្តំ បដិច្ច ឧប្បជ្ជតិ លាភនានត្តំ ឥមេ នវ នានត្តា តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ នវធម្មវវត្ថានេ បញ្ញា ធម្មនានត្តេ ញាណំ ។

[១៨៤] កថំ អភិញ្ញាបញ្ញា ញាតដ្ឋេ ញាណំ បរិញ្ញាបញ្ញា តីរណដ្ឋេ ញាណំ បហានេបញ្ញា បរិច្ចាគដ្ឋេ ញាណំ ភាវនាបញ្ញា ឯករសដ្ឋេ ញាណំ សច្ឆិកិរិយាបញ្ញា ផស្សនដ្ឋេ ញាណំ ។ យេ យេ ធម្មា អភិញ្ញាតា ហោន្តិ តេ តេ ធម្មា ញាតា ហោន្តិ យេ យេ ធម្មា បរិញ្ញាតា ហោន្តិ តេ តេ ធម្មា តីរិតា ហោន្តិ យេ យេ ធម្មា បហីនា ហោន្តិ

សេចក្ដីផ្សេង ៗ គឺសញ្ញា កើតឡើងព្រោះអាស្រ័យសេចក្ដីផ្សេង ៗ គឺវេទនា សេចក្ដីផ្សេង ៗ គឺសង្កប្បៈ កើតឡើង ព្រោះអាស្រ័យសេចក្ដីផ្សេង ៗ គឺសញ្ញា សេចក្ដីផ្សេង ៗ គឺឆន្ទៈ កើតឡើងព្រោះអាស្រ័យសេចក្ដីផ្សេង ៗ គឺសង្កប្បៈ សេចក្ដីផ្សេង ៗ គឺបរិឡាហៈ (ការក្ដៅក្រហាយ) កើតឡើងព្រោះអាស្រ័យសេចក្ដីផ្សេង ៗ គឺឆន្ទៈ សេចក្ដីផ្សេង ៗ គឺបរិយេសនា (ការស្វែងរក) កើតឡើងព្រោះអាស្រ័យសេចក្ដីផ្សេង ៗ គឺបរិឡាហៈ សេចក្ដីផ្សេង ៗ គឺលាភ កើតឡើងព្រោះអាស្រ័យសេចក្ដីផ្សេង ៗ គឺបរិយេសនា នេះសេចក្ដីផ្សេង ៗ ៩ ដែលឈ្មោះថាញាណដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការកំណត់នូវធម៌ ៩ យ៉ាង ឈ្មោះថាធម្មនានត្តញ្ញាណ ។

[១៨៥] បញ្ញាដែលជាគ្រឿងដឹងដ៏ប្រសើរ ឈ្មោះថាញាតដ្ឋញ្ញាណ បញ្ញាសម្រាប់ដឹងជ្រួតជ្រាប ឈ្មោះថាតីរណដ្ឋញ្ញាណ បញ្ញាសម្រាប់លះ ឈ្មោះថា បរិច្ចាគដ្ឋញ្ញាណ បញ្ញាជាគ្រឿងអប់រំ ឈ្មោះថាឯករសដ្ឋញ្ញាណ បញ្ញាជាគ្រឿងធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាផស្សនដ្ឋញ្ញាណ តើដូចម្ដេច ។ ពួកធម៌ណា ៗ ដែលបុគ្គលដឹងច្បាស់ហើយ ពួកធម៌នោះ ៗ ឈ្មោះថាបុគ្គលដឹងហើយ ពួកធម៌ណា ៗ ដែលបុគ្គលកំណត់ដឹងហើយ ពួកធម៌នោះ ៗ ឈ្មោះថាបុគ្គលពិចារណាហើយ ពួកធម៌ណា ៗ ដែលបុគ្គលលះបង់ហើយ

តេ តេ ធម្មា បរិច្ចត្តា ហោន្តិ យេ យេ ធម្មា ភាវិតា ហោន្តិ តេ តេ ធម្មា ឯករសា ហោន្តិ យេ យេ ធម្មា សច្ឆិកតា ហោន្តិ តេ តេ ធម្មា ផុសិតា ហោន្តិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ អភិញ្ញាបញ្ញា ញាតដ្ឋេ ញាណំ បរិញ្ញាបញ្ញា តីរណដ្ឋេ ញាណំ បហានប្បញ្ញា បរិច្ចាគដ្ឋេ ញាណំ ភាវនាបញ្ញា ឯករសដ្ឋេ ញាណំ សច្ឆិកិរិយាបញ្ញា ផស្សនដ្ឋេ ញាណំ ។

[១៨៦] កថំ អត្ថនានត្តេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ធម្មនានត្តេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ និរុត្តិនានត្តេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ បដិភាណនានត្តេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ ។

សទ្ធិន្ទ្រិយំ ធម្មោ វីរិយិន្ទ្រិយំ ធម្មោ សតិន្ទ្រិយំ ធម្មោ សមាធិន្ទ្រិយំ ធម្មោ បញ្ញិន្ទ្រិយំ ធម្មោ អញ្ញោ សទ្ធិន្ទ្រិយំ ធម្មោ អញ្ញោ វីរិយិន្ទ្រិយំ ធម្មោ អញ្ញោ សតិន្ទ្រិយំ ធម្មោ អញ្ញោ សមាធិន្ទ្រិយំ ធម្មោ អញ្ញោ បញ្ញិន្ទ្រិយំ ធម្មោ យេន ញាណេន ឥមេ នានា

ពួកធម៌នោះ ៗ ឈ្មោះថាបុគ្គលលះស្រឡះហើយ ពួកធម៌ណា ៗ ដែលបុគ្គលចម្រើនហើយ ពួកធម៌នោះ ៗ ឈ្មោះថាមានរសតែមួយ ពួកធម៌ណា ៗ ដែលបុគ្គលធ្វើឲ្យជាក់ច្បាស់ហើយ ពួកធម៌នោះ ៗ ឈ្មោះថាបុគ្គលប៉ះពាល់ហើយ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះលោកពោលថា បញ្ញាជាគ្រឿងដឹងដ៏ប្រសើរ ឈ្មោះថាញាតដ្ឋញ្ញាណ បញ្ញាសម្រាប់ដឹងជ្រួតជ្រាប ឈ្មោះថាតីរណដ្ឋញ្ញាណ បញ្ញាសម្រាប់លះ ឈ្មោះថាបរិច្ចាគដ្ឋញ្ញាណ បញ្ញាជាគ្រឿងអប់រំ ឈ្មោះថាឯករសដ្ឋញ្ញាណ បញ្ញាជាគ្រឿងធ្វើឲ្យជាក់ច្បាស់ ឈ្មោះថាផស្សនដ្ឋញ្ញាណ ។

[១៨៦] បញ្ញាក្នុងអត្ថផ្សេង ៗ ឈ្មោះថាអត្ថប្បដិសម្ភិទាញាណ បញ្ញា ក្នុងធម៌ផ្សេង ៗ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ បញ្ញាក្នុងនិរុត្តិផ្សេងៗ ឈ្មោះថានិរុត្តិបដិសម្ភិទាញាណ បញ្ញាក្នុងបដិភាណផ្សេង ៗ ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ តើដូចម្តេច ។

ធម៌គឺសទ្ធិន្ទ្រិយ ធម៌គឺវីរិយិន្ទ្រិយ ធម៌គឺសតិន្ទ្រិយ ធម៌គឺសមាធិន្ទ្រិយ ធម៌គឺបញ្ញិន្ទ្រិយ ធម៌គឺសទ្ធិន្ទ្រិយផ្សេង ធម៌គឺវីរិយិន្ទ្រិយផ្សេង ធម៌គឺសតិន្ទ្រិយផ្សេង ធម៌គឺសមាធិន្ទ្រិយផ្សេង ធម៌គឺបញ្ញិន្ទ្រិយផ្សេង ពួកធម៌ផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា

ធម្មា ញាតា តេនេវ ញាណេន ឥមេ នានា ធម្មា បដិវិទិតាតិ តេន វុច្ចតិ ធម្មនានត្តេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ ។

[១៨៧] អធិមោក្ខដ្ឋោ អត្ថោ បគ្គហដ្ឋោ អត្ថោ ឧបដ្ឋានដ្ឋោ អត្ថោ អវិក្ខេបដ្ឋោ អត្ថោ ទស្សនដ្ឋោ អត្ថោ អញ្ញោ អធិមោក្ខដ្ឋោ អត្ថោ អញ្ញោ បគ្គហដ្ឋោ អត្ថោ អញ្ញោ ឧបដ្ឋានដ្ឋោ អត្ថោ អញ្ញោ អវិក្ខេបដ្ឋោ អត្ថោ អញ្ញោ ទស្សនដ្ឋោ អត្ថោ យេន ញាណេន ឥមេ នានា អត្ថា ញាតា តេនេវ ញាណេន ឥមេ នានា អត្ថា បដិវិទិតាតិ តេន វុច្ចតិ អត្ថនានត្តេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ។

[១៨៨] បញ្ច ធម្មេ សន្ទស្សេតុំ ព្យញ្ជននិរុត្តាភិលាបា បញ្ច អត្ថេ សន្ទស្សេតុំ ព្យញ្ជននិរុត្តាភិលាបា អញ្ញា ធម្មនិរុត្តិយោ អញ្ញា អត្ថនិរុត្តិយោ យេន ញាណេន ឥមា នានា និរុត្តិយោ ញាតា តេនេវ ញាណេន ឥមា នានា និរុត្តិយោ បដិវិទិតាតិ តេន វុច្ចតិ និរុត្តិនានត្តេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ ។

ពួកធម៌ផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងធម៌ផ្សេង ៗ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ។

[១៨៧] អត្ថគឺសេចក្ដីនៃការជឿស៊ប់ អត្ថគឺសេចក្ដីនៃការផ្គងឡើង អត្ថគឺសេចក្ដីនៃការប្រុងប្រយ័ត្ន អត្ថគឺសេចក្ដីនៃការមិនរាយមាយ អត្ថគឺសេចក្ដីនៃការឃើញ អត្ថគឺសេចក្ដីនៃការជឿស៊ប់ផ្សេង អត្ថគឺសេចក្ដីនៃការផ្គងឡើងផ្សេង អត្ថគឺសេចក្ដីនៃការប្រុងប្រយ័ត្នផ្សេង អត្ថគឺសេចក្ដីនៃការមិនរាយមាយផ្សេង អត្ថគឺសេចក្ដីនៃការឃើញផ្សេង អត្ថទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា អត្ថទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងអត្ថផ្សេង ៗ ឈ្មោះថាអត្ថប្បដិសម្ភិទាញាណ ។

[១៨៨] ការពោលដោយព្យញ្ជនៈនិងនិរុត្តិ ដើម្បីពន្យល់នូវធម៌ទាំង ៥ ការពោលដោយព្យញ្ជនៈនិងនិរុត្តិ ដើម្បីពន្យល់នូវអត្ថទាំង ៥ ធម្មនិរុត្តិផ្សេង អត្ថនិរុត្តិផ្សេង និរុត្តិទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា និរុត្តិទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងនិរុត្តិផ្សេង ៗ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ។

[១៨៩] បញ្ចសុ ធម្មេសុ ញាណានិ បញ្ចសុ អត្ថេសុ ញាណានិ ឆសុ និរុត្តីសុ ញាណានិ អញ្ញានិ ធម្មេសុ ញាណានិ អញ្ញានិ អត្ថេសុ ញាណានិ អញ្ញានិ និរុត្តីសុ ញាណានិ យេន ញាណេន ឥមេ នានា ញាណា ញាតា តេនេវ ញាណេន ឥមេ នានា ញាណា បដិវិទិតាតិ តេន វុច្ចតិ បដិភាណនានត្តេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ ។

[១៩០] សទ្ធាពលំ ធម្មោ វីរិយពលំ ធម្មោ សតិពលំ ធម្មោ សមាធិពលំ ធម្មោ បញ្ញាពលំ ធម្មោ អញ្ញោ សទ្ធាពលំ ធម្មោ អញ្ញោ វីរិយពលំ ធម្មោ អញ្ញោ សតិពលំ ធម្មោ អញ្ញោ សមាធិពលំ ធម្មោ អញ្ញោ បញ្ញាពលំ ធម្មោ យេន ញាណេន ឥមេ នានា ធម្មា ញាតា តេនេវ ញាណេន ឥមេ នានា ធម្មា បដិវិទិតាតិ តេន វុច្ចតិ ធម្មនានត្តេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ ។

[១៩១] អស្សទ្ធិយេ អកម្បិយដ្ឋោ អត្ថោ កោសជ្ជេ អកម្បិយដ្ឋោ អត្ថោ បមាទេ អកម្បិយដ្ឋោ អត្ថោ ឧទ្ធច្ចេ អកម្បិយដ្ឋោ អត្ថោ

[១៨៩] ពួកញាណក្នុងធម៌ទាំង ៥ ពួកញាណក្នុងអត្ថទាំង ៥ ពួកញាណក្នុងនិរុត្តិទាំង ១០ ពួកញាណក្នុងធម៌ទាំងឡាយផ្សេង ពួកញាណក្នុងអត្ថទាំងឡាយផ្សេង ពួកញាណក្នុងនិរុត្តិទាំងឡាយផ្សេង ពួកញាណផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា ពួកញាណផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយ ដោយញាណនោះ ហេតុនោះលោកពោលថា បញ្ញាក្នុងបដិភាណផ្សេង ៗ ឈ្មោះថាបដិភាណប្បដិ-សម្ភិទាញាណ ។

[១៩០] ធម៌គឺសទ្ធាពលៈ ធម៌គឺវិរិយពលៈ ធម៌គឺសតិពលៈ ធម៌គឺសមាធិពលៈ ធម៌គឺបញ្ញាពលៈ ធម៌គឺសទ្ធាពលៈផ្សេង ធម៌គឺវិរិយ-ពលៈផ្សេង ធម៌គឺសតិពលៈផ្សេង ធម៌គឺសមាធិពលៈផ្សេង ធម៌គឺបញ្ញា-ពលៈផ្សេង ពួកធម៌ផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា ពួកធម៌ផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះលោកពោលថា បញ្ញាក្នុងធម៌ផ្សេង ៗ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ។

[១៩១] អត្ថគឺសេចក្តីនៃការមិនញាប់ញ័រ ក្នុងអស្សទ្ធិយៈ(ការមិនជឿ) អត្ថគឺសេចក្តីនៃការមិនញាប់ញ័រ ក្នុងកោសជ្ជៈ អត្ថគឺសេចក្តីនៃការមិនញាប់ញ័រក្នុងបមាទៈ អត្ថគឺសេចក្តីនៃការមិនញាប់ញ័រ ក្នុងឧទ្ធច្ចៈ

អវិជ្ជាយ អកម្បិយដ្ឋោ អត្ថោ អញ្ញោ អស្សទ្ធិយេ អកម្បិយដ្ឋោ អត្ថោ អញ្ញោ កោសជ្ជេ អកម្បិ-យដ្ឋោ អត្ថោ អញ្ញោ បមាទេ អកម្បិយដ្ឋោ អត្ថោ អញ្ញោ ឧទ្ធច្ចេ អកម្បិយដ្ឋោ អត្ថោ អញ្ញោ អវិជ្ជាយ អកម្បិយដ្ឋោ អត្ថោ យេន ញាណេន ឥមេ នានា អត្ថា ញាតា តេនេវ ញាណេន ឥមេ នានា អត្ថា បដិវិទិតាតិ តេន វុច្ចតិ អត្ថនានត្តេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ។

[១៩២] បញ្ច ធម្មេ សន្ទស្សេតុំ ព្យញ្ជននិរុត្តា-ភិលាបា បញ្ច អត្ថេ សន្ទស្សេតុំ ព្យញ្ជននិរុត្តាភិលាបា អញ្ញា ធម្មនិរុត្តិយោ អញ្ញា អត្ថនិរុត្តិយោ យេន ញាណេន ឥមា នានា និរុត្តិយោ ញាតា តេនេវ ញាណេន ឥមា នានា និរុត្តិយោ បដិវិទិតាតិ តេន វុច្ចតិ និរុត្តិនានត្តេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ ។

[១៩៣] បញ្ចសុ ធម្មេសុ ញាណានិ បញ្ចសុ អត្ថេសុ ញាណានិ ទសសុ និរុត្តីសុ ញាណានិ អញ្ញានិ ធម្មេសុ ញាណានិ អញ្ញានិ អត្ថេសុ ញាណានិ អញ្ញានិ និរុត្តីសុ ញាណានិ

អត្ថគឺសេចក្តីនៃការមិនញាប់ញ័រក្នុងអវិជ្ជា អត្ថគឺសេចក្តីនៃការមិនញាប់ញ័រក្នុងអស្សទ្ធិយៈផ្សេង អត្ថគឺសេចក្តីនៃការមិនញាប់ញ័រក្នុងកោសជ្ជៈផ្សេង អត្ថគឺសេចក្តីនៃការមិនញាប់ញ័រក្នុងបមាទៈផ្សេង អត្ថគឺសេចក្តីនៃការមិនញាប់ញ័រក្នុងឧទ្ធច្ចៈផ្សេង អត្ថគឺសេចក្តីនៃការមិនញាប់ញ័រក្នុងអវិជ្ជាផ្សេង អត្ថទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា អត្ថទាំង-ឡាយផ្សេងៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងអត្ថផ្សេង ៗ ឈ្មោះថាអត្ថប្បដិសម្ភិទាញាណ ។

[១៩២] ការពោលដោយព្យញ្ជនៈនិងនិរុត្តិ ដើម្បីពន្យល់នូវធម៌ទាំង ៥ ការពោលដោយព្យញ្ជនៈនិងនិរុត្តិ ដើម្បីពន្យល់នូវអត្ថទាំង ៥ ធម្មនិរុត្តិផ្សេង អត្ថនិរុត្តិផ្សេង និរុត្តិទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា និរុត្តិទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងនិរុត្តិផ្សេង ៗ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ។

[១៩៣] ពួកញាណក្នុងធម៌ទាំង ៥ ពួកញាណក្នុងអត្ថទាំង ៥ ពួកញាណក្នុងនិរុត្តិទាំង ១០ ពួកញាណក្នុងធម៌ទាំងឡាយផ្សេង ពួកញាណក្នុងអត្ថទាំងឡាយផ្សេង ពួកញាណ ក្នុងនិរុត្តិទាំងឡាយផ្សេង

យេន ញាណេន ឥមេ នានា ញាណា ញាតា តេនេវ ញាណេន ឥមេ នានា ញាណា បដិវិទិតាតិ តេន វុច្ចតិ បដិភាណនានត្តេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ ។

[១៩៤] សតិសម្ពោជ្ឈង្គោ ធម្មោ ធម្មវិចយសម្ពោជ្ឈង្គោ ធម្មោ វីរិយសម្ពោជ្ឈង្គោ ធម្មោ បីតិសម្ពោជ្ឈង្គោ ធម្មោ បស្សទ្ធិសម្ពោជ្ឈង្គោ ធម្មោ សមាធិសម្ពោជ្ឈង្គោ ធម្មោ ឧបេក្ខាសម្ពោជ្ឈង្គោ ធម្មោ អញ្ញោ សតិសម្ពោជ្ឈង្គោ ធម្មោ អញ្ញោ ធម្មវិចយសម្ពោជ្ឈង្គោ ធម្មោ អញ្ញោ វីរិយសម្ពោជ្ឈង្គោ ធម្មោ អញ្ញោ បីតិសម្ពោជ្ឈង្គោ ធម្មោ អញ្ញោ បស្សទ្ធិសម្ពោជ្ឈង្គោ ធម្មោ អញ្ញោ សមាធិសម្ពោជ្ឈង្គោ ធម្មោ អញ្ញោ ឧបេក្ខាសម្ពោជ្ឈង្គោ ធម្មោ យេន ញាណេន ឥមេ នានា ធម្មា ញាតា តេនេវ ញាណេន ឥមេ នានា ធម្មា បដិវិទិតាតិ តេន វុច្ចតិ ធម្មនានត្តេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ ។

[១៩៥] ឧបដ្ឋានដ្ឋោ អត្ថោ បរិចយដ្ឋោ អត្ថោ

ញាណទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងហើយ ដោយញាណណា ញាណទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយ ដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងបដិភាណផ្សេងៗ ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ ។

[១៩៤] ធម៌គឺសតិសម្ពោជ្ឈង្គ ធម៌គឺធម្មវិចយសម្ពោជ្ឈង្គ ធម៌គឺវីរិយសម្ពោជ្ឈង្គ ធម៌គឺបីតិសម្ពោជ្ឈង្គ ធម៌គឺបស្សទ្ធិសម្ពោជ្ឈង្គ ធម៌គឺសមាធិសម្ពោជ្ឈង្គ ធម៌គឺឧបេក្ខាសម្ពោជ្ឈង្គ ធម៌គឺសតិសម្ពោជ្ឈង្គផ្សេង ធម៌គឺធម្មវិចយសម្ពោជ្ឈង្គផ្សេង ធម៌គឺវីរិយសម្ពោជ្ឈង្គផ្សេង ធម៌គឺបីតិសម្ពោជ្ឈង្គផ្សេង ធម៌គឺបស្សទ្ធិសម្ពោជ្ឈង្គផ្សេង ធម៌គឺសមាធិសម្ពោ-ជ្ឈង្គផ្សេង ធម៌គឺឧបេក្ខាសម្ពោជ្ឈង្គផ្សេង ពួកធម៌ផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា ពួកធម៌ផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងធម៌ផ្សេង ៗ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ។

[១៩៥] អត្ថគឺសេចក្តីនៃការប្រុងប្រយ័ត្ន អត្ថគឺសេចក្តីនៃការជ្រើសរើស

បក្គហដ្ឋោ អត្ថោ ផរណដ្ឋោ អត្ថោ ឧបសមដ្ឋោ អត្ថោ អវិក្ខេបដ្ឋោ អត្ថោ បដិសង្ខានដ្ឋោ អត្ថោ អញ្ញោ ឧបដ្ឋានដ្ឋោ អត្ថោ អញ្ញោ បវិចយដ្ឋោ អត្ថោ អញ្ញោ បក្គហដ្ឋោ អត្ថោ អញ្ញោ ផរណដ្ឋោ អត្ថោ អញ្ញោ ឧបសមដ្ឋោ អត្ថោ អញ្ញោ អវិក្ខេបដ្ឋោ អត្ថោ អញ្ញោ បដិសង្ខានដ្ឋោ អត្ថោ យេន ញាណេន ឥមេ នានា អត្ថា ញាតា តេនេវ ញាណេន ឥមេ នានា អត្ថា បដិវិទិតាតិ តេន វុច្ចតិ អត្ថនានត្តេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ។

[១៩៦] សត្ត ធម្មេ សន្ទស្សេតុំ ព្យញ្ជននិរុត្តាភិលាបា សត្ត អត្ថេ សន្ទស្សេតុំ ព្យញ្ជននិរុត្តាភិលាបា អញ្ញា ធម្មនិរុត្តិយោ អញ្ញា អត្ថនិរុត្តិយោ យេន ញាណេន ឥមា នានា និរុត្តិយោ ញាតា តេនេវ ញាណេន ឥមា នានា និរុត្តិយោ បដិវិទិតាតិ តេន វុច្ចតិ និរុត្តិនានត្តេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ ។

[១៩៧] សត្តសុ ធម្មេសុ ញាណានិ សត្តសុ អត្ថេសុ ញាណានិ ចុទ្ទសសុ និរុត្តីសុ ញាណានិ អញ្ញានិ ធម្មេសុ ញាណានិ

អត្ថគឺសេចក្តីនៃការផ្គងឡើង អត្ថគឺសេចក្តីនៃការផ្សាយ អត្ថគឺសេចក្តីនៃការស្ងប់ អត្ថគឺសេចក្តីនៃការមិនរាយមាយ អត្ថគឺសេចក្តីនៃការពិចារណា អត្ថគឺសេចក្តីនៃការប្រុងប្រយ័ត្នផ្សេង អត្ថគឺសេចក្តីនៃការជ្រើសរើសផ្សេង អត្ថគឺសេចក្តីនៃការផ្គងឡើងផ្សេង អត្ថគឺសេចក្តីនៃការផ្សាយផ្សេង អត្ថគឺសេចក្តីនៃការស្ងប់ផ្សេង អត្ថគឺសេចក្តីនៃការមិនរាយមាយផ្សេង អត្ថគឺសេចក្តីនៃការពិចារណាផ្សេង អត្ថទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា អត្ថទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងអត្ថផ្សេង ៗ ឈ្មោះថាអត្ថប្បដិសម្ភិទាញាណ ។

[១៩៦] ការពោលដោយព្យញ្ជនៈនិងនិរុត្តិ ដើម្បីពន្យល់នូវធម៌ទាំង ៧ ការពោលដោយព្យញ្ជនៈនិងនិរុត្តិ ដើម្បីពន្យល់នូវអត្ថទាំង ៧ ធម្មនិរុត្តិផ្សេង អត្ថនិរុត្តិផ្សេង និរុត្តិទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា និរុត្តិទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងនិរុត្តិផ្សេង ៗ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ។

[១៩៧] ពួកញាណក្នុងធម៌ទាំង ៧ ពួកញាណក្នុងអត្ថទាំង ៧ ពួកញាណ ក្នុងនិរុត្តិទាំង ១៤ ពួកញាណក្នុងធម៌ទាំងឡាយ ផ្សេង

អញ្ញានិ អត្ថេសុ ញាណានិ អញ្ញានិ និរុត្តីសុ ញាណានិ យេន ញាណេន ឥមេ នានា ញាណា ញាតា តេនេវ ញាណេន ឥមេ នានា ញាណា បដិវិទិតាតិ តេន វុច្ចតិ បដិភាណនានត្តេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ ។

[១៩៨] សម្មាទិដ្ឋិ ធម្មោ សម្មាសង្កប្បោ ធម្មោ សម្មាវាចា ធម្មោ សម្មាកម្មន្តោ ធម្មោ សម្មាអាជីវោ ធម្មោ សម្មាវាយាមោ ធម្មោ សម្មាសតិ ធម្មោ សម្មាសមាធិ ធម្មោ អញ្ញោ សម្មាទិដ្ឋិ ធម្មោ អញ្ញោ សម្មាសង្កប្បោ ធម្មោ អញ្ញោ សម្មាវាចា ធម្មោ អញ្ញោ សម្មាកម្មន្តោ ធម្មោ អញ្ញោ សម្មាអាជីវោ ធម្មោ អញ្ញោ សម្មាវាយាមោ ធម្មោ អញ្ញោ សម្មាសតិ ធម្មោ អញ្ញោ សម្មាសមាធិ ធម្មោ យេន ញាណេន ឥមេ នានា ធម្មា ញាតា តេនេវ ញាណេន ឥមេ នានា ធម្មា បដិវិទិតាតិ តេន វុច្ចតិ ធម្មនានត្តេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ ។

[១៩៩] ឧបដ្ឋានដ្ឋោ អត្ថោ អភិនិរោបនដ្ឋោ អត្ថោ

ពួកញាណក្នុងអត្ថទាំងឡាយផ្សេង ពួកញាណក្នុងនិរុត្តិទាំងឡាយផ្សេង ញាណទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងហើយ ដោយញាណណា ញាណទាំងឡាយ ផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយ ដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងបដិភាណផ្សេង ៗ ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ ។

[១៩៨] ធម៌គឺសម្មាទិដ្ឋិ ធម៌គឺសម្មាសង្កប្បៈ ធម៌គឺសម្មាវាចា ធម៌គឺសម្មាកម្មន្តៈ ធម៌គឺសម្មាអាជីវៈ ធម៌គឺសម្មាវាយាមៈ ធម៌គឺសម្មាសតិ ធម៌គឺសម្មាសមាធិ ធម៌គឺសម្មាទិដ្ឋិផ្សេង ធម៌គឺសម្មាសង្កប្បៈផ្សេង ធម៌គឺសម្មាវាចាផ្សេង ធម៌គឺសម្មាកម្មន្តៈផ្សេង ធម៌គឺសម្មាអាជីវៈផ្សេង ធម៌គឺសម្មាវាយាមៈផ្សេង ធម៌គឺសម្មាសតិផ្សេង ធម៌គឺសម្មាសមាធិផ្សេង ធម៌ទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា ធម៌ទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងធម៌ផ្សេង ៗ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ។

[១៩៩] អត្ថគឺសេចក្តីនៃការឃើញ អត្ថគឺសេចក្តីនៃការលើកចិត្តឡើង

បរិគ្គហដ្ឋោ អត្ថោ សមុដ្ឋានដ្ឋោ អត្ថោ បហានដ្ឋោ អត្ថោ បគ្គហដ្ឋោ អត្ថោ ឧបដ្ឋានដ្ឋោ អត្ថោ អវិក្ខេបដ្ឋោ អត្ថោ អញ្ញោ ទស្សនដ្ឋោ អត្ថោ អញ្ញោ អភិនិរោបនដ្ឋោ អត្ថោ អញ្ញោ បរិគ្គហដ្ឋោ អត្ថោ អញ្ញោ សមុដ្ឋានដ្ឋោ អត្ថោ អញ្ញោ បហានដ្ឋោ អត្ថោ អញ្ញោ បគ្គហដ្ឋោ អត្ថោ អញ្ញោ ឧបដ្ឋានដ្ឋោ អត្ថោ អញ្ញោ អវិក្ខេបដ្ឋោ អត្ថោ យេន ញាណេន ឥមេ នានា អត្ថា ញាតា តេនេវ ញាណេន ឥមេ នានា អត្ថា បដិវិទិតាតិ តេន វុច្ចតិ អត្ថនានត្តេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ។

[២០០] អដ្ឋ ធម្មេ សន្ទស្សេតុំ ព្យញ្ជននិរុត្តាភិលាបា អដ្ឋ អត្ថេ សន្ទស្សេតុំ ព្យញ្ជននិរុត្តាភិលាបា អញ្ញា ធម្មនិរុត្តិយោ អញ្ញា អត្ថនិរុត្តិយោ យេន ញាណេន ឥមា នានា និរុត្តិយោ ញាតា តេនេវ ញាណេន ឥមា នានា និរុត្តិយោ បដិវិទិតាតិ តេន វុច្ចតិ និរុត្តិនានត្តេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ ។

(កាន់អារម្មណ៍) អត្ថគឺសេចក្តីនៃការរក្សាទុក អត្ថគឺសេចក្តីនៃការតាំងឡើងព្រម អត្ថគឺសេចក្តីនៃការផ្សំផង់ អត្ថគឺសេចក្តីនៃការផ្គងឡើង អត្ថគឺសេចក្តីនៃការប្រុងប្រយ័ត្ន អត្ថគឺសេចក្តីនៃការមិនរាយមាយ អត្ថគឺសេចក្តីនៃការឃើញជាទៃ អត្ថគឺសេចក្តីនៃការលើកចិត្តឡើង (កាន់អារម្មណ៍)ផ្សេង អត្ថគឺសេចក្តីនៃការរក្សាទុកផ្សេង អត្ថគឺសេចក្តីនៃការតាំងឡើងព្រមផ្សេង អត្ថគឺសេចក្តី នៃការផ្សំផង់ផ្សេង អត្ថគឺសេចក្តីនៃការផ្គងឡើងផ្សេង អត្ថគឺសេចក្តីនៃការប្រុងប្រយ័ត្នផ្សេង អត្ថគឺសេចក្តីនៃការមិនរាយមាយផ្សេង អត្ថទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា អត្ថទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងអត្ថផ្សេង ៗ ឈ្មោះថាអត្ថប្បដិ-សម្ភិទាញាណ ។

[២០០] ការពោលដោយព្យញ្ជនៈនិងនិរុត្តិ ដើម្បីពន្យល់នូវធម៌ទាំង ៨ ការពោលដោយព្យញ្ជនៈនិងនិរុត្តិ ដើម្បីពន្យល់នូវអត្ថទាំង ៨ ធម្មនិរុត្តិផ្សេង អត្ថនិរុត្តិផ្សេង និរុត្តិទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា និរុត្តិទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងនិរុត្តិផ្សេង ៗ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ។

[២០១] អជ្ឈត្តុ ធម្មេសុ ញាណានិ អជ្ឈត្តុ អត្ថេសុ ញាណានិ សោឡសសុ និរុត្តីសុ ញាណា-និ អញ្ញានិ ធម្មេសុ ញាណានិ អញ្ញានិ អត្ថេសុ ញាណានិ អញ្ញានិ និរុត្តីសុ ញាណានិ យេន ញាណេន ឥមេ នានា ញាណា ញាតា តេនេវ ញាណេន ឥមេ នានា ញាណា បដិវិទិតាតិ តេន វុច្ចតិ បដិភាណនានត្តេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ អត្ថនានត្តេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ធម្មនានត្តេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ និរុត្តិនានត្តេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ បដិ-ភាណនានត្តេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ ។

[២០២] កថំ វិហារនានត្តេ បញ្ញា វិហារដ្ឋេ ញាណំ សមាបត្តិនានត្តេ បញ្ញា សមាបត្តដ្ឋេ ញាណំ វិហារសមាបត្តិនានត្តេ បញ្ញា វិហារសមាបត្តដ្ឋេ ញាណំ ។

[២០១] ពួកញាណក្នុងធម៌ទាំង ៨ ពួកញាណក្នុងអត្ថទាំង ៨ ពួកញាណក្នុងនិរុត្តិទាំង ១៦ ពួកញាណក្នុងធម៌ទាំងឡាយផ្សេង ពួកញាណក្នុងអត្ថទាំងឡាយផ្សេង ពួកញាណក្នុងនិរុត្តិទាំងឡាយផ្សេង ញាណទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងហើយដោយញាណណា ញាណទាំងឡាយផ្សេង ៗ នេះ បុគ្គលដឹងច្បាស់ហើយ ដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងបដិភាណផ្សេង ៗ ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ព្រោះហេតុនោះ លោកពោលថា បញ្ញាក្នុងអត្ថផ្សេង ៗ ឈ្មោះថាអត្ថប្បដិសម្ភិទាញាណ បញ្ញាក្នុងធម៌ផ្សេង ៗ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ បញ្ញាក្នុងនិរុត្តិផ្សេង ៗ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ បញ្ញាក្នុងបដិភាណផ្សេង ៗ ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ ។

[២០២] បញ្ញាក្នុងវិបស្សនាវិហារផ្សេង ៗ ឈ្មោះថាវិហារដ្ឋញ្ញាណ បញ្ញាក្នុងផលសមាបត្តិផ្សេង ៗ ឈ្មោះថាសមាបត្តដ្ឋញ្ញាណ បញ្ញាក្នុងវិហារសមាបត្តិផ្សេង ៗ ឈ្មោះថាវិហារសមាបត្តដ្ឋញ្ញាណ តើដូចម្តេច ។

និមិត្តំ ភយតោ សម្បស្សមានោ អនិមិត្តេ អធិ-មុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ អនិមិត្តោ វិហា-រោ បណិធឹ ភយតោ សម្បស្សមានោ អប្បណិហិតេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ អប្បណិហិតោ វិហារោ អភិនិវេសំ ភយតោ សម្បស្សមានោ សុញ្ញតេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ សុញ្ញតោ វិហារោ ។

[២០៣] និមិត្តំ ភយតោ សម្បស្សមានោ អនិមិត្តេ អ-ធិមុត្តត្តា បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ អនិមិត្តំ អា-វជ្ជិត្វា សមាបជ្ជតិ អនិមិត្តា សមាបត្តិ បណិធឹ ភយតោ

បុគ្គលកាលពិចារណាឃើញ នូវនិមិត្តថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលមិនមាននិមិត្ត ឈ្មោះថាអនិមិត្តវិហារធម៌ (សភាវៈជាទីសម្រាកមិនមានកិលេសជានិមិត្ត) បុគ្គលកាលពិចារណាឃើញនូវបណិធិ (ធម្មជាតិមានកិលេសជាទីតាំង) ថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលមិនមានកិលេសជាទីតាំង ឈ្មោះថាអប្បណិហិតវិហារធម៌ (សភាវៈជាទីសម្រាកមិនមានកិលេសជាទីតាំង) បុគ្គលកាលពិចារណាឃើញនូវអភិនិវេសៈ (ការប្រកាន់មាំ) ថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលសូន្យចាកកិលេស ឈ្មោះថាសុញ្ញតវិហារធម៌ (សភាវៈជាទីសម្រាកសូន្យចាកអត្តា) ។

[២០៣] បុគ្គលកាលពិចារណាឃើញនូវនិមិត្តថាគួរខ្លាច រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលមិនមាននិមិត្ត ហើយពិចារណានូវធម៌មិនមាននិមិត្ត គឺនិព្វានដែលជាទីរលត់ទុក្ខ ហើយចូល (កាន់ផលសមាបត្តិ) ឈ្មោះថាអនិមិត្តសមាបត្តិ (សមាបត្តិមិនមានកិលេសជានិមិត្ត) បុគ្គលកាលពិចារណាឃើញនូវបណិធិ ថាគួរខ្លាច

សម្បស្សមានោ អប្បណិហិតេ អធិមុត្តត្តា បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ អប្បណិហិតំ អាវជ្ជិត្វា សមាបជ្ជតិ អប្បណិហិតា សមាបត្តិ អភិនិវេសំ ភយតោ សម្បស្សមានោ សុញ្ញតេ អធិមុត្តត្តា បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ សុញ្ញតំ អាវជ្ជិត្វា សមាបជ្ជតិ សុញ្ញតា សមាបត្តិ ។

[២០៤] និមិត្តំ ភយតោ សម្បស្សមានោ អនិមិត្តេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ អនិមិត្តំ អាវជ្ជិត្វា សមាបជ្ជតិ អនិមិត្តា វិហារសមាបត្តិ បណិធឹ ភយតោ សម្បស្សមានោ អប្បណិហិតេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ អប្បណិហិតំ អាវជ្ជិត្វា សមាបជ្ជតិ

*រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វាន ដែលមិនមានបណិធិ ហើយពិចារណានូវធម៌ដែលមិនមានបណិធិ គឺនិព្វាន ជាទីរលត់ទុក្ខ ហើយចូល (កាន់ផលសមាបត្តិ) ឈ្មោះថាអប្បណិហិត-សមាបត្តិ (សមាបត្តិមិនមានកិលេសជាទីតាំង) បុគ្គលកាលពិចារណា ឃើញនូវអភិនិវេសៈ ថាគួរខ្លាច រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្ត ទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលសូន្យចាកអត្តា ហើយពិចារណា នូវធម៌ដែលសូន្យចាកអត្តា គឺនិព្វានជាទីរលត់ទុក្ខ ហើយចូល (កាន់ផល-សមាបត្តិ) ឈ្មោះថាសុញ្ញតសមាបត្តិ (សមាបត្តិសូន្យចាកអត្តា) ។*

[២០៤] *បុគ្គលកាលពិចារណាឃើញ នូវនិមិត្តថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលមិនមាននិមិត្ត រមែងព្រងើយកន្តើយ ក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌ ដែលមិនមាននិមិត្ត គឺនិព្វានជាទីរលត់ទុក្ខ ហើយចូល (កាន់ផលសមាបត្តិ) ឈ្មោះថាអនិមិត្តវិហារ-សមាបត្តិ (វិហារសមាបត្តិមិនមាននិមិត្ត) បុគ្គលកាលពិចារណាឃើញ នូវបណិធិថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ ក្នុងព្រះនិព្វានមិនមានបណិធិ រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណា នូវធម៌មិនមានបណិធិ គឺនិព្វានជាទីរលត់ទុក្ខ ហើយចូល (កាន់ផលសមាបត្តិ)*

អប្បណិហិតា វិហារសមាបត្តិ អភិនិវេសំ ភយតោ សម្បស្សមានោ សុញ្ញតេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ សុញ្ញតំ អាវជ្ជិត្វា សមាបជ្ជតិ សុញ្ញតា វិហារសមាបត្តិ ។

[២០៨] រូបនិមិត្តំ ភយតោ សម្បស្សមានោ អនិមិត្តេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ អនិមិត្តោ វិហារោ រូបបណិធឹ ភយតោ សម្បស្សមានោ អប្បណិហិតេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ អប្បណិហិតោ វិហារោ រូបាភិនិវេសំ ភយតោ សម្បស្សមានោ សុញ្ញតេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ សុញ្ញតោ វិហារោ ។

ឈ្មោះថាអប្បណិហិតវិហារសមាបត្តិ (វិហារសមាបត្តិមិនមានបណិធិ) បុគ្គលកាលពិចារណាឃើញ នូវអភិនិវេសៈថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលសូន្យចាកអត្តា រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌ដែលសូន្យចាកអត្តា គឺនិព្វានជាទីរលត់ទុក្ខ ហើយចូល (កាន់ផលសមាបត្តិ) ឈ្មោះថាសុញ្ញតវិហារសមាបត្តិ (វិហារសមាបត្តិសូន្យចាកអត្តា) ។

[២០៥] បុគ្គលកាលពិចារណាឃើញ នូវរូបនិមិត្តថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមាននិមិត្ត ឈ្មោះថាអនិមិត្តវិហារធម៌ (សភាវៈជាទីសម្រាកមិនមានកិលេសជានិមិត្ត) បុគ្គលកាលពិចារណាឃើញ នូវរូបបណិធិ ថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ ក្នុងព្រះនិព្វានមិនមានបណិធិ ឈ្មោះថាអប្បណិហិតវិហារធម៌ (សភាវៈជាទីសម្រាកមិនមានបណិធិ) បុគ្គលកាលពិចារណាឃើញ នូវរូបាភិនិវេសៈ (ការប្រកាន់មាំនូវរូប) ថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ ក្នុងព្រះនិព្វានដែលសូន្យចាកអត្តា ឈ្មោះថាសុញ្ញតវិហារធម៌ (សភាវៈជាទីសម្រាកសូន្យចាកអត្តា) ។

[២០៦] រូបនិមិត្តំ ភយតោ សម្បស្សមានោ អនិមិត្តេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ អនិមិត្តំ អាវជ្ជិត្វា សមាបជ្ជតិ អនិមិត្តា សមាបត្តិ រូបបណិធឹ ភយតោ សម្បស្សមានោ អប្ប-ណិហិតេ អធិមុត្តត្តា បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ អប្បណិហិតំ អាវជ្ជិត្វា សមាបជ្ជតិ អប្បណិ-ហិតា សមាបត្តិ រូបាភិនិវេសំ ភយតោ សម្បស្ស-មានោ សុញ្ញតេ អធិមុត្តត្តា បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ សុញ្ញតំ អាវជ្ជិត្វា សមាបជ្ជតិ សុញ្ញ-តា សមាបត្តិ ។

[២០៧] រូបនិមិត្តំ ភយតោ សម្បស្សមានោ អនិមិត្តេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ បវត្តំ អជ្ឈុបេ-ក្ខិត្វា និរោធំ និព្វានំ អនិមិត្តំ អាវជ្ជិត្វា សមាបជ្ជតិ អនិមិត្តា វិហារសមាបត្តិ រូបបណិធឹ ភយតោ សម្ប-ស្សមានោ អប្បណិហិតេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ

[២០៦] បុគ្គលកាលពិចារណាឃើញនូវរូបនិមិត្តថាគួរខ្លាច រមែងព្រ-ងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌មិនមាននិមិត្ត គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូល (កាន់ផលសមាបត្តិ) ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមាននិមិត្ត ឈ្មោះថាអនិមិត្តសមាបត្តិ បុគ្គលកាលពិចារណាឃើញ នូវរូបបណិធិថាគួរខ្លាច រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌មិនមានបណិធិ គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូល (កាន់ផលសមាបត្តិ) ព្រោះចុះចិត្តស៊ប់ ក្នុងព្រះនិព្វានមិនមានបណិធិ ឈ្មោះថាអប្បណិហិតសមាបត្តិ បុគ្គលកាលពិចារណាឃើញ នូវរូបាភិនិវេសៈថាគួរខ្លាច ព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌ដ៏សូន្យចាកអត្តា គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូល (កាន់ផលសមាបត្តិ) ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដ៏សូន្យចាកអត្តា ឈ្មោះថាសុញ្ញតសមាបត្តិ ។

[២០៧] បុគ្គលកាលពិចារណាឃើញនូវនិមិត្តថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមាននិមិត្ត រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារ-ណានូវធម៌មិនមាននិមិត្តគឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូល(កាន់ផលស-មាបត្តិ) ឈ្មោះថាអនិមិត្តវិហារសមាបត្តិ បុគ្គលកាលពិចារណាឃើញនូវរូប-បណិធិថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលមិនមានបណិធិ រមែងព្រងើយកន្តើយ

បស្សតិ បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ អប្បណិហិ-
តំ អាវជ្ជិត្វា សមាបជ្ជតិ អប្បណិហិតា វិហារសមាបត្តិ
រូបាភិនិវេសំ ភយតោ សម្បស្សមានោ សុញ្ញតេ
អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ បវត្តំ អជ្ឈុ-
បេក្ខិត្វា និរោធំ និព្វានំ សុញ្ញតំ អាវជ្ជិត្វា សមា-
បជ្ជតិ សុញ្ញតា វិហារសមាបត្តិ ។

[២០៨] វេទនានិមិត្តំ ។ បេ ។ សញ្ញានិមិត្តំ
សង្ខារនិមិត្តំ វិញ្ញាណនិមិត្តំ ចក្ខុំ ។ បេ ។ ជរាមរ-
ណនិមិត្តំ ភយតោ សម្បស្សមានោ អនិមិត្តេ
អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ អនិមិត្តោ
វិហារោ ជរាមរណបណិធឹ ភយតោ សម្បស្សមា-
នោ អប្បណិហិតេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ
បស្សតិ អប្បណិហិតោ វិហារោ ជរាមរណាភិនិ-
វេសំ ភយតោ សម្បស្សមានោ សុញ្ញតេ អធិមុត្តត្តា
ផុស្ស ផុស្ស វយំ បស្សតិ សុញ្ញតោ វិហារោ ។

នឹងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌មិនមានបណិធិ គឺព្រះនិព្វាន ជាទីរលត់ទុក្ខ ហើយចូល (កាន់ផលសមាបត្តិ) ឈ្មោះថាអប្បណិហិត-វិហារសមាបត្តិ បុគ្គលកាលពិចារណាឃើញ នូវរូបាភិនិវេសៈថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដ៏សូន្យចាកអត្តា រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌ ដ៏សូន្យចាកអត្តា គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូល (កាន់ផលសមាបត្តិ) ឈ្មោះថាសុញ្ញតវិហារសមាបត្តិ ។

[២០៨] បុគ្គលកាលពិចារណាឃើញ នូវវេទនានិមិត្ត ។ បេ ។ នូវសញ្ញានិមិត្ត នូវសង្ខារនិមិត្ត នូវវិញ្ញាណនិមិត្ត នូវចក្ខុ ។ បេ ។ នូវជរាមរណនិមិត្តថាគួរខ្លាច រមែងពាល់ត្រូវរឿយៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមាននិមិត្ត ឈ្មោះថាអនិមិត្ត-វិហារធម៌ បុគ្គលកាលពិចារណាឃើញ នូវជរាមរណបណិធិថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វាន មិនមានបណិធិ ឈ្មោះថាអប្បណិហិតវិហារធម៌ បុគ្គលកាលពិចារណាឃើញ នូវជរាមរណាភិនិវេសៈថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលសូន្យចាកអត្តា ឈ្មោះថាសុញ្ញតវិហារធម៌ ។

[២០៩] ជរាមរណនិមិត្តំ ភយតោ សម្បស្សមានោ អនិមិត្តេ អធិមុត្តត្តា បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ អនិមិត្តំ អាវជ្ជិត្វា សមាបជ្ជតិ អនិមិត្តា សមាបត្តិ ជរាមរណបណិធឹ ភយតោ សម្បស្សមានោ អប្បណិហិតេ អធិមុត្តត្តា បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ អប្បណិហិតំ អាវជ្ជិត្វា សមាបជ្ជតិ អប្បណិហិតា សមាបត្តិ ជរាមរណាភិនិវេសំ ភយតោ សម្បស្សមានោ សុញ្ញតេ អធិមុត្តត្តា បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ សុញ្ញតំ អាវជ្ជិត្វា សមាបជ្ជតិ សុញ្ញតា សមាបត្តិ ។

[២១០] ជរាមរណនិមិត្តំ ភយតោ សម្បស្សមានោ អនិមិត្តេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ អនិមិត្តំ អាវជ្ជិត្វា សមាបជ្ជតិ អនិមិត្តា វិហារសមាបត្តិ ជរាមរណបណិធឹ ភយតោ សម្បស្សមានោ

[២០៩] បុគ្គលកាលពិចារណាឃើញ នូវជរាមរណនិមិត្ត ថាគួរខ្លាច រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមាននិមិត្ត ហើយពិចារណានូវធម៌មិនមាននិមិត្ត គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូលកាន់ (ផលសមាបត្តិ) ឈ្មោះថាអនិមិត្តសមាបត្តិ បុគ្គលកាលពិចារណាឃើញនូវជរាមរណបណិធិ ថាគួរខ្លាច រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមានបណិធិ ហើយពិចារណានូវធម៌មិនមានបណិធិ គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូលកាន់ (ផលសមាបត្តិ) ឈ្មោះថាអប្បណិហិតសមាបត្តិ បុគ្គលកាលពិចារណាឃើញនូវជរាមរណាភិនិវេសៈ ថាគួរខ្លាច រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលសូន្យចាកអត្តា ហើយពិចារណានូវធម៌ដ៏សូន្យចាកអត្តា គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូលកាន់ (ផលសមាបត្តិ) ឈ្មោះថាសុញ្ញតសមាបត្តិ ។

[២១០] បុគ្គលកាលពិចារណាឃើញនូវជរាមរណនិមិត្ត ថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានដែលមិនមាននិមិត្ត រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណា នូវធម៌ដែលមិនមាននិមិត្ត គឺព្រះនិព្វានជាទីរលត់ទុក្ខ ហើយចូល (កាន់ផលសមាបត្តិ) ឈ្មោះថាអនិមិត្តវិហារសមាបត្តិ បុគ្គលកាលពិចារណាឃើញនូវជរាមរណបណិធិថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ

អប្បណិហិតេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ អប្បណិហិតំ អាវជ្ជិត្វា សមាបជ្ជតិ អប្បណិហិតា វិហារសមាបត្តិ ជរាមរណាភិនិវេសំ ភយតោ សម្បស្សមានោ សុញ្ញ-តេ អធិមុត្តត្តា ផុស្ស ផុស្ស វយំ បស្សតិ បវត្តំ អជ្ឈុបេក្ខិត្វា និរោធំ និព្វានំ សុញ្ញតំ អាវជ្ជិត្វា សមា-បជ្ជតិ សុញ្ញតា វិហារសមាបត្តិ អញ្ញោ អនិមិត្តោ វិហារោ អញ្ញោ អប្បណិហិតោ វិហារោ អញ្ញោ សុញ្ញ-តោ វិហារោ អញ្ញា អនិមិត្តា សមាបត្តិ អញ្ញា អប្បណិហិតា សមាបត្តិ អញ្ញា សុញ្ញតា សមាបត្តិ អញ្ញា អនិមិត្តា វិហារសមាបត្តិ អញ្ញា អប្បណិហិតា វិហារសមាបត្តិ អញ្ញា សុញ្ញតា វិហារសមាបត្តិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ វិហារនានត្តេ បញ្ញា វិហារដ្ឋេ ញាណំ សមាបត្តិ-នានត្តេ បញ្ញា សមាបត្តដ្ឋេ ញាណំ វិហារសមាបត្តិ-នានត្តេ បញ្ញា វិហារសមាបត្តដ្ឋេ ញាណំ ។

[២១១] កថំ អវិក្ខេបបរិសុទ្ធត្តា អាសវសមុ-ច្ឆេទេ បញ្ញា អានន្តរិកសមាធិស្មឹ[១] ញាណំ ។

១ ម. អានន្តរិយសមាធិស្មឹ ។

ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមាន បណិធិ រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌ មិនមានបណិធិ គឺព្រះនិព្វានជាទីរលត់ទុក្ខ ឈ្មោះថាអប្បណិហិតវិហារ-សមាបត្តិ បុគ្គលកាលពិចារណាឃើញ នូវជរាមរណាភិនិវេសៈ ថាគួរខ្លាច រមែងពាល់ត្រូវរឿយ ៗ ហើយឃើញនូវកិរិយាសូន្យទៅ ព្រោះចុះចិត្តស៊ប់ ក្នុងព្រះនិព្វានដ៏សូន្យចាកអត្តា រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ ហើយពិចារណានូវធម៌ដ៏សូន្យចាកអត្តា គឺព្រះនិព្វានជាទីរលត់ទុក្ខ ឈ្មោះថាសុញ្ញតវិហារសមាបត្តិ អនិមិត្តវិហារធម៌ដោយឡែក អប្បណិហិតវិហារ-ធម៌ដោយឡែក សុញ្ញតវិហារធម៌ដោយឡែក អនិមិត្តសមាបត្តិដោយឡែក អប្បណិហិតសមាបត្តិដោយឡែក សុញ្ញតសមាបត្តិដោយឡែក អនិមិត្ត-វិហារសមាបត្តិ ដោយឡែក អប្បណិហិតវិហារសមាបត្តិដោយឡែក សុញ្ញតវិហារសមាបត្តិដោយឡែក ដែលឈ្មោះថាញាណ ដោយអត្ថថា ដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងវិបស្សនាវិហារផ្សេង ៗ ឈ្មោះថាវិហារ-ដ្ឋញ្ញាណ បញ្ញាក្នុងផលសមាបត្តិផ្សេង ៗ ឈ្មោះថាសមាបត្តដ្ឋញ្ញាណ បញ្ញាក្នុងវិហារសមាបត្តិផ្សេង ៗ ឈ្មោះថាវិហារសមាបត្តដ្ឋញ្ញាណ ។

[២១១] បញ្ញាក្នុងការផ្តាច់បង់ នូវអាសវៈ ព្រោះចិត្តបរិសុទ្ធ ដោយការមិនរាយមាយ ឈ្មោះថាអានន្តរិកសមាធិញ្ញាណ តើដូចម្តេច ។

នេក្ខម្មវសេន ចិត្តស្សេកគ្គតា អវិក្ខេបោ សមាធិ តស្ស សមាធិស្ស វសេន ឧប្បជ្ជតិ ញាណំ តេន ញាណេន អាសវា ខីយន្តិ ឥតិ បឋមំ សមថោ បច្ឆា ញាណំ តេន ញាណេន អាសវានំ ខយោ ហោតិ តេន វុច្ចតិ អវិក្ខេបបរិសុទ្ធត្តា អាសវសមុច្ឆេទេ បញ្ញា អានន្តរិកសមាធិស្មិំ ញាណំ ។

[២១២] អាសវាតិ កតមេ តេ អាសវា ។ កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។

កត្ថេតេ អាសវា ខីយន្តិ ។ សោតាបត្តិមគ្គេន អនវសេសោ ទិដ្ឋាសវោ ខីយតិ អបាយគមនីយោ កាមាសវោ ខីយតិ អបាយគមនីយោ ភវាសវោ ខីយតិ អបាយគមនីយោ អវិជ្ជាសវោ ខីយតិ ឯត្ថេតេ អាសវា ខីយន្តិ សកទាគាមិមគ្គេន ឱឡារិកោ កាមាសវោ ខីយតិ តទេកដ្ឋោ ភវាសវោ ខីយតិ តទេកដ្ឋោ អវិជ្ជាសវោ ខីយតិ ឯត្ថេតេ អាសវា ខីយន្តិ

សេចក្តីមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃនេក្ខម្មៈ ឈ្មោះថាសមាធិ ញាណកើតឡើងដោយអំណាចនៃសមាធិនោះ អាសវៈទាំងឡាយរមែងអស់ទៅ ដោយញាណនោះ ព្រោះហេតុនោះ សមថៈ (ការស្ងប់គឺសមាធិ កើត) មុន ញាណ (កើត) ក្រោយ ការអស់ទៅនៃអាសវៈទាំងឡាយ រមែងកើតមានដោយញាណនោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការផ្តាច់បង់នូវអាសវៈ ព្រោះចិត្តបរិសុទ្ធដោយការមិនរាយមាយ ឈ្មោះថាអានន្តរិកសមាធិញ្ញាណ ។

[២១២] សំណួរត្រង់ពាក្យថា អាសវៈទាំងឡាយ តើអាសវៈទាំង-ឡាយនោះ អ្វីខ្លះ ។ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។

អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌ណា ។ ទិដ្ឋាសវៈ រមែងអស់ មិនមានសេសសល់ កាមាសវៈដែលញ៉ាំងសត្វឲ្យទៅកាន់អបាយ រមែងអស់ ភវាសវៈ ដែលញ៉ាំងសត្វឲ្យទៅកាន់អបាយ រមែងអស់ អវិជ្ជាសវៈ ដែលញ៉ាំងសត្វឲ្យទៅកាន់អបាយ រមែងអស់ ដោយសោតាបត្តិមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌នុ៎ះឯង កាមាសវៈ ដ៏គ្រោតគ្រាត រមែងអស់ ភវាសវៈ ដែលឋិតនៅជាមួយនឹងកាមាសវៈនោះ រមែងអស់ អវិជ្ជាសវៈដែលឋិតនៅ ជាមួយនឹងភវាសវៈនោះ រមែងអស់ ដោយសកទាគាមិមគ្គ អាសវៈទាំងឡាយនុ៎ះ

អនាគាមិមគ្គេន អនវសេសោ កាមាសវោ ខីយតិ តទេកដ្ឋោ ភវាសវោ ខីយតិ តទេកដ្ឋោ អវិជ្ជាសវោ ខីយតិ ឯត្ថេតេ អាសវា ខីយន្តិ អរហត្តមគ្គេន អនវសេសោ ភវាសវោ ខីយតិ អនវសេសោ អវិជ្ជាសវោ ខីយតិ ឯត្ថេតេ អាសវា ខីយន្តិ ។

[២១៣] អព្យាបាទវសេន ។ បេ ។ អាលោកសញ្ញាវសេន អវិក្ខេបវសេន ធម្មវវត្ថានវសេន ញាណវសេន បាមុជ្ជវសេន បឋមជ្ឈានវសេន ទុតិយជ្ឈានវសេន តតិយជ្ឈានវសេន ចតុត្ថជ្ឈានវសេន អាកាសានញ្ចាយតនសមាបត្តិវសេន វិញ្ញាណញ្ចាយតនសមាបត្តិវសេន អាកិញ្ចញ្ញាយតនសមាបត្តិវសេន នេវសញ្ញានាសញ្ញាយតនសមាបត្តិវសេន បឋវីកសិណវសេន អាបោកសិណវសេន តេជោកសិណវសេន វាយោកសិណវសេន នីលកសិណវសេន បីតកសិណវសេន លោហិតកសិណវសេន ឱទាតកសិណវសេន អាកាសកសិណវសេន

រមែងអស់ ក្នុងធម៌នុ៎ះឯង កាមាសវៈ រមែងអស់ មិនមានសេសសល់ ភវាសវៈ ដែលឋិតនៅជាមួយនឹងកាមាសវៈនោះ រមែងអស់ អវិជ្ជាសវៈ ដែលឋិតនៅជាមួយនឹងភវាសវៈនោះ រមែងអស់ ដោយអនាគាមិមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌នុ៎ះឯង ភវាសវៈរមែងអស់មិនមានសេសសល់ អវិជ្ជាសវៈរមែងអស់ មិនមានសេសសល់ ដោយអរហត្តមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌នុ៎ះឯង ។

[២១៣] សេចក្ដីមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចការមិនព្យាបាទ ។ បេ ។ ដោយអំណាចអាលោកសញ្ញា ដោយអំណាចនៃកិរិយាមិនរាយមាយ ដោយអំណាចនៃកិរិយាកំណត់នូវធម៌ ដោយអំណាចញាណ ដោយអំណាចបាមុជ្ជៈ (អំណរទន់) ដោយអំណាចបឋមជ្ឈាន ដោយអំណាចទុតិយជ្ឈាន ដោយអំណាចតតិយជ្ឈាន ដោយអំណាចចតុត្ថជ្ឈាន ដោយអំណាចអាកាសានញ្ចាយតនសមាបត្តិ ដោយអំណាចវិញ្ញាណញ្ចាយតនសមាបត្តិ ដោយអំណាចអាកិញ្ចញ្ញាយតនសមាបត្តិ ដោយអំណាចនេវសញ្ញានាសញ្ញាយតនសមាបត្តិ ដោយអំណាចបឋវីកសិណ ដោយអំណាចអាបោកសិណ ដោយអំណាចតេជោកសិណ ដោយអំណាចវាយោកសិណ ដោយអំណាចនីលកសិណ ដោយអំណាចបីតកសិណ ដោយអំណាចលោហិតកសិណ ដោយអំណាចឱទាតកសិណ ដោយអំណាចអាកាសកសិណ

វិញ្ញាណកសិណវសេន ពុទ្ធានុស្សតិវសេន ធម្មា-
នុស្សតិវសេន សង្ឃានុស្សតិវសេន សីលានុស្សតិវ-
សេន ចាគានុស្សតិវសេន ទេវតានុស្សតិវសេន
អានាបានស្សតិវសេន មរណស្សតិវសេន កាយគ-
តាសតិវសេន ឧបសមានុស្សតិវសេន ឧទ្ធុមាតក-
សញ្ញាវសេន វិនីលកសញ្ញាវសេន វិបុព្វកសញ្ញាវ-
សេន វិច្ឆិទ្ទកសញ្ញាវសេន វិក្ខាយិតកសញ្ញាវសេន
វិក្ខិត្តកសញ្ញាវសេន ហតវិក្ខិត្តកសញ្ញាវសេន លោ-
ហិតកសញ្ញាវសេន បុឡុវកសញ្ញាវសេន អដ្ឋិកស-
ញ្ញាវសេន ទីឃំ អស្សាសវសេន ទីឃំ បស្សាសវ-
សេន រស្សំ អស្សាសវសេន រស្សំ បស្សាសវសេន
សព្វកាយប្បដិសំវេទី អស្សាសវសេន សព្វ-
កាយប្បដិសំវេទី បស្សាសវសេន បស្សម្ភយំ
កាយសង្ខារំ អស្សាសវសេន បស្សម្ភយំ កាយ-
សង្ខារំ បស្សាសវសេន បីតិប្បដិសំវេទី
អស្សាសវសេន បីតិប្បដិសំវេទី បស្សាសវសេន

ដោយអំណាចវិញ្ញាណកសិណ ដោយអំណាចពុទ្ធានុស្សតិ ដោយអំណាចធម្មានុស្សតិ ដោយអំណាចសង្ឃានុស្សតិ ដោយអំណាចសីលានុស្សតិ ដោយអំណាចចាគានុស្សតិ ដោយអំណាចទេវតានុស្សតិ ដោយអំណាចអានាបានស្សតិ ដោយអំណាចមរណស្សតិ ដោយអំណាចកាយគតាសតិ ដោយអំណាចឧបសមានុស្សតិ ដោយអំណាចឧទ្ធុមាតកសញ្ញា ដោយអំណាចវិនីលកសញ្ញា ដោយអំណាចវិបុព្វកសញ្ញា ដោយអំណាចវិច្ឆិទ្ទកសញ្ញា ដោយអំណាចវិក្ខាយិតកសញ្ញា ដោយអំណាចវិក្ខិត្តកសញ្ញា ដោយអំណាចហតវិក្ខិត្តកសញ្ញា ដោយអំណាចលោហិតកសញ្ញា ដោយអំណាចបុឡុវកសញ្ញា ដោយអំណាចអដ្ឋិកសញ្ញា ដោយអំណាចការដកដង្ហើមចេញវែង ដោយអំណាចការដកដង្ហើមចូលវែង ដោយអំណាចការដកដង្ហើមចេញខ្លី ដោយអំណាចការដកដង្ហើមចូលខ្លី ដោយអំណាចការដឹងច្បាស់ នូវកាយ គឺខ្យល់ចេញទាំងពួងហើយដកដង្ហើមចេញ ដោយអំណាចការដឹងច្បាស់ នូវកាយគឺខ្យល់ចូលទាំងពួងហើយដកដង្ហើមចូល ដោយអំណាចការញុំាងកាយសង្ខារឲ្យស្ងប់ហើយដកដង្ហើមចេញ ដោយអំណាចការញុំាងកាយសង្ខារឲ្យស្ងប់ហើយដកដង្ហើមចូល ដោយអំណាចការដឹងច្បាស់នូវបីតិហើយដកដង្ហើមចេញ ដោយអំណាចការដឹងច្បាស់នូវបីតិហើយដកដង្ហើមចូល

សុខប្បដិសំវេទី អស្សាសវសេន សុខប្បដិសំវេទី បស្សាសវសេន ចិត្តសង្ខារប្បដិសំវេទី អស្សាសវសេន ចិត្តសង្ខារប្បដិសំវេទី បស្សាសវសេន បស្សម្ភយំ ចិត្តសង្ខារំ អស្សាសវសេន បស្សម្ភយំ ចិត្តសង្ខារំ បស្សាសវសេន ចិត្តប្បដិសំវេទី អស្សាសវសេន ចិត្តប្បដិសំវេទី បស្សាសវសេន អភិប្បមោទយំ ចិត្តំ អស្សាសវសេន អភិប្បមោទយំ ចិត្តំ បស្សាសវសេន សមាទហំ ចិត្តំ ។ បេ ។ វិមោចយំ ចិត្តំ អនិច្ចានុបស្សី វិរាគានុបស្សី និរោធានុបស្សី បដិនិស្សគ្គានុបស្សី អស្សាសវសេន បដិនិស្សគ្គានុបស្សី បស្សាសវសេន ចិត្តស្សេកគ្គតា អវិក្ខេបោ សមាធិ តស្ស សមាធិស្ស វសេន ឧប្បជ្ជតិ ញាណំ តេន ញាណេន អាសវា ខីយន្តិ ឥតិ បឋមំ សមថោ បច្ឆា ញាណំ តេន ញាណេន អាសវានំ ខយោ ហោតិ តេន វុច្ចតិ

ដោយអំណាចការដឹងច្បាស់នូវសេចក្ដីសុខ ហើយដកដង្ហើមចេញ ដោយអំណាចការដឹងច្បាស់ នូវសេចក្ដីសុខ ហើយដកដង្ហើមចូល ដោយអំណាចការដឹងច្បាស់នូវចិត្តសង្ខារហើយដកដង្ហើមចេញ ដោយអំណាចការដឹងច្បាស់នូវចិត្តសង្ខារហើយដកដង្ហើមចូល ដោយអំណាចការញុំាងចិត្តសង្ខារឲ្យស្ងប់ ហើយដកដង្ហើមចេញ ដោយអំណាចការញុំាងចិត្ត-សង្ខារឲ្យស្ងប់ហើយដកដង្ហើមចូល ដោយអំណាចការដឹងច្បាស់នូវចិត្តហើយដកដង្ហើមចេញ ដោយអំណាចការដឹងច្បាស់នូវចិត្ត ហើយដកដង្ហើមចូល ដោយអំណាចការញុំាងចិត្តឲ្យរីករាយហើយដកដង្ហើមចេញ ដោយអំណាចការញុំាងចិត្តឲ្យរីករាយហើយដកដង្ហើមចូល ដោយអំណាចការតាំងចិត្តឲ្យមាំ ។ បេ ។ ការញុំាងចិត្តឲ្យផុតស្រឡះ ការឃើញរឿយ ៗ ថាមិនទៀង ការឃើញរឿយ ៗ នូវវិរាគៈ ការឃើញរឿយ ៗ នូវនិរោធៈ ការឃើញរឿយ ៗ នូវបដិនិស្សគ្គៈ (ធម៌ជាគ្រឿងលះបង់នូវកិលេស) ហើយដកដង្ហើមចេញ ដោយអំណាចកិរិយាឃើញនូវបដិ-និស្សគ្គៈ ហើយដកដង្ហើមចូល ឈ្មោះថាសមាធិ ញាណរមែងកើតឡើង ដោយអំណាចនៃសមាធិនោះ អាសវៈទាំងឡាយ រមែងអស់ដោយញាណនោះ ព្រោះហេតុនោះ សមថៈ (ការស្ងប់ គឺសមាធិកើត) មុន ញាណ (កើត) ក្រោយ ការអស់នៃអាសវៈទាំងឡាយរមែងកើតមាន ដោយញាណនោះ ហេតុនោះ លោកពោលថា

អវិក្ខេបបរិសុទ្ធត្តា អាសវសមុច្ឆេទេ បញ្ញា អានន្តរិក-
សមាធិស្មឹ ញាណំ ។

[២១៤] អាសវាតិ កតមេ តេ អាសវា ។
កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។

កត្ថេតេ អាសវា ខីយន្តិ ។ សោតាបត្តិមគ្គេន
អនវសេសោ ទិដ្ឋាសវោ ខីយតិ អបាយគមនីយោ
កាមាសវោ ខីយតិ អបាយគមនីយោ ភវាសវោ
ខីយតិ អបាយគមនីយោ អវិជ្ជាសវោ ខីយតិ
ឯត្ថេតេ អាសវា ខីយន្តិ ។

សកទាគាមិមគ្គេន ឱឡារិកោ កាមាសវោ
ខីយតិ តទេកដ្ឋោ ភវាសវោ ខីយតិ តទេកដ្ឋោ
អវិជ្ជាសវោ ខីយតិ ឯត្ថេតេ អាសវា ខីយន្តិ ។

អនាគាមិមគ្គេន អនវសេសោ កាមាសវោ ខីយតិ
តទេកដ្ឋោ ភវាសវោ ខីយតិ តទេកដ្ឋោ អវិជ្ជាសវោ
ខីយតិ ឯត្ថេតេ អាសវា ខីយន្តិ ។

បញ្ញាក្នុងការផ្តាច់បង់នូវអាសវៈ ព្រោះចិត្តបរិសុទ្ធដោយការមិនរាយមាយ ឈ្មោះថាអានន្តរិកសមាធិញ្ញាណ ។

[២១៤] សំណួរត្រង់ពាក្យថា អាសវៈទាំងឡាយ តើអាសវៈទាំង-ឡាយនោះ អ្វីខ្លះ ។ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។

អាសវៈទាំងឡាយនុ៎ះ អស់ក្នុងធម៌ណា ។ ទិដ្ឋាសវៈ រមែងអស់មិនមានសេសសល់ កាមាសវៈដែលញុំាងសត្វឲ្យទៅកាន់អបាយ រមែងអស់ ភវាសវៈដែលញុំាងសត្វឲ្យទៅកាន់អបាយ រមែងអស់ អវិជ្ជាសវៈដែលញុំាងសត្វឲ្យទៅកាន់អបាយ រមែងអស់ ដោយសោតាបត្តិមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌នុ៎ះឯង ។

កាមាសវៈដ៏គ្រោតគ្រាត រមែងអស់ ភវាសវៈដែលឋិតនៅជាមួយនឹងកាមាសវៈនោះ រមែងអស់ អវិជ្ជាសវៈដែលឋិតនៅ ជាមួយនឹងភវាសវៈនោះ រមែងអស់ ដោយសកទាគាមិមគ្គ អាសវៈទាំង-ឡាយនុ៎ះ រមែងអស់ក្នុងធម៌នុ៎ះឯង ។

កាមាសវៈ រមែងអស់មិនមានសេសសល់ ភវាសវៈដែលឋិតនៅជាមួយនឹងកាមាសវៈនោះ រមែងអស់ អវិជ្ជាសវៈដែលឋិតនៅជាមួយនឹងភវាសវៈនោះ រមែងអស់ ដោយអនាគាមិមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ក្នុងធម៌នុ៎ះឯង ។

អរហត្តមគ្គេន អនវសេសោ ភវាសវោ ខីយតិ អនវសេសោ អវិជ្ជាសវោ ខីយតិ ឯត្ថេតេ អាសវា ខីយន្តិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ អវិក្ខេបបរិសុទ្ធត្តា អាសវសមុច្ឆេទេ បញ្ញា អានន្តរិកសមាធិស្មឹ ញាណំ ។

[២១៨] កថំ ទស្សនាធិបតេយ្យំ សន្តោ ច វិហារាធិគមោ បណីតាធិមុត្តតា បញ្ញា អរណវិហារេ ញាណំ ។ ទស្សនាធិបតេយ្យន្តិ អនិច្ចានុបស្សនា ទស្សនាធិបតេយ្យំ ទុក្ខានុបស្សនា ទស្សនាធិបតេយ្យំ អនត្តានុបស្សនា ទស្សនាធិបតេយ្យំ រូបេ អនិច្ចានុប-ស្សនា ទស្សនាធិបតេយ្យំ រូបេ ទុក្ខានុបស្សនា ទស្ស-នាធិបតេយ្យំ រូបេ អនត្តានុបស្សនា ទស្សនាធិប-តេយ្យំ វេទនាយ ។ បេ ។ សញ្ញាយ សង្ខារេសុ វិញ្ញា-ណេ ចក្ខុស្មឹ ។ បេ ។ ជរាមរណេ អនិច្ចានុប-ស្សនា ទស្សនាធិបតេយ្យំ ជរាមរណេ ទុក្ខានុបស្សនា

ភវាសវៈ រមែងអស់ មិនមានសេសសល់ អវិជ្ជាសវៈ រមែងអស់ មិនមានសេសសល់ ដោយអរហត្តមគ្គ អាសវៈទាំងឡាយនុ៎ះ រមែងអស់ ក្នុងធម៌នុ៎ះឯង ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការផ្តាច់បង់នូវអាសវៈ ព្រោះចិត្តបរិសុទ្ធ ដោយការមិនរាយមាយ ឈ្មោះថាអានន្តរិកសមាធិញ្ញាណ ។

[២១៥] បញ្ញា គឺទស្សនាធិបតេយ្យ (សេចក្តីឃើញជាធំ) ផង ការបាននូវវិហារធម៌ដ៏ស្ងប់ និងសេចក្តីចុះចិត្តស៊ប់ក្នុងធម៌ដ៏ឧត្តមផង ឈ្មោះថាអរណវិហារញ្ញាណ តើដូចម្តេច ។ ពាក្យថា ទស្សនាធិបតេយ្យ គឺការឃើញរឿយ ៗ ថាមិនទៀង ឈ្មោះថាទស្សនាធិបតេយ្យ ការឃើញរឿយ ៗ ថាជាទុក្ខ ឈ្មោះថាទស្សនាធិបតេយ្យ ការឃើញរឿយ ៗ ថាមិនមែនខ្លួន ឈ្មោះថាទស្សនាធិបតេយ្យ ការឃើញរឿយ ៗ ក្នុងរូបថាមិនទៀង ឈ្មោះថាទស្សនាធិបតេយ្យ ការឃើញរឿយ ៗ ក្នុងរូបថាជាទុក្ខ ឈ្មោះថាទស្សនាធិបតេយ្យ ការឃើញរឿយ ៗ ក្នុងរូបថាមិនមែនខ្លួន ឈ្មោះថាទស្សនាធិបតេយ្យ ការឃើញរឿយ ៗ ក្នុងវេទនា ។ បេ ។ ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។ បេ ។ ក្នុងជរាមរណៈ ថាមិនទៀង ឈ្មោះថាទស្សនាធិបតេយ្យ ការឃើញរឿយ ៗ ក្នុងជរាមរណៈ ថាជាទុក្ខ

ឧស្សុជាធិបតេយ្យំ ជវាមរណេ អនត្តានុបស្សនា ឧស្សុជាធិបតេយ្យំ ។

[២១៦] សន្តោ ច វិហារាធិគមោតិ សុញ្ញតោ វិហារោ សន្តោ វិហារាធិគមោ អនិមិត្តោ វិហារោ សន្តោ វិហារាធិគមោ អប្បណិហិតោ វិហារោ សន្តោ វិហារាធិគមោ ។

បណីតាធិមុត្តតាតិ សុញ្ញតេ អធិមុត្តតា បណីតា-ធិមុត្តតា អនិមិត្តេ អធិមុត្តតា បណីតាធិមុត្តតា អប្បណិហិតេ អធិមុត្តតា បណីតាធិមុត្តតា ។

អរណវិហារោតិ បឋមជ្ឈានំ អរណវិហារោ ទុតិ-យជ្ឈានំ អរណវិហារោ តតិយជ្ឈានំ អរណវិហារោ ចតុត្ថជ្ឈានំ អរណវិហារោ អាកាសានញ្ចាយតនស-មាបត្តិ អរណវិហារោ ។ បេ ។ នេវសញ្ញានាសញ្ញា-យតនសមាបត្តិ អរណវិហារោ ។

អរណវិហារោតិ កេនដ្ឋេន អរណវិហារោ ។

ឈ្មោះថាទស្សនាធិបតេយ្យ ការឃើញរឿយ ៗ ក្នុងជរាមរណៈ ថាមិនមែនខ្លួន ឈ្មោះថាទស្សនាធិបតេយ្យ ។

[២១៦] ពាក្យថា ការបាននូវវិហារធម៌ដ៏ស្ងប់ គឺវិហារធម៌ដ៏សូន្យចាកកិលេស ឈ្មោះថាការបាននូវវិហារធម៌ដ៏ស្ងប់ វិហារធម៌មិនមាននិមិត្ត ឈ្មោះថាការបាននូវវិហារធម៌ដ៏ស្ងប់ វិហារធម៌មិនមានបណិធិ ឈ្មោះថាការបាននូវវិហារធម៌ដ៏ស្ងប់ ។

ពាក្យថា សេចក្តីចុះចិត្តស៊ប់ក្នុងធម៌ដ៏ឧត្តម គឺសេចក្តីចុះចិត្តស៊ប់ក្នុងព្រះនិព្វានដ៏សូន្យចាកកិលេស ឈ្មោះថាសេចក្តីចុះចិត្តស៊ប់ ក្នុងធម៌ដ៏ឧត្តម សេចក្តីចុះចិត្តស៊ប់ក្នុងព្រះនិព្វានមិនមាននិមិត្ត ឈ្មោះថាសេចក្តីចុះចិត្តស៊ប់ក្នុងធម៌ដ៏ឧត្តម សេចក្តីចុះចិត្តស៊ប់ ក្នុងធម៌មិនមានបណិធិ ឈ្មោះថាសេចក្តីចុះចិត្តស៊ប់ក្នុងធម៌ដ៏ឧត្តម ។

ពាក្យថា អរណវិហារ គឺបឋមជ្ឈាន ឈ្មោះថាអរណវិហារ ទុតិយជ្ឈាន ឈ្មោះថាអរណវិហារ តតិយជ្ឈាន ឈ្មោះថាអរណវិហារ ចតុត្ថជ្ឈាន ឈ្មោះថាអរណវិហារ អាកាសានញ្ចាយតនសមាបត្តិ ឈ្មោះថាអរណវិហារ ។ បេ ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថាអរណវិហារ ។

សំណួរត្រង់ពាក្យថា អរណវិហារ តើអរណវិហារ ដោយអត្ថដូចម្តេច ។

បឋមជ្ឈានេន នីវរណេ ហរតីតិ អរណវិហារោ ទុតិយជ្ឈានេន វិតក្កវិចារេ ហរតីតិ អរណវិហារោ តតិយជ្ឈានេន បីតឹ ហរតីតិ អរណវិហារោ ចតុត្ថជ្ឈានេន សុខទុក្ខេ ហរតីតិ អរណវិហារោ អាកាសានញ្ចាយតនសមាបត្តិយា រូបសញ្ញំ បដិឃសញ្ញំ នានត្តសញ្ញំ ហរតីតិ អរណវិហារោ វិញ្ញាណញ្ចាយតនសមាបត្តិយា អាកាសានញ្ចាយតនសញ្ញំ ហរតីតិ អរណវិហារោ អាកិញ្ចញ្ញាយតនសមាបត្តិយា វិញ្ញាណញ្ចាយតនសញ្ញំ ហរតីតិ អរណវិហារោ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា អាកិញ្ចញ្ញាយតនសញ្ញំ ហរតីតិ អរណវិហារោ អយំ អរណវិហារោ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ទស្សនាធិបតេយ្យំ សន្តោ ច វិហារាធិគមោ បណីតាធិមុត្តតា បញ្ញា អរណវិហារេ ញាណំ ។

[២១៧] កថំ ទ្វីហិ ពលេហិ សមន្នាគតត្តា តយោ ច សង្ខារានំ បដិប្បស្សទ្ធិយា សោឡសហិ ញាណចរិយាហិ នវហិ សមាធិចរិយាហិ វសីភាវតា បញ្ញា និរោធសមាបត្តិយា ញាណំ ។

*សភាវៈនាំចេញនូវនីវរណធម៌ទាំងឡាយដោយបឋមជ្ឈាន ឈ្មោះថាអរណាវិហារ សភាវៈនាំចេញនូវវិតក្កៈ និង វិចារៈ ដោយទុតិយជ្ឈាន ឈ្មោះថាអរណាវិហារ សភាវៈនាំចេញនូវបីតិដោយតតិយជ្ឈាន ឈ្មោះថាអរណាវិហារ សភាវៈនាំចេញនូវសុខនិងទុក្ខដោយចតុត្ថជ្ឈាន ឈ្មោះថាអរណាវិហារ សភាវៈនាំចេញរូបសញ្ញា បដិឃសញ្ញា និងនានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ ឈ្មោះថាអរណាវិហារ សភាវៈនាំចេញនូវអាកាសានញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ ឈ្មោះថាអរណាវិហារ សភាវៈនាំចេញនូវវិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ ឈ្មោះថាអរណាវិហារ សភាវៈនាំចេញនូវអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថាអរណាវិហារ នេះឈ្មោះថាអរណាវិហារ ដែលឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាគឺទស្សនាធិបតេយ្យផង ការបាននូវវិហារធម៌ស្ងប់ និងសេចក្ដីចុះចិត្តស៊ប់ក្នុងធម៌ដ៏ឧត្តមផង ឈ្មោះថាអរណាវិហារញ្ញាណ ។*

*[២១៧] បញ្ញាដែលមានភាពស្ទាត់ជំនាញ ព្រោះហេតុប្រកបដោយកម្លាំង ២ ផង ព្រោះការស្ងប់រម្ងាប់នៃសង្ខារ ៣ ផង ព្រោះញាណចរិយាទាំង ១៦ ផង ព្រោះសមាធិចរិយាទាំង ៩ ផង ឈ្មោះថានិរោធសមាបត្តិញ្ញាណ តើដូចម្ដេច ។*

ទ្វីហិ ពលេហីតិ ទ្វេ ពលានិ សមថពលំ វិបស្សនាពលំ ។

[២១៨] កតមំ សមថពលំ ។ នេក្ខម្មវសេន ចិត្តស្សេកគ្គតា អវិក្ខេបោ សមថពលំ អព្យាបាទវសេន ចិត្តស្សេកគ្គតា អវិក្ខេបោ សមថពលំ អាលោកសញ្ញាវសេន ចិត្តស្សេកគ្គតា អវិក្ខេបោ សមថពលំ អវិក្ខេបវសេន ចិត្តស្សេកគ្គតា អវិក្ខេបោ សមថពលំ ។ បេ ។ បដិនិស្សគ្គានុបស្សី អស្សាសវសេន ចិត្តស្សេកគ្គតា អវិក្ខេបោ សមថពលំ បដិនិស្សគ្គានុបស្សី បស្សាសវសេន ចិត្តស្សេកគ្គតា អវិក្ខេបោ សមថពលំ ។

[២១៩] សមថពលន្តិ កេនដ្ឋេន សមថពលំ ។ បឋមជ្ឈានេន នីវរណេ ន កម្បតីតិ សមថពលំ ទុតិយជ្ឈានេន វិតក្កវិចារេ ន កម្បតីតិ សមថពលំ

ពាក្យថា ដោយកម្លាំង ២ គឺ កម្លាំងមាន ២ យ៉ាងគឺ កម្លាំងសមថៈ ១ កម្លាំងវិបស្សនា ១ ។

[២១៨] កម្លាំងសមថៈ តើដូចម្តេច ។ ការមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃនេក្ខម្មៈ ឈ្មោះថាកម្លាំងសមថៈ ការមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃការមិនព្យាបាទ ឈ្មោះថាកម្លាំងសមថៈ ការមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាច នៃអាលោកសញ្ញា ឈ្មោះថាកម្លាំងសមថៈ ការមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃការមិនរាយមាយ ឈ្មោះថាកម្លាំងសមថៈ ។ បេ ។ ការមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃកិរិយាឃើញរឿយ ៗ នូវធម៌ជាគ្រឿងលះបង់នូវកិលេស ហើយដកដង្ហើមចេញ ឈ្មោះថាកម្លាំងសមថៈ ការមិនរាយមាយ គឺភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃកិរិយាឃើញរឿយ ៗ នូវធម៌ជាគ្រឿងលះបង់នូវកិលេសហើយដកដង្ហើមចូល ឈ្មោះថាកម្លាំងសមថៈ ។

[២១៩] សំណួរត្រង់ពាក្យថា កម្លាំងសមថៈ តើកម្លាំងសមថៈដោយអត្ថដូចម្តេច ។ ធម្មជាតមិនកម្រើក ក្នុងនីវរណធម៌ ដោយបឋមជ្ឈាន ឈ្មោះថា កម្លាំងសមថៈ ធម្មជាតមិនកម្រើក ក្នុងវិតក្កៈនិងវិចារៈ ដោយទុតិយជ្ឈាន ឈ្មោះថា កម្លាំងសមថៈ

តតិយជ្ឈានេន បីតិយា ន កម្បតីតិ សមថពលំ ចតុត្ថជ្ឈានេន សុខទុក្ខេ ន កម្បតីតិ សមថពលំ អាកាសានញ្ចាយតនសមាបត្តិយា រូបសញ្ញាយ បដិឃសញ្ញាយ នានត្តសញ្ញាយ ន កម្បតីតិ សមថពលំ វិញ្ញាណញ្ចាយតនសមាបត្តិយា អាកាសានញ្ចាយតនសញ្ញាយ ន កម្បតីតិ សមថពលំ អាកិញ្ចញ្ញាយតនសមាបត្តិយា វិញ្ញាណញ្ចាយតនសញ្ញាយ ន កម្បតីតិ សមថពលំ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា អាកិញ្ចញ្ញាយតនសញ្ញាយ ន កម្បតីតិ សមថពលំ ឧទ្ធច្ចេ ច ឧទ្ធច្ចសហគតក្កិលេសេ ច ខន្ធេ ច ន កម្បតិ ន ចលតិ ន វេធតីតិ សមថពលំ ឥទំ សមថពលំ ។

[២២០] កតមំ វិបស្សនាពលំ ។ អនិច្ចានុបស្សនា វិបស្សនាពលំ ទុក្ខានុបស្សនា វិបស្សនាពលំ អនត្តានុបស្សនា វិបស្សនាពលំ និព្វិទានុបស្សនា វិបស្សនាពលំ វិរាគានុបស្សនា វិបស្សនាពលំ និរោធានុបស្សនា

សមថៈ ធម្មជាតមិនកម្រើកក្នុងបីតិ ដោយតតិយជ្ឈាន ឈ្មោះថាកម្លាំងសមថៈ ធម្មជាតមិនកម្រើកក្នុងសុខនិងទុក្ខ ដោយចតុត្ថជ្ឈាន ឈ្មោះថាកម្លាំងសមថៈ ធម្មជាតមិនកម្រើកក្នុងរូបសញ្ញា ក្នុងបដិឃសញ្ញាក្នុងនានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ ឈ្មោះថាកម្លាំងសមថៈ ធម្មជាតមិនកម្រើកក្នុងអាកាសានញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ ឈ្មោះថាកម្លាំងសមថៈ ធម្មជាតមិនកម្រើកក្នុងវិញ្ញាណញ្ចាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ ឈ្មោះថាកម្លាំងសមថៈ ធម្មជាតមិនកម្រើកក្នុងអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថាកម្លាំងសមថៈ ធម្មជាតមិនកម្រើក មិនឃ្លេងឃ្លោង មិនញាប់ញ័រ ក្នុងឧទ្ធច្ចៈផង ក្នុងកិលេសដែលប្រកបដោយឧទ្ធច្ចៈផង ក្នុងខន្ធផង ឈ្មោះថាកម្លាំងសមថៈ នេះកម្លាំងសមថៈ ។

[២២០] កម្លាំងវិបស្សនា តើដូចម្តេច ។ ការឃើញរឿយ ៗ ថាមិនទៀង ឈ្មោះថាកម្លាំងវិបស្សនា ការឃើញរឿយ ៗ ថាជាទុក្ខ ឈ្មោះថាកម្លាំងវិបស្សនា ការឃើញរឿយ ៗ ថា មិនមែនខ្លួន ឈ្មោះថាកម្លាំងវិបស្សនា ការឃើញរឿយ ៗ ថាគួរនឿយណាយ ឈ្មោះថាកម្លាំងវិបស្សនា ការឃើញរឿយ ៗ ថាជាគ្រឿងប្រាសចាកតម្រេក ឈ្មោះថាកម្លាំងវិបស្សនា ការឃើញរឿយ ៗ ថាជាទីរំលត់ទុក្ខ ឈ្មោះថាកម្លាំងវិបស្សនា

វិបស្សនាពលំ បដិនិស្សគ្គានុបស្សនា វិបស្សនាពលំ រូបេ អនិច្ចានុបស្សនា វិបស្សនាពលំ ។ បេ ។ រូបេ បដិនិស្សគ្គានុបស្សនា វិបស្សនាពលំ វេទនាយ ។ បេ ។ សញ្ញាយ សង្ខារេសុ វិញ្ញាណេ ចក្ខុស្មឹ ។ បេ ។ ជរាមរណេ អនិច្ចានុបស្សនា វិបស្សនាពលំ ។ បេ ។ ជរាមរណេ បដិនិស្សគ្គានុបស្សនា វិបស្សនាពលំ ។

[២២១] វិបស្សនាពលន្តិ កេនដ្ឋេន វិបស្សនាពលំ ។ អនិច្ចានុបស្សនាយ និច្ចសញ្ញាយ ន កម្បតីតិ វិបស្សនាពលំ ទុក្ខានុបស្សនាយ សុខសញ្ញាយ ន កម្បតីតិ វិបស្សនាពលំ អនត្តានុបស្សនាយ អត្តសញ្ញាយ ន កម្បតីតិ វិបស្សនាពលំ និព្វិទានុបស្សនាយ នន្ទិយា ន កម្បតីតិ វិបស្សនាពលំ វិរាគានុបស្សនាយ រាគេ ន កម្បតីតិ វិបស្សនាពលំ និរោធានុបស្សនាយ សមុទយេ ន កម្បតីតិ វិបស្សនាពលំ បដិនិស្សគ្គានុបស្សនាយ អាទានេ ន កម្បតីតិ វិបស្សនាពលំ អវិជ្ជាយ ច អវិជ្ជាសហគតកិលេសេ ច ខន្ធេ ច ន កម្បតីតិ ន ចលតិ ន វេធតីតិ វិបស្សនាពលំ ឥទំ វិបស្សនាពលំ ។

ការឃើញរឿយ ៗ ថា គួរលះបង់ ឈ្មោះថាកម្លាំងវិបស្សនា ការឃើញរឿយ ៗ ថា មិនទៀងក្នុងរូប ឈ្មោះថាកម្លាំងវិបស្សនា ។ បេ ។ ការឃើញរឿយ ៗ ថា ជាគ្រឿងលះបង់ក្នុងរូប ឈ្មោះថាកម្លាំងវិបស្សនា ការឃើញរឿយ ៗ ថា មិនទៀង ក្នុងវេទនា ។ បេ ។ ក្នុងសញ្ញា ក្នុងសង្ខារ ក្នុងវិញ្ញាណ ក្នុងចក្ខុ ។ បេ ។ ក្នុងជរាមរណៈ ឈ្មោះថាកម្លាំងវិបស្សនា ។ បេ ។ ការឃើញរឿយ ៗ ថា ជាគ្រឿងលះបង់ក្នុងជរាមរណៈ ឈ្មោះថាកម្លាំងវិបស្សនា ។

[២២១] សំណួរត្រង់ពាក្យថា កម្លាំងវិបស្សនា តើកម្លាំងវិបស្សនាដោយអត្ថដូចម្តេច ។ ធម្មជាតមិនកម្រើកក្នុងនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា ឈ្មោះថាកម្លាំងវិបស្សនា ធម្មជាតមិនកម្រើកក្នុងសុខសញ្ញា ដោយទុក្ខានុបស្សនា ឈ្មោះថាកម្លាំងវិបស្សនា ធម្មជាតមិនកម្រើកក្នុងអត្តសញ្ញា ដោយអនត្តានុបស្សនា ឈ្មោះថាកម្លាំងវិបស្សនា ធម្មជាតមិនកម្រើកក្នុងសេចក្តីត្រេកអរ ដោយនិព្វិទានុបស្សនា ឈ្មោះថាកម្លាំងវិបស្សនា ធម្មជាតមិនកម្រើកក្នុងរាគៈ ដោយវិរាគានុបស្សនា ឈ្មោះថាកម្លាំងវិបស្សនា ធម្មជាតមិនកម្រើកក្នុងកិរិយាកើតឡើង ដោយនិរោធានុបស្សនា ឈ្មោះថាកម្លាំងវិបស្សនា ធម្មជាតមិនកម្រើកក្នុងសេចក្តីប្រកាន់មាំ ដោយបដិនិស្សគ្គានុបស្សនា ឈ្មោះថាកម្លាំងវិបស្សនា ធម្មជាតមិនកម្រើក មិនឃ្លេងឃ្លោង មិនញាប់ញ័រ ក្នុងអវិជ្ជាផង ក្នុងកិលេសដែលប្រកបដោយអវិជ្ជាផង ក្នុងខន្ធផង ឈ្មោះថាកម្លាំងវិបស្សនា នេះកម្លាំងវិបស្សនា ។

[២២២] តយោ ច សង្ខារានំ បដិប្បស្សទ្ធិយាតិ កាតមេសំ តិណ្ណន្នំ សង្ខារានំ បដិប្បស្សទ្ធិយា ។ ទុតិយជ្ឈានំ សមាបន្នស្ស វិតក្កវិចារា វចីសង្ខារា បដិប្បស្សទ្ធា ហោន្តិ ចតុត្ថជ្ឈានំ សមាបន្នស្ស អស្សា-សបស្សាសា កាយសង្ខារា បដិប្បស្សទ្ធា ហោន្តិ សញ្ញាវេទយិតនិរោធំ សមាបន្នស្ស សញ្ញា ច វេទនា ច ចិត្តសង្ខារា បដិប្បស្សទ្ធា ហោន្តិ ឥមេសំ តិណ្ណន្នំ សង្ខារានំ បដិប្បស្សទ្ធិយា ។

[២២៣] សោឡសហិ ញាណចរិយាហីតិ កាតមា-ហិ សោឡសហិ ញាណចរិយាហិ ។ អនិច្ចានុបស្សនា ញាណចរិយា ទុក្ខានុបស្សនា ញាណចរិយា អនត្តា-នុបស្សនា ញាណចរិយា និព្វិទានុបស្សនា ញាណ-ចរិយា វិរាគានុបស្សនា ញាណចរិយា និរោធានុបស្ស-នា ញាណចរិយា បដិនិស្សគ្គានុបស្សនា ញាណចរិ-យា វិវដ្ដនានុបស្សនា ញាណចរិយា សោតាបត្តិមគ្គោ ញាណចរិយា សោតាបត្តិផលសមាបត្តិ ញាណចរិយា

[២២២] *សំណួរត្រង់ពាក្យថា ការស្ងប់រម្ងាប់នៃសង្ខារ ៣ តើការស្ងប់រម្ងាប់នៃសង្ខារ ៣ ដូចម្តេច ។ កាលបុគ្គលចូលកាន់ទុតិយជ្ឈាន វចីសង្ខារ គឺវិតក្កៈ និងវិចារៈ រមែងស្ងប់រម្ងាប់ កាលបុគ្គលចូលកាន់ចតុត្ថជ្ឈាន កាយសង្ខារ គឺអស្សាសៈ និងបស្សាសៈ រមែងស្ងប់រម្ងាប់ កាលបុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ ចិត្តសង្ខារ គឺសញ្ញានិងវេទនា រមែងស្ងប់រម្ងាប់ នេះការស្ងប់រម្ងាប់នៃសង្ខារ ៣ ។*

[២២៣] *សំណួរត្រង់ពាក្យថា ញាណចរិយា ១៦ តើញាណចរិយា ១៦ ដូចម្តេច ។ ការឃើញរឿយ ៗ ថាមិនទៀង ឈ្មោះថាញាណចរិយា ការឃើញរឿយ ៗ ថាជាទុក្ខ ឈ្មោះថាញាណចរិយា ការឃើញរឿយ ៗ ថាមិនមែនខ្លួន ឈ្មោះថាញាណចរិយា ការឃើញរឿយ ៗ ថាគួរនឿយណាយ ឈ្មោះថាញាណចរិយា ការឃើញរឿយ ៗ ថាជាគ្រឿងប្រាសចាកតម្រេក ឈ្មោះថាញាណចរិយា ការឃើញរឿយ ៗ ថាជាគ្រឿងរំលត់ទុក្ខ ឈ្មោះថាញាណចរិយា ការឃើញរឿយ ៗ ថាជាគ្រឿងលះបង់កិលេស ឈ្មោះថាញាណចរិយា ការឃើញរឿយ ៗ ថាជាគ្រឿងប្រាសចាកការវិលវល់ ឈ្មោះថាញាណចរិយា សោតាបត្តិមគ្គ ឈ្មោះថាញាណចរិយា សោតាបត្តិផលសមាបត្តិ ឈ្មោះថាញាណចរិយា*

សកទាគាមិមគ្គោ ញាណចរិយា សកទាគាមិផលសមាបត្តិ ញាណចរិយា អនាគាមិមគ្គោ ញាណចរិយា អនាគាមិផលសមាបត្តិ ញាណចរិយា អរហត្តមគ្គោ ញាណចរិយា អរហត្តផលសមាបត្តិ ញាណចរិយា ឥមាហិ សោឡសហិ ញាណចរិយាហិ ។

[២២៤] នវហិ សមាធិចរិយាហីតិ កតមាហិ នវហិ សមាធិចរិយាហិ បឋមជ្ឈានំ សមាធិចរិយា ទុតិយជ្ឈានំ សមាធិចរិយា តតិយជ្ឈានំ សមាធិចរិយា ចតុត្ថជ្ឈានំ សមាធិចរិយា អាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ សមាធិចរិយា[១] បឋមជ្ឈានំ បដិលាភត្ថាយ វិតក្កោ ច វិចារោ ច បីតិ ច សុខញ្ច ចិត្តេកគ្គតា ច ។ បេ ។ នេវសញ្ញានាសញ្ញាយតនសមាបត្តឹ បដិលាភត្ថាយ វិតក្កោ ច វិចារោ ច បីតិ ច សុខញ្ច ចិត្តេកគ្គតា ច ឥមាហិ នវហិ[២] សមាធិចរិយាហិ ។

---

១ ឱ. ម. អាកាសានញ្ចាយតនសមាបត្តិ ។ បេ ។ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ សមាធិចរិយាតិ ទិស្សន្តិ ។ ២ ឱ. សោឡសហិ ។

សកទាគាមិមគ្គ ឈ្មោះថា ញាណចរិយា សកទាគាមិផលសមាបត្តិ ឈ្មោះថាញាណចរិយា អនាគាមិមគ្គ ឈ្មោះថាញាណចរិយា អនាគាមិ-ផលសមាបត្តិ ឈ្មោះថាញាណចរិយា អរហត្តមគ្គ ឈ្មោះថាញាណចរិយា អរហត្តផលសមាបត្តិ ឈ្មោះថាញាណចរិយា នេះញាណចរិយា ១៦ ។

[២២៤] សំណួរត្រង់ពាក្យថា សមាធិចរិយា ៩ តើសមាធិចរិយា ៩ ដូចម្តេច ។ បឋមជ្ឈាន ឈ្មោះថាសមាធិចរិយា ទុតិយជ្ឈាន ឈ្មោះថាសមាធិចរិយា តតិយជ្ឈាន ឈ្មោះថាសមាធិចរិយា ចតុត្ថជ្ឈាន ឈ្មោះថាសមាធិចរិយា អាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចា-យតនសមាបត្តិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថាសមាធិ-ចរិយា វិតក្កៈ វិចារៈ បីតិ សុខៈ និងចិត្តេកគ្គតា (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍ដល់កិរិយាបាន នូវបឋមជ្ឈាន ។ បេ ។ វិតក្កៈ វិចារៈ បីតិ សុខៈ និង ចិត្តេកគ្គតា (ប្រព្រឹត្តទៅ) ដើម្បីប្រយោជន៍ដល់កិរិយាបាន នូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ នេះសមាធិចរិយា ៩ ។

[២២៨] វសីតិ បញ្ច វសិយោ អាវជ្ជនាវសី សមាបជ្ជនាវសី អធិដ្ឋានវសី វុដ្ឋានវសី បច្ចវេក្ខណាវសី ។ បឋមជ្ឈានំ យត្ថិច្ឆកំ យទិច្ឆកំ យាវតិច្ឆកំ អាវជ្ជតិ[១] អាវជ្ជនាយ ទន្ធាយិតត្តំ នត្ថីតិ អាវជ្ជនាវសី បឋមជ្ឈានំ យត្ថិច្ឆកំ យទិច្ឆកំ យាវតិច្ឆកំ សមាបជ្ជតិ សមាបជ្ជនាយ ទន្ធាយិតត្តំ នត្ថីតិ សមាបជ្ជនាវសី បឋមជ្ឈានំ យត្ថិច្ឆកំ យទិច្ឆកំ យាវតិច្ឆកំ អធិដ្ឋាតិ អធិដ្ឋានេ ទន្ធាយិតត្តំ នត្ថីតិ អធិដ្ឋានវសី បឋមជ្ឈានំ យត្ថិច្ឆកំ យទិច្ឆកំ យាវតិច្ឆកំ វុដ្ឋាតិ វុដ្ឋានេ ទន្ធាយិតត្តំ នត្ថីតិ វុដ្ឋានវសី បឋមជ្ឈានំ យត្ថិច្ឆកំ យទិច្ឆកំ យាវតិច្ឆកំ បច្ចវេក្ខតិ បច្ចវេក្ខណាយ ទន្ធាយិតត្តំ នត្ថីតិ បច្ចវេក្ខណាវសី ទុតិយជ្ឈានំ ។ បេ ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិ យត្ថិច្ឆកំ យទិច្ឆកំ

---

១ ម. អាបជ្ជតិ ។

[២២៥] ពាក្យថា សេចក្ដីស្ទាត់ អធិប្បាយថា សេចក្ដីស្ទាត់មាន ៥ យ៉ាង គឺសេចក្ដីស្ទាត់ក្នុងការនឹក ១ សេចក្ដីស្ទាត់ក្នុងការចូល ១ សេចក្ដីស្ទាត់ក្នុងការអធិដ្ឋាន ១ សេចក្ដីស្ទាត់ក្នុងការចេញ ១ សេចក្ដីស្ទាត់ក្នុងការពិចារណា ១ ។ បុគ្គលនឹកនូវបឋមជ្ឈានដែលខ្លួនប្រាថ្នាក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា សេចក្ដីយឺតយូរក្នុងការនឹកមិនមាន ហេតុនោះ ឈ្មោះថាសេចក្ដីស្ទាត់ក្នុងការនឹក បុគ្គលចូលកាន់បឋមជ្ឈានដែលខ្លួនប្រាថ្នាក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា សេចក្ដីយឺតយូរក្នុងការចូលមិនមាន ហេតុនោះ ឈ្មោះថាសេចក្ដីស្ទាត់ក្នុងការចូល បុគ្គលអធិដ្ឋាននូវបឋមជ្ឈានដែលខ្លួនប្រាថ្នាក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា សេចក្ដីយឺតយូរក្នុងការអធិដ្ឋានមិនមាន ហេតុនោះ ឈ្មោះថាសេចក្ដីស្ទាត់ក្នុងការអធិដ្ឋាន បុគ្គលចេញអំពីបឋមជ្ឈានដែលខ្លួនប្រាថ្នាក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា សេចក្ដីយឺតយូរក្នុងការចេញមិនមាន ហេតុនោះ ឈ្មោះថាសេចក្ដីស្ទាត់ក្នុងការចេញ បុគ្គលពិចារណានូវបឋមជ្ឈានដែលខ្លួនប្រាថ្នាក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា សេចក្ដីយឺតយូរក្នុងការពិចារណាមិនមាន ហេតុនោះ ឈ្មោះថាសេចក្ដីស្ទាត់ក្នុងការពិចារណា បុគ្គលនឹកនូវទុតិយជ្ឈាន ។ បេ ។ នូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ដែលខ្លួនប្រាថ្នាក្នុងទីណា

យាវតិច្ឆកំ អាវជ្ជតិ[១] អាវជ្ជនាយ ទន្ធាយិតត្តំ នត្ថីតិ អាវជ្ជនាវសី នេវសញ្ញានាសញ្ញាយតនសមាបត្តិ យត្ថិច្ឆកំ យទិច្ឆកំ យាវតិច្ឆកំ សមាបជ្ជតិ ។ បេ ។ អធិដ្ឋាតិ វុដ្ឋាតិ បច្ចវេក្ខតិ បច្ចវេក្ខណាយ ទន្ធាយិតត្តំ នត្ថីតិ បច្ចវេក្ខណាវសី ឥមា បញ្ច វសិយោ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ទ្វីហិ ពលេហិ សមន្នាគតត្តា តយោ ច សង្ខារានំ បដិប្បស្សទ្ធិយា សោឡសហិ ញាណចរិយាហិ នវហិ សមាធិចរិយាហិ វសីភាវតា បញ្ញា និរោធសមាបត្តិយា ញាណំ ។

[២២៦] កថំ សម្បជានស្ស បវត្តបរិយាទានេ បញ្ញា បរិនិព្វានេ ញាណំ ។ ឥធ សម្បជានោ នេក្ខម្មេន កាមច្ឆន្ទស្ស បវត្តំ បរិយាទិយតិ អព្យាបាទេន ព្យាបាទស្ស បវត្តំ បរិយាទិយតិ អាលោកសញ្ញាយ ថីនមិទ្ធស្ស បវត្តំ បរិយាទិយតិ អវិក្ខេបេន ឧទ្ធច្ចស្ស បវត្តំ បរិយាទិយតិ ធម្មវវត្ថានេន វិចិកិច្ឆាយ ។ បេ ។

១ អាវជ្ជេតិ ។

ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា សេចក្តីយឺតយូរក្នុងការទឹកមិនមាន ហេតុនោះ ឈ្មោះថាសេចក្តីស្ទាត់ក្នុងការទឹក បុគ្គលចូលកាន់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ដែលខ្លួនប្រាថ្នាក្នុងទីណា ប្រាថ្នាក្នុងកាលណា ប្រាថ្នាត្រឹមណា ។ បេ ។ បុគ្គលអធិដ្ឋាន ចេញ ពិចារណា សេចក្តីយឺតយូរក្នុងការពិចារណាមិនមាន ហេតុនោះ ឈ្មោះថាសេចក្តីស្ទាត់ក្នុងការពិចារណា នេះឯង សេចក្តីស្ទាត់ ៥ យ៉ាង ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាគឺភាវៈនៃសេចក្តីស្ទាត់ ព្រោះហេតុប្រកបដោយកម្លាំងទាំង ២ ផង ដោយការស្ងប់រម្ងាប់សង្ខារ ៣ ផង ដោយញាណចរិយា ១៦ ផង ដោយសមាធិចរិយា ៩ ផង ឈ្មោះថានិរោធសមាបត្តិញ្ញាណ ។

[២២៦] បញ្ញាក្នុងការបង្អស់ នូវការប្រព្រឹត្តទៅ នៃកិលេសនិងខន្ធ របស់បុគ្គលអ្នកដឹងខ្លួន ឈ្មោះថាបរិនិព្វានញ្ញាណ តើដូចម្តេច ។ បុគ្គលដឹងខ្លួន ក្នុងលោកនេះ បង្អស់នូវការប្រព្រឹត្តទៅ នៃកាមច្ឆន្ទៈ ដោយនេក្ខម្មៈ បង្អស់នូវការប្រព្រឹត្តទៅ នៃព្យាបាទ ដោយអព្យាបាទ បង្អស់នូវការប្រព្រឹត្តទៅ នៃថីនមិទ្ធៈ ដោយអាលោកសញ្ញា បង្អស់នូវការប្រព្រឹត្តទៅនៃឧទ្ធច្ចៈ ដោយអវិក្ខេបៈ បង្អស់នូវការប្រព្រឹត្តទៅ នៃវិចិកិច្ឆា ដោយធម្មវវត្ថានៈ ។ បេ ។

ញាណេន អវិជ្ជាយ ចាមុជ្ជេន អរតិយា បឋមជ្ឈានេន នីវរណានំ បវត្តំ បរិយាទិយតិ ។ បេ ។ អរហត្តមគ្គេន សព្វកិលេសានំ បវត្តំ បរិយាទិយតិ អថវា បន សម្បជានស្ស អនុបាទិសេសាយ និព្វានធាតុយា និព្វាយន្តស្ស(១) ឥទញ្ចេវ ចក្ខុប្បវត្តំ បរិយាទិយតិ អញ្ញញ្ច ចក្ខុបវត្តំ ន ឧប្បជ្ជតិ ឥទញ្ចេវ សោតប្ប-វត្តំ ។ បេ ។ ឃានប្បវត្តំ ជិវ្ហាបវត្តំ កាយប្បវត្តំ មនោបវត្តំ បរិយាទិយតិ អញ្ញញ្ច មនោបវត្តំ ន ឧប្បជ្ជតិ ឥទំ សម្បជានស្ស បវត្តបរិយាទានេ បញ្ញា បរិនិព្វានេ ញាណំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ សម្បជានស្ស បវត្តបរិយាទានេ បញ្ញា បរិនិព្វានេ ញាណំ ។

[២២៧] កថំ សព្វធម្មានំ សម្មាសមុច្ឆេទេ និរោធេ ច អនុបដ្ឋានតា បញ្ញា សមសីសដ្ឋេ ញាណំ ។

សព្វធម្មានន្តិ បញ្ចក្ខន្ធា ទ្វាទសាយតនានិ អ-ដ្ឋារស ធាតុយោ កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា កាមាវចរា ធម្មា រូបាវចរា ធម្មា អរូបាវចរា ធម្មា អបរិយាបន្នា ធម្មា ។

---

១ ឱ. ម. បរិនិព្វាយន្តស្ស ។

នៃអវិជ្ជា ដោយញាណ នៃអរតិ ដោយបាមុជ្ជៈ នៃនីវរណៈទាំងឡាយ ដោយបឋមជ្ឈាន ។ បេ ។ បង្អស់នូវការប្រព្រឹត្តទៅ នៃកិលេសទាំងអស់ ដោយអរហត្តមគ្គម្យ៉ាងទៀត កាលបុគ្គលអ្នកដឹងខ្លួន និព្វាន ដោយអនុបាទិសេសនិព្វានធាតុ ការប្រព្រឹត្តទៅនៃចក្ខុនេះ រមែងអស់ទៅ ទាំងការប្រព្រឹត្តដទៃនៃចក្ខុ ក៏មិនកើតឡើងដែរ ការប្រព្រឹត្តទៅនៃសោតៈនេះ ។ បេ ។ ការប្រព្រឹត្តទៅនៃឃានៈ ការប្រព្រឹត្តទៅនៃជិវ្ហា ការប្រព្រឹត្តទៅនៃកាយ ការប្រព្រឹត្តទៅនៃចិត្ត រមែងអស់ទៅ ទាំងការប្រព្រឹត្តដទៃ នៃចិត្ត ក៏មិនកើតឡើងដែរ នេះឯងបញ្ញាក្នុងការបង្អស់នូវការប្រព្រឹត្តទៅ នៃកិលេស និងខន្ធ របស់បុគ្គលអ្នកដឹងខ្លួន ឈ្មោះថាបរិនិព្វានញ្ញាណ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថាបញ្ញា ក្នុងការបង្អស់នូវការប្រព្រឹត្តទៅនៃកិលេស របស់បុគ្គលអ្នកដឹងខ្លួន ឈ្មោះថាបរិនិព្វានញ្ញាណ ។

[២២៧] បញ្ញា គឺការមិនប្រាកដក្នុងការផ្តិលផ្តាច់ដោយប្រពៃនូវធម៌ទាំងពួងផង ក្នុងការរំលត់ផង ឈ្មោះថាសមសីសដ្ឋញ្ញាណ តើដូចម្តេច ។

ពាក្យថា ធម៌ទាំងពួង បានដល់ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ពួកកុសលធម៌ ពួកអកុសលធម៌ ពួកអព្យាកតធម៌ ពួកកាមាវចរ-ធម៌ ពួករូបាវចរធម៌ ពួកអរូបាវចរធម៌ ពួកអបរិយាបន្នធម៌ ។

[២២៨] សម្មាសមុច្ឆេទេតិ នេក្ខម្មេន កាមច្ឆន្ទំ សម្មា សមុច្ឆិន្ទតិ អព្យាបាទេន ព្យាបាទំ សម្មា សមុច្ឆិន្ទតិ អាលោកសញ្ញាយ ថីនមិទ្ធំ សម្មា សមុច្ឆិន្ទតិ អវិក្ខេបេន ឧទ្ធច្ចំ សម្មា សមុច្ឆិន្ទតិ ធម្មវវត្ថានេន វិចិកិច្ឆំ សម្មា សមុច្ឆិន្ទតិ ញាណេន អវិជ្ជំ សម្មា សមុច្ឆិន្ទតិ បាមុជ្ជេន អរតឹ សម្មា សមុច្ឆិន្ទតិ បឋមជ្ឈានេន នីវរណេ សម្មា សមុច្ឆិន្ទតិ ។ បេ ។ អរហត្តមគ្គេន សព្វកិលេសេ សម្មា សមុច្ឆិន្ទតិ ។

[២២៩] និរោធេតិ នេក្ខម្មេន កាមច្ឆន្ទំ និរោធេតិ អព្យាបាទេន ព្យាបាទំ និរោធេតិ អាលោកសញ្ញាយ ថីនមិទ្ធំ និរោធេតិ អវិក្ខេបេន ឧទ្ធច្ចំ និរោធេតិ ធម្មវវត្ថានេន វិចិកិច្ឆំ និរោធេតិ ញាណេន អវិជ្ជំ និរោធេតិ បាមុជ្ជេន អរតឹ និរោធេតិ បឋមជ្ឈានេន នីវរណេ និរោធេតិ ។ បេ ។ អរហត្តមគ្គេន សព្វកិលេសេ និរោធេតិ ។

[២៣០] អនុបដ្ឋានតាតិ នេក្ខម្មំ បដិលទ្ធស្ស កាមច្ឆន្ទោ ន ឧបដ្ឋាតិ អព្យាបាទំ បដិលទ្ធស្ស ព្យាបាទោ ន ឧបដ្ឋាតិ អាលោកសញ្ញំ បដិលទ្ធស្ស ថីនមិទ្ធំ

[២២៨] ពាក្យថា ការផ្តិលផ្តាច់ ដោយប្រពៃ អធិប្បាយថា បុគ្គលកាត់ផ្តាច់ដោយប្រពៃនូវកាមច្ឆន្ទៈ ដោយនេក្ខម្មៈ កាត់ផ្តាច់ដោយប្រពៃនូវព្យាបាទដោយអព្យាបាទ កាត់ផ្តាច់ដោយប្រពៃនូវថីនមិទ្ធៈ ដោយអាលោកសញ្ញា កាត់ផ្តាច់ដោយប្រពៃនូវឧទ្ធច្ចៈ ដោយអវិក្ខេបៈ កាត់ផ្តាច់ដោយប្រពៃនូវវិចិកិច្ឆា ដោយធម្មវវត្ថានៈ កាត់ផ្តាច់ដោយប្រពៃនូវអវិជ្ជា ដោយញាណ កាត់ផ្តាច់ដោយប្រពៃនូវអរតិ ដោយបាមុជ្ជៈ កាត់ផ្តាច់ដោយប្រពៃនូវពួកនីវរណៈ ដោយបឋមជ្ឈាន ។ បេ ។ កាត់ផ្តាច់ដោយប្រពៃនូវកិលេសទាំងពួង ដោយអរហត្តមគ្គ ។

[២២៩] ពាក្យថា ការរំលត់ គឺបុគ្គលរំលត់ នូវកាមច្ឆន្ទៈ ដោយនេក្ខម្មៈ រំលត់នូវព្យាបាទ ដោយអព្យាបាទ រំលត់នូវថីនមិទ្ធៈ ដោយអាលោកសញ្ញា រំលត់នូវឧទ្ធច្ចៈ ដោយអវិក្ខេបៈ រំលត់នូវវិចិកិច្ឆា ដោយធម្មវវត្ថានៈ រំលត់នូវអវិជ្ជា ដោយញាណ រំលត់នូវអរតិ ដោយបាមុជ្ជៈ រំលត់នូវពួកនីវរណៈ ដោយបឋមជ្ឈាន ។ បេ ។ រំលត់នូវពួកកិលេសទាំងពួង ដោយអរហត្តមគ្គ ។

[២៣០] ពាក្យថា មិនប្រាកដ គឺ កាលបុគ្គលបានសិប់នូវនេក្ខម្មៈ កាមច្ឆន្ទៈមិនប្រាកដ កាលបុគ្គលបានសិប់ នូវអព្យាបាទ ព្យាបាទមិនប្រាកដ កាលបុគ្គលបានសិប់ នូវអាលោកសញ្ញា ថីនមិទ្ធៈមិនប្រាកដ

ន ឧបដ្ឋាតិ អភិក្ខេបំ បដិលទ្ធស្ស ឧទ្ធច្ចំ ន ឧបដ្ឋាតិ ធម្មវវត្ថានំ បដិលទ្ធស្ស វិចិកិច្ឆា ន ឧបដ្ឋាតិ ញាណំ បដិលទ្ធស្ស អវិជ្ជា ន ឧបដ្ឋាតិ បាមុជ្ជំ បដិលទ្ធស្ស អរតិ ន ឧបដ្ឋាតិ បឋមជ្ឈានំ បដិលទ្ធស្ស នីវរណា ន ឧបដ្ឋន្តិ[១] ។ បេ ។ អរហត្តមគ្គំ បដិលទ្ធស្ស សព្វកិលេសា ន ឧបដ្ឋន្តិ ។

[២៣១] សមន្តិ កាមច្ឆន្ទស្ស បហីនត្តា នេក្ខម្មំ សមំ ព្យាបាទស្ស បហីនត្តា អព្យាបាទោ សមំ ថីនមិទ្ធស្ស បហីនត្តា អាលោកសញ្ញា សមំ ឧទ្ធច្ចស្ស បហីនត្តា អវិក្ខេបោ សមំ វិចិកិច្ឆាយ បហីនត្តា ធម្មវវត្ថានំ សមំ អវិជ្ជាយ បហីនត្តា ញាណំ សមំ អរតិយា បហីនត្តា បាមុជ្ជំ សមំ នីវរណានំ បហីនត្តា បឋមជ្ឈានំ សមំ ។ បេ ។ សព្វក្កិលេសានំ បហីនត្តា អរហត្តមគ្គោ សមំ ។

[២៣២] សីសន្តិ តេរស សីសានិ បលិពោធសីសញ្ច តណ្ហា ពន្ធនសីសញ្ច[២] មានោ បរាមាសសីសញ្ច ទិដ្ឋិ វិក្ខេបសីសញ្ច ឧទ្ធច្ចំ

១ ម. ឧបដ្ឋហន្តិ ។ ២ ឱ. ម. វិនិពន្ធនសីសញ្ច ។

កាលបុគ្គលបានសិប់នូវអវិក្ខេបៈ ឧទ្ធច្ចៈ មិនប្រាកដ កាលបុគ្គលបាន សិប់នូវធម្មវវត្ថានៈ វិចិកិច្ឆា មិនប្រាកដ កាលបុគ្គលបានសិប់នូវញាណ អវិជ្ជា មិនប្រាកដ កាលបុគ្គលបានសិប់នូវបាមុជ្ជៈ អរតិ មិនប្រាកដ កាលបុគ្គលបានសិប់នូវបឋមជ្ឈាន ពួកនីវរណៈ មិនប្រាកដ ។ បេ ។ កាលបុគ្គលបានសិប់នូវអរហត្តមគ្គ ពួកកិលេសទាំងពួង មិនប្រាកដ ។

[២៣១] ពាក្យថា ស្ងប់រម្ងាប់ សេចក្តីថា នេក្ខម្មៈ ឈ្មោះថាស្ងប់រម្ងាប់ ព្រោះលះបង់កាមច្ឆន្ទៈ អព្យាបាទ ឈ្មោះថាស្ងប់រម្ងាប់ ព្រោះលះបង់ព្យាបាទ អាលោកសញ្ញា ឈ្មោះថាស្ងប់រម្ងាប់ ព្រោះលះបង់ថីនមិទ្ធៈ អវិក្ខេបៈ ឈ្មោះថាស្ងប់រម្ងាប់ ព្រោះលះបង់ឧទ្ធច្ចៈ ធម្មវវត្ថានៈ ឈ្មោះថាស្ងប់រម្ងាប់ ព្រោះលះបង់វិចិកិច្ឆា ញាណ ឈ្មោះថាស្ងប់រម្ងាប់ ព្រោះលះបង់អវិជ្ជា បាមុជ្ជៈ ឈ្មោះថាស្ងប់រម្ងាប់ ព្រោះលះបង់អរតិ បឋមជ្ឈាន ឈ្មោះថាស្ងប់រម្ងាប់ ព្រោះលះបង់នីវរណៈ ។ បេ ។ អរហត្តមគ្គ ឈ្មោះថាស្ងប់រម្ងាប់ ព្រោះលះបង់កិលេសទាំងពួង ។

[២៣២] ពាក្យថា ជាប្រធាន[១] សេចក្តីថា ប្រធាន ១៣ យ៉ាង គឺ តណ្ហា ជាប្រធានក្នុងបលិពោធ (ការរារាំងផ្លូវនិព្វាន) ១ មានះ ជា ប្រធានក្នុងការជាប់ចំពាក់ ១ ទិដ្ឋិ ជាប្រធានក្នុងការស្ទាបអង្អែល ១

១ "ប្រធាន" បាលីថា "សីសំ" ប្រែថា "ប្រធាន" ក៏បាន ថា "ក្បាល" ក៏បាន ។

កិលេសសីសញ្ច អវិជ្ជា អធិមោក្ខសីសញ្ច សទ្ធា បគ្គហសីសញ្ច វីរិយំ ឧបដ្ឋានសីសញ្ច សតិ អវិក្ខេបសីសញ្ច សមាធិ ទស្សនសីសញ្ច បញ្ញា បវត្តសីសញ្ច ជីវិតិន្ទ្រិយំ គោចរសីសញ្ច វិមោក្ខោ សង្ខារសីសញ្ច និរោធោ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ សព្វធម្មានំ សមុច្ឆេទេ និរោធេ ច អនុបដ្ឋានតា បញ្ញា សមសីសដ្ឋេ ញាណំ ។

[២៣៣] កថំ បុថុនានត្តេកត្តតេជបរិយាទានេ បញ្ញា សល្លេខដ្ឋេ ញាណំ ។

បុថូតិ រាគោ បុថុ ទោសោ បុថុ មោហោ បុថុ កោធោ ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ សព្វេ កិលេសា សព្វេ ទុច្ចរិតា សព្វេ អភិសង្ខារា សព្វេ ភវគាមិកម្មា បុថុ(២) ។

---

១ ម. សង្កិលេសសីសញ្ច ។ ២ ម. អយំ បាឋោ នត្ថិ ។

ឧទ្ធច្ចៈ ជាប្រធានក្នុងការរាយមាយ ១ អវិជ្ជា ជាប្រធានក្នុងសេចក្ដីសៅហ្មង ១ សទ្ធា ជាប្រធានក្នុងសេចក្ដីជឿស៊ប់ ១ វិរិយៈ ជាប្រធានក្នុងការផ្គងឡើង ១ សតិ ជាប្រធានក្នុងការប្រុងប្រយ័ត្ន ១ សមាធិ ជាប្រធានក្នុងការមិនរាយមាយ ១ បញ្ញា ជាប្រធានក្នុងការយល់ឃើញ ១ ជីវិតិន្ទ្រិយ ជាប្រធានក្នុងការប្រព្រឹត្ត ១ វិមោក្ខ ជាប្រធានក្នុងគោចរ ១ និរោធ ជាប្រធានក្នុងសង្ខារ ១ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះលោកពោលថា បញ្ញា មិនប្រាកដក្នុងការផ្ដិលផ្ដាច់ដោយប្រពៃ នូវធម៌ទាំងពួងផង ក្នុងការរំលត់ផង ឈ្មោះថាសមសីសដ្ឋញ្ញាណ ។

[២៣៣] បញ្ញាក្នុងការរំលត់នូវភ្លើងដ៏ក្រាស់មានភាពផ្សេង ៗ និងមានភាពតែមួយ ឈ្មោះថា សល្លេខដ្ឋញ្ញាណ តើដូចម្ដេច ។

ពាក្យថា ក្រាស់ សេចក្ដីថា ក្រាស់ គឺរាគៈ ក្រាស់ គឺទោសៈ ក្រាស់ គឺមោហៈ ក្រាស់ គឺកោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ កិលេសទាំងពួង ទុច្ចរិតទាំងពួង អភិសង្ខារទាំងពួង ភវគាមិកម្មទាំងពួង ។

[២៣៨] ណានត្តេកត្តន្តិ កាមច្ឆន្ទោ ណានត្តំ នេក្ខម្មំ ឯកត្តំ ព្យាបាទោ ណានត្តំ អព្យាបាទោ ឯកត្តំ ថីនមិទ្ធំ ណានត្តំ អាលោកសញ្ញា ឯកត្តំ ឧទ្ធច្ចំ ណានត្តំ អវិក្ខេបោ ឯកត្តំ វិចិកិច្ឆា ណានត្តំ ធម្មវវត្ថានំ ឯកត្តំ អវិជ្ជា ណានត្តំ ញាណំ ឯកត្តំ អរតិ ណានត្តំ បាមុជ្ជំ ឯកត្តំ នីវរណា ណានត្តំ បឋមជ្ឈានំ ឯកត្តំ ។ បេ ។ សព្វេ កិលេសា ណានត្តំ អរហត្តមគ្គោ ឯកត្តំ ។

[២៣៩] តេជោតិ បញ្ច តេជា ចរណតេជោ គុណតេជោ បញ្ញាតេជោ បុញ្ញតេជោ ធម្មតេជោ ចរណតេជេន តេជិតត្តា ទុស្សីល្យតេជំ បរិយាទិយតិ គុណតេជេន តេជិតត្តា អគុណតេជំ បរិយាទិយតិ បញ្ញាតេជេន តេជិតត្តា ទុប្បញ្ញាតេជំ បរិយាទិយតិ បុញ្ញតេជេន តេជិតត្តា អបុញ្ញតេជំ បរិយាទិយតិ ធម្មតេជេន តេជិតត្តា អធម្មតេជំ បរិយាទិយតិ ។

[២៣៤] ពាក្យថា ភាពផ្សេង ៗ និងភាពតែមួយ គឺកាមច្ឆន្ទៈ ឈ្មោះថាភាពផ្សេង ៗ នេក្ខម្មៈ ឈ្មោះថាភាពតែមួយ ព្យាបាទ ឈ្មោះថាភាពផ្សេង ៗ អព្យាបាទ ឈ្មោះថាភាពតែមួយ ថីនមិទ្ធៈ ឈ្មោះថាភាពផ្សេង ៗ អាលោកសញ្ញា ឈ្មោះថាភាពតែមួយ ឧទ្ធច្ចៈ ឈ្មោះថាភាពផ្សេង ៗ អវិក្ខេបៈ ឈ្មោះថាភាពតែមួយ វិចិកិច្ឆា ឈ្មោះថាភាពផ្សេង ៗ ធម្មវវត្ថានៈ ឈ្មោះថាភាពតែមួយ អវិជ្ជា ឈ្មោះថាភាពផ្សេង ៗ ញាណ ឈ្មោះថាភាពតែមួយ អរតិ ឈ្មោះថាភាពផ្សេង ៗ បាមុជ្ជៈ ឈ្មោះថាភាពតែមួយ នីវរណៈ ឈ្មោះថាភាពផ្សេងៗ បឋមជ្ឈាន ឈ្មោះថាភាពតែមួយ ។ បេ ។ កិលេសទាំងពួង ឈ្មោះថាភាពផ្សេង ៗ អរហត្តមគ្គ ឈ្មោះថាភាពតែមួយ ។

[២៣៥] ពាក្យថា ភ្លើង សេចក្តីថា ភ្លើង ៥ ភ្លើងគឺចរណៈ (ចរណតេជៈ) ១ ភ្លើងគឺគុណ (គុណតេជៈ) ១ ភ្លើងគឺប្រាជ្ញា (បញ្ញាតេជៈ) ១ ភ្លើងគឺបុណ្យ (បុញ្ញតេជៈ) ១ ភ្លើងគឺធម៌ (ធម្មតេជៈ) ១ បុគ្គលលត់ភ្លើងគឺភាពទ្រុស្តសីល ព្រោះដុតកម្តៅ ដោយភ្លើងគឺចរណៈ លត់ភ្លើងគឺការមិនមានគុណ ព្រោះដុតកម្តៅដោយភ្លើងគឺគុណ លត់ភ្លើងគឺការមិនមានប្រាជ្ញា ព្រោះដុតកម្តៅដោយភ្លើងគឺបញ្ញា លត់ភ្លើងគឺឥតបុណ្យ ព្រោះដុតកម្តៅដោយភ្លើងគឺបុណ្យ លត់ភ្លើងគឺអធម៌ ព្រោះដុតកម្តៅ ដោយភ្លើងគឺធម៌ ។

[២៣៦] សល្លេខោតិ កាមច្ឆន្ទោ អសល្លេខោ នេក្ខម្មំ សល្លេខោ ព្យាបាទោ អសល្លេខោ អព្យាបាទោ សល្លេខោ ថីនមិទ្ធំ អសល្លេខោ អាលោកសញ្ញា សល្លេខោ ឧទ្ធច្ចំ អសល្លេខោ អវិក្ខេបោ សល្លេខោ វិចិកិច្ឆា អសល្លេខោ ធម្មវវត្ថានំ សល្លេខោ អវិជ្ជា អសល្លេខោ ញាណំ សល្លេខោ អរតិ អសល្លេខោ បាមុជ្ជំ សល្លេខោ នីវរណា អសល្លេខោ បឋមជ្ឈានំ សល្លេខោ ។ បេ ។ សព្វកិលេសា អសល្លេខោ អរហត្តមគ្គោ សល្លេខោ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ បុថុនានត្តេកត្តតេជបរិយាទានេ បញ្ញា សល្លេខដ្ឋេ ញាណំ ។

[២៣៧] កថំ អសល្លីនត្តបហិតត្តបគ្គហដ្ឋេ[១] បញ្ញា វីរិយារម្ភេ ញាណំ ។ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ អសល្លីនត្តបហិតត្តបគ្គហដ្ឋេ បញ្ញា វីរិយារម្ភេ ញាណំ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ អសល្លីនត្តបហិតត្តបគ្គហដ្ឋេ បញ្ញា វីរិយារម្ភេ ញាណំ ។

១ ម. អសល្លីនត្តំ បហិតត្តា បគ្គហដ្ឋេ ។

[២៣៦] ពាក្យថា ផ្លូវផង់ សេចក្តីថា កាមច្ឆន្ទៈ ឈ្មោះថាមិនផ្លូវផង់ នេក្ខម្មៈ ឈ្មោះថាផ្លូវផង់ ព្យាបាទៈ ឈ្មោះថាមិនផ្លូវផង់ អព្យាបាទៈ ឈ្មោះថាផ្លូវផង់ ថីនមិទ្ធៈ ឈ្មោះថាមិនផ្លូវផង់ អាលោកសញ្ញា ឈ្មោះថាផ្លូវផង់ ឧទ្ធច្ចៈ ឈ្មោះថាមិនផ្លូវផង់ អវិក្ខេបៈ ឈ្មោះថាផ្លូវផង់ វិចិកិច្ឆា ឈ្មោះថាមិនផ្លូវផង់ ធម្មវវត្ថានៈ ឈ្មោះថាផ្លូវផង់ អវិជ្ជា ឈ្មោះថាមិនផ្លូវផង់ ញាណ ឈ្មោះថាផ្លូវផង់ អរតិ ឈ្មោះថាមិនផ្លូវផង់ បាមុជ្ជៈ ឈ្មោះថាផ្លូវផង់ នីវរណៈ ឈ្មោះថាមិនផ្លូវផង់ បឋមជ្ឈាន ឈ្មោះថាផ្លូវផង់ ។ បេ ។ កិលេសទាំងពួង ឈ្មោះថាមិនផ្លូវផង់ អរហត្តមគ្គ ឈ្មោះថាផ្លូវផង់ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការរំលត់ភ្លើងដ៏ក្រាស់ មានភាពផ្សេង ៗ និងមានភាពតែមួយ ឈ្មោះថាសល្លេខដ្ឋញ្ញាណ ។

[២៣៧] បញ្ញាក្នុងការផ្គង របស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ឈ្មោះថា វីរិយារម្ភញ្ញាណ តើដូចម្តេច ។ បញ្ញាក្នុងការផ្គង របស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីមិនឲ្យកើតនូវអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត ឈ្មោះថាវីរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គង របស់បុគ្គលមានចិត្តមិនរួញរានិងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីលះបង់នូវអកុ-សលធម៌ដ៏លាមក ដែលកើតឡើងហើយ ឈ្មោះថា វីរិយារម្ភញ្ញាណ

អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ អសល្លីនត្តបហិតត្តបក្ខហាដ្ឋេ បញ្ញា វីរិយារម្ភេ ញាណំ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ ចារិបូរិយា អសល្លីនត្តបហិតត្តបក្ខហាដ្ឋេ បញ្ញា វីរិយារម្ភេ ញាណំ ។

[២៣៨] អនុប្បន្នស្ស អនុប្បាទាយ អសល្លីនត្តបហិតត្តបក្ខហាដ្ឋេ បញ្ញា វីរិយារម្ភេ ញាណំ ឧប្បន្នស្ស កាមច្ឆន្ទស្ស បហានាយ អសល្លីនត្តបហិតត្តបក្ខហាដ្ឋេ បញ្ញា វីរិយារម្ភេ ញាណំ អនុប្បន្នស្ស នេក្ខម្មស្ស ឧប្បាទាយ អសល្លីនត្តបហិតត្តបក្ខហាដ្ឋេ បញ្ញា វីរិយារម្ភេ ញាណំ ឧប្បន្នស្ស នេក្ខម្មស្ស ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ ។ បេ ។ ចារិបូរិយា អសល្លីនត្តបហិតត្តបក្ខហាដ្ឋេ បញ្ញា វីរិយារម្ភេ ញាណំ ។ បេ ។ អនុប្បន្នានំ សព្វកិលេសានំ អនុប្បាទាយ អសល្លីនត្តបហិតត្តបក្ខហាដ្ឋេ បញ្ញា វីរិយារម្ភេ ញាណំ ឧប្បន្នានំ សព្វកិលេសានំ

បញ្ញាក្នុងការផ្គង របស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីបង្កើតនូវកុសលធម៌ដែលមិនទាន់កើត ឈ្មោះថាវិរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គង របស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីតាំងនៅ មិនឲ្យវិនាស ឲ្យចម្រើនទូលំទូលាយ ឲ្យចម្រើន ពេញលេញ នូវកុសលធម៌ ដែលកើតឡើងហើយ ឈ្មោះថាវិរិយារម្ភញ្ញាណ ។

[២៣៨] បញ្ញាក្នុងការផ្គង របស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីមិនបង្កើតនូវកាមច្ឆន្ទៈ ដែលមិនទាន់កើត ឈ្មោះថាវិរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយដើម្បីលះបង់កាមច្ឆន្ទៈ ដែលកើតឡើងហើយ ឈ្មោះថាវិរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយដើម្បីបង្កើតនូវនេក្ខម្មៈ ដែលមិនទាន់កើត ឈ្មោះថាវិរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីតាំងនៅមិនឲ្យវិនាស ឲ្យចម្រើន ។ បេ ។ ឲ្យពេញលេញនូវនេក្ខម្មៈ ដែលកើតឡើងហើយ ឈ្មោះថាវិរិយារម្ភញ្ញាណ ។ បេ ។ បញ្ញាក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីមិនបង្កើតនូវកិលេសទាំងពួង ដែលមិនទាន់កើត ឈ្មោះថាវិរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គងរបស់បុគ្គល

បហានាយ អសល្លីនត្តបហិតត្តបគ្គហដ្ឋេ បញ្ញា វីរិយារម្ភេ ញាណំ ។ បេ ។ អនុប្បន្នស្ស អរហត្តមគ្គស្ស ឧប្បាទាយ អសល្លីនត្តបហិតត្តបគ្គហដ្ឋេ បញ្ញា វីរិយារម្ភេ ញាណំ ឧប្បន្នស្ស អរហត្តមគ្គស្ស ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា អសល្លីនត្តបហិតត្តបគ្គហដ្ឋេ បញ្ញា វីរិយារម្ភេ ញាណំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ អសល្លីនត្តបហិតត្តបគ្គហដ្ឋេ បញ្ញា វីរិយារម្ភេ ញាណំ ។

[២៣៩] កថំ នានាធម្មប្បកាសនតា បញ្ញា អត្ថសន្ទស្សនេ ញាណំ ។ នានាធម្មាតិ បញ្ចក្ខន្ធា ទ្វាទសាយតនានិ អដ្ឋារស ធាតុយោ កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា កាមាវចរា ធម្មា រូបាវចរា ធម្មា អរូបាវចរា ធម្មា អបរិយាបន្នា ធម្មា ។

[២៤០] បកាសនតាតិ រូបំ អនិច្ចតោ បកាសេតិ រូបំ ទុក្ខតោ បកាសេតិ រូបំ អនត្តតោ បកាសេតិ ។

មានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីលះបង់នូវកិលេសទាំងពួងដែលកើតឡើងហើយ ឈ្មោះថាវីរិយារម្ភញ្ញាណ ។ បេ ។ បញ្ញាក្នុងការផ្គង របស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីបង្កើតនូវអរហត្តមគ្គដែលមិនទាន់កើត ឈ្មោះថាវីរិយារម្ភញ្ញាណ បញ្ញាក្នុងការផ្គង របស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ដើម្បីតាំងនៅ មិនឲ្យវិនាស ឲ្យចម្រើនទូលំទូលាយ ឲ្យចម្រើន ពេញលេញ នូវអរហត្តមគ្គ ដែលកើតហើយ ឈ្មោះថាវីរិយារម្ភញ្ញាណ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការផ្គង របស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ឈ្មោះថាវីរិយារម្ភញ្ញាណ ។

[២៣៩] បញ្ញាគឺការប្រកាស នូវធម៌ផ្សេង ៗ ឈ្មោះថាអត្ថសន្ទស្សនញ្ញាណ តើដូចម្ដេច ។ ឈ្មោះថាធម៌ផ្សេង ៗ បានដល់ ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ពួកកុសលធម៌ ពួកអកុសលធម៌ ពួកអព្យាកតធម៌ ពួកកាមាវចរធម៌ ពួករូបាវចរធម៌ ពួកអរូបាវចរធម៌ ពួកអបរិយាបន្នធម៌ ។

[២៤០] ពាក្យថា ប្រកាសន៍ គឺប្រកាសនូវរូប ថាមិនទៀង ប្រកាស នូវរូប ថាជាទុក្ខ ប្រកាសនូវរូប ថាមិនមែនខ្លួន

វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ ចក្ខុំ ។ បេ ។ ជរាមរណំ អនិច្ចតោ បកាសេតិ ជរាមរណំ ទុក្ខតោ បកាសេតិ ជរាមរណំ អនត្តតោ បកាសេតិ ។

[២៤១] អត្ថសន្ទស្សនេតិ កាមច្ឆន្ទំ បជហន្តោ នេក្ខម្មត្ថំ សន្ទស្សេតិ ព្យាបាទំ បជហន្តោ អព្យាបាទត្ថំ សន្ទស្សេតិ ថីនមិទ្ធំ បជហន្តោ អាលោកសញ្ញត្ថំ សន្ទស្សេតិ ឧទ្ធច្ចំ បជហន្តោ អវិក្ខេបត្ថំ សន្ទស្សេតិ វិចិកិច្ឆំ បជហន្តោ ធម្មវវត្ថានត្ថំ សន្ទស្សេតិ អវិជ្ជំ បជហន្តោ ញាណត្ថំ សន្ទស្សេតិ អរតឹ បជហន្តោ បាមុជ្ជត្ថំ សន្ទស្សេតិ នីវរណេ បជហន្តោ បឋមជ្ឈានត្ថំ សន្ទស្សេតិ ។ បេ ។ សព្វកិលេសេ បជហន្តោ អរហត្តមគ្គត្ថំ សន្ទស្សេតិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ នានាធម្មប្បកាសនតា បញ្ញា អត្ថសន្ទស្សនេ ញាណំ ។

[២៤២] កថំ សព្វធម្មានំ ឯកសង្គហតានានត្តេកត្តបដិវេធេ[១] បញ្ញា ទស្សនវិសុទ្ធិញាណំ ។ សព្វធម្មានន្តិ បញ្ចក្ខន្ធា ។ បេ ។ អបរិយាបន្នា ធម្មា ។

១ ម. ឯកសង្គហិតា ។

ប្រកាសនូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ នូវជរា-មរណៈថាមិនទៀង ប្រកាសនូវជរាមរណៈ ថាជាទុក្ខ ប្រកាសនូវជរា-មរណៈថា មិនមែនខ្លួន ។

[២៤១] ពាក្យថា អត្ថសន្ទស្សនៈ (ការឃើញច្បាស់នូវអត្ថ) គឺ បុគ្គលកាលលះបង់កាមច្ឆន្ទៈ រមែងឃើញច្បាស់នូវអត្ថនៃនេក្ខម្មៈ កាលលះបង់ព្យាបាទ រមែងឃើញច្បាស់ នូវអត្ថនៃអព្យាបាទ កាលលះបង់ថីនមិទ្ធៈ រមែងឃើញច្បាស់នូវអត្ថនៃអាលោកសញ្ញា កាលលះបង់ឧទ្ធច្ចៈ រមែងឃើញច្បាស់នូវអត្ថនៃអវិក្ខេបៈ កាលលះបង់វិចិកិច្ឆា រមែងឃើញច្បាស់នូវអត្ថនៃធម្មវវត្ថានៈ កាលលះបង់អវិជ្ជា រមែងឃើញច្បាស់នូវអត្ថនៃញាណ កាលលះបង់អរតិ រមែងឃើញច្បាស់នូវអត្ថនៃបាមុជ្ជៈ កាលលះបង់នីវរណៈ រមែងឃើញច្បាស់នូវអត្ថនៃបឋមជ្ឈាន ។ បេ ។ កាលលះបង់កិលេសទាំងពួង រមែងឃើញច្បាស់នូវអត្ថនៃអរហត្តមគ្គ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាគឺការប្រកាសនូវធម៌ផ្សេងៗ ឈ្មោះថាអត្ថសន្ទស្សនញ្ញាណ ។

[២៤២] បញ្ញាក្នុងការត្រាស់ដឹង នូវការសង្គ្រោះធម៌ទាំងពួងឲ្យមកតែមួយ នូវកិលេសមានភាពផ្សេង ៗ និងគុណមានភាពតែមួយ ឈ្មោះថាទស្សនវិសុទ្ធិញ្ញាណ តើដូចម្តេច ។ ឈ្មោះថា ធម៌ទាំងពួង បានដល់ខន្ធ ៥ ។ បេ ។ ពួកអបរិយាបន្នធម៌ ។

ឯកសង្គហាតាតិ ទ្វាទសហិ អាការេហិ សព្វេ ធម្មា ឯកសង្គហិតា តថដ្ឋេន អនត្តដ្ឋេន សច្ចដ្ឋេន បដិវេធដ្ឋេន អភិជាននដ្ឋេន បរិជាននដ្ឋេន ធម្មដ្ឋេន ជាតដ្ឋេន[១] ញាតដ្ឋេន សច្ឆិកិរិយដ្ឋេន ផុស្សនដ្ឋេន អភិសមយដ្ឋេន ឥមេហិ ទ្វាទសហិ អាការេហិ សព្វេ ធម្មា ឯកសង្គហិតា ។

នានត្តេកត្តន្តិ កាមច្ឆន្ទោ នានត្តំ នេក្ខម្មំ ឯកត្តំ ។ បេ ។ សព្វកិលេសា នានត្តំ អរហត្តមគ្គោ ឯកត្តំ ។

បដិវេធេតិ ទុក្ខសច្ចំ បរិញ្ញាបដិវេធំ បដិវិជ្ឈតិ សមុទយសច្ចំ បហានប្បដិវេធំ បដិវិជ្ឈតិ និរោធសច្ចំ សច្ឆិកិរិយាបដិវេធំ បដិវិជ្ឈតិ មគ្គសច្ចំ ភាវនាបដិវេធំ បដិវិជ្ឈតិ ។

ទស្សនវិសុទ្ធីតិ សោតាបត្តិមគ្គក្ខណេ ទស្សនំ វិសុជ្ឈតិ សោតាបត្តិផលក្ខណេ ទស្សនំ វិសុទ្ធំ សកទាគាមិមគ្គក្ខណេ ទស្សនំ វិសុជ្ឈតិ សកទាគាមិផលក្ខណេ

១ ឱ. ម. ធាតុដ្ឋេន ។

ពាក្យថា សង្រ្គោះឲ្យមកតែមួយ គឺធម៌ទាំងពួង លោករួបរួមមកតែមួយវិញ ដោយអាការ ១២ គឺ ដោយអត្ថថាពិត ១ ដោយអត្ថថាមិនមែនខ្លួន ១ ដោយអត្ថថាទៀង ១ ដោយអត្ថថាចាក់ធ្លុះ ១ ដោយអត្ថថាដឹងច្បាស់ ១ ដោយអត្ថថាកំណត់ដឹង ១ ដោយអត្ថថាទ្រទ្រង់ ១ ដោយអត្ថថាជាធាតុ ១ ដោយអត្ថថាដឹង ១ ដោយអត្ថថាធ្វើឲ្យជាក់ច្បាស់ ១ ដោយអត្ថថាពាល់ត្រូវ ១ ដោយអត្ថថាត្រាស់ដឹង ១ នេះធម៌ទាំងពួង លោករួបរួមមកតែមួយ ដោយអាការ ១២ ។

ពាក្យថា កិលេសមានភាពផ្សេង ៗ និងគុណមានភាពតែមួយ គឺកាមច្ឆន្ទៈ ឈ្មោះថាភាពផ្សេង ៗ នេក្ខម្មៈ ឈ្មោះថាភាពតែមួយ ។ បេ ។ កិលេសទាំងពួង ឈ្មោះថាភាពផ្សេង ៗ អរហត្តមគ្គ ឈ្មោះថាភាពតែមួយ ។

ពាក្យថា ការត្រាស់ដឹង គឺត្រាស់ដឹងទុក្ខសច្ច ជាបរិញ្ញាបដិវេធ ត្រាស់ដឹងសមុទយសច្ច ជាបហានប្បដិវេធ ត្រាស់ដឹងនិរោធសច្ច ជាសច្ឆិកិរិយាបដិវេធ ត្រាស់ដឹងមគ្គសច្ច ជាភាវនាបដិវេធ ។

ពាក្យថា ទស្សនវិសុទ្ធិ គឺ ទស្សនៈ (ការឃើញ) រមែងស្អាតក្នុងខណៈនៃសោតាបត្តិមគ្គ ទស្សនៈ ស្អាតវិសេសហើយ ក្នុងខណៈនៃសោតាបត្តិផល ទស្សនៈ កំពុងស្អាត ក្នុងខណៈនៃសកទាគាមិមគ្គ ទស្សនៈ ស្អាតវិសេសហើយ ក្នុងខណៈ នៃសកទាគាមិផល

ទស្សនំ វិសុទ្ធំ អនាគាមិមគ្គក្ខណេ ទស្សនំ វិសុជ្ឈតិ អនាគាមិផលក្ខណេ ទស្សនំ វិសុទ្ធំ អរហត្តមគ្គក្ខណេ ទស្សនំ វិសុជ្ឈតិ អរហត្តផលក្ខណេ ទស្សនំ វិសុទ្ធំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ សព្វធម្មានំ ឯកសង្គហតានានត្តេកត្តប្បដិវេធេ បញ្ញា ទស្សនវិសុទ្ធិញាណំ ។

[២៤៣] កថំ វិទិតត្តា បញ្ញា ខន្តិញាណំ ។ រូបំ អនិច្ចតោ វិទិតំ រូបំ ទុក្ខតោ វិទិតំ រូបំ អនត្តតោ វិទិតំ យំ យំ វិទិតំ តំ តំ ខមតីតិ វិទិតត្តា បញ្ញា ខន្តិញាណំ វេទនំ សញ្ញំ សង្ខារេ[១] វិញ្ញាណំ ចក្ខុំ ។ បេ ។ ជរាមរណំ អនិច្ចតោ វិទិតំ ជរាមរណំ ទុក្ខតោ វិទិតំ ជរាមរណំ អនត្តតោ វិទិតំ យំ យំ វិទិតំ តំ តំ ខមតីតិ វិទិតត្តា បញ្ញា ខន្តិញាណំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ វិទិតត្តា បញ្ញា ខន្តិញាណំ ។

---

១ ឱ. ម. វេទនា ។ បេ ។ សញ្ញា សង្ខារា ។

ទស្សនៈ កំពុងស្អាត ក្នុងខណៈនៃអនាគាមិមគ្គ ទស្សនៈ ស្អាតវិសេសហើយ ក្នុងខណៈនៃអនាគាមិផល ទស្សនៈកំពុងស្អាត ក្នុងខណៈនៃអរហត្តមគ្គ ទស្សនៈស្អាតវិសេសហើយក្នុងខណៈនៃអរហត្តផល ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការត្រាស់ដឹងនូវការសង្គ្រោះ នូវធម៌ទាំងពួងឲ្យមកតែមួយ នូវកិលេសមានភាពផ្សេង ៗ និងគុណមានភាពតែមួយ ឈ្មោះថាទស្សនវិសុទ្ធិញ្ញាណ ។

[៤៨៣] បញ្ញា ព្រោះការដឹងច្បាស់ ឈ្មោះថាខន្តិញ្ញាណ តើដូចម្ដេច ។ បុគ្គលដឹងច្បាស់រូបថាមិនទៀង ដឹងច្បាស់រូបថាជាទុក្ខ ដឹងច្បាស់រូបថាជាអនត្តា រូបណា ៗ ដែលបុគ្គលដឹងច្បាស់ហើយ រូបនោះ ៗ គួរ (ជាយ៉ាងនោះមែន) ហេតុនោះ បញ្ញាព្រោះការដឹងច្បាស់ ឈ្មោះថាខន្តិញ្ញាណ បុគ្គលដឹងច្បាស់ នូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ ជរាមរណៈ ថាមិនទៀង ដឹងច្បាស់ជរាមរណៈ ថាជាទុក្ខ ដឹងច្បាស់ជរាមរណៈ ថាជាអនត្តា ជរាមរណៈណា ៗ ដែលបុគ្គលដឹងច្បាស់ជរាមរណៈ នោះ ៗ គួរ (ជាយ៉ាងនោះមែន) ហេតុនោះ បញ្ញាព្រោះការដឹងច្បាស់ ឈ្មោះថាខន្តិញ្ញាណ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាព្រោះការដឹងច្បាស់ ឈ្មោះថាខន្តិញ្ញាណ ។

[២៤៤] កថំ ផុដ្ឋត្តា បញ្ញា បរិយោគាហនេ ញាណំ ។ រូបំ អនិច្ចតោ ផុសតិ រូបំ ទុក្ខតោ ផុសតិ រូបំ អនត្តតោ ផុសតិ យំ យំ ផុសតិ តំ តំ បរិយោគាហតីតិ ផុដ្ឋត្តា បញ្ញា បរិយោគាហនេ ញាណំ វេទនំ សញ្ញំ សង្ខារេ វិញ្ញាណំ ចក្ខុំ ។ បេ ។ ជរាមរណំ អនិច្ចតោ ផុសតិ ទុក្ខតោ ផុសតិ អនត្តតោ ផុសតិ យំ យំ ផុសតិ តំ តំ បរិយោគាហតីតិ ផុដ្ឋត្តា បញ្ញា បរិយោគាហនេ ញាណំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ផុដ្ឋត្តា បញ្ញា បរិយោគាហនេ ញាណំ ។

[២៤៥] កថំ សមោទហនេ[១] បញ្ញា បវេសវិហារេ ញាណំ ។ មិច្ឆាទិដ្ឋិប្បច្ចយាបិ វេទយិតំ មិច្ឆាទិដ្ឋិវូបសមប្បច្ចយាបិ វេទយិតំ សម្មាទិដ្ឋិប្បច្ចយាបិ វេទយិតំ សម្មាទិដ្ឋិវូបសមប្បច្ចយាបិ វេទយិតំ មិច្ឆាសង្កប្បប្បច្ចយាបិ វេទយិតំ មិច្ឆាសង្កប្បវូបសមប្បច្ចយាបិ វេទយិតំ សម្មាសង្កប្បប្បច្ចយាបិ វេទយិតំ សម្មាសង្កប្បប្បច្ចយាបិ វេទយិតំ

១ ម. សមោទាហនេ ។

[២៤៤] បញ្ញាព្រោះការពាល់ត្រូវ ឈ្មោះថាបរិយោគាហនញ្ញាណ តើដូចម្ដេច ។ បុគ្គលពាល់ត្រូវនូវរូប ថាមិនទៀង ពាល់ត្រូវនូវរូបថាជាទុក្ខ ពាល់ត្រូវនូវរូប ថាជាអនត្តា ពាល់ត្រូវនូវរូបណា ៗ ស្ទង់នូវរូបនោះ ៗ (ឃើញថាជាយ៉ាងនោះមែន) ហេតុនោះ បញ្ញាព្រោះសេចក្ដីពាល់ត្រូវ ឈ្មោះថាបរិយោគាហនញ្ញាណ បុគ្គលពាល់ត្រូវ នូវវេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។ បេ ។ ជរាមរណៈ ថាមិនទៀង ថាជាទុក្ខ ថាជាអនត្តា ពាល់ត្រូវនូវជរាមរណៈ ណា ៗ ស្ទង់នូវជរាមរណៈនោះ ៗ (ឃើញថាជាយ៉ាងនោះមែន) ហេតុនោះ បញ្ញាព្រោះការពាល់ត្រូវ ឈ្មោះថា បរិយោគាហនញ្ញាណ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់ នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាព្រោះការពាល់ត្រូវ ឈ្មោះថាបរិយោគាហនញ្ញាណ ។

[២៤៥] បញ្ញាក្នុងការប្រមូល ឈ្មោះថាបទេសវិហារញ្ញាណ តើដូចម្ដេច ។ វេទនា ព្រោះមិច្ឆាទិដ្ឋិជាបច្ច័យក៏មាន វេទនា ព្រោះការរម្ងាប់នូវមិច្ឆាទិដ្ឋិជាបច្ច័យក៏មាន វេទនា ព្រោះសម្មាទិដ្ឋិជាបច្ច័យក៏មាន វេទនា ព្រោះការរម្ងាប់នូវសម្មាទិដ្ឋិជាបច្ច័យក៏មាន វេទនា ព្រោះមិច្ឆាសង្កប្បៈជាបច្ច័យក៏មាន វេទនា ព្រោះការរម្ងាប់ នូវមិច្ឆា-សង្កប្បៈជាបច្ច័យក៏មាន វេទនា ព្រោះសម្មាសង្កប្បៈជាបច្ច័យក៏មាន

សម្មាសង្កប្បរូបសមប្បច្ចយាបិ វេទយិតំ ។ បេ ។ មិច្ឆាវិមុត្តិប្បច្ចយាបិ វេទយិតំ មិច្ឆាវិមុត្តិរូបសមប្បច្ចយាបិ វេទយិតំ សម្មាវិមុត្តិប្បច្ចយាបិ វេទយិតំ សម្មាវិមុត្តិរូបសមប្បច្ចយាបិ វេទយិតំ ឆន្ទប្បច្ចយាបិ វេទយិតំ ឆន្ទរូបសមប្បច្ចយាបិ វេទយិតំ វិតក្កប្បច្ចយាបិ វេទយិតំ វិតក្ករូបសមប្បច្ចយាបិ វេទយិតំ សញ្ញាបច្ចយាបិ វេទយិតំ សញ្ញារូបសមប្បច្ចយាបិ វេទយិតំ ឆន្ទោ ច អរូបសន្តោ ហោតិ វិតក្កា ច អរូបសន្តា ហោន្តិ សញ្ញា ច អរូបសន្តា ហោន្តិ តប្បច្ចយាបិ វេទយិតំ ឆន្ទោ ច រូបសន្តោ ហោតិ វិតក្កា ច អរូបសន្តា ហោន្តិ សញ្ញា ច អរូបសន្តា ហោន្តិ តប្បច្ចយាបិ វេទយិតំ ឆន្ទោ ច រូបសន្តោ ហោតិ វិតក្កា ច រូបសន្តា ហោន្តិ សញ្ញា ច អរូបសន្តា ហោន្តិ តប្បច្ចយាបិ វេទយិតំ ឆន្ទោ ច រូបសន្តោ ហោតិ វិតក្កា ច រូបសន្តា ហោន្តិ សញ្ញា ច រូបសន្តា ហោន្តិ ឌ តប្បច្ចយាបិ វេទយិតំ

វេទនា ព្រោះការរម្ងាប់នូវសម្មាសង្កប្បៈ ជាបច្ច័យក៏មាន ។ បេ ។ វេទនា ព្រោះមិច្ឆាវិមុត្តិជាបច្ច័យក៏មាន វេទនា ព្រោះការរម្ងាប់ នូវមិច្ឆាវិមុត្តិ ជាបច្ច័យក៏មាន វេទនា ព្រោះសម្មាវិមុត្តិជាបច្ច័យក៏មាន វេទនា ព្រោះ រម្ងាប់ នូវសម្មាវិមុត្តិជាបច្ច័យក៏មាន វេទនា ព្រោះឆន្ទៈជាបច្ច័យក៏មាន វេទនា ព្រោះការរម្ងាប់នូវឆន្ទៈជាបច្ច័យក៏មាន វេទនា ព្រោះវិតក្កៈជា បច្ច័យក៏មាន វេទនា ព្រោះការរម្ងាប់នូវវិតក្កៈជាបច្ច័យក៏មាន វេទនា ព្រោះសញ្ញាជាបច្ច័យក៏មាន វេទនា ព្រោះការរម្ងាប់នូវសញ្ញាជាបច្ច័យ ក៏មាន ឆន្ទៈមិនស្ងប់ វិតក្កៈមិនស្ងប់ សញ្ញាមិនស្ងប់ វេទនា ព្រោះ ឆន្ទៈជាដើមមិនស្ងប់នោះជាបច្ច័យក៏មាន ឆន្ទៈស្ងប់ តែវិតក្កៈមិនស្ងប់ សញ្ញាមិនស្ងប់ វេទនា ព្រោះវិតក្កៈនិងសញ្ញាមិនស្ងប់នោះជាបច្ច័យ ក៏មាន ឆន្ទៈស្ងប់ វិតក្កៈស្ងប់ តែសញ្ញាមិនស្ងប់ វេទនា ព្រោះ សញ្ញាមិនស្ងប់នោះជាបច្ច័យក៏មាន ឆន្ទៈស្ងប់ វិតក្កៈស្ងប់ សញ្ញា ស្ងប់ វេទនា មិនមាន ព្រោះឆន្ទៈជាដើមស្ងប់នោះជាបច្ច័យក៏មាន

អប្បត្តស្ស បត្តិយា អត្ថិ អាយវំ តស្មឹ[១] ឋានេ អនុប្បត្តេ តប្បច្ចយាបិ វេទយិតំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ សមោធ-ឋានេ បញ្ញា បទេសវិហារេ ញាណំ ។

[២៤៦] កថំ អធិបតត្តា បញ្ញា សញ្ញាវិវដ្ដេ ញាណំ ។ នេក្ខម្មាធិបតត្តា បញ្ញា កាមច្ឆន្ទតោ សញ្ញាយ វិវដ្ដតីតិ អធិបតត្តា បញ្ញា សញ្ញាវិវដ្ដេ ញាណំ អព្យាបាទាធិបតត្តា បញ្ញា ព្យាបាទតោ សញ្ញាយ វិវដ្ដតីតិ អធិបតត្តា បញ្ញា សញ្ញាវិវដ្ដេ ញាណំ អាលោកសញ្ញាធិបតត្តា បញ្ញា ថីនមិទ្ធតោ សញ្ញា-យ វិវដ្ដតីតិ អធិបតត្តា បញ្ញា សញ្ញាវិវដ្ដេ ញាណំ អវិក្ខេបាធិបតត្តា បញ្ញា ឧទ្ធច្ចតោ សញ្ញាយ វិវដ្ដតីតិ អធិបតត្តា បញ្ញា សញ្ញាវិវដ្ដេ ញាណំ ធម្មវវត្ថានា-ធិបតត្តា បញ្ញា វិចិកិច្ឆាយ សញ្ញាយ វិវដ្ដតីតិ អធិបតត្តា បញ្ញា សញ្ញាវិវដ្ដេ ញាណំ ញាណា-ធិបតត្តា បញ្ញា អវិជ្ជាយ សញ្ញាយ វិវដ្ដតីតិ អធិបតត្តា

១ ឱ. អាយវំ តស្មឹបិ ។ ម. អាសវំ តស្មឹបិ ។

សេចក្តីព្យាយាម ដើម្បីសម្រេចអរហត្តដែលមិនទាន់សម្រេច នាកាល ឋានៈគឺអរហត្តនោះសម្រេចហើយ វេទនា ព្រោះបច្ច័យនៃព្រះអរហត្ត នោះក៏មាន ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថា បញ្ញា ដោយអត្ថថាដឹងច្បាស់ នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការប្រមូល ឈ្មោះថាបទេសវិហារញ្ញាណ ។

[៤៤៦] បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថាសញ្ញាវិវដ្តញ្ញាណ តើដូចម្តេច ។ បញ្ញាព្រោះមាននេក្ខម្មៈជាអធិបតី រមៀលចេញចាកកាមច្ឆន្ទសញ្ញា ហេតុនោះ បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថាសញ្ញាវិវដ្តញ្ញាណ បញ្ញាព្រោះការមិនមានព្យាបាទជាអធិបតី រមៀលចេញចាកព្យាបាទសញ្ញា ហេតុនោះ បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថាសញ្ញាវិវដ្តញ្ញាណ បញ្ញាព្រោះមានអាលោកសញ្ញាជាអធិបតី រមៀលចេញចាកថីនមិទ្ធសញ្ញា ហេតុនោះ បញ្ញា ព្រោះភាពជាអធិបតី ឈ្មោះថាសញ្ញាវិវដ្តញ្ញាណ បញ្ញាព្រោះមានអវិក្ខេបៈជាអធិបតី រមៀលចេញចាកឧទ្ធច្ចសញ្ញា ហេតុនោះ បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថាសញ្ញាវិវដ្តញ្ញាណ បញ្ញាព្រោះមានធម្មវវត្ថានជាអធិបតី រមៀលចេញចាកវិចិកិច្ឆាសញ្ញា ហេតុនោះ បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថាសញ្ញាវិវដ្តញ្ញាណ បញ្ញាព្រោះមានញាណជាអធិបតី រមៀលចេញចាកអវិជ្ជា-

បញ្ញា សញ្ញាវិវដ្ដេ ញាណំ ចាមុច្ឆាធិបតត្តា បញ្ញា អរតិយា សញ្ញាយ វិវដ្ដតីតិ អធិបតត្តា បញ្ញា សញ្ញាវិវដ្ដេ ញាណំ បឋមជ្ឈានាធិបតត្តា បញ្ញា នីវរណេហិ សញ្ញាយ វិវដ្ដតីតិ អធិបតត្តា បញ្ញា សញ្ញាវិវដ្ដេ ញាណំ ។ បេ ។ អរហត្តមគ្គាធិបតត្តា បញ្ញា សព្វក្កិលេសេហិ សញ្ញាយ វិវដ្ដតីតិ អធិបតត្តា បញ្ញា សញ្ញាវិវដ្ដេ ញាណំ តំញាតដ្ឋេន ញាណំ បជានដ្ឋេន បញ្ញា តេន វុច្ចតិ អធិបតត្តា បញ្ញា សញ្ញាវិវដ្ដេ ញាណំ ។

[២៤៧] កថំ នានត្តេ បញ្ញា ចេតោវិវដ្ដេ ញាណំ ។ កាមច្ឆន្ទោ នានត្តំ នេក្ខម្មំ ឯកត្តំ នេក្ខម្មេកត្តំ ចេតយតោ កាមច្ឆន្ទតោ ចិត្តំ វិវដ្ដតីតិ នានត្តេ បញ្ញា ចេតោវិវដ្ដេ ញាណំ ព្យាបាទោ នានត្តំ អព្យាបាទោ ឯកត្តំ អព្យាបាទេកត្តំ ចេតយតោ ព្យាបាទតោ ចិត្តំ វិវដ្ដតីតិ នានត្តេ បញ្ញា ចេតោវិវដ្ដេ ញាណំ

សញ្ញា ហេតុនោះ បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថាសញ្ញាវិវដ្ដ-ញាណ បញ្ញាព្រោះមានបាមុជ្ជៈជាអធិបតី រមៀលចេញចាកអរតិសញ្ញា ហេតុនោះ បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថាសញ្ញាវិវដ្ដញាណ បញ្ញាព្រោះមានបឋមជ្ឈានជាអធិបតី រមៀលចេញចាកនីវរណសញ្ញា ហេតុនោះ បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថាសញ្ញាវិវដ្ដញាណ ។ បេ ។ បញ្ញាព្រោះមានអរហត្តមគ្គ ជាអធិបតី រមៀលចេញចាកសព្វកិលេស-សញ្ញា ហេតុនោះ បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថាសញ្ញាវិវដ្ដ-ញាណ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថាសញ្ញាវិវដ្ដញាណ ។

[២៤៧] បញ្ញា ក្នុងភាពផ្សេង ៗ ឈ្មោះថាចេតោវិវដ្ដញាណ តើដូចម្ដេច ។ កាមច្ឆន្ទៈ ឈ្មោះថាភាពផ្សេង ៗ នេក្ខម្មៈ ឈ្មោះថាភាពតែមួយ កាលបុគ្គលត្រិះរិះនូវនេក្ខម្មៈដែលជាភាពតែមួយ ចិត្តរមែងរមៀលចាកកាមច្ឆន្ទៈ ហេតុនោះ បញ្ញាក្នុងភាពផ្សេង ៗ ឈ្មោះថាចេតោវិវដ្ដញាណ ព្យាបាទ ឈ្មោះថាភាពផ្សេង ៗ អព្យាបាទ ឈ្មោះថាភាពតែមួយ កាលបុគ្គលត្រិះរិះនូវអព្យាបាទ ដែលជាភាពតែមួយ ចិត្តរមែងរមៀលចាកព្យាបាទ ហេតុនោះ បញ្ញាក្នុងភាពផ្សេង ៗ ឈ្មោះថាចេតោវិវដ្ដញាណ

ថីនមិទ្ធំ ជានត្តំ អាលោកសញ្ញា ឯកត្តំ អាលោកសញ្ញេកត្តំ ចេតយតោ ថីនមិទ្ធតោ ចិត្តំ វិវដ្ដតីតិ ជានត្តេ បញ្ញា ចេតោវិវដ្ដេ ញាណំ ។ បេ ។ សព្វក្កិលេសា ជានត្តំ អរហត្តមគ្គោ ឯកត្តំ អរហត្តមគ្គេកត្តំ ចេតយតោ សព្វក្កិលេសេហិ ចិត្តំ វិវដ្ដតីតិ ជានត្តេ បញ្ញា ចេតោវិវដ្ដេ ញាណំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ជានត្តេ បញ្ញា ចេតោវិវដ្ដេ ញាណំ ។

[២៤៨] កថំ អធិដ្ឋានេ បញ្ញា ចិត្តវិវដ្ដេ ញាណំ ។ កាមច្ឆន្ទំ បជហន្តោ នេក្ខម្មវសេន ចិត្តំ អធិដ្ឋាតីតិ អធិដ្ឋានេ បញ្ញា ចិត្តវិវដ្ដេ ញាណំ ព្យាបាទំ បជហន្តោ អព្យាបាទវសេន ចិត្តំ អធិដ្ឋាតីតិ អធិដ្ឋានេ បញ្ញា ចិត្តវិវដ្ដេ ញាណំ ថីនមិទ្ធំ បជហន្តោ អាលោកសញ្ញាវសេន ចិត្តំ អធិដ្ឋាតីតិ អធិដ្ឋានេ បញ្ញា ចិត្តវិវដ្ដេ ញាណំ ។ បេ ។ សព្វក្កិលេសេ បជហន្តោ អរហត្តមគ្គវសេន ចិត្តំ អធិដ្ឋាតីតិ

ថីនមិទ្ធៈ ឈ្មោះថាភាពផ្សេង ៗ អាលោកសញ្ញា ឈ្មោះថាភាពតែមួយ កាលបុគ្គលត្រិះរិះនូវអាលោកសញ្ញា ដែលជាភាពតែមួយ ចិត្តរមែងរមៀលចេញចាកថីនមិទ្ធៈ ហេតុនោះ បញ្ញាក្នុងភាពផ្សេង ៗ ឈ្មោះថាចេតោវិវដ្តញ្ញាណ ។ បេ ។ កិលេសទាំងពួង ឈ្មោះថាភាពផ្សេង ៗ អរហត្តមគ្គ ឈ្មោះថាភាពតែមួយ កាលបុគ្គលត្រិះរិះ នូវអរហត្តមគ្គដែលជាភាពតែមួយ ចិត្តរមៀលចេញចាកកិលេសទាំងពួង ហេតុនោះ បញ្ញាក្នុងភាពផ្សេង ៗ ឈ្មោះថាចេតោវិវដ្តញ្ញាណ ឈ្មោះថាញាណដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងភាពផ្សេង ៗ ឈ្មោះថាចេតោវិវដ្តញ្ញាណ ។

[២៤៨] បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថាចិត្តវិវដ្តញ្ញាណ តើដូចម្តេច ។ បុគ្គលកាលលះនូវកាមច្ឆន្ទៈ តែងអធិដ្ឋានចិត្តដោយអំណាចនេក្ខម្មៈ ហេតុនោះ បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថាចិត្តវិវដ្តញ្ញាណ បុគ្គលកាលលះនូវព្យាបាទ តែងអធិដ្ឋានចិត្តដោយអំណាចអព្យាបាទ ហេតុនោះ បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថាចិត្តវិវដ្តញ្ញាណ បុគ្គលកាលលះនូវថីន-មិទ្ធៈ តែងអធិដ្ឋានចិត្ត ដោយអំណាចអាលោកសញ្ញា ហេតុនោះ បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថាចិត្តវិវដ្តញ្ញាណ ។ បេ ។ បុគ្គលកាលលះនូវកិលេសទាំងអស់ តែងអធិដ្ឋានចិត្ត ដោយអំណាចអរហត្តមគ្គ

អធិដ្ឋានេ បញ្ញា ចិត្តវិវដ្ដេ ញាណំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ អធិដ្ឋានេ បញ្ញា ចិត្តវិវដ្ដេ ញាណំ ។

[២៤៩] កថំ សុញ្ញតេ បញ្ញា ញាណវិវដ្ដេ ញាណំ ចក្ខុំ[១] សុញ្ញំ អត្តេន វា អត្តនីយេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វាតិ យថាភូតំ ជានតោ បស្សតោ ច កាមាភិនិវេសតោ[២] ញាណំ វិវដ្ដតីតិ សុញ្ញតេ បញ្ញា ញាណវិវដ្ដេ ញាណំ សោតំ សុញ្ញំ ។ បេ ។ ឃានំ សុញ្ញំ ជិវ្ហា សុញ្ញា កាយោ សុញ្ញោ មនោ សុញ្ញោ អត្តេន វា អត្តនីយេន វា និច្ចេន វា ធុវេន វា សស្សតេន វា អវិបរិណាមធម្មេន វាតិ យថាភូតំ ជានតោ បស្សតោ ច កាមាភិនិវេសតោ[៣] ញាណំ វិវដ្ដតីតិ សុញ្ញតេ បញ្ញា ញាណវិវដ្ដេ ញាណំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ សុញ្ញតេ បញ្ញា ញាណវិវដ្ដេ ញាណំ ។

---

១ ម. ចក្ខុ ។ ២ ឱ. ម. ជានតោ បស្សតោ ចក្ខាភិនិវេសតោ ។ ៣ ឱ. ម. ជានតោ បស្សតោ មនាភិនិវេសតោ ។

ហេតុនោះ បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថាចិត្តវិវដ្តញ្ញាណ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថាចិត្តវិវដ្តញ្ញាណ ។

[២៤៩] បញ្ញាក្នុងសភាវៈសូន្យ ឈ្មោះថាញាណវិវដ្តញ្ញាណ តើដូចម្តេច ។ កាលបុគ្គលដឹងច្បាស់ ឃើញច្បាស់តាមពិតថា ចក្ខុសូន្យចាកខ្លួន ចាកវត្ថុជារបស់ខ្លួន ចាកការទៀងទាត់ ចាកការឋិតថេរ ចាកការប្រាកដ ឬចាករបស់ដែលមិនមានការប្រែប្រួលជាធម្មតា ញាណក៏រមៀលចេញចាកសេចក្តីប្រកាន់ស្អិតនូវកាម ហេតុនោះ បញ្ញាក្នុងសភាវៈសូន្យ ឈ្មោះថាញាណវិវដ្តញ្ញាណ កាលបុគ្គលដឹងច្បាស់ ឃើញច្បាស់តាមពិតថា ត្រចៀកសូន្យ ។ បេ ។ ច្រមុះសូន្យ អណ្តាតសូន្យ កាយសូន្យ ចិត្តសូន្យ ចាកខ្លួន ចាកវត្ថុជារបស់ខ្លួន ចាកការទៀងទាត់ ចាកការឋិតថេរ ចាកការប្រាកដ ឬចាករបស់ដែលមិនប្រែប្រួលជាធម្មតា ញាណក៏រមៀលចេញចាកសេចក្តីប្រកាន់ស្អិតនូវកាម ហេតុនោះ បញ្ញាក្នុងសភាវៈសូន្យ ឈ្មោះថាញាណវិវដ្តញ្ញាណ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងសភាវៈសូន្យ ឈ្មោះថាញាណ-វិវដ្តញ្ញាណ ។

[២៤០] កថំ វោស្សគ្គេ បញ្ញា វិមោក្ខវិវដ្ដេ ញាណំ ។ នេក្ខម្មេន កាមច្ឆន្ទំ វោស្សជ្ជតីតិ វោ-ស្សគ្គេ បញ្ញា វិមោក្ខវិវដ្ដេ ញាណំ អព្យាបាទេន ព្យាបាទំ វោស្សជ្ជតីតិ វោស្សគ្គេ បញ្ញា វិមោក្ខវិវដ្ដេ ញាណំ អាលោកសញ្ញាយ ថីនមិទ្ធំ វោស្សជ្ជតីតិ វោស្សគ្គេ បញ្ញា វិមោក្ខវិវដ្ដេ ញាណំ អវិក្ខេបេន ឧទ្ធច្ចំ វោស្សជ្ជតីតិ វោស្សគ្គេ បញ្ញា វិមោក្ខវិវដ្ដេ ញាណំ ធម្មវវត្ថានេន វិចិកិច្ឆំ វោស្សជ្ជតីតិ វោស្ស-គ្គេ បញ្ញា វិមោក្ខវិវដ្ដេ ញាណំ ។ បេ ។ អរហត្ត-មគ្គេន សព្វក្កិលេសេ វោស្សជ្ជតីតិ វោស្សគ្គេ បញ្ញា វិមោក្ខវិវដ្ដេ ញាណំ តំញាតដ្ឋេន ញាណំ បជា-ននដ្ឋេន បញ្ញា តេន វុច្ចតិ វោស្សគ្គេ បញ្ញា វិមោ-ក្ខវិវដ្ដេ ញាណំ ។

[២៤១] កថំ តថដ្ឋេ បញ្ញា សច្ចវិវដ្ដេ ញាណំ ។ ទុក្ខស្ស បីឡនដ្ឋំ សង្ខតដ្ឋំ សន្តាបដ្ឋំ វិបរិណាមដ្ឋំ បរិជានន្តោ វិវដ្ដតីតិ តថដ្ឋេ បញ្ញា សច្ចវិវដ្ដេ ញាណំ

[២៥០] បញ្ញាក្នុងការលះបង់ ឈ្មោះថាវិមោក្ខវិវដ្តញ្ញាណ តើដូចម្តេច ។ បុគ្គលលះបង់កាមច្ឆន្ទៈ ដោយនេក្ខម្មៈ ហេតុនោះ បញ្ញាក្នុងការលះបង់ ឈ្មោះថាវិមោក្ខវិវដ្តញ្ញាណ បុគ្គលលះបង់ព្យាបាទដោយអព្យាបាទ ហេតុនោះ បញ្ញាក្នុងការលះបង់ ឈ្មោះថាវិមោក្ខវិវដ្ត-ញ្ញាណ បុគ្គលលះបង់ថីនមិទ្ធៈដោយអាលោកសញ្ញា ហេតុនោះ បញ្ញាក្នុងការលះបង់ ឈ្មោះថាវិមោក្ខវិវដ្តញ្ញាណ បុគ្គលលះបង់ឧទ្ធច្ចៈដោយអវិក្ខេបៈ ហេតុនោះ បញ្ញាក្នុងការលះបង់ ឈ្មោះថាវិមោក្ខវិវដ្តញ្ញាណ បុគ្គលលះបង់វិចិកិច្ឆាដោយធម្មវវត្ថាន ហេតុនោះ បញ្ញាក្នុងការលះបង់ ឈ្មោះថាវិមោក្ខវិវដ្តញ្ញាណ ។ បេ ។ បុគ្គលលះបង់កិលេសទាំងអស់ដោយអរហត្តមគ្គ ហេតុនោះ បញ្ញាក្នុងការលះបង់ ឈ្មោះថាវិមោក្ខ-វិវដ្តញ្ញាណ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការលះបង់ ឈ្មោះថាវិមោក្ខវិវដ្តញ្ញាណ ។

[២៥១] បញ្ញាក្នុងអត្ថថាជារបស់ពិត ឈ្មោះថា សច្ចវិវដ្តញ្ញាណ តើដូចម្តេច ។ បុគ្គលកាលកំណត់នូវអត្ថថាបៀតបៀន អត្ថថាប្រជុំតាក់តែងអត្ថថាក្តៅសព្វ អត្ថថាប្រែប្រួលនៃទុក្ខសច្ច រមែងត្រឡប់ (ចាកកាម) ហេតុនោះ បញ្ញា ក្នុងអត្ថថាជារបស់ពិត ឈ្មោះថាសច្ចវិវដ្តញ្ញាណ

២៤៩

សមុទយស្ស អាយុហនដ្ឋំ និទានដ្ឋំ សញ្ញោគដ្ឋំ បលិពោធដ្ឋំ បជហន្តោ វិវដ្តតីតិ តថដ្ឋេ បញ្ញា សច្ចវិវដ្តេ ញាណំ និរោធស្ស និស្សរណដ្ឋំ វិវេកដ្ឋំ អសង្ខតដ្ឋំ អមតដ្ឋំ សច្ឆិករោន្តោ វិវដ្តតីតិ តថដ្ឋេ បញ្ញា សច្ចវិវដ្តេ ញាណំ មគ្គស្ស និយ្យានដ្ឋំ ហេតុដ្ឋំ ទស្សនដ្ឋំ អាធិបតេយ្យដ្ឋំ ភាវេន្តោ វិវដ្តតីតិ តថដ្ឋេ បញ្ញា សច្ចវិវដ្តេ ញាណំ សញ្ញាវិវដ្តោ ចេតោវិវដ្តោ ចិត្តវិវដ្តោ ញាណវិវដ្តោ វិមោក្ខវិវដ្តោ សច្ចវិវដ្តោ សញ្ជានន្តោ វិវដ្តតីតិ សញ្ញាវិវដ្តោ ចេតយន្តោ វិវដ្តតីតិ ចេតោវិវដ្តោ វិជានន្តោ វិវដ្តតីតិ ចិត្តវិវដ្តោ

បុគ្គលកាលលះបង់ នូវអត្ថថាប្រមូលមក អត្ថថានិទាន អត្ថថាប្រកបព្រម អត្ថថាជាប់ចំពាក់ នៃសមុទយសច្ច រមែងត្រឡប់ (ចាកកាម) ហេតុនោះ បញ្ញាក្នុងអត្ថថាជារបស់ពិត ឈ្មោះថាសច្ចវិវដ្ដញ្ញាណ បុគ្គលកាលធ្វើឲ្យជាក់ច្បាស់ នូវអត្ថថារលាស់ចេញ អត្ថថាស្ងប់ស្ងាត់ អត្ថថាមិនមានបច្ច័យតាក់តែង អត្ថថាអមតៈ នៃនិរោធសច្ច រមែងត្រឡប់ (ចាកកាម) ហេតុនោះ បញ្ញាក្នុងអត្ថថាជារបស់ពិត ឈ្មោះថាសច្ចវិវដ្ដញ្ញាណ បុគ្គលកាលចម្រើននូវអត្ថថាចេញទៅ អត្ថថាជាហេតុ អត្ថថាឃើញ អត្ថថាភាពជាអធិបតី នៃមគ្គសច្ច រមែងត្រឡប់ (ចាកកាម) ហេតុនោះ បញ្ញាក្នុងអត្ថថាជារបស់ពិត ឈ្មោះថាសច្ចវិវដ្ដញ្ញាណ (វិវដ្ដបុគ្គលមាន ៦ គឺ) សញ្ញាវិវដ្ដបុគ្គល ១ ចេតោវិវដ្ដបុគ្គល ១ ចិត្តវិវដ្ដបុគ្គល ១ ញាណវិវដ្ដបុគ្គល ១ វិមោក្ខវិវដ្ដបុគ្គល ១ សច្ចវិវដ្ដបុគ្គល ១ ។ បុគ្គលណាកាលដឹងច្បាស់ រមៀលចេញ (ចាកកិលេសទាំងពួង) បុគ្គលនោះ ឈ្មោះថាសញ្ញាវិវដ្ដបុគ្គល បុគ្គលណាកាលត្រិះរិះ រមៀលចេញ (ចាកកាមច្ឆន្ទៈ) បុគ្គលនោះ ឈ្មោះថាចេតោវិវដ្ដបុគ្គល បុគ្គលណាកាលដឹងវិសេស រមៀល (ចាកកិលេស) បុគ្គលនោះ ឈ្មោះថាចិត្តវិវដ្ដបុគ្គល

ញាណំ ករោន្តោ វិវដ្ដតីតិ ញាណវិវដ្ដោ វោស្សជ្ជន្តោ វិវដ្ដតីតិ វិមោក្ខវិវដ្ដោ តថដ្ឋេ វិវដ្ដតីតិ សច្ចវិវដ្ដោ ។

[២៤២] យត្ថ សញ្ញាវិវដ្ដោ តត្ថ ចេតោវិវដ្ដោ យត្ថ ចេតោវិវដ្ដោ តត្ថ សញ្ញាវិវដ្ដោ យត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ តត្ថ ចិត្តវិវដ្ដោ យត្ថ ចិត្តវិវដ្ដោ តត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ យត្ថ សញ្ញាវិវដ្ដោ ចេតោ-វិវដ្ដោ ចិត្តវិវដ្ដោ តត្ថ ញាណវិវដ្ដោ យត្ថ ញាណ-វិវដ្ដោ តត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ ចិត្តវិវដ្ដោ យត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ ចិត្តវិវដ្ដោ ញាណ-វិវដ្ដោ តត្ថ វិមោក្ខវិវដ្ដោ យត្ថ វិមោក្ខវិវដ្ដោ តត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ ចិត្តវិវដ្ដោ ញាណវិវដ្ដោ

បុគ្គលណាកាលធ្វើនូវញាណ រមៀលចេញ (ចាកសេចក្តីប្រកាន់នូវកាម) បុគ្គលនោះ ឈ្មោះថាញាណវិវដ្តបុគ្គល បុគ្គលណាកាលលះបង់ រមៀលចេញ (ចាកកិលេស) បុគ្គលនោះ ឈ្មោះថាវិមោក្ខវិវដ្តបុគ្គល បុគ្គលណាតាំងនៅក្នុងសេចក្តីពិត រមៀលចេញ (ចាកកាម) បុគ្គលនោះ ឈ្មោះថាសច្ចវិវដ្តបុគ្គល ។

[២៥២] សញ្ញាវិវដ្តបុគ្គល មានក្នុងខណៈនៃមគ្គណា ចេតោវិវដ្ត-បុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរ ចេតោវិវដ្តបុគ្គល មានក្នុងខណៈនៃមគ្គណា សញ្ញាវិវដ្តបុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរ សញ្ញាវិវដ្ត-បុគ្គល ចេតោវិវដ្តបុគ្គល មានក្នុងខណៈនៃមគ្គណា ចិត្តវិវដ្តបុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរ ចិត្តវិវដ្តបុគ្គល មានក្នុងខណៈនៃមគ្គណា សញ្ញា-វិវដ្តបុគ្គល ចេតោវិវដ្តបុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរ សញ្ញាវិវដ្ត-បុគ្គល ចេតោវិវដ្តបុគ្គល ចិត្តវិវដ្តបុគ្គល មានក្នុងខណៈនៃមគ្គណា ញាណ-វិវដ្តបុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរ ញាណវិវដ្តបុគ្គល មានក្នុងខណៈនៃមគ្គណា សញ្ញាវិវដ្តបុគ្គល ចេតោវិវដ្តបុគ្គល ចិត្តវិវដ្តបុគ្គលក៏មានក្នុងខណៈនៃមគ្គនោះដែរ សញ្ញាវិវដ្តបុគ្គល ចេតោវិវដ្តបុគ្គល ចិត្តវិវដ្ត-បុគ្គល ញាណវិវដ្តបុគ្គល មានក្នុងខណៈនៃមគ្គណា វិមោក្ខវិវដ្តបុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរ វិមោក្ខវិវដ្តបុគ្គល មានក្នុងខណៈនៃមគ្គណា សញ្ញាវិវដ្តបុគ្គល ចេតោវិវដ្តបុគ្គល ចិត្តវិវដ្តបុគ្គល ញាណវិវដ្តបុគ្គល

យត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ ចិត្តវិវដ្ដោ ញាណវិវ-
ដ្ដោ វិមោក្ខវិវដ្ដោ តត្ថ សច្ចវិវដ្ដោ យត្ថ សច្ចវិវដ្ដោ
តត្ថ សញ្ញាវិវដ្ដោ ចេតោវិវដ្ដោ ចិត្តវិវដ្ដោ ញាណវិវដ្ដោ
វិមោក្ខវិវដ្ដោ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន
បញ្ញា តេន វុច្ចតិ តជដ្ឋេ បញ្ញា សច្ចវិវដ្ដេ ញាណំ ។

[២៥៣] កថំ កាយម្បិ ចិត្តម្បិ ឯក-
វវត្ថានតា សុខសញ្ញញ្ច លហុសញ្ញញ្ច អធិដ្ឋាន-
វសេន ឥជ្ឈនដ្ឋេ បញ្ញា ឥទ្ធិវិធេ ញាណំ ។
ឥធ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិ-
បាទំ ភាវេតិ វីរិយចិត្តសមាធិ ។ បេ ។ ចិត្ត-
សមាធិ ។ បេ ។ វីមំសាសមាធិប្បធានសង្ខារ-
សមន្នាគតំ ឥទ្ធិបាទំ ភាវេតិ សោ ឥមេសុ ចតូសុ
ឥទ្ធិបាទេសុ ចិត្តំ បរិភាវេតិ បរិទមេតិ មុទុំ ករោតិ
កម្មនីយំ សោ ឥមេសុ ចតូសុ ឥទ្ធិបាទេសុ ចិត្តំ
បរិភាវេត្វា បរិទមេត្វា មុទុំ ករិត្វា កម្មនីយំ

ក៏មានក្នុងខណៈនៃមគ្គនោះដែរ សញ្ញាវិវដ្តបុគ្គល ចេតោវិវដ្តបុគ្គល ចិត្តវិវដ្តបុគ្គល ញាណវិវដ្តបុគ្គល វិមោក្ខវិវដ្តបុគ្គល មានក្នុងខណៈនៃមគ្គណា សច្ចវិវដ្តបុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរ សច្ចវិវដ្តបុគ្គលមានក្នុងខណៈនៃមគ្គណា សញ្ញាវិវដ្តបុគ្គល ចេតោវិវដ្តបុគ្គល ចិត្តវិវដ្តបុគ្គល ញាណវិវដ្តបុគ្គល វិមោក្ខវិវដ្តបុគ្គល ក៏មានក្នុងខណៈនៃមគ្គនោះដែរ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងអត្ថថាជារបស់ពិត ឈ្មោះថាសច្ចវិវដ្តញាណ ។

[២៥៣] បញ្ញាក្នុងអត្ថថាសម្រេច ដោយអំណាចនៃការអធិដ្ឋាននូវសុខសញ្ញា[១] និងលហុសញ្ញា[២] ព្រោះការកំណត់នូវកាយនិងចិត្តថាតែមួយ ឈ្មោះថាឥទ្ធិវិធញ្ញាណ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ដែលប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ចម្រើននូវឥទ្ធិបាទដែលប្រកបដោយវីរិយសមាធិ ។ បេ ។ ចិត្តសមាធិ ។ បេ ។ វីមំសាសមាធិនិងបធានសង្ខារ ភិក្ខុនោះអប់រំ បង្វឹកចិត្ត ធ្វើចិត្តឲ្យទន់ គួរដល់កម្ម ក្នុងឥទ្ធិបាទទាំង ៤ នេះ ភិក្ខុនោះលុះអប់រំ បង្វឹកចិត្ត ធ្វើចិត្តឲ្យទន់

១ សញ្ញាដែលប្រកបដោយឧបេក្ខាក្នុងចតុត្ថជ្ឈាន ។ ២ សញ្ញាដែលរួចស្រឡះចាកនីវរណធម៌ផង ចាកធម៌ជាទំនាស់មានវិតក្កៈជាដើមផង ។ អដ្ឋកថា ។

កាយម្បិ ចិត្តេ សមោទហតិ ចិត្តម្បិ កាយេ សមោទហតិ កាយវសេន ចិត្តំ បរិណាមេតិ ចិត្តវសេន កាយំ បរិណាមេតិ កាយវសេន ចិត្តំ អធិដ្ឋាតិ ចិត្តវសេន កាយំ អធិដ្ឋាតិ កាយវសេន ចិត្តំ បរិណាមេត្វា ចិត្តវសេន កាយំ បរិណាមេត្វា កាយវសេន ចិត្តំ អធិដ្ឋហិត្វា ចិត្តវសេន កាយំ អធិដ្ឋហិត្វា សុខសញ្ញញ្ច លហុសញ្ញញ្ច កាយេ ឱក្កមិត្វា វិហរតិ សោ តថា ភាវិតេន ចិត្តេន បរិសុទ្ធេន បរិយោទាតេន ឥទ្ធិវិធញ្ញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ សោ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ បឋវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆតិ សេយ្យថាបិ បឋវិយំ អាកាសេបិ

គួរដល់កម្ម ក្នុងឥទ្ធិបាទទាំង ៤ នេះហើយ ក៏បញ្ចូលកាយក្នុងចិត្តខ្លះ បញ្ចូលចិត្តក្នុងកាយខ្លះ បង្អោនចិត្តដោយអំណាចនៃកាយខ្លះ បង្អោនកាយដោយអំណាចនៃចិត្តខ្លះ អធិដ្ឋានចិត្តដោយអំណាចនៃកាយខ្លះ អធិដ្ឋានកាយ ដោយអំណាចនៃចិត្តខ្លះ លុះបង្អោនចិត្ត ដោយអំណាចនៃកាយបង្អោនកាយដោយអំណាចនៃចិត្ត អធិដ្ឋានចិត្តដោយអំណាចនៃកាយ អធិដ្ឋានកាយដោយអំណាចនៃចិត្តហើយ ក៏បញ្ចូលនូវសុខសញ្ញានិងលហុសញ្ញាទៅក្នុងកាយ ភិក្ខុនោះ មានចិត្តអប់រំ បរិសុទ្ធ ផូរផង់ ដូច្នោះហើយក៏បង្អោនបន្ទន់ចិត្តទៅ ក្នុងឥទ្ធិវិធញ្ញាណ ភិក្ខុនោះ តែងបានសោយនូវចំណែកនៃឫទ្ធិច្រើនយ៉ាង គឺធ្វើមនុស្សតែមួយរូប ឲ្យទៅជាច្រើនរូបក៏បានខ្លះ ធ្វើមនុស្សច្រើនរូប ឲ្យទៅជាមួយរូបក៏បានខ្លះ ធ្វើទីកំបាំងឲ្យទៅជាទីវាលក៏បាន ធ្វើទីវាលឲ្យទៅជាទីកំបាំងក៏បាន ដើរ (ទម្លុះ) ទៅខាងក្រៅជញ្ជាំង ខាងក្រៅកំពែង ខាងក្រៅភ្នំ មិនទើសទាក់ដូចជាដើរទៅក្នុងទីវាលក៏បាន ធ្វើនូវការមុជចុះនិងងើបឡើងក្នុងផែនដី ដូចជាមុជងើបក្នុងទឹកក៏បាន ដើរទៅលើទឹកមិនបែកធ្លាយ ដូចជាដើរលើផែនដីក៏បាន

បល្លង្កេន ចង្កមតិ[១] សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសតិ[២] បរិមជ្ជតិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ កាយម្បិ ចិត្តម្បិ ឯកវវត្ថានតា សុខសញ្ញញ្ច លហុសញ្ញញ្ច អធិដ្ឋានវសេន ឥជ្ឈនដ្ឋេ បញ្ញា ឥទ្ធិវិធេ ញាណំ ។

[២៨៤] កថំ វិតក្កវិប្ផារវសេន នានត្តេកត្តសទ្ទនិមិត្តានំ បរិយោគាហនេ បញ្ញា សោតធាតុវិសុទ្ធិញ្ញាណំ ។ ឥធ ភិក្ខុ ឆន្ទសមាធិវីរិយសមាធិចិត្តសមាធិវីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ សោ ឥមេសុ ចតូសុ ឥទ្ធិបាទេសុ ចិត្តំ បរិភាវេតិ បរិទមេតិ មុទុំ ករោតិ កម្មនិយំ សោ ឥមេសុ ចតូសុ ឥទ្ធិបាទេសុ ចិត្តំ បរិភាវេត្វា បរិទមេត្វា មុទុំ ករិត្វា កម្មនិយំ ទូរេបិ សទ្ទានំ សទ្ទនិមិត្តំ មនសិករោតិ សន្តិកេបិ សទ្ទានំ សទ្ទនិមិត្តំ

១ ឱ. ម. កមតិ ។ ២ ម. បរាមសតិ ។

ទៅទាំងក្អែនព្ធ័អាកាសក៏បាន ដូចជាសត្វស្លាប អាចចាប់ស្ទាបអង្អែល ព្រះចន្ទនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ ដែលមានអានុភាពច្រើនយ៉ាងនេះក៏បាន ញុាំងអំណាចឲ្យប្រព្រឹត្តទៅដោយកាយ រហូតទៅទល់នឹងព្រហ្មលោកក៏បាន ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះលោកពោលថា បញ្ញា ក្នុងអត្ថថាសម្រេច ដោយអំណាចនៃការអធិដ្ឋាននូវសុខសញ្ញានិងលហុសញ្ញា ព្រោះការកំណត់នូវកាយនិងចិត្តថាតែមួយ ឈ្មោះថាឥទ្ធិវិធញ្ញាណ ។

[២៥៤] បញ្ញាក្នុងការស្ទង់នូវសទ្ទនិមិត្ត មានភាពផ្សេងគ្នានិងមានភាពតែមួយ ដោយអំណាចនៃការផ្សាយទៅនៃវិតក្កៈ ឈ្មោះថាសោតធាតុវិសុទ្ធិញ្ញាណ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទដែលប្រកបដោយឆន្ទសមាធិ វីរិយសមាធិ ចិត្តសមាធិ វីមំសាសមាធិ និងបធានសង្ខារ ភិក្ខុនោះ អប់រំ បង្វឹកចិត្ត ធ្វើចិត្តឲ្យទន់ គួរដល់កម្មក្នុងឥទ្ធិបាទទាំង ៤ នេះ ភិក្ខុនោះលុះអប់រំបង្វឹកចិត្តធ្វើចិត្តឲ្យទន់ គួរដល់កម្មក្នុងឥទ្ធិបាទទាំង ៤ នេះហើយ រមែងធ្វើទុកក្នុងចិត្ត នូវសទ្ទនិមិត្តនៃសំឡេងក្នុងទីឆ្ងាយក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេង ក្នុងទីជិតក៏បាន

មនសិការោតិ ឱឡារិកានំបិ សទ្ទានំ សទ្ទនិមិត្តំ មនសិការោតិ សុខុមកានំបិ[១] សទ្ទានំ សទ្ទនិមិត្តំ មនសិការោតិ សណ្ហាសណ្ហានំបិ សទ្ទានំ សទ្ទនិមិត្តំ មនសិការោតិ បុរត្ថិមាយ ទិសាយ សទ្ទានំ សទ្ទនិមិត្តំ មនសិការោតិ បច្ឆិមាយ ទិសាយ សទ្ទានំ សទ្ទនិមិត្តំ មនសិការោតិ ឧត្តរាយ ទិសាយ សទ្ទានំ សទ្ទនិមិត្តំ មនសិការោតិ ទក្ខិណាយ ទិសាយ សទ្ទានំ សទ្ទនិមិត្តំ មនសិការោតិ បុរត្ថិមាយបិ អនុទិសាយ សទ្ទានំ សទ្ទនិមិត្តំ មនសិការោតិ បច្ឆិមាយបិ អនុទិសាយ សទ្ទានំ សទ្ទនិមិត្តំ មនសិការោតិ ឧត្តរាយបិ អនុទិសាយ សទ្ទានំ សទ្ទនិមិត្តំ មនសិការោតិ ទក្ខិណាយបិ អនុទិសាយ សទ្ទានំ សទ្ទនិមិត្តំ មនសិការោតិ ហេដ្ឋិមាយបិ ទិសាយ សទ្ទានំ សទ្ទនិមិត្តំ មនសិការោតិ ឧបរិមាយបិ ទិសាយ សទ្ទានំ សទ្ទនិមិត្តំ មនសិការោតិ សោ តថា[២] ភាវិតេន ចិត្តេន បរិសុទ្ធេន បរិយោទាតេន សោតធាតុយា

---

១ ឱ. ម. សុខុមានំបិ ។ ២ ឱ. តត្ថ ។

ធ្វើទុកក្នុងចិត្ត នូវសទ្ទនិមិត្តនៃសំឡេង ដែលគ្រោតគ្រាតក៏បាន ធ្វើទុកក្នុងចិត្តនូវសទ្ទនិមិត្តនៃសំឡេង ដែលល្អិតល្អន់ក៏បាន ធ្វើទុកក្នុងចិត្ត នូវសទ្ទនិមិត្តនៃសំឡេង ដែលល្អិតក្រៃលែងក៏បាន ធ្វើទុកក្នុងចិត្ត នូវសទ្ទ-និមិត្តនៃសំឡេង ក្នុងទិសខាងកើតក៏បាន ធ្វើទុកក្នុងចិត្ត នូវសទ្ទនិមិត្តនៃសំឡេង ក្នុងទិសខាងលិចក៏បាន ធ្វើទុកក្នុងចិត្ត នូវសទ្ទនិមិត្តនៃសំឡេង ក្នុងទិសខាងជើងក៏បាន ធ្វើទុកក្នុងចិត្ត នូវសទ្ទនិមិត្តនៃសំឡេង ក្នុងទិសខាងត្បូងក៏បាន ធ្វើទុកក្នុងចិត្ត នូវសទ្ទនិមិត្តនៃសំឡេង ក្នុងទិសបន្ទាប់ទិសខាងកើតក៏បាន ធ្វើទុកក្នុងចិត្ត នូវសទ្ទនិមិត្តនៃសំឡេង ក្នុងទិសបន្ទាប់ទិសខាងលិចក៏បាន ធ្វើទុកក្នុងចិត្ត នូវសទ្ទនិមិត្តនៃសំឡេង ក្នុងទិសបន្ទាប់ទិសខាងជើងក៏បាន ធ្វើទុកក្នុងចិត្ត នូវសទ្ទនិមិត្តនៃសំឡេងក្នុងទិសបន្ទាប់ទិសខាងត្បូងក៏បាន ធ្វើទុកក្នុងចិត្ត នូវសទ្ទនិមិត្តនៃសំឡេង ក្នុងទិសខាងក្រោមក៏បាន ធ្វើទុកក្នុងចិត្ត នូវសទ្ទនិមិត្តនៃសំឡេង ក្នុងទិសខាងលើក៏បាន ភិក្ខុនោះមានចិត្តអប់រំ បរិសុទ្ធផូរផង់ ដូច្នោះហើយ តែងបង្អោន បន្ទន់ចិត្តទៅ ក្នុងសោតធាតុ-

វិសុទ្ធិញាណាយ(១) ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ សោ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណាតិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ច តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ វិតក្កវិប្ផារវសេន នានត្តេកត្តសទ្ទនិមិត្តានំ បរិយោគាហណេ បញ្ញា សោតធាតុវិសុទ្ធិញាណំ ។

[២៥៥] កថំ តិណ្ណំ ចិត្តានំ វិប្ផារត្តា ឥន្ទ្រិយានំ បសាទវសេន នានត្តេកត្តវិញ្ញាណចរិយាបរិយោគាហណេ បញ្ញា ចេតោបរិយញាណំ ។ ឥធ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិ ។ បេ ។ ចិត្តសមាធិ ។ បេ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ សោ ឥមេសុ ចតូសុ ឥទ្ធិបាទេសុ ចិត្តំ បរិភាវេតិ បរិទមេតិ មុទុំ ករោតិ កម្មនិយំ សោ ឥមេសុ ចតូសុ ឥទ្ធិបាទេសុ ចិត្តំ បរិភាវេត្វា បរិទមេត្វា មុទុំ ករិត្វា កម្មនិយំ ឯវំ ជានាតិ

១ ឱ. សោតធាតុវិសុទ្ធិញាណាយ ។

វិសុទ្ធិញ្ញាណ ភិក្ខុនោះរមែងស្តាប់ឮនូវសំឡេង២ យ៉ាង គឺសំឡេងជាទិព្វ ១ សំឡេងជារបស់មនុស្ស ១ ទាំងឆ្ងាយទាំងជិត ដោយសោតធាតុដូចជាទិព្វ ដ៏ស្អាត កន្លងនូវសោតធាតុនៃមនុស្ស (សាមញ្ញ) ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់ នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការស្ទង់នូវសទ្ទនិមិត្ត មានភាពផ្សេង ៗ និងមានភាពតែមួយ ដោយអំណាចនៃការផ្សាយនូវ វិតក្កៈ ឈ្មោះថាសោតធាតុវិសុទ្ធិញ្ញាណ ។

[២៥៥] បញ្ញាក្នុងការស្ទង់នូវការត្រាច់ទៅនៃវិញ្ញាណ មានភាព ផ្សេង ៗ និងមានភាពតែមួយ ដោយអំណាចនៃបសាទ របស់ឥន្ទ្រិយ ទាំងឡាយ ព្រោះផ្សាយទៅ នៃចិត្តទាំង ៣[១] ឈ្មោះថាចេតោបរិយ-ញ្ញាណ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទដែល ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើននូវឥទ្ធិបាទដែលប្រកប ដោយវីរិយសមាធិ ។ បេ ។ ចិត្តសមាធិ ។ បេ ។ វីមំសាសមាធិ និងបធានសង្ខារ ភិក្ខុនោះ អប់រំ បង្វឹកចិត្ត ធ្វើចិត្តឲ្យទន់ គួរដល់កម្ម ក្នុងឥទ្ធិបាទទាំង ៤ នេះ ភិក្ខុនោះ លុះអប់រំ បង្វឹកចិត្ត ធ្វើចិត្តឲ្យទន់ គួរដល់កម្ម ក្នុងឥទ្ធិបាទទាំង ៤ នេះហើយ រមែងដឹងយ៉ាងនេះថា

១ សោមនស្ស ទោមនស្ស ឧបេក្ខា ។ អដ្ឋកថា ។

ឥទំ រូបំ សោមនស្សិន្ទ្រិយសមុដ្ឋិតំ ឥទំ រូបំ ទោមនស្សិន្ទ្រិយសមុដ្ឋិតំ ឥទំ រូបំ ឧបេក្ខិន្ទ្រិយសមុដ្ឋិតន្តិ សោ តថា ភាវិតេន ចិត្តេន បរិសុទ្ធេន បរិយោទាតេន ចេតោ បរិយញ្ញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ សោ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានាតិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ សមោហំ វា ចិត្តំ វីតមោហំ វា ចិត្តំ សង្ខិត្តំ វា ចិត្តំ វិក្ខិត្តំ វា ចិត្តំ មហគ្គតំ វា ចិត្តំ អមហគ្គតំ វា ចិត្តំ សឧត្តរំ វា ចិត្តំ អនុត្តរំ វា ចិត្តំ សមាហិតំ វា ចិត្តំ អសមាហិតំ វា ចិត្តំ វិមុត្តំ វា ចិត្តំ អវិមុត្តំ វា ចិត្តំ អធិមុត្តំ វា ចិត្តំ អនធិមុត្តំ វា ចិត្តំ អនធិមុត្តំ ចិត្តន្តិ បជានាតិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន

រូបនេះ កើតឡើងដោយសោមនស្សិន្ទ្រិយ រូបនេះ កើតឡើងដោយទោមនស្សិន្ទ្រិយ រូបនេះ កើតឡើងដោយឧបេក្ខិន្ទ្រិយ ភិក្ខុនោះមានចិត្តអប់រំ បរិសុទ្ធ ផូរផង់ ដូច្នោះហើយ ក៏បង្អោនបន្ទន់ចិត្តទៅក្នុងចេតោបរិយញ្ញាណ ភិក្ខុនោះ រមែងកំណត់ដឹងនូវចិត្តរបស់សត្វដទៃរបស់បុគ្គលដទៃ ដោយចិត្តរបស់ខ្លួន ដឹងនូវចិត្តដែលប្រកបដោយរាគៈថាចិត្តប្រកបដោយរាគៈផង ដឹងនូវចិត្តដែលប្រាសចាករាគៈ ថាចិត្តប្រាសចាករាគៈផង ដឹងនូវចិត្តដែលប្រកបដោយទោសៈ ថាចិត្តប្រកបដោយទោសៈផង ដឹងនូវចិត្តដែលប្រាសចាកទោសៈផង ដឹងនូវចិត្តដែលប្រកបដោយមោហៈផង ដឹងនូវចិត្តដែលប្រាសចាកមោហៈផង នូវចិត្តដែលរួញរាផង នូវចិត្តដែលរាយមាយផង នូវចិត្តដែលជាមហគ្គតៈ គឺចិត្តដល់ភាពធំ (បានដល់រូបាវចរនិងអរូបាវចរ) ផង នូវចិត្តដែលមិនមែនជាមហគ្គតៈគឺជាកាមាវចរផង នូវចិត្តដែលមានចិត្តដទៃក្រៃលែងជាង គឺជាកាមាវចរផង នូវចិត្តដែលមិនមានចិត្តដទៃក្រៃលែងជាង គឺរូបាវចរនិងអរូបាវចរផង នូវចិត្តដែលតាំងមាំផង នូវចិត្តដែលមិនបានតាំងមាំផង នូវចិត្តដែលរួចស្រឡះផង នូវចិត្តដែលមិនរួចស្រឡះផង នូវចិត្តដែលចុះស៊ប់ផង នូវចិត្តដែលមិនចុះស៊ប់ ថាចិត្តមិនចុះស៊ប់ផង ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ

វុច្ចតិ តិណ្ណំ ចិត្តានំ វិប្ផារត្តា ឥន្ទ្រិយានំ បសាទវសេន ជានេត្តេកត្តវិញ្ញាណចរិយាបរិយោគាហនេ បញ្ញា ចេតោបរិយញ្ញាណំ ។

[២៤៦] កថំ បច្ចយប្បវត្តានំ ធម្មានំ នានត្តេកត្តកម្មវិប្ផារវសេន បរិយោគាហនេ បញ្ញា បុព្វេនិវាសានុស្សតិញ្ញាណំ ។ ឥធ ភិក្ខុ ឆន្ទសមាធិ ។ បេ ។ មុទុំ ករិត្វា កម្មនីយំ ឯវំ បជានាតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ យទិទំ អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ

ហេតុនោះ លោកពោលថា បញ្ញាក្នុងការស្ទង់នូវការត្រាច់ទៅនៃវិញ្ញាណ មានភាពផ្សេង ៗ និងមានភាពតែមួយ ដោយអំណាចនៃបសាទ របស់ឥន្ទ្រិយទាំងឡាយ ព្រោះផ្សាយទៅនៃចិត្តទាំង ៣ ឈ្មោះថាចេតោបរិយញ្ញាណ ។

[២៥៦] បញ្ញាក្នុងការស្ទង់នូវធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅព្រោះបច្ច័យ ដោយអំណាចនៃការផ្សាយទៅនៃកម្ម ដែលមានភាពផ្សេង ៗ និងមានភាពតែមួយ ឈ្មោះថាបុព្វេនិវាសានុស្សតិញ្ញាណ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ (ចម្រើននូវឥទ្ធិបាទ) ប្រកបដោយឆន្ទសមាធិ ។ បេ ។ លុះធ្វើចិត្តឲ្យទន់ គួរដល់កម្មហើយ រមែងដឹងយ៉ាងនេះថា កាលបើធម្មជាតនេះមាន ធម្មជាតនោះ ក៏មានដែរ ព្រោះតែធម្មជាតនេះកើតឡើង ទើបធម្មជាតនុ៎ះកើតឡើងដែរ គឺសង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ លំបាកចិត្ត និងសេចក្តីតានតឹងចិត្ត ក៏កើតមានព្រម

ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ សោ តថា ភាវិតេន ចិត្តេន បរិសុទ្ធេន បរិយោទាតេន បុព្វេនិវាសានុស្សតិញ្ញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តារីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ តំញាតដ្ឋេន ញាណំ

ការកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានយ៉ាងនេះ ភិក្ខុនោះ មានចិត្តអប់រំ បរិសុទ្ធ ផូរផង់ដូច្នោះហើយ ក៏បង្អោនបន្ទន់ចិត្តទៅក្នុងបុព្វេនិវាសានុស្សតិញ្ញាណ ភិក្ខុនោះ រមែងរលឹកឃើញនូវបុព្វេនិវាស ច្រើនយ៉ាង គឺរលឹកឃើញបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ មួយរយជាតិខ្លះ មួយពាន់ជាតិខ្លះ មួយសែនជាតិខ្លះ អស់សំវដ្តកប្បដ៏ច្រើនខ្លះ វិវដ្តកប្បដ៏ច្រើនខ្លះ អស់សំវដ្តវិវដ្តកប្បដ៏ច្រើនខ្លះថា អាត្មាអញកើតហើយ ក្នុងទីឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ បាននូវសុខនិងទុក្ខយ៉ាងនេះ មានទីបំផុតអាយុយ៉ាងនេះ អាត្មាអញនោះ លុះច្យុតចាកទីនោះ បានទៅកើតក្នុងទីឯណោះ កាលដែលកើតក្នុងទីនោះ អាត្មាអញមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ បាននូវសុខនិងទុក្ខយ៉ាងនេះ មានទីបំផុតអាយុយ៉ាងនេះ អាត្មាអញនោះ លុះច្យុតចាកទីនោះ ទើបមកកើតក្នុងទីនេះ (ភិក្ខុនោះ) រមែងរលឹកឃើញនូវបុព្វេនិវាសច្រើនយ៉ាង ព្រមទាំងអាការ ព្រមទាំងឧទ្ទេស យ៉ាងនេះឯង ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ

បជាននដ្ឋេន បញ្ញា តេន វុច្ចតិ បច្ចយប្បវត្តានំ ធម្មានំ នានត្តេកត្តកម្មវិប្ផារវសេន បរិយោគាហនេ បញ្ញា បុព្វេនិវាសានុស្សតិញ្ញាណំ ។

[២៤៧] កថំ ឱភាសវសេន នានត្តេកត្តរូបនិ-មិត្តានំ ទស្សនដ្ឋេ បញ្ញា ទិព្វចក្ខុញ្ញាណំ ។ ឥធ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិ ។ បេ ។ ចិត្តសមាធិ ។ បេ ។ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភា-វេតិ សោ ឥមេសុ ចតូសុ ឥទ្ធិបាទេសុ ចិត្តំ បរិភាវេតិ បរិទមេតិ មុទុំ ករោតិ កម្មនីយំ សោ ឥមេសុ ចតូសុ ឥទ្ធិបាទេសុ ចិត្តំ បរិភាវេត្វា បរិទមេត្វា មុទុំ ករិត្វា កម្មនីយំ អាលោកសញ្ញំ មនសិករោតិ ទិវាសញ្ញំ អធិដ្ឋាតិ យថា ទិវា តថា រត្តិ យថា រត្តិ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ សោ តថា ភាវិតេន ចិត្តេន បរិសុទ្ធេន បរិយោទាតេន សត្តានំ ចុតូបបាតញ្ញា-ណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន

ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាក្នុងការស្ទង់ នូវធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅព្រោះបច្ច័យ ដោយអំណាចនៃការផ្សាយទៅនៃកម្ម មានភាពផ្សេង ៗ និងមានភាពតែមួយ ឈ្មោះថាបុព្វេនិវាសានុស្សតិញ្ញាណ ។

[២៥៧] បញ្ញាក្នុងអត្ថថាឃើញនូវរូបនិមិត្ត មានភាពផ្សេង ៗ និងមានភាពតែមួយ ដោយអំណាចនៃពន្លឺ ឈ្មោះថាទិព្វចក្ខុញ្ញាណ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើននូវឥទ្ធិបាទប្រកបដោយវីរិយសមាធិ ។ បេ ។ ចិត្តសមាធិ ។ បេ ។ វីមំសាសមាធិ និងបធានសង្ខារ ភិក្ខុនោះ រមែងអប់រំ បង្វឹកចិត្ត ធ្វើចិត្តឲ្យទន់ គួរដល់កម្ម ក្នុងឥទ្ធិបាទទាំង ៤ នេះ ភិក្ខុនោះ លុះអប់រំ បង្វឹកចិត្ត ធ្វើចិត្តឲ្យទន់ គួរដល់កម្មក្នុងឥទ្ធិបាទទាំង ៤ នេះហើយ ទើបធ្វើទុកក្នុងចិត្ត នូវអាលោកសញ្ញា អធិដ្ឋាននូវទិវាសញ្ញា (សេចក្ដីសម្គាល់ក្នុងពេលថ្ងៃ) ថា ក្នុងវេលាថ្ងៃយ៉ាងណា ក្នុងវេលាយប់ ក៏យ៉ាងនោះ យប់យ៉ាងណា ថ្ងៃក៏យ៉ាងនោះ (ភិក្ខុនោះ) មានចិត្តបើកហើយ ឥតមានកិលេសរួបរឹត រមែងចម្រើននូវចិត្តដែលប្រកបដោយពន្លឺបាន ភិក្ខុនោះ មានចិត្តអប់រំ បរិសុទ្ធផូរផង់ដូច្នោះហើយ ក៏បង្អោនបន្ទន់ចិត្ត ទៅក្នុងសត្តានំចុតូបបាតញ្ញាណ ភិក្ខុនោះ មានទិព្វចក្ខុដ៏ស្អាត បរិសុទ្ធ កន្លងនូវចក្ខុរបស់មនុស្សសាមញ្ញ

២៦០

សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆា-ទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុ-ចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្ម-សមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុ-ទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ឱភាសវសេន នានត្តេកត្តរូបនិមិត្តានំ ទស្ស-នដ្ឋេ បញ្ញា ទិព្វចក្ខុញាណំ ។

រមែងឃើញនូវសត្វទាំងឡាយ កំពុងច្យុត កំពុងកើត ថោកទាប ឧត្តម មានរូបល្អ រូបអាក្រក់ ទៅកាន់សុគតិ ទៅកាន់ទុគ្គតិ រមែងដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមយថាកម្មថា ឱហ្ន៎ ពួកសត្វដ៏ចម្រើននេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ សមាទាននូវមិច្ឆាទិដ្ឋិ ពួកសត្វនោះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ចំណែកខាងពួកសត្វដ៏ចម្រើននេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀល នូវពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ សមាទាននូវសម្មាទិដ្ឋិ ពួកសត្វនោះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ភិក្ខុនោះមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងនូវចក្ខុរបស់មនុស្សសាមញ្ញ រមែងឃើញនូវពួកសត្វដែលកំពុងច្យុត កំពុងកើត ថោកទាប ឧត្តម មានរូបល្អ រូបអាក្រក់ ទៅកាន់សុគតិ ទៅកាន់ទុគ្គតិ រមែងដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្ម យ៉ាងនេះឯង ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះលោកពោលថា បញ្ញាក្នុងអត្ថថាឃើញនូវរូបនិមិត្ត មានភាពផ្សេង ៗ និងមានភាពតែមួយ ដោយអំណាចនៃពន្លឺ ឈ្មោះថាទិព្វចក្ខុញ្ញាណ ។

[២៨៨] កថំ ចតុស្សដ្ឋិយា អាការេហិ តិណ្ណន្នំ ឥន្ទ្រិយានំ វសីភាវតា បញ្ញា អាសវានំ ខយេ ញាណំ ។ កតមេសំ តិណ្ណន្នំ ឥន្ទ្រិយានំ ។ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយស្ស អញ្ញិន្ទ្រិយស្ស អញ្ញាតាវិន្ទ្រិយស្ស ។ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ កតិដ្ឋានានិ គច្ឆតិ អញ្ញិន្ទ្រិយំ កតិដ្ឋានានិ គច្ឆតិ អញ្ញាតាវិន្ទ្រិយំ កតិដ្ឋានានិ គច្ឆតិ ។ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ ឯកំ ឋានំ គច្ឆតិ សោតាបត្តិមគ្គំ អញ្ញិន្ទ្រិយំ ឆ ឋានានិ គច្ឆតិ សោតាបត្តិផលំ សកទាគាមិមគ្គំ សកទាគាមិផលំ អនាគាមិមគ្គំ អនាគាមិផលំ អរហត្តមគ្គំ អញ្ញាតាវិន្ទ្រិយំ ឯកំ ឋានំ គច្ឆតិ អរហត្តផលំ ។

[២៨៩] សោតាបត្តិមគ្គក្ខណេ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយស្ស សទ្ធិន្ទ្រិយំ អធិមោក្ខបរិវារំ ហោតិ វីរិយិន្ទ្រិយំ បគ្គហបរិវារំ ហោតិ សតិន្ទ្រិយំ ឧបដ្ឋានបរិវារំ ហោតិ សមាធិន្ទ្រិយំ អវិក្ខេបបរិវារំ ហោតិ បញ្ញិន្ទ្រិយំ ទស្សនបរិវារំ ហោតិ មនិន្ទ្រិយំ វិជាននបរិវារំ ហោតិ សោមនស្សិន្ទ្រិយំ អភិនន្ទនបរិវារំ[១]

១ ម. អភិសន្ទនបរិវារំ ។

[២៥៨] បញ្ញាដែលស្ទាត់ជំនាញ នៃឥន្ទ្រិយទាំង ៣ ដោយអាការ ៦៤ ឈ្មោះថាអាសវក្ខយញ្ញាណ តើដូចម្តេច ។

ឥន្ទ្រិយ ៣ តើអ្វីខ្លះ ។ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញាតាវិន្ទ្រិយ ១ ។

អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ដល់នូវឋាន[១] ប៉ុន្មានយ៉ាង អញ្ញិន្ទ្រិយ ដល់នូវឋានប៉ុន្មានយ៉ាង អញ្ញាតាវិន្ទ្រិយ ដល់នូវឋានប៉ុន្មានយ៉ាង ។ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ដល់នូវឋានមួយ គឺសោតាបត្តិមគ្គ អញ្ញិន្ទ្រិយ ដល់នូវឋាន ៦ គឺ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អញ្ញាតាវិន្ទ្រិយ ដល់នូវឋានមួយ គឺ អរហត្តផល ។

[២៥៩] ក្នុងខណៈនៃសោតាបត្តិមគ្គ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ មានសទ្ធិន្ទ្រិយ ដែលមានការជឿស៊ប់ជាបរិវារ មានវីរិយិន្ទ្រិយ ដែលមានការផ្គងឡើង ជាបរិវារ មានសតិន្ទ្រិយ ដែលមានការប្រុងប្រយ័ត្នជាបរិវារ មានសមាធិន្ទ្រិយ ដែលមានការមិនរាយមាយ ជាបរិវារ មានបញ្ញិន្ទ្រិយ ដែលមានការឃើញជាបរិវារ មានមនិន្ទ្រិយ ដែលមានការដឹងច្បាស់ជាបរិវារ មានសោមនស្សិន្ទ្រិយ ដែលមានការសើមជ្រាយជាបរិវារ

១ ពាក្យថា "ដល់នូវឋាន" គឺ "សម្រេច-កើតមាន-ក្នុងហេតុ" ។

ហោតិ ជីវិតិន្ទ្រិយំ បវត្តសន្តតាធិបតេយ្យបរិវារំ ហោតិ សោតាបត្តិមគ្គក្ខណេ ជាតា ធម្មា ឋបេត្វា ចិត្តសមុដ្ឋានំ រូបំ សព្វេវ កុសលា ហោន្តិ សព្វេវ អនាសវា ហោន្តិ សព្វេវ និយ្យានិកា ហោន្តិ សព្វេវ អបចយគាមិនោ ហោន្តិ សព្វេវ លោកុត្តរា ហោន្តិ សព្វេវ និព្វានារម្មណា ហោន្តិ សោតាបត្តិមគ្គក្ខណេ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយស្ស ឥមានិ អដ្ឋិន្ទ្រិយានិ សហជាតបរិវារា ហោន្តិ អញ្ញមញ្ញបរិវារា ហោន្តិ និស្សយបរិវារា ហោន្តិ សម្បយុត្តបរិវារា ហោន្តិ សហគតា ហោន្តិ សហជាតា ហោន្តិ សំសដ្ឋា ហោន្តិ សម្បយុត្តា ហោន្តិ តេវ តស្ស អាការា ចេវ ហោន្តិ បរិវារា ច ។

[២៦០] សោតាបត្តិផលក្ខណេ អញ្ញិន្ទ្រិយស្ស សទ្ធិន្ទ្រិយំ អធិមោក្ខបរិវារំ ហោតិ វីរិយិន្ទ្រិយំ បគ្គហបរិវារំ ហោតិ សតិន្ទ្រិយំ ឧបដ្ឋានបរិវារំ ហោតិ សមាធិន្ទ្រិយំ អវិក្ខេបបរិវារំ ហោតិ បញ្ញិន្ទ្រិយំ ទស្សនបរិវារំ ហោតិ មនិន្ទ្រិយំ វិជាននបរិវារំ ហោតិ សោមនស្សិន្ទ្រិយំ អភិសន្ទនបរិវារំ

មានជីវិតិន្ទ្រិយ ដែលមានភាពនៃសន្តតិ កំពុងប្រព្រឹត្តទៅជាអធិបតីជាបរិវារ ធម៌ទាំងឡាយដែលកើតក្នុងខណៈនៃសោតាបត្តិមគ្គ លើកលែងតែរូបដែលមានចិត្តជាសមុដ្ឋានចេញ សុទ្ធតែជាកុសលទាំងអស់ សុទ្ធតែមិនមានអាសវៈទាំងអស់ សុទ្ធតែនាំសត្វចេញចាកវដ្តៈទាំងអស់ សុទ្ធតែដល់នូវការមិនសន្សំនូវកិលេសទាំងអស់ សុទ្ធតែជាលោកុត្តរៈ ទាំងអស់ សុទ្ធតែមាននិព្វានជាអារម្មណ៍ទាំងអស់ ក្នុងខណៈនៃសោតាបត្តិមគ្គ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ មានឥន្ទ្រិយទាំង ៨ នេះ ដែលមានសហជាតប្បច្ច័យជាបរិវារ ដែលមានអញ្ញមញ្ញប្បច្ច័យជាបរិវារ ដែលមាននិស្សយប្បច្ច័យជាបរិវារ ដែលមានសម្បយុត្តប្បច្ច័យជាបរិវារ ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយឡំជាមួយគ្នា ប្រកបជាមួយគ្នា ធម៌ទាំងនោះ ជាអាការៈផង ជាបរិវារផង នៃអនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះ ។

[២៦០] ក្នុងខណៈនៃសោតាបត្តិផល អញ្ញិន្ទ្រិយ មានសទ្ធិន្ទ្រិយ ដែលមានការជឿស៊ប់ជាបរិវារ មានវីរិយិន្ទ្រិយ មានដែលមានការផ្គងឡើងជាបរិវារ មានសតិន្ទ្រិយ ដែលមានការប្រុងប្រយ័ត្នជាបរិវារ មានសមាធិន្ទ្រិយ ដែលមានការមិនរាយមាយជាបរិវារ មានបញ្ញិន្ទ្រិយ ដែលមានការឃើញជាបរិវារ មានមនិន្ទ្រិយ ដែលមានការដឹងច្បាស់ជាបរិវារ មានសោមនស្សិន្ទ្រិយ ដែលមានការសើមជ្រាយជាបរិវារ

ហោតិ ជីវិតិន្ទ្រិយំ បវត្តសន្តតាធិបតេយ្យបរិវារំ ហោតិ សោតាបត្តិផលក្ខណេ ជាតា ធម្មា សព្វេវ អព្យាកតា ហោន្តិ ឋបេត្វា ចិត្តសមុដ្ឋានំ រូបំ សព្វេវ អនាសវា ហោន្តិ សព្វេវ លោកុត្តរា ហោន្តិ សព្វេវ និព្វានារម្មណា ហោន្តិ សោតាបត្តិផលក្ខណេ អញ្ញិន្ទ្រិយស្ស ឥមានិ អដ្ឋិន្ទ្រិយានិ សហជាតបរិវារា ហោន្តិ អញ្ញមញ្ញបរិវារា ហោន្តិ និស្សយបរិវារា ហោន្តិ សម្បយុត្តបរិវារា ហោន្តិ សហគតា ហោន្តិ សហជាតា ហោន្តិ សំសដ្ឋា ហោន្តិ សម្បយុត្តា ហោន្តិ តេវ តស្ស អាការា ចេវ ហោន្តិ បរិវារា ច ។

[២៦១] សកទាគាមិមគ្គក្ខណេ ។ បេ ។ សកទាគាមិផលក្ខណេ ។ បេ ។ អនាគាមិមគ្គក្ខណេ ។ បេ ។ អនាគាមិផលក្ខណេ ។ បេ ។ អរហត្តមគ្គក្ខណេ អញ្ញិន្ទ្រិយស្ស សទ្ធិន្ទ្រិយំ អធិមោក្ខបរិវារំ ហោតិ ។ បេ ។ ជីវិតិន្ទ្រិយំ បវត្តសន្តតាធិបតេយ្យបរិវារំ ហោតិ អរហត្តមគ្គក្ខណេ ជាតា ធម្មា ឋបេត្វា ចិត្តសមុដ្ឋានំ រូបំ សព្វេវ កុសលា ហោន្តិ

មានជីវិតិន្ទ្រិយ ដែលមានភាពនៃសន្តតិ កំពុងប្រព្រឹត្តទៅជាអធិបតី ជាបរិវារ ធម៌ទាំងឡាយដែលកើតក្នុងខណៈនៃសោតាបត្តិផល លើកលែងតែរូបដែលមានចិត្តជាសមុដ្ឋានចេញ សុទ្ធតែជាអព្យាក្រឹតទាំងអស់ សុទ្ធតែមិនមានអាសវៈទាំងអស់ សុទ្ធតែជាលោកុត្តរៈទាំងអស់ សុទ្ធតែមាននិព្វានជាអារម្មណ៍ទាំងអស់ ក្នុងខណៈនៃសោតាបត្តិផល អញ្ញិន្ទ្រិយ មានឥន្ទ្រិយទាំង ៨ នេះ ដែលមានសហជាតប្បច្ច័យជាបរិវារ ដែលមានអញ្ញមញ្ញប្បច្ច័យជាបរិវារ ដែលមាននិស្សយប្បច្ច័យជាបរិវារ ដែលមានសម្បយុត្តប្បច្ច័យជាបរិវារ ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយឡំជាមួយគ្នា ប្រកបជាមួយគ្នា ធម៌ទាំងនោះ ជាអាការផង ជាបរិវារផង នៃអញ្ញិន្ទ្រិយនោះ ។

[២៦១] ក្នុងខណៈនៃសកទាគាមិមគ្គ ។ បេ ។ ក្នុងខណៈនៃសកទាគាមិផល ។ បេ ។ ក្នុងខណៈនៃអនាគាមិមគ្គ ។ បេ ។ ក្នុងខណៈនៃអនាគាមិផល ។ បេ ។ ក្នុងខណៈនៃអរហត្តមគ្គ អញ្ញិន្ទ្រិយ មានសទ្ធិន្ទ្រិយ ដែលមានការជឿស៊ប់ជាបរិវារ ។ បេ ។ មានជីវិតិន្ទ្រិយ ដែលមានភាពនៃសន្តតិ កំពុងប្រព្រឹត្តទៅជាអធិបតី ជាបរិវារ ធម៌ទាំងឡាយ ដែលកើតក្នុងខណៈនៃអរហត្តមគ្គ លើកលែងតែរូប ដែលមានចិត្តជាសមុដ្ឋានចេញ សុទ្ធតែជាកុសល ទាំងអស់

សព្វេវ អនាសវា ហោន្តិ សព្វេវ និយ្យានិកា ហោន្តិ សព្វេវ អបចយគាមិនោ ហោន្តិ សព្វេវ លោកុត្តរា ហោន្តិ សព្វេវ និព្វានារម្មណា ហោន្តិ អរហត្តមគ្គក្ខណេ អញ្ញិន្ទ្រិយស្ស ឥមានិ អដ្ឋិន្ទ្រិយានិ សហជាតបរិវារា ហោន្តិ អញ្ញមញ្ញបរិវារា ហោន្តិ និស្សយបរិវារា ហោន្តិ សម្បយុត្តបរិវារា ហោន្តិ សហគតា ហោន្តិ សហជាតា ហោន្តិ សំសដ្ឋា ហោន្តិ សម្បយុត្តា ហោន្តិ តេវ អាការា ចេវ ហោន្តិ បរិវារា ច ។

[២៦២] អរហត្តផលក្ខណេ អញ្ញាតាវិន្ទ្រិយស្ស សទ្ធិន្ទ្រិយំ អធិមោក្ខបរិវារំ ហោតិ វីរិយិន្ទ្រិយំ បគ្គហបរិវារំ ហោតិ សតិន្ទ្រិយំ ឧបដ្ឋានបរិវារំ ហោតិ សមាធិន្ទ្រិយំ អវិក្ខេបបរិវារំ ហោតិ បញ្ញិន្ទ្រិយំ ទស្សនបរិវារំ ហោតិ មនិន្ទ្រិយំ វិជាននបរិវារំ ហោតិ សោមនស្សិន្ទ្រិយំ អភិសន្ទនបរិវារំ ហោតិ ជីវិតិន្ទ្រិយំ បវត្តសន្តតាធិបតេយ្យបរិវារំ ហោតិ អរហត្តផលក្ខណេ ជាតា ធម្មា សព្វេវ អព្យាកតា ហោន្តិ ឋបេត្វា ចិត្តសមុដ្ឋានំ រូបំ សព្វេវ

សុទ្ធតែមិនមានអាសវៈទាំងអស់ សុទ្ធតែនាំសត្វឲ្យចេញចាកវដ្ដៈទាំងអស់ សុទ្ធតែដល់នូវការមិនសន្សំនូវកិលេសទាំងអស់ សុទ្ធតែជាលោកុត្តរៈទាំងអស់ សុទ្ធតែមាននិព្វាន ជាអារម្មណ៍ទាំងអស់ ក្នុងខណៈនៃអរហត្តមគ្គ អញ្ញិន្ទ្រិយ មានឥន្ទ្រិយទាំង ៨ នេះ ដែលមានសហជាតប្បច្ច័យ ជាបរិវារ ដែលមានអញ្ញមញ្ញប្បច្ច័យ ជាបរិវារ ដែលមាននិស្សយប្បច្ច័យ ជាបរិវារ ដែលមានសម្បយុត្តប្បច្ច័យ ជាបរិវារ ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយឡំគ្នា ប្រកបជាមួយគ្នា ធម៌ទាំងនោះ ជាអាការៈផង ជាបរិវារផង នៃអញ្ញិន្ទ្រិយនោះ ។

[២៦២] ក្នុងខណៈនៃអរហត្តផល អញ្ញាតាវិន្ទ្រិយ មានសទ្ធិន្ទ្រិយ ដែលមានការជឿស៊ប់ជាបរិវារ មានវីរិយិន្ទ្រិយ ដែលមានការផ្គងឡើងជាបរិវារ មានសតិន្ទ្រិយ ដែលមានការប្រុងប្រយ័ត្នជាបរិវារ មានសមាធិន្ទ្រិយ ដែលមានការមិនរាយមាយជាបរិវារ មានបញ្ញិន្ទ្រិយ ដែលមានការឃើញ ជាបរិវារ មានមនិន្ទ្រិយ ដែលមានការដឹងច្បាស់ ជាបរិវារ មានសោមនស្សិន្ទ្រិយ ដែលមានការសើមជ្រាយ ជាបរិវារ មានជីវិតិន្ទ្រិយ ដែលមានភាពនៃសន្តតិ កំពុងប្រព្រឹត្តទៅ ជាអធិបតីជាបរិវារ ធម៌ទាំងឡាយដែលកើតក្នុងខណៈនៃអរហត្តផល លើកលែងតែរូប ដែលមានចិត្ត ជាសមុដ្ឋានចេញ សុទ្ធតែជាអព្យាក្រឹតទាំងអស់

អនាសវា ហោន្តិ សព្វេវ លោកុត្តរា ហោន្តិ សព្វេវ និព្វានារម្មណា ហោន្តិ អរហត្តផលក្ខណេ អញ្ញា-តាវិន្ទ្រិយស្ស ឥមានិ អដ្ឋិន្ទ្រិយានិ សហជាតបរិវារា ហោន្តិ អញ្ញមញ្ញបរិវារា ហោន្តិ និស្សយបរិវារា ហោន្តិ សម្បយុត្តបរិវារា ហោន្តិ សហគតា ហោន្តិ សហ-ជាតា ហោន្តិ សំសដ្ឋា ហោន្តិ សម្បយុត្តា ហោន្តិ តេវ តស្ស អាការា ចេវ ហោន្តិ បរិវារា ច ឥតិ ឥមានិ អដ្ឋដ្ឋកានិ ចតុស្សដ្ឋី ហោន្តិ ។

[២៦៣] អាសវាតិ កតមេ តេ អាសវា ។ កាមាសវោ ភវាសវោ ទិដ្ឋាសវោ អវិជ្ជាសវោ ។ កត្ថេតេ អាសវា ខីយន្តិ ។ សោតាបត្តិមគ្គេន អនវ-សេសោ ទិដ្ឋាសវោ ខីយតិ អបាយគមនីយោ កាមា-សវោ ខីយតិ អបាយគមនីយោ ភវាសវោ ខីយតិ អបាយគមនីយោ អវិជ្ជាសវោ ខីយតិ ឯត្ថេតេ អា-សវា ខីយន្តិ សកទាគាមិមគ្គេន ឱឡារិកោ កាមា-សវោ ខីយតិ តទេកដ្ឋោ ភវាសវោ ខីយតិ

សុទ្ធតែមិនមានអាសវៈទាំងអស់ សុទ្ធតែជាលោកុត្តរៈទាំងអស់ សុទ្ធតែមាននិព្វានជាអារម្មណ៍ទាំងអស់ ក្នុងខណៈនៃអរហត្តផល អញ្ញាតាវិន្ទ្រិយ មានឥន្ទ្រិយទាំង ៨ នេះ ដែលមានសហជាតប្បច្ច័យ ជាបរិវារ ដែលមានអញ្ញមញ្ញប្បច្ច័យ ជាបរិវារ ដែលមាននិស្សយប្បច្ច័យ ជាបរិវារ ដែលមានសម្បយុត្តប្បច្ច័យជាបរិវារ ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយឡំគ្នា ប្រកបជាមួយគ្នា ធម៌ទាំងនោះ ជាអាការផង ជាបរិវារផង នៃអញ្ញាតាវិន្ទ្រិយនោះ ឥន្ទ្រិយនេះ មានប្រមាណ ៨ ប្រាំបីដង ត្រូវជា ៦៤ យ៉ាងនេះឯង ។

[២៦៣] សំណួរត្រង់ពាក្យថា អាសវៈ តើអាសវៈ ដូចម្តេចខ្លះ ។ កាមាសវៈ ១ ភវាសវៈ ១ ទិដ្ឋាសវៈ ១ អវិជ្ជាសវៈ ១ ។ អាសវៈទាំងនុ៎ះ រមែងអស់ក្នុងធម៌ដូចម្តេច ។ ទិដ្ឋាសវៈ អស់ឥតមានសេសសល់ កាមាសវៈ ដែលញុំាងសត្វឲ្យទៅកាន់អបាយ ក៏អស់ ភវាសវៈ ដែលញុំាងសត្វឲ្យទៅកាន់អបាយ ក៏អស់ អវិជ្ជាសវៈ ដែលញុំាងសត្វឲ្យទៅកាន់អបាយ ក៏អស់ ដោយសោតាបត្តិមគ្គ អាសវៈទាំងនេះ រមែងអស់ក្នុងធម៌នេះឯង កាមាសវៈដ៏គ្រោតគ្រាត រមែងអស់ ភវាសវៈ ដែលបិតនៅជាមួយនឹងកាមាសវៈនោះ ក៏អស់

តទេកដ្ឋោ អវិជ្ជាសវោ ខីយតិ ឯត្ថេតេ អាសវា ខីយន្តិ អនាគាមិមគ្គេន អនវសេសោ កាមាសវោ ខីយតិ តទេកដ្ឋោ ភវាសវោ ខីយតិ តទេកដ្ឋោ អវិជ្ជាសវោ ខីយតិ ឯត្ថេតេ អាសវា ខីយន្តិ អរហត្ត-មគ្គេន អនវសេសោ ភវាសវោ ខីយតិ[១] អវិជ្ជាសវោ ខីយតិ ឯត្ថេតេ អាសវា ខីយន្តិ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ចតុស្ស-ដ្ឋិយា អាការេហិ តិណ្ណន្នំ ឥន្ទ្រិយានំ វសីភាវតា-បញ្ញា អាសវានំ ខយេ ញាណំ ។

[២៦៤] កថំ បរិញ្ញដ្ឋេ បញ្ញា ទុក្ខេ ញាណំ បហានដ្ឋេ បញ្ញា សមុទយេ ញាណំ សច្ឆិកិរិយដ្ឋេ បញ្ញា និរោធេ ញាណំ ភាវនដ្ឋេ បញ្ញា មគ្គេ ញាណំ ។ ទុក្ខស្ស បីឡនដ្ឋោ សន្តាបដ្ឋោ សង្ខតដ្ឋោ វិបរិណា-មដ្ឋោ បរិញ្ញដ្ឋោ សមុទយស្ស អាយូហនដ្ឋោ និទានដ្ឋោ សញ្ញោគដ្ឋោ បលិពោធដ្ឋោ បហានដ្ឋោ និរោធស្ស

១ ឱ. ម. ឯត្ថន្តរេ អនវសេសោតិ ទិស្សតិ ។

*អវិជ្ជាសវៈ ដែលបិតនៅជាមួយ នឹងភវាសវៈនោះ ក៏អស់ ដោយសកទាគាមិមគ្គ អាសវៈទាំងនេះ រមែងអស់ក្នុងធម៌នេះឯង កាមាសវៈ អស់ឥតមានសេសសល់ ភវាសវៈដែលបិតនៅជាមួយគ្នានឹងកាមាសវៈនោះក៏អស់ អវិជ្ជាសវៈ ដែលបិតនៅជាមួយនឹងភវាសវៈនោះក៏អស់ ដោយអនាគាមិមគ្គ អាសវៈទាំងនេះ រមែងអស់ក្នុងធម៌នេះឯង ភវាសវៈ អស់ឥតមានសេសសល់ អវិជ្ជាសវៈអស់ដោយអរហត្តមគ្គ អាសវៈទាំងនេះ រមែងអស់ ក្នុងធម៌នេះឯង ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា បញ្ញាដែលស្ទាត់ជំនាញ នៃឥន្ទ្រិយទាំង ៣ ដោយអាការ ៦៤ ឈ្មោះថាអាសវក្ខយញ្ញាណ ។*

[២៦៤] *បញ្ញា ក្នុងអត្ថថាកំណត់ដឹង ឈ្មោះថាទុក្ខញ្ញាណ បញ្ញាក្នុងអត្ថថាលះ ឈ្មោះថាសមុទយញ្ញាណ បញ្ញាក្នុងអត្ថថាធ្វើឲ្យជាក់ច្បាស់ ឈ្មោះថានិរោធញ្ញាណ បញ្ញាក្នុងអត្ថថាចម្រើន ឈ្មោះថាមគ្គញ្ញាណ តើដូចម្តេច ។ ទុក្ខសច្ច មានអត្ថថាបៀតបៀន មានអត្ថថាក្តៅក្រហាយ មានអត្ថថាបច្ច័យតាក់តែង មានអត្ថថាប្រែប្រួល មានអត្ថថាគួរកំណត់ដឹង សមុទយសច្ច មានអត្ថថាប្រមូលមក មានអត្ថថាជាហេតុ មានអត្ថថាប្រកបព្រម មានអត្ថថាកង្វល់ មានអត្ថថាលះបង់ និរោធសច្ច*

និស្សរណដ្ឋោ វិវេកដ្ឋោ អសង្ខតដ្ឋោ អមតដ្ឋោ សច្ឆិកិរិយដ្ឋោ មគ្គស្ស និយ្យានដ្ឋោ ហេតដ្ឋោ ទស្សនដ្ឋោ អាធិបតេយ្យដ្ឋោ ភាវនដ្ឋោ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ បរិញ្ញដ្ឋេ បញ្ញា ទុក្ខេ ញាណំ បហានដ្ឋេ បញ្ញា សមុទយេ ញាណំ សច្ឆិកិរិយដ្ឋេ បញ្ញា និរោធេ ញាណំ ភាវនដ្ឋេ បញ្ញា មគ្គេ ញាណំ ។

[២៦៨] កថំ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ ។ មគ្គសមង្គិស្ស ញាណំ ទុក្ខេ-បេតំ ញាណំ ទុក្ខសមុទយេបេតំ ញាណំ ទុក្ខ-និរោធេបេតំ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទា-យបេតំ ញាណំ ។

[២៦៦] តត្ថ កតមំ ទុក្ខេ ញាណំ ។ ទុក្ខំ អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា វិចយោ បវិចយោ ធម្មវិចយោ សល្លក្ខណា ឧបលក្ខណា បច្ចុបលក្ខណា បណ្ឌិច្ចំ កោសល្លំ នេបុញ្ញំ

មានអត្ថថារលាស់ចេញ មានអត្ថថាស្ងាត់ មានអត្ថថាមិនមានបច្ច័យប្រជុំតាក់តែង មានអត្ថថាមិនស្លាប់ មានអត្ថថាធ្វើឲ្យជាក់ច្បាស់ មគ្គសច្ចមានអត្ថថាស្រោចស្រង់ មានអត្ថថាជាហេតុ មានអត្ថថាឃើញ មានអត្ថថាជាអធិបតី មានអត្ថថាគួរចម្រើន ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌ ឈ្មោះថាបញ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះលោកពោលថា បញ្ញាក្នុងអត្ថថាកំណត់ដឹង ឈ្មោះថាទុក្ខញ្ញាណ បញ្ញាក្នុងអត្ថថាលះ ឈ្មោះថាសមុទយញ្ញាណ បញ្ញាក្នុងអត្ថថាធ្វើឲ្យជាក់ច្បាស់ឈ្មោះថានិរោធញ្ញាណ បញ្ញាក្នុងអត្ថថាចម្រើន ឈ្មោះថាមគ្គញ្ញាណ ។

[២៦៥] ទុក្ខញ្ញាណ ទុក្ខសមុទយញ្ញាណ ទុក្ខនិរោធញ្ញាណ ទុក្ខនិរោធគាមិនីបដិបទាញាណ តើដូចម្តេច ។ ញាណ របស់បុគ្គលដែលប្រកបព្រមដោយមគ្គ ឈ្មោះថាទុក្ខញ្ញាណផង ឈ្មោះថាទុក្ខសមុទ-យញ្ញាណផង ឈ្មោះថាទុក្ខនិរោធញ្ញាណផង ឈ្មោះថាទុក្ខនិរោធគា-មិនីបដិបទាញាណផង ។

[២៦៦] បណ្តាញាណទាំងនោះ ទុក្ខញ្ញាណ តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ សេចក្តីពិចារណាធម៌ សេចក្តីជ្រើសរើស សេចក្តីពិចារណា ការកំណត់ ការកត់សម្គាល់ ការកត់ត្រា ភាពជាបណ្ឌិត ភាពជាអ្នកឈ្លាសវៃ ភាពជាបុគ្គលមានសេចក្តីជ្រះស្អាត

វេភព្យា ចិន្តា ឧបបរិក្ខា ភូរិ មេធា បរិណាយិកា វិប-
ស្សនា សម្បជញ្ញំ បតោទោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញា-
ពលំ បញ្ញាសត្ថំ បញ្ញាចាសាទោ បញ្ញាអាលោកោ
បញ្ញាឱភាសោ បញ្ញាបជ្ជោតោ បញ្ញារតនំ អមោហោ
ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ ទុក្ខេ ញាណំ ។

[២៦៧] ទុក្ខសមុទយំ អារព្ភ ។ បេ ។ ទុក្ខនិ-
រោធំ អារព្ភ ។ បេ ។ ទុក្ខនិរោធគាមិនឹ បដិបទំ
អារព្ភ យា ឧប្បជ្ជតិ បញ្ញា បជាននា ។ បេ ។
អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ ទុក្ខនិ-
រោធគាមិនិយា បដិបទាយ ញាណំ តំញាតដ្ឋេន
ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ ទុក្ខេ ញាណំ
ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខ-
និរោធគាមិនិយា បដិបទាយ ញាណំ ។

[២៦៨] កថំ អត្ថប្បដិសម្ភិទេ ញាណំ ធម្មប្បដិសម្ភិ-
ទេ ញាណំ និរុត្តិប្បដិសម្ភិទេ ញាណំ បដិភាណប្បដិ-
សម្ភិទេ ញាណំ ។ អត្ថេសុ ញាណំ អត្ថប្បដិសម្ភិទា

ភាពជាបុគ្គលមានសេចក្តីភ្លឺច្បាស់ ការគិត សេចក្តីយល់ ធម្មជាតដូចជាផែនដី ធម្មជាតកម្ចាត់កិលេស ធម្មជាតណែនាំ ធម្មជាតឃើញច្បាស់ សេចក្តីដឹងល្អ សភាពដូចជាជន្លួញ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ គ្រឿងសស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា ឱភាសគឺបញ្ញា គ្រឿងផ្ទុះគឺបញ្ញា រតនៈគឺបញ្ញា សេចក្តីមិនវង្វេង ធម្មវិចយៈ សម្មាទិដ្ឋិ ឯណា ប្រារព្ធនូវសេចក្តីទុក្ខ ហើយកើតឡើង នេះលោកហៅថា ទុក្ខញ្ញាណ ។

[២៦៧] បញ្ញា ការដឹងច្បាស់ ។ បេ ។ សេចក្តីមិនវង្វេង ធម្មវិចយៈ សម្មាទិដ្ឋិ ណា ប្រារព្ធនូវទុក្ខសមុទ័យ ។ បេ ។ ប្រារព្ធនូវទុក្ខនិរោធ ។ បេ ។ ប្រារព្ធនូវទុក្ខនិរោធគាមិនីបដិបទា ហើយកើតឡើង នេះលោកហៅថា ទុក្ខនិរោធគាមិនីបដិបទាញាណ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាប្រាជ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌នោះ ហេតុនោះ លោកពោលថា ទុក្ខញ្ញាណ ទុក្ខសមុទយញ្ញាណ ទុក្ខនិរោធញ្ញាណ ទុក្ខនិរោធគាមិនីបដិបទាញាណ ។

[២៦៨] អត្ថប្បដិសម្ភិទាញាណ ធម្មប្បដិសម្ភិទាញាណ និរុត្តិប្បដិសម្ភិទាញាណ បដិភាណប្បដិសម្ភិទាញាណ តើដូចម្តេច ។ ញាណ ក្នុងអត្ថទាំងឡាយ ឈ្មោះថាអត្ថប្បដិសម្ភិទាញាណ ញាណក្នុងធម៌ទាំងឡាយ

២៦៩



ធម្មេសុ ញាណំ ធម្មប្បដិសម្ភិទា និរុត្តីសុ ញាណំ និរុត្តិប្បដិសម្ភិទា បដិភាណេសុ ញាណំ បដិភាណប្បដិសម្ភិទា អត្ថនានត្តេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ធម្មនានត្តេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ និរុត្តិនានត្តេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ បដិភាណនានត្តេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ អត្ថវវត្ថានេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ធម្មវវត្ថានេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ និរុត្តិវវត្ថានេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ បដិភាណវវត្ថានេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ អត្ថសល្លក្ខណេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ធម្មសល្លក្ខណេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ និរុត្តិសល្លក្ខណេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ បដិភាណសល្លក្ខណេ បញ្ញា

ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ញាណក្នុងនិរុត្តិទាំងឡាយ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ញាណក្នុងបដិភាណ ឈ្មោះថាបដិភាណ-ប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងអត្ថផ្សេង ៗ ឈ្មោះថាអត្ថប្បដិសម្ភិ-ទាញាណ ប្រាជ្ញា ក្នុងធម៌ផ្សេង ៗ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងនិរុត្តិផ្សេង ៗ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងបដិភាណផ្សេង ៗ ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការស្ទង់នូវអត្ថ ឈ្មោះថាអត្ថប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការស្ទង់នូវធម៌ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការស្ទង់នូវនិរុត្តិ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការស្ទង់នូវបដិភាណ ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការកំណត់នូវអត្ថ ឈ្មោះថាអត្ថប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការកំណត់នូវធម៌ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការកំណត់នូវនិរុត្តិ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការកំណត់នូវបដិភាណ ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការកត់សម្គាល់នូវអត្ថ ឈ្មោះថាអត្ថប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការកត់សម្គាល់នូវធម៌ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការកត់សម្គាល់នូវនិរុត្តិ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការកត់សម្គាល់នូវបដិភាណ

បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ អត្ថឧបលក្ខណេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ធម្មឧបលក្ខណេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ និរុត្តិឧបលក្ខណេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ បដិភាណឧបល-ក្ខណេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ អត្ថ-ប្បភេទេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ធម្មប្ប-ភេទេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ និរុត្តិប្បភេទេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ បដិភាណប្បភេទេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ អត្ថប្បភា-វនេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ធម្មប្បភាវនេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ និរុត្តិប្បភាវនេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ បដិភាណប្បភាវនេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ អត្ថជ្ជោតនេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ធម្មជ្ជោតនេ បញ្ញា ធម្មប្ប-បដិសម្ភិទេ ញាណំ និរុត្តិជ្ជោតនេ បញ្ញា និរុត្តិប្បដិ-សម្ភិទេ ញាណំ បដិភាណជ្ជោតនេ បញ្ញា បដិ-ភាណប្បដិសម្ភិទេ ញាណំ អត្ថវិរោចនេ បញ្ញា

ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការបែកធ្លាយអត្ថ ឈ្មោះថាអត្ថប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការបែកធ្លាយធម៌ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការបែកធ្លាយនិរុត្តិ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការបែកធ្លាយបដិភាណ ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការបង្កើតនូវអត្ថ ឈ្មោះថាអត្ថប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការបង្កើតនូវធម៌ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការបង្កើតនូវនិរុត្តិ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការបង្កើតនូវបដិភាណ ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការធ្វើឲ្យភ្លឺនូវអត្ថ ឈ្មោះថាអត្ថប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការធ្វើឲ្យភ្លឺនូវធម៌ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការធ្វើឲ្យភ្លឺនូវនិរុត្តិ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការធ្វើឲ្យភ្លឺនូវបដិភាណ ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការធ្វើអត្ថឲ្យភ្លឺរុងរឿង ឈ្មោះថា

អត្ថប្បដិសម្ភិទេ ញាណំ ធម្មវិរោចនេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ និរុត្តិវិរោចនេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ បដិភាណវិរោចនេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ អត្ថប្បកាសនេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ ធម្មប្បកាសនេ បញ្ញា ធម្មប្បដិសម្ភិទេ ញាណំ និរុត្តិប្បកាសនេ បញ្ញា និរុត្តិប្បដិសម្ភិទេ ញាណំ បដិភាណប្បកាសនេ បញ្ញា បដិភាណប្បដិសម្ភិទេ ញាណំ តំញាតដ្ឋេន ញាណំ បជាននដ្ឋេន បញ្ញា តេន វុច្ចតិ អត្ថប្បដិសម្ភិទេ ញាណំ ធម្មប្បដិសម្ភិទេ ញាណំ និរុត្តិប្បដិសម្ភិទេ ញាណំ បដិភាណប្បដិសម្ភិទេ ញាណំ ។

[២៦៩] កតមំ តថាគតស្ស ឥន្ទ្រិយានំ បរោបរិយត្តេ ញាណំ[១] ។ ឥធ តថាគតោ សត្តេ បស្សតិ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ អប្បេកច្ចេ ន បរលោកវជ្ជភយទស្សាវិនោ[២] ។

១ ឱ. ម. ឥន្ទ្រិយបរោបរិយត្តេ ញាណំ ។ ២ ម. បរលោកវជ្ជភយទស្សាវិនេ ។

អត្ថប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការធ្វើធម៌ឲ្យភ្លឺរុងរឿង ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការធ្វើនិរុត្តិឲ្យភ្លឺរុងរឿង ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការធ្វើបដិភាណឲ្យភ្លឺរុងរឿង ឈ្មោះថាបដិភាណប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការប្រកាសនូវអត្ថ ឈ្មោះថាអត្ថប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការប្រកាសនូវធម៌ ឈ្មោះថាធម្មប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការប្រកាសនូវនិរុត្តិ ឈ្មោះថានិរុត្តិប្បដិសម្ភិទាញាណ ប្រាជ្ញា ក្នុងការប្រកាសនូវបដិភាណ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ ឈ្មោះថាញាណ ដោយអត្ថថាដឹងនូវធម៌នោះ ឈ្មោះថាប្រាជ្ញា ដោយអត្ថថាដឹងច្បាស់នូវធម៌ ហេតុនោះ លោកពោលថា អត្ថប្បដិសម្ភិទាញាណ ធម្មប្បដិសម្ភិទាញាណ និរុត្តិប្បដិសម្ភិទាញាណ បដិភាណប្បដិសម្ភិទាញាណ ។

[២៦៩] ឥន្ទ្រិយបរោបរិយត្តញ្ញាណ របស់តថាគត តើដូចម្តេច ។ ព្រះតថាគតទ្រង់ឃើញពួកសត្វក្នុងលោកនេះ ដែលមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយចាស់ក្លា មានឥន្ទ្រិយទន់ មានអាការល្អ មានអាការអាក្រក់ ជាសត្វគួរឲ្យត្រាស់ដឹងបានដោយងាយ ឲ្យត្រាស់ដឹងបានដោយក្រ សត្វពួកខ្លះ ឃើញបរលោកនិងទោសមានរាគៈជាដើមថាជាភ័យ សត្វពួកខ្លះ មិនឃើញបរលោកនិងទោសមានរាគៈជាដើមថាជាភ័យឡើយ (ញាណបែបនេះ ឈ្មោះថាឥន្ទ្រិយបរោបរិយត្តញ្ញាណរបស់ព្រះតថាគត) ។

[២៧០] អប្បរជក្ខេ មហារជក្ខេតិ សទ្ធោ បុគ្គលោ អប្បរជក្ខោ អស្សទ្ធោ បុគ្គលោ មហារជក្ខោ អារ-ទ្ធវីរិយោ បុគ្គលោ អប្បរជក្ខោ កុសីតោ បុគ្គលោ មហារជក្ខោ ឧបដ្ឋិតស្សតិ បុគ្គលោ អប្បរជក្ខោ មុដ្ឋស្សតិ បុគ្គលោ មហារជក្ខោ សមាហិតោ បុគ្គលោ អប្បរជក្ខោ អសមាហិតោ បុគ្គលោ មហារជក្ខោ បញ្ញវា បុគ្គលោ អប្បរជក្ខោ ទុប្បញ្ញោ បុគ្គលោ មហារជក្ខោ ។

[២៧១] តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេតិ សទ្ធោ បុគ្គលោ តិក្ខិន្ទ្រិយោ អស្សទ្ធោ បុគ្គលោ មុទិន្ទ្រិយោ អារទ្ធ-វីរិយោ បុគ្គលោ តិក្ខិន្ទ្រិយោ កុសីតោ បុគ្គលោ មុទិន្ទ្រិយោ ឧបដ្ឋិតស្សតិ បុគ្គលោ តិក្ខិន្ទ្រិយោ មុដ្ឋស្សតិ បុគ្គលោ មុទិន្ទ្រិយោ សមាហិតោ

[២៧០] ត្រង់ពាក្យថា មានធូលីតិច ក្នុងភ្នែក មានធូលីច្រើន ក្នុងភ្នែក គឺ បុគ្គលដែលមានសទ្ធា ឈ្មោះថាអ្នកមានធូលីតិច ក្នុងភ្នែក បុគ្គលដែលឥតសទ្ធា ឈ្មោះថាអ្នកមានធូលីច្រើន ក្នុងភ្នែក បុគ្គលដែលមានព្យាយាមប្រារព្ធហើយ ឈ្មោះថាអ្នកមានធូលីតិច ក្នុងភ្នែក បុគ្គលដែលខ្ជិលច្រអូស ឈ្មោះថាអ្នកមានធូលីច្រើន ក្នុងភ្នែក បុគ្គលដែលមានស្មារតីតម្កល់មាំ ឈ្មោះថាអ្នកមានធូលីតិច ក្នុងភ្នែក បុគ្គលដែលភ្លេចស្មារតី ឈ្មោះថា អ្នកមានធូលីច្រើនក្នុងភ្នែក បុគ្គលដែលមានចិត្តតម្កល់មាំ ឈ្មោះថាអ្នកមានធូលីតិច ក្នុងភ្នែក បុគ្គលដែលមានចិត្តមិនតម្កល់មាំ ឈ្មោះថាអ្នកមានធូលីច្រើន ក្នុងភ្នែក បុគ្គលដែលមានប្រាជ្ញា ឈ្មោះថាអ្នកមានធូលីតិច ក្នុងភ្នែក បុគ្គលដែលឥតប្រាជ្ញា ឈ្មោះថាអ្នកមានធូលីច្រើនក្នុងភ្នែក ។

[២៧១] ត្រង់ពាក្យថា មានឥន្ទ្រិយចាស់ក្លា មានឥន្ទ្រិយទន់ គឺបុគ្គលដែលមានសទ្ធា ឈ្មោះថាអ្នកមានឥន្ទ្រិយចាស់ក្លា បុគ្គលដែលឥតសទ្ធា ឈ្មោះថា អ្នកមានឥន្ទ្រិយទន់ បុគ្គលដែលមានព្យាយាមប្រារព្ធហើយ ឈ្មោះថាអ្នកមានឥន្ទ្រិយចាស់ក្លា បុគ្គលដែលខ្ជិលច្រអូស ឈ្មោះថាអ្នកមានឥន្ទ្រិយទន់ បុគ្គលដែលមានស្មារតីតម្កល់មាំ ឈ្មោះថាអ្នកមានឥន្ទ្រិយចាស់ក្លា បុគ្គលដែលភ្លេចស្មារតី ឈ្មោះថាអ្នកមានឥន្ទ្រិយទន់

បុគ្គលោ តិក្ខិន្ទ្រិយោ អសមាហិតោ បុគ្គលោ មុទិ-
ន្ទ្រិយោ បញ្ញវា បុគ្គលោ តិក្ខិន្ទ្រិយោ ទុប្បញ្ញោ
បុគ្គលោ មុទិន្ទ្រិយោ ។

[២៧២] ស្វាការេ ទ្វាការេតិ សទ្ធោ បុគ្គលោ
ស្វាកាលោ អស្សទ្ធោ បុគ្គលោ ទ្វាកាលោ អារទ្ធវីរិ-
យោ បុគ្គលោ ស្វាកាលោ កុសីតោ បុគ្គលោ ទ្វា-
កាលោ ឧបដ្ឋិតស្សតិ បុគ្គលោ ស្វាកាលោ មុដ្ឋស្សតិ
បុគ្គលោ ទ្វាកាលោ សមាហិតោ បុគ្គលោ ស្វា-
កាលោ អសមាហិតោ បុគ្គលោ ទ្វាកាលោ បញ្ញវា
បុគ្គលោ ស្វាកាលោ ទុប្បញ្ញោ បុគ្គលោ ទ្វាកាលោ ។

[២៧៣] សុវិញ្ញាបយេ ទុវិញ្ញាបយេតិ សទ្ធោ បុគ្គ-
លោ សុវិញ្ញាបយោ អស្សទ្ធោ បុគ្គលោ ទុវិញ្ញាបយោ

បុគ្គលដែលមានចិត្តតម្កល់មាំ ឈ្មោះថាអ្នកមានឥន្ទ្រិយចាស់ក្លា បុគ្គលដែលមានចិត្តមិនតម្កល់មាំ ឈ្មោះថាអ្នកមានឥន្ទ្រិយទន់ បុគ្គលដែលមានប្រាជ្ញា ឈ្មោះថាអ្នកមានឥន្ទ្រិយចាស់ក្លា បុគ្គលដែលឥតប្រាជ្ញា ឈ្មោះថាអ្នកមានឥន្ទ្រិយទន់ ។

[២៧២] ត្រង់ពាក្យថា មានអាការល្អ មានអាការអាក្រក់ គឺបុគ្គលដែលមានសទ្ធា ឈ្មោះថាអ្នកមានអាការល្អ បុគ្គលដែលឥតសទ្ធា ឈ្មោះថាអ្នកមានអាការអាក្រក់ បុគ្គលដែលមានព្យាយាមប្រារព្ធហើយ ឈ្មោះថាអ្នកមានអាការល្អ បុគ្គលដែលខ្ជិលច្រអូស ឈ្មោះថាអ្នកមានអាការអាក្រក់ បុគ្គលដែលមានស្មារតីតម្កល់មាំ ឈ្មោះថាអ្នកមានអាការល្អ បុគ្គលដែលភ្លេចស្មារតី ឈ្មោះថាអ្នកមានអាការអាក្រក់ បុគ្គលដែលមានចិត្តតម្កល់មាំ ឈ្មោះថាអ្នកមានអាការល្អ បុគ្គលដែលមានចិត្តមិនតម្កល់មាំ ឈ្មោះថាអ្នកមានអាការអាក្រក់ បុគ្គលដែលមានប្រាជ្ញា ឈ្មោះថាអ្នកមានអាការល្អ បុគ្គលដែលឥតប្រាជ្ញា ឈ្មោះថាអ្នកមានអាការអាក្រក់ ។

[២៧៣] ពាក្យថា គួរឲ្យត្រាស់ដឹងបានដោយងាយ គួរឲ្យត្រាស់ដឹងបានដោយក្រ គឺបុគ្គលដែលមានសទ្ធា ឈ្មោះថាអ្នកគួរឲ្យត្រាស់ដឹងបានដោយងាយ បុគ្គលដែលឥតសទ្ធា ឈ្មោះថាអ្នកគួរឲ្យត្រាស់ដឹង

អារទ្ធវីរិយោ បុគ្គលោ សុវិញ្ញាបយោ កុសីតោ បុគ្គ-
លោ ទុវិញ្ញាបយោ ឧបដ្ឋិតស្សតិ បុគ្គលោ សុវិ-
ញ្ញាបយោ មុដ្ឋស្សតិ បុគ្គលោ ទុវិញ្ញាបយោ សមា-
ហិតោ បុគ្គលោ សុវិញ្ញាបយោ អសមាហិតោ បុគ្គ-
លោ ទុវិញ្ញាបយោ បញ្ញវា បុគ្គលោ សុវិញ្ញាបយោ
ទុប្បញ្ញោ បុគ្គលោ ទុវិញ្ញាបយោ ។

[២៧៤] អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ
អប្បេកច្ចេ នបរលោកវជ្ជភយទស្សាវិនោតិ សទ្ធោ
បុគ្គលោ បរលោកវជ្ជភយទស្សាវី អស្សទ្ធោ
បុគ្គលោ នបរលោកវជ្ជភយទស្សាវី អារទ្ធវីរិយោ
បុគ្គលោ បរលោកវជ្ជភយទស្សាវី កុសីតោ បុគ្គ-
លោ នបរលោកវជ្ជភយទស្សាវី ឧបដ្ឋិតស្សតិ

បានដោយក្រ បុគ្គលដែលមានព្យាយាមប្រារព្ធហើយ ឈ្មោះថាអ្នកគួរឲ្យត្រាស់ដឹងបានដោយងាយ បុគ្គលដែលខ្ជិលច្រអូស ឈ្មោះថាអ្នកគួរឲ្យត្រាស់ដឹងបានដោយក្រ បុគ្គលដែលមានស្មារតីតម្កល់មាំ ឈ្មោះថាអ្នកគួរឲ្យត្រាស់ដឹងបានដោយងាយ បុគ្គលដែលភ្លេចស្មារតី ឈ្មោះថាអ្នកគួរឲ្យត្រាស់ដឹងបានដោយក្រ បុគ្គលដែលមានចិត្តតម្កល់មាំ ឈ្មោះថាអ្នកគួរឲ្យត្រាស់ដឹងបានដោយងាយ បុគ្គលដែលមានចិត្តមិនតម្កល់មាំ ឈ្មោះថាអ្នកគួរឲ្យត្រាស់ដឹងបានដោយក្រ បុគ្គលដែលមានប្រាជ្ញា ឈ្មោះថាអ្នកគួរឲ្យត្រាស់ដឹងបានដោយងាយ បុគ្គលដែលឥតប្រាជ្ញា ឈ្មោះថាអ្នកគួរឲ្យត្រាស់ដឹងបានដោយក្រ ។

[២៧៤] ពាក្យថា សត្វពួកខ្លះ ឃើញបរលោកនិងទោស មានរាគៈជាដើមថាជាភ័យ សត្វពួកខ្លះ មិនឃើញបរលោកនិងទោស មានរាគៈជាដើមថាជាភ័យ សេចក្តីថា បុគ្គលដែលមានសទ្ធា ឈ្មោះថាអ្នកឃើញបរលោកនិងទោសមានរាគៈជាដើមថាជាភ័យ បុគ្គលដែលឥតសទ្ធា ឈ្មោះថាអ្នកមិនឃើញនូវបរលោកនិងទោស មានរាគៈជាដើមថាជាភ័យ បុគ្គលដែលមានព្យាយាមប្រារព្ធហើយ ឈ្មោះថាអ្នកឃើញនូវបរលោកនិងទោស មានរាគៈជាដើមថាជាភ័យ បុគ្គលដែលខ្ជិលច្រអូស ឈ្មោះថាអ្នកមិនឃើញ នូវបរលោកនិងទោស មានរាគៈជាដើមថាជាភ័យ

បុគ្គលោ បរលោកវជ្ជភយទស្សាវី មុដ្ឋស្សតិ បុគ្គលោ នបរលោកវជ្ជភយទស្សាវី សមាហិតោ បុគ្គលោ បរលោកវជ្ជភយទស្សាវី អសមាហិតោ បុគ្គលោ នបរលោកវជ្ជភយទស្សាវី បញ្ញវា បុគ្គលោ បរលោកវជ្ជភយទស្សាវី ទុប្បញ្ញោ បុគ្គលោ នបរលោកវជ្ជភយទស្សាវី ។

[២៧៤] លោកោតិ ខន្ធលោកោ ធាតុលោកោ អាយតនលោកោ វិបត្តិភវលោកោ វិបត្តិសម្ភវលោកោ សម្បត្តិភវលោកោ សម្បត្តិសម្ភវលោកោ ឯកោ លោកោ សព្វេ សត្តា អាហារដ្ឋិតិកា ទ្វេ លោកា នាមញ្ច រូបញ្ច តយោ លោកា តិស្សោ វេទនា ចត្តារោ លោកា ចត្តារោ អាហារា បញ្ច លោកា បញ្ចុបាទានក្ខន្ធា ឆ លោកា ឆ អជ្ឈត្តិកានិ អាយតនានិ សត្ត លោកា សត្ត វិញ្ញាណដ្ឋិ-

បុគ្គលដែលមានស្មារតីតម្កល់មាំ ឈ្មោះថាអ្នកឃើញនូវបរលោកនិងទោសមានរាគៈជាដើមថាជាភ័យ បុគ្គលដែលភ្លេចស្មារតី ឈ្មោះថាអ្នកមិនឃើញនូវបរលោកនិងទោសមានរាគៈជាដើមថាជាភ័យ បុគ្គលដែលមានចិត្តតម្កល់មាំ ឈ្មោះថាអ្នកឃើញនូវបរលោកនិងទោសមានរាគៈជាដើមថាជាភ័យ បុគ្គលដែលមានចិត្តមិនតម្កល់មាំ ឈ្មោះថាអ្នកមិនឃើញនូវបរលោកនិងទោស មានរាគៈជាដើមថាជាភ័យ បុគ្គលដែលមានប្រាជ្ញា ឈ្មោះថា អ្នកឃើញនូវបរលោកនិងទោស មានរាគៈជាដើមថាជាភ័យ បុគ្គលដែលឥតប្រាជ្ញា ឈ្មោះថាអ្នកមិនឃើញនូវបរលោកនិងទោសមានរាគៈជាដើមថាជាភ័យ ។

[២៧៥] ពាក្យថា លោក បានដល់ខន្ធលោក ធាតុលោក អាយតនលោក វិបត្តិភវលោក គឺអបាយលោក វិបត្តិសម្ភវលោក គឺអកុសលកម្មដែលនាំទៅកើតក្នុងអបាយ សម្បត្តិភវលោក គឺសុគតិលោក សម្បត្តិសម្ភវលោក គឺកុសលកម្មដែលនាំទៅកើតក្នុងសុគតិលោក លោក ១ បានដល់ពួកសត្វទាំងអស់ដែលតាំងនៅបានដោយអាហារ លោក ២ បានដល់នាម ១ រូប ១ លោក ៣ បានដល់វេទនា ៣ លោក ៤ បានដល់អាហារ ៤ លោក ៥ បានដល់ឧបាទានក្ខន្ធ ៥ លោក ៦ បានដល់អាយតនៈខាងក្នុង ៦ លោក ៧ បានដល់ទីតាំងនៃវិញ្ញាណ ៧

តិយោ អដ្ឋ លោកា អដ្ឋ លោកធម្មា នវ លោកា នវ សត្តាវាសា ទស លោកា ទសាយតនានិ ទ្វាទស លោកា ទ្វាទសាយតនានិ អដ្ឋារស លោកា អដ្ឋារស ធាតុយោ ។

[២៧៦] វជ្ជន្តិ សព្វេ កិលេសា វជ្ជា សព្វេ ទុច្ចរិតា វជ្ជា សព្វេ អភិសង្ខារា វជ្ជា សព្វេ ភវគ្គាមិកម្មា វជ្ជា ឥតិ ឥមស្មឹ ច លោកេ ឥមស្មឹ ច វជ្ជេ តិព្វា ភយសញ្ញា បច្ចុបដ្ឋិតា ហោតិ សេយ្យថាបិ ឧក្ខិត្តាសិកេ វធកេ ឥមេហិ បញ្ញាសាយ អាការេហិ ឥមានិ បញ្ចិន្ទ្រិយានិ ជានាតិ បស្សតិ អញ្ញាតិ បដិវិជ្ឈតិ ឥទំ តថាគតស្ស ឥន្ទ្រិយានំ បរោបរិយត្តេ ញាណំ ។

[២៧៧] កតមំ តថាគតស្ស សត្តានំ អាសយានុសយេ ញាណំ ។ ឥធ តថាគតោ សត្តានំ អាសយំ ជានាតិ អនុសយំ ជានាតិ ចរិតំ ជានាតិ អធិមុត្តឹ ជានាតិ ភព្វាភព្វេ សត្តេ បជានាតិ ។

[២៧៨] កតមោ ច សត្តានំ អាសយោ ។

លោក ៨ បានដល់លោកធម៌ ៨ លោក ៩ បានដល់ទីនៅរបស់សត្វ ៩ លោក ១០ បានដល់អាយតនៈទាំង ១០ លោក ១២ បានដល់អាយតនៈ ១២ លោក ១៨ បានដល់ធាតុ ១៨ ។

[២៧៦] ពាក្យថា ទោស សេចក្តីថា កិលេសទាំងអស់ ឈ្មោះថាទោស ទុច្ចរិតទាំងអស់ ឈ្មោះថាទោស អភិសង្ខារទាំងអស់ ឈ្មោះថាទោស ភវគាមិកម្មទាំងអស់ ឈ្មោះថាទោស សេចក្តីសម្គាល់ថាភ័យដ៏ក្លៀវក្លា រមែងប្រាកដក្នុងលោកនេះផង ក្នុងទោសនេះផង ដោយការយល់ឃើញយ៉ាងនេះឯង ប្រៀបដូចពេជ្ឈឃាដលើកនូវដាវ (ប្រុងនឹងប្រហារ) ព្រះតថាគតទ្រង់ជ្រាប ឃើញ យល់ ចាក់ធ្លុះ នូវឥន្ទ្រិយទាំង ៥ នេះ ដោយអាការទាំង ៥០ នេះ នេះឯង ឈ្មោះថាឥន្ទ្រិយ-បរោបរិយត្តិញ្ញាណ របស់ព្រះតថាគត ។

[២៧៧] សត្តាសយានុសយញ្ញាណ របស់ព្រះតថាគត តើដូចម្តេច ។ ព្រះតថាគតជ្រាបនូវអាសយធម៌ ជ្រាបនូវអនុសយធម៌ ជ្រាបនូវចរិត ជ្រាបនូវអធ្យាស្រ័យរបស់សត្វទាំងឡាយ ជ្រាបនូវពួកសត្វដែលមានភ័ព្វនិងឥតភ័ព្វ ក្នុងលោកនេះ (ញាណបែបនេះ ឈ្មោះថាសត្តាសយានុសយញ្ញាណ របស់ព្រះតថាគត) ។

[២៧៨] អាសយធម៌ របស់ពួកសត្វ តើដូចម្តេច ។

២៧៧



សស្សតោ លោកោតិ វា អសស្សតោ លោកោតិ វា អន្តវា លោកោតិ វា អនន្តវា លោកោតិ វា តំ ជីវំ តំ សរីរន្តិ វា អញ្ញំ ជីវំ អញ្ញំ សរីរន្តិ វា ហោតិ តថាគតោ បរម្មរណាតិ វា ន ហោតិ តថាគតោ បរម្មរណាតិ វា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ វា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មណាតិ វា ឥតិ ភវទិដ្ឋិសន្និស្សិតា វា សត្តា ហោន្តិ វិភវទិដ្ឋិសន្និស្សិតា វា ឯតេ វា បន ឧភោ អន្តេ អនុបគម្ម ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អនុលោមិកា ខន្តិ បដិលទ្ធា ហោតិ យថា-ភូតំ វា ញាណំ កាមំ សេវន្តញ្ញេវ ជានាតិ អយំ បុគ្គលោ កាមគរុកោ កាមាសយោ កាមាធិមុត្តោ-តិ កាមំ[១] សេវន្តញ្ញេវ ជានាតិ អយំ បុគ្គលោ នេក្ខម្មគរុកោ នេក្ខម្មាសយោ នេក្ខម្មាធិមុត្តោតិ នេក្ខម្មំ សេវន្តញ្ញេវ ជានាតិ អយំ បុគ្គលោ ព្យាបាទគរុកោ ព្យាបាទាសយោ ព្យាបាទាធិមុត្តោតិ

១ ឱ. កាយំ ។

ពួកសត្វដែលអាស្រ័យនូវភវទិដ្ឋិក្តី អាស្រ័យនូវវិភវទិដ្ឋិក្តីថា លោកទៀងឬថាលោកមិនទៀង ថាលោកមានទីបំផុត ថាលោកមិនមានទីបំផុត ថានោះជាជីវៈ នោះជាសរីរៈ ថាជីវៈដទៃ សរីរៈដទៃ ថាសត្វស្លាប់ទៅកើតទៀត ថាសត្វស្លាប់ទៅមិនកើតទៀត ថាសត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មាន ឬថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន មួយទៀត អនុលោមិកខន្តី ក្នុងធម៌ទាំងឡាយដែលកើតឡើងព្រោះអាស្រ័យនូវធម៌នេះជាបច្ច័យ សត្វតែងបានព្រោះមិនអាស្រ័យនូវអន្តធម៌ទាំងពីរនេះ មួយវិញទៀត យថាភូតញ្ញាណ រមែងដឹងនូវបុគ្គលអ្នកសេពកាម គឺដឹងនូវបុគ្គលអ្នកសេពកាមថា បុគ្គលនេះ ធ្ងន់ក្នុងកាម ដេកត្រាំក្នុងកាម ចុះចិត្តស៊ប់ក្នុងកាម ដឹងនូវបុគ្គលអ្នកសេពនូវនេក្ខម្មៈថា បុគ្គលនេះ ធ្ងន់ក្នុងនេក្ខម្មៈ ដេកត្រាំក្នុងនេក្ខម្មៈ ចុះចិត្តស៊ប់ក្នុងនេក្ខម្មៈ ដឹងនូវបុគ្គលអ្នកសេពនូវព្យាបាទថា បុគ្គលនេះ ធ្ងន់ក្នុងព្យាបាទ ដេកត្រាំក្នុងព្យាបាទ

ព្យាទាធំ សេវន្តញ្ញេវ ជាជាតិ អយំ បុគ្គលោ អព្យា-
ចាទគរុកោ អព្យាចាទាសយោ អព្យាចាទាធិមុត្តោតិ
អព្យាចាធំ សេវន្តញ្ញេវ ជាជាតិ អយំ បុគ្គលោ
ថីនមិទ្ធគរុកោ ថីនមិទ្ធាសយោ ថីនមិទ្ធាធិមុត្តោតិ
ថីនមិទ្ធំ សេវន្តញ្ញេវ ជាជាតិ អយំ បុគ្គលោ អា-
លោកសញ្ញាគរុកោ អាលោកសញ្ញាសយោ អា-
លោកសញ្ញាធិមុត្តោតិ អាលោកសញ្ញំ សេវន្តញ្ញេវ
ជាជាតិ អយំ សត្តានំ អាសយោ ។

[២៧៩] កតមោ ច សត្តានំ អនុសយោ ។
សត្តានុសយា កាមរាគានុសយោ បដិឃានុសយោ
មានានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ ភវ-
រាគានុសយោ អវិជ្ជានុសយោ យំ លោកេ បិយរូបំ
សាតរូបំ ឯត្ថ សត្តានំ កាមរាគានុសយោ អនុសេតិ
យំ លោកេ អប្បិយរូបំ អសាតរូបំ ឯត្ថ សត្តានំ
បដិឃានុសយោ អនុសេតិ ឥតិ ឥមេសុ ទ្វីសុ ធម្មេ-
សុ អវិជ្ជា អនុបតិតា តទេកដ្ឋោ មានោ ច ទិដ្ឋិ ច
វិចិកិច្ឆា ច ទដ្ឋព្វា អយំ សត្តានំ អនុសយោ ។

ចុះចិត្តស៊ប់ក្នុងព្យាបាទ ដឹងនូវបុគ្គលអ្នកសេពនូវអព្យាបាទថា បុគ្គលនេះ ធ្ងន់ក្នុងអព្យាបាទ ដេកត្រាំក្នុងអព្យាបាទ ចុះចិត្តស៊ប់ ក្នុងអព្យាបាទ ដឹងនូវបុគ្គលអ្នកសេពនូវថីនមិទ្ធៈថា បុគ្គលនេះ ធ្ងន់ក្នុងថីនមិទ្ធៈ ដេកត្រាំក្នុងថីនមិទ្ធៈ ចុះចិត្តស៊ប់ក្នុងថីនមិទ្ធៈ ដឹងនូវបុគ្គលអ្នកសេពនូវអាលោកសញ្ញាថា បុគ្គលនេះ ធ្ងន់ក្នុងអាលោកសញ្ញា ដេកត្រាំក្នុងអាលោកសញ្ញា ចុះចិត្តស៊ប់ក្នុងអាលោកសញ្ញា នេះឈ្មោះថាអាសយធម៌ របស់ពួកសត្វ ។

[២៧៩] អនុសយធម៌របស់សត្វ តើដូចម្តេច ។ អនុសយធម៌ ៧ គឺ កាមរាគានុស័យ ១ បដិឃានុស័យ ១ មានានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ ភវរាគានុស័យ ១ អវិជ្ជានុស័យ ១ អារម្មណ៍ណាមានសភាពគួរស្រឡាញ់ គួរត្រេកអរក្នុងលោក កាមរាគានុស័យរបស់ពួកសត្វ រមែងដេកត្រាំ ក្នុងអារម្មណ៍នោះ អារម្មណ៍ណាមានសភាពមិនគួរស្រឡាញ់ មិនគួរត្រេកអរក្នុងលោក បដិឃានុស័យរបស់ពួកសត្វ រមែងដេកត្រាំក្នុងអារម្មណ៍នោះ អវិជ្ជាតែងជាប់តាមក្នុងធម៌ទាំងពីរនេះ ឯមានះ ទិដ្ឋិនិងវិចិកិច្ឆា ដែលឋិតនៅជាមួយនឹងអវិជ្ជានោះ អ្នកប្រាជ្ញគប្បីយល់តាមន័យដូចបានពោលមកនេះឯង នេះឈ្មោះថាអនុសយធម៌ របស់ពួកសត្វ ។

[២៨០] កតមញ្ច សត្តានំ ចរិតំ ។ បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារោ អនេញ្ជាភិសង្ខារោ បរិត្តភូមកោ វា មហាភូមកោ វា ឥទំ សត្តានំ ចរិតំ ។

[២៨១] កតមា ច សត្តានំ អធិមុត្តិ ។ សន្តិ សត្តា ហីនាធិមុត្តិកា សន្តិ សត្តា បណីតាធិមុត្តិកា ហីនាធិមុត្តិកា សត្តា ហីនាធិមុត្តិកេ សត្តេ សេវន្តិ ភជន្តិ បយិរុបាសន្តិ បណីតាធិមុត្តិកា សត្តា បណីតាធិមុត្តិកេ សត្តេ សេវន្តិ ភជន្តិ បយិរុបាសន្តិ អតីតម្បិ អទ្ធានំ ហីនាធិមុត្តិកា សត្តា ហីនាធិមុត្តិកេ សត្តេ សេវឹសុ ភជឹសុ បយិរុបាសឹសុ បណីតាធិមុត្តិកា សត្តា បណីតាធិមុត្តិកេ សត្តេ សេវឹសុ ភជឹសុ បយិរុបាសឹសុ អនាគតម្បិ អទ្ធានំ ហីនាធិមុត្តិកា សត្តា ហីនាធិមុត្តិកេ សត្តេ សេវិស្សន្តិ ភជិស្សន្តិ បយិរុបាសិស្សន្តិ បណីតាធិមុត្តិកា សត្តា បណីតាធិមុត្តិកេ សត្តេ សេវិស្សន្តិ ភជិស្សន្តិ បយិ-

[២៨០] ចរិតរបស់ពួកសត្វ តើដូចម្តេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អនេញ្ជាភិសង្ខារ ដែលជាភូមិតូច ឬភូមិធំ នេះឈ្មោះថាចរិតរបស់ពួកសត្វ ។

[២៨១] អធ្យាស្រ័យរបស់ពួកសត្វ តើដូចម្តេច ។ ពួកសត្វដែលមានអធ្យាស្រ័យថោកទាបក៏មាន ពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ក៏មាន ពួកសត្វដែលមានអធ្យាស្រ័យថោកទាប រមែងគប់រក សេពគប់ចូលទៅអង្គុយជិត នូវពួកសត្វដែលមានអធ្យាស្រ័យថោកទាប (ដូចគ្នា) ពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ រមែងគប់រក សេពគប់ ចូលទៅអង្គុយជិត នូវពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ (ដូចគ្នា) សូម្បីក្នុងកាលកន្លងទៅហើយ ពួកសត្វដែលមានអធ្យាស្រ័យថោកទាប គប់រកហើយ សេពគប់ហើយ ចូលទៅអង្គុយជិតហើយ នូវពួកសត្វដែលមានអធ្យាស្រ័យថោកទាប (ដូចគ្នា) ពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់គប់រកហើយ សេពគប់ហើយ ចូលទៅអង្គុយជិតហើយ នូវពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ (ដូចគ្នា) សូម្បីក្នុងកាលជាអនាគត ពួកសត្វដែលមានអធ្យាស្រ័យថោកទាប នឹងគប់រក នឹងសេពគប់ នឹងចូលទៅអង្គុយជិត នូវពួកសត្វដែលមានអធ្យាស្រ័យថោកទាប (ដូចគ្នា) ពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ នឹងគប់រក នឹងសេពគប់ នឹងចូលទៅអង្គុយជិត នូវពួកសត្វដែលមានអធ្យាស្រ័យខ្ពង់ខ្ពស់ (ដូចគ្នា)

វុច្ចាសិស្សន្តិ អយំ សត្តានំ អធិមុត្តិ ។

[២៨២] កតមេ សត្តា អភព្វា ។ យេ តេ សត្តា កម្មាវរណេន សមន្នាគតា កិលេសាវរណេន សមន្នាគតា វិបាកាវរណេន សមន្នាគតា អស្សទ្ធា អច្ឆន្ទិកា ទុប្បញ្ញា អភព្វា និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ឥមេ តេ សត្តា អភព្វា ។

[២៨៣] កតមេ សត្តា ភព្វា ។ យេ តេ សត្តា ន កម្មាវរណេន សមន្នាគតា ន កិលេសាវរណេន សមន្នាគតា ន វិបាកាវរណេន សមន្នាគតា សទ្ធា ឆន្ទិកា បញ្ញវន្តោ ភព្វា និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ឥមេ តេ សត្តា ភព្វា ឥទំ តថាគតស្ស សត្តានំ អាសយានុសយេ ញាណំ ។

[២៨៤] កតមំ តថាគតស្ស យមកប្បាដិហិរេ[១] ញាណំ ។ ឥធ តថាគតោ យមកប្បាដិហិរំ ករោតិ អសាធារណំ សាវកេហិ ឧបរិមកាយតោ អគ្គិក្ខន្ធោ បវត្តតិ ហេដ្ឋិមកាយតោ ឧទកធារា បវត្តតិ ហេដ្ឋិមកាយតោ អគ្គិក្ខន្ធោ បវត្តតិ

១ ឱ. យមកប្បាដិហារេ ។

នេះឈ្មោះថាអធ្យាស្រ័យរបស់ពួកសត្វ ។

[២៨២] ពួកសត្វដែលឥតភ័ព្វ តើដូចម្តេច ។ ពួកសត្វណា ដែលប្រកបដោយទំនប់គឺកម្ម ប្រកបដោយទំនប់គឺកិលេស ប្រកបដោយទំនប់គឺវិបាក ជាសត្វមិនមានសទ្ធា មិនមានឆន្ទៈ ឥតប្រាជ្ញា មិនគួរដើម្បីចុះកាន់និយាមៈ (គន្លង) ដែលត្រឹមត្រូវក្នុងកុសលធម៌ទាំងឡាយ ពួកសត្វទាំងនេះ ឈ្មោះថាអ្នកឥតភ័ព្វ ។

[២៨៣] ពួកសត្វដែលមានភ័ព្វ តើដូចម្តេច ។ ពួកសត្វណា ដែលមិនប្រកបដោយទំនប់គឺកម្ម មិនប្រកបដោយទំនប់គឺកិលេស មិនប្រកបដោយទំនប់គឺវិបាក ជាសត្វមានសទ្ធា មានឆន្ទៈ មានប្រាជ្ញា គួរដើម្បីចុះកាន់និយាមៈ (គន្លង) ដែលត្រឹមត្រូវក្នុងកុសលធម៌ទាំងឡាយ ពួកសត្វទាំងនេះ ឈ្មោះថាអ្នកមានភ័ព្វ នេះឈ្មោះថាសត្តាសយានុសយញ្ញាណ របស់ព្រះតថាគត ។

[២៨៤] យមកប្បាដិហិរញ្ញាណ របស់ព្រះតថាគត តើដូចម្តេច ។ ព្រះតថាគតទ្រង់ធ្វើយមកប្បាដិហារ្យ ដែលមិនទូទៅដល់ពួកសាវ័កក្នុងលោកនេះ គឺគំនរភ្លើងចេញអំពីព្រះកាយខាងលើ ផ្ទារទឹកចេញអំពីព្រះកាយខាងក្រោម គំនរភ្លើងចេញអំពីព្រះកាយខាងក្រោម

ឧបរិមកាយតោ ឧទកធារា បវត្តតិ បុរត្ថិមកាយតោ អគ្គិក្ខន្ធោ បវត្តតិ បច្ឆិមកាយតោ ឧទកធារា បវត្តតិ បច្ឆិមកាយតោ អគ្គិក្ខន្ធោ បវត្តតិ បុរត្ថិមកាយតោ ឧទកធារា បវត្តតិ ទក្ខិណអក្ខិតោ អគ្គិក្ខន្ធោ បវត្តតិ វាមអក្ខិតោ ឧទកធារា បវត្តតិ វាមអក្ខិតោ អគ្គិក្ខន្ធោ បវត្តតិ ទក្ខិណអក្ខិតោ ឧទកធារា បវត្តតិ ទក្ខិណកណ្ណសោតតោ អគ្គិក្ខន្ធោ បវត្តតិ វាមកណ្ណសោតតោ ឧទកធារា បវត្តតិ វាមកណ្ណសោតតោ អគ្គិក្ខន្ធោ បវត្តតិ ទក្ខិណកណ្ណសោតតោ ឧទកធារា បវត្តតិ ទក្ខិណនាសិកាសោតតោ អគ្គិក្ខន្ធោ បវត្តតិ វាមនាសិកាសោតតោ ឧទកធារា បវត្តតិ វាមនាសិកាសោតតោ អគ្គិក្ខន្ធោ បវត្តតិ ទក្ខិណនាសិកាសោតតោ ឧទកធារា បវត្តតិ ទក្ខិណអង្សកូដតោ អគ្គិក្ខន្ធោ បវត្តតិ វាមអង្សកូដតោ ឧទកធារា បវត្តតិ វាមអង្សកូដតោ អគ្គិក្ខន្ធោ បវត្តតិ ទក្ខិណអង្សកូដតោ ឧទកធារា

ផ្ការទឹកចេញអំពីព្រះកាយខាងលើ គំនរភ្លើងចេញអំពីព្រះកាយខាងមុខ ផ្ការទឹកចេញអំពីព្រះកាយខាងក្រោយ គំនរភ្លើងចេញអំពីព្រះកាយខាងក្រោយ ផ្ការទឹកចេញអំពីព្រះកាយខាងមុខ គំនរភ្លើងចេញអំពីព្រះនេត្រខាងស្តាំ ផ្ការទឹកចេញអំពីព្រះនេត្រខាងឆ្វេង គំនរភ្លើងចេញអំពីព្រះនេត្រខាងឆ្វេង ផ្ការទឹកចេញអំពីព្រះនេត្រខាងស្តាំ គំនរភ្លើងចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងឆ្វេង គំនរភ្លើងចេញ អំពីរន្ធព្រះកាណ៌ខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះកាណ៌ខាងស្តាំ គំនរភ្លើងចេញអំពីរន្ធព្រះនាសិកាខាងស្តាំ ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង គំនរភ្លើងចេញអំពីរន្ធព្រះនាសិកាខាងឆ្វេង ផ្ការទឹកចេញអំពីរន្ធព្រះនាសិកាខាងស្តាំ គំនរភ្លើងចេញអំពីចង្កួយព្រះអង្សាខាងស្តាំ ផ្ការទឹកចេញអំពីចង្កួយព្រះអង្សាខាងឆ្វេង គំនរភ្លើងចេញអំពីចង្កួយព្រះអង្សាខាងឆ្វេង ផ្ការទឹកចេញអំពីចង្កួយព្រះអង្សាខាងស្តាំ

បវត្តតិ ទក្ខិណហត្ថតោ អគ្គិក្ខន្ធោ បវត្តតិ វាមហត្ថតោ ឧទកធារា បវត្តតិ វាមហត្ថតោ អគ្គិក្ខន្ធោ បវត្តតិ ទក្ខិណហត្ថតោ ឧទកធារា បវត្តតិ ទក្ខិណបស្សតោ អគ្គិក្ខន្ធោ បវត្តតិ វាមបស្សតោ ឧទកធារា បវត្តតិ វាមបស្សតោ អគ្គិក្ខន្ធោ បវត្តតិ ទក្ខិណបស្សតោ ឧទកធារា បវត្តតិ ទក្ខិណបាទតោ អគ្គិក្ខន្ធោ បវត្តតិ វាមបាទតោ ឧទកធារា បវត្តតិ វាមបាទតោ អគ្គិក្ខន្ធោ បវត្តតិ ទក្ខិណបាទតោ ឧទកធារា បវត្តតិ អង្គុលង្គុលេហិ អគ្គិក្ខន្ធោ បវត្តតិ អង្គុលន្តរិកាហិ ឧទកធារា បវត្តតិ អង្គុលន្តរិកាហិ អគ្គិក្ខន្ធោ បវត្តតិ អង្គុលង្គុលេហិ ឧទកធារា បវត្តតិ ឯកេកលោមតោ អគ្គិក្ខន្ធោ បវត្តតិ ឯកេកលោមតោ ឧទកធារា បវត្តតិ លោមកូបតោ លោមកូបតោ អគ្គិក្ខន្ធោ បវត្តតិ លោមកូបតោ លោមកូបតោ ឧទកធារា បវត្តតិ ឆន្នំ វណ្ណានំ នីលានំ បីតកានំ

គំនរភ្លើងចេញ អំពីព្រះហស្តខាងស្តាំ ផ្ការទឹកចេញអំពីព្រះហស្តខាងឆ្វេង គំនរភ្លើងចេញអំពីព្រះហស្តខាងឆ្វេង ផ្ការទឹកចេញអំពីព្រះហស្តខាងស្តាំ គំនរភ្លើងចេញអំពីខាងខាងស្តាំ ផ្ការទឹកចេញអំពីខាងខាងឆ្វេង គំនរភ្លើងចេញ អំពីខាងខាងឆ្វេង ផ្ការទឹកចេញអំពីខាងខាងស្តាំ គំនរភ្លើងចេញអំពីព្រះបាទខាងស្តាំ ផ្ការទឹកចេញអំពីព្រះបាទខាងឆ្វេង គំនរភ្លើងចេញអំពីព្រះបាទខាងឆ្វេង ផ្ការទឹកចេញអំពីព្រះបាទខាងស្តាំ គំនរភ្លើងចេញអំពីព្រះអង្គុលីមួយ ៗ ផ្ការទឹកចេញអំពីចន្លោះនៃព្រះអង្គុលី គំនរភ្លើងចេញអំពីចន្លោះនៃព្រះអង្គុលី ផ្ការទឹកចេញអំពីព្រះអង្គុលីមួយ ៗ គំនរភ្លើងចេញអំពីព្រះលោមាមួយ ៗ ផ្ការទឹកចេញអំពីព្រះលោមាមួយ ៗ គំនរភ្លើងចេញអំពីរណ្តៅព្រះលោមាមួយ ៗ ផ្ការទឹកចេញអំពីរណ្តៅព្រះលោមា (ព្រះមានព្រះភាគទ្រង់បញ្ចេញ) នូវព្រះឆព្វណ្ណរង្សីខៀវ លឿង

លោហិតកានំ ឱទាតានំ មញ្ជេដ្ឋានំ បភស្សរានំ ភគវា ចង្កមតិ និម្មិតោ តិដ្ឋតិ វា និសីទតិ វា សេយ្យំ វា កប្បេតិ ភគវា តិដ្ឋតិ និម្មិតោ ចង្ក-មតិ វា និសីទតិ វា សេយ្យំ វា កប្បេតិ ភគវា និសីទតិ និម្មិតោ ចង្កមតិ វា តិដ្ឋតិ វា សេយ្យំ វា កប្បេតិ ភគវា សេយ្យំ កប្បេតិ និម្មិតោ ចង្កមតិ វា តិដ្ឋតិ វា និសីទតិ វា ភគវា(១) ចង្កមតិ វា និសីទតិ វា សេយ្យំ វា កប្បេតិ និម្មិតោ តិដ្ឋតិ ភគវា ចង្កមតិ វា តិដ្ឋតិ វា សេយ្យំ វា កប្បេតិ និម្មិតោ និសីទតិ ភគវា តិដ្ឋតិ វា និសីទតិ វា ចង្កមតិ វា និម្មិតោ សេយ្យំ កប្បេតិ ឥទំ តថាគតស្ស យមក-បាដិហីរេ ញាណំ ។

[២៨៤] កតមំ តថាគតស្ស មហាករុណាសមាបត្តិ-យា ញាណំ ។ ពហុកេហិ អាការេហិ បស្សន្តានំ ពុទ្ធានំ

១ ឱ. ម. និម្មិតោ ចង្កមតិ ភគវា តិដ្ឋតិ វា និសីទតិ វា សេយ្យំ វា កប្បេតិ និម្មិតោ តិដ្ឋតិ ភគវា ចង្កមតិ វា និសីទតិ វា សេយ្យំ វា កប្បេតិ និម្មិតោ និសីទតិ ភគវា ចង្កមតិ វា តិដ្ឋតិ វា សេយ្យំ វា កប្បេតិ និម្មិតោ សេយ្យំ កប្បេតិ ភគវា ចង្កមតិ វា តិដ្ឋតិ វា និសីទតិ វា ឥទំ តថាគតស្ស យមកប្បាដិហីរេ ញាណំ ។

ក្រហម ស ហង្សបាទ ផ្សេង ៗ ព្រះមានព្រះភាគទ្រង់ចង្រ្កម ព្រះពុទ្ធនិម្មិត ទ្រង់ឈរ ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ឈរ ព្រះពុទ្ធ-និម្មិតទ្រង់ចង្រ្កម ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់គង់ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ព្រះមានព្រះភាគទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់គង់ ព្រះមានព្រះភាគទ្រង់ចង្រ្កម ឬទ្រង់គង់ ឬទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់ឈរ ព្រះមានព្រះភាគទ្រង់ចង្រ្កម ឬទ្រង់ឈរ ឬទ្រង់ផ្ទំ ព្រះពុទ្ធនិម្មិតទ្រង់គង់ ព្រះមានព្រះភាគទ្រង់ឈរ ឬទ្រង់គង់ ឬទ្រង់ចង្រ្កម ព្រះពុទ្ធនិម្មិតទ្រង់ផ្ទំ នេះឈ្មោះថា យមកប្បាដិហិរញ្ញាណ របស់ព្រះតថាគត ។

[២៨៥] មហាករុណាសមាបត្តិញ្ញាណ របស់ព្រះតថាគត តើដូចម្តេច ។ កាលព្រះពុទ្ធមានព្រះភាគទាំងឡាយ ទ្រង់ឃើញ ដោយអាការច្រើន

ភគវន្តានំ សត្ថេសុ មហាករុណា ឱក្កមតិ អាទិត្តោ លោកសន្និវាសោតិ បស្សន្តានំ ពុទ្ធានំ ភគវន្តានំ សត្ថេសុ មហាករុណា ឱក្កមតិ ឧយ្យុត្តោ លោកសន្និវាសោតិ ។ បេ ។ ឱក្កមតិ បយាតោ លោកសន្និវាសោតិ ។ បេ ។ ឱក្កមតិ កុម្មគ្គំ បដិបន្នោ លោកសន្និវាសោតិ បស្សន្តានំ ពុទ្ធានំ ភគវន្តានំ សត្ថេសុ មហាករុណា ឱក្កមតិ ឧបនីយតិ លោកោ អទ្ធុវោតិ បស្សន្តានំ ពុទ្ធានំ ភគវន្តានំ សត្ថេសុ មហាករុណា ឱក្កមតិ អត្តាណោ លោកោ អនភិស្សរោតិ[១] បស្សន្តានំ ពុទ្ធានំ ភគវន្តានំ សត្ថេសុ មហាករុណា ឱក្កមតិ អស្សកោ លោកោ សព្វំ បហាយ គមនីយន្តិ បស្សន្តានំ ពុទ្ធានំ ភគវន្តានំ សត្ថេសុ មហាករុណា ឱក្កមតិ ឩនោ លោកោ អតិត្តោ តណ្ហាទាសោតិ បស្សន្តានំ ពុទ្ធានំ ភគវន្តានំ សត្ថេសុ មហាករុណា ឱក្កមតិ អត្តាណោ លោកសន្និវាសោតិ បស្សន្តានំ ពុទ្ធានំ ។ បេ ។ អលេណោ លោកសន្និវាសោតិ បស្សន្តានំ ។ បេ ។

១ ម. អនភិសរោតិ ។

មហាករុណា រមែងចុះស៊ប់ក្នុងពួកសត្វ គឺកាលព្រះពុទ្ធមានព្រះភាគទ្រង់ឃើញថា លោកសន្និវាសត្រូវភ្លើងឆេះសព្វហើយ មហាករុណាចុះស៊ប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគទ្រង់ឃើញថា លោកសន្និវាសមានសេចក្តីខ្វល់ខ្វាយ (ជានិច្ច) ។ បេ ។ ថា លោកសន្និវាសមានដំណើរទៅ (ជានិច្ច) ។ បេ ។ ព្រះសម្ពុទ្ធមានព្រះភាគទ្រង់ឃើញថា លោកសន្និវាស ដើរទៅកាន់ផ្លូវខុស មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគទ្រង់ឃើញថា សត្វលោកមិនទៀង ត្រូវជរានាំចូលទៅ (រកសេចក្តីស្លាប់) មហាករុណា ក៏ចុះស៊ប់ក្នុងពួកសត្វ កាលព្រះពុទ្ធមានព្រះភាគទ្រង់ឃើញថា សត្វលោកឥតមានទីពឹង ឥតមានទីផ្អែក មហាករុណាក៏ចុះស៊ប់ ក្នុងពួកសត្វ កាលព្រះពុទ្ធ មានព្រះភាគ ទ្រង់ឃើញថា សត្វលោកគ្មានអ្វីជារបស់ខ្លួន ត្រូវលះបោលរបស់ទាំងអស់ហើយទៅ មហាករុណាក៏ចុះស៊ប់ ក្នុងពួកសត្វ កាលព្រះពុទ្ធ មានព្រះភាគ ទ្រង់ឃើញថា សត្វលោកមានសេចក្តីខ្វះខាត មិនឆ្អែត ជាទាសៈនៃតណ្ហា មហាករុណាក៏ចុះស៊ប់ ក្នុងពួកសត្វ កាលព្រះពុទ្ធទ្រង់ឃើញថា លោកសន្និវាស ឥតទីពឹង ។ បេ ។ កាលទ្រង់ឃើញថា លោកសន្និវាស ឥតទីពួន ។ បេ ។

អសរណោ លោកសន្និវាសោតិ បស្សន្តានំ ។ បេ ។ អសរណីភូតោ លោកសន្និវាសោតិ បស្សន្តានំ ។ បេ ។ ឧទ្ធតោ លោកោ អវូបសន្តោតិ បស្សន្តានំ ។ បេ ។ សសល្លោ លោកសន្និវាសោ វិទ្ធោ បុថុសល្លេហិ តស្ស នត្ថញ្ញោ កោចិ សល្លានំ ឧទ្ធតោ អញ្ញត្រ មយាតិ បស្សន្តានំ អវិជ្ជន្ធការាវរណោ លោកសន្និវាសោ កិលេសបញ្ជរំ បក្ខិត្តោ តស្ស នត្ថញ្ញោ កោចិ អាលោកំ ទស្សេតា អញ្ញត្រ មយាតិ បស្សន្តានំ អវិជ្ជាគតោ លោកសន្និវាសោ អន្ធភូតោ បរិយោនទ្ធោ[១] តន្តាកុលជាតោ[២] គុឡាគុណ្ឋិកជាតោ[៣] មុញ្ជបព្វជភូតោ អបាយទុគ្គតិវិនិបាតំ សំសារំ នាតិវត្តតីតិ បស្សន្តានំ អវិជ្ជាវិសទោសសល្លិត្តោ លោកសន្និវាសោ កិលេសកលិភូតោតិ បស្សន្តានំ រាគទោសមោហជដិតោ[៤] លោកសន្និវាសោ តស្ស

---

១ ឱ. បរិយោនន្ធោ ។ ២ ម. តន្តាកុលកជាតោ ។ ៣ ម. គុលាគុណ្ឋិកជាតោ ។ ៤ ម. រាគទោសមោហជដាជដិតោ ។

ទ្រង់ឃើញថា លោកសន្និវាសឥតទីពឹង ។ បេ ។ ទ្រង់ឃើញថា លោក-សន្និវាសមិនមានវត្ថុជាទីពឹង ។ បេ ។ ទ្រង់ឃើញថា សត្វលោកកំពុងវេវវាយមិនស្ងប់រម្ងាប់ ។ បេ ។ ទ្រង់ឃើញថា លោកសន្និវាសប្រកបដោយសរមុតហើយ ដោយសរផ្សេង ៗ បុគ្គលដទៃនីមួយ ក្រៅពីតថាគតនឹងដកសររបស់លោកសន្និវាសនោះមិនមានឡើយ ទ្រង់ឃើញថា លោក-សន្និវាស មានងងឹតគឺអវិជ្ជា ជាគ្រឿងរារាំង ធ្លាក់ចុះក្នុងទ្រុងគឺកិលេស បុគ្គលដទៃនីមួយ ជាអ្នកបង្ហាញនូវពន្លឺដល់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសលុះក្នុងអំណាចអវិជ្ជា ជាអ្នកងងឹតងងល់ ត្រូវអវិជ្ជារួបរឹត សាំញ៉ាំដូចអំបោះនៃជាងតម្បាញស្មុគ្រស្មាញ ដូចអំបោះដែលជាងតម្បាញ ប្រឡាក់ដោយទឹកបាយ ដូចស្មៅយាប្លងនិងស្មៅជំពោកទន្សាយ មិនប្រព្រឹត្តកន្លង នូវអបាយ ទុគ្គតិ វិនិបាត និងសង្សារបានឡើយ ទ្រង់ឃើញថា លោកសន្និវាស ជាប់ដោយទោសគឺពិសនៃអវិជ្ជា ប្រកបដោយកំហុសគឺកិលេស ទ្រង់ឃើញថា លោកសន្និវាស ត្រូវរាគៈ ទោសៈ មោហៈ ចាក់ស្រែះហើយ

ឧត្តញ្ញោ កោចិ ឧជុំ វិជជិតា[(១)] អញ្ញត្រ មយាតិ បស្សន្តានំ តណ្ហាសង្ឃាដប្បដិមុក្កោ លោកសន្និវាសោតិ បស្សន្តានំ តណ្ហាជាលេន ឱត្ថតោ លោកសន្និវាសោតិ បស្សន្តានំ តណ្ហាសោតេន វុយ្ហតិ លោកសន្និវាសោតិ បស្សន្តានំ តណ្ហាសញ្ញោជនេន សញ្ញុត្តោ លោកសន្និវាសោតិ បស្សន្តានំ តណ្ហានុសយេន អនុសដោ[(២)] លោកសន្និវាសោតិ បស្សន្តានំ តណ្ហាសន្តាបេន សន្តប្បតិ លោកសន្និវាសោតិ បស្សន្តានំ តណ្ហាបរិឡាហេន បរិឌយ្ហតិ លោកសន្និវាសោតិ បស្សន្តានំ ទិដ្ឋិសង្ឃាដប្បដិមុក្កោ លោកសន្និវាសោតិ បស្សន្តានំ ទិដ្ឋិជាលេន ឱត្ថតោ លោកសន្និវាសោតិ បស្សន្តានំ ទិដ្ឋិសោតេន វុយ្ហតិ លោកសន្និវាសោតិ បស្សន្តានំ ទិដ្ឋិសញ្ញោជនេន សញ្ញុត្តោ លោកសន្និវាសោតិ បស្សន្តានំ ទិដ្ឋានុសយេន អនុសដោ លោកសន្និវាសោតិ បស្សន្តានំ

១ ម. វិជដំ វិជដេតា ។ ២ ឱ. អនុសហគតោ ។

បុគ្គលដទៃនីមួយ ជាអ្នកដោះនូវបណ្តាញ របស់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសស៊កចុះក្នុងឃ្នាបគឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាស ត្រូវបណ្តាញគឺតណ្ហារួបរឹត ទ្រង់ឃើញថា លោកសន្និវាស ត្រូវខ្សែតណ្ហាបន្សាត់ទៅហើយ ទ្រង់ឃើញថា លោកសន្និវាសប្រកបហើយដោយចំណងគឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាស ត្រាំនៅក្នុងតម្រាំគឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាសក្តៅដោយកម្តៅគឺតណ្ហា ទ្រង់ឃើញថា លោកសន្និវាសក្តៅក្រហាយដោយសេចក្តីក្តៅក្រហាយគឺតណ្ហា ទ្រង់ឃើញថា លោក-សន្និវាស ស៊កចុះក្នុងឃ្នាបគឺទិដ្ឋិ ទ្រង់ឃើញថា លោកសន្និវាស ត្រូវបណ្តាញគឺទិដ្ឋិរួបរឹតហើយ ទ្រង់ឃើញថា លោកសន្និវាស ត្រូវខ្សែទិដ្ឋិបន្សាត់ទៅ ទ្រង់ឃើញថា លោកសន្និវាស ប្រកបដោយគ្រឿងប្រកបគឺទិដ្ឋិ ទ្រង់ឃើញថា លោកសន្និវាស ត្រាំនៅក្នុងតម្រាំ គឺទិដ្ឋិ

ទិដ្ឋិសន្តាបេន សន្តប្បតិ លោកសន្និវាសោតិ បស្ស-ន្តានំ ទិដ្ឋិបរិឡាហេន បរិឌយ្ហតិ[១] លោកសន្និវាសោតិ បស្សន្តានំ ជាតិយា អនុគតោ លោកសន្និវាសោតិ បស្សន្តានំ ។ បេ ។ ជរាយ អនុសដោ លោកសន្និ-វាសោតិ បស្សន្តានំ ។ បេ ។ ព្យាធិនា អភិភូតោ លោកសន្និវាសោតិ បស្សន្តានំ ។ បេ ។ មរណេន អព្ភាហតោ[២] លោកសន្និវាសោតិ បស្សន្តានំ ។ បេ ។ ទុក្ខបតិតោ[៣] លោកសន្និវាសោតិ បស្សន្តានំ តណ្ហាយ ឧឌ្ឌិតោ លោកសន្និវាសោតិ បស្សន្តានំ ជរាបាការបរិក្ខិត្តោ លោកសន្និវាសោតិ បស្សន្តានំ មច្ចុបាសេន[៤] បរិក្ខិត្តោ លោកសន្និវាសោតិ បស្ស-ន្តានំ មហាពន្ធនពទ្ធោ លោកសន្និវាសោ រាគពន្ធ-នេន ទោសពន្ធនេន មោហពន្ធនេន មានពន្ធនេន ទិដ្ឋិពន្ធនេន កិលេសពន្ធនេន ទុច្ចរិតពន្ធនេន

---

១ ឱ. បរិឡយ្ហតិ ។ ២ ម. អព្ភាហតោ ។ ៣ ម. ទុក្ខេ បតិដ្ឋិតោ ។ ៤ ឱ. បច្ចុបាសេន ។

ទ្រង់ឃើញថា លោកសន្និវាសក្ដៅដោយកម្ដៅគឺទិដ្ឋិ ទ្រង់ឃើញថា លោក-សន្និវាស ក្ដៅក្រហាយដោយសេចក្ដីក្ដៅក្រហាយគឺទិដ្ឋិ ទ្រង់ឃើញថា លោកសន្និវាសប្រកបដោយជាតិជានិច្ច ។ បេ ។ ទ្រង់ឃើញថា លោក-សន្និវាស ត្រាំក្នុងជរា ។ បេ ។ ទ្រង់ឃើញថា លោកសន្និវាសត្រូវព្យាធិគ្របសង្កត់ហើយ ។ បេ ។ ទ្រង់ឃើញថា លោកសន្និវាស ត្រូវមរណៈបៀតបៀន ។ បេ ។ ទ្រង់ឃើញថា លោកសន្និវាស មានទុក្ខធ្លាក់ត្រូវហើយ ទ្រង់ឃើញថា លោកសន្និវាសត្រូវតណ្ហាទាក់ជាប់ហើយ ទ្រង់ឃើញថា លោកសន្និវាសស្រោបហើយដោយកំពែងគឺជរា ទ្រង់ឃើញថា លោកសន្និវាសត្រូវអន្ទាក់គឺមច្ចុរឹតរួត ទ្រង់ឃើញថា លោកសន្និ-វាស ជាប់ដោយចំណងច្រើន គឺ ចំណងរាគៈ ចំណងទោសៈ ចំណងមោហៈ ចំណងមានះ ចំណងទិដ្ឋិ ចំណងកិលេស ចំណងទុច្ចរិត

តស្ស នត្ថញ្ញោ កោចិ ពន្ធំ[១] មោចេតា អញ្ញត្រ ម-យាតិ បស្សន្តានំ មហាសម្ពាធប្បដិបន្នោ លោកសន្និ-វាសោ តស្ស នត្ថញ្ញោ កោចិ ឱភាសំ[២] ទស្សេតា អញ្ញត្រ មយាតិ បស្សន្តានំ មហាបលិពោធេន បលិ-ពុទ្ធោ លោកសន្និវាសោ តស្ស នត្ថញ្ញោ កោចិ បលិពោធំ ឆេទេតា[៣] អញ្ញត្រ មយាតិ បស្សន្តានំ ។ បេ ។ មហាបបាតេ បតិតោ លោកសន្និវាសោ តស្ស នត្ថញ្ញោ កោចិ បបាតា ឧទ្ធត្តា អញ្ញត្រ មយាតិ បស្សន្តានំ មហាកន្តារំ បដិបន្នោ លោក-សន្និវាសោ តស្ស នត្ថញ្ញោ កោចិ កន្តារំ តារេតា អញ្ញត្រ មយាតិ បស្សន្តានំ មហាសំសារ បដិបន្នោ លោកសន្និវាសោ តស្ស នត្ថញ្ញោ កោចិ សំសារា មោចេតា អញ្ញត្រ មយាតិ បស្សន្តានំ មហាវិទុគ្គេ សម្បរិវត្តតិ លោកសន្និវាសោ តស្ស នត្ថញ្ញោ កោចិ វិទុគ្គា ឧទ្ធត្តា អញ្ញត្រ មយាតិ បស្សន្តានំ

១ ម. ពន្ធនំ ។ ២ ឱ. ម. ឧភាសំ ។ ៣ ម. ឆេតា ។

បុគ្គលដទៃនីមួយ ជាអ្នកស្រាយនូវចំណងរបស់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសដើរទៅកាន់ទីចង្អៀតខ្លាំង បុគ្គលដទៃនីមួយ ជាអ្នកបង្ហាញនូវពន្លឺដល់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសមានកង្វល់ដោយកង្វល់ច្រើន បុគ្គលដទៃនីមួយ ជាអ្នកកាត់នូវកង្វល់របស់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ។ បេ ។ ទ្រង់ឃើញថា លោកសន្និវាសធ្លាក់ចុះក្នុងជ្រោះធំ បុគ្គលដទៃនីមួយ ជាអ្នកស្រង់លោកសន្និវាសនោះ ឲ្យរួចពីជ្រោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសដើរទៅកាន់ផ្លូវលំបាកខ្លាំង បុគ្គលដទៃនីមួយ ជាអ្នកចម្លងលោកសន្និវាសនោះ ឲ្យឆ្លងផ្លូវលំបាក ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសដើរទៅក្នុងមហាសង្សារ បុគ្គលដទៃនីមួយ ជាអ្នកស្រាយលោកសន្និវាសនោះឲ្យរួចចាកសង្សារ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាស វិលវល់នៅក្នុងផ្លូវកម្រខ្លាំង បុគ្គលដទៃនីមួយ ជាអ្នកស្រង់លោកសន្និវាសនោះ ឲ្យរួចចាកផ្លូវកម្រ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា

មហាបល្លេបេ បលិបន្នោ លោកសន្និវាសោ[១] រាគ-គ្គិនា ទោសគ្គិនា មោហគ្គិនា ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អព្ភាហតោ តស្ស នត្ថញ្ញោ កោចិ និព្វាបេតា អញ្ញត្រ មយាតិ បស្សន្តានំ ឧន្និតកោ លោកសន្និវាសោ ហញ្ញតិ និច្ចមត្តាណោ បត្តទណ្ឌោ តក្កាពេតិ បស្សន្តានំ វដ្ដពន្ធនពន្ធោ[២] លោកសន្និ-វាសោ អាឃាតនបច្ចុបដ្ឋិតោ តស្ស នត្ថញ្ញោ កោចិ ពន្ធំ មោចេតា អញ្ញត្រ មយាតិ បស្សន្តានំ អនាថោ លោកសន្និវាសោ បរមការុញ្ញប្បត្តោ តស្ស នត្ថញ្ញោ កោចិ តាយេតា អញ្ញត្រ មយាតិ បស្សន្តានំ ។ បេ ។ ទុក្ខាភិតុន្នោ លោកសន្និវាសោ ចិររត្ត-បីឡិតោតិ បស្សន្តានំ និច្ចគធិតោ លោកសន្និវា-សោ និច្ចបិបាសិតោតិ បស្សន្តានំ ។ បេ ។

១ ឱ. ម. ឯត្ថន្តរេ តស្ស នត្ថញ្ញោ កោចិ បលិបា ឧទ្ធតា អញ្ញត្រ មយាតិ បស្សន្តានំ ។ បេ ។ អព្ភាហតោ លោកសន្និវាសោ ។ បេ ។ អាទិត្តោ លោកសន្និវាសោតិ ទិស្សន្តិ ។

២ ឱ. ម. វដ្ដពន្ធនពន្ធោ ។

លោកសន្និវាសលិចចុះក្នុងល្បាប់ជ្រៅ ត្រូវភ្លើងគឺរាគៈ ភ្លើងគឺទោសៈ ភ្លើងគឺមោហៈ និងជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស ឧបាយាសៈញាំញីហើយ បុគ្គលដទៃទីមួយ ជាអ្នកលត់ភ្លើងរបស់លោក-សន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និ-វាស អណ្តែតឡើង ឥតមានទីពឹងជានិច្ច មានអាជ្ញាត្រូវហើយ ធ្វើតាមតែអាជ្ញានោះ រមែងលំបាក ទ្រង់ឃើញថា លោកសន្និវាសជាប់ចំណងវដ្តៈប្រាកដក្នុងទីសម្រាប់សម្លាប់ បុគ្គលដទៃទីមួយ ជាអ្នកស្រាយចំណងឲ្យដល់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសឥតមានទីពំនាក់ ដល់នូវភាពគួរអាណិតក្រៃពេក បុគ្គលដទៃទីមួយ ជាអ្នកជួយស្រោចស្រង់លោកសន្និវាសនោះ ក្រៅពីតថាគតមិនមានឡើយ ។ បេ ។ ទ្រង់ឃើញថា លោកសន្និវាសត្រូវសេចក្តីទុក្ខចាក់ដោតហើយ ត្រូវសេចក្តីទុក្ខបៀតបៀនហើយអស់កាលយូរ ទ្រង់ឃើញថា លោកសន្និវាសជាប់ចំពាក់ជានិច្ច ស្រេកឃ្លានជានិច្ច ។ បេ ។

អន្ធោ លោកសន្និវាសោ អចក្ខុកោតិ បស្សន្តានំ ហតនេត្តោ លោកសន្និវាសោ អបរិណាយកោតិ បស្សន្តានំ វិបថំ បក្ខន្តោ[១] លោកសន្និវាសោ អញ្ជសាបរទ្ធោ តស្ស នត្ថញ្ញោ កោចិ អរិយបថំ អានេតា អញ្ញត្រ មយាតិ បស្សន្តានំ មហោឃ-បក្ខន្ទោ លោកសន្និវាសោ តស្ស នត្ថញ្ញោ កោចិ ឱឃា ឧទ្ធតា អញ្ញត្រ មយាតិ បស្សន្តានំ ទ្វីហិ ទិដ្ឋិគតេហិ បរិយុដ្ឋិតោ លោកសន្និវាសោតិ បស្សន្តានំ តីហិ ទុច្ចរិតេហិ វិប្បដិបន្នោ លោក-សន្និវាសោតិ បស្សន្តានំ យោគេហិ ប្វរិតោ[២] លោកសន្និវាសោ ចតុយោគយោជិតោតិ បស្សន្តានំ ចតូហិ គន្ថេហិ គន្ថិតោ លោកសន្និវាសោតិ បស្ស-ន្តានំ ចតូហិ ឧបាទានេហិ ឧបាទិយតិ លោកសន្និ-វាសោតិ បស្សន្តានំ បញ្ចគតិសមារុឡ្ហោ លោកសន្និ-វាសោតិ បស្សន្តានំ បញ្ចហិ កាមគុណេហិ រជ្ជតិ លោកសន្និវាសោតិ បស្សន្តានំ បញ្ចហិ នីវរណេហិ

---

១ ម. បក្ខន្ទោ ។ ២ ឱ. ម. ចតូហិ យោគេហិ យុត្តោ ។

ទ្រង់ឃើញថា លោកសន្និវាសខ្វាក់ ឥតមានចក្ខុ ទ្រង់ឃើញថា លោក-សន្និវាស មានភ្នែកវិនាសហើយ ឥតមានអ្នកដឹកដៃ ទ្រង់ឃើញថា លោកសន្និវាស ស្ទុះទៅកាន់ផ្លូវខុស ដើរខុសផ្លូវ បុគ្គលដទៃទីមួយ ជាអ្នកនាំ លោកសន្និវាសនោះ ឲ្យដើរទៅកាន់ផ្លូវដ៏ប្រសើរ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាសស្ទុះទៅក្នុងជំនន់ធំ បុគ្គលដទៃទីមួយ ជាអ្នកស្រង់នូវលោកសន្និវាសនោះអំពីជំនន់ ក្រៅពីតថាគតមិនមានឡើយ ទ្រង់ឃើញថា លោកសន្និវាស ត្រូវទិដ្ឋិទាំងពីររួបរឹត ទ្រង់ឃើញថា លោកសន្និវាសប្រតិបត្តិខុសព្រោះទុច្ចរិតទាំង ៣ ទ្រង់ឃើញថា លោកសន្និវាសពេញដោយយោគធម៌ ប្រកបដោយយោគ-ធម៌ទាំង ៤ ទ្រង់ឃើញថា លោកសន្និវាសចាក់ស្រែះហើយដោយគណ្ឋ-កិលេសទាំង ៤ ទ្រង់ឃើញថា លោកសន្និវាសប្រកាន់មាំដោយឧបា-ទានទាំង ៤ ទ្រង់ឃើញថា លោកសន្និវាសឡើងកាន់គតិទាំង ៥ ទ្រង់ឃើញថា លោកសន្និវាសរមែងត្រេកអរដោយកាមគុណទាំង ៥ ទ្រង់ឃើញថា លោកសន្និវាស ត្រូវនីវរណៈទាំង ៥ គ្របសង្កត់ហើយ

ឱត្ថតោ លោកសន្និវាសោតិ បស្សន្តានំ ឆហិ វិវាទ-មូលេហិ វិវទតិ លោកសន្និវាសោតិ បស្សន្តានំ ឆហិ តណ្ហាកាយេហិ រជ្ជតិ លោកសន្និវាសោតិ បស្ស-ន្តានំ ឆហិ ទិដ្ឋិគតេហិ បរិយុដ្ឋិតោ លោកសន្និវាសោតិ បស្សន្តានំ សត្តហិ អនុសយេហិ អនុសដោ លោក-សន្និវាសោតិ បស្សន្តានំ សត្តហិ សញ្ញោជនេហិ សញ្ញុត្តោ លោកសន្និវាសោតិ បស្សន្តានំ សត្តហិ មានេហិ ឧណ្ណតោ លោកសន្និវាសោតិ បស្សន្តានំ អដ្ឋហិ លោកធម្មេហិ សម្បរិវត្តតិ លោកសន្និវា-សោតិ បស្សន្តានំ អដ្ឋហិ មិច្ឆត្តេហិ និយតោ លោក-សន្និវាសោតិ បស្សន្តានំ អដ្ឋហិ បុរិសទោសេហិ ទុស្សតិ លោកសន្និវាសោតិ បស្សន្តានំ នវហិ អា-ឃាតវត្ថូហិ អាឃាតោ[១] លោកសន្និវាសោតិ បស្ស-ន្តានំ នវវិធមានេហិ ឧណ្ណតោ លោកសន្និវាសោតិ បស្សន្តានំ នវហិ តណ្ហាមូលកេហិ ធម្មេហិ រជ្ជតិ លោកសន្និវាសោតិ បស្សន្តានំ ទសហិ កិលេសវត្ថូ-ហិ កិលិស្សតិ លោកសន្និវាសោតិ បស្សន្តានំ

---

១ ឱ. ម. អាឃាតិតោ ។

ទ្រង់ឃើញថា លោកសន្និវាសរមែងវិវាទដោយវិវាទមូលទាំង ៦ ទ្រង់ឃើញថា លោកសន្និវាសរមែងត្រេកអរដោយតណ្ហាកាយទាំង ៦ ទ្រង់ឃើញថា លោកសន្និវាសត្រូវទិដ្ឋិទាំង ៦ រួបរឹតហើយ ទ្រង់ឃើញថា លោកសន្និវាសត្រាំនៅហើយដោយតម្រាំទាំង ៧ ទ្រង់ឃើញថា លោក-សន្និវាសប្រកបហើយដោយសញ្ញោជនៈទាំង ៧ ទ្រង់ឃើញថា លោក-សន្និវាសប៉ោងឡើងហើយដោយមានះទាំង ៧ ទ្រង់ឃើញថា លោក-សន្និវាសវិលវល់តាមលោកធម៌ទាំង ៨ ទ្រង់ឃើញថា លោកសន្និវាសទៀងដោយមិច្ឆត្តធម៌ទាំង ៨ ទ្រង់ឃើញថា លោកសន្និវាសរមែងប្រទូស្តដោយទោសសម្រាប់បុរស ៨ ទ្រង់ឃើញថា លោកសន្និវាសចងគំនុំដោយអាឃាតវត្ថុទាំង ៩ ទ្រង់ឃើញថា លោកសន្និវាសប៉ោងឡើងហើយដោយមានះទាំង ៩ ទ្រង់ឃើញថា លោកសន្និវាសរមែងត្រេកអរដោយតណ្ហាមូលកធម៌ទាំង ៩ ទ្រង់ឃើញថា លោកសន្និវាសរមែងសៅហ្មងដោយកិលេសវត្ថុទាំង ១០ ទ្រង់ឃើញថា លោកសន្និវាស

ទសហិ អាឃាតវត្ថូហិ អាឃាតោ លោកសន្និវាសោតិ បស្សន្តានំ ទសហិ អកុសលេហិ កម្មបថេហិ សមន្នាគតោ លោកសន្និវាសោតិ បស្សន្តានំ ទសហិ សញ្ញោជនេហិ សញ្ញុត្តោ លោកសន្និវាសោតិ បស្សន្តានំ ទសហិ មិច្ឆត្តេហិ និយតោ លោកសន្និវាសោតិ បស្សន្តានំ ទសវត្ថុកាយ មិច្ឆាទិដ្ឋិយា សមន្នាគតោ លោកសន្និវាសោតិ បស្សន្តានំ ទសវត្ថុកាយ សក្កាយទិដ្ឋិយា[១] សមន្នាគតោ លោកសន្និវាសោតិ បស្សន្តានំ អដ្ឋសតតណ្ហាបបញ្ចេហិ[២] បបញ្ចិតោ លោកសន្និវាសោតិ បស្សន្តានំ ពុទ្ធានំ ភគវន្តានំ សត្តេសុ មហាករុណា ឱក្កមតិ ទ្វាសដ្ឋិយា ទិដ្ឋិគតេហិ បរិយុដ្ឋិតោ លោកសន្និវាសោតិ បស្សន្តានំ ពុទ្ធានំ ភគវន្តានំ សត្តេសុ មហាករុណា ឱក្កមតិ អហញ្ចម្ហិ តិណ្ណោ លោកោ ច អតិណ្ណោ អហញ្ចម្ហិ មុត្តោ លោកោ ច អមុត្តោ អហញ្ចម្ហិ ទន្តោ

---

១ ឱ. ម. អន្តគាហិកាយ ទិដ្ឋិយា ។ ២ ឱ. ម. អដ្ឋសតតណ្ហាបបញ្ចសតេហិ ។

ចងគំនុំដោយអាឃាតវត្ថុទាំង ១០ ទ្រង់ឃើញថា លោកសន្និវាស ប្រកបព្រមហើយដោយអកុសលកម្មបថទាំង ១០ ទ្រង់ឃើញថា លោក-សន្និវាសប្រកបដោយសញ្ញោជនៈទាំង ១០ ទ្រង់ឃើញថា លោកសន្និ-វាសទៀងដោយមិច្ឆត្តធម៌ទាំង ១០ ទ្រង់ឃើញថា លោកសន្និវាស ប្រកបហើយដោយមិច្ឆាទិដ្ឋិមានវត្ថុ ១០ ទ្រង់ឃើញថា លោកសន្និវាស ប្រកបហើយដោយសក្កាយទិដ្ឋិមានវត្ថុ ១០ ព្រះពុទ្ធមានព្រះភាគទាំង-ឡាយ ទ្រង់ឃើញថា លោកសន្និវាសត្រូវបបញ្ចធម៌គឺតណ្ហាទាំង ១០៨ ឲ្យយឺតយូរហើយ មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ ព្រះពុទ្ធ មានព្រះភាគទាំងឡាយ ទ្រង់ឃើញថា លោកសន្និវាសត្រូវទិដ្ឋិទាំង ៦២ រួបរឹតហើយ មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ ព្រះពុទ្ធមានព្រះ ភាគទាំងឡាយ ទ្រង់ឃើញថា តថាគតឆ្លងរួចហើយ ឯសត្វលោក មិនទាន់ឆ្លងនៅឡើយ តថាគតរួចហើយ ឯសត្វលោកមិនទាន់រួចនៅ ឡើយ តថាគតហ្វឹកហ្វឺនហើយ ឯសត្វលោកមិនទាន់ហ្វឹកហ្វឺននៅឡើយ

លោកោ ច អនន្តោ អហញ្ចម្ហិ សន្តោ លោកោ ច អសន្តោ អហញ្ចម្ហិ អស្សត្ថោ លោកោ ច អនស្សត្ថោ អហញ្ចម្ហិ បរិនិព្វុតោ លោកោ ច អបរិនិព្វុតោ អហញ្ចម្ហិ[១] តិណ្ណោ តារេតុំ មុត្តោ មោចេតុំ ទន្តោ ទមេតុំ សន្តោ សមេតុំ អស្សត្ថោ អស្សាសេតុំ បរិនិព្វុតោ បរិនិព្វាបេតុន្តិ[២] បស្សន្តានំ ពុទ្ធានំ ភគវន្តានំ សត្តេសុ មហាករុណា ឱក្កមតិ ឥទំ តថាគតស្ស មហាករុណា សមាបត្តិយា ញាណំ ។

[២៨៦] កតមំ តថាគតស្ស សព្វញ្ញុតញ្ញាណំ ។ សព្វសង្ខតមសង្ខតំ អនវសេសំ ជានាតីតិ សព្វញ្ញុត-ញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ អនាគតំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ

១ ឱ. ម. បហោមិ ក្វាហំ ។ ២ ម. បរេច បរិនិព្វានបេតុន្តិ ។

តថាគតស្ងប់ហើយ ឯសត្វលោក មិនទាន់ស្ងប់នៅឡើយ តថាគតសប្បាយចិត្តហើយ ឯសត្វលោក មិនទាន់សប្បាយចិត្តនៅឡើយ តថាគតរលត់កិលេសហើយ ឯសត្វលោក មិនទាន់រលត់កិលេសនៅឡើយ តថាគតឆ្លងហើយ ដើម្បីចម្លង (សត្វលោក) តថាគតរួចហើយ ដើម្បីញុំាងសត្វលោកឲ្យរួច តថាគតហ្វឹកហ្វឺនហើយ ដើម្បីហ្វឹកហ្វឺនសត្វលោក តថាគតស្ងប់រម្ងាប់ហើយ ដើម្បីញុំាងសត្វលោកឲ្យស្ងប់រម្ងាប់ តថាគតសប្បាយចិត្តហើយ ដើម្បីញុំាងសត្វលោកឲ្យសប្បាយចិត្ត តថាគតរលត់កិលេសហើយ ដើម្បីញុំាងសត្វលោកឲ្យរលត់កិលេស មហាករុណាក៏ចុះស៊ប់ក្នុងពួកសត្វ នេះឈ្មោះថាមហាករុណាសមាបត្តិញ្ញាណ របស់ព្រះតថាគត ។

[២៨៦] សព្វញ្ញុតញ្ញាណ របស់ព្រះតថាគត តើដូចម្តេច ។ ព្រះតថាគត ទ្រង់ជ្រាបសង្ខតធម៌និងអសង្ខតធម៌ទាំងអស់ មិនមានសេសសល់ ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវហេតុជាអនាគត ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ

តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ អតីតំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ បច្ចុប្បន្នំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ ចក្ខុញ្ចេវ រូបា ច ឯវំ តំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ សោតញ្ចេវ សទ្ទា ច ។ បេ ។ ឃានញ្ចេវ គន្ធា ច ជិវ្ហា ចេវ រសា ច កាយោ ចេវ ផោដ្ឋព្វា ច មនោ ចេវ ធម្មា ច ឯវំ តំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ ។

[២៨៧] យាវតា អនិច្ចដ្ឋំ ទុក្ខដ្ឋំ អនត្តដ្ឋំ សព្វំ[១] ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ

១ ឱ. តំ សព្វំ ។

គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណ-ញាណ ព្រះតថាគត ទ្រង់ជ្រាបសព្វនូវហេតុជាអតីតៈ ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ព្រះតថាគត ទ្រង់ជ្រាបសព្វនូវហេតុជាបច្ចុប្បន្ន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ភ្នែកនិងរូប(យ៉ាងណា) ព្រះតថាគត ទ្រង់ជ្រាបសព្វនូវធម៌នោះ យ៉ាងនោះដែរ ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ត្រចៀកនិងសំឡេង ។ បេ ។ ច្រមុះនិងក្លិន អណ្តាតនិងរស កាយនិងសម្ផស្ស ចិត្តនិងធម្មារម្មណ៍ យ៉ាងណា ព្រះតថាគត ទ្រង់ជ្រាបសព្វនូវធម៌នោះទាំងអស់ យ៉ាងនោះដែរ ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ។

[២៨៧] ព្រះតថាគត ទ្រង់ជ្រាបសព្វ នូវអត្ថនៃអនិច្ចធម៌ នូវអត្ថនៃទុក្ខធម៌ នូវអត្ថនៃអនត្តធម៌ ទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំង ក្នុងញាណនោះ មិនមាន

អនាវរណំ ញាណំ យាវតា រូបស្ស អនិច្ចដ្ឋំ ទុក្ខដ្ឋំ អនត្តដ្ឋំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ យាវតា វេទ-នាយ យាវតា សញ្ញាយ យាវតា សង្ខារានំ យាវតា វិញ្ញាណស្ស យាវតា ចក្ខុស្ស ។ បេ ។ ជរាមរ-ណស្ស អនិច្ចដ្ឋំ ទុក្ខដ្ឋំ អនត្តដ្ឋំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ ។

[២៨៨] យាវតា អភិញ្ញាយ អភិញ្ញដ្ឋំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ យាវតា បរិញ្ញាយ បរិញ្ញដ្ឋំ យាវតា បហានាយ បហានដ្ឋំ យាវតា

ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ព្រះតថាគត ទ្រង់ជ្រាបសព្វ នូវអត្ថនៃអនិច្ចធម៌ នូវអត្ថនៃទុក្ខធម៌ នូវអត្ថនៃអនត្តធម៌ របស់រូបទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វ នូវអត្ថនៃអនិច្ចធម៌ នូវអត្ថនៃទុក្ខធម៌ នូវអត្ថនៃអនត្តធម៌ របស់វេទនាទាំងប៉ុន្មាន របស់សញ្ញាទាំងប៉ុន្មាន របស់សង្ខារទាំងប៉ុន្មាន របស់វិញ្ញាណទាំងប៉ុន្មាន របស់ចក្ខុទាំងប៉ុន្មាន ។ បេ ។ របស់ជរាមរណៈទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ។

[២៨៨] ព្រះតថាគត ទ្រង់ជ្រាបសព្វ នូវអត្ថនៃការដឹងច្បាស់ របស់អភិញ្ញាទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំង ក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនា-វរណញ្ញាណ ព្រះតថាគត ទ្រង់ជ្រាបសព្វ នូវអត្ថនៃការកំណត់ដឹង របស់បរិញ្ញាទាំងប៉ុន្មាន នូវអត្ថនៃការលះបង់ របស់បហានៈទាំងប៉ុន្មាន

ការដោយ ការជង្ហំ យាវតា សច្ចិកិរិយាយ សច្ចិកិរិយជ្ជំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ យាវតា ខន្ធានំ ខន្ធជ្ជំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ យាវតា ធាតូនំ ធាតុជ្ជំ យាវតា អាយតនានំ អាយតនជ្ជំ យាវតា សង្ខតានំ សង្ខតជ្ជំ យាវតា អសង្ខតស្ស អសង្ខតជ្ជំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ ។

[២៨៩] យាវតា កុសលេ ធម្មេ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ យាវតា អកុសលេ ធម្មេ យាវតា អព្យាកតេ ធម្មេ

នូវអត្ថនៃការបម្រើន របស់ភាវនាទាំងប៉ុន្មាន នូវអត្ថនៃការធ្វើឲ្យជាក់ច្បាស់ របស់សច្ឆិកិរិយាទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណ-ញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វ នូវអត្ថនៃគំនរ របស់ខន្ធទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វ នូវអត្ថនៃធាតុ របស់ធាតុទាំងប៉ុន្មាន នូវអត្ថនៃអាយតនៈ របស់អាយតនៈទាំងប៉ុន្មាន នូវអត្ថនៃសង្ខតធម៌ របស់សង្ខតធម៌ទាំងប៉ុន្មាន នូវអត្ថនៃអសង្ខតធម៌ របស់អសង្ខតធម៌ ទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំង ក្នុងញាណនោះ មិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ។

[២៨៩] ព្រះតថាគតទ្រង់ជ្រាបសព្វ នូវកុសលធម៌ទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំង ក្នុងញាណនោះ មិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វ នូវអកុសលធម៌ ទាំងប៉ុន្មាន នូវអព្យាកតធម៌ ទាំងប៉ុន្មាន

យាវតា កាមាវចរេ ធម្មេ យាវតា រូបាវចរេ ធម្មេ យាវតា អរូបាវចរេ ធម្មេ យាវតា អបរិយាបន្នេ ធម្មេ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ យាវតា ទុក្ខស្ស ទុក្ខដ្ឋំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ ។ យាវតា សមុទយស្ស សមុទយដ្ឋំ យាវតា និរោធស្ស និរោធដ្ឋំ យាវតា មគ្គស្ស មគ្គដ្ឋំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ ។

[២៩០] យាវតា អត្ថប្បដិសម្ភិទាយ អត្ថប្បដិសម្ភិទដ្ឋំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ ។ បេ ។ យាវតា ធម្មប្បដិសម្ភិទាយ ធម្មប្បដិសម្ភិទដ្ឋំ

នូវកាមាវចរធម៌ទាំងប៉ុន្មាន នូវរូបាវចរធម៌ទាំងប៉ុន្មាន នូវអរូបាវចរធម៌ទាំងប៉ុន្មាន នូវអបរិយាបន្នធម៌ទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វ នូវអត្ថនៃទុក្ខ របស់ទុក្ខសច្ចទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វនូវអត្ថនៃសមុទ័យ របស់សមុទយសច្ចទាំងប៉ុន្មាន នូវអត្ថនៃនិរោធ របស់និរោធសច្ចទាំងប៉ុន្មាន នូវអត្ថនៃមគ្គ របស់មគ្គសច្ចទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំង ក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ។

[២៩០] ព្រះតថាគតទ្រង់ជ្រាបសព្វ នូវអត្ថនៃការបែកធ្លាយអត្ថ របស់អត្ថប្បដិសម្ភិទាទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ ។ បេ ។ ព្រះតថាគតទ្រង់ជ្រាបសព្វ នូវអត្ថនៃការបែកធ្លាយធម៌ របស់ធម្មប្បដិ-

យាវតា និរុត្តិប្បដិសម្ភិទាយ និរុត្តិប្បដិសម្ភិទដ្ឋំ យាវតា បដិភាណប្បដិសម្ភិទាយ បដិភាណប្បដិសម្ភិទដ្ឋំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ យាវតា ឥន្ទ្រិយបរោបរិយត្តេ ញាណំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អា-វរណំ នត្ថីតិ អនាវរណំ ញាណំ យាវតា សត្តានំ អាសយានុសយេ ញាណំ យាវតា យមកប្បាដិ-ហិរេ ញាណំ យាវតា មហាករុណាសមាបត្តិយា ញាណំ សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ ។

[២៩១] យាវតា សទេវកស្ស លោកស្ស សមា-រកស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា សព្វំ ជានាតីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ ។

សម្ភិទាទាំងប៉ុន្មាន នូវអត្ថនៃការបែកធ្លាយនិរុត្តិ របស់និរុត្តិប្បដិសម្ភិទាទាំងប៉ុន្មាន នូវអត្ថនៃការបែកធ្លាយបដិភាណ របស់បដិភាណប្បដិសម្ភិទាទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំង ក្នុងញាណនោះ មិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វ នូវឥន្ទ្រិយបរោបរិយត្តញ្ញាណ ទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំង ក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ព្រះតថាគតទ្រង់ជ្រាបសព្វ នូវសត្តាសយានុសយញ្ញាណ ទាំងប៉ុន្មាន នូវយមកប្បាដិហិរញ្ញាណ ទាំងប៉ុន្មាន នូវមហាករុណាសមាបត្តិញ្ញាណទាំងប៉ុន្មាន ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ។

[២៩១] ព្រះតថាគតទ្រង់ជ្រាបសព្វ ដោយព្រះទ័យ នូវអារម្មណ៍ដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដែលពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសទាំងប៉ុន្មាន បានឃើញ ឮ ពាល់ត្រូវ ដឹង សម្រេច ស្វែងរក ត្រាច់រង្គាត់តាមហើយ ព្រោះហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ។

ន តស្ស អទិដ្ឋមិធត្ថិ កិញ្ចិ
អថោ អវិញ្ញាតម ជានិតព្វំ
សព្វំ អភិញ្ញាសិ យទត្ថិ នេយ្យំ
តថាគតោ តេន (សមយេន) សមន្តចក្ខូតិ ។

[២៩២] សមន្តចក្ខូតិ កេនដ្ឋេន សមន្តចក្ខុ ។ ចុទ្ទស ពុទ្ធញ្ញាណានិ ទុក្ខេ ញាណំ ពុទ្ធញ្ញាណំ ទុក្ខសមុទយេ ញាណំ ពុទ្ធញ្ញាណំ ទុក្ខនិរោធេ ញាណំ ពុទ្ធញ្ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ ពុទ្ធញ្ញាណំ អត្ថប្បដិសម្ភិទេ ញាណំ ពុទ្ធញ្ញាណំ ធម្មប្បដិសម្ភិទេ ញាណំ ពុទ្ធញ្ញាណំ និរុត្តិប្បដិសម្ភិទេ ញាណំ ពុទ្ធញ្ញាណំ បដិភាណប្បដិសម្ភិទេ ញាណំ ពុទ្ធញ្ញាណំ ឥន្ទ្រិយបរោបរិយត្តេ ញាណំ ពុទ្ធញ្ញាណំ សត្តានំ អាសយានុសយេ ញាណំ ពុទ្ធញ្ញាណំ យមកប្បាដិហិរេ ញាណំ ពុទ្ធញ្ញាណំ មហាករុណាសមាបត្តិយា ញាណំ ពុទ្ធញ្ញាណំ សព្វញ្ញុតញ្ញាណំ ពុទ្ធញ្ញាណំ អនាវរណញ្ញាណំ ពុទ្ធញ្ញាណំ ឥមានិ ចុទ្ទស ពុទ្ធញ្ញាណានិ ឥមេសំ ចុទ្ទសន្នំ ពុទ្ធញ្ញាណានំ

របស់អ្វីមួយ ក្នុងលោកនេះ ដែលព្រះតថាគតនោះ មិនឃើញហើយ មិនមានឡើយ មួយទៀត របស់ណាដែលគេគប្បីដឹងហើយ តែសត្វលោកមិនដឹង មិនស្គាល់ ព្រះតថាគតទ្រង់ជ្រាបច្បាស់ នូវរបស់នោះទាំងអស់ ហេតុនោះទើបឈ្មោះថាសមន្តចក្ខុ ។

[២៩២] សំណួរត្រង់ពាក្យថា សមន្តចក្ខុ តើសមន្តចក្ខុ ដោយអត្ថដូចម្តេច ។ ពុទ្ធញ្ញាណ ១៤ គឺ ទុក្ខញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ ទុក្ខសមុទយញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ ទុក្ខនិរោធញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ ទុក្ខនិរោធគាមិនីបដិបទាញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ អត្ថប្បដិសម្ភិទាញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ ធម្មប្បដិសម្ភិទាញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ និរុត្តិប្បដិសម្ភិទាញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ បដិភាណប្បដិសម្ភិទាញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ ឥន្ទ្រិយបរោបរិយត្តញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ សត្តាសយានុសយញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ យមកប្បាដិហិរញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ មហាករុណាសមាបត្តិញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ សព្វញ្ញុតញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ អនាវរណញ្ញាណ ឈ្មោះថាពុទ្ធញ្ញាណ ១ ទាំង ១៤ នេះ ឈ្មោះថាពុទ្ធញ្ញាណ បណ្តាពុទ្ធញ្ញាណទាំង ១៤ នេះ

អាទិតោ[១] អដ្ឋ ញាណានិ សាវកសាធារណានិ ឆ ញាណានិ អសាធារណានិ សាវកេហិ ។

[២៩៣] យាវតា ទុក្ខស្ស ទុក្ខដ្ឋោ សព្វោ ញាតោ អញ្ញាតោ ទុក្ខដ្ឋោ នត្ថីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ យាវតា ទុក្ខស្ស ទុក្ខដ្ឋោ សព្វោ ញាតោ សព្វោ ទិដ្ឋោ សព្វោ វិទិតោ សព្វោ សច្ឆិកតោ សព្វោ ផស្សិតោ បញ្ញាយ អផស្សិតោ បញ្ញាយ ទុក្ខដ្ឋោ នត្ថីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ យាវតា សមុទយស្ស សមុទយដ្ឋោ យាវតា និរោធស្ស និរោធដ្ឋោ យាវតា មគ្គស្ស មគ្គដ្ឋោ យាវតា អត្ថប្បដិសម្ភិទាយ អត្ថប្បដិសម្ភិទដ្ឋោ យាវតា ធម្មប្បដិសម្ភិទាយ ធម្មប្បដិសម្ភិទដ្ឋោ យាវតា និរុត្តិប្បដិសម្ភិទាយ និរុត្តិប្បដិសម្ភិទដ្ឋោ យាវតា បដិភាណប្បដិសម្ភិទាយ បដិភាណប្បដិសម្ភិទដ្ឋោ សព្វោ ញាតោ

១ ឱ. ម. អយំ បាឋោ នត្ថិ ។

ញាណ ៨ ខាងដើម ទូទៅដល់ពួកសាវ័ក ឯញាណ ៦ (ខាងចុង) មិនទូទៅដល់ពួកសាវ័កឡើយ ។

[២៩៣] អត្ថនៃទុក្ខ របស់ទុក្ខសច្ចទាំងប៉ុន្មាន ព្រះតថាគតទ្រង់ជ្រាបសព្វហើយ អត្ថនៃទុក្ខ ឈ្មោះថាព្រះតថាគតមិនជ្រាប មិនមានឡើយ ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ អត្ថនៃទុក្ខ របស់ទុក្ខសច្ចទាំងប៉ុន្មាន ព្រះតថាគតទ្រង់ជ្រាបសព្វហើយ ឃើញសព្វហើយ ដឹងច្បាស់សព្វហើយ ធ្វើឲ្យជាក់ច្បាស់សព្វហើយ ពាល់ត្រូវសព្វហើយដោយប្រាជ្ញា អត្ថនៃទុក្ខ ឈ្មោះថាព្រះតថាគតមិនពាល់ត្រូវហើយដោយប្រាជ្ញា មិនមានឡើយ ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ អត្ថនៃសមុទ័យ របស់សមុទយសច្ចទាំងប៉ុន្មាន អត្ថនៃនិរោធ របស់និរោធសច្ចទាំងប៉ុន្មាន អត្ថនៃមគ្គ របស់មគ្គសច្ចទាំងប៉ុន្មាន អត្ថនៃការបែកធ្លាយនូវអត្ថ របស់អត្ថប្បដិសម្ភិទាទាំងប៉ុន្មាន អត្ថនៃការបែកធ្លាយធម៌ របស់ធម្មប្បដិសម្ភិទាទាំងប៉ុន្មាន អត្ថនៃការបែកធ្លាយនិរុត្តិ របស់និរុត្តិប្បដិសម្ភិទាទាំងប៉ុន្មាន អត្ថនៃការបែកធ្លាយបដិភាណ របស់បដិភាណប្បដិសម្ភិទាទាំងប៉ុន្មាន ព្រះតថាគតទ្រង់ជ្រាបសព្វហើយ ឃើញ

៣០១



សព្វោ ទិដ្ឋោ សព្វោ វិទិតោ សព្វោ សច្ឆិកតោ សព្វោ ផស្សិតោ បញ្ញាយ អផស្សិតោ បញ្ញាយ បដិភាណប្បដិសម្ភិទដ្ឋោ នត្ថីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ យាវតា ឥន្ទ្រិយបរោបរិយត្តេ ញាណំ យាវតា សត្តានំ អាសយានុសយេ ញាណំ យាវតា យមកប្បាដិហីរេ ញាណំ យាវតា មហាករុណាសមាបត្តិយា ញាណំ សព្វំ ញាតំ សព្វំ ទិដ្ឋំ សព្វំ វិទិតំ សព្វំ សច្ឆិកតំ សព្វំ ផស្សិតំ បញ្ញាយ អផស្សិតំ បញ្ញាយ មហាករុណាសមាបត្តិយា ញាណំ នត្ថីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ យាវតា សទេវកស្ស លោកស្ស សមារកស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា សព្វំ ញាតំ សព្វំ ទិដ្ឋំ សព្វំ វិទិតំ

សព្វហើយ ដឹងច្បាស់សព្វហើយ ធ្វើឲ្យជាក់ច្បាស់សព្វហើយ ពាល់ត្រូវសព្វហើយ ដោយប្រាជ្ញា អត្ថនៃការបែកធ្លាយបដិភាណ ឈ្មោះជាព្រះតថាគត មិនពាល់ត្រូវហើយ ដោយប្រាជ្ញា មិនមានឡើយ ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំង ក្នុងញាណនោះ មិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ឥន្ទ្រិយបរោបរិយត្ត-ញ្ញាណទាំងប៉ុន្មាន សត្តាសយានុសយញ្ញាណទាំងប៉ុន្មាន យមកប្បា-ដិហិរញ្ញាណទាំងប៉ុន្មាន មហាករុណាសមាបត្តិញ្ញាណទាំងប៉ុន្មាន ព្រះតថាគតទ្រង់ជ្រាបសព្វហើយ ឃើញសព្វហើយ ដឹងច្បាស់សព្វហើយ ធ្វើឲ្យជាក់ច្បាស់សព្វហើយ ពាល់ត្រូវសព្វហើយ ដោយប្រាជ្ញា មហា-ករុណាសមាបត្តិញ្ញាណ ឈ្មោះថាព្រះតថាគតមិនពាល់ត្រូវហើយដោយប្រាជ្ញា មិនមានឡើយ ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំង ក្នុងញាណនោះ មិនមាន ហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ របស់អ្វីមួយដែលសត្វលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដែលពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសទាំងប៉ុន្មាន ឃើញហើយ ឮហើយ ពាល់ត្រូវហើយ ដឹងហើយ សម្រេចហើយ ស្វែងរកហើយ ត្រាច់រង្គាត់តាមហើយ ព្រះតថាគតទ្រង់ជ្រាបសព្វហើយ ឃើញសព្វហើយ ជ្រាបច្បាស់សព្វហើយ

សព្វំ សច្ឆិកតំ សព្វំ ផស្សិតំ បញ្ញាយ អផស្សិតំ បញ្ញាយ នត្ថីតិ សព្វញ្ញុតញ្ញាណំ តត្ថ អាវរណំ នត្ថីតិ អនាវរណំ ញាណំ ។

ន តស្ស អទិដ្ឋមិធត្ថិ កិញ្ចិ
អថោ អវិញ្ញាតមជានិតព្វំ
សព្វំ អភិញ្ញាសិ យទត្ថិ នេយ្យំ
តថាគតោ តេន (សមយេន) សមន្តចក្ខូតិ ។

ញាណកថា និដ្ឋិតា ។

ធ្វើឲ្យជាក់ច្បាស់សព្វហើយ ពាល់ត្រូវសព្វហើយ ដោយប្រាជ្ញា របស់អ្វីមួយ ឈ្មោះថាព្រះតថាគតមិនពាល់ត្រូវដោយប្រាជ្ញា មិនមានឡើយ ហេតុនោះ ឈ្មោះថាសព្វញ្ញុតញ្ញាណ គ្រឿងរារាំងក្នុងញាណនោះមិនមាន ព្រោះហេតុនោះ ឈ្មោះថាអនាវរណញ្ញាណ ។

របស់អ្វីមួយ ក្នុងលោកនេះ ដែលព្រះតថាគតនោះមិន
ឃើញហើយ មិនមានឡើយ មួយទៀត របស់ណា
ដែលគេគប្បីដឹង តែសត្វលោកមិនដឹង មិនស្គាល់ ព្រះ
តថាគតទ្រង់ជ្រាបច្បាស់ នូវរបស់នោះទាំងអស់ ហេតុ
នោះ ទើបឈ្មោះថាសមន្តចក្ខុ ។

ចប់ ញាណកថា ។

---

# សុត្តន្តបិដកេ
# ខុទ្ទកនិកាយស្ស  បដិសម្ភិទាមគ្គោ
# បឋមោ  ភាគោ

---

មាតិកា                                                    អង្កេ


*ញាណកថាមាតិកុទ្ទេសោ* ........................................ ១


## មហាវគ្គេ  ញាណកថា


*ញាណកថានិទ្ទេសោ* ........................................ ៦

*សុតមយញ្ញាណនិទ្ទេសោ* ........................................ ៦

*អភិញ្ញេយ្យនិទ្ទេសោ* ........................................ ៧

*បរិញ្ញេយ្យនិទ្ទេសោ* ........................................ ៤៩

*បហាតព្វនិទ្ទេសោ* ........................................ ៥៧

*ភាវេតព្វនិទ្ទេសោ* ........................................ ៦១

*សច្ឆិកាតព្វនិទ្ទេសោ* ........................................ ៧៨

*ហានភាគិយចតុក្កនិទ្ទេសោ* ........................................ ៨០

*លក្ខណត្តិកនិទ្ទេសោ* ........................................ ៨២


## អរិយសច្ចចតុក្កេ


*ទុក្ខសច្ចនិទ្ទេសោ* ........................................ ៨២

# សុត្តន្តបិដក
# ខុទ្ទកនិកាយ  បដិសម្ភិទាមគ្គ
# បឋមភាគ

---

## មាតិកា ទំព័រ


*ញាណកថាមាតិកុទ្ទេស*.................................................... ១


## មហាវគ្គ  ញាណកថា


*ញាណកថានិទ្ទេស*.......................................................... ៦

*សុតមយញ្ញាណនិទ្ទេស*..................................................... ៦

*អភិញ្ញេយ្យនិទ្ទេស*........................................................ ៧

*បរិញ្ញេយ្យនិទ្ទេស*......................................................... ៤៩

*បហាតព្វនិទ្ទេស*........................................................... ៥៧

*ភាវេតព្វនិទ្ទេស*........................................................... ៦១

*សច្ឆិកាតព្វនិទ្ទេស*......................................................... ៧៨

*ហានភាគិយចតុក្កនិទ្ទេស*.................................................. ៨០

*លក្ខណត្តិកនិទ្ទេស*......................................................... ៨៤


## អរិយសច្ចចតុក្កៈ


*ទុក្ខសច្ចនិទ្ទេស*............................................................ ៨៤

# មាតិកាបត្តានិ

## មហាវគ្គេ ញាណកថា

មាតិកា អង្កេ


សមុទយសច្ចនិទ្ទេសោ................................................ ៨៤
និរោធសច្ចនិទ្ទេសោ................................................... ៨៤
មគ្គសច្ចនិទ្ទេសោ........................................................ ៨៤
សច្ចបកិណ្ណកា........................................................... ៨៥
សីលមយញ្ញាណនិទ្ទេសោ.......................................... ៩៦
សមាធិភាវនាមយញ្ញាណនិទ្ទេសោ.............................. ១០៩
ធម្មដ្ឋិតិញ្ញាណនិទ្ទេសោ.............................................. ១១៣
សម្មសនញ្ញាណនិទ្ទេសោ ........................................... ១២០
ឧទយព្វយញ្ញាណនិទ្ទេសោ.......................................... ១២៣
ភង្គានុបស្សនាញាណនិទ្ទេសោ.................................... ១២៩
អាទីនវញ្ញាណនិទ្ទេសោ.............................................. ១៣២
សង្ខារុបេក្ខាញាណនិទ្ទេសោ....................................... ១៣៥
គោត្រភូញាណនិទ្ទេសោ ............................................ ១៤៧
មគ្គញ្ញាណនិទ្ទេសោ .................................................. ១៥៥
ផលញ្ញាណនិទ្ទេសោ................................................... ១៥៩

# សន្លឹកប្រាប់មាតិកា

## មាតិកា ទំព័រ

## មហាវគ្គ ញាណកថា


*សមុទយសច្ចនិទ្ទេស...................................................... ៨៤*

*និរោធសច្ចនិទ្ទេស ...................................................... ៨៤*

*មគ្គសច្ចនិទ្ទេស.......................................................... ៨៤*

*សច្ចបកិណ្ណកៈ .......................................................... ៨៥*

*សីលមយញ្ញាណនិទ្ទេស ............................................... ៩៦*

*សមាធិភាវនាមយញ្ញាណនិទ្ទេស.................................. ១០៩*

*ធម្មដ្ឋិតិញ្ញាណនិទ្ទេស ..................................................១១៣*

*សម្មសនញ្ញាណនិទ្ទេស................................................ ១២០*

*ឧទយព្វយញ្ញាណនិទ្ទេស...............................................១២៣*

*ភង្គានុបស្សនាញាណនិទ្ទេស........................................ ១២៩*

*អាទីនវញ្ញាណនិទ្ទេស ...................................................១៣២*

*សង្ខារុបេក្ខាញាណនិទ្ទេស............................................១៣៥*

*គោត្រភូញាណនិទ្ទេស ................................................. ១៤៧*

*មគ្គញ្ញាណនិទ្ទេស....................................................... ១៥៥*

*ផលញ្ញាណនិទ្ទេស...................................................... ១៥៩*

# មាតិកាបត្ថានិ

## មាតិកា អង្កេ

## មហាវគ្គេ ញាណកថា

វិមុត្តិញ្ញាណនិទ្ទេសោ................................................... ១៦២
បច្ចវេក្ខណញ្ញាណនិទ្ទេសោ......................................... ១៦៤
វត្ថុនានត្តញ្ញាណនិទ្ទេសោ........................................... ១៦៩
គោចរនានត្តញ្ញាណនិទ្ទេសោ ....................................... ១៦៩
ចរិយានានត្តញ្ញាណនិទ្ទេសោ .......................................១៧៨
ភូមិនានត្តញ្ញាណនិទ្ទេសោ ........................................... ១៩២
ធម្មនានត្តញ្ញាណនិទ្ទេសោ ...........................................១៩៣
ញាណបញ្ចកនិទ្ទេសោ................................................. ១៩៩
បដិសម្ភិទាញាណនិទ្ទេសោ ......................................... ២០០
ញាណត្តយនិទ្ទេសោ................................................... ២០៨
អានន្តរិកសមាធិញ្ញាណនិទ្ទេសោ................................ ២១០
អរណវិហារញ្ញាណនិទ្ទេសោ ....................................... ២២១
និរោធសមាបត្តិញ្ញាណនិទ្ទេសោ ...................................២២៣
បរិនិព្វានញ្ញាណនិទ្ទេសោ............................................២៣០
សមសីសត្ថញ្ញាណនិទ្ទេសោ .........................................២៣១

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

## មហាវគ្គ ញាណកថា


វិមុត្តិញ្ញាណនិទ្ទេស ........................................................ ១៦២
បច្ចវេក្ខណញ្ញាណនិទ្ទេស .............................................. ១៦៤
វត្ថុនានត្តញ្ញាណនិទ្ទេស................................................. ១៦៩
គោចរនានត្តញ្ញាណនិទ្ទេស ............................................. ១៦៩
ចរិយានានត្តញ្ញាណនិទ្ទេស .............................................១៧៨
ភូមិនានត្តញ្ញាណនិទ្ទេស ................................................ ១៩២
ធម្មនានត្តញ្ញាណនិទ្ទេស .................................................១៩៣
ញាណបញ្ចកនិទ្ទេស ...................................................... ១៩៩
បដិសម្ភិទាញាណនិទ្ទេស ............................................... ២០០
ញាណត្តយនិទ្ទេស.......................................................... ២០៨
អានន្តរិកសមាធិញ្ញាណនិទ្ទេស ...................................... ២១០
អរណវិហារញ្ញាណនិទ្ទេស ............................................. ២២១
និរោធសមាបត្តិញ្ញាណនិទ្ទេស........................................២២៣
បរិនិព្វានញ្ញាណនិទ្ទេស ................................................២៣០
សមសីសត្តញ្ញាណនិទ្ទេស ..............................................២៣១

៣០៧

# មាតិកាបត្តានិ

មាតិកា អង្កេ

## មហាវគ្គេ ញាណកថា

*សល្លេខត្តញ្ញាណនិទ្ទេសោ*..........................................២៣៤
*វីរិយារម្ភញ្ញាណនិទ្ទេសោ*............................................២៣៦
*អត្ថសន្ទស្សនញ្ញាណនិទ្ទេសោ* ....................................២៣៨
*ទស្សនបរិសុទ្ធិញ្ញាណនិទ្ទេសោ*....................................២៣៩
*ខន្តិញ្ញាណបរិយោគាហណញ្ញាណនិទ្ទេសោ* .............. ២៤០
*បទេសវិហារញ្ញាណនិទ្ទេសោ* ...................................... ២៤២
*វិវដ្តញ្ញាណនិទ្ទេសោ*.................................................... ២៤៤
*ឥទ្ធិវិធញ្ញាណនិទ្ទេសោ*................................................ ២៥១
*សោតធាតុវិសុទ្ធិញ្ញាណនិទ្ទេសោ*.................................២៥៣
*ចេតោបរិយញ្ញាណនិទ្ទេសោ*........................................ ២៥៥
*បុព្វេនិវាសានុស្សតិញ្ញាណនិទ្ទេសោ*.............................២៥៧
*ទិព្វចក្ខុញ្ញាណនិទ្ទេសោ* .............................................. ២៥៩
*អាសវក្ខយញ្ញាណនិទ្ទេសោ*......................................... ២៦១
*សច្ចញ្ញាណចតុក្កទ្វយនិទ្ទេសោ*................................... ២៦១
*សុទ្ធិកបដិសម្ភិទាញាណនិទ្ទេសោ*............................... ២៦៨
*ឥន្ទ្រិយបរោបរិយត្តញ្ញាណនិទ្ទេសោ* ...........................២៧១

---

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

## មហាវគ្គ ញាណកថា

*សល្លេខត្ថញ្ញាណនិទ្ទេស*..............................................២៣៤
*វីរិយារម្ភញ្ញាណនិទ្ទេស*................................................២៣៦
*អត្ថសន្ទស្សនញ្ញាណនិទ្ទេស*........................................២៣៨
*ទស្សនបរិសុទ្ធិញ្ញាណនិទ្ទេស*........................................២៣៩
*ខន្តិញ្ញាណបរិយោគាហណញ្ញាណនិទ្ទេស*.................. ២៤០
*បទេសវិហារញ្ញាណនិទ្ទេស*......................................... ២៤២
*វិវដ្តញ្ញាណនិទ្ទេស*...................................................... ២៤៤
*ឥទ្ធិវិធញ្ញាណនិទ្ទេស*.................................................. ២៥១
*សោតធាតុវិសុទ្ធិញ្ញាណនិទ្ទេស*....................................២៥៣
*ចេតោបរិយញ្ញាណនិទ្ទេស*.......................................... ២៥៥
*បុព្វេនិវាសានុស្សតិញ្ញាណនិទ្ទេស*................................២៥៧
*ទិព្វចក្ខុញ្ញាណនិទ្ទេស*................................................. ២៥៩
*អាសវក្ខយញ្ញាណនិទ្ទេស*............................................ ២៦១
*សច្ចញ្ញាណចតុក្កទ្វយនិទ្ទេស*....................................... ២៦១
*សុទ្ធិកបដិសម្ភិទាញាណនិទ្ទេស*.................................. ២៦៨
*ឥន្ទ្រិយបរោបរិយត្តញ្ញាណនិទ្ទេស*.............................. ២៧១

---

## រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

## គណៈកម្មការពុទ្ធិកាវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ  និងបោះពុម្ពសាឡើងវិញនូវសៀវភៅព្រះត្រៃបិដកបាលី  និងសេចក្តីប្រែជាភាសាខ្មែរ ដែលជាស្នាដៃ របស់លោកអ្នកប្រាជ្ញជំនាន់មុន  គឺអាស្រ័យដោយការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាជ្ញាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ដោយកុសលផលបុណ្យទាំងអម្បាលមាណ ដែលកើតអំពីធម្មទាននេះ

សូមឲ្យព្រះពុទ្ធសាសនាផ្សាយទៅគ្រប់ទិសទីទូទាំងសកលលោក

សូមឲ្យសព្វសត្វទាំងឡាយទាំងពួងបាននូវសេចក្តីសុខសួស្តី

សូមឲ្យមនុស្សគ្រប់ជាតិសាសន៍មានភាតរភាពនឹងគ្នា

សូមឲ្យពិភពលោកទាំងមូលមានសុខសន្តិភាព  ។

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ  ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន  សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៥២៩,  (៨៥៥) ៨៨៧ ៩៦១ ៥២៩

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org

*“Wherever the Buddha’s teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share.”*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**

# NAME OF SPONSOR
# 助印功德芳名

**Book's Title: KHMER PALI TRIPITAKA VOL.57 ~ VOL.70**
**(SUTTANTA PITAKA)**

**書 名：柬埔寨巴利文大藏經 第五十七冊至第七十冊 （經藏）**

**Book Serial No., 書 號：CA157 ~ CA170**

N.T. Dollars：

**1,209,840：**〔釋心庭、蔡耀裕、葉明炤、葉王桂花、賴錦瑩、黃怡禎、黃智美、黃寶嬌、黃彩嬉、黃世熙、黃婕寧、黃婕米、黃婕棋、徐淑美、林燦東、邱彩華、林裕翔、林宜蒨、林若好、陳健明、陳俊廷、陳俊弘、蔡文裕、蔡欣洲、蔡慶雲、黃張緣、丁全福。〕

（迴向正法久住，所有成佛功德法，悉以迴向諸群生，願令一切皆清淨，到佛莊嚴之彼岸。）

**1,315,974：** 佛陀教育基金會。

**Amount:** N.T. Dollars **2,525,814；Print 2,000 sets**

**以上合計：新台幣 2,525,814 元；恭印二千套。**

**Dedication of Merits:**

Wherever the Buddha's teachings have flourished, either in cities or countrysides,
People would gain inconceivable benefits.
The land and people would be enveloped in peace.
The sun and moon will shine clear and bright.
Wind and rain would appear accordingly, and there will be no disasters.
Nations would be prosperous and there would be no use for soldiers or weapons.
People would abide by morality and accord with laws.
They would be courteous and humble, and everyone would be content without injustices.
There would be no thefts or violence.
The strong would not dominate the weak and everyone would get their fair share.

**回向：**天下和順，日月清明，風雨以時，災厲不起，國豐民安，兵戈無用，崇德興仁，務修禮讓，國無盜賊，無有怨枉，強不凌弱，各得其所。
法界一切有情，所有六道四生，宿世冤親，現世業債，咸憑法力，悉得解脫。現世者增福延壽，發菩提心，常隨佛學，勤修精進，利濟群生。已故者往生淨土，同出苦輪，共登覺岸，直證阿鞞跋致，圓滿無上菩提。

**附記：**本會接受善信發心印贈經書，其必要之費用，皆經本會審慎評估；若有結餘，均續作本會之印(購)經書及運費使用，為施主廣積陰德。

# DEDICATION OF MERIT

May the merit and virtue
accrued from this work
adorn Amitabha Buddha's Pure Land,
repay the four great kindnesses above,
and relieve the suffering of
those on the three paths below.
May those who see or hear of these efforts
generate Bodhi-mind,
spend their lives devoted to the Buddha Dharma,
and finally be reborn together in
the Land of Ultimate Bliss.

Homage to Amita Buddha!

**NAMO AMITABHA**

**南無阿彌陀佛**


《柬埔寨巴利文大藏經 第六十九冊（經藏）》

〈KHMER PALI TRIPITAKA VOL.69 (SUTTANTA PITAKA)〉

財團法人佛陀教育基金會 印贈

台北市杭州南路一段五十五號十一樓

Printed and donated for free distribution by

**The Corporate Body of the Buddha Educational Foundation**

11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.

Tel: 886-2-23951198 , Fax: 886-2-23913415

Email: overseas@budaedu.org

Website: http://www.budaedu.org

Mobile Web: m.budaedu.org



**This book is strictly for free distribution, it is not to be sold.**

សម្រាប់ចែកជាធម្មទាន



Printed in Taiwan

2,000 copies; July 2015

CA169 - 13310